# ព្រះ

# ត្រៃបិដកបាលី

និង

## សេចក្តីប្រែជាភាសាខ្មែរ

# វិនយបិដក

## មហាវគ្គ តតិយភាគ

# ៨

កឋិនក្ខន្ធកៈ ចីវរក្ខន្ធកៈ

ចម្បេយ្យក្ខន្ធកៈ និង កោសម្ពិក្ខន្ធកៈ

បោះពុម្ពលើកទី ២

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

ព.ស ២៥១៣

ichi Ito
Shigeta

វិនយបិដក មហាវគ្គ

ទុតិយភាគ

៨

[illegible]

[illegible]

ព. ស. ២៥០០

## តតិយោ ភាគោ

## កឋិនក្ខន្ធកំ

[១] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន តិំសមត្តា បាវេយ្យកា[១] ភិក្ខូ សព្ពេ អារញ្ញិកា សព្ពេ បិណ្ឌបាតិកា សព្ពេ បំសុកូលិកា សព្ពេ តេចីវរិកា សាវត្ថិំ គច្ឆន្តា ភគវន្តំ ទស្សនាយ ឧបកដ្ឋាយ វស្សូបនាយិកាយ នាសក្ខិំសុ សាវត្ថិយំ វស្សូបនាយិកំ សម្ភាវេតុំ អន្តរាមគ្គេ សាកេតេ វស្សំ ឧបគច្ឆិំសុ ។ តេ ឧក្កណ្ឋិតរូបា វស្សំ វសិំសុ អាសន្នេ នោ ភគវា វិហរតិ ឆសុ យោជនេសុ ន ច មយំ លភាម ភគវន្តំ ទស្សនាយាតិ ។ អថ ខោ តេ ភិក្ខូ វស្សំ វុត្ថា តេមាសច្ចយេន កតាយ បវារណាយ ទេវេ វស្សន្តេ ឧទកសង្គហេ ឧទកចិក្ខល្លេ ទុក្ខប្បត្តា

១ បាវេយ្យកាតិបិ បាឋោ ។

## ភាគទី ៣

## កឋិនក្ខន្ធកៈ

[១] សម័យនោះ ព្រះពុទ្ធមានព្រះភាគគង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ពួកភិក្ខុនៅក្នុងដែនបាវា[១] ប្រមាណ ៣០ រូប សុទ្ធតែជាអ្នកប្រព្រឹត្តនៅក្នុងព្រៃ ជាអ្នកប្រព្រឹត្តបិណ្ឌបាត ជាអ្នកប្រព្រឹត្តប្រើសំពត់បង្សុកូល ជាអ្នកប្រព្រឹត្តប្រើតែចីវរ ៣ គប់រូបទាំងអស់ នាំគ្នាទៅកាន់ក្រុងសាវត្ថី ដើម្បីគាល់ព្រះមានព្រះភាគ កាលបើកំរិតដែលចូលវស្សាជិតណាស់មកហើយ ក៏មិនអាចនឹងទៅឲ្យទាន់ចូលវស្សា ក្នុងក្រុងសាវត្ថីបានឡើយ ហើយនាំគ្នាចូលទៅចាំវស្សាក្នុងក្រុងសាកេតត្រង់កណ្តាលផ្លូវ ។ ភិក្ខុទាំងនោះនៅចាំវស្សា ទាំងមានសេចក្តីអផ្សុក ព្រោះគិតថា ព្រះមានព្រះភាគ ព្រះអង្គគង់នៅក្នុងទីជិតយើងទាំងឡាយ ចំងាយ ៦ យោជន៍អំពីទីនេះទៅ យើងទាំងឡាយមិនសមបើមិនបានទៅគាល់ព្រះអង្គសោះ ។ គ្រានោះ ពួកភិក្ខុទាំងនោះនៅចាំវស្សាអស់ត្រីមាស[២] រួចហើយក៏នាំគ្នាធ្វើបវារណា (វេចវារ) នៅមានទឹកភ្លៀងធ្លាក់ជោគជាំ មានទឹកភក់ជ្រាំនៅឡើយ (ភិក្ខុទាំងនោះ) គឺមានចីវរទាំងឡាយ ទទឹកជោក បានសេចក្តី

១ បាវាជនបទ នៅក្នុងដែនជម្ពូទ្វីប ។ ២ បីខែ ។

ចីវរេហិ កិលន្តរូបា យេន សាវត្ថី ជេតវនំ អនាថ-
បិណ្ឌិកស្ស អារាមោ យេន ភគវា តេនុបសង្កមឹសុ
ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។
អាចិណ្ណំ ខោ បនេតំ ពុទ្ធានំ ភគវន្តានំ អាគន្តុកេហិ
ភិក្ខូហិ សទ្ធឹ បដិសម្មោទិតុំ ។ អថខោ ភគវា តេ ភិក្ខូ
ឯតទវោច កច្ចិ ភិក្ខវេ ខមនីយំ កច្ចិ យាបនីយំ កច្ចិ
សមគ្គា សម្មោទមានា អវិវទមានា ផាសុកំ វស្សំ វសិត្ថ
ន ច បិណ្ឌកេន កិលមិត្ថាតិ ។ ខមនីយំ ភគវា
យាបនីយំ ភគវា សមគ្គា ច មយំ ភន្តេ សម្មោទមានា
អវិវទមានា ផាសុំ វស្សំ វសិម្ហា ន ច បិណ្ឌកេន កិលមិម្ហា
ឥធ មយំ ភន្តេ តឹសមត្តា បាវេយ្យកា ភិក្ខូ សាវត្ថឹ
អាគច្ឆន្តា ភគវន្តំ ទស្សនាយ ឧបកដ្ឋាយ វស្សូបនា-
យិកាយ នាសក្ខិម្ហា សាវត្ថិយំ វស្សូបនាយិកំ សម្ភា-
វេតុំ អន្តរាមគ្គេ សាកេតេ វស្សំ ឧបគច្ឆិម្ហា តេ



លំបាកកាយ នាំគ្នាដើរសំដៅទៅកាន់ក្រុងសាវត្ថី ហើយចូលទៅវត្តជេតពន
របស់អនាថបិណ្ឌិកសេដ្ឋី ដែលព្រះដ៏មានព្រះភាគគង់នៅ លុះចូលទៅដល់
ហើយក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ ការ
ស្រុះស្រួលទទួលជាមួយនឹងពួកភិក្ខុអាគន្តុកៈនេះ ជាទំនៀមរបស់ព្រះ
ពុទ្ធដ៏មានព្រះភាគគ្រប់ព្រះអង្គ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់
មានព្រះបន្ទូលនេះនឹងភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងឡាយ អ្នករាល់គ្នា
ល្មមអត់ទ្រាំបានទេឬ អ្នករាល់គ្នាល្មមប្រព្រឹត្តទៅបានស្រួលទេឬ អ្នក
ទាំងឡាយមានសេចក្ដីសាមគ្គីស្រុះស្រួលមិនវិវាទគ្នា នៅចាំវស្សា
ស្រួលបួលមិនលំបាកដោយអាហារបិណ្ឌបាតទេឬ ។ ភិក្ខុទាំងនោះក្រាប
បង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គទាំងអស់គ្នាល្មមអត់ទ្រាំ
បាន បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គទាំងអស់គ្នាល្មមប្រព្រឹត្តទៅបាន
បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គទាំងអស់គ្នាសាមគ្គីស្រុះស្រួល ឥតមានវិវាទ
ទាស់ទែងគ្នាទេ នៅចាំវស្សាក៏ស្រួលបួលមិនលំបាកដោយអាហារបិណ្ឌ-
បាតទេ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គទាំងឡាយនៅក្នុងដែនបាវា
ប្រមាណ ៣០ រូប មកកាន់ក្រុងសាវត្ថីនេះ ដើម្បីគាល់ព្រះអង្គ កាលបើ
កំពុងចូលវស្សាជិតណាស់ហើយ ក៏មិនអាចនឹងមកទាន់ពេលចូលវស្សាក្នុង
ក្រុងសាវត្ថីបានឡើយ ក៏នៅចាំវស្សាក្នុងក្រុងសាកេតកណ្ដាលផ្លូវ

មយំ ភន្តេ ឧក្កណ្ឋិតរូបា វស្សំ វសិម្ហា អាសន្នេ នោ ភគវា វិហរតិ ឥតោ ឆសុ យោជនេសុ ន ច មយំ លភាម ភគវន្តំ ទស្សនាយាតិ អថ ខោ មយំ ភន្តេ វុត្ថវស្សា តេមាសច្ចយេន កតាយ បវារណាយ ទេវេ វស្សន្តេ ឧទកសង្គហេ ឧទកចិក្ខល្លេ ឱកបុណ្ណេហិ ចីវរេហិ កិលន្តរូបា អទ្ធានំ អាគតាតិ ។

[២] អថ ខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ វស្សំវុត្ថានំ ភិក្ខូនំ កឋិនំ អត្ថរិតុំ ។ អត្ថតកឋិនានំ វោ ភិក្ខវេ បញ្ច[១] កប្បិស្សន្តិ អនាមន្តចារោ អសមាទានចារោ គណភោជនំ យាវទត្ថចីវរំ យោ ច តត្ថ ចីវរុប្បាទោ សោ នេសំ ភវិស្សតីតិ ។

១ បញ្ចានិសំសានីតិ ទិស្សតិ ។



(នោះទៅ) បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គទាំងនោះនៅចាំវស្សាទាំង មានសេចក្តីអផ្សុក ព្រោះគិតថា ព្រះដ៏មានព្រះភាគព្រះអង្គគង់នៅក្នុងទី ជិតយើងទាំងឡាយ ចម្ងាយ ៦ យោជន៍អំពីទីនេះទៅ យើងទាំងឡាយ មិនសមបើមិនបានទៅគាល់ព្រះអង្គសោះ បពិត្រព្រះអង្គដ៏ចំរើន លុះ ខ្ញុំព្រះអង្គទាំងអស់គ្នានៅចាំវស្សាអស់ត្រៃមាស ហើយក៏ធ្វើបវារណា (ហើយមកនេះ) នៅមានទឹកភ្លៀងធ្លាក់ជោគជាំ មានទឹកកក់អិលទៅ ឡើយ ទើបខ្ញុំព្រះអង្គទាំងអស់គ្នាមានចីវរទាំងឡាយទទឹកជោក ប្រកប សេចក្តីលំបាកកាយមកតាមផ្លូវឆ្ងាយ ។

[២] ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគទ្រង់ ធ្វើធម្មីកថាហើយត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យពួកភិក្ខុដែលបាននៅចាំវស្សារួចហើយក្រាលកឋិនបាន ។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយបានក្រាលកឋិនហើយ នឹង សម្រេចអានិសង្ស ៥ យ៉ាង គឺត្រាច់ទៅ (ណា) មិនបាច់លា (ភិក្ខុផងគ្នា)១ ត្រាច់ទៅ (ណា) មិនបាច់យកត្រៃចីវរ (គ្រប់ប្រដាប់)១ (ឆាន់) គណភោជនបាន ១ (ទុកដាក់) អតិរេកចីវរបានតាមត្រូវការ ១ ចីវរណា ដែលកើតឡើងក្នុងអាវាសនោះ ចីវរនោះនឹងបានដល់ភិក្ខុទាំងនោះ១ ។

អត្ថតកឋិនានំ វោ ភិក្ខវេ ឥមានិ បញ្ច[១] កប្បិស្សន្តិ ។
ឯវញ្ច បន ភិក្ខវេ កឋិនំ អត្ថរិតព្វំ ។ ព្យត្តេន ភិក្ខុនា
បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ
សង្ឃោ ឥទំ សង្ឃស្ស កឋិនទុស្សំ ឧប្បន្នំ ។ យទិ
សង្ឃស្ស បត្តកល្លំ សង្ឃោ ឥមំ កឋិនទុស្សំ ឥត្ថន្នា-
មស្ស ភិក្ខុនោ ទទេយ្យ កឋិនំ អត្ថរិតុំ ។ ឯសា
ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ ឥទំ សង្ឃស្ស
កឋិនទុស្សំ ឧប្បន្នំ ។ សង្ឃោ ឥមំ កឋិនទុស្សំ
ឥត្ថន្នាមស្ស ភិក្ខុនោ ទេតិ កឋិនំ អត្ថរិតុំ ។ យស្សា-
យស្មតោ ខមតិ ឥមស្ស កឋិនទុស្សស្ស ឥត្ថន្នាមស្ស
ភិក្ខុនោ ទានំ កឋិនំ អត្ថរិតុំ សោ តុណ្ហស្ស យស្ស
នក្ខមតិ សោ ភាសេយ្យ ។ ទិន្នំ ឥទំ សង្ឃេន
កឋិនទុស្សំ ឥត្ថន្នាមស្ស ភិក្ខុនោ កឋិនំ អត្ថរិតុំ ។
ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។
ឯវំ ខោ ភិក្ខវេ អត្ថតំ ហោតិ កឋិនំ ឯវំ អនត្ថតំ ។

១ បញ្ចានិសំសានីតិ ទិស្សតិ ។



ម្នាលភិក្ខុទាំងឡាយ អានិសង្សទាំង ៥ នេះនឹងសមគួរដល់អ្នកទាំងឡាយ
ដែលបានក្រាលកឋិន ។ ម្នាលភិក្ខុទាំងឡាយ គឺឯកឋិន(នោះ)ត្រូវអ្នក
ទាំងឡាយក្រាលយ៉ាងនេះ ។ គឺត្រូវឲ្យភិក្ខុអ្នកឈ្លាសប្រតិពលផ្តំសង្ឃឲ្យ
ដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ (ផង) សំពត់កឋិន
នេះកើតឡើងដល់សង្ឃហើយ ។ បើកម្មមានកាលគួរដល់សង្ឃហើយ ទូ
សង្ឃឲ្យសំពត់កឋិននេះដល់ភិក្ខុឈ្មោះនេះ ដើម្បីនឹងក្រាលកឋិន ។ នេះ
ជាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ (ផង) សំ-
ពត់កឋិននេះកើតឡើងដល់សង្ឃហើយ ។ (ឥឡូវ) សង្ឃឲ្យសំពត់កឋិន
នេះដល់ភិក្ខុឈ្មោះនេះ ដើម្បីនឹងក្រាលកឋិន ។ ការឲ្យសំពត់កឋិននេះ
ដល់ភិក្ខុឈ្មោះនេះ ដើម្បីនឹងក្រាលកឋិន (បើ) គួរដល់លោកដ៏មាន
អាយុអង្គណា ត្រូវលោកដ៏មានអាយុអង្គនោះស្ងៀម (បើ) មិនគួរដល់
លោកដ៏មានអាយុអង្គណា ៗ ត្រូវលោកដ៏មានអាយុអង្គនោះនិយាយ
ឡើង ។ សំពត់កឋិននេះសង្ឃឲ្យដល់ភិក្ខុឈ្មោះនេះ ដើម្បីនឹងក្រាលកឋិន
ហើយ ។ ការឲ្យសំពត់កឋិននេះដល់ភិក្ខុឈ្មោះនេះ ទំនងជាគួរដល់សង្ឃ
ហើយ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកនូវការនេះ
ដោយអាការស្ងៀមនៅយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ឯកឋិនដែល
ភិក្ខុក្រាលឡើងបែបនេះ ក្រាលមិនឡើងបែបនេះ ។

(៣) កថញ្ច ភិក្ខវេ អនត្ថតំ ហោតិ កឋិនំ ។
ន ឧល្លិខិតមត្តេន អត្ថតំ ហោតិ កឋិនំ ។ ន ធោវ-
នមត្តេន អត្ថតំ ហោតិ កឋិនំ ។ ន ចីវរវិចារណមត្តេន
អត្ថតំ ហោតិ កឋិនំ ។ ន ឆេទនមត្តេន អត្ថតំ ហោ-
តិ កឋិនំ ។ ន ពន្ធនមត្តេន អត្ថតំ ហោតិ កឋិនំ ។
ន ឱវដ្ដិយករណមត្តេន អត្ថតំ ហោតិ កឋិនំ ។ ន
កណ្ឌុសករណមត្តេន អត្ថតំ ហោតិ កឋិនំ ។ ន
ទឡ្ហីកម្មករណមត្តេន អត្ថតំ ហោតិ កឋិនំ ។ ន
អនុវាតករណមត្តេន អត្ថតំ ហោតិ កឋិនំ ។ ន
បរិភណ្ឌករណមត្តេន អត្ថតំ ហោតិ កឋិនំ ។ ន
ឱវទ្ធេយ្យករណមត្តេន អត្ថតំ ហោតិ កឋិនំ ។ ន
កម្ពលមទ្ទនមត្តេន អត្ថតំ ហោតិ កឋិនំ ។ ន និមិត្ត-
កតេន អត្ថតំ ហោតិ កឋិនំ ។ ន បរិកថាកតេន អត្ថតំ



(៣) ម្នាលភិក្ខុទាំងឡាយ ចំណែកកឋិនដែលភិក្ខុក្រាលមិនឡើង
តើដូចម្តេច ។ (ឯកឋិនដែលភិក្ខុក្រាលមិនឡើងនោះគឺ) សំពត់ដែលគ្រាន់
តែកោសខ្នួសគែមចំណាំហើយក្រាល មិនឡើងជាកឋិន ។ សំពត់ដែល
គ្រាន់តែបោកគក់លាងហើយក្រាល មិនឡើងជាកឋិន ។ សំពត់ដែលគ្រាន់
តែចាត់ចែងលក្ខណៈចីវរ (ថាវែងប៉ុណ្ណេះ ទទឹងប៉ុណ្ណេះជាដើម) ហើយក្រាល
មិនឡើងជាកឋិន ។ សំពត់ដែលគ្រាន់តែកាត់ហើយក្រាល មិនឡើងជា
កឋិន ។ សំពត់ដែលគ្រាន់តែដេរភ្ជាប់គ្នាហើយក្រាល មិនឡើងជាក-
ឋិន ។ សំពត់ដែលគ្រាន់តែដេរ (មានដេរបណ្តោយជាដើម) ហើយក្រាល
មិនឡើងជាកឋិន ។ សំពត់ដែលគ្រាន់តែភ្ជាប់កណ្ដុំហើយក្រាល មិន
ឡើងជាកឋិន ។ សំពត់ដែលគ្រាន់តែថែមសំពត់ឲ្យមាំហើយក្រាល មិន
ឡើងជាកឋិន ។ សំពត់ដែលគ្រាន់តែប្រក់អនុវាតខាងខ្នងហើយក្រាល
មិនឡើងជាកឋិន ។ សំពត់ដែលគ្រាន់តែប្រក់អនុវាតខាងពោះ ហើយ
ក្រាល មិនឡើងជាកឋិន ។ សំពត់ដែលគ្រាន់តែដេរផ្គួបគ្នាហើយក្រាល
មិនឡើងជាកឋិន ។ សំពត់ដែលគ្រាន់តែជ្រលក់ម្តងមានពណ៌ដូចក្ដុងជើ
ចុងស្លឹកឈើទុំហើយក្រាល មិនឡើងជាកឋិន ។ សំពត់ដែលបានមក
ព្រោះធ្វើនិមិត្តហើយក្រាល មិនឡើងជាកឋិន ។ សំពត់ដែលបានមក

ហោតិ កឋិនំ ។ ន កុក្កុកតេន អត្ថតំ ហោតិ កឋិនំ ។ ន សន្និធិកតេន អត្ថតំ ហោតិ កឋិនំ ។ ន និស្សគ្គិយេន អត្ថតំ ហោតិ កឋិនំ ។ ន អកប្បកតេន អត្ថតំ ហោតិ កឋិនំ ។ ន អញ្ញត្រ សង្ឃាដិយា អត្ថតំ ហោតិ កឋិនំ ។ ន អញ្ញត្រ ឧត្តរាសង្គេន អត្ថតំ ហោតិ កឋិនំ ។ ន អញ្ញត្រ អន្តរវាសកេន អត្ថតំ ហោតិ កឋិនំ ។ ន អញ្ញត្រ បញ្ចកេន វា អតិរេកបញ្ចកេន វា តទហេវ សញ្ឆិន្នេន សមណ្ឌលីកតេន អត្ថតំ ហោតិ កឋិនំ ។ ន អញ្ញត្រ បុគ្គលស្ស អត្ថារា អត្ថតំ ហោតិ កឋិនំ ។ ន សម្មា ចេ អត្ថតំ ហោតិ កឋិនំ ។ តញ្ចេ និស្សីមដ្ឋោ អនុមោទតិ ឯវំបិ អនត្ថតំ ហោតិ កឋិនំ ។ ឯវំ ខោ ភិក្ខវេ អនត្ថតំ ហោតិ កឋិនំ ។

(៦) កថញ្ច ភិក្ខវេ អត្ថតំ ហោតិ កឋិនំ ។ អហតេន អត្ថតំ ហោតិ កឋិនំ ។ អហតកប្បេន អត្ថតំ ហោតិ កឋិនំ ។ បិលោតិកាយ អត្ថតំ



ព្រោះនិយាយបញ្ចុះបញ្ចូលគេហើយក្រាល មិនឡើងជាកឋិន ។ សំពត់ដែលខ្ចីគេមកក្រាល មិនឡើងជាកឋិន ។ សំពត់ដែលមិនបានធ្វើឲ្យស្រេចក្នុងថ្ងៃនោះហើយក្រាល មិនឡើងជាកឋិន ។ សំពត់ដែលធ្វើឲ្យកន្លងរាត្រី ទុកឲ្យអរុណរះឡើងកាត់ហើយក្រាល មិនឡើងជាកឋិន ។ សំពត់ដែលមិនបានធ្វើកប្បហើយក្រាល មិនឡើងជាកឋិន ។ វៀរលែកសង្ឃាដិហើយក្រាល មិនឡើងជាកឋិន ។ វៀរលែកឧត្តរាសង្គហើយក្រាល មិនឡើងជាកឋិន ។ វៀរលែកអន្តរវាសកហើយក្រាល មិនឡើងជាកឋិន ។ វៀរលែកចីវរមានមណ្ឌលគប់គ្រាន់ដែលកាត់ជាប់ជាបញ្ចខណ្ឌ លើសពីបញ្ចខណ្ឌ ក្នុងថ្ងៃនោះឯងហើយក្រាល ក៏មិនឡើងជាកឋិន ។ មិនវៀរបុគ្គលក្រាល (ទៅឲ្យសង្ឃឬគណៈក្រាលវិញ) មិនឡើងជាកឋិន ។ ការក្រាលមិនត្រឹមត្រូវ ក៏មិនឡើងជាកឋិន ។ បើភិក្ខុនៅក្រៅសីមាហើយអនុមោទនាកឋិននោះ ការក្រាលបែបនេះមិនឡើងជាកឋិនឡើយ ។ ម្នាលភិក្ខុទាំងឡាយ ការក្រាលកឋិនដូចន័យដែលតថាគតពោលមកនេះឯង មិនឡើងជាកឋិនទេ ។

(៦) ម្នាលភិក្ខុទាំងឡាយ ចំណែកកឋិនដែលភិក្ខុក្រាលឡើង (នោះ) តើដូចម្ដេច ។ (ឯកឋិនដែលភិក្ខុក្រាលឡើងនោះគឺ) សំពត់ថ្មីក្រាលឡើងជាកឋិន ។ សំពត់ដំនំក្រាលឡើងជាកឋិន ។ សំពត់ចាស់

ហោតិ កឋិនំ ។ បំសុកូលេន អត្ថតំ ហោតិ កឋិនំ ។ បាបណិកេន អត្ថតំ ហោតិ កឋិនំ ។ អនិមិត្តកតេន អត្ថតំ ហោតិ កឋិនំ ។ អបរិកថាកតេន អត្ថតំ ហោតិ កឋិនំ ។ អកុក្កុកតេន អត្ថតំ ហោតិ កឋិនំ ។ អសន្និធិកតេន អត្ថតំ ហោតិ កឋិនំ ។ អនិស្សគ្គិយេន អត្ថតំ ហោតិ កឋិនំ ។ កប្បកតេន អត្ថតំ ហោតិ កឋិនំ ។ សង្ឃាដិយា អត្ថតំ ហោតិ កឋិនំ ។ ឧត្តរាសង្គេន អត្ថតំ ហោតិ កឋិនំ ។ អន្តរវាសកេន អត្ថតំ ហោតិ កឋិនំ ។ បញ្ចកេន វា អតិរេកបញ្ចកេន វា តទហេវ សញ្ឆិន្នេន សមណ្ឌលិកតេន អត្ថតំ ហោតិ កឋិនំ ។ បុគ្គលស្ស អត្ថារា អត្ថតំ ហោតិ កឋិនំ ។ សម្មា ចេ អត្ថតំ ហោតិ កឋិនំ ។ តញ្ចេ សីមដ្ឋោ អនុមោទតិ ឯវម្បិ អត្ថតំ ហោតិ កឋិនំ ។ ឯវំ ខោ ភិក្ខវេ អត្ថតំ ហោតិ កឋិនំ ។



ក្រាលឡើងជាកឋិន ។ សំពត់បង្សុកូល ក្រាលឡើងជាកឋិន ។ សំពត់ដែលធ្លាក់ទៀបកន្លែងផ្សារ ក្រាលឡើងជាកឋិន ។ សំពត់ដែលបានមកដោយមិនបានធ្វើនិមិត្ត ក្រាលឡើងជាកឋិន ។ សំពត់ដែលចុះមកដោយមិនបាននិយាយបញ្ចុះបញ្ចូល ក្រាលឡើងជាកឋិន ។ សំពត់ដែលមិនខ្ចីគេ ក្រាលឡើងជាកឋិន ។ សំពត់ដែលបានធ្វើឲ្យស្រេចក្នុងថ្ងៃនោះ ក្រាលឡើងជាកឋិន ។ សំពត់ដែលមិនធ្វើឲ្យក្នុងរាត្រី ក៏មិនឲ្យអរុណរះឡើងជាន់ ក្រាលឡើងជាកឋិន ។ សំពត់ដែលបានធ្វើពិន្ទុកប្បហើយ ក្រាលឡើងជាកឋិន ។ សង្ឃាដិ ក្រាលឡើងជាកឋិន ។ ឧត្តរាសង្គ ក្រាលឡើងជាកឋិន ។ អន្តរវាសក ក្រាលឡើងជាកឋិន ។ សំពត់ដែលមានមណ្ឌលគ្រប់គ្រាន់កាត់ដាច់ត្រឹមត្រូវជាបញ្ចខណ្ឌ លើសពីបញ្ចខណ្ឌ ក្នុងថ្ងៃនោះឯង ហើយក្រាលឡើងជាកឋិន ។ ឲ្យបុគ្គលក្រាល ទើបឡើងជាកឋិន ។ ការក្រាលដោយត្រឹមត្រូវ ទើបបានឡើងជាកឋិន ។ បើភិក្ខុនៅក្នុងសីមា ហើយអនុមោទនាកឋិននោះ ការក្រាលបែបនេះ ទើបឡើងជាកឋិន ។ ម្នាលភិក្ខុទាំងឡាយ ការក្រាលកឋិន ដូចន័យដែលតថាគតពោលមកនេះឯង ទើបឡើងជាកឋិនបាន ។

[៨] កថញ្ច ភិក្ខវេ ឧព្ភតំ ហោតិ កឋិនំ ។ អដ្ឋិមា ភិក្ខវេ មាតិកា កឋិនស្ស ឧព្ភារាយ បក្កមនន្តិកា និដ្ឋានន្តិកា សន្និដ្ឋានន្តិកា នាសនន្តិកា សវនន្តិកា អាសាវច្ឆេទិកា សីមាតិក្កន្តិកា សហុព្ភារាតិ ។

[២] ភិក្ខុ អត្ថតកឋិនោ កតចីវរំ អាទាយ បក្កមតិ ន បច្ចេស្សន្តិ ។ តស្ស ភិក្ខុនោ បក្កមនន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ ចីវរំ អាទាយ បក្កមតិ ។ តស្ស ពហិសីមគតស្ស ឯវំ ហោតិ ឥមំ ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ សោ តំ ចីវរំ ការេតិ ។ តស្ស ភិក្ខុនោ និដ្ឋានន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ ចីវរំ អាទាយ បក្កមតិ ។ តស្ស ពហិសីមគតស្ស ឯវំ ហោតិ នេវិមំ ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ តស្ស ភិក្ខុនោ សន្និដ្ឋានន្តិកោ កឋិនុទ្ធារោ ។



[៨] ម្នាលភិក្ខុទាំងឡាយ ឯកឋិនគឺដោះ (នោះ) តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មាតិកាទាំង ៨ ប្រការនេះនាំឲ្យកឋិនដោះ គឺ មានការចៀសចេញទៅជាកំណត់ ១ មានការធ្វើចីវរសម្រេចជាកំណត់ ១ មានសេចក្តីសន្និដ្ឋានជាកំណត់ ១ មានចីវរវិនាសទៅជាកំណត់ ១ មានការឮដំណឹងជាកំណត់ ១ អស់សេចក្តីសង្ឃឹម ១ មានការកន្លងនូវខេត្តកឋិនជាកំណត់ ១ សង្ឃព្រមព្រៀងគ្នាដោះកឋិន ១ ។

[២] ភិក្ខុបានក្រាលកឋិនរួចហើយនាំយកចីវរដែលខ្លួនធ្វើស្រេច ចៀសចេញទៅដោយគិតថា អាត្មាអញនឹងមិនត្រឡប់វិញទេ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ត្រឹមការដែលចៀសចេញទៅជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយនាំយកចីវរចៀសចេញទៅ ។ កាលភិក្ខុនោះទៅដល់ក្រៅសីមាក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញនឹងមិនត្រឡប់វិញទេ ។ ភិក្ខុនោះក៏បានធ្វើចីវរនោះឲ្យស្រេច ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះត្រឹមធ្វើចីវរឲ្យស្រេចជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយ នាំយកចីវរចៀសចេញទៅ ។ កាលភិក្ខុនោះទៅដល់ក្រៅសីមាក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញនឹងមិនធ្វើចីវរនេះ អាត្មាអញនឹងមិនត្រឡប់វិញទេ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ត្រឹមសេចក្តីសន្និដ្ឋានជាកំណត់ ។

ភិក្ខុ អត្ថតកឋិនោ ចីវរំ អាទាយ បក្កមតិ ។ តស្ស ពហិសីមគតស្ស ឯវំ ហោតិ ឥធេវិមំ ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ សោ តំ ចីវរំ ការេតិ ។ តស្ស តំ ចី-វរំ ការិយមានំ នស្សតិ ។ តស្ស ភិក្ខុនោ នាសនន្តិ-កោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ ចីវរំ អាទា-យ បក្កមតិ បច្ចេស្សន្តិ ។ សោ ពហិសីមគតោ តំ ចីវរំ ការេតិ ។ សោ កតចីវរោ សុណាតិ ឧព្ភតំ កិរ តស្មឹ អាវាសេ កឋិនន្តិ ។ តស្ស ភិក្ខុនោ សវនន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ ចីវរំ អាទាយ បក្កមតិ បច្ចេស្សន្តិ ។ សោ ពហិសីមគតោ តំ ចីវរំ ការេតិ ។ សោ កតចីវរោ បច្ចេស្សំ បច្ចេស្សន្តិ ពហិទ្ធា កឋិនុទ្ធារំ វីតិនាមេតិ ។ តស្ស ភិក្ខុនោ សីមាតិក្កន្តិ-កោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ ចីវរំ អាទាយ បក្កមតិ បច្ចេស្សន្តិ ។ សោ ពហិសីមគតោ តំ ចីវរំ



ភិក្ខុបានក្រាលកឋិនរួចហើយនាំយកចីវរចៀសចេញទៅ ។ កាលភិក្ខុនោះទៅដល់ក្រៅសីមាក៏មានសេចក្ដីត្រិះរិះយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញនឹងមិនត្រឡប់វិញទេ ។ ភិក្ខុនោះក៏បានធ្វើចីវរនោះ ។ កាលភិក្ខុនោះកំពុងធ្វើ ចីវរនោះក៏វិនាសទៅ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ត្រង់ទីវិនាសជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយនាំយកចីវរចៀសចេញទៅដោយគិតថា អាត្មាអញនឹងត្រឡប់វិញ ។ ភិក្ខុនោះទៅដល់ក្រៅសីមាក៏បានធ្វើចីវរនោះ ។ លុះភិក្ខុនោះធ្វើចីវរស្រេចហើយឮដំណឹងថា សង្ឃបានដកកឋិនក្នុងអាវាសនោះហើយ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ត្រង់បានឮដំណឹងជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយនាំយកចីវរចៀសចេញទៅដោយគិតថា អាត្មាអញនឹងត្រ-ឡប់វិញ ។ ភិក្ខុនោះទៅដល់ក្រៅសីមាក៏បានធ្វើចីវរនោះ ។ លុះភិក្ខុនោះធ្វើចីវរស្រេចហើយក៏នៅតែគិតថា អាត្មាអញនឹងត្រឡប់វិញ អាត្មាអញនឹងត្រឡប់វិញដែរ (តែមិនទាន់បានត្រឡប់ទៅឡើយ) កឋិនក៏ដោះខាងក្រៅ (នោះ) ទៅ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ត្រង់កន្លងទីដកកឋិនជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយនាំយកចីវរចៀសចេញទៅដោយគិតថា អាត្មាអញនឹងត្រឡប់វិញ ។ ភិក្ខុនោះទៅដល់ក្រៅសីមា

ការេតិ ។ សោ កតចីវរោ បច្ចេស្សំ បច្ចេស្សន្តិ សុណាតិ កឋិនុព្ភារំ ។ តស្ស ភិក្ខុនោ សហ ភិក្ខូហិ កឋិនុព្ភារោ ។

អាទាយសត្តកំ និដ្ឋិតំ បឋមំ ។

(៨) ភិក្ខុ អត្ថតកឋិនោ កតចីវរំ សមាទាយ បក្កមតិ ន បច្ចេស្សន្តិ ។ តស្ស ភិក្ខុនោ បក្កមនន្តិកោ កឋិនុព្ភារោ ។ ភិក្ខុ អត្ថតកឋិនោ ចីវរំ សមាទាយ បក្កមតិ ។ តស្ស ពហិសីមគតស្ស ឯវំ ហោតិ ឥធេវិមំ ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ សោ តំ ចីវរំ ការេតិ ។ តស្ស ភិក្ខុនោ និដ្ឋានន្តិកោ កឋិនុព្ភារោ ។ ភិក្ខុ អត្ថតកឋិនោ ចីវរំ សមាទាយ បក្កមតិ ។ តស្ស ពហិសីមគតស្ស ឯវំ ហោតិ នេវិមំ ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ តស្ស ភិក្ខុនោ សន្និដ្ឋានន្តិកោ



ក៏បានធ្វើចីវរនោះ ។ លុះភិក្ខុនោះបានធ្វើចីវររួចហើយក៏គិតថា អាត្មាអញនឹងត្រឡប់វិញ អាត្មាអញនឹងត្រឡប់វិញ ហើយក៏បានមកទាន់ពេលដោះកឋិនមែន ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ជាមួយនឹងភិក្ខុទាំងឡាយ ។

ចប់ អាទាយសត្តកៈ ទីបឋម ។

(៨) ភិក្ខុបានក្រាលកឋិនរួចហើយ ប្រមូលយកចីវរដែលធ្វើហើយ ចៀសចេញទៅដោយគិតថា អាត្មាអញនឹងមិនត្រឡប់វិញទេ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ត្រង់ការដែលចៀសចេញទៅជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយ ប្រមូលយកចីវរចៀសចេញទៅ ។ កាលភិក្ខុនោះទៅដល់ក្រៅសីមាក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញនឹងមិនត្រឡប់វិញទេ ។ ភិក្ខុនោះក៏បានធ្វើចីវរនោះឲ្យស្រេច ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ត្រង់ធ្វើចីវរឲ្យស្រេចជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយ ប្រមូលយកចីវរចៀសចេញទៅ ។ កាលភិក្ខុនោះទៅដល់ក្រៅសីមាក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញនឹងមិនធ្វើចីវរនេះទេ អាត្មាអញនឹងមិនត្រឡប់វិញទេ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ត្រង់សេចក្តីសន្និដ្ឋាន

កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ ចីវរំ សមាទាយ បក្កមតិ ។ តស្ស ពហិសីមគតស្ស ឯវំ ហោតិ ឥធេវិមំ ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ សោ តំ ចីវរំ ការេតិ ។ តស្ស ភិក្ខុនោ តំ ចីវរំ ការយមានំ នស្សតិ ។ តស្ស ភិក្ខុនោ នាសនន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ ចីវរំ សមាទាយ បក្កមតិ បច្ចេស្សន្តិ ។ សោ ពហិសីមគតោ តំ ចីវរំ ការេតិ ។ សោ កតចីវរោ សុណាតិ ឧព្ភតំ កិរ តស្មឹ អាវាសេ កឋិនន្តិ ។ តស្ស ភិក្ខុនោ សវនន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ ចីវរំ សមាទាយ បក្កមតិ បច្ចេស្សន្តិ ។ សោ ពហិសីមគតោ តំ ចីវរំ ការេតិ ។ សោ កតចីវរោ បច្ចេស្សំ បច្ចេស្សន្តិ ពហិទ្ធា កឋិនុទ្ធារំ វីតិនាមេតិ ។ តស្ស ភិក្ខុនោ សីមាតិក្កន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ ចីវរំ សមាទាយ បក្កមតិ បច្ចេស្សន្តិ ។ សោ



ជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយ ប្រមូលយកចីវរចៀសចេញទៅ ។ កាលភិក្ខុនោះទៅដល់ក្រៅសីមាក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញនឹងមិនត្រឡប់វិញទេ ។ ភិក្ខុនោះក៏បានធ្វើចីវរនោះ ។ កាលភិក្ខុនោះកំពុងធ្វើ ចីវរនោះក៏វិនាសទៅ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ត្រង់ចីវរវិនាសជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយ ប្រមូលយកចីវរចៀសចេញទៅដោយគិតថា អាត្មាអញនឹងត្រឡប់វិញ ។ ភិក្ខុនោះទៅដល់ក្រៅសីមាក៏បានធ្វើចីវរនោះ ។ លុះភិក្ខុនោះបានធ្វើចីវររួចហើយ ទើបឮដំណឹងថា កឋិនក្នុងអាវាសនោះ សង្ឃបានព្រមគ្នាដកហើយ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ត្រង់បានឮដំណឹងជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយ ប្រមូលយកចីវរចៀសចេញទៅដោយគិតថា អាត្មាអញនឹងត្រឡប់វិញ ។ ភិក្ខុនោះទៅដល់ក្រៅសីមាក៏បានធ្វើចីវរនោះ ។ លុះភិក្ខុនោះបានធ្វើចីវរស្រេចហើយក៏នៅតែគិតថា អាត្មាអញនឹងត្រឡប់វិញ អាត្មាអញនឹងត្រឡប់វិញដែរ (តែមិនទាន់បានត្រឡប់ទៅឡើយ) កឋិនក៏ដោះនៅទីក្រៅ (នោះ) ទៅ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ត្រង់កន្លងនូវកឋិនជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយ ប្រមូលយកចីវរចៀសចេញទៅដោយគិតថា អាត្មាអញនឹងត្រឡប់វិញ ។ ភិក្ខុនោះ

ពហិសីមគតោ តំ ចីវរំ ការេតិ ។ សោ កតចីវរោ
បច្ចេស្សំ បច្ចេស្សន្តិ ពហិទ្ធា កឋិនុទ្ធារំ ។ តស្ស
ភិក្ខុនោ សហ ភិក្ខូហិ កឋិនុទ្ធារោ ។

សមាទាយសត្តកំ និដ្ឋិតំ ទុតិយំ ។

[៩] ភិក្ខុ អត្ថតកឋិនោ វិប្បកតំ ចីវរំ អាទាយ
បក្កមតិ ។ តស្ស ពហិសីមគតស្ស ឯវំ ហោតិ ឥធេ-
វិមំ ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ សោ តំ ចីវរំ
ការេតិ ។ តស្ស ភិក្ខុនោ និដ្ឋានន្តិកោ កឋិនុទ្ធារោ ។
ភិក្ខុ អត្ថតកឋិនោ វិប្បកតំ ចីវរំ អាទាយ បក្កមតិ ។
តស្ស ពហិសីមគតស្ស ឯវំ ហោតិ នេវិមំ ចីវរំ ការេស្សំ
ន បច្ចេស្សន្តិ ។ តស្ស ភិក្ខុនោ សន្និដ្ឋានន្តិកោ
កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ វិប្បកតំ ចីវរំ អាទាយ
បក្កមតិ ។ តស្ស ពហិសីមគតស្ស ឯវំ ហោតិ ឥធេវិមំ



ទៅដល់ក្រៅសីមាក៏បានធ្វើចីវរនោះ ។ លុះភិក្ខុនោះបានធ្វើចីវររួចហើយ
គិតថា អាត្មាអញនឹងត្រឡប់វិញ អាត្មាអញនឹងត្រឡប់វិញ ហើយក៏បាន
មកទាន់ពេលដោះកឋិនមែន ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ជាមួយ
នឹងភិក្ខុទាំងឡាយ ។

ចប់ សមាទាយសត្តកៈ ទី ២ ។

(៩) ភិក្ខុបានក្រាលកឋិនរួចហើយនាំយកចីវរដែលធ្វើមិនទាន់
ស្រេចស្រួលចេញទៅ ។ កាលភិក្ខុនោះទៅដល់ក្រៅសីមាក៏មានសេចក្តី
ត្រិះរិះយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញនឹង
មិនត្រឡប់វិញទេ ។ ភិក្ខុនោះក៏បានធ្វើចីវរនោះឲ្យស្រេច ។ កឋិន
របស់ភិក្ខុនោះឈ្មោះថាដោះ ត្រង់ធ្វើចីវរស្រេចជាកំណត់ ។ ភិក្ខុបាន
ក្រាលកឋិនរួចហើយនាំយកចីវរដែលធ្វើមិនទាន់ស្រេចស្រួលចេញទៅ ។
កាលភិក្ខុនោះទៅដល់ក្រៅសីមាក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញ
នឹងមិនធ្វើចីវរនេះទេ អាត្មាអញនឹងមិនត្រឡប់វិញទេ ។ កឋិនរបស់
ភិក្ខុនោះឈ្មោះថាដោះ ត្រង់សេចក្តីសន្និដ្ឋានជាកំណត់ ។ ភិក្ខុបាន
ក្រាលកឋិនរួចហើយនាំយកចីវរដែលធ្វើមិនទាន់ស្រេចស្រួលចេញទៅ ។
កាលភិក្ខុនោះទៅដល់ក្រៅសីមាក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មា

ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ សោ តំ ចីវរំ ការេតិ ។ តស្ស តំ ចីវរំ ករិយមានំ នស្សតិ ។ តស្ស ភិក្ខុនោ នាសនន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ វិប្បកតចីវរំ អាទាយ បក្កមតិ បច្ចេស្សន្តិ ។ សោ ពហិសីមគតោ តំ ចីវរំ ការេតិ ។ សោ កតចីវរោ សុណាតិ ឧព្ភតំ កិរ តស្មិំ អាវាសេ កឋិនន្តិ ។ តស្ស ភិក្ខុនោ សវនន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ វិប្បកតចីវរំ អាទាយ បក្កមតិ បច្ចេស្សន្តិ ។ សោ ពហិសីមគតោ តំ ចីវរំ ការេតិ ។ សោ កតចីវរោ បច្ចេស្សំ បច្ចេស្សន្តិ ពហិទ្ធា កឋិនុទ្ធារំ វីតិនាមេតិ ។ តស្ស ភិក្ខុនោ សីមាតិក្កន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ វិប្បកតចីវរំ អាទាយ បក្កមតិ បច្ចេស្សន្តិ ។ សោ ពហិសីមគតោ តំ ចីវរំ ការេតិ ។



អញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញនឹងមិនត្រឡប់វិញទេ ។ ភិក្ខុនោះក៏បានធ្វើចីវរនោះ ។ កាលភិក្ខុនោះកំពុងធ្វើ ចីវរនោះក៏វិនាសទៅ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ព្រោះចីវរវិនាសជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយនាំយកចីវរដែលធ្វើមិនទាន់ស្រេចចេញទៅដោយគិតថា អាត្មាអញនឹងត្រឡប់វិញ ។ ភិក្ខុនោះទៅដល់ក្រៅសីមាក៏បានធ្វើចីវរនោះ ។ លុះភិក្ខុនោះបានធ្វើចីវររួចហើយក៏ស្រាប់តែឮដំណឹងថា កឋិនក្នុងអាវាសនោះសង្ឃព្រមគ្នាដកហើយ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ព្រោះបានឮដំណឹងជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយនាំយកចីវរដែលធ្វើមិនទាន់ស្រេចចេញទៅដោយគិតថា អាត្មាអញនឹងត្រឡប់វិញ ។ ភិក្ខុនោះទៅដល់ក្រៅសីមាក៏បានធ្វើចីវរនោះ ។ លុះភិក្ខុនោះបានធ្វើចីវររួចហើយគិតថា អាត្មាអញនឹងត្រឡប់វិញ អាត្មាអញនឹងត្រឡប់វិញដែរ (តែមិនទាន់បានត្រឡប់មកវិញឡើយ) កឋិនក៏ដោះខាងក្រៅ (នោះ) ទៅ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ព្រោះកន្លងខេត្តកឋិនជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយនាំយកចីវរដែលធ្វើមិនទាន់ស្រេចចេញទៅដោយគិតថា អាត្មាអញនឹងត្រឡប់វិញ ។ ភិក្ខុនោះទៅដល់ក្រៅសីមាក៏បានធ្វើចីវរនោះ ។

សោ កតចីវរោ បច្ចេស្សំ បច្ចេស្សន្តិ សម្ភុណាតិ កឋិ-នុទ្ធារំ ។ តស្ស ភិក្ខុនោ សហ ភិក្ខូហិ កឋិនុទ្ធារោ ។

អាទាយឆក្កំ និដ្ឋិតំ តតិយំ ។

(៥) ភិក្ខុ អត្ថតកឋិនោ វិប្បកតចីវរំ សមាទាយ បក្កមតិ ។ តស្ស ពហិសីមគតស្ស ឯវំ ហោតិ ឥធេវិមំ ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ សោ តំ ចីវរំ ការេតិ ។ តស្ស ភិក្ខុនោ និដ្ឋានន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ វិប្បកតចីវរំ សមាទាយ បក្កមតិ ។ តស្ស ពហិសីមគតស្ស ឯវំ ហោតិ នេវិមំ ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ តស្ស ភិក្ខុនោ សន្និដ្ឋានន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ វិប្បកតចីវរំ សមាទាយ បក្កមតិ ។ តស្ស ពហិសីមគតស្ស ឯវំ ហោតិ ឥធេវិមំ



លុះភិក្ខុនោះធ្វើចីវររួចហើយក៏គិតថា អាត្មាអញនឹងត្រឡប់វិញ អាត្មាអញនឹងត្រឡប់វិញ ហើយក៏បានមកទាន់ពេលដោះកឋិនដែរ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ជាមួយនឹងភិក្ខុទាំងឡាយ ។

ចប់ អាទាយឆក្កៈ ទី ៣ ។

(៥) ភិក្ខុបានក្រាលកឋិនរួចហើយ ប្រមូលយកចីវរដែលធ្វើមិនទាន់ស្រេចចៀសចេញទៅ ។ កាលភិក្ខុនោះទៅដល់ក្រៅសីមាក៏មានសេចក្តីគិតយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញនឹងមិនត្រឡប់វិញទេ ។ ភិក្ខុនោះក៏បានធ្វើចីវរនោះឲ្យស្រេច ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ត្រង់ធ្វើចីវរស្រេចជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយ ប្រមូលយកចីវរដែលធ្វើមិនទាន់ស្រេចចៀសចេញទៅ ។ កាលភិក្ខុនោះទៅដល់ក្រៅសីមាក៏មានសេចក្តីគិតយ៉ាងនេះថា អាត្មាអញនឹងមិនធ្វើចីវរនេះទេ អាត្មាអញនឹងមិនត្រឡប់វិញទេ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ត្រង់សេចក្តីសន្និដ្ឋានជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយ ប្រមូលយកចីវរដែលធ្វើមិនទាន់ស្រេចចៀសចេញទៅ ។ កាលភិក្ខុនោះទៅដល់ក្រៅសីមាក៏មានគំនិតយ៉ាងនេះថា អាត្មា

ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ សោ តំ ចីវរំ ការេតិ ។ តស្ស តំ ចីវរំ ករិយមានំ នស្សតិ ។ តស្ស ភិក្ខុនោ នាសនន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ វិប្ប-កតំ ចីវរំ អាទាយ បក្កមតិ បច្ចេស្សន្តិ ។ សោ ពហិសីមគតោ តំ ចីវរំ ការេតិ ។ សោ កតចីវរោ សុណាតិ ឧព្ភតំ កិរ តស្មិំ អាវាសេ កឋិនន្តិ ។ តស្ស ភិក្ខុនោ សវនន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតក-ឋិនោ វិប្បកតំ ចីវរំ អាទាយ បក្កមតិ បច្ចេស្សន្តិ ។ សោ ពហិសីមគតោ តំ ចីវរំ ការេតិ ។ សោ កតចីវរោ បច្ចេស្សំ បច្ចេស្សន្តិ ពហិទ្ធា កឋិនុទ្ធារំ វីតិនាមេតិ ។ តស្ស ភិក្ខុនោ សីមាតិក្កន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ វិប្បកតចីវរំ អាទាយ បក្កមតិ បច្ចេស្សន្តិ ។ សោ ពហិសីមគតោ តំ ចីវរំ ការេតិ ។



អញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញនឹងមិនត្រឡប់វិញទេ ។ ភិក្ខុនោះក៏បានធ្វើចីវរនោះ ។ កាលភិក្ខុនោះកំពុងធ្វើ ចីវររបស់ភិក្ខុនោះក៏វិនាសទៅ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ព្រោះចីវរវិនាសជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយប្រមូលយកចីវរដែលធ្វើមិនទាន់ស្រេចស្រួលចេញទៅដោយគិតថា អាត្មាអញនឹងត្រឡប់វិញ ។ ភិក្ខុនោះទៅដល់ក្រៅសីមាក៏បានធ្វើចីវរនោះ ។ លុះភិក្ខុនោះធ្វើចីវរហើយឮដំណឹងថា កឋិនក្នុងអាវាសនោះសង្ឃព្រមគ្នាដកហើយ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ព្រោះឮដំណឹងជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយនាំយកចីវរដែលធ្វើមិនទាន់ស្រេចស្រួលចេញទៅដោយគំនិតគិតថា អាត្មាអញនឹងត្រឡប់វិញ ។ ភិក្ខុនោះទៅដល់ក្រៅសីមាក៏បានធ្វើចីវរនោះ ។ លុះភិក្ខុនោះធ្វើចីវរហើយក៏នៅគិតថា អាត្មាអញនឹងត្រឡប់វិញ អាត្មាអញនឹងត្រឡប់វិញដែរ (តែមិនទាន់បានត្រឡប់នៅឡើយ) កឋិនក៏ដោះអស់ក្រៅ ( នោះ ) ទៅ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ព្រោះកន្លងនូវខេត្តកឋិនជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយប្រមូលយកចីវរដែលធ្វើមិនទាន់ស្រេចស្រួលចេញទៅដោយគំនិតថា អាត្មាអញនឹងត្រឡប់វិញ ។ ភិក្ខុនោះទៅដល់ក្រៅសីមាក៏បានធ្វើចីវរនោះ ។

សោ កតចីវរោ បច្ចេស្សំ បច្ចេស្សន្តិ សម្ភុណាតិ កឋិនុទ្ធារំ ។ តស្ស ភិក្ខុនោ សហ ភិក្ខូហិ កឋិនុទ្ធារោ ។

អាទាយសត្តកំ និដ្ឋិតំ បឋមំ ។

(១០) ភិក្ខុ អត្ថតកឋិនោ ចីវរំ អាទាយ បក្កមតិ ។ តស្ស ពហិសីមគតស្ស ឯវំ ហោតិ ឥធេវិមំ ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ សោ តំ ចីវរំ ការេតិ ។ តស្ស ភិក្ខុនោ និដ្ឋានន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ ចីវរំ អាទាយ បក្កមតិ ។ តស្ស ពហិសីមគតស្ស ឯវំ ហោតិ នេវិមំ ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ តស្ស ភិក្ខុនោ សន្និដ្ឋានន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ ចីវរំ អាទាយ បក្កមតិ ។ តស្ស ពហិសីមគតស្ស ឯវំ ហោតិ ឥធេវិមំ ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ សោ តំ ចីវរំ ការេតិ ។ តស្ស តំ ចីវរំ កយិរមានំ នស្សតិ ។ តស្ស ភិក្ខុនោ នាសនន្តិកោ កឋិនុទ្ធារោ ។



ភិក្ខុនោះធ្វើចីវរហើយ តាំងចិត្តថា អាត្មាអញនឹងត្រឡប់វិញ អាត្មាអញនឹងត្រឡប់វិញ ហើយក៏បានមកទាន់ពេលដោះកឋិនដែរ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ជាមួយនឹងភិក្ខុទាំងឡាយ ។

ចប់ សមាទាយវគ្គៈ ទី ១ ។

[១០] ភិក្ខុបានក្រាលកឋិនរួចហើយនាំយកចីវរចៀសចេញទៅ ។ កាលភិក្ខុនោះទៅដល់ក្រៅសីមា ក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញនឹងមិនត្រឡប់វិញទេ ។ ភិក្ខុនោះក៏បានធ្វើចីវរនោះឲ្យសម្រេច ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ព្រោះធ្វើចីវរសម្រេចជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយនាំយកចីវរចៀសចេញទៅ ។ កាលភិក្ខុនោះទៅដល់ក្រៅសីមាក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងមិនធ្វើចីវរនេះទេ អាត្មាអញនឹងមិនត្រឡប់វិញទេ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ព្រោះសេចក្តីសន្និដ្ឋានជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយនាំយកចីវរចៀសចេញទៅ ។ កាលភិក្ខុនោះទៅដល់ក្រៅសីមាក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញនឹងមិនត្រឡប់វិញទេ ។ ភិក្ខុនោះក៏បានធ្វើចីវរនោះ ។ កាលភិក្ខុនោះកំពុងធ្វើ ចីវរនោះក៏វិនាសទៅ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ព្រោះចីវរវិនាសជាកំណត់ ។

(១១) ភិក្ខុ អត្ថតកឋិនោ ចីវរំ អាទាយ បក្កមតិ
ន បច្ចេស្សន្តិ ។ តស្ស ពហិសីមគតស្ស ឯវំ ហោតិ
ឥធេវិមំ ចីវរំ ការេស្សន្តិ ។ សោ តំ ចីវរំ ការេតិ ។
តស្ស ភិក្ខុនោ និដ្ឋានន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ
អត្ថតកឋិនោ ចីវរំ អាទាយ បក្កមតិ ន បច្ចេស្សន្តិ ។
តស្ស ពហិសីមគតស្ស ឯវំ ហោតិ នេវិមំ ចីវរំ ការេ-
ស្សន្តិ ។ តស្ស ភិក្ខុនោ សន្និដ្ឋានន្តិកោ កឋិនុទ្ធា-
រោ ។ ភិក្ខុ អត្ថតកឋិនោ ចីវរំ អាទាយ បក្កមតិ ន
បច្ចេស្សន្តិ ។ តស្ស ពហិសីមគតស្ស ឯវំ ហោតិ ឥធេវិមំ
ចីវរំ ការេស្សន្តិ ។ សោ តំ ចីវរំ ការេតិ ។ តស្ស តំ
ចីវរំ ករិយមានំ នស្សតិ ។ តស្ស ភិក្ខុនោ នាសនន្តិ-
កោ កឋិនុទ្ធារោ ។

(១២) ភិក្ខុ អត្ថតកឋិនោ ចីវរំ អាទាយ បក្ក-
មតិ អនធិដ្ឋិតេន នេវស្ស ហោតិ បច្ចេស្សន្តិ ន បនស្ស



[១១] ភិក្ខុបាន[ក្រាល]កឋិនរួចហើយ នាំយកចីវរចៀសចេញទៅ
ដោយតាំងចិត្តថា អាត្មាអញនឹងមិន[ត្រឡប់]មកវិញទេ ។ កាលភិក្ខុនោះទៅ
ដល់[ក្រៅ]សីមាក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះ
ឯង ។ ភិក្ខុនោះក៏បានធ្វើចីវរនោះឲ្យសម្រេច ។ កឋិនរបស់ភិក្ខុនោះ
ឈ្មោះថាដោះ [ព្រោះ]ធ្វើចីវរសម្រេចជាកំណត់ ។ ភិក្ខុបាន[ក្រាល]កឋិនរួច
ហើយ នាំយកចីវរចៀសចេញទៅដោយតាំងចិត្តថា អាត្មាអញនឹងមិន[ត្រ-
ឡប់]មកវិញទេ ។ កាលភិក្ខុនោះទៅដល់[ក្រៅ]សីមា ក៏មានគំនិតយ៉ាងនេះ
ថា អាត្មាអញនឹងមិនធ្វើចីវរនេះទៀយ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថា
ដោះ [ព្រោះ]សេចក្តីសន្និដ្ឋានជាកំណត់ ។ ភិក្ខុបាន[ក្រាល]កឋិនរួចហើយ
នាំយកចីវរចៀសចេញទៅដោយតាំងចិត្តថា អាត្មាអញនឹងមិន[ត្រឡប់]មកវិញ
ទេ ។ កាលភិក្ខុនោះទៅដល់[ក្រៅ]សីមាក៏មានគំនិតយ៉ាងនេះថា អាត្មា
អញនឹងធ្វើចីវរនេះក្នុងទីនេះឯង ។ ភិក្ខុនោះក៏បានធ្វើចីវរនោះ ។ កាល
ភិក្ខុនោះកំពុងធ្វើ ចីវរនោះក៏វិនាសទៅ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថា
ដោះ [ព្រោះ]ចីវរវិនាសជាកំណត់ ។

[១២] ភិក្ខុបាន[ក្រាល]កឋិនរួចហើយ នាំយកចីវរចៀសចេញទៅ
ដោយមិនបានតាំងចិត្ត គឺភិក្ខុនោះគ្មានគំនិតថា អាត្មាអញនឹង[ត្រឡប់]មកវិញ

ហោតិ ន បច្ចេស្សន្តិ ។ តស្ស ពហិសីមគតស្ស ឯវំ ហោតិ ឥធេវិមំ ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ សោ តំ ចីវរំ ការេតិ ។ តស្ស ភិក្ខុនោ និដ្ឋានន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ ចីវរំ អាទាយ បក្កមតិ អនធិដ្ឋិតេន នេវស្ស ហោតិ បច្ចេស្សន្តិ ន បនស្ស ហោតិ ន បច្ចេស្សន្តិ ។ តស្ស ពហិសីមគតស្ស ឯវំ ហោតិ នេវិមំ ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ តស្ស ភិក្ខុនោ សន្និដ្ឋានន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ ចីវរំ អាទាយ បក្កមតិ អនធិដ្ឋិតេន នេវស្ស ហោតិ បច្ចេស្សន្តិ ន បនស្ស ហោតិ ន បច្ចេស្សន្តិ ។ តស្ស ពហិសីមគតស្ស ឯវំ ហោតិ ឥធេវិមំ ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ សោ តំ ចីវរំ ការេតិ ។ តស្ស តំ ចីវរំ ករិយមានំ នស្សតិ ។ តស្ស ភិក្ខុនោ នាសនន្តិកោ កឋិនុទ្ធារោ ។



តាំងពីគំនិតរបស់ភិក្ខុនោះថា អាត្មាអញនឹងមិនត្រឡប់វិញ ក៏គ្មានដែរ(១) ។ កាលភិក្ខុនោះទៅដល់ក្រៅសីមា ក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញនឹងមិនត្រឡប់វិញទេ ។ ភិក្ខុនោះក៏បានធ្វើចីវរនោះឲ្យសម្រេច ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ព្រោះចីវរសម្រេចជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយ នាំយកចីវរចៀសចេញទៅដោយមិនបានតាំងចិត្ត ភិក្ខុនោះគ្មានគំនិតថា អាត្មាអញនឹងត្រឡប់វិញ តាំងពីគំនិតរបស់ភិក្ខុនោះថា អាត្មាអញនឹងមិនត្រឡប់វិញក៏គ្មានដែរ ។ កាលភិក្ខុនោះទៅដល់ក្រៅសីមា ក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងមិនធ្វើចីវរនេះទេ អាត្មាអញនឹងមិនត្រឡប់វិញទេ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ព្រោះសេចក្តីសន្និដ្ឋានជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយ នាំយកចីវរចៀសចេញទៅដោយមិនបានតាំងចិត្ត ភិក្ខុនោះគ្មានគំនិតថា អាត្មាអញនឹងត្រឡប់វិញ តាំងពីគំនិតរបស់ភិក្ខុនោះថា អាត្មាអញនឹងមិនត្រឡប់វិញ ក៏គ្មានដែរ ។ កាលភិក្ខុនោះទៅដល់ក្រៅសីមា ក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញនឹងមិនត្រឡប់វិញទេ ។ ភិក្ខុនោះក៏បានធ្វើចីវរនោះ ។ កាលភិក្ខុនោះកំពុងធ្វើ ចីវរនោះក៏វិនាសទៅ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ព្រោះចីវរវិនាសជាកំណត់ ។

---

១ ភិក្ខុនេះមានគំនិតជាកណ្តាល មិនគិតថាត្រឡប់វិញឬមិនត្រឡប់វិញជាដាច់ខាតទេ ។

[១៣] ភិក្ខុ អត្ថតកឋិនោ ចីវរំ អាទាយ បក្កមតិ បច្ចេស្សន្តិ ។ តស្ស ពហិសីមគតស្ស ឯវំ ហោតិ ឥធេវិមំ ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ សោ តំ ចីវរំ ការេតិ ។ តស្ស ភិក្ខុនោ និដ្ឋានន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ ចីវរំ អាទាយ បក្កមតិ បច្ចេស្សន្តិ ។ តស្ស ពហិសីមគតស្ស ឯវំ ហោតិ នេវិមំ ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ តស្ស ភិក្ខុនោ សន្និដ្ឋានន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ ចីវរំ អាទាយ បក្កមតិ បច្ចេស្សន្តិ ។ តស្ស ពហិសីមគតស្ស ឯវំ ហោតិ ឥធេវិមំ ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ សោ តំ ចីវរំ ការេតិ ។ តស្ស តំ ចីវរំ ករិយមានំ នស្សតិ ។ តស្ស ភិក្ខុនោ នាសនន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ ចីវរំ អាទាយ បក្កមតិ បច្ចេស្សន្តិ ។ សោ ពហិសីមគតោ តំ ចីវរំ ការេតិ ។ សោ កតចីវរោ សុណាតិ ឧព្ភតំ កិរ





[១៣] ភិក្ខុបានក្រាលកឋិនរួចហើយនាំយកចីវរចៀសចេញទៅ ដោយបំណងថា អាត្មាអញនឹងត្រឡប់វិញ ។ កាលភិក្ខុនោះទៅដល់ក្រៅសីមា ក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញនឹងមិនត្រឡប់វិញទេ ។ ភិក្ខុនោះក៏បានធ្វើចីវរនោះឲ្យសម្រេច ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ព្រោះចីវរសម្រេចជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយនាំយកចីវរចៀសចេញទៅ ដោយបំណងថា អាត្មាអញនឹងត្រឡប់វិញ ។ កាលភិក្ខុនោះទៅដល់ក្រៅសីមាក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងមិនធ្វើចីវរនេះទេ អាត្មាអញនឹងមិនត្រឡប់វិញទេ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ព្រោះសេចក្តីសន្និដ្ឋានជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយនាំយកចីវរចៀសចេញទៅដោយបំណងថា អាត្មាអញនឹងត្រឡប់វិញ ។ កាលភិក្ខុនោះទៅដល់ក្រៅសីមាក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញនឹងមិនត្រឡប់វិញទេ ។ ភិក្ខុនោះក៏បានធ្វើចីវរនោះ ។ កាលភិក្ខុនោះកំពុងធ្វើ ចីវរនោះក៏វិនាសទៅ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ព្រោះចីវរវិនាសជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយនាំយកចីវរចៀសចេញទៅដោយបំណងថា អាត្មាអញនឹងត្រឡប់វិញ ។ ភិក្ខុនោះទៅដល់ក្រៅសីមា ក៏បានធ្វើចីវរនោះ ។ ភិក្ខុនោះធ្វើចីវររួចហើយ ឮដំណឹងថា

តស្មឹ អាវាសេ កឋិនន្តិ ។ តស្ស ភិក្ខុនោ សវនន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ ចីវរំ អាទាយ បក្កមតិ បច្ចេស្សន្តិ ។ សោ ពហិសីមគតោ តំ ចីវរំ ការេតិ ។ សោ កតចីវរោ បច្ចេស្សំ បច្ចេស្សន្តិ ពហិទ្ធា កឋិនុទ្ធារំ វីតិនាមេតិ ។ តស្ស ភិក្ខុនោ សីមាតិក្កន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ ចីវរំ អាទាយ បក្កមតិ បច្ចេស្សន្តិ ។ សោ ពហិសីមគតោ តំ ចីវរំ ការេតិ ។ សោ កតចីវរោ បច្ចេស្សំ បច្ចេស្សន្តិ សម្ភុណាតិ កឋិនុទ្ធារំ ។ តស្ស ភិក្ខុនោ សហ ភិក្ខូហិ កឋិនុទ្ធារោ ។

(១៤) ភិក្ខុ អត្ថតកឋិនោ ចីវរំ សមាទាយ បក្កមតិ ។ (អាទាយវារសទិសំ វិត្ថារេតព្វំ) ។ ភិក្ខុ អត្ថតកឋិនោ វិប្បកតចីវរំ អាទាយ បក្កមតិ ។ តស្ស ពហិសីមគតស្ស ឯវំ ហោតិ ឥធេវិមំ ចីវរំ



កឋិនក្នុងអាវាសនោះ សង្ឃក្រាលដកហើយ ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ព្រោះការស្តាប់ជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយនាំយកចីវរចេញទៅ ដោយបំណងថា អាត្មាអញនឹងត្រឡប់វិញ ។ ភិក្ខុនោះទៅដល់ក្រៅសីមាក៏បានធ្វើចីវរនោះ ។ លុះភិក្ខុនោះធ្វើចីវរស្រេចហើយគិតថា អាត្មាអញនឹងត្រឡប់វិញ អាត្មាអញនឹងត្រឡប់វិញដែរ (តែមិនទាន់បានត្រឡប់ទៅឡើយ) កឋិនក៏ដោះទាំងក្រៅ (នោះ)ទៅ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ព្រោះកន្លងដោះកឋិនជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយនាំយកចីវរចេញទៅ ដោយបំណងថា អាត្មាអញនឹងត្រឡប់វិញ ។ លុះភិក្ខុនោះទៅដល់ក្រៅសីមាក៏បានធ្វើចីវរនោះ ។ ភិក្ខុនោះធ្វើចីវរនោះស្រេចហើយគិតថា អាត្មាអញនឹងត្រឡប់វិញ អាត្មាអញនឹងត្រឡប់វិញ ហើយក៏បានមកទាន់ពេលដោះកឋិនមែន ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ជាមួយនឹងភិក្ខុទាំងឡាយ ។

(១៤) ភិក្ខុបានក្រាលកឋិនរួចហើយប្រមូលយកចីវរចេញទៅ ។ (ពាក្យយ៉ាងនេះ ប្រហែលនឹងអាទាយវារៈ បណ្ឌិតគប្បីសំដែងឲ្យពិស្តារចុះ) ។ ភិក្ខុបានក្រាលកឋិនរួចហើយនាំយកចីវរដែលធ្វើមិនទាន់ស្រេចបានចេញទៅ ។ កាលភិក្ខុនោះទៅដល់ក្រៅសីមាក៏មានគំនិត

ការេស្សំ ន បច្ចេស្សន្តិ ។ សោ តំ ចីវរំ ការេតិ ។ តស្ស ភិក្ខុនោ និដ្ឋានន្តិកោ កឋិនុទ្ធារោ ។ (សមាទាយវារសង្ខិត្តំ ឯវំ វិត្ថារេតព្វំ) ។

(១៨) ភិក្ខុ អត្ថតកឋិនោ វិប្បកតចីវរំ សមាទាយ បក្កមតិ ។ តស្ស ពហិសីមគតស្ស ឯវំ ហោតិ ឥធេវិមំ ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ សោ តំ ចីវរំ ការេតិ ។ តស្ស ភិក្ខុនោ និដ្ឋានន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ វិប្បកតចីវរំ សមាទាយ បក្កមតិ ។ តស្ស ពហិសីមគតស្ស ឯវំ ហោតិ នេវិមំ ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ តស្ស ភិក្ខុនោ សន្និដ្ឋានន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ វិប្បកតចីវរំ សមាទាយ បក្កមតិ ។ តស្ស ពហិសីមគតស្ស ឯវំ ហោតិ ឥធេវិមំ ចីវរំ ការេស្សំ



យ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញនឹងមិនត្រឡប់វិញទេ ។ ភិក្ខុនោះក៏ធ្វើចីវរនោះឲ្យសម្រេច ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ព្រោះចីវរសម្រេចជាកំណត់ ។ (ពាក្យយ៉ាងនេះ ប្រហែលនឹងសមាទាយវារៈ បណ្ឌិតគប្បីសំដែងឲ្យពិស្តារចុះ) ។

(១៨) ភិក្ខុបានក្រាលកឋិនរួចហើយ ប្រមូលយកចីវរដែលធ្វើមិនទាន់សម្រេចចៀសចេញទៅ ។ កាលភិក្ខុនោះទៅដល់ក្រៅសីមាក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញនឹងមិនត្រឡប់វិញទេ ។ ភិក្ខុនោះក៏ធ្វើចីវរនោះឲ្យសម្រេច ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ព្រោះចីវរសម្រេចជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយប្រមូលយកចីវរដែលធ្វើមិនទាន់សម្រេចចៀសចេញទៅ ។ កាលភិក្ខុនោះទៅដល់ក្រៅសីមាក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងមិនធ្វើចីវរនេះទេ អាត្មាអញនឹងមិនត្រឡប់វិញទេ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ព្រោះសេចក្តីសន្និដ្ឋានជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយប្រមូលយកចីវរដែលធ្វើមិនទាន់សម្រេចចៀសចេញទៅ ។ កាលភិក្ខុនោះទៅដល់ក្រៅសីមាក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង

ន បច្ចេស្សន្តិ ។ សោ តំ ចីវរំ ការេតិ ។ តស្ស តំ ចីវរំ ករិយមានំ នស្សតិ ។ តស្ស ភិក្ខុនោ នាសនន្តិកោ កឋិនុទ្ធារោ ។

(១៦) ភិក្ខុ អត្ថតកឋិនោ វិប្បកតចីវរំ សមាទាយ បក្កមតិ ន បច្ចេស្សន្តិ ។ តស្ស ពហិសីមគតស្ស ឯវំ ហោតិ ឥធេវិមំ ចីវរំ ការេស្សន្តិ ។ សោ តំ ចីវរំ ការេតិ ។ តស្ស ភិក្ខុនោ និដ្ឋានន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ វិប្បកតចីវរំ សមាទាយ បក្កមតិ ន បច្ចេស្សន្តិ ។ តស្ស ពហិសីមគតស្ស ឯវំ ហោតិ នេវិមំ ចីវរំ ការេស្សន្តិ ។ តស្ស ភិក្ខុនោ សន្និដ្ឋានន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ វិប្បកតចីវរំ សមាទាយ បក្កមតិ ន បច្ចេស្សន្តិ ។ តស្ស ពហិសីមគតស្ស ឯវំ ហោតិ



អាត្មាអញនឹងមិនត្រឡប់វិញទេ ។ ភិក្ខុនោះក៏បានធ្វើចីវរនោះ ។ កាលភិក្ខុនោះកំពុងធ្វើ ចីវរនោះក៏វិនាសទៅ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ព្រោះចីវរវិនាសជាកំណត់ ។

(១៦) ភិក្ខុបានក្រាលកឋិនរួចហើយ ប្រមូលយកចីវរដែលធ្វើមិនទាន់សម្រេចចៀសចេញទៅដោយបំណងថា អាត្មាអញនឹងមិនត្រឡប់វិញទេ ។ កាលភិក្ខុនោះទៅដល់ក្រៅសីមាក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង ។ ភិក្ខុនោះក៏បានធ្វើចីវរនោះឲ្យសម្រេច ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ព្រោះចីវរសម្រេចជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយ ប្រមូលយកចីវរដែលធ្វើមិនទាន់សម្រេចចៀសចេញទៅដោយបំណងថា អាត្មាអញនឹងមិនត្រឡប់វិញទេ ។ កាលភិក្ខុនោះទៅដល់ក្រៅសីមាក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងមិនធ្វើចីវរនេះទេ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ព្រោះសេចក្តីសន្និដ្ឋានជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយ ប្រមូលយកចីវរដែលធ្វើមិនទាន់សម្រេចចៀសចេញទៅដោយបំណងថា អាត្មាអញនឹងមិនត្រឡប់វិញទេ ។ កាលភិក្ខុនោះទៅដល់ក្រៅសីមាក៏មានគំនិតយ៉ាងនេះថា

ឥធេវិមំ ចីវរំ ការេស្សន្តិ ។ សោ តំ ចីវរំ ការេតិ ។ តស្ស តំ ចីវរំ ករិយមានំ នស្សតិ ។ តស្ស ភិក្ខុនោ នាសនន្តិកោ កឋិនុទ្ធារោ ។

[៣៧] ភិក្ខុ អត្ថតកឋិនោ វិប្បកតចីវរំ សមាទាយ បក្កមតិ អនធិដ្ឋិតេន នេវស្ស ហោតិ បច្ចេស្សន្តិ ន បនស្ស ហោតិ ន បច្ចេស្សន្តិ ។ តស្ស ពហិសីមគតស្ស ឯវំ ហោតិ ឥធេវិមំ ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ សោ តំ ចីវរំ ការេតិ ។ តស្ស ភិក្ខុនោ និដ្ឋានន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ វិប្បកតចីវរំ សមាទាយ បក្កមតិ អនធិដ្ឋិតេន នេវស្ស ហោតិ បច្ចេស្សន្តិ ន បនស្ស ហោតិ ន បច្ចេស្សន្តិ ។ តស្ស ពហិសីមគតស្ស ឯវំ ហោតិ នេវិមំ ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ តស្ស ភិក្ខុនោ សន្និដ្ឋានន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ វិប្បកតចីវរំ សមាទាយ បក្កមតិ



អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង ។ ភិក្ខុនោះក៏បានធ្វើចីវរនោះ ។ កាលភិក្ខុនោះកំពុងធ្វើ ចីវរនោះក៏វិនាសទៅ ។ កឋិនរបស់ភិក្ខុនោះឈ្មោះជាដោះ [ត្រង់ចីវរវិនាសជាកំណត់] ។

(៣៧) - ភិក្ខុបាន[ក្រាលកឋិនរួច]ហើយ [ប្រមូលយកចីវរដែលធ្វើមិនទាន់ស[ម្រេច]]ចេញទៅដោយមិនបានតាំងចិត្ត គឺភិក្ខុនោះគ្មានគំនិតថា អាត្មាអញនឹង[ត្រឡប់វិញ] ទាំងគំនិតរបស់ភិក្ខុនោះថា អាត្មាអញនឹងមិន[ត្រឡប់វិញ]ក៏គ្មានដែរ ។ កាលភិក្ខុនោះទៅដល់[ក្រៅសីមា]ក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញនឹងមិន[ត្រឡប់វិញ]ទេ ។ ភិក្ខុនោះក៏បានធ្វើចីវរនោះឲ្យសម្រេច ។ កឋិនរបស់ភិក្ខុនោះឈ្មោះជាដោះ [ត្រង់ចីវរសម្រេចជាកំណត់] ។ ភិក្ខុបាន[ក្រាលកឋិនរួច]ហើយ [ប្រមូលយកចីវរដែលធ្វើមិនទាន់ស[ម្រេច]]ចេញទៅ ដោយមិនបានតាំងចិត្ត គឺភិក្ខុនោះគ្មានគំនិតថា អាត្មាអញនឹង[ត្រឡប់វិញ] ទាំងគំនិតរបស់ភិក្ខុនោះថា អាត្មាអញនឹងមិន[ត្រឡប់វិញ]ក៏គ្មានដែរ ។ កាលភិក្ខុនោះទៅដល់[ក្រៅសីមា]ក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងមិនធ្វើចីវរនេះទេ អាត្មាអញនឹងមិន[ត្រឡប់វិញ]ទេ ។ កឋិនរបស់ភិក្ខុនោះឈ្មោះជាដោះ [ត្រង់សេចក្តីសន្និដ្ឋានជាកំណត់] ។ ភិក្ខុបាន[ក្រាលកឋិនរួច]ហើយ [ប្រមូលយកចីវរដែលធ្វើមិនទាន់ស[ម្រេច]]ចេញទៅ

អនធិដ្ឋិតេន នេវស្ស ហោតិ បច្ចេស្សន្តិ ន បនស្ស ហោតិ ន បច្ចេស្សន្តិ ។ តស្ស ពហិសីមគតស្ស ឯវំ ហោតិ ឥធេវិមំ ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ សោ តំ ចីវរំ ការេតិ ។ តស្ស តំ ចីវរំ ការយមានំ នស្សតិ ។ តស្ស ភិក្ខុនោ នាសនន្តិកោ កឋិនុទ្ធារោ ។

[១៨] ភិក្ខុ អត្ថតកឋិនោ វិប្បកតចីវរំ សមាទាយ បក្កមតិ បច្ចេស្សន្តិ ។ តស្ស ពហិសីមគតស្ស ឯវំ ហោតិ ឥធេវិមំ ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ សោ តំ ចីវរំ ការេតិ ។ តស្ស ភិក្ខុនោ និដ្ឋានន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ វិប្បកតចីវរំ សមាទាយ បក្កមតិ បច្ចេស្សន្តិ ។ តស្ស ពហិសីមគតស្ស ឯវំ ហោតិ នេវិមំ ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ តស្ស ភិក្ខុនោ សន្និដ្ឋានន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ វិប្បកតចីវរំ សមាទាយ បក្កមតិ



ដោយមិនបានតាំងចិត្ត គឺភិក្ខុនោះគ្មានគំនិតថា អាត្មាអញនឹងត្រឡប់វិញ ទាំងគំនិតរបស់ភិក្ខុនោះថា អាត្មាអញនឹងមិនត្រឡប់វិញក៏គ្មានដែរ ។ កាលភិក្ខុនោះទៅដល់ក្រៅសីមាក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញនឹងមិនត្រឡប់វិញទេ ។ ភិក្ខុនោះក៏បានធ្វើចីវរនោះ ។ កាលភិក្ខុនោះកំពុងធ្វើ ចីវរនោះក៏វិនាសទៅ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ត្រង់ចីវរវិនាសជាកំណត់ ។

[១៨] ភិក្ខុបានក្រាលកឋិនរួចហើយ ប្រមូលយកចីវរដែលធ្វើមិនទាន់សម្រេចចៀសចេញទៅដោយបំណងថា អាត្មាអញនឹងត្រឡប់វិញ ។ កាលភិក្ខុនោះទៅដល់ក្រៅសីមាក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញនឹងមិនត្រឡប់វិញទេ ។ ភិក្ខុនោះក៏បានធ្វើចីវរនោះឲ្យសម្រេច ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ត្រង់ចីវរសម្រេចជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយ ប្រមូលយកចីវរដែលធ្វើមិនទាន់សម្រេចចៀសចេញទៅដោយបំណងថា អាត្មាអញនឹងត្រឡប់វិញ ។ កាលភិក្ខុនោះទៅដល់ក្រៅសីមាក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងមិនធ្វើចីវរនេះ អាត្មាអញនឹងមិនត្រឡប់វិញទេ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ត្រង់សេចក្តីសន្និដ្ឋានជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយ ប្រមូលយកចីវរដែលធ្វើមិនទាន់សម្រេចចៀសចេញទៅ

បច្ចេស្សន្តិ ។ តស្ស ពហិសីមគតស្ស ឯវំ ហោតិ ឥធេវិមំ
ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ សោ តំ ចីវរំ ការេតិ ។
តស្ស តំ ចីវរំ ករិយមានំ នស្សតិ ។ តស្ស ភិក្ខុនោ
នាសនន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ
វិប្បកតចីវរំ អាទាយ បក្កមតិ បច្ចេស្សន្តិ ។ សោ
ពហិសីមគតោ តំ ចីវរំ ការេតិ ។ សោ កតចីវរោ
សុណាតិ ឧព្ភតំ កិរ តស្មឹ អាវាសេ កឋិនន្តិ ។ តស្ស
ភិក្ខុនោ សវនន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិ-
នោ វិប្បកតចីវរំ អាទាយ បក្កមតិ បច្ចេស្សន្តិ ។
សោ ពហិសីមគតោ តំ ចីវរំ ការេតិ ។ សោ កត-
ចីវរោ បច្ចេស្សំ បច្ចេស្សន្តិ ពហិទ្ធា កឋិនុទ្ធារំ វីតិនា-
មេតិ ។ តស្ស ភិក្ខុនោ សីមាតិក្កន្តិកោ កឋិនុទ្ធារោ ។
ភិក្ខុ អត្ថតកឋិនោ វិប្បកតចីវរំ អាទាយ បក្កមតិ



ដោយបំណងថា អាត្មាអញនឹងត្រឡប់វិញ ។ កាលភិក្ខុនោះទៅដល់
ក្រៅសីមាក៏មានចំណង់យ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង
អាត្មាអញនឹងមិនត្រឡប់វិញទេ ។ ភិក្ខុនោះក៏បានធ្វើចីវរនោះ ។ កាលភិក្ខុ
នោះកំពុងធ្វើ ចីវរនោះក៏វិនាសទៅ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ
ត្រង់ចីវរវិនាសជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយ ប្រមូលយកចីវរ
ដែលធ្វើមិនទាន់សម្រេច ចៀសចេញទៅដោយបំណងថា អាត្មាអញនឹង
ត្រឡប់វិញ ។ ភិក្ខុនោះទៅដល់ក្រៅសីមាក៏បានធ្វើចីវរនោះ ។ លុះភិក្ខុ
នោះធ្វើចីវរសម្រេចហើយក៏ឮដំណឹងថាកឋិនក្នុងអាវាសនោះ សង្ឃព្រម
គ្នាដកហើយ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ត្រង់បានឮដំណឹង
ជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយ ប្រមូលយកចីវរដែលធ្វើមិន
ទាន់សម្រេចចៀសចេញទៅដោយបំណងថា អាត្មាអញនឹងត្រឡប់វិញ ។
ភិក្ខុនោះទៅដល់ក្រៅសីមាក៏បានធ្វើចីវរនោះ ។ ភិក្ខុនោះធ្វើចីវរសម្រេច
ហើយគិតថា អាត្មាអញនឹងត្រឡប់វិញ អាត្មាអញនឹងត្រឡប់វិញដែរ (តែ
មិនទាន់បានត្រឡប់មកទៀយ) កឋិនក៏ដោះខាងក្រៅ(នោះ)ទៅ ។ កឋិន
របស់ភិក្ខុនោះឈ្មោះថាដោះត្រង់កន្លងសីមាជាកំណត់ ។ ភិក្ខុបានក្រាល
កឋិនរួចហើយប្រមូលយកចីវរដែលធ្វើមិនទាន់សម្រេចចៀសចេញទៅ

បច្ចេស្សន្តិ ។ សោ ពហិសីមគតោ តំ ចីវរំ ការេតិ ។ សោ កតចីវរោ បច្ចេស្សំ បច្ចេស្សន្តិ សម្ភុណាតិ កឋិនុទ្ធារំ ។ តស្ស ភិក្ខុនោ សហ ភិក្ខូហិ កឋិនុទ្ធារោ ។

សមាទាយភាណវារំ និដ្ឋិតំ ។

(១៨) ភិក្ខុ អត្ថតកឋិនោ ចីវរាសាយ បក្កមតិ ។ សោ ពហិសីមគតោ តំ ចីវរាសំ បយិរុបាសតិ អនាសាយ លភតិ អាសាយ ន លភតិ ។ តស្ស ឯវំ ហោតិ ឥធេវិមំ ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ សោ តំ ចីវរំ ការេតិ ។ តស្ស ភិក្ខុនោ និដ្ឋានន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ ចីវរាសាយ បក្កមតិ ។ សោ ពហិសីមគតោ តំ ចីវរាសំ បយិរុបាសតិ អនាសាយ លភតិ អាសាយ ន លភតិ ។ តស្ស ឯវំ ហោតិ



ទៅយ៉ាងណាចុះ គង់គ្នាអញនឹងត្រឡប់វិញ ។ ភិក្ខុនោះទៅដល់ក្រៅសីមា ក៏បានធ្វើចីវរនោះ ។ លុះភិក្ខុនោះធ្វើចីវរស្រេចហើយគិតថា គង់គ្នាអញនឹងត្រឡប់វិញ គង់គ្នាអញនឹងត្រឡប់វិញ ហើយក៏បានមកទាន់ពេលដោះកឋិនវិញ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ជាមួយនឹងភិក្ខុទាំងឡាយ ។

ចប់ សមាទាយភាណវារៈ ។

(១៨) ភិក្ខុបានក្រាលកឋិនរួចហើយចៀសចេញទៅព្រោះចង់បានចីវរ ។ ភិក្ខុនោះទៅដល់ក្រៅសីមាក៏ចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ ក៏បាន (ចីវរ) ខុសបំណង តែមិនបានតាមបំណង ។ ភិក្ខុនោះមានគំនិតយ៉ាងនេះថា គង់គ្នាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង គង់គ្នាអញនឹងមិនត្រឡប់វិញទេ ។ ភិក្ខុនោះក៏បានធ្វើចីវរនោះឲ្យស្រេច ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ព្រោះចីវរស្រេចជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយចៀសចេញទៅព្រោះចង់បានចីវរ ។ ភិក្ខុនោះទៅដល់ក្រៅសីមាក៏ចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ ក៏បាន (ចីវរ) ខុសបំណង តែមិនបានតាមបំណង ។ ភិក្ខុនោះមានគំនិតយ៉ាងនេះថា

នេវិមំ ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ តស្ស ភិក្ខុនោ សន្និដ្ឋានន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ ចីវរាសាយ បក្កមតិ ។ សោ ពហិសីមគតោ តំ ចីវរាសំ បយិរុបាសតិ អនាសាយ លភតិ អាសាយ ន លភតិ ។ តស្ស ឯវំ ហោតិ នេវិមំ ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ សោ តំ ចីវរំ ការេតិ ។ តស្ស តំ ចីវរំ កយិរមានំ នស្សតិ ។ តស្ស ភិក្ខុនោ នាសនន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ ចីវរាសាយ បក្កមតិ ។ តស្ស ពហិសីមគតស្ស ឯវំ ហោតិ នេវិមំ ចីវរាសំ បយិរុបាសិស្សំ ន បច្ចេស្សន្តិ ។ សោ តំ ចីវរាសំ បយិរុបាសតិ ។ តស្ស សា ចីវរាសា ឧបច្ឆិជ្ជតិ ។ តស្ស ភិក្ខុនោ អាសាវច្ឆេទិកោ កឋិនុទ្ធារោ ។

[៦០] ភិក្ខុ អត្ថតកឋិនោ ចីវរាសាយ បក្កមតិ ន បច្ចេស្សន្តិ ។ សោ ពហិសីមគតោ តំ ចីវរាសំ បយិរុបាសតិ



អាត្មាអញនឹងមិនធ្វើចីវរនេះទេ អាត្មាអញនឹងមិនត្រឡប់មកវិញទេ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ព្រោះសេចក្ដីសន្និដ្ឋានជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយចៀសចេញទៅព្រោះចង់បានចីវរ ។ លុះភិក្ខុនោះទៅដល់ក្រៅសីមាក៏ចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ ក៏បាន (ចីវរ) ខុសបំណង មិនបានតាមបំណង ។ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះ គង់តែនេះឯង អាត្មាអញនឹងមិនត្រឡប់មកវិញទេ ។ ភិក្ខុនោះក៏បានធ្វើចីវរនោះ ។ កាលភិក្ខុនោះកំពុងធ្វើ ចីវរនោះក៏វិនាសទៅ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ព្រោះចីវរវិនាសជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយចៀសចេញទៅព្រោះចង់បានចីវរ ។ កាលភិក្ខុនោះទៅដល់ក្រៅសីមាក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងចូលទៅកាន់ទីដែលអាត្មាអញចង់បានចីវរនេះ គង់តែនេះឯង អាត្មាអញនឹងមិនត្រឡប់មកវិញទេ ។ ភិក្ខុនោះក៏ចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ ។ ឯសេចក្ដីចង់បានចីវររបស់ភិក្ខុនោះក៏ដាច់ទៅ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ព្រោះអស់សេចក្ដីសង្ឃឹម ។

(៦០) ភិក្ខុបានក្រាលកឋិនរួចហើយចៀសចេញទៅព្រោះចង់បានចីវរ ដោយបំណងថា អាត្មាអញនឹងមិនត្រឡប់មកវិញទេ ។ ភិក្ខុនោះទៅដល់ក្រៅសីមាក៏ចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ

អនាសាយ លភតិ អាសាយ ន លភតិ ។ តស្ស ឯវំ ហោតិ ឥធេវិមំ ចីវរំ ការេស្សាមិ ។ សោ តំ ចីវរំ ការេតិ ។ តស្ស ភិក្ខុនោ និដ្ឋានន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ ចីវរាសាយ បក្កមតិ ន បច្ចេស្សន្តិ ។ សោ ពហិសីមគតោ តំ ចីវរាសំ បយិរុបាសតិ អនាសាយ លភតិ អាសាយ ន លភតិ ។ តស្ស ឯវំ ហោតិ នេវិមំ ចីវរំ ការេស្សាមិ ។ តស្ស ភិក្ខុនោ សន្និដ្ឋានន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ ចីវរាសាយ បក្កមតិ ន បច្ចេស្សន្តិ ។ សោ ពហិសីមគតោ តំ ចីវរាសំ បយិរុបាសតិ អនាសាយ លភតិ អាសាយ ន លភតិ ។ តស្ស ឯវំ ហោតិ ឥធេវិមំ ចីវរំ ការេស្សាមិ ។ សោ តំ ចីវរំ ការេតិ ។ តស្ស តំ ចីវរំ កយិរមានំ នស្សតិ ។ តស្ស ភិក្ខុនោ នាសនន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ ចីវរាសាយ បក្កមតិ ន បច្ចេស្សន្តិ ។ តស្ស ពហិសីមគតស្ស



ក៏បាន (ចីវរ) ខុសបំណង តែមិនបានតាមបំណង ។ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះ ក្នុងទីនេះឯង ។ ភិក្ខុនោះក៏បានធ្វើចីវរនោះឲ្យសម្រេច ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ត្រង់ចីវរសម្រេចជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយចៀសចេញទៅព្រោះចង់បានចីវរ ដោយបំណងថា អាត្មាអញនឹងមិនត្រឡប់វិញទេ ។ ភិក្ខុនោះទៅដល់ក្រៅសីមាហើយចូលទៅកាន់ទីដែលខ្លួនចង់បានចីវរ ក៏បាន (ចីវរ) ខុសបំណង តែមិនបានតាមបំណង ។ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញនឹងមិនធ្វើចីវរនេះទេ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ត្រង់សេចក្តីសន្និដ្ឋានជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយចៀសចេញទៅព្រោះចង់បានចីវរ ដោយបំណងថា អាត្មាអញនឹងមិនត្រឡប់វិញទេ ។ ភិក្ខុនោះទៅដល់ក្រៅសីមាក៏ចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ ក៏បាន (ចីវរ) ខុសបំណង តែមិនបានតាមបំណង ។ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះ ក្នុងទីនេះឯង ។ ភិក្ខុនោះក៏បានធ្វើចីវរនោះ ។ កាលភិក្ខុនោះកំពុងធ្វើ ចីវរនោះក៏វិនាសទៅ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ត្រង់ចីវរវិនាសជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយចៀសចេញទៅព្រោះចង់បានចីវរ ដោយបំណងថា អាត្មាអញនឹងមិនត្រឡប់វិញទេ ។ កាលភិក្ខុនោះទៅដល់ក្រៅសីមា

យំ ហោតិ ឥធេវិមំ ចីវរាសំ បយិរុបាសិស្សន្តិ ។ សោ តំ ចីវរាសំ បយិរុបាសតិ ។ តស្ស សា ចីវរាសា ឧបច្ឆិជ្ជតិ ។ តស្ស ភិក្ខុនោ អាសាវច្ឆេទិកោ កឋិនុទ្ធារោ ។

[៦១] ភិក្ខុ អត្ថតកឋិនោ ចីវរាសាយ បក្កមតិ អនធិដ្ឋិតេន នេវស្ស ហោតិ បច្ចេស្សន្តិ ន បនស្ស ហោតិ ន បច្ចេស្សន្តិ ។ សោ ពហិសីមគតោ តំ ចីវរាសំ បយិរុបាសតិ អនាសាយ លភតិ អាសាយ ន លភតិ ។ តស្ស ឯវំ ហោតិ ឥធេវិមំ ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ សោ តំ ចីវរំ ការេតិ ។ តស្ស ភិក្ខុនោ និដ្ឋានន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ ចីវរាសាយ បក្កមតិ អនធិដ្ឋិតេន នេវស្ស ហោតិ បច្ចេស្សន្តិ ន បនស្ស ហោតិ ន បច្ចេស្សន្តិ ។ សោ ពហិសីមគតោ តំ ចីវរាសំ បយិរុបាសតិ អនាសាយ លភតិ អាសាយ ន លភតិ ។ តស្ស



កើតមានគំនិតយ៉ាងនេះថា អាត្មាអញនឹងចូលទៅកាន់ទីដែលអាត្មាអញចង់បានចីវរនេះ គង់ទីនេះឯង ។ ភិក្ខុនោះក៏ចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ ។ ឯសេចក្តីចង់បានចីវររបស់ភិក្ខុនោះក៏ដាច់ទៅ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ព្រោះអស់សេចក្តីសង្ឃឹម ។

[៦១] ភិក្ខុបាន(ក្រាលកឋិនរួចហើយ)ចៀសចេញទៅព្រោះចង់បានចីវរដោយមិនបានតាំងចិត្ត គឺភិក្ខុនោះគ្មានគំនិតថា អាត្មាអញនឹងត្រឡប់វិញ តាំងគំនិតរបស់ភិក្ខុនោះថា អាត្មាអញនឹងមិនត្រឡប់វិញក៏គ្មានដែរ ។ ភិក្ខុនោះទៅដល់ក្រៅសីមា ក៏ចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ ក៏បាន ( ចីវរ ) ខុសបំណង ក៏មិនបានតាមបំណង ។ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះ គង់ទីនេះឯង អាត្មាអញនឹងមិនត្រឡប់វិញទេ ។ ភិក្ខុនោះក៏ធ្វើចីវរនោះឲ្យសម្រេច ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ព្រោះចីវរសម្រេចជាកំណត់ ។ ភិក្ខុបាន(ក្រាលកឋិនរួចហើយ)ចៀសចេញទៅព្រោះចង់បានចីវរ ដោយមិនបានតាំងចិត្ត គឺភិក្ខុនោះគ្មានគំនិតថា អាត្មាអញនឹងត្រឡប់វិញ តាំងគំនិតរបស់ភិក្ខុនោះថា អាត្មាអញនឹងមិនត្រឡប់វិញ ក៏គ្មានដែរ ។ ភិក្ខុនោះទៅដល់ក្រៅសីមា ក៏ចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ ក៏បាន(ចីវរ)ខុសបំណង ក៏មិនបានតាមបំណង ។ ភិក្ខុនោះមានគំនិតយ៉ាងនេះថា

ឯវំ ហោតិ នេវិមំ ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ តស្ស ភិក្ខុនោ សន្និដ្ឋានន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតក-ឋិនោ ចីវរាសាយ បក្កមតិ អនធិដ្ឋិតេន នេវស្ស ហោតិ បច្ចេស្សន្តិ ន បនស្ស ហោតិ ន បច្ចេស្សន្តិ ។ សោ ពហិ-សីមគតោ តំ ចីវរាសំ បយិរុបាសតិ អនាសាយ លភតិ អាសាយ ន លភតិ ។ តស្ស ឯវំ ហោតិ ឥធេវិមំ ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ សោ តំ ចីវរំ ការេតិ ។ តស្ស តំ ចីវរំ កយិរមានំ នស្សតិ ។ តស្ស ភិក្ខុនោ នាស-នន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ ចីវរាសាយ បក្កមតិ អនធិដ្ឋិតេន នេវស្ស ហោតិ បច្ចេស្សន្តិ ន បនស្ស ហោតិ ន បច្ចេស្សន្តិ ។ តស្ស ពហិសីមគ-តស្ស ឯវំ ហោតិ ឥធេវិមំ ចីវរាសំ បយិរុបាសិស្សំ ន



អាត្មាអញនឹងមិនធ្វើចីវរនេះទេ អាត្មាអញនឹងមិនត្រឡប់មកវិញទេ ។ កឋិន របស់ភិក្ខុនោះឈ្មោះថាដោះ ត្រឹមសេចក្ដីសន្និដ្ឋានជាដាច់ណាត់ ។ ភិក្ខុបាន ក្រាលកឋិនរួចហើយ ចេញទៅព្រោះសង្ឃឹមបានចីវរ ដោយមិនបាន តាំងចិត្ត តែភិក្ខុនោះគ្មានគំនិតថា អាត្មាអញនឹងត្រឡប់មកវិញ តាំងគំនិតរបស់ ភិក្ខុនោះថា អាត្មាអញនឹងមិនត្រឡប់មកវិញ ក៏គ្មានដែរ ។ ភិក្ខុនោះទៅដល់ ក្រៅសីមា ក៏ចូលទៅកាន់ទីដែលខ្លួនសង្ឃឹមបានចីវរនោះ ក៏បាន (ចីវរ) ខុស បំណង មិនបានតាមបំណង ។ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មា អញនឹងធ្វើចីវរនេះ ក្នុងទីនេះឯង អាត្មាអញនឹងមិនត្រឡប់មកវិញទេ ។ ភិក្ខុ នោះក៏បានធ្វើចីវរនោះ ។ កាលភិក្ខុនោះកំពុងធ្វើ ចីវរនោះក៏វិនាសទៅ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ត្រឹមចីវរវិនាសជាដាច់ណាត់ ។ ភិក្ខុបាន ក្រាលកឋិនរួចហើយ ចេញទៅព្រោះសង្ឃឹមបានចីវរ ដោយមិនបាន តាំងចិត្ត តែភិក្ខុនោះគ្មានគំនិតថា អាត្មាអញនឹងត្រឡប់មកវិញ តាំងគំនិត របស់ភិក្ខុនោះថា អាត្មាអញនឹងមិនត្រឡប់មកវិញ ក៏គ្មានដែរ ។ កាលភិក្ខុ នោះទៅដល់ក្រៅសីមា ក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងចូលទៅ កាន់ទីដែលអាត្មាអញសង្ឃឹមបានចីវរនេះ ក្នុងទីនេះឯង អាត្មាអញនឹងមិន

បច្ចេស្សន្តិ ។ សោ តំ ចីវរាសំ បយិរុបាសតិ ។ តស្ស សា ចីវរាសា ឧបច្ឆិជ្ជតិ ។ តស្ស ភិក្ខុនោ អាសាវច្ឆេទិកោ កឋិនុទ្ធារោ ។

អនាសាទោឡសកំ និដ្ឋិតំ ។

[៦៦] ភិក្ខុ អត្ថតកឋិនោ ចីវរាសាយ បក្កមតិ បច្ចេស្សន្តិ ។ សោ តហិំ សីមគតោ តំ ចីវរាសំ បយិរុបាសតិ អនាសាយ លភតិ អាសាយ ន លភតិ ។ តស្ស ឯវំ ហោតិ ឥធេវិមំ ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ សោ តំ ចីវរំ ការេតិ ។ តស្ស ភិក្ខុនោ និដ្ឋានន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ ចីវរាសាយ បក្កមតិ បច្ចេស្សន្តិ ។ សោ តហិំ សីមគតោ តំ ចីវរាសំ បយិរុបាសតិ អនាសាយ លភតិ អាសាយ ន លភតិ ។ តស្ស ឯវំ ហោតិ នេវិមំ ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ តស្ស ភិក្ខុនោ សន្និដ្ឋានន្តិកោ កឋិនុទ្ធារោ ។





ត្រឡប់វិញទេ ។ ភិក្ខុនោះចូលទៅកាន់ទីដែលខ្លួនប៉ងបានចីវរនោះ ។ ឯសេចក្តីប៉ងបានចីវរនោះរបស់ភិក្ខុនោះក៏ដាច់ទៅ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ (ព្រោះអស់សេចក្តីសង្ឃឹម) ។

ចប់ (អនាសាទ្វាទសកៈ) វុលបំណង ១២ ប្រការ ។

[៦៦] ភិក្ខុបាន (ក្រាលកឋិនរួចហើយទៀត) ចេញទៅ (ព្រោះប៉ងបាន) ចីវរដោយបំណងថា អាត្មាអញនឹង (ត្រឡប់) វិញ ។ ភិក្ខុនោះទៅដល់ក្រៅសីមា ចូលទៅកាន់ទីដែលខ្លួនប៉ងបានចីវរនោះ ក៏បាន (ចីវរ) ក្រៅអំពីបំណង តែមិនបានតាមបំណង ។ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញនឹងមិន (ត្រឡប់) វិញទេ ។ ភិក្ខុនោះក៏ធ្វើចីវរនោះឲ្យសម្រេច ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ (ព្រោះធ្វើចីវរសម្រេច) ជាកំណត់ ។ ភិក្ខុបាន (ក្រាលកឋិនរួចហើយទៀត) ចេញទៅ (ព្រោះប៉ងបាន) ចីវរដោយបំណងថា អាត្មាអញនឹង (ត្រឡប់) វិញ ។ ភិក្ខុនោះទៅដល់ក្រៅសីមាហើយ ចូលទៅកាន់ទីដែលខ្លួនប៉ងបានចីវរ ក៏បាន (ចីវរ) ក្រៅអំពីបំណង តែមិនបានតាមបំណង ។ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញនឹងមិនធ្វើចីវរនេះទេ អាត្មាអញនឹងមិន (ត្រឡប់) វិញទេ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ (ព្រោះសេចក្តីសន្និដ្ឋាន) ជាកំណត់ ។

ភិក្ខុ អត្ថតកឋិនោ ចីវរាសាយ បក្កមតិ បច្ចេស្សន្តិ ។ សោ ពហិសីមគតោ តំ ចីវរាសំ បយិរុបាសតិ អនាសាយ លភតិ អាសាយ ន លភតិ ។ តស្ស ឯវំ ហោតិ ឥធេវិមំ ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ សោ តំ ចីវរំ ការេតិ ។ តស្ស តំ ចីវរំ ករិយមានំ នស្សតិ ។ តស្ស ភិក្ខុនោ នាសនន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ ចីវរាសាយ បក្កមតិ បច្ចេស្សន្តិ ។ តស្ស ពហិសីមគតស្ស ឯវំ ហោតិ ឥធេវិមំ ចីវរាសំ បយិរុបាសិស្សំ ន បច្ចេស្សន្តិ ។ សោ តំ ចីវរាសំ បយិរុបាសតិ ។ តស្ស សា ចីវរាសា ឧបច្ឆិជ្ជតិ ។ តស្ស ភិក្ខុនោ អាសាវច្ឆេទិកោ កឋិនុទ្ធារោ ។

(៦៣) ភិក្ខុ អត្ថតកឋិនោ ចីវរាសាយ បក្កមតិ បច្ចេស្សន្តិ ។ សោ ពហិសីមគតោ សុណាតិ ឧព្ភតំ កិរ តស្មឹ អាវាសេ កឋិនន្តិ ។ តស្ស ឯវំ ហោតិ យតោ តស្មឹ អាវាសេ ឧព្ភតំ កឋិនំ ឥធេវិមំ ចីវរាសំ



ភិក្ខុបានក្រាលកឋិនរួចហើយ ចៀសចេញទៅ ព្រោះបង់បានចីវរដោយចំណង់ថា អាត្មាអញនឹងត្រឡប់វិញ ។ ភិក្ខុនោះទៅដល់ក្រៅសីមាហើយ ចូលទៅកាន់ទីដែលខ្លួនបង់បានចីវរនោះ ក៏បាន (ចីវរ) ក្រៅតាមបំណង គឺមិនបានតាមបំណង ។ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញនឹងមិនត្រឡប់វិញទេ ។ ភិក្ខុនោះក៏បានធ្វើចីវរនោះ ។ កាលភិក្ខុនោះកំពុងធ្វើ ចីវរនោះក៏វិនាសទៅ ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ព្រោះចីវរវិនាសជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយ ចៀសចេញទៅ ព្រោះបង់បានចីវរដោយចំណង់ថា អាត្មាអញនឹងត្រឡប់វិញ ។ ភិក្ខុនោះទៅដល់ក្រៅសីមាហើយមានគំនិតយ៉ាងនេះថា អាត្មាអញនឹងចូលទៅកាន់ទីដែលអាត្មាអញបង់បានចីវរនេះក្នុងទីនេះឯង អាត្មាអញនឹងមិនត្រឡប់វិញទេ ។ ភិក្ខុនោះចូលទៅកាន់ទីដែលខ្លួនបង់បានចីវរនោះ ។ ឯសេចក្ដីបង់បានចីវរនោះរបស់ភិក្ខុនោះក៏ដាច់ទៅ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ព្រោះអស់សេចក្ដីសង្ឃឹម ។

(៦៣) ភិក្ខុបានក្រាលកឋិនរួចហើយ ចៀសចេញទៅ ព្រោះបង់បានចីវរដោយបំណងថា អាត្មាអញនឹងត្រឡប់វិញ ។ ភិក្ខុនោះទៅដល់ក្រៅសីមា ក៏ឮដំណឹងថា កឋិនក្នុងអាវាសនោះសង្ឃព្រមគ្នាដកហើយ ។ ភិក្ខុនោះមានគំនិតយ៉ាងនេះថា កឋិនក្នុងអាវាសនោះកាលណា បើសង្ឃ

បយិរុបាសិស្សន្តិ ។ សោ តំ ចីវរាសំ បយិរុបាសតិ អាសាយ លភតិ អនាសាយ ន លភតិ ។ តស្ស ឯវំ ហោតិ ឥធេវិមំ ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ សោ តំ ចីវរំ ការេតិ ។ តស្ស ភិក្ខុនោ និដ្ឋានន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ ចីវរាសាយ បក្កមតិ បច្ចេស្សន្តិ ។ សោ ពហិសីមគតោ សុណាតិ ឧព្ភតំ កិរ តស្មឹ អាវាសេ កឋិនន្តិ ។ តស្ស ឯវំ ហោតិ យតោ តស្មឹ អាវាសេ ឧព្ភតំ កឋិនំ ឥធេវ ចីវរាសំ បយិរុបាសិស្សន្តិ ។ សោ តំ ចីវរាសំ បយិរុបាសតិ អាសាយ លភតិ អនាសាយ ន លភតិ ។ តស្ស ឯវំ ហោតិ នេវិមំ ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ តស្ស ភិក្ខុនោ សន្និដ្ឋានន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ ចីវរាសាយ បក្កមតិ បច្ចេស្សន្តិ ។ សោ ពហិសីមគតោ សុណាតិ ឧព្ភតំ កិរ តស្មឹ អាវាសេ



ព្រមដកហើយ អាត្មាអញនឹងចូលទៅកាន់ទីដែលអាត្មាអញចង់បានចីវរនេះក្នុងទីនេះឯង ។ ភិក្ខុនោះចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ ក៏បាន (ចីវរ) ត្រូវតាមបំណង នឹងមិនបានខុសបំណង ។ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញនឹងមិនត្រឡប់វិញទេ ។ ភិក្ខុនោះក៏បានធ្វើចីវរនោះឲ្យសម្រេច ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ត្រង់ចីវរសម្រេចជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយ ទៀសចេញទៅ ព្រោះចង់បានចីវរដោយបំណងថា អាត្មាអញនឹងត្រឡប់វិញ ។ ភិក្ខុនោះទៅដល់ក្រៅសីមា ក៏ឮដំណឹងថា កឋិនក្នុងអាវាសនោះសង្ឃព្រមដកហើយ ។ ភិក្ខុនោះមានគំនិតយ៉ាងនេះថា កឋិនក្នុងអាវាសនោះ កាលណាបើសង្ឃព្រមដកហើយ អាត្មាអញនឹងចូលទៅកាន់ទីដែលអាត្មាអញ ចង់បានចីវរនេះក្នុងទីនេះឯង ។ ភិក្ខុនោះចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ ក៏បាន (ចីវរ) ត្រូវតាមបំណងនឹងមិនបានខុសបំណង ។ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញនឹងមិនធ្វើចីវរនេះ អាត្មាអញនឹងមិនត្រឡប់វិញទេ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ត្រង់សេចក្តីសន្និដ្ឋានជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយ ទៀសចេញទៅ ព្រោះចង់បានចីវរដោយបំណងថា អាត្មាអញនឹងត្រឡប់វិញ ។ ភិក្ខុនោះទៅដល់ក្រៅសីមា ក៏ឮដំណឹងថា កឋិនក្នុងអាវាសនោះ

កឋិនន្តិ ។ តស្ស ឯវំ ហោតិ យតោ តស្មឹ អាវាសេ ឧព្ភតំ កឋិនំ ឥធេវិមំ ចីវរាសំ បយិរុបាសិស្សន្តិ ។ សោ តំ ចីវរាសំ បយិរុបាសតិ អាសាយ លភតិ អនាសាយ ន លភតិ ។ តស្ស ឯវំ ហោតិ ឥធេវិមំ ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ សោ តំ ចីវរំ ការេតិ ។ តស្ស តំ ចីវរំ កយិរមានំ នស្សតិ ។ តស្ស ភិក្ខុនោ នាសនន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ ចីវរាសាយ បក្កមតិ បច្ចេស្សន្តិ ។ សោ ពហិសីមគតោ សុណាតិ ឧព្ភតំ កិរ តស្មឹ អាវាសេ កឋិនន្តិ ។ តស្ស ឯវំ ហោតិ យតោ តស្មឹ អាវាសេ ឧព្ភតំ កឋិនំ ឥធេវិមំ ចីវរាសំ បយិរុបាសិស្សំ ន បច្ចេស្សន្តិ ។ សោ តំ ចីវរាសំ បយិរុបាសតិ ។ តស្ស សា ចីវរាសា ឧបច្ឆិជ្ជតិ ។ តស្ស ភិក្ខុនោ អាសាវច្ឆេទិកោ កឋិនុទ្ធារោ ។



សង្ឃព្រមគ្នាដកហើយ ។ ភិក្ខុនោះមានគំនិតយ៉ាងនេះថា កឋិនក្នុងអាវាសនោះកាលណាបើសង្ឃព្រមគ្នាដកហើយ អាត្មាអញនឹងចូលទៅកាន់ទីដែលអាត្មាអញចង់បានចីវរនេះក្នុងទីនេះឯង ។ ភិក្ខុនោះចូលទៅកាន់ទីដែលខ្លួនចង់បានចីវរ ក៏បាន (ចីវរ) ត្រង់ការមិនបំណង គឺមិនបានត្រង់បំណង ។ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញនឹងមិនត្រឡប់ទៅវិញទេ ។ ភិក្ខុនោះក៏ធ្វើចីវរនោះ ។ កាលភិក្ខុនោះកំពុងធ្វើ ចីវរក៏វិនាសទៅ ។ កឋិនរបស់ភិក្ខុនោះឈ្មោះនាសនៈ ត្រូវចីវរវិនាសជាកំណត់ ។ ភិក្ខុបាន (ក្រាលកឋិនរួចហើយ) ចេញទៅព្រោះចង់បានចីវរដោយបំណងថា អាត្មាអញនឹងត្រឡប់វិញ ។ ភិក្ខុនោះទៅដល់ក្រៅសីមាក៏ឮដំណឹងថា កឋិនក្នុងអាវាសនោះ សង្ឃព្រមគ្នាដកហើយ ។ ភិក្ខុនោះមានគំនិតយ៉ាងនេះថា កឋិនក្នុងអាវាសនោះ កាលណា បើសង្ឃព្រមគ្នាដកហើយ អាត្មាអញនឹងចូលទៅកាន់ទីដែលអាត្មាអញចង់បានចីវរនេះក្នុងទីនេះឯង អាត្មាអញនឹងមិនត្រឡប់វិញទេ ។ ភិក្ខុនោះចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ ។ ឯសេចក្តីចង់បានចីវរនោះរបស់ភិក្ខុនោះក៏ដាច់ទៅ ។ កឋិនរបស់ភិក្ខុនោះឈ្មោះអាសាវច្ឆេទិកៈ ត្រូវអស់សេចក្តីសង្ឃឹម ។

(៦៤) ភិក្ខុ អត្ថតកឋិនោ ចីវរាសាយ បក្កមតិ បច្ចេស្សន្តិ ។ សោ ពហិសីមគតោ តំ ចីវរាសំ បយិរុបាសតិ អាសាយ លភតិ អនាសាយ ន លភតិ ។ សោ តំ ចីវរំ ករោតិ ។ សោ កតចីវរោ សុណាតិ ឧព្ភតំ កិរ តស្មឹ អាវាសេ កឋិនន្តិ ។ តស្ស ភិក្ខុនោ សវនន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ ចីវរាសាយ បក្កមតិ បច្ចេស្សន្តិ ។ តស្ស ពហិសីមគតស្ស ឯវំ ហោតិ ឥធេវិមំ ចីវរាសំ បយិរុបាសិស្សំ ន បច្ចេស្សន្តិ ។ សោ តំ ចីវរាសំ បយិរុបាសតិ ។ តស្ស សា ចីវរាសា ឧបច្ឆិជ្ជតិ ។ តស្ស ភិក្ខុនោ អាសាវច្ឆេទិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ ចីវរាសាយ បក្កមតិ បច្ចេស្សន្តិ ។ សោ ពហិសីមគតោ តំ ចីវរាសំ បយិរុបាសតិ អាសាយ លភតិ អនាសាយ ន លភតិ ។ សោ តំ ចីវរំ ករោតិ ។ សោ កតចីវរោ



(៦៤) ភិក្ខុបានក្រាលកឋិនរួចហើយចៀសចេញទៅ ព្រោះចង់បានចីវរ ដោយប៉ុនប៉ងថា អាត្មាអញនឹងត្រឡប់វិញ ។ ភិក្ខុនោះទៅដល់ក្រៅសីមា ក៏ចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ ក៏បាន (ចីវរ) ត្រូវតាមបំណង ឥតមិនបានខុសបំណង ។ ភិក្ខុនោះក៏បានធ្វើចីវរនោះ ។ លុះភិក្ខុនោះធ្វើចីវររួចហើយ ក៏ឮដំណឹងថា កឋិនក្នុងអាវាសនោះ សង្ឃព្រមគ្នាដកហើយ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ត្រង់ឮដំណឹងជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយចៀសចេញទៅ ព្រោះចង់បានចីវរដោយប៉ុនប៉ងថា អាត្មាអញនឹងត្រឡប់វិញ ។ ភិក្ខុនោះទៅដល់ក្រៅសីមាក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងចូលទៅកាន់ទីដែលអាត្មាអញចង់បានចីវរនេះ ក្នុងទីនេះឯង អាត្មាអញនឹងមិនត្រឡប់វិញទេ ។ ភិក្ខុនោះចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ ។ សេចក្ដីចង់បានចីវររបស់ភិក្ខុនោះក៏ដាច់ទៅ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ត្រង់អស់សេចក្ដីសង្ឃឹម ។ ភិក្ខុបានក្រាលកឋិនរួចហើយចៀសចេញទៅ ព្រោះចង់បានចីវរ ដោយប៉ុនប៉ងថា អាត្មាអញនឹងមិនត្រឡប់វិញទេ ។ ភិក្ខុនោះទៅដល់ក្រៅសីមា ក៏ចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ ក៏បាន(ចីវរ)ត្រូវតាមបំណងឥតមិនបានខុសបំណង ។ ភិក្ខុនោះក៏បានធ្វើចីវរនោះ ។ ភិក្ខុនោះធ្វើចីវររួចហើយ

បច្ចេស្សំ បច្ចេស្សន្តិ ពហិទ្ធា កឋិនុទ្ធារំ វីតិនាមេតិ ។ តស្ស ភិក្ខុនោ សីមាតិក្កន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ ចីវរាសាយ បក្កមតិ បច្ចេស្សន្តិ ។ សោ ពហិសីមគតោ តំ ចីវរាសំ បយិរុបាសតិ អាសាយ លភតិ អនាសាយ ន លភតិ ។ សោ តំ ចីវរំ ការេតិ ។ សោ កតចីវរោ បច្ចេស្សំ បច្ចេស្សន្តិ សម្ភុណាតិ កឋិនុទ្ធារំ ។ តស្ស ភិក្ខុនោ សហ ភិក្ខូហិ កឋិនុទ្ធារោ ។

អាសាទោឡសកំ និដ្ឋិតំ ។

[២៥] ភិក្ខុ អត្ថតកឋិនោ កេនចិទេវ ករណីយេន បក្កមតិ ។ តស្ស ពហិសីមគតស្ស ចីវរាសា ឧប្បជ្ជតិ ។ សោ តំ ចីវរាសំ បយិរុបាសតិ អនាសាយ លភតិ អាសាយ ន លភតិ ។ តស្ស ឯវំ ហោតិ ឥធេវិមំ ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ សោ តំ ចីវរំ ការេតិ ។ តស្ស ភិក្ខុនោ និដ្ឋានន្តិកោ កឋិ-



គិតថា អាត្មាអញនឹងត្រឡប់វិញ អាត្មាអញនឹងត្រឡប់វិញដែរ តែមិនទាន់បានត្រឡប់នៅឡើយ) កឋិនក៏ដោះនៅក្រៅ (សីមា) ទៅ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ព្រោះកន្លងខេត្តសីមាជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយបៀសចេញទៅ ព្រោះចង់បានចីវរ ដោយចំណង់ថា អាត្មាអញនឹងត្រឡប់វិញ ។ ភិក្ខុនោះទៅដល់ក្រៅសីមា ក៏ចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ ក៏បាន (ចីវរ) ត្រូវតាមបំណង គឺមិនបានខុសបំណង ។ ភិក្ខុនោះក៏បានធ្វើចីវរនោះ ។ ភិក្ខុនោះធ្វើចីវររួចហើយគិតថា អាត្មាអញនឹងត្រឡប់វិញ អាត្មាអញនឹងត្រឡប់វិញ ហើយក៏មកតាមពេលដោះកឋិនដែរ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ជាមួយនឹងភិក្ខុទាំងឡាយ ។

ចប់ (អាសាចីវរ) ត្រូវជាវិធាន ១៦ ប្រការ ។

[២៥] ភិក្ខុបានក្រាលកឋិនរួចហើយ បៀសចេញទៅដោយមានកិច្ចឯណាមួយ ។ កាលភិក្ខុនោះទៅដល់ក្រៅសីមា សេចក្តីចង់បានចីវរក៏កើតឡើង ។ ភិក្ខុនោះចូលទៅកាន់ទីដែលខ្លួនចង់បានចីវរ ក៏បាន (ចីវរ) ខុសបំណង គឺមិនបានតាមបំណង ។ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញនឹងមិនត្រឡប់វិញទេ ។ ភិក្ខុនោះក៏ធ្វើចីវរនោះឲ្យសម្រេច ។ កឋិនរបស់ភិក្ខុនោះឈ្មោះ

នុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ កេនចិទេវ ករណី-
យេន បក្កមតិ ។ តស្ស ពហិសីមគតស្ស ចីវរាសា
ឧប្បជ្ជតិ ។ សោ តំ ចីវរាសំ បយិរុបាសតិ អនាសាយ
លភតិ អាសាយ ន លភតិ ។ តស្ស ឯវំ ហោតិ
ឥធេវិមំ ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ តស្ស ភិក្ខុនោ
សន្និដ្ឋានន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ
កេនចិទេវ ករណីយេន បក្កមតិ ។ តស្ស ពហិ-
សីមគតស្ស ចីវរាសា ឧប្បជ្ជតិ ។ សោ តំ ចីវរាសំ
បយិរុបាសតិ អនាសាយ លភតិ អាសាយ ន ល-
ភតិ ។ តស្ស ឯវំ ហោតិ ឥធេវិមំ ចីវរំ ការេស្សំ ន
បច្ចេស្សន្តិ ។ សោ តំ ចីវរំ ការេតិ ។ តស្ស តំ
ចីវរំ កយិរមានំ នស្សតិ ។ តស្ស ភិក្ខុនោ នាស-
នន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ កេ-
នចិទេវ ករណីយេន បក្កមតិ ។ តស្ស ពហិសីម-
គតស្ស ចីវរាសា ឧប្បជ្ជតិ ។ តស្ស ឯវំ ហោតិ
ឥធេវិមំ ចីវរាសំ បយិរុបាសិស្សំ ន បច្ចេស្សន្តិ ។



ថា ដោះ ត្រង់ចីវរសម្រេចជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយ
ចៀសចេញទៅដោយមានកិច្ចឯណានីមួយ ។ ភិក្ខុនោះទៅដល់ក្រៅសីមា
សេចក្តីប៉ង់បានចីវរក៏កើតឡើង ។ ភិក្ខុនោះចូលទៅកាន់ទីដែលខ្លួនប៉ង់បាន
ចីវរនោះ ក៏បាន (ចីវរ) ខុសបំណង គឺមិនបានតាមបំណង ។ ភិក្ខុនោះ
មានគំនិតយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះ ។ អាត្មាអញនឹងមិន
ត្រឡប់វិញទេ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ត្រង់សេចក្តី
សន្និដ្ឋានជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយចៀសចេញទៅដោយ
មានកិច្ចឯណានីមួយ ។ ភិក្ខុនោះទៅដល់ក្រៅសីមាហើយ សេចក្តីប៉ង់បាន
ចីវរក៏កើតឡើង ។ ភិក្ខុនោះចូលទៅកាន់ទីដែលខ្លួនប៉ង់បានចីវរនោះ ក៏បាន
(ចីវរ) ខុសបំណង គឺមិនបានត្រូវតាមបំណង ។ ភិក្ខុនោះមានគំនិតយ៉ាង
នេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញនឹងមិនត្រឡប់
វិញទេ ។ ភិក្ខុនោះក៏បានធ្វើចីវរនោះ ។ កាលភិក្ខុនោះកំពុងធ្វើ ចីវរនោះ
ក៏វិនាសទៅ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ត្រង់ចីវរវិនាសជា
កំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយ ចៀសចេញទៅដោយមានកិច្ច
ឯណានីមួយ ។ ភិក្ខុនោះទៅដល់ក្រៅសីមា សេចក្តីប៉ង់បានចីវរក៏កើត
ឡើង ។ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញនឹងចូលទៅកាន់ទីដែល
អាត្មាអញប៉ង់បានចីវរនេះក្នុងទីនេះឯង អាត្មាអញនឹងមិនត្រឡប់វិញទេ ។

សោ តំ ចីវរាសំ បយិរុបាសតិ ។ តស្ស សា ចីវរាសា ឧបច្ឆិជ្ជតិ ។ តស្ស ភិក្ខុនោ អាសាវច្ឆេទិកោ កឋិនុទ្ធារោ ។

[៦៦] ភិក្ខុ អត្ថតកឋិនោ កេនចិទេវ ករណីយេន បក្កមតិ ន បច្ចេស្សន្តិ ។ តស្ស ពហិសីមគតស្ស ចីវរាសា ឧប្បជ្ជតិ ។ សោ តំ ចីវរាសំ បយិរុបាសតិ អនាសាយ លភតិ អាសាយ ន លភតិ ។ តស្ស ឯវំ ហោតិ ឥធេវិមំ ចីវរំ ការេស្សន្តិ ។ សោ តំ ចីវរំ ការេតិ ។ តស្ស ភិក្ខុនោ និដ្ឋានន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ កេនចិទេវ ករណីយេន បក្កមតិ ន បច្ចេស្សន្តិ ។ តស្ស ពហិសីមគតស្ស ចីវរាសា ឧប្បជ្ជតិ ។ សោ តំ ចីវរាសំ បយិរុបាសតិ អនាសាយ លភតិ អាសាយ ន លភតិ ។ តស្ស ឯវំ ហោតិ នេវិមំ ចីវរំ ការេស្សន្តិ ។ តស្ស ភិក្ខុនោ សន្និដ្ឋានន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ កេនចិទេវ ករណីយេន បក្កមតិ



ភិក្ខុនោះចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ ។ ឯសេចក្តីចង់បានចីវរនោះរបស់ភិក្ខុនោះក៏ដាច់ទៅ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ព្រោះអស់សេចក្តីសង្ឃឹម ។

(៦៦) ភិក្ខុបានក្រាលកឋិនរួចហើយ ចៀសចេញទៅដោយមានកិច្ចឯណានីមួយ ដោយបំណងថា អាត្មាអញនឹងមិនត្រឡប់វិញទេ ។ កាលភិក្ខុនោះទៅដល់ក្រៅសីមា សេចក្តីចង់បានចីវរក៏កើតឡើង ។ ភិក្ខុនោះចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ ក៏បាន (ចីវរ) ខុសបំណង គឺមិនបានត្រូវតាមបំណង ។ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង ។ ភិក្ខុនោះក៏បានធ្វើចីវរនោះឲ្យសម្រេច ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ព្រោះចីវរសម្រេចជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយ ចៀសចេញទៅដោយមានកិច្ចឯណានីមួយ ដោយបំណងថា អាត្មាអញនឹងមិនត្រឡប់វិញទេ ។ កាលភិក្ខុនោះទៅដល់ក្រៅសីមា សេចក្តីចង់បានចីវរក៏កើតឡើង ។ ភិក្ខុនោះចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ ក៏បាន (ចីវរ) ខុសបំណង គឺមិនបានត្រូវតាមបំណង ។ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញនឹងមិនធ្វើចីវរនេះទេ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ព្រោះសេចក្តីសន្និដ្ឋានជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយ ចៀសចេញទៅដោយមានកិច្ចឯណានីមួយ

ន បច្ចេស្សន្តិ ។ តស្ស ពហិសីមគតស្ស ចីវរាសា ឧប្បជ្ជតិ ។ សោ តំ ចីវរាសំ បយិរុបាសតិ អនាសាយ លភតិ អាសាយ ន លភតិ ។ តស្ស ឯវំ ហោតិ ឥធេវិមំ ចីវរំ ការេស្សន្តិ ។ សោ តំ ចីវរំ ការេតិ ។ តស្ស តំ ចីវរំ គយិរមានំ នស្សតិ ។ តស្ស ភិក្ខុនោ នាសនន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ កេនចិទេវ ករណីយេន បក្កមតិ ន បច្ចេស្សន្តិ ។ តស្ស ពហិសីមគតស្ស ចីវរាសា ឧប្បជ្ជតិ ។ តស្ស ឯវំ ហោតិ ឥធេវិមំ ចីវរាសំ បយិរុបាសិស្សន្តិ ។ សោ តំ ចីវរាសំ បយិរុបាសតិ ។ តស្ស សា ចីវរាសា ឧបច្ឆិជ្ជតិ ។ តស្ស ភិក្ខុនោ អាសាវច្ឆេទិកោ កឋិនុទ្ធារោ ។

(៦៧) ភិក្ខុ អត្ថតកឋិនោ កេនចិទេវ ករណីយេន បក្កមតិ អនធិដ្ឋិតេន នេវស្ស ហោតិ បច្ចេស្សន្តិ ន



ដោយចំណងថា អាត្មាអញនឹងមិនត្រឡប់វិញទេ ។ កាលភិក្ខុនោះទៅដល់ក្រៅសីមា សេចក្ដីចង់បានចីវរកើតឡើង ។ ភិក្ខុនោះចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ ក៏បាន (ចីវរ) ខុសចំណង់ គឺមិនបានត្រូវតាមចំណង់ ។ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង ។ ភិក្ខុនោះក៏បានធ្វើចីវរនោះ ។ កាលភិក្ខុនោះកំពុងធ្វើ ចីវរក៏វិនាសទៅ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ត្រង់ចីវរវិនាសជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយ ទៀសចេញទៅដោយមានកិច្ចឯណានីមួយ ដោយចំណងថា អាត្មាអញនឹងមិនត្រឡប់វិញទេ ។ កាលភិក្ខុនោះទៅដល់ក្រៅសីមាសេចក្ដីចង់បានចីវរកើតឡើង ។ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញនឹងចូលទៅកាន់ទីដែលអាត្មាអញចង់បានចីវរនេះក្នុងទីនេះឯង ។ ភិក្ខុនោះចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ ។ តែសេចក្ដីចង់បានចីវររបស់ភិក្ខុនោះក៏ដាច់ទៅ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ត្រង់អស់សេចក្ដីសង្ឃឹម ។

(៦៧) ភិក្ខុបានក្រាលកឋិនរួចហើយ ទៀសចេញទៅដោយមានកិច្ចឯណានីមួយ ដោយមិនបានតាំងចិត្ត គឺភិក្ខុនោះគ្មានគំនិតថា អាត្មាអញនឹងត្រឡប់វិញ ទាំងគំនិតរបស់ភិក្ខុនោះថា អាត្មាអញនឹងមិនត្រឡប់វិញ

បនស្ស ហោតិ ន បច្ចេស្សន្តិ ។ តស្ស ពហិសីម-
គតស្ស ចីវរាសា ឧប្បជ្ជតិ ។ សោ តំ ចីវរាសំ បយិរុបា-
សតិ អនាសាយ លភតិ អាសាយ ន លភតិ ។ តស្ស
ឯវំ ហោតិ ឥធេវិមំ ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ សោ
តំ ចីវរំ ការេតិ ។ តស្ស ភិក្ខុនោ និដ្ឋានន្តិកោ កឋិ-
នុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ កេនចិទេវ ករណីយេន
បក្កមតិ អនធិដ្ឋិតេន នេវស្ស ហោតិ បច្ចេស្សន្តិ ន
បនស្ស ហោតិ ន បច្ចេស្សន្តិ ។ តស្ស ពហិសីមគតស្ស
ចីវរាសា ឧប្បជ្ជតិ ។ សោ តំ ចីវរាសំ បយិរុបាសតិ
អនាសាយ លភតិ អាសាយ ន លភតិ ។ តស្ស
ឯវំ ហោតិ នេវិមំ ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។
តស្ស ភិក្ខុនោ សន្និដ្ឋានន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ
អត្ថតកឋិនោ កេនចិទេវ ករណីយេន បក្កមតិ អន-
ធិដ្ឋិតេន នេវស្ស ហោតិ បច្ចេស្សន្តិ ន បនស្ស ហោតិ
ន បច្ចេស្សន្តិ ។ តស្ស ពហិសីមគតស្ស ចីវរាសា



ក៏គ្មានដែរ ។ កាលភិក្ខុនោះទៅដល់ក្រៅសីមា សេចក្តីប៉ងនឹងបានចីវរ
ក៏កើតឡើង ។ ភិក្ខុនោះចូលទៅកាន់ទីដែលខ្លួនប៉ងនឹងបានចីវរនោះ ក៏បាន
(ចីវរ) ខុសបំណង គឺមិនបានត្រូវតាមបំណង ។ ភិក្ខុនោះមានគំនិតយ៉ាងនេះ
ថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញនឹងមិនត្រឡប់វិញទេ ។
ភិក្ខុនោះក៏បានធ្វើចីវរនោះឲ្យសម្រេច ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ
ត្រង់ចីវរសម្រេចជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយ ចៀសចេញ
ទៅដោយមានកិច្ចករណីយៈមួយ ដោយមិនបានតាំងចិត្ត គឺភិក្ខុនោះគ្មាន
គំនិតថា អាត្មាអញនឹងត្រឡប់វិញ ទាំងគំនិតរបស់ភិក្ខុនោះថា អាត្មាអញ
នឹងមិនត្រឡប់វិញ ក៏គ្មានដែរ ។ កាលភិក្ខុនោះទៅដល់ក្រៅសីមា
សេចក្តីប៉ងនឹងបានចីវរក៏កើតឡើង ។ ភិក្ខុនោះចូលទៅកាន់ទីដែលខ្លួនប៉ងនឹង
បានចីវរនោះ ក៏បាន (ចីវរ) ខុសបំណង គឺមិនបានត្រូវតាមបំណង ។
ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញនឹងមិនធ្វើចីវរនេះទេ អាត្មាអញ
នឹងមិនត្រឡប់វិញទេ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ត្រង់សេចក្តី
សន្និដ្ឋានជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយ ចៀសចេញទៅដោយ
មានកិច្ចករណីយៈមួយ ដោយមិនបានតាំងចិត្ត គឺភិក្ខុនោះគ្មានគំនិតថា
អាត្មាអញនឹងត្រឡប់វិញ ទាំងគំនិតរបស់ភិក្ខុនោះថា អាត្មាអញនឹងមិន
ត្រឡប់វិញ ក៏គ្មានដែរ ។ ភិក្ខុនោះទៅដល់ក្រៅសីមា សេចក្តីប៉ងនឹងបានចីវរ

ឧប្បជ្ជតិ ។ សោ តំ ចីវរាសំ បយិរុបាសតិ អនាសាយ លភតិ អាសាយ ន លភតិ ។ តស្ស ឯវំ ហោតិ ឥធេវិមំ ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ សោ តំ ចីវរំ ការេតិ ។ តស្ស តំ ចីវរំ កយិរមានំ នស្សតិ ។ តស្ស ភិក្ខុនោ នាសនន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ កេនចិទេវ ករណីយេន បក្កមតិ អនធិដ្ឋិតេន នេវស្ស ហោតិ បច្ចេស្សន្តិ ន បនស្ស ហោតិ ន បច្ចេស្សន្តិ ។ តស្ស ពហិសីមគតស្ស ចីវរាសា ឧប្បជ្ជតិ ។ តស្ស ឯវំ ហោតិ ឥធេវិមំ ចីវរាសំ បយិរុបាសិស្សំ ន បច្ចេស្សន្តិ ។ សោ តំ ចីវរាសំ បយិរុបាសតិ ។ តស្ស សា ចីវរាសា ឧបច្ឆិជ្ជតិ ។ តស្ស ភិក្ខុនោ អាសាវច្ឆេទិកោ កឋិនុទ្ធារោ ។

ករណីយទោឡសកំ និដ្ឋិតំ ។



ក៏កើតឡើង ។ កាលភិក្ខុនោះចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ ក៏បាន(ចីវរ)ខុសបំណង គឺមិនបានតាមបំណង ។ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញនឹងមិនត្រឡប់វិញទេ ។ ភិក្ខុនោះក៏ធ្វើចីវរនោះ ។ កាលភិក្ខុនោះកំពុងធ្វើ ចីវរក៏វិនាសទៅ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ [ត្រង់ចីវរវិនាសជាកំណត់ ។ ភិក្ខុបាន [ក្រាលកឋិនហើយចៀសចេញទៅ ដោយមានកិច្ចណាមួយ ដោយមិនបានតាំងចិត្ត គឺភិក្ខុនោះគ្មានគំនិតថា អាត្មាអញនឹងត្រឡប់វិញ តាំងគំនិតរបស់ភិក្ខុនោះថា អាត្មាអញនឹងមិនត្រឡប់វិញ ក៏គ្មានដែរ ។ កាលភិក្ខុនោះទៅដល់ក្រៅសីមា សេចក្ដីចង់បានចីវរក៏កើតឡើង ។ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញនឹងចូលទៅកាន់ទីដែលអាត្មាអញចង់បានចីវរនេះក្នុងទីនេះឯង អាត្មាអញនឹងមិនត្រឡប់វិញទេ ។ ភិក្ខុនោះចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ ។ ឯសេចក្ដីចង់បានចីវររបស់ភិក្ខុនោះក៏ដាច់ទៅ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ [ត្រង់អស់សេចក្ដីសង្ឃឹម ។

ចប់ ករណីយវត្ថុ ១២ ប្រការ ។

(៦៨) ភិក្ខុ អត្ថតកឋិនោ ទិសង្គមិកោ បក្កមតិ ចីវរប្បដិវិសំ អបវិណាយមានោ[១] តមេនំ ទិសង្គតំ ភិក្ខូ បុច្ឆន្តិ កហំ ត្វំ អាវុសោ វស្សំវុត្ថោ កត្ថ ច តេ ចីវរប្បដិវិសោតិ ។ សោ ឯវំ វទេតិ អមុកស្មឹ អាវាសេ វស្សំវុត្ថោម្ហិ តត្ថ ច មេ ចីវរប្បដិវិសោតិ ។ តេ ឯវំ វទន្តិ គច្ឆាវុសោ តំ ចីវរំ អាហរ មយន្តេ ឥធ ចីវរំ ករិស្សាមាតិ ។ សោ តំ អាវាសំ គន្ត្វា ភិក្ខូ បុច្ឆតិ កហំ មេ អាវុសោ ចីវរប្បដិវិសោតិ ។ តេ ឯវំ វទន្តិ អយន្តេ អាវុសោ ចីវរប្បដិវិសោ កហំ គមិស្សសីតិ ។ សោ ឯវំ វទេតិ អមុកំ នាម អាវាសំ គមិស្សាមិ តត្ថ មេ ភិក្ខូ ចីវរំ ករិស្សន្តីតិ ។ តេ ឯវំ វទន្តិ អលំ អាវុសោ មា អគមាសិ មយន្តេ ឥធ ចីវរំ ករិស្សាមាតិ ។ តស្ស ឯវំ ហោតិ នេវិមំ ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ សោ តំ ចីវរំ ការេតិ ។ តស្ស ភិក្ខុនោ

១ ម. អបវិលាយមានោ ។



(៦៨) ភិក្ខុបានក្រាលកឋិនរួចហើយ មានដំណើរទៅកាន់ទិសតំបៀស ចេញទៅ តែមានសេចក្តីរួលរ៉ាយនឹងចំណែកនៃចីវរ (របស់ខ្លួន) ភិក្ខុទាំងឡាយសួរភិក្ខុដែលទៅកាន់ទិសនោះថា ម្នាលលោកដ៏មានអាយុ លោកនៅចាំវស្សាក្នុងអាវាសណា ម្យ៉ាងទៀត ចំណែកចីវររបស់លោក(មាននៅ)ក្នុងអាវាសណា ។ ភិក្ខុនោះពោលតបយ៉ាងនេះថា ខ្ញុំនៅចាំវស្សាក្នុងអាវាសឯណោះ ឯចំណែកចីវររបស់ខ្ញុំ (ក៏មាននៅ) ក្នុងអាវាសនោះដែរ ។ ហើយភិក្ខុទាំងនោះពោលយ៉ាងនេះថា ម្នាលលោកដ៏មានអាយុ ចូរលោកទៅយកចីវរនោះមក យើងទាំងឡាយនឹងធ្វើចីវរឲ្យលោកក្នុងទីនេះ ។ លុះភិក្ខុនោះទៅកាន់អាវាសនោះហើយ ក៏សួរភិក្ខុទាំងឡាយថា នែលោកដ៏មានអាយុទាំងឡាយ ចំណែកចីវររបស់ខ្ញុំក្នុងទីណា ។ ភិក្ខុទាំងនោះពោលតបយ៉ាងនេះថា ម្នាលលោកដ៏មានអាយុ ចីវរនេះជាចំណែករបស់លោកហើយ តើលោកនឹងទៅក្នុងទីឯណា ។ ភិក្ខុនោះឆ្លើយយ៉ាងនេះថា ខ្ញុំនឹងទៅកាន់អាវាសឯណោះ ព្រោះពួកភិក្ខុក្នុងអាវាសនោះប្រុងនឹងធ្វើចីវរឲ្យខ្ញុំ ។ ភិក្ខុទាំងនោះនិយាយយ៉ាងនេះថា ល្ហើយលោកដ៏មានអាយុ លោកកុំទៅឡើយ យើងទាំងឡាយនឹងធ្វើចីវរឲ្យលោកក្នុងទីនេះ ។ ឯភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញនឹងមិនត្រឡប់វិញទេ ។ ភិក្ខុនោះក៏បានធ្វើចីវរនោះឲ្យសម្រេច ។ កឋិនរបស់ភិក្ខុនោះ

ចិដ្ឋានដ្ឋិកោ កាបិទុក្ខាកេ ។ ភិក្ខុ អត្តតកាបិតោ
និសន្តិមកោ បញ្ញមតិ ។ បេ ។ តស្ស ភិក្ខុនោ សដ្ឋ-
ដ្ឋានដ្ឋិកោ កាបិទុក្ខាកេ ។ ភិក្ខុ អត្តតកាបិតោ និសន្ត
មិកោ បញ្ញមតិ ។ បេ ។ តស្ស ភិក្ខុនោ ជាសនដ្ឋិកោ
កាបិទុក្ខាកេ ។

(៦៤) ភិក្ខុ អត្តតកាបិតោ និសន្តមិកោ បញ្ញមតិ
ចិរប្បដិវិសំ អចវិលាយមានោ ។ តមេនំ និសន្តំ ភិក្ខុ
បុច្ឆន្តិ កាយាំ ត្វំ អាវុសោ វស្សំ វុត្ថោ កត្ថ ច តេ
ចិរប្បដិវិសោតិ ។ សោ ឯវំ វទេតិ អមុកស្មិំ អាវាសេ
វស្សំ វុត្ថោម្ហិ តត្ថ ច មេ ចិរប្បដិវិសោតិ ។ តេ ឯវំ
វទន្តិ កញ្ចាវុសោ តំ ចិរំ អាវាស មយន្តេ ឥធ ចិរំ
កាវិស្សាមាតិ ។ សោ តំ អាភស្ស តត្ថ ភិក្ខុ បុច្ឆតិ
កាយាំ មេ អាវុសោ ចិរប្បដិវិសោតិ ។ តេ ឯវំ វទន្តិ
អយន្តេ អាវុសោ ចិរប្បដិវិសោតិ ។ សោ តំ ចិរំ
អាដាយ តំ អាភស្ស គច្ឆតិ ។ តមេនំ អត្តនាគ្ន



ឈ្មោះថានោះ ត្រង់ពីរសេរប្រែថាគំណត់ ។ ភិក្ខុបានក្រាលកបិលរួច
ហើយមានដំណើរទៅកាន់ទិសក៏ទៀសចេញទៅ ។ បេ ។ កបិលរបស់ភិក្ខុ
នោះឈ្មោះថានោះ ត្រង់សេចក្តីសន្និដ្ឋានជាគំណត់ ។ ភិក្ខុបានក្រាល
កបិលរួចហើយមានដំណើរទៅកាន់ទិសក៏ទៀសចេញទៅ ។ បេ ។ កបិល
របស់ភិក្ខុនោះឈ្មោះថានោះ ត្រង់ពីរវិតាសជាគំណត់ ។

(៦៤) ភិក្ខុបានក្រាលកបិលរួចហើយ មានដំណើរទៅកាន់ទិសក៏
ទៀសចេញទៅ គ្មានសេចក្តីរលំខ្លាយនឹងចំណែកចីវរ (របស់ខ្លួន) ។
ភិក្ខុទាំងឡាយសួរភិក្ខុដែលទៅកាន់ទិសនោះថា ម្នាលលោកដ៏មានអាយុ
លោកនៅចាំវស្សាក្នុងអាវាសណា មួយទៀត ចំណែកចីវររបស់លោក
(មាននៅ) ក្នុងអាវាសណា ។ ភិក្ខុនោះឆ្លើយតបយ៉ាងនេះថា ខ្ញុំនៅចាំវស្សា
ក្នុងអាវាសឯណោះ ឯចំណែកចីវររបស់ខ្ញុំ (មាននៅ) ក្នុងអាវាសនោះដែរ ។
ភិក្ខុទាំងនោះនិយាយថា ម្នាលលោកដ៏មានអាយុ ចូរលោកទៅយកចីវរ
នោះមក យើងទាំងឡាយនឹងធ្វើចីវរឲ្យលោកក្នុងទីនេះ ។ លុះភិក្ខុនោះ
ទៅកាន់អាវាសនោះហើយក៏សួរភិក្ខុទាំងឡាយថា នែលោកដ៏មានអាយុ
ទាំងឡាយ ចំណែកចីវររបស់ខ្ញុំ (ទុក) ក្នុងទីឯណា ។ ភិក្ខុទាំងនោះឆ្លើយ
តបយ៉ាងនេះថា ម្នាលលោកដ៏មានអាយុ ចីវរនេះជាចំណែករបស់លោក ។
ភិក្ខុនោះក៏ទាំយកចីវរនោះហើយដើរទៅកាន់អាវាសនោះ ។ ដល់កាល

ភិក្ខូ បុច្ឆន្តិ អាវុសោ កហំ គមិស្សសីតិ ។ សោ ឯវំ វទេតិ អមុត្រ នាម អាវាសំ គមិស្សាមិ តត្ថ មេ ភិក្ខូ ចីវរំ ទស្សន្តីតិ ។ តេ ឯវំ វទន្តិ អលំ អាវុសោ មា អគមាសិ មយន្តេ ឥធ ចីវរំ ទស្សាមាតិ ។ តស្ស ឯវំ ហោតិ ឥធេវិមំ ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ សោ តំ ចីវរំ ការេតិ ។ តស្ស ភិក្ខុនោ និដ្ឋានន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ និស្សីមគតោ បក្កមតិ ចីវរប្បដិវីសំ អបវិលាយមានោ ។ តមេនំ និស្សីមគតំ ភិក្ខូ បុច្ឆន្តិ កហំ តេ អាវុសោ វស្សំ វុត្ថំ កត្ថ ច តេ ចី-វរប្បដិវីសោតិ ។ សោ ឯវំ វទេតិ អមុត្រាស្មិំ អាវាសេ វស្សំ វុត្ថម្ហិ តត្ថ ច មេ ចីវរប្បដិវីសោតិ ។ តេ ឯវំ វទន្តិ គច្ឆាវុសោ តំ ចីវរំ អាហរ មយន្តេ ឥធ ចីវរំ ទស្សាមាតិ ។ សោ តំ អាវាសំ គន្ត្វា ភិក្ខូ បុច្ឆតិ



កណ្ដាលផ្លូវ ភិក្ខុទាំងឡាយក៏សួរភិក្ខុនោះថា ម្នាលលោកដ៏មានអាយុ លោកទៅណា ។ ភិក្ខុនោះប្រាប់យ៉ាងនេះថា ខ្ញុំនឹងទៅកាន់អាវាសឯណោះ (ឯទៀត) ពួកភិក្ខុក្នុងអាវាសនោះមុខជានឹងធ្វើចីវរឲ្យខ្ញុំ ។ ភិក្ខុទាំងនោះនិយាយយ៉ាងនេះថា ណ្ហើយលោកដ៏មានអាយុ លោកកុំទៅឡើយ យើងទាំងឡាយនឹងធ្វើចីវរឲ្យលោកក្នុងទីនេះ ។ ភិក្ខុនោះមានគំនិតយ៉ាងនេះថា គួរតែអាត្មាធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញនឹងមិនត្រឡប់មកវិញទេ ។ ភិក្ខុនោះក៏ធ្វើចីវរនោះឲ្យសម្រេច ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ព្រោះចីវរសម្រេចជាកំណត់ ។ ភិក្ខុក្រាលកឋិនរួចហើយ មានដំណើរទៅកាន់ទិស ក៏ចៀសចេញទៅ ក្នុងវេលាកំពុងស្ដាយនូវចំណែកចីវរ (របស់ខ្លួនទេ) ។ ភិក្ខុទាំងឡាយសួរភិក្ខុដែលទៅកាន់ទិសនោះថា ម្នាលលោកដ៏មានអាយុ លោកនៅចាំវស្សាក្នុងអាវាសណា មួយទៀត ចំណែកចីវររបស់លោក (មាននៅ) ក្នុងអាវាសណា ។ ភិក្ខុនោះឆ្លើយតបយ៉ាងនេះថា ខ្ញុំនៅចាំវស្សាក្នុងអាវាសឯណោះ ឯចំណែកចីវររបស់ខ្ញុំ (មាននៅ) ក្នុងអាវាសនោះដែរ ។ ភិក្ខុទាំងនោះនិយាយយ៉ាងនេះថា ម្នាលលោកដ៏មានអាយុ លោកចូរទៅយកចីវរនោះមក យើងទាំងឡាយនឹងធ្វើចីវរឲ្យលោកក្នុងទីនេះ ។ លុះភិក្ខុនោះទៅកាន់អាវាសនោះហើយក៏សួរភិក្ខុទាំងឡាយថា

ទេថ មេ អាវុសោ ចីវរបដិវីសោតិ ។ តេ ឯវំ វទន្តិ អយម្បិ អាវុសោ ចីវរបដិវីសោតិ ។ សោ តំ ចីវរំ អាទាយ តំ អាវាសំ គន្ត្វា ។ ឯតទវោច អញ្ញតរេ ភិក្ខូ បុច្ឆន្តិ អាវុសោ ទេថ មេ ចីវរបដិវីសោតិ ។ សោ ឯវំ វទតិ អញ្ញំ ឯវ អាវាសំ គច្ឆាមិ តត្ថ មេ ភិក្ខូ ចីវរំ ទស្សន្តីតិ ។ តេ ឯវំ វទន្តិ អលំ អាវុសោ មា អគមាសិ អយម្បិ តេ ចីវរំ ទស្សាមាតិ ។ តស្ស ឯវំ ហោតិ ទេវិ ចីវរំ ទស្សាមិ ន បរេ ទស្សន្តិ ។ តស្ស ភិក្ខុនោ សត្ថុសាសនេ កម្មបុគ្គលោ ។ ភិក្ខុ អត្តនោ បារាជិកោ និសិន្ទមនោ បត្តមត្តំ ចីវរបដិវីសំ អលភិត្វា ឯវមាហ ។ ឯវមេតំ និសីទិត្វា ភិក្ខូ បុច្ឆន្តិ ទេថ ទំ អាវុសោ ទេសំ វុត្តា ឯត្ថ ច តេ ចីវរបដិវីសោតិ ។ សោ ឯវំ វទតិ អញ្ញស្មឹ អាវាសេ ទេសំ វុត្តោ ឯត្ថ ច មេ ចីវរបដិវីសោតិ ។ តេ ឯវំ វទន្តិ តត្រាវុសោ





នៃលោកដ៏មានអាយុតាំងឡាយ ចំណែកចីវររបស់ខ្ញុំ (ចុះ) ក្នុងទីឯណា ។ ភិក្ខុទាំងនោះនិយាយយ៉ាងនេះថា ម្នាលលោកដ៏មានអាយុ ចំណែកនេះជាចំណែករបស់លោក ។ ភិក្ខុនោះក៏នាំយកចីវរនោះហើយដើរទៅកាន់អាវាសនោះ ។ ដល់ទៅកណ្តាលផ្លូវ ភិក្ខុទាំងឡាយក៏សួរភិក្ខុនោះថា ម្នាលលោកដ៏មានអាយុ លោកទៅក្នុងទីណា ។ ភិក្ខុនោះឆ្លើយប្រាប់យ៉ាងនេះថា ខ្ញុំទៅកាន់អាវាសឯណោះ (វិញ) ពួកភិក្ខុក្នុងអាវាសនោះមុខជានឹងឲ្យចីវរខ្ញុំ ។ ភិក្ខុទាំងនោះនិយាយយ៉ាងនេះថា ណ្ហើយលោកដ៏មានអាយុ លោកកុំទៅឡើយ យើងទាំងឡាយនឹងឲ្យចីវរឲ្យលោកក្នុងទីនេះ ។ ភិក្ខុនោះមានគំនិតយ៉ាងនេះថា ភិក្ខុអញនឹងមិនឲ្យចីវរនេះទេ ភិក្ខុអញទាំងនោះនឹងឲ្យ (ខ្ញុំ) វិញទេ ។ កង្វល់របស់ភិក្ខុនោះឈ្មោះជាថេរៈ ព្រោះសេចក្តីសង្ស័យ ។ ភិក្ខុបានក្រាលគំនិតរួចហើយមាននិស្ស័យទៅកាន់ទិស គឺ ទៀតថា ចេញទៅក្នុងសេចក្តីល្មោភ ក្នុងទីចំណែកចីវរ(របស់ខ្លួន) ។ ភិក្ខុទាំងឡាយសួរភិក្ខុដែលទៅកាន់ទិសនោះថា ម្នាលលោកដ៏មានអាយុ លោកទៅពីអាវាសក្នុងទីណា ម្តងទៀតចំណែកចីវររបស់លោក (មាននៅ) ក្នុងអាវាសណា ។ ភិក្ខុនោះប្រាប់យ៉ាងនេះថា ខ្ញុំទៅពីអាវាសក្នុងអាវាសឯណោះ ឯចំណែកចីវររបស់ខ្ញុំ (មាននៅ) ក្នុងអាវាសនោះដែរ ។ ភិក្ខុទាំងនោះនិយាយយ៉ាងនេះថា ម្នាលលោកដ៏មានអាយុ ចូរលោកនាំយកចីវរ

តំ ចីវរំ អាហរ មយន្តេ ឥធ ចីវរំ ករិស្សាមាតិ ។ សោ តំ អាវាសំ គន្ត្វា ភិក្ខូ បុច្ឆតិ កហំ មេ អាវុសោ ចីវរប្បដិវីសោតិ ។ តេ ឯវំ វទន្តិ អយន្តេ អាវុសោ ចីវរប្បដិវីសោតិ ។ សោ តំ ចីវរំ អាទាយ តំ អាវាសំ គច្ឆតិ ។ តមេនំ អន្តរាមគ្គេ ភិក្ខូ បុច្ឆន្តិ អាវុសោ កហំ គមិស្សសីតិ ។ សោ ឯវំ វទេតិ អមុកំ នាម អាវាសំ គមិស្សាមិ តត្ថ មេ ភិក្ខូ ចីវរំ ករិស្សន្តីតិ ។ តេ ឯវំ វទន្តិ អលំ អាវុសោ មា អគមាសិ មយន្តេ ឥធ ចីវរំ ករិស្សាមាតិ ។ តស្ស ឯវំ ហោតិ ឥធេវិមំ ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ សោ តំ ចីវរំ ការេតិ ។ តស្ស តំ ចីវរំ កយិរមានំ នស្សតិ ។ តស្ស ភិក្ខុនោ នាសនន្តិកោ កឋិនុទ្ធារោ ។

[៣០] ភិក្ខុ អត្ថតកឋិនោ ទិសង្គមិកោ បក្កមតិ ចីវរប្បដិវីសំ អបវិលាយមានោ ។ តមេនំ ទិសង្គតំ ភិក្ខូ បុច្ឆន្តិ កហំ ត្វំ អាវុសោ វស្សំ វុត្ថោ



ពោះមក យើងទាំងឡាយនឹងធ្វើចីវរឲ្យលោកក្នុងទីនេះ ។ លុះភិក្ខុនោះទៅកាន់អាវាសនោះហើយក៏សួរភិក្ខុទាំងឡាយថា នែលោកដ៏មានអាយុទាំងឡាយ ចំណែកចីវររបស់ខ្ញុំ (ទុក) ក្នុងទីណា ។ ភិក្ខុទាំងនោះនិយាយយ៉ាងនេះថា ម្នាលលោកដ៏មានអាយុ ចីវរនេះជាចំណែករបស់លោក ។ ភិក្ខុនោះក៏កាន់យកចីវរនោះហើយទៅកាន់អាវាសនោះ ។ ដល់ពាក់កណ្ដាលផ្លូវ ភិក្ខុទាំងឡាយសួរភិក្ខុនោះថា ម្នាលលោកដ៏មានអាយុ លោកទៅឯណា ។ ភិក្ខុនោះតបយ៉ាងនេះថា ខ្ញុំនឹងទៅកាន់អាវាសឯណោះ ព្រោះភិក្ខុទាំងឡាយក្នុងអាវាសនោះប្រុងនឹងធ្វើចីវរឲ្យខ្ញុំ ។ ភិក្ខុទាំងនោះនិយាយយ៉ាងនេះថា ណ្ហើយលោកដ៏មានអាយុ លោកកុំទៅឡើយ យើងទាំងឡាយនឹងធ្វើចីវរឲ្យលោកក្នុងទីនេះ ។ ភិក្ខុនោះមានគំនិតយ៉ាងនេះថា គួរអញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញនឹងមិនត្រឡប់វិញទេ ។ ភិក្ខុនោះក៏ធ្វើចីវរនោះ ។ កាលភិក្ខុនោះកំពុងធ្វើ ចីវរនោះក៏វិនាសទៅ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ព្រោះចីវរវិនាសជាកំណត់ ។

[៣០] ភិក្ខុបានក្រាលកឋិនរួចហើយ មានដំណើរទៅកាន់ទិស ក៏បៀសវាចេញទៅ គ្មានសេចក្ដីរំពឹងនឹងចំណែកចីវរ (របស់ខ្លួន) ។ ភិក្ខុទាំងឡាយសួរភិក្ខុដែលទៅកាន់ទិសនោះថា ម្នាលលោកដ៏មានអាយុ លោកនៅចាំវស្សាក្នុងអាវាសណា

អត្ថុ ច តេ ចីវរប្បដិវិសោតិ ។ សោ ឯវំ វទេតិ អមុកស្មឹ អាវាសេ វស្សំ វុត្ថោម្ហិ តត្ថ ច មេ ចីវរប្បដិវិសោតិ ។ តេ ឯវំ វទន្តិ គច្ឆាវុសោ តំ ចីវរំ អាហរ មយន្តេ ឥធ ចីវរំ ករិស្សាមាតិ ។ សោ តំ អាវាសំ គន្ត្វា ភិក្ខូ បុច្ឆតិ កហំ មេ អាវុសោ ចីវរប្បដិវិសោតិ ។ តេ ឯវំ វទន្តិ អយន្តេ អាវុសោ ចីវរប្បដិវិសោតិ ។ សោ តំ ចីវរំ អាទាយ តំ អាវាសំ គច្ឆតិ ។ តស្ស តំ អាវាសំ គតស្ស ឯវំ ហោតិ ឥធេវិមំ ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ សោ តំ ចីវរំ ការេតិ ។ តស្ស ភិក្ខុនោ និដ្ឋានន្តិកោ កឋិនុព្ភារោ ។ ភិក្ខុ អត្ថតកឋិនោ ទិសង្គមិកោ បក្កមតិ ។បេ។ នេវិមំ ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ តស្ស ភិក្ខុនោ សន្និដ្ឋានន្តិកោ កឋិនុព្ភារោ ។ ភិក្ខុ អត្ថតកឋិនោ ទិសង្គមិកោ បក្កមតិ ។បេ។ ឥធេវិមំ ចីវរំ ការេស្សំ



មួយទៀត ចំណែកចីវររបស់លោក (ខាងនៅ) ក្នុងអាវាសណា ។ ភិក្ខុនោះប្រាប់យ៉ាងនេះថា ខ្ញុំនៅចាំវស្សាក្នុងអាវាសឯណោះ ឯចំណែកចីវររបស់ខ្ញុំ (ខាងនៅ) ក្នុងអាវាសនោះដែរ ។ ភិក្ខុទាំងនោះនិយាយយ៉ាងនេះថា ម្នាលលោកដ៏មានអាយុ លោកចូរទៅយកចីវរនោះមក យើងទាំងឡាយនឹងធ្វើចីវរឲ្យលោកក្នុងទីនេះ ។ លុះភិក្ខុនោះទៅកាន់អាវាសនោះហើយ ក៏សួរភិក្ខុទាំងឡាយថា នែលោកដ៏មានអាយុទាំងឡាយ ចំណែកចីវររបស់ខ្ញុំ (ខុក) ក្នុងទីណា ។ ភិក្ខុទាំងនោះនិយាយយ៉ាងនេះថា ម្នាលលោកដ៏មានអាយុ ចីវរនេះជាចំណែករបស់លោក ។ ភិក្ខុនោះក៏នាំយកចីវរនោះហើយទៅកាន់អាវាសនោះ ។ លុះភិក្ខុនោះទៅដល់អាវាសនោះហើយ មានគំនិតយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញនឹងមិនត្រឡប់វិញទេ ។ ភិក្ខុនោះក៏បានធ្វើចីវរនោះឲ្យសម្រេច ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ព្រោះចីវរសម្រេចជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយមានដំណើរទៅកាន់ទិសតៀសចេញទៅ ។បេ។ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញនឹងមិនធ្វើចីវរនេះទេ អាត្មាអញនឹងមិនត្រឡប់វិញទេ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ព្រោះសេចក្តីសន្និដ្ឋានជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយមានដំណើរទៅកាន់ទិសតៀសចេញទៅ ។បេ។ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះ

ន បច្ចេស្សន្តិ ។ សោ តំ ចីវរំ ការេតិ ។ តស្ស តំ ចីវរំ ករិយមានំ នស្សតិ ។ តស្ស ភិក្ខុនោ នាសនន្តិកោ កឋិនុទ្ធារោ ។

អនបេក្ខនវកំ និដ្ឋិតំ ។

(៣១) ភិក្ខុ អត្ថតកឋិនោ ផាសុវិហារិកោ ចីវរំ អាទាយ បក្កមតិ អមុត្រ នាម អាវាសំ គមិស្សាមិ តត្ថ ចេ មេ[១] ផាសុ ភវិស្សតិ វសិស្សាមិ នោ ចេ មេ ផាសុ ភវិស្សតិ អមុត្រ នាម អាវាសំ គមិស្សាមិ តត្ថ ចេ មេ ផាសុ ភវិស្សតិ វសិស្សាមិ នោ ចេ មេ ផាសុ ភវិស្សតិ អមុត្រ នាម អាវាសំ គមិស្សាមិ តត្ថ ចេ មេ ផាសុ ភវិស្សតិ វសិស្សាមិ នោ ចេ មេ ផាសុ ភវិស្សតិ បច្ចេស្សន្តិ ។ តស្ស ពហិសីមគតស្ស ឯវំ ហោតិ ឥធេវិមំ ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ សោ តំ ចីវរំ ការេតិ ។ តស្ស ភិក្ខុនោ និដ្ឋានន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ ផាសុវិហារិកោ ចីវរំ អាទាយ បក្កមតិ

១ ម. តត្ថ មេ ។



ក្នុងទីនេះឯង អាត្មាអញនឹងមិនត្រឡប់វិញទេ ។ ភិក្ខុនោះក៏ធ្វើចីវរនោះ ។ កាលភិក្ខុនោះកំពុងធ្វើ ចីវរនោះក៏វិនាសទៅ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថា ដោះ ត្រង់ចីវរវិនាសជាកំណត់ ។

ចប់ សេចក្តីមិនខ្វល់ខ្វាយ(ក្នុងចីវរ) ៩ ប្រការ ។

(៣១) ភិក្ខុបានក្រាលកឋិនរួចហើយជាសុខសប្បាយ ហើយនាំយកចីវរចៀសចេញទៅ ដោយគិតថា អាត្មាអញនឹងទៅកាន់អាវាសឯណោះ បើក្នុងអាវាសនោះមានសេចក្តីសប្បាយដល់អាត្មាអញ ។ នឹងនៅ បើគ្មានសេចក្តីសប្បាយដល់អាត្មាអញទេ អាត្មាអញនឹងទៅកាន់អាវាសឯណោះ(ទៀត) បើក្នុងអាវាសនោះមានសេចក្តីសប្បាយដល់អាត្មាអញ ។ នឹងនៅ បើគ្មានសេចក្តីសប្បាយដល់អាត្មាអញទេ អាត្មាអញនឹងទៅកាន់អាវាសឯណោះ ( ទៀត ) បើក្នុងអាវាសនោះមានសេចក្តីសប្បាយដល់អាត្មាអញ ។ នឹងនៅ បើគ្មានសេចក្តីសប្បាយដល់អាត្មាអញទេ អាត្មាអញនឹងត្រឡប់វិញ ។ ភិក្ខុនោះទៅដល់ក្រៅសីមាក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញនឹងមិនត្រឡប់វិញទេ ។ ភិក្ខុនោះក៏បានធ្វើចីវរនោះឲ្យសម្រេច ។ កឋិនរបស់ភិក្ខុនោះឈ្មោះថា ដោះ ត្រង់ចីវរសម្រេចជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចហើយជាសុខសប្បាយ ហើយនាំយកចីវរចៀសចេញទៅ ដោយគិតថា អាត្មាអញ

អមុត្រំ នាម អាវាសំ គមិស្សាមិ តត្ថ ចេ មេ ផាសុ
ភវិស្សតិ វសិស្សាមិ នោ ចេ មេ ផាសុ ភវិស្សតិ
អមុត្រំ នាម អាវាសំ គមិស្សាមិ តត្ថ ចេ មេ ផា-
សុ ភវិស្សតិ វសិស្សាមិ នោ ចេ មេ ផាសុ ភវិស្សតិ
អមុត្រំ នាម អាវាសំ គមិស្សាមិ តត្ថ ចេ មេ ផាសុ
ភវិស្សតិ វសិស្សាមិ នោ ចេ មេ ផាសុ ភវិស្សតិ បច្ចេ-
ស្សន្តិ ។ តស្ស ពហិសីមគតស្ស ឯវំ ហោតិ នេវ
ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ តស្ស ភិក្ខុនោ សន្និដ្ឋា-
នន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ អត្ថតកឋិនោ ផា-
សុវិហារិកោ ចីវរំ អាទាយ បក្កមតិ អមុត្រំ នាម
អាវាសំ គមិស្សាមិ តត្ថ ចេ មេ ផាសុ ភវិស្សតិ
វសិស្សាមិ នោ ចេ មេ ផាសុ ភវិស្សតិ អមុត្រំ
នាម អាវាសំ គមិស្សាមិ តត្ថ ចេ មេ ផាសុ ភវិស្សតិ
វសិស្សាមិ នោ ចេ មេ ផាសុ ភវិស្សតិ អមុត្រំ
នាម អាវាសំ គមិស្សាមិ តត្ថ ចេ មេ ផាសុ ភវិស្ស-
តិ វសិស្សាមិ នោ ចេ មេ ផាសុ ភវិស្សតិ



ទីនេះទៅកាន់អាវាសឯណោះ បើគង់នៅអាវាសនោះមានសេចក្ដីសប្បាយដល់
អាត្មាអញ ។ នឹងនៅ បើឥតមានសេចក្ដីសប្បាយដល់អាត្មាអញទេ អាត្មា
អញនឹងទៅកាន់អាវាសឯណោះ (ទៀត) បើគង់នៅអាវាសនោះមានសេចក្ដី
សប្បាយដល់អាត្មាអញ ។ នឹងនៅ បើឥតមានសេចក្ដីសប្បាយដល់អាត្មា
អញទេ អាត្មាអញនឹងទៅកាន់អាវាសឯណោះ (ទៀត) បើគង់នៅអាវាសនោះ
មានសេចក្ដីសប្បាយដល់អាត្មាអញ ។ នឹងនៅ បើឥតមានសេចក្ដីសប្បាយ
ដល់អាត្មាអញទេ អាត្មាអញនឹងត្រឡប់វិញ ។ ភិក្ខុនោះទៅដល់ក្រៅសី-
មាក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងមិនធ្វើចីវរនេះទេ អាត្មាអញនឹង
មិនត្រឡប់វិញទេ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ត្រង់សេចក្ដីសន្និដ្ឋាន
ជាកំណត់ ។ ភិក្ខុមានក្រាលកឋិនរួចហើយនៅជាសុខសប្បាយ ហើយនាំយកចីវរ
ដែលមិនទាន់ធ្វើរួចចេញទៅ ដោយគិតថា អាត្មាអញនឹងទៅកាន់អា-
វាសឯណោះ បើគង់នៅអាវាសនោះមានសេចក្ដីសប្បាយដល់អាត្មាអញ ។ នឹង
នៅ បើឥតមានសេចក្ដីសប្បាយដល់អាត្មាអញទេ អាត្មាអញនឹងទៅកាន់
អាវាសឯណោះ (ទៀត) បើគង់នៅអាវាសនោះមានសេចក្ដីសប្បាយដល់អាត្មា
អញ ។ នឹងនៅ បើឥតមានសេចក្ដីសប្បាយដល់អាត្មាអញទេ អាត្មាអញនឹង
ទៅកាន់អាវាសឯណោះ (ទៀត) បើគង់នៅអាវាសនោះមានសេចក្ដីសប្បាយ
ដល់អាត្មាអញ ។ នឹងនៅ បើឥតមានសេចក្ដីសប្បាយដល់អាត្មាអញទេ

បច្ចេស្សំ ។ តស្ស ពហិសីមគតស្ស ឯវំ ហោតិ
ឥធេវិមំ ចីវរំ ការេស្សំ ន បច្ចេស្សន្តិ ។ សោ តំ
ចីវរំ ការេតិ ។ តស្ស តំ ចីវរំ ការយមានំ នស្សតិ ។
តស្ស ភិក្ខុនោ នាសនន្តិកោ កឋិនុទ្ធារោ ។ ភិក្ខុ
អត្ថតកឋិនោ ផាសុវិហារិកោ ចីវរំ អាទាយ បក្កមតិ
អមុកំ នាម អាវាសំ គមិស្សាមិ តត្ថ មេ ផាសុ
ភវិស្សតិ វសិស្សាមិ នោ ចេ មេ ផាសុ ភវិស្សតិ
អមុកំ នាម អាវាសំ គមិស្សាមិ តត្ថ មេ ផាសុ
ភវិស្សតិ វសិស្សាមិ នោ ចេ មេ ផាសុ ភវិស្សតិ អមុកំ
នាម អាវាសំ គមិស្សាមិ តត្ថ មេ ផាសុ ភវិស្សតិ
វសិស្សាមិ នោ ចេ មេ ផាសុ ភវិស្សតិ បច្ចេស្សន្តិ ។
សោ ពហិសីមគតោ តំ ចីវរំ ការេតិ ។ សោ កតចី-
វរោ បច្ចេស្សំ បច្ចេស្សន្តិ ពហិទ្ធា កឋិនុទ្ធារំ វីតិនា-
មេតិ ។ តស្ស ភិក្ខុនោ សីមាតិក្កន្តិកោ កឋិនុទ្ធា-
រោ ។ ភិក្ខុ អត្ថតកឋិនោ ផាសុវិហារិកោ ចីវ-



អាត្មាអញនឹងត្រឡប់វិញ ។ ភិក្ខុនោះទៅដល់ក្រៅសីមាក៏មានគំនិតយ៉ាង
នេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញនឹងមិនត្រឡប់វិញ
ទេ ។ ភិក្ខុនោះក៏ធ្វើចីវរនោះឲ្យសម្រេច ។ កាលភិក្ខុនោះកំពុងធ្វើ ចីវរ
នោះក៏វិនាសទៅ ។ ការដោះរបស់ភិក្ខុនោះឈ្មោះថាដោះ ក្រង់ចីវរវិនាស
ជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចនៅជាសុខសប្បាយ ហើយនាំយក
ចីវរដែលមិនទាន់ធ្វើចៀសចេញទៅ ដោយគិតថាអាត្មាអញនឹងទៅកាន់
អាវាសឯណោះ បើក្នុងអាវាសនោះមានសេចក្ដីសប្បាយដល់អាត្មាអញ ៗ
នឹងនៅ បើគ្មានសេចក្ដីសប្បាយដល់អាត្មាអញទេ អាត្មាអញនឹងទៅ
កាន់អាវាសឯណោះ (ទៀត) បើក្នុងអាវាសនោះមានសេចក្ដីសប្បាយដល់
អាត្មាអញ ៗ នឹងនៅ បើគ្មានសេចក្ដីសប្បាយដល់អាត្មាអញទេ អាត្មា
អញនឹងទៅកាន់អាវាសឯណោះ (ទៀត) បើក្នុងអាវាសនោះមានសេចក្ដី
សប្បាយដល់អាត្មាអញ ៗ នឹងនៅ បើគ្មានសេចក្ដីសប្បាយដល់អាត្មា
អញទេ អាត្មាអញនឹងត្រឡប់វិញ ។ ភិក្ខុនោះទៅដល់ក្រៅសីមា ក៏ធ្វើ
ចីវរនោះ ។ ភិក្ខុនោះធ្វើចីវររួចហើយគិតថា អាត្មាអញនឹងត្រឡប់វិញ
អាត្មាអញនឹងត្រឡប់វិញដែរ (តែមិនទាន់មកនៅឡើយ) កឋិនក៏ដោះ
ខាងក្រៅ (នោះ) ទៅ ។ ការដោះរបស់ភិក្ខុនោះឈ្មោះថាដោះ ក្រង់
កន្លងសីមាជាកំណត់ ។ ភិក្ខុបានក្រាលកឋិនរួចនៅជាសុខសប្បាយ

អាទាយ បក្កមតិ អមុកំ នាម អាវាសំ គមិស្សាមិ តត្ថ ចេ មេ ផាសុ ភវិស្សតិ វសិស្សាមិ នោ ចេ មេ ផាសុ ភវិស្សតិ អមុកំ នាម អាវាសំ គមិស្សាមិ តត្ថ ចេ មេ ផាសុ ភវិស្សតិ វសិស្សាមិ នោ ចេ មេ ផាសុ ភវិស្សតិ អមុកំ នាម អាវាសំ គមិស្សាមិ តត្ថ ចេ មេ ផាសុ ភវិស្សតិ វសិស្សាមិ នោ ចេ មេ ផាសុ ភវិស្សតិ បច្ចេស្សន្តិ ។ សោ ពហិសីមគតោ តំ ចីវរំ ការេតិ ។ សោ កតចីវរោ បច្ចេស្សំ បច្ចេស្សន្តិ សម្ភុណាតិ កឋិនុទ្ធារំ ។ តស្ស ភិក្ខុនោ សហ ភិក្ខូហិ កឋិនុទ្ធារោ ។

ផាសុវិហារបញ្ចកំ និដ្ឋិតំ ។

[៣២] ទ្វេមេ ភិក្ខវេ កឋិនស្ស បលិពោធា ទ្វេ អបលិពោធា ។ កតមេ ច ភិក្ខវេ ទ្វេ កឋិនស្ស



សុខសប្បាយ ហើយនាំយកចីវរដែលមិនទាន់ធ្វើ ហើយចៀសចេញទៅ ដោយគិតថា អាត្មាអញនឹងទៅកាន់អាវាសឯណោះ បើកុដិអាវាសនោះមានសេចក្ដីសប្បាយដល់អាត្មាអញ ។ នឹងនៅ បើឥតមានសេចក្ដីសប្បាយដល់អាត្មាអញទេ អាត្មាអញនឹងទៅកាន់អាវាសឯណោះ (ទៀត) បើកុដិអាវាសនោះមានសេចក្ដីសប្បាយដល់អាត្មាអញ ។ នឹងនៅ បើឥតមានសេចក្ដីសប្បាយដល់អាត្មាអញទេ អាត្មាអញនឹងទៅកាន់អាវាសឯណោះ (ទៀត) បើកុដិអាវាសនោះមានសេចក្ដីសប្បាយដល់អាត្មាអញ ។ នឹងនៅ បើឥតមានសេចក្ដីសប្បាយដល់អាត្មាអញទេ អាត្មាអញនឹងត្រឡប់វិញ ។ ភិក្ខុនោះទៅដល់ក្រៅសីមា ក៏ធ្វើចីវរនោះឲ្យសម្រេច ។ ភិក្ខុនោះធ្វើចីវរស្រេចហើយគិតថា អាត្មាអញនឹងត្រឡប់វិញ អាត្មាអញនឹងត្រឡប់វិញ ហើយក៏មកទាន់ពេលដោះកឋិននោះវិញ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថា ដោះជាមួយនឹងភិក្ខុទាំងឡាយ ។

ចប់ កិរិយានៅជាសុខសប្បាយ ៥ ប្រការ ។

(៣២) ម្នាលភិក្ខុទាំងឡាយ បលិពោធ (កង្វល់) របស់កឋិននេះ មាន ២ យ៉ាង អបលិពោធ (គ្មានកង្វល់) របស់កឋិននេះមាន ២ យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ បលិពោធរបស់កឋិនទាំង ២ យ៉ាង (នោះ)

បលិពោធា ។ អាវាសបលិពោធោ ច ចីវរបលិពោធោ ច ។ កថញ្ច ភិក្ខវេ អាវាសបលិពោធោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ វសតិ វា តស្មិំ អាវាសេ សាបេក្ខោ វា បក្កមតិ បច្ចេស្សន្តិ ។ ឯវំ ខោ ភិក្ខវេ អាវាសបលិពោធោ ហោតិ ។ កថញ្ច ភិក្ខវេ ចីវរបលិពោធោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុនោ ចីវរំ អកតំ វា ហោតិ វិប្បកតំ ចីវរាសា វា អនុបច្ឆិន្នា ។ ឯវំ ខោ ភិក្ខវេ ចីវរបលិពោធោ ហោតិ ។ ឥមេ ខោ ភិក្ខវេ ទ្វេ កឋិនស្ស បលិពោធា ។ កតមេ ច ភិក្ខវេ ទ្វេ កឋិនស្ស អបលិពោធា ។ អាវាសាបលិពោធោ ច ចីវរាបលិពោធោ ច ។ កថញ្ច ភិក្ខវេ អាវាសាបលិពោធោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ បក្កមតិ តម្ហា អាវាសា ចត្តេន វន្តេន មុត្តេន អនបេក្ខេន ន បច្ចេស្សន្តិ ។



ដូចម្តេច ។ (ឯបលិពោធរបស់កឋិនទាំង ២ យ៉ាងនោះ) គឺ អាវាសបលិពោធ (កង្វល់ក្នុងអាវាស) ១ ចីវរបលិពោធ (កង្វល់ក្នុងចីវរ) ១ ។ ម្នាលភិក្ខុទាំងឡាយ ឯអាវាសបលិពោធ (នោះ) ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ នៅក្នុងអាវាសនោះក្តី មានសេចក្តីអាល័យចំពោះអាវាសនោះ ហើយចៀសចេញទៅ ដោយបំណងថា អាត្មាអញនឹងត្រឡប់វិញក្តី ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯងហៅថាអាវាសបលិពោធ ។ ម្នាលភិក្ខុទាំងឡាយ ឯចីវរបលិពោធ (នោះ) តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ចីវរដែលភិក្ខុក្នុងសាសនានេះមិនទាន់បានធ្វើ ឬធ្វើបានខ្លះហើយ តែមិនទាន់ស្រេច ទាំងសេចក្តីប្រាថ្នាចីវរក៏មិនទាន់ដាច់នៅឡើយ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះហើយ ដែលហៅថា ចីវរបលិពោធ ។ ម្នាលភិក្ខុទាំងឡាយ បលិពោធរបស់កឋិនមាន ២ យ៉ាងដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចំណែកអបលិពោធរបស់កឋិនមាន ២ យ៉ាង (នោះ) ដូចម្តេចខ្លះ ។ (ឯអបលិពោធទាំង ២ យ៉ាងនោះ) គឺ អាវាសាបលិពោធ (គ្មានកង្វល់ក្នុងអាវាស) ១ ចីវរាបលិពោធ (គ្មានកង្វល់ក្នុងចីវរ) ១ ។ ម្នាលភិក្ខុទាំងឡាយ អាវាសាបលិពោធ (នោះ) តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះដើរចៀសចេញទៅចាកអាវាសនោះ ដោយលះបង់ចោលស្រឡះ លែងអាល័យថា អាត្មាអញនឹងមិនត្រឡប់វិញទេ ។

ឯវំ ខោ ភិក្ខវេ អាវាសអបលិពោធោ ហោតិ ។ កថញ្ច ភិក្ខវេ ចីវរអបលិពោធោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុនោ ចីវរំ កតំ វា ហោតិ នដ្ឋំ វា វិនដ្ឋំ វា ទឌ្ឍំ វា ចីវរាសា វា ឧបច្ឆិន្នា ។ ឯវំ ខោ ភិក្ខវេ ចីវរអបលិពោធោ ហោតិ ។ ឥមេ ខោ ភិក្ខវេ ទ្វេ កឋិនស្ស អបលិពោធាតិ ។

កឋិនក្ខន្ធកំ និដ្ឋិតំ សត្តមំ ។

ឥមម្ហិ ខន្ធកេ វត្ថូ ទ្វាទស ពេយ្យាលមុខានិ ឯកំ សតំ អដ្ឋារស ។

តស្សុទ្ទានំ

(៣៣) តឹស បាវេយ្យកា ភិក្ខូ
សាកេតុក្កណ្ឋិតា វស្សំ
វស្សំវុដ្ឋោកបុណ្ណេហិ
អាគមុំ ជិនទស្សនំ
ឥទំ វត្ថុ កឋិនស្ស
កប្បិស្សន្តិ ច បញ្ចកា
អនាមន្តា អសមាចារា



ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯងហៅថា អាវាសអបលិពោធ ។ ម្នាលភិក្ខុទាំងឡាយ ចុះចីវរអបលិពោធ (នោះ) តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ចីវរដែលភិក្ខុគិតនឹងសាងនោះបានធ្វើហើយក្តី បាត់ទៅក្តី វិនាសទៅក្តី ឆេះទៅក្តី សេចក្តីប្រាថ្នាចីវរដាច់ទៅក្តី ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯង ហៅថាចីវរអបលិពោធ ។ ម្នាលភិក្ខុទាំងឡាយ អបលិពោធរបស់កឋិនមាន ២ យ៉ាងដូច្នេះឯង ។

ចប់ កឋិនក្ខន្ធកៈ ទី ៧ ។

ក្នុងកឋិនក្ខន្ធកៈនេះ មានរឿង ១១៨ មុខបេយ្យាល ១២ ជាប្រមាណ ។

ឧទ្ទាននៃកឋិនក្ខន្ធកៈនោះគឺ

(៣៣) រឿងពួកបាវេយ្យកភិក្ខុ ៣០ រូប មានសេចក្តីអផ្សុកទៅក្នុងស្រុកសាកេត លុះនៅចាំវស្សារួចហើយ ក៏មានចីវរទទឹកជោកមកគាល់ព្រះជិនស្រី នេះជារឿង (ខាងដើម) នៃកឋិន ១ រឿងអានិសង្សទាំង ៥ សម្រេចដល់ភិក្ខុដែលបានក្រាលកឋិនហើយ គឺ ភិក្ខុចេញទៅណា មិនបាច់លាភិក្ខុឯទៀត ត្រាច់ទៅណា មិនបាច់យកត្រៃចីវរគ្រប់ប្រដាប់បាន

តថេវ គណភោជនំ
យាវទត្ថញ្ច ឧប្បាទោ
អត្ថតានំ ភវិស្សតិ ។
ញត្តិ ឯវត្ថតញ្ចេវ
ឯវញ្ចេវ អនត្ថតំ
ឧល្លិខិ ធោវនា ចេវ
វិចារណញ្ច ឆេទនំ
ពន្ធោវដ្ដិកណ្ឌុសំ
ទឡ្ហីកម្មានុវាតិកា
បរិភណ្ឌំ ឱវទ្ធេយ្យំ
មទ្ទនា និមិត្តកថា
កុក្កុ សន្និធិ និស្សគ្គិ
នកប្បញ្ញត្រ តេ តយោ
អញ្ញត្រ បញ្ចាតិរេក



ឆាន់គណភោជនបាន ទុកដាក់ចីវរកើតបានតាមត្រូវការ និងចីវរដែលកើតឡើងដល់សង្ឃគួរបានដល់ពួកភិក្ខុដែលបានក្រាលកឋិនហើយ ១ ។ ឡើងសូត្រញត្តិ ១ ឡើងក្រាលកឋិនឡើងបែបយ៉ាងនេះ និងក្រាលកឋិនមិនឡើងបែបយ៉ាងនេះ (ឯការក្រាលកឋិនមិនឡើងនោះ)គឺ(ក្រាលដោយសំពត់គ្រាន់តែ)គូសក្រែកចំណាំ ១ គ្រាន់តែបោកគក់លាង ១ គ្រាន់តែពាក់វែងវែលក ១ គ្រាន់តែកាត់ ១ គ្រាន់តែដាក់ភ្ជាប់គ្នា ១ គ្រាន់តែដេរ ១ គ្រាន់តែភ្ជាប់ឈ្នាប់ ១ គ្រាន់តែថែមសំពត់ឱ្យមាំ ១ គ្រាន់តែប្រក់អនុវាត (ខាងខ្នង)១ គ្រាន់តែប្រក់អនុវាត (ខាងពោះ)១ គ្រាន់តែដេរឡប្តាប់ភ្ជាប់ ១ គ្រាន់តែជ្រលក់ឱ្យមានពណ៌ដូចភ្នែកបក្សីសុកជើង ១ សំពត់ដែលបានមកព្រោះធ្វើនិមិត្ត ១ សំពត់ដែលបានមកព្រោះនិយាយបញ្ឆិតបញ្ឆៀង ១ សំពត់ដែលខ្ចីគេ ១ សំពត់ដែលមិនបានធ្វើឱ្យសម្រេចក្នុងថ្ងៃនោះ ១ សំពត់ដែលធ្វើឱ្យកន្លងត្រៃនិស្សគ្គិយ ឱ្យអរុណរះឡើងទាន់ ១ សំពត់ដែលមិនបានធ្វើពិន្ទុកប្បៈ ១ វៀរលែងសំពត់សង្ឃាដី ១ វៀរលែងតែសំពត់ដណ្ដប់ក្រៅព្រោះ

សញ្ឆិន្នេន សមណ្ឌលិ
នាញ្ញត្រ បុគ្គលា សម្មា
និស្សីមដ្ឋោ អនុមោទតិ
កឋិនំ អនត្ថតំ ហោតិ
យំ ពុទ្ធេន ទេសិតំ
អហតាហតកប្បបិលោតិ
បំសុកូលបណិកាយ ១
អនិមិត្តា បរិកថា
អកុក្កុ កសន្និធិ ១
អនិស្សគ្គិ កប្បកតេ
ន តិចីវរេ ១
បញ្ចកេ អតិរេក ប
ញ្ចកំ សមណ្ឌលីកតេ
បុគ្គល បត្ថារា សម្មា
សីមដ្ឋោ អនុមោទតិ
ឯវំ កឋិនត្ថារោ
ទុក្ខាសង្ខាតិកា



ដែលកាត់ដាច់ជាបញ្ចខ័ណ្ឌក្តី លើសពីបញ្ចខ័ណ្ឌក្តី ១ មិនឲ្យបុគ្គលក្រាល ព្រោះឲ្យសង្ឃឬគណៈក្រាលវិញ ១ ការក្រាលមិនត្រឹមត្រូវ ឬភិក្ខុនៅក្រៅសីមាអនុមោទនា ១ កឋិនដែលក្រាលមិនឡើង ព្រោះព្រះពុទ្ធជាម្ចាស់ទ្រង់សំដែងហើយយ៉ាងនេះឯង (ឯការក្រាលកឋិនឡើងនោះគឺ) ក្រាលដោយសំពត់ថ្មី ១ សំពត់ពិន ១ សំពត់ចាស់ ១ សំពត់បំសុកូល ១ សំពត់ធ្លាក់ចុះទៀបហាងផ្សារ ១ សំពត់ដែលបានមកដោយមិនបានធ្វើនិមិត្ត ១ សំពត់ដែលបានមកដោយមិនបាននិយាយបញ្ចុះបញ្ចូល ១ សំពត់ដែលមិនខ្ចីគេ ១ សំពត់ដែលបានធ្វើសម្រេចក្នុងថ្ងៃនោះ ១ សំពត់ដែលមិនធ្វើឲ្យគេទុកក្រៃ មិនឲ្យអរុណរះឡើងកាត់ ១ សំពត់ដែលបានធ្វើពិន្ទុកប្ប ១ ក្រាលដោយចីវរទាំង ៣ (ចីវរណាមួយក៏បាន) ១ សំពត់ដែលធ្វើឲ្យមានមណ្ឌលត្រឹមត្រូវ កាត់ដាច់ត្រឹមត្រូវជាបញ្ចខ័ណ្ឌក្តី លើសពីបញ្ចខ័ណ្ឌក្តី ១ ឲ្យបុគ្គលក្រាល ១ ការក្រាលដោយត្រឹមត្រូវ ឬភិក្ខុនៅក្នុងសីមាអនុមោទនា ១ ការក្រាលឡើងនៃកឋិនដោយអាការយ៉ាងនេះឯង មាតិកានាំឲ្យកឋិនដោះ មាន ៨

បក្កមនញ្ច និដ្ឋានំ
សន្និដ្ឋានញ្ច នាសនំ
សវនំ អាសាវច្ឆេទិ
សីមា សហុព្ភារបញ្ចមី
កតចីវរមាទាយ
ន បច្ចេស្សន្តិ គច្ឆតិ
តស្ស តំ កឋិនុទ្ធារោ
ហោតិ បក្កមនន្តិកោ
អាទាយ ចីវរំ យាតិ
និស្សីមេ ឥទំ ចិន្តយិ
ការេស្សំ ន បច្ចេស្សំ
និដ្ឋាបេ កឋិនុទ្ធារោ ។
អាទាយ និស្សីមំ នេវ
ន បច្ចេស្សន្តិ មានសោ
តស្ស តំ កឋិនុទ្ធារោ
សន្និដ្ឋានន្តិកោ ភវេ





យ៉ាងនេះ គឺមានការចៀសចេញទៅជាកំណត់ ១ មានការធ្វើចីវរស្រេចជាកំណត់ ១ មានសេចក្តីសន្និដ្ឋានជាកំណត់ ១ មានចីវរវិនាសជាកំណត់ ១ មានការឮដំណឹងជាកំណត់ ១ អស់សេចក្តីសង្ឃឹម ១ មានការកន្លងទៅក្រៅសីមាជាកំណត់ ១ ស្ទើរព្រមព្រៀងគ្នានឹងកឋិនមួយទៀតជាគំរប់ប្រាំ ១ អធិប្បាយថា ) ភិក្ខុនាំយកចីវរដែលធ្វើហើយចៀសចេញទៅ ដោយគំនិតថា អាត្មាអញនឹងមិនត្រឡប់វិញទេ កឋិននោះ របស់ភិក្ខុនោះ ឈ្មោះថាដោះ ព្រោះចៀសចេញទៅជាកំណត់ ភិក្ខុនាំយកចីវរចៀសចេញទៅ លុះទៅដល់ក្រៅសីមាក៏មានគំនិតថា អាត្មាអញនឹងធ្វើចីវរក្នុងទីនេះ អាត្មាអញនឹងមិនត្រឡប់វិញទេ កឋិន (របស់ភិក្ខុនោះ) ឈ្មោះថាដោះ ព្រោះធ្វើចីវរស្រេចជាកំណត់ ។ ភិក្ខុនាំយកចីវរចៀសចេញទៅ លុះទៅដល់ក្រៅសីមាក៏មានគំនិតថា អាត្មាអញនឹងមិនធ្វើ (ចីវរនេះ) អាត្មាអញនឹងមិនត្រឡប់វិញទេ កឋិនរបស់ភិក្ខុនោះ ឈ្មោះថា ដោះ ព្រោះសេចក្តីសន្និដ្ឋានជាកំណត់ ភិក្ខុ

អាទាយ ចីវរំ យាតិ
នំ ស្បៀម ឥធ ចិន្តយំ
ការេស្សំ ន បច្ចេស្សន្តិ
កយិរន្តស្ស នស្សតិ
តស្ស តំ កឋិនុទ្ធារោ
ភវតិ នាសនន្តិកោ
អាទាយ យាតិ បច្ចេស្សំ
ពហិ ការេតិ ចីវរំ
កតចីវរោ សុណាតិ
ឧព្ភតំ កឋិនំ តហឹ
តស្ស តំ កឋិនុទ្ធារោ
ភវតិ សវនន្តិកោ
អាទាយ យាតិ បច្ចេស្សំ
ពហិ ការេតិ ចីវរំ
កតចីវរោ ពហិទ្ធា
នាមេតិ កឋិនុទ្ធារំ
តស្ស តំ កឋិនុទ្ធារោ





នាំយកចីវរចៀសចេញទៅ លុះទៅដល់ក្រៅសីមាក៏មានគំ-និតថា អាត្មាអញនឹងធ្វើចីវរក្នុងទីនេះ អាត្មាអញនឹងមិនត្រ-ឡប់វិញទេ កាលភិក្ខុនោះកំពុងធ្វើ ចីវរនៅក្រៅសីមា កឋិននោះរបស់ភិក្ខុនោះឈ្មោះថា ដោះ ត្រង់ចីវរវិនាសជាកំណត់ ភិក្ខុនាំយកចីវរចៀសចេញទៅ ដោយបំណងថា អាត្មាអញនឹងត្រឡប់វិញ ក៏ធ្វើចីវរ(នោះ)ខាងក្រៅសីមា លុះធ្វើចីវរស្រេច ស្រាប់តែឮដំណឹងថា កឋិនក្នុងអាវាសនោះសង្ឃព្រមគ្នាដកហើយ កឋិននោះរបស់ភិក្ខុនោះឈ្មោះថា ដោះ ត្រង់ឮដំណឹងជាកំណត់ ភិក្ខុនាំយកចីវរចៀសចេញទៅ ដោយបំណងថា អាត្មាអញនឹងត្រឡប់វិញ ក៏ធ្វើចីវរ(នោះ)ខាងក្រៅសីមា លុះធ្វើស្រេចហើយក៏បង្អង់រឿយៗការដោះកឋិន (នោះ)កន្លងហួសទៅខាងក្រៅសីមា កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ

សីមាតិក្កន្តិកោ ភវេ
អាទាយ យាតិ បច្ចេស្សំ
ពហិ ករោតិ ចីវរំ
កតចីវរោ បច្ចេស្សំ
សម្ភោតិ នាបច្ចេស្សំ
អស្ស តំ នាបិន្ទានេ
សហ ភិក្ខុហិ ជាយតិ
អាទាយ ច សមាទាយ
សត្ត សត្ត វិធា ភវេ
បក្កមនន្តិកា ឆក្កំ
ជាតេ វិប្បកតេ[1] ឥតិ
អាទាយ ចិស្សន្ទនំ
ករោតស្សំ ឥតិ ជាយតិ
និដ្ឋានំ សន្និដ្ឋានញ្ច
នាសនញ្ច ឥមេ តយោ

---

[1] ឱ. ឆញ្ញ វិប្បកតេ ។



ត្រូវកន្លងទៅក្រៅសីមាជាកំណាត់ ភិក្ខុនាំយកចីវរចៀសចេញ ទៅ ដោយគិតថា គង់អាត្មាអញនឹងត្រឡប់វិញ ក៏ធ្វើចីវរ (នោះ) ខាងក្រៅសីមា លុះធ្វើចីវររួចហើយក៏មានគំនិត ថា អាត្មាអញនឹងត្រឡប់វិញ ហើយក៏បានមកដល់វេលាដោះ កឋិនខាងក្រៅ កឋិនរបស់ភិក្ខុនោះឈ្មោះថា ដោះ ជាមួយនឹង ភិក្ខុទាំងឡាយ គួររៀនការដាយនឹងសមាទាយ (ទាំង២នេះ) មានប្រការ ៧ ៗ ដំណើរគួររៀនដែលភិក្ខុធ្វើចីវរមិនទាន់ ស្រេច ៦ ប្រការ គឺការដោះកឋិនត្រូវចៀសចេញទៅជា កំណាត់ ១ ការដោះកឋិនត្រូវធ្វើចីវរស្រេច ១ ត្រូវសេចក្ដី សន្និដ្ឋានជាកំណាត់ ១ ត្រូវចីវរវិនាសជាកំណាត់ ១ ទាំង ៣ នេះកើតដោយភិក្ខុនាំយក (ចីវរចៀសចេញទៅ) ខាងក្រៅសីមាហើយមានគំនិតថា អាត្មាអញនឹងធ្វើ (ចីវរ)

អាទាយ ច បក្កមតិ

ពហិសីមេ ករោមិតិ

និដ្ឋានំ សន្និដ្ឋានម្បិ

នាសនម្បិ សវនន្តិយោ

អនធិដ្ឋិតេន នេវស្ស

ហេដ្ឋា តីណិ នយា វិធី

អាទាយ យាតិ បច្ចស្ស

ពហិសីមេ ករោមិតិ

ច បក្កមតិ ការេតិ

និដ្ឋានេ នេមិច្ចុកេ

សន្និដ្ឋានំ នាសនញ្ច

សវនំ សីមតិក្កមា

សហ ភិក្ខូហិ ជាយេថ





កថានេះ និដ្ឋានន្តិកា សន្និដ្ឋានន្តិកា នាសនន្តិកា តាំងពីនេះថា ភិក្ខុនាំយក (ចីវរទៅសាចញ្ចូលនេះ) ដោយបំណងថា អាត្មាអញនឹងមិនត្រឡប់វិញ អាត្មាអញនឹងធ្វើចីវរនៅក្រៅសីមា រឿងនេះ[illegible]តែ ៧ ដែលមានកះទាំងនោះក្រោយថា (ភិក្ខុនាំយកចីវរទៅសាចញ្ចូលទៅ) ដោយមិនបានតាំងចិត្ត គឺភិក្ខុនោះមិនបានគិតថា (អាត្មាអញនឹងត្រឡប់វិញ ឬមិនត្រឡប់វិញទេ) ការដោះកឋិនត្រូវដោយកិរិយាសម្រេចធ្វើជាកំណត់ ១ ត្រូវសេចក្តីសន្និដ្ឋានជាកំណត់ ១ ត្រូវចីវរវិនាសជាកំណត់ ១ ត្រូវឮដំណឹងជាកំណត់ ១ ត្រូវកន្លងសីមាក្រៅកឋិនជាកំណត់ ១ ដោះជាមួយនឹងភិក្ខុទាំងឡាយ ១ (ការទី ៦ នេះ) ថា ភិក្ខុកាន់យក(ចីវរ)ទៅសាចញ្ចូលទៅដោយបំណងថា អាត្មាអញនឹងត្រឡប់វិញ អាត្មាអញនឹងធ្វើចីវរនៅក្រៅសីមា (លុះកិច្ចនោះធ្វើ) ក៏គិតថា អាត្មាអញនឹងមិនត្រឡប់វិញ ហើយក៏ធ្វើចីវរឲ្យសម្រេច

ឥទំ បណ្ណរសំ គតំ
សមានាយ វិប្បកតា
សមានាយ បុនា កតា
ទ្វេ តេ ចតុរោ ភវា
សព្វេ បណ្ណរសា ឥមេ
អសមានាយ ច សមានាយ
ការណិយោ ច តេ តយោ
ឆយតោ តំ វិជានេយ្យ
តយោ ទ្វាទស ទ្វាទស
អបរិលាយមានេ[១]
ចាតុ បញ្ចវីសំ តយោ
បលិពោធាបលិពោធា
ឆុព្ភាសំ ឆយតោ ការតុ្គ ។

១ ម. អបលិទ្ធតា ខេត្ត ។



ហៅជ័យនេះជាតក់មាន ១៨ ប្រការ រឿងកិច្ចប្រមូលយកចីវរ
ដែលធ្វើមិនទាន់ស្រេច និងប្រមូលយកចីវរ ដែលធ្វើស្រេច
ដូចគ្នា ការតាំងនៃនេះមួយតាំងអស់ត្រូវជា ១៨ ប្រការ រឿង
តាំង ៣ នោះ គឺធ្មចីវរនុងបំណង ១ ធ្មចីវរត្រូវបំណង ១
កិច្ចដែលត្រូវធ្វើ ១ មណ្ឌលគលប្បិជ័យរឿងនោះ ដោយទិយចា
មានដប់តែ ៣ ដង រឿងសេចក្តីមិនខ្វល់ខ្វាយ (ក្នុងចីវរ)
មាន ៩ ប្រការ រឿងកិច្ចដោយសុខសប្បាយមាន ៩ ប្រការ
រឿងបលិពោធទំនឹងអបលិពោធ ក្នុងកឋិន ទីចីវរនោះ ១
ឯកវ្វាន (នៃកឋិនក្ខន្ធកៈនេះ) រមើលដូចត្រូវហើយ ដោយ
ន័យ (ដូចពោលមកហើយនេះឯង) ។

# ចីវរក្ខន្ធកំ

[៣៤] តេន សមយេន ពុទ្ធោ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន វេសាលី ឥទ្ធា ចេវ ហោតិ ផីតា ច ពហុជនា អាកិណ្ណមនុស្សា សុភិក្ខា ច សត្ត ច បាសាទសហស្សានិ សត្ត ច បាសាទសតានិ សត្ត ច បាសាទា សត្ត ច កូដាគារសហស្សានិ សត្ត ច កូដាគារសតានិ សត្ត ច កូដាគារានិ សត្ត ច អារាមសហស្សានិ សត្ត ច អារាមសតានិ សត្ត ច អារាមា សត្ត ច បោក្ខរណីសហស្សានិ សត្ត ច បោក្ខរណីសតានិ សត្ត ច បោក្ខរណិយោ អម្ពបាលី ច គណិកា អភិរូបា ហោតិ ទស្សនីយា បាសាទិកា បរមាយ វណ្ណបោក្ខរតាយ សមន្នាគតា បទក្ខិណា នច្ចេ ច គីតេ ច វាទិតេ ច អភិសដា អត្ថិកានំ អត្ថិកានំ មនុស្សានំ បញ្ញាសាយ ច រត្តឹ គច្ឆតិ ។ តាយ ច វេសាលី ភិយ្យោសោ មត្តាយ ឧបសោភតិ ។ អថខោ រាជគហកោ

# ចីវរក្ខន្ធកៈ

[៣៤] សម័យនោះ ព្រះពុទ្ធមានព្រះភាគ គង់នៅក្នុងវេឡុវ័ន កលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ សម័យនោះឯង ក្រុងវេសាលី ក៏ស្តុកស្តម្ភទូលាយ មានជនច្រើន មានមនុស្សម៉ឹកដង់ផាស មានអាហារ ផុះកំពូល ចំណីក៏សម្បូណ៌ មានប្រាសាទ ៧ពាន់ ៧រយ ៧ប្រាសាទ មានផ្ទះកំពូល ៧ពាន់ ៧រយ ៧ផ្ទះ មានសួនច្បារ ៧ពាន់ ៧រយ ៧សួនច្បារ មានស្រះបោក្ខរណី ៧ពាន់ ៧រយ ៧ស្រះ ក៏មានស្រីគណិកា (ម្នាក់) ឈ្មោះអម្ពបាលី រូបល្អគួរជាទីពិតពិលមើលមើល ជាទីនាំឲ្យកើតសេចក្តីជ្រះថ្លា ប្រកបដោយសម្បុរល្អ ទីដ៏ជាទីគាប់ចិត្តរបស់ជនពន់ពេក ហើយជាស្រីប្រសប់ ក្នុងការល្បែងរាំច្រៀងនិងការប្រគុំភ្លេង ជាស្រីដែលពួកមនុស្ស ត្រូវការរាំទីជុំនាំ តែងចូលទៅរកច្រើន ឯនាង (នោះ) ទៅក្នុងមួយយប់ៗ (កៃដ៏យកថ្លៃ) ៥០ កហាបណៈ ។ ឯក្រុងវេសាលីសោភ ល្អដ៏ក្រៃលែងលុបប្រមាណ ព្រោះនាងអម្ពបាលីនោះ ។ គ្រានោះ មានពួកកុដុម្ពីនៅក្រុងរាជគ្រឹះ

នេគមោ វេសាលឹ អគមាសិ កេនចិទេវ ករណីយេន ។ អទ្ទសា ខោ រាជគហកោ នេគមោ វេសាលឹ ឥទ្ធញ្ច ផីតញ្ច ពហុជនំ អាកិណ្ណមនុស្សំ សុភិក្ខញ្ច សត្ត ច បាសាទសហស្សានិ សត្ត ច បាសាទសតានិ សត្ត ច បាសាទេ សត្ត ច កូដាគារសហស្សានិ សត្ត ច កូដាគារសតានិ សត្ត ច កូដាគារានិ សត្ត ច អារាមសហស្សានិ សត្ត ច អារាមសតានិ សត្ត ច អារាមេ សត្ត ច បោក្ខរណីសហស្សានិ សត្ត ច បោក្ខរណីសតានិ សត្ត ច បោក្ខរណិយោ អម្ពបាលិញ្ច គណិកំ អភិរូបំ ទស្សនីយំ បាសាទិកំ បរមាយ វណ្ណបោក្ខរតាយ សមន្នាគតំ បទក្ខំ នច្ចេ ច គីតេ ច វាទិតេ ច អភិសដំ អត្ថិកានំ អត្ថិកានំ មនុស្សានំ បញ្ញាសាយ ច រត្តឹ គច្ឆន្តឹ តាយ ច វេសាលឹ ភិយ្យោសោ មត្តាយ ឧបសោភន្តឹ[១] ។ អថ ខោ រាជគហកោ នេគមោ វេសាលិយំ តំ ករណីយំ តីរេត្វា

១ ឱ. ឧបសោភិតន្តិ ។



បានទៅក្រុងវេសាលី ដោយមានកិច្ចណាមួយ ។ ពួកកុដុម្ពីនៅក្រុងរាជគ្រឹះ ក៏បានឃើញក្រុងវេសាលីស្តុកស្តម្ភទូលាយ មានជនច្រើន មានមនុស្សដើរដេរដាស មានភោជនាហារបរិបូណ៌ មានប្រាសាទ ៧ ពាន់ ៧ រយ ៧ ប្រាសាទ មានផ្ទះកំពូល ៧ ពាន់ ៧ រយ ៧ ផ្ទះ មានសួនច្បារ ៧ ពាន់ ៧ រយ ៧ សួនច្បារ មានស្រះបោក្ខរណី ៧ ពាន់ ៧ រយ ៧ ស្រះ ហើយមានស្រីផ្កាមាសម្នាក់ឈ្មោះអម្ពបាលី រូបល្អគួរជាទីពិតពិល រមិលមើល គាប់ចិត្តគួរសេចក្តីជ្រះថ្លា ប្រកបដោយសម្បុរល្អ ដ៏ជាទីគាប់ចិត្តរបស់ជនឆាត់ឆក ហើយប្រសប់ក្នុងការល្បួង រាំច្រៀងប្រគំ ជាស្រីដែលពួកមនុស្សអ្នកត្រូវការនាំគ្នាទៅរកច្រើន ឯតម្លៃនាងនោះមួយយប់ ១ យប់ (យកថ្លៃ) ៥០ កហាបណៈ ឯក្រុងវេសាលី ក៏ជាទីរុងរឿងលើសប្រមាណ ព្រោះនាងអម្ពបាលីនោះ ។ វេលានោះ ពួកកុដុម្ពីនៅក្រុងរាជគ្រឹះ បានសម្រេចនូវកិច្ចដែលខ្លួនត្រូវធ្វើនោះ ក្នុងក្រុងវេសាលីរួចហើយ ក៏ត្រឡប់មក

បុនទេវ រាជគហំ បច្ចាគច្ឆិ យេន រាជា មាគធោ សេ-
និយោ ពិម្ពិសារោ តេនុបសង្កមិ ឧបសង្កមិត្វា រាជានំ
មាគធំ សេនិយំ ពិម្ពិសារំ ឯតទវោច វេសាលី ទេវ ឥទ្ធា
ចេវ ផីតា ច ពហុជនា អាកិណ្ណមនុស្សា សុភិក្ខា ច
សត្ត ច បាសាទសហស្សានិ សត្ត ច បាសាទសតានិ
សត្ត ច បាសាទា សត្ត ច កូដាគារសហស្សានិ សត្ត
ច កូដាគារសតានិ សត្ត ច កូដាគារា សត្ត ច អារាម-
សហស្សានិ សត្ត ច អារាមសតានិ សត្ត ច អារាមា
សត្ត ច បោក្ខរណីសហស្សានិ សត្ត ច បោក្ខរណីស-
តានិ សត្ត ច បោក្ខរណិយោ អម្ពបាលី ច គណិកា
អភិរូបា ទស្សនីយា បាសាទិកា បរមាយ វណ្ណបោក្ខ-
រតាយ សមន្នាគតា បទក្ខិណា នច្ចេ ច គីតេ ច វាទិតេ ច
អភិសដា អត្ថិកានំ អត្ថិកានំ មនុស្សានំ បញ្ញាសា-
យ ច រត្តឹ គច្ឆតិ តាយ ច វេសាលី ភិយ្យោសោ
មត្តាយ ឧបសោភតិ សាធុ ទេវ មយំបិ គណិកំ
វុដ្ឋាបេយ្យាមាតិ ។ តេនហិ ភណេ តាទិសំ កុមារឹ
ជានាថ[១] យំ តុម្ហេ គណិកំ វុដ្ឋាបេយ្យាថាតិ ។

១ ម. ជានាហ ។



ក្រុងរាជគ្រឹះវិញ បានចូលទៅគាល់ព្រះបាទមាគធសេនិយពិម្ពិសារ លុះ
ចូលទៅដល់ហើយ ក៏ក្រាបបង្គំទូលព្រះបាទមាគធសេនិយពិម្ពិសារដូច្នេះ
ថា បពិត្រព្រះសម្មតិទេព ក្រុងវេសាលីក៏ស្តុកស្តម្ភទូលាយ មានជនច្រើន
មានពួកមនុស្សម៉ឺនដេរដាស មានអាហារបរិភោគសម្បូណ៌ មានប្រាសាទ ៧
ពាន់ ៧ រយ ៧ ប្រាសាទ មានផ្ទះកំពូល ៧ ពាន់ ៧ រយ ៧ ផ្ទះ មានសួនច្បារ ៧
ពាន់ ៧ រយ ៧ សួនច្បារ មានស្រះបោក្ខរណី ៧ ពាន់ ៧ រយ ៧ ស្រះ ទាំងមាន
ស្រីផ្កាមាស(ខ្ញាក់) ឈ្មោះអម្ពបាលី រូបល្អ គួរនឹងពិតពិលរមិលមើល គួរ
ឲ្យកើតសេចក្តីជ្រះថ្លា ហើយប្រកបដោយសម្បុរល្អ ដ៏ជាទីគាប់ចិត្តរបស់
ជនគ្រប់ពេក ហើយជាស្រីប្រសប់ក្នុងការរាំច្រៀងនិងដេញដំប្រគំ
ជាស្រីដែលពួកមនុស្សត្រូវការហើយបាន ក៏តែងចូលទៅរកច្រើន ឯនាង
(នោះ) នៅក្នុង ១ យប់ៗ យកថ្លៃ ៥០ កហាបណៈ ឯក្រុងវេសាលីល្អដោយ
ក្រៃលែងជាងប្រមាណ ព្រោះនាងអម្ពបាលីនោះ បពិត្រព្រះសម្មតិទេព
សូមទាំងយើងខ្ញុំតាំងស្រីផ្កាមាសឡើងខ្លះ ទើបជាការល្អ ។ ស្តេចនោះទ្រង់
ត្រាស់តបថា នែនាយ បើដូច្នោះអ្នកទាំងឡាយចូរជ្រើសរើសនាងកុមារី
ណាដែលមានរូបល្អប្រហែលនាងនោះ តាំងឲ្យជាស្រីផ្កាមាសឡើង ។

តេន ខោ បន សមយេន រាជគហេ សាលវតី នាម
កុមារី អភិរូបា ហោតិ ទស្សនីយា បាសាទិកា បរមាយ
វណ្ណបោក្ខរតាយ សមន្នាគតា ។ អថខោ រាជគហកោ
នេគមោ សាលវតឹ កុមារឹ គណិកំ វុដ្ឋាបេសិ ។ អថ-
ខោ សាលវតី គណិកា នចិរស្សេវ បទក្ខិណា អហោសិ
នច្ចេ ច គីតេ ច វាទិតេ ច អភិសដា អត្ថិកានំ
អត្ថិកានំ មនុស្សានំ បដិសតេន ច រត្តឹ គច្ឆតិ ។
អថខោ សាលវតី គណិកា នចិរស្សេវ គព្ភិនី អ-
ហោសិ ។ អថខោ សាលវតិយា គណិកាយ ឯតទ-
ហោសិ ឥត្ថី ខោ គព្ភិនី បុរិសានំ អមនាបា សចេ មំ
កោចិ ជានិស្សតិ សាលវតី គណិកា គព្ភិនីតិ សព្វោ
មេ សក្ការោ បរិហាយិស្សតិ[១] យន្នូនាហំ គិលានំ[២]
បដិវេទេយ្យន្តិ ។ អថខោ សាលវតី គណិកា ទោវារិកំ
អាណាបេសិ មា ភណេ ទោវារិក កោចិ បុរិសោ បាវិសិ
យោ ច មំ បុច្ឆតិ គិលានាតិ បដិវេទេហីតិ ។ ឯវំ
អយ្យេតិ ខោ សោ ទោវារិកោ សាលវតិយា គណិកាយ

១ ពីរក្បួនថា [illegible] ។ ២ ។ គិលានាតិ ។



សម័យនោះឯង ក្នុងក្រុងរាជគ្រឹះ មាននាងកុមារីម្នាក់ឈ្មោះសាលវតី រូបល្អ
គួរជាទីពិតពិលរមិលរមើល នាំឲ្យកើតសេចក្ដីជ្រះថ្លា ហើយប្រកបដោយ
សម្បុរល្អ ដ៏ជាទីគាប់ចិត្តរបស់ជនដទៃក្រៃពេក ។ វេលានោះ ពួកកុដុម្ពីនៅ
ក្រុងរាជគ្រឹះ ក៏ផ្ទងតាំងនាងសាលវតីកុមារីឲ្យធ្វើជាស្រីផ្កាមាស ។ គ្រា
នោះមិនយូរប៉ុន្មាន នាងសាលវតីស្រីផ្កាមាសក៏ជាស្រីប្រសប់ក្នុងការល្បែង
រាំច្រៀងនិងដេញដំប្រគំ ជាស្រីដែលពួកមនុស្សត្រូវការតាំងពីប៉ុន្មាននាក់នឹង
ចូលទៅរកច្រើន ឯនាងនោះទៅក្នុង ១ យប់ (យកថ្លៃ) ១០០ កហាបណៈ ។
លំដាប់នោះ នាងសាលវតីស្រីផ្កាមាសមិនយូរប៉ុន្មានក៏មានគភ៌ឡើង ។
វេលានោះ នាងសាលវតីស្រីផ្កាមាសមានសេចក្ដីត្រិះរិះដូច្នេះថា (មន្ត្រា)
ស្រីដែលមានគភ៌ហើយរមែងមិនជាទីគាប់ចិត្តរបស់ពួកបុរសឡើយ ប្រសិន
បើបុរសណាមួយនឹងដឹងថា នាងសាលវតីស្រីផ្កាមាសមានគភ៌
ហើយ គ្រឿងសក្ការៈ ទាំងអស់របស់អាត្មាអញនឹងសាបសូន្យ (មិនខាន)
បើដូច្នោះ គួរតែអញប្រាប់គេថាមានជម្ងឺ ។ គ្រានោះ នាងសាលវតីស្រី
ផ្កាមាសក៏បង្គាប់នាយទ្វារបាលថា នែនាយទ្វារ កុំឲ្យបុរសណាមួយចូល
មកឡើយ ចុះជនណាមកសួររកខ្ញុំ អ្នកឯងត្រូវប្រាប់ថា នាងសាលវតី
មានជម្ងឺ ។ នាយទ្វារនោះក៏បានទទួលពាក្យនាងសាលវតីស្រីផ្កាមាស

បដិវេទេសិ ។ អថខោ សាលវតី គណិកា តស្ស គព្ភស្ស បរិបាកមន្វាយ(១) បុត្តំ វិជាយិ ។ អថខោ សាលវតី គណិកា ទាសឹ អាណាបេសិ ហន្ទ ជេ ឥមំ ទារកំ កត្តរសុប្បេ បក្ខិបិត្វា នីហរិត្វា សង្ការកូដេ ឆឌ្ឌេហីតិ ។ ឯវំ អយ្យេតិ ខោ សា ទាសី សាលវតិយា គណិកាយ បដិស្សុណិត្វា តំ ទារកំ កត្តរសុប្បេ បក្ខិបិត្វា នីហរិត្វា សង្ការកូដេ ឆឌ្ឌេសិ ។ តេន ខោ បន សមយេន អភយោ នាម រាជកុមារោ កាលស្សេវ រាជុបដ្ឋានំ គច្ឆន្តោ អទ្ទស តំ ទារកំ កាកេហិ សម្បរិកិណ្ណំ ទិស្វាន មនុស្សេ បុច្ឆិ កិមេតំ ភណេ កាកេហិ សម្បរិកិណ្ណន្តិ ។ ទារកោ ទេវាតិ ។ ជីវតិ ភណេតិ ។ ជីវតិ ទេវាតិ ។ តេនហិ ភណេ តំ ទារកំ អម្ហាកំ អន្តេបុរំ នេត្វា ធាតីនំ ទេថ បោសេតុន្តិ ។ ឯវំ ទេវាតិ ខោ តេ មនុស្សា អភយស្ស រាជកុមារស្ស បដិស្សុណិត្វា តំ ទារកំ អភយស្ស រាជកុមារស្ស អន្តេបុរំ នេត្វា ធាតីនំ អទំសុ បោសេថាតិ ។

១ ម. បរិបាកំ គព្ភាយ ។



ដោយពាក្យថា ឈឺណាស់ ។ លំដាប់នោះ នាងសាលវតីស្រីគណិកា លុះដល់គភ៌នោះចាស់ហើយ ក៏សម្រាលកូនប្រុស ១ មក ។ វេលានោះ នាងសាលវតីស្រីគណិកាបង្គាប់ខ្ញុំស្រីថា នែនាង ហ៏ នាងឯងចូរដាក់ទារកនេះក្នុងចង្អេរចាស់ហើយនាំយកទៅចោលលើគំនរសម្រាមចុះ ។ ខ្ញុំស្រីនោះបានទទួលស្តាប់ពាក្យនាងសាលវតីស្រីគណិកាដោយពាក្យថា ចាស អ្នកម្ចាស់ ហើយក៏ដាក់ទារកនោះក្នុងចង្អេរចាស់ហើយនាំយកទៅចោលលើគំនរសម្រាម ។ សម័យនោះឯង ព្រះរាជកុមារឈ្មោះអភយៈចេញទៅកាន់បម្រើស្តេចក្នុងវេលាព្រឹក ក៏បានឃើញទារកនោះមានពួកសត្វក្អែកចោមរោម លុះឃើញហើយក៏សួរពួកមនុស្សទាំងឡាយថា នែនាយ អ្វីនេះដែលពួកក្អែកចោមរោម ។ មនុស្សទាំងនោះក្រាបបង្គំទូលថា សូមទ្រង់មេត្តាប្រោស ទារក ។ រាជកុមារត្រាស់សួរថា នែនាយ ទារកនេះនៅរស់ទេឬ ។ មនុស្សទាំងនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស នៅរស់ទេ ។ រាជកុមារក៏ត្រាស់ថា នែនាយ បើដូច្នោះ អ្នកទាំងឡាយចូរនាំយកទារកនោះទៅក្នុងព្រះរាជវាំងយើង ហើយប្រគល់ឲ្យពួកស្រីមេដោះចិញ្ចឹម ។ មនុស្សទាំងនោះបានទទួលពាក្យអភយរាជកុមារដោយពាក្យថា បពិត្រព្រះសម្មតិទេព ករុណាវិសេស ក៏នាំយកទារកនោះទៅក្នុងព្រះរាជវាំងរបស់អភយរាជកុមារ ហើយប្រគល់ឲ្យទៅពួកស្រីមេដោះថា នាងទាំងឡាយចូរចិញ្ចឹមចុះ ។

តស្ស ជីវតីតិ ជីវកោតិ នាមំ អកំសុ កុមារេន បោសាបិតោតិ កោមារភច្ចោតិ នាមំ អកំសុ ។ អថ ខោ ជីវកោ កោមារភច្ចោ ន ចិរស្សេវ វិញ្ញុតំ បាបុណិ ។ អថ ខោ ជីវកោ កោមារភច្ចោ យេន អភយោ រាជកុមារោ តេនុបសង្កមិ ឧបសង្កមិត្វា អភយំ រាជកុមារំ ឯតទវោច កា មេ ទេវ មាតា កោ បិតាតិ ។ អហម្បិ ខោ តេ ភណេ ជីវក មាតរំ ន ជានាមិ អបិចាហំ តេ បិតា ត្វំ[១] មយាសិ បោសាបិតោតិ ។ អថ ខោ ជីវកស្ស កោមារភច្ចស្ស ឯតទហោសិ ឥមានិ ខោ រាជកុលានិ ន សុករានិ អសិប្បេន ឧបជីវិតុំ យន្នូនាហំ សិប្បំ សិក្ខេយ្យន្តិ ។

[៣៨] តេន ខោ បន សមយេន តក្កសិលាយំ ទិសាបាមោក្ខោ វេជ្ជោ បដិវសតិ ។ អថ ខោ ជីវកោ កោមារភច្ចោ អភយំ រាជកុមារំ អនាបុច្ឆា យេន តក្កសិលា តេន បក្កាមិ អនុបុព្វេន យេន តក្កសិលា យេន វេជ្ជោ តេនុបសង្កមិ ឧបសង្កមិត្វា តំ

១ ឧភយនិយមបោត្ថកេ អយំ បាឋោ ន ទិស្សតិ ។



ជនទាំងឡាយបានឲ្យឈ្មោះកុមារនោះថា ជីវកៈ ដោយហេតុថា កុមារនោះនៅរស់ ឲ្យឈ្មោះកុមារនោះ (ថែមទៀត) ថា កោមារភច្ច ព្រោះថាកុមារនោះអភយរាជកុមារបានឲ្យគេរើសយកមកចិញ្ចឹម ។ គ្រានោះ ជីវកកោមារភច្ចមិនយូរប៉ុន្មានក៏បានជាអ្នកដឹងក្ដីឡើង ។ វេលានោះ ជីវកកោមារភច្ចបានចូលទៅគាល់អភយរាជកុមារ លុះចូលទៅដល់ហើយបានក្រាបបង្គំទូលអភយរាជកុមារដូច្នេះថា បពិត្រព្រះសម្មតិទេព អ្នកណាជាមាតារបស់ខ្ញុំ អ្នកណាជាបិតារបស់ខ្ញុំ ។ អភយរាជកុមារតបថា ហៃឪជីវកៈ ទុកជាអញក៏មិនបានស្គាល់មាតារបស់អ្នកដែរ ប៉ុន្តែខ្លួនអញនុ៎ះហ្នឹងជាបិតារបស់អ្នក (ព្រោះ) អ្នកឯងអញបានឲ្យគេយកមកចិញ្ចឹម ។ លំដាប់នោះ ជីវកកោមារភច្ចមានសេចក្ដីត្រិះរិះដូច្នេះថា ក្នុងរាជត្រកូលនេះ តែបុគ្គលគ្មានសិល្បសាស្ត្រ ហើយមិនងាយនឹងចិញ្ចឹមជីវិតបានទេ បើដូច្នោះមានតែអាត្មាអញគួររៀនសិល្បសាស្ត្រ ។

[៣៨] សម័យនោះឯង មានពេទ្យម្នាក់ជាទិសាបាមោក្ខ នៅអាស្រ័យក្នុងក្រុងតក្កសិលា ។ វេលានោះ ជីវកកោមារភច្ចមិនបានលាអភយរាជកុមារឡើយ ហើយចេញដំណើរទៅកាន់ក្រុងតក្កសិលា ក៏បានចូលទៅរកពេទ្យនោះឯក្រុងតក្កសិលាដោយលំដាប់ លុះចូលទៅដល់

វេជ្ជំ ឯតទវោច ឥច្ឆាមហំ អាចរិយ សិប្បំ សិក្ខិតុន្តិ ។ តេនហិ ភណេ ជីវក សិក្ខស្សូតិ ។ អថខោ ជីវកោ កោមារភច្ចោ ពហុញ្ច គណ្ហាតិ លហុញ្ច គណ្ហាតិ សុដ្ឋុ(១) ច ឧបធារេតិ គហិតញ្ចស្ស ន បមុស្សតិ ។ អថខោ ជីវកស្ស កោមារភច្ចស្ស សត្តន្នំ វស្សានំ អច្ចយេន ឯតទហោសិ អហំ ខោ ពហុញ្ច គណ្ហាមិ លហុញ្ច គណ្ហាមិ សុដ្ឋុ ច ឧបធារេមិ គហិតញ្ច មេ ន បមុស្សតិ សត្ត ច មេ វស្សានិ អធីយន្តស្ស នយិមស្ស សិប្បស្ស អន្តោ បញ្ញាយតិ កទា ឥមស្ស សិប្បស្ស អន្តោ បញ្ញាយិស្សតីតិ ។ អថខោ ជីវកោ កោមារភច្ចោ យេន សោ វេជ្ជោ តេនុបសង្កមិ ឧបសង្កមិត្វា តំ វេជ្ជំ ឯតទវោច អហំ ខោ អាចរិយ ពហុញ្ច គណ្ហាមិ លហុញ្ច គណ្ហាមិ សុដ្ឋុ ច ឧបធារេមិ គហិតញ្ច មេ ន បមុស្សតិ សត្ត ច មេ វស្សានិ អធីយន្តស្ស នយិមស្ស សិប្បស្ស អន្តោ បញ្ញាយតិ

១ ឱ. សុដ្ឋុ ។



ហើយក៏និយាយពាក្យនេះនឹងពេទ្យនោះថា បពិត្រលោកអាចារ្យ ខ្ញុំប្រាថ្នានឹងសិក្សាសិល្បសាស្ត្រ ។ អាចារ្យពេទ្យនោះក៏តបវិញថា នែនាយជីវកៈ បើដូច្នោះអ្នកឯងចូររៀនចុះ ។ វេលានោះ ជីវកកោមារភច្ចក៏រៀនសិល្បសាស្ត្របានច្រើនផង រៀនបានឆាប់ផង ចាំទុកបានល្អផង សិល្បសាស្ត្រដែលជីវកកោមារភច្ចនោះបានរៀនហើយក៏មិនភ្លេចទៅផង ។ លុះកន្លង ៧ ឆ្នាំទៅហើយ ទើបជីវកកោមារភច្ចមានសេចក្តីរិះគិតដូច្នេះថា អាត្មាអញរៀនសិល្បសាស្ត្របានច្រើនផង រៀនបានឆាប់ផង ចាំទុកបានល្អផង សិល្បសាស្ត្រដែលអញបានរៀនហើយក៏មិនភ្លេចទៅផង ម្យ៉ាងទៀត កាលអាត្មាអញរៀនអស់ ៧ ឆ្នាំហើយ ក៏រកទីបំផុតសិល្បសាស្ត្រនេះមិនប្រាកដឡើយ ទីបំផុតសិល្បសាស្ត្រនេះតើនឹងបានប្រាកដក្នុងវេលាណា ។ លំដាប់នោះ ជីវកកោមារភច្ចក៏បានចូលទៅរកពេទ្យនោះ លុះចូលទៅដល់ហើយក៏និយាយពាក្យនេះនឹងពេទ្យនោះថា បពិត្រលោកអាចារ្យ ខ្ញុំរៀនសិល្បសាស្ត្របានច្រើនផង រៀនបានឆាប់ផង ចាំទុកបានល្អផង សិល្បសាស្ត្រដែលខ្ញុំបានរៀនហើយមិនភ្លេចទៅវិញផង ម្យ៉ាងទៀត ខ្ញុំរៀនអស់ ៧ ឆ្នាំហើយ ក៏រកទីបំផុតសិល្បសាស្ត្រនេះមិនប្រាកដសោះ ទីបំផុត

កទា ឥមស្ស សិប្បស្ស អន្តោ បញ្ញាយិស្សតីតិ ។ តេនហិ ភណេ ជីវក ខណិត្តឹ អាទាយ តក្កសិលាយ សមន្តា យោជនំ អាហិណ្ឌិត្វា(១) យំ កិញ្ចិ អភេសជ្ជំ បស្សេយ្យាសិ តំ អាហរាតិ ។ ឯវំ អាចរិយាតិ ខោ ជីវកោ កោមារភច្ចោ តស្ស វេជ្ជស្ស បដិស្សុណិត្វា ខណិត្តឹ អាទាយ តក្កសិលាយ សមន្តា យោជនំ អាហិណ្ឌន្តោ ន កិញ្ចិ អភេសជ្ជំ អទ្ទស ។ អថខោ ជីវកោ កោមារភច្ចោ យេន សោ វេជ្ជោ តេនុបសង្កមិ ឧបសង្កមិត្វា តំ វេជ្ជំ ឯតទវោច អាហិណ្ឌន្តោម្ហិ អាចរិយ តក្កសិលាយ សមន្តា យោជនំ ន កិញ្ចិ អភេសជ្ជំ អទ្ទសន្តិ ។ សុសិក្ខិតោសិ ភណេ ជីវក អលន្តេ ឯត្តកំ ជីវិកាយាតិ ជីវកស្ស កោមារភច្ចស្ស បរិត្តំ បាថេយ្យំ បាទាសិ ។ អថខោ ជីវកោ កោមារភច្ចោ តំ បរិត្តំ បាថេយ្យំ អាទាយ យេន រាជគហំ តេន បក្កាមិ ។ អថខោ ជីវកស្ស កោមារភច្ចស្ស តំ បរិត្តំ បាថេយ្យំ អន្តរាមគ្គេ សាកេតេ បរិក្ខយំ អគមាសិ ។ អថខោ ជីវកស្ស កោមារភច្ចស្ស

១ ឱ. អាហិណ្ឌន្តោ ។



សិល្បសាស្ត្រនេះតើនឹងបានច្បាស់ក្នុងកាលណា ។ ឯអាចារ្យនោះក៏ប្រាប់ថា នែនាយជីវកៈ បើដូច្នោះអ្នកឯងចូរកាន់យកចបជីកដើរទៅចំនួន ១ យោជន៍ជុំវិញក្រុងតក្កសិលា ហើយគន់មើលវត្ថុឯណាមួយដែលមិនមែនជាថ្នាំ ចូរអ្នកនាំវត្ថុនោះមក ។ ឯជីវកកោមារភច្ចទទួលស្តាប់ពាក្យពេទ្យនោះដោយពាក្យថា បាទ លោកអាចារ្យ ហើយក៏កាន់ចបជីកដើរទៅចំនួន ១ យោជន៍ជុំវិញក្រុងតក្កសិលា ក៏មិនឃើញមានវត្ថុមួយដែលមិនមែនជាថ្នាំឡើយ ។ គ្រានោះ ជីវកកោមារភច្ចក៏បានចូលទៅរកពេទ្យនោះវិញ លុះចូលទៅដល់ហើយក៏បាននិយាយពាក្យនេះនឹងពេទ្យនោះថា បពិត្រលោកអាចារ្យ ខ្ញុំបានដើរទៅចំនួន ១ យោជន៍ជុំវិញក្រុងតក្កសិលា ក៏មិនឃើញមានវត្ថុអ្វីមួយដែលមិនមែនជាថ្នាំសោះ ។ ឯអាចារ្យនោះក៏និយាយថា នែនាយជីវកៈ អ្នកឯងរៀនបានចេះ[ល្អ]ហើយ សិល្បសាស្ត្រប៉ុណ្ណេះល្មមចិញ្ចឹមជីវិតរបស់អ្នកឯងបានហើយ ។ ក៏ប្រគល់ស្បៀងបន្តិចបន្តួចឲ្យជីវកកោមារភច្ច ។ លំដាប់នោះ ជីវកកោមារភច្ចក៏បាននាំយកស្បៀងបន្តិចបន្តួចនោះចេញដើរសំដៅទៅក្រុងរាជគ្រឹះវិញ ។ វេលានោះ ស្បៀងបន្តិចបន្តួចរបស់ជីវកកោមារភច្ចនោះ ក៏អស់រលីងទៅត្រង់ក្រុងសាកេត នៅពាក់កណ្ដាលផ្លូវ ។ គ្រានោះ ជីវកកោមារភច្ចក៏មាន

ឯវំ ហោសិ ឥមេ ខោ មគ្គា កន្តារា អប្បោទកា អប្បភក្ខា ន សុករា អបាថេយ្យេន គន្តុំ យន្នូនាហំ បាថេយ្យំ បរិយេសេយ្យន្តិ ។

(៣៦) តេន ខោ បន សមយេន សាកេតេ សេដ្ឋិភរិយាយ សត្តវស្សិកោ សីសាពាធោ ហោតិ ។ ពហូ មហន្តា មហន្តា ទិសាបាមោក្ខា វេជ្ជា អាគន្ត្វា នាសក្ខិំសុ អរោគំ កាតុំ ពហុំ ហិរញ្ញំ អា-ទាយ អគមំសុ ។ អថខោ ជីវកោ កោមារភច្ចោ សាកេតំ បវិសិត្វា មនុស្សេ បុច្ឆិ កោ ភណេ គិលា-នោ កំ តិកិច្ឆាមីតិ ។ ឯតិស្សា អាចរិយ សេដ្ឋិភរិយា-យ សត្តវស្សិកោ សីសាពាធោ គច្ឆ អាចរិយ សេដ្ឋិ-ភរិយំ តិកិច្ឆាហីតិ ។ អថខោ ជីវកោ កោមារភច្ចោ យេន សេដ្ឋិស្ស គហបតិស្ស និវេសនំ តេនុបសង្កមិ ឧប-សង្កមិត្វា ទោវារិកំ អាណាបេសិ គច្ឆ ភណេ ទោវារិក សេដ្ឋិភរិយាយ បាវទ វេជ្ជោ អយ្យេ អាគតោ សោ តំ ទដ្ឋុកាមោតិ ។ ឯវមាចរិយាតិ ខោ សោ ទោវារិកោ ជីវកស្ស កោមារភច្ចស្ស បដិស្សុណិត្វា យេន សេដ្ឋិ-



សេចក្តីរិះគិតដូច្នេះថា ផ្លូវទាំងនេះជាផ្លូវដាច់ស្រយាល មានទឹកតិច មានចំណីអាហារតិច ជនណាដែលមិនមានស្បៀងអាហារហើយមិនងាយនឹងទៅបានឡើយ បើដូច្នោះ គួរតែអាត្មាអញស្វែងរកស្បៀងសិន (រូបសំពៅ) ។

(៣៦) សម័យនោះឯង ក្នុងក្រុងសាកេត មានភរិយាសេដ្ឋីម្នាក់ កើតជម្ងឺឈឺក្បាល ៧ ឆ្នាំហើយ ។ ពួកពេទ្យដែលជាទិសាបាមោក្ខយ៉ាងធំៗច្រើននាក់នាំគ្នាមកព្យាបាល ក៏មិនអាចធ្វើឲ្យជាសះស្បើយបាន ហើយនាំយកប្រាក់ទៅជាច្រើន ។ គ្រានោះ ជីវកកោមារភច្ចបានចូលទៅក្រុងសាកេត ហើយសួរមនុស្សទាំងឡាយថា នែនាយ ជនណាមានជម្ងឺ (នុះ) ជនណាឲ្យខ្ញុំព្យាបាល (នុះ) ។ មនុស្សទាំងនោះប្រាប់ថា បពិត្រលោកអាចារ្យ មានតែភរិយាសេដ្ឋីនេះមានជម្ងឺឈឺក្នុងក្បាល ៧ ឆ្នាំហើយ បពិត្រលោកអាចារ្យ អញ្ជើញទៅព្យាបាលភរិយាសេដ្ឋីចុះ ។ វេលានោះ ជីវកកោមារភច្ចក៏បានចូលទៅកាន់លំនៅរបស់សេដ្ឋីគហបតី លុះចូលទៅដល់ហើយក៏បង្គាប់នាយទ្វារថា នែនាយទ្វារ ចូរអ្នកឯងទៅជំរាបភរិយាសេដ្ឋីថា បពិត្រអ្នកម្ចាស់ ឥឡូវមានគ្រូពេទ្យអញ្ជើញមក គាត់ចង់ឃើញអ្នកម្ចាស់ ។ នាយទ្វារនោះបានទទួលស្តាប់ពាក្យជីវកកោមារភច្ច ដោយពាក្យថា បាទលោកអាចារ្យ ហើយក៏ចូលទៅរកភរិយាសេដ្ឋី

ភរិយា តេនុបសង្កមិ ឧបសង្កមិត្វា សេដ្ឋិភរិយំ ឯតទ-
វោច វេជ្ជោ អយ្យេ អាគតោ សោ តំ ទដ្ឋុកាមោតិ ។
កីទិសោ ភណេ ទោវារិក វេជ្ជោតិ ។ ទហរកោ
អយ្យេតិ ។ អលំ ភណេ ទោវារិក កឹ មេ ទហរកោ
វេជ្ជោ ករិស្សតិ ពហូ មហន្តា មហន្តា ទិសាបាមោក្ខា
វេជ្ជា អាគន្ត្វា នាសក្ខឹសុ អរោគំ កាតុំ ពហុំ
ហិរញ្ញំ អាទាយ គច្ឆន្តីតិ ។ អថខោ សោ ទោវារិកោ
យេន ជីវកោ កោមារភច្ចោ តេនុបសង្កមិ ឧបសង្ក-
មិត្វា ជីវកំ កោមារភច្ចំ ឯតទវោច សេដ្ឋិភរិយា អា-
ចរិយ ឯវមាហ អលំ ភណេ ទោវារិក កឹ មេ ទហ-
រកោ វេជ្ជោ ករិស្សតិ ពហូ មហន្តា មហន្តា ទិសាបា-
មោក្ខា វេជ្ជា អាគន្ត្វា នាសក្ខឹសុ អរោគំ
កាតុំ ពហុំ ហិរញ្ញំ អាទាយ គច្ឆន្តីតិ ។ គច្ឆ ភណេ
ទោវារិក សេដ្ឋិភរិយំ ឯវំ វទេហិ វេជ្ជោ អយ្យេ ឯវមា-
ហ មា កិរ អយ្យេ បុរេ កិញ្ចិ អទាសិ យទា អរោគា
អហោសិ តទា យំ ឥច្ឆេយ្យាសិ តំ ទជ្ជេយ្យាសីតិ ។
ឯវំ អាចរិយាតិ ខោ សោ ទោវារិកោ ជីវកស្ស



លុះចូលទៅដល់ហើយ ក៏បាននិយាយពាក្យនេះនឹងភរិយាសេដ្ឋីថា បពិត្រ
អ្នកម្ចាស់ ឥឡូវនេះមានគ្រូពេទ្យអញ្ជើញមក គាត់ចង់ឃើញអ្នកម្ចាស់ ។ ឯ
ភរិយាសេដ្ឋីក៏សួរថា នែនាយទ្វារ គ្រូពេទ្យនោះតើបែបយ៉ាងណា ។ នាយ
ទ្វារឆ្លើយថា បពិត្រអ្នកម្ចាស់ គ្រូពេទ្យនោះនៅក្មេងទេ ។ ឯភរិយាសេដ្ឋី
ក៏តបថា កុំឡើយនាយទ្វារ គ្រូពេទ្យនៅក្មេងម្តេចនឹងធ្វើរោគអញឲ្យជាម្តេច
បាន គ្រូពេទ្យដែលជាទិសាបាមោក្ខយ៉ាងធំៗ ច្រើននាក់ក៏បានមកព្យា-
បាលហើយ ក៏គង់មិនអាចនឹងធ្វើរោគឲ្យសះជាបាន នាំយកប្រាក់ជាច្រើន
ទៅហើយ ។ គ្រានោះ នាយទ្វារក៏បានចូលទៅរកជីវកកោមារភច្ច
វិញ លុះចូលទៅដល់ហើយក៏បាននិយាយពាក្យនេះនឹងជីវកកោមារភច្ចថា
បពិត្រលោកអាចារ្យ ភរិយាសេដ្ឋីបាននិយាយយ៉ាងនេះថា កុំឡើយនាយ
ទ្វារ គ្រូពេទ្យនៅក្មេងម្តេចនឹងព្យាបាលរោគអញឲ្យសះជាម្តេចបាន គ្រូពេទ្យ
ដែលជាទិសាបាមោក្ខធំៗ ច្រើននាក់បានមកព្យាបាលក៏គង់មិនអាចនឹងធ្វើ
រោគឲ្យសះជាបាន នាំយកប្រាក់ជាច្រើនទៅហើយ ។ ឯជីវកកោមារភច្ចក៏
និយាយវិញថា នែនាយទ្វារ ចូរអ្នកឯងទៅនិយាយនឹងភរិយាសេដ្ឋីថា បពិត្រអ្នក
ម្ចាស់ គ្រូពេទ្យបាននិយាយពាក្យយ៉ាងនេះថា បពិត្រអ្នកម្ចាស់ អ្នកម្ចាស់
កុំអាលឲ្យវត្ថុអ្វីៗ មុនឡើយ ចាំអ្នកម្ចាស់ជារោគពេលណា អ្នកម្ចាស់ចង់ឲ្យ
វត្ថុណាក៏គប្បីឲ្យវត្ថុនោះ ក្នុងពេលនោះចុះ ។ នាយទ្វារទទួលស្តាប់

កោមារភច្ចស្ស បដិស្សុណិត្វា យេន សេដ្ឋិភរិយា តេនុ- បសង្កមិ ឧបសង្កមិត្វា សេដ្ឋិភរិយំ ឯតទវោច វេជ្ជោ អយ្យេ ឯវមាហ មា កិរ អយ្យេ បុរេ កិញ្ចិ អទាសិ យទា អរោគា អហោសិ តទា យំ ឥច្ឆេយ្យាសិ តំ ទជ្ជេយ្យាសីតិ ។ តេនហិ ភណេ ទោវារិក វេជ្ជោ អា- គច្ឆតូតិ ។ ឯវំ អយ្យេតិ ខោ សោ ទោវារិកោ សេដ្ឋិ- ភរិយាយ បដិស្សុណិត្វា យេន ជីវកោ កោមារភច្ចោ តេនុបសង្កមិ ឧបសង្កមិត្វា ជីវកំ កោមារភច្ចំ ឯតទ- វោច សេដ្ឋិភរិយា តំ អាចរិយ បក្កោសតីតិ ។ អថខោ ជីវកោ កោមារភច្ចោ យេន សេដ្ឋិភរិយា តេនុបសង្កមិ ឧបសង្កមិត្វា សេដ្ឋិភរិយាយ វិការំ សល្លក្ខេត្វា សេដ្ឋិ- ភរិយំ ឯតទវោច បសតេន អយ្យេ សប្បិនា អត្ថោតិ ។ អថខោ សេដ្ឋិភរិយា ជីវកស្ស កោមារ- ភច្ចស្ស បសតំ សប្បឹ ទាបេសិ ។ អថខោ ជីវកោ កោមារភច្ចោ តំ បសតំ សប្បឹ នានាភេសជ្ជេហិ និប្បចិត្វា សេដ្ឋិភរិយំ មញ្ចកេ ឧត្តានំ និបជ្ជាបេត្វា(១)

---

១ និបាតេត្វាតិបិ បាឋោ ។



ពាក្យជីវកកោមារភច្ចដោយពាក្យថា បាទលោកអាចារ្យ ហើយក៏ចូលទៅរកភរិយាសេដ្ឋីវិញ លុះចូលទៅដល់ហើយក៏បាននិយាយពាក្យនេះនឹងភរិយាសេដ្ឋីថា បពិត្រអ្នកម្ចាស់ គ្រូពេទ្យបាននិយាយពាក្យយ៉ាងនេះថា បពិត្រអ្នកម្ចាស់ អ្នកម្ចាស់កុំគប្បីឲ្យវត្ថុអ្វី ៗ មុនឡើយ ចាំអ្នកម្ចាស់ជារោគវេលាណា អ្នកម្ចាស់ចង់ឲ្យវត្ថុណា ក៏គប្បីឲ្យវត្ថុនោះក្នុងវេលានោះចុះ ។ ឯភរិយាសេដ្ឋីក៏ប្រាប់ថា នែនាយទ្វារ បើដូច្នោះសូមឲ្យគ្រូពេទ្យអញ្ជើញចូលមកចុះ ។ នាយទ្វារនោះបានទទួលស្ដាប់ពាក្យភរិយាសេដ្ឋីដោយពាក្យថា បាទអ្នកម្ចាស់ ហើយក៏ចូលទៅរកជីវកកោមារភច្ចវិញ លុះចូលទៅដល់ហើយ ក៏បាននិយាយពាក្យនេះនឹងជីវកកោមារភច្ចថា បពិត្រលោកអាចារ្យ ភរិយាសេដ្ឋីឲ្យអញ្ជើញលោក ។ វេលានោះ ជីវកកោមារភច្ចក៏បានចូលទៅរកភរិយាសេដ្ឋី លុះចូលទៅដល់ហើយ ក៏សង្កេតស្គាល់អាការរបស់ភរិយាសេដ្ឋី ហើយបាននិយាយពាក្យនេះនឹងភរិយាសេដ្ឋីថា បពិត្រអ្នកម្ចាស់ ខ្ញុំបាទត្រូវការសប្បិ ១ ចុកដៃ ។ លំដាប់នោះ ភរិយាសេដ្ឋីក៏បានបង្គាប់ឲ្យគេឲ្យសប្បិ ១ ចុកដៃទៅជីវកកោមារភច្ច ។ គ្រានោះ ជីវកកោមារភច្ចក៏ចម្អិនសប្បិនោះជាមួយនឹងថ្នាំទាំងឡាយផ្សេង ៗ រួចហើយឲ្យភរិយាសេដ្ឋីដេកផ្ងារលើគ្រែហើយ

នត្ថុតោ អទាសិ ។ អថខោ តំ សប្បិ នត្ថុតោ ទិន្នំ មុខតោ ឧគ្គញ្ឆិ ។ អថខោ សេដ្ឋិភរិយា តំ បដិគ្គហេ និដ្ឋុភិត្វា ទាសី អាណាបេសិ ហន្ទ ជេ ឥមំ សប្បិំ បិចុនា គណ្ហាហីតិ ។ អថខោ ជីវកស្ស កោមារភច្ចស្ស ឯតទហោសិ អច្ឆរិយំ វត ភោ(១) យាវ លូខាយំ ឃរណី យត្រ ហិ នាម ឥមំ ឆឌ្ឌនីយធម្មំ សប្បិំ បិចុនា គាហាបេស្សតិ ពហុកានិ ច មេ មហគ្ឃានិ មហគ្ឃានិ ភេសជ្ជានិ ឧបគតានិ កិម្បិមាយំ កញ្ចិ(២) ទេយ្យធម្មំ ទស្សតីតិ ។ អថខោ សេដ្ឋិភរិយា ជីវកស្ស កោមារភច្ចស្ស វិការំ សល្លក្ខេត្វា ជីវកំ កោមារភច្ចំ ឯតទវោច កិស្ស ត្វំ អាចរិយ វិមនោសីតិ ។ ឥធ មេ ឯតទហោសិ អច្ឆរិយំ វត ភោ យាវ លូខាយំ ឃរណី យត្រ ហិ នាម ឥមំ ឆឌ្ឌនីយធម្មំ សប្បិំ បិចុនា គាហាបេស្សតិ ពហុកានិ ច មេ មហគ្ឃានិ មហគ្ឃានិ ភេសជ្ជានិ ឧបគតានិ កិម្បិមាយំ កញ្ចិ ទេយ្យធម្មំ ទស្សតីតិ ។ មយំ ខោ អាចរិយ អាគារិកា នាម ឧបជានាមេតស្ស

[illegible]



បញ្ច្រកច្រមុះនោះ ។ ខណៈនោះ សប្បិដែលជីវកកោមារភច្ចបានច្រកទៅហើយតាមរន្ធច្រមុះ ក៏ចេញតាមមាត់ ។ គ្រានោះ ភរិយាសេដ្ឋីស្ដោះសប្បិនោះទៅក្នុងភាជនៈហើយបង្គាប់ទាសីថា ចូរនាងយកសំឡីមកជ្រលក់សប្បិនេះចេញ ។ គ្រានោះ ជីវកកោមារភច្ចមានសេចក្ដីរិះគិតដូច្នេះថា អើ អស្ចារ្យអើម៉្លេះ ស្រីម្ចាស់ផ្ទះនេះជាស្រីកំណាញ់ណាស់តើ ព្រោះនាងឲ្យទាសីយកសំឡីមកជ្រលក់សប្បិនេះ ដែលជារបស់គួរតែចោល ម្យ៉ាងទៀត ថ្នាំដែលមានដំឡៃច្រើនៗ អញបានប្រើប្រាស់អស់ច្រើនទៅហើយ ស្រីម្ចាស់ផ្ទះនេះ នឹងឲ្យទេយ្យធម៌ (រង្វាន់) តិចតួចដល់អញដូចម្ដេចបាន ។ លំដាប់នោះ ភរិយាសេដ្ឋីសង្កេតស្គាល់អាការជីវកកោមារភច្ច ហើយក៏បាននិយាយពាក្យនេះនឹងជីវកកោមារភច្ចថា នែលោកអាចារ្យ ហេតុអ្វីបានជាអ្នកមានចិត្តព្រួយម្ល៉េះ ។ ឯជីវកកោមារភច្ចតបវិញថា ខ្ញុំបានមានសេចក្ដីរិះគិតក្នុងទីនេះយ៉ាងនេះថា អស្ចារ្យអើម៉្លេះ ស្រីម្ចាស់ផ្ទះនេះជាស្រីកំណាញ់ណាស់តើ ព្រោះនាងឲ្យទាសីយកសំឡីមកជ្រលក់សប្បិនេះ ដែលជារបស់គួរតែចោល ម្យ៉ាងទៀត ថ្នាំដែលមានដំឡៃច្រើនៗ អញបានប្រើប្រាស់អស់ច្រើនទៅហើយ ស្រីម្ចាស់ផ្ទះនេះនឹងឲ្យទេយ្យធម៌តិចតួចដល់គាត់ដូចម្ដេចបាន ។ ឯភរិយាសេដ្ឋីតបវិញថា នែលោកអាចារ្យ យើងជាស្រីគ្រប់គ្រងផ្ទះក្រោមសំចៃសប្បិនេះ

សញ្ញមស្ស វរមេតំ សប្បិ ទាសានំ វា កម្មការានំ វា បាទព្ភញ្ជនំ វា បទីបករណេ វា អាសិត្តំ មា ខោ ត្វំ អាចរិយ វិមនោ អហោសិ ន តេ ទេយ្យធម្មោ ហាយិស្សតីតិ ។ អថខោ ជីវកោ កោមារភច្ចោ សេដ្ឋិភរិយាយ សត្តវស្សិកំ សីសាពាធំ ឯកេនេវ នត្ថុកម្មេន អបកឌ្ឍិ ។ អថខោ សេដ្ឋិភរិយា អរោគា សមានា ជីវកស្ស កោមារភច្ចស្ស ចត្តារិ សហស្សានិ អទាសិ ។ បុត្តោ មាតា មេ អរោគា ឋិតាតិ ចត្តារិ សហស្សានិ អទាសិ ។ សុណិសា សស្សុ មេ អរោគា ឋិតាតិ ចត្តារិ សហស្សានិ អទាសិ ។ សេដ្ឋី គហបតិ ភរិយា មេ អរោគា ឋិតាតិ ចត្តារិ សហស្សានិ អទាសិ ទាសញ្ច ទាសិញ្ច អស្សរថញ្ច អទាសិ ។ អថខោ ជីវកោ កោមារភច្ចោ តានិ សោឡសសហស្សានិ អាទាយ ទាសញ្ច ទាសិញ្ច អស្សរថញ្ច យេន រាជគហំ តេន បក្កាមិ អនុបុព្វេន យេន រាជគហំ យេន អភយោ រាជកុមារោ តេនុបសង្កមិ ឧបសង្កមិត្វា អភយំ រាជកុមារំ ឯតទវោច ឥទំ មេ ទេវ បឋមកម្មំ



សប្បិនេះមិនធ្វើជាចំណាយដល់ពួកទាសៈកម្មករ ឬជូនលាបជើងក្ដី ក៏គួរដាក់ធ្វើប្រទីប ក៏នឹងតែប្រសើរ នែលោកអាចារ្យ លោកកុំតូចចិត្តឡើយ ទេយ្យធម៌របស់លោកមុខជាមិនសាបសូន្យទេ ។ ខណៈនោះ ជីវកកោមារភច្ចក៏ដកនូវជំងឺឈឺក្បាល ៧ ឆ្នាំរបស់ភរិយាសេដ្ឋីដោយការធ្វើនត្ថុកម្មតែម្ដងប៉ុណ្ណោះ ។ វេលានោះ ភរិយាសេដ្ឋីក៏បានសះជាពីរោគនោះទៅ ហើយបានឲ្យ (ទ្រាប់) ចំនួន ៤ ពាន់កហាបណៈទៅជីវកកោមារភច្ច ។ ឯកូនប្រុសគិតថា មាតារបស់អាត្មាអញបានសះជាពីរោគហើយ ក៏បានឲ្យ (ទ្រាប់) ចំនួន ៤ ពាន់កហាបណៈទៀត ។ ឯស្រីជាកូនប្រសាគិតថា ម្ដាយក្មេករបស់អាត្មាអញបានសះជាពីរោគហើយ ក៏បានឲ្យ (ទ្រាប់) ចំនួន ៤ ពាន់កហាបណៈទៀត ។ ឯសេដ្ឋីគហបតីគិតថា ភរិយារបស់អាត្មាអញបានសះជាពីរោគហើយ ក៏ឲ្យ (ទ្រាប់) ចំនួន ៤ ពាន់កហាបណៈ ហើយឲ្យទាសាទាសីនឹងរទេះសេះ (ថែមទៀត) ។ គ្រានោះ ជីវកកោមារភច្ចបាននាំយក (ទ្រាប់) ទាំង ១៦ ពាន់កហាបណៈនោះ នឹងទាសាទាសីព្រមទាំងរទេះសេះហើយចេញទៅក្រុងរាជគ្រឹះ ក៏បានចូលទៅរកអភយរាជកុមារក្នុងក្រុងរាជគ្រឹះដោយលំដាប់ លុះចូលទៅដល់ហើយ ក៏បាននិយាយពាក្យនេះនឹងអភយរាជកុមារថា សូមទ្រង់មេត្តាប្រោស ទ្រាប់

សោឡសសហស្សានិ ទាសោ ច ទាសី ច អស្សរថោ ច ។ តំ មេ ទេវោ បោសាវនិកំ បដិច្ឆតូតិ ។ អលំ ភណេ ជីវក តុយ្ហមេវ(១) ហោតុ អម្ហាកញ្ញេវ(២) អន្តេបុរេ និវេសនំ មាបេហីតិ ។ ឯវំ ទេវាតិ ខោ ជីវកោ កោមារភច្ចោ អភយស្ស រាជកុមារស្ស បដិស្សុណិត្វា អភយស្ស រាជកុមារស្ស អន្តេបុរេ និវេសនំ មាបេសិ ។

[៣៧] តេន ខោ បន សមយេន រញ្ញោ មាគធស្ស សេនិយស្ស ពិម្ពិសារស្ស ភគន្ទលាពាធោ ហោតិ ។ សាដកា លោហិតេន មក្ខិយន្តិ ។ ទេវិយោ ទិស្វា ឧប្បណ្ឌេន្តិ ឧតុនីទានិ ទេវោ បុប្ផំ ទេវស្ស ឧប្បន្នំ ន ចិរំ(៣) ទេវោ វិជាយិស្សតីតិ ។ តេន រាជា មង្កុ ហោតិ ។ អថខោ រាជា មាគធោ សេនិយោ ពិម្ពិសារោ អភយំ រាជកុមារំ ឯតទវោច មយ្ហំ ខោ ភណេ អភយ តាទិសោ អាពាធោ សាដកា លោហិតេន មក្ខិយន្តិ ទេវិយោ មំ ទិស្វា ឧប្បណ្ឌេន្តិ ឧតុនីទានិ ទេវោ បុប្ផំ ទេវស្ស ឧប្បន្នំ

១ ម. តុយ្ហំ ។ ២ អម្ហាកញ្ញេវ ។ ៣ ម. ចិរស្សេវ ទេវោ ។



ចំនួន ១៦ ពាន់ក្តី ទាសក្តី ទាសីក្តី សេះនឹងរថក្តី នេះជាស្នាដៃដំបូងរបស់ទូលបង្គំជាខ្ញុំ សូមព្រះសម្មតិទេព ទ្រង់ទទួលយកគ្រឿងសម្រាប់ចិញ្ចឹមរបស់ទូលបង្គំជាខ្ញុំចុះ ។ អភយរាជកុមារក៏តបថា នែជីវកៈ ណ្ហើយ (របស់ទាំងនេះ) ស្រេចនឹងអ្នកឯងចុះ ប៉ុន្តែអ្នកឯងចូរសាងលំនៅក្នុងវាំងរបស់យើង ។ ជីវកកោមារភច្ច ទទួលស្តាប់ព្រះបន្ទូលអភយរាជកុមារដោយពាក្យថា បពិត្រព្រះសម្មតិទេព ព្រះករុណាវិសេស ហើយក៏បានសាងលំនៅក្នុងវាំងរបស់អភយរាជកុមារ ។

[៣៧] សម័យនោះឯង ព្រះបាទមាគធសេនិយពិម្ពិសារ ទ្រង់កើតរោគឫសដូងបាត ។ សំពត់សាដកទាំងឡាយក៏សឹងតែប្រឡាក់ដោយឈាម ។ ពួកព្រះនាងទេវីឃើញហើយក៏ចំអកថា ឥឡូវនេះព្រះសម្មតិទេពទ្រង់មានរដូវហើយ ផ្កាឈាមបានកើតឡើងដល់ព្រះសម្មតិទេពហើយ មិនយូរប៉ុន្មានទេ ព្រះសម្មតិទេពមុខជានឹងប្រសូត(បុត្រ)មិនខាន ។ ព្រះមហាក្សត្រក៏ទ្រង់អៀនខ្មាស់ដោយហេតុនោះ ។ វេលានោះ ព្រះបាទមាគធសេនិយពិម្ពិសារ ទ្រង់មានព្រះរាជឱង្ការសួរទៅអភយរាជកុមារថា នែអភយៈ យើងមានជម្ងឺប្រាកដដូច្នោះហើយ សំពត់ទាំងសំពត់សាដកប្រឡាក់ទៅដោយឈាម ឯពួកនាងទេវីឃើញហើយក៏ចំអកថា ឥឡូវនេះព្រះសម្មតិទេពទ្រង់មានរដូវហើយ ផ្កាឈាមបានកើតឡើង

នចិរស្ស ទេវោ វិជាយិស្សតីតិ ឥង្ឃ ភណេ អភយ តាទិសំ វេជ្ជំ ជានាហិ យោ មំ តិកិច្ឆេយ្យាតិ ។ អយំ ទេវ អម្ហាកំ ជីវកោ វេជ្ជោ តរុណោ ភទ្រកោ សោ ទេវំ តិកិច្ឆិស្សតីតិ ។ តេនហិ ភណេ អភយ ជីវកំ វេជ្ជំ អាណាបេហិ សោ មំ តិកិច្ឆិស្សតីតិ ។ អថខោ អភយោ រាជកុមារោ ជីវកំ កោមារភច្ចំ អាណាបេសិ គច្ឆ ភណេ ជីវក រាជានំ តិកិច្ឆាហីតិ ។ ឯវំ ទេវាតិ ខោ ជីវកោ កោមារភច្ចោ អភយស្ស រាជកុមារស្ស បដិស្សុណិត្វា នខេន ភេសជ្ជំ អាទាយ យេន រាជា មាគធោ សេនិយោ ពិម្ពិសារោ តេនុបសង្កមិ ឧបសង្កមិត្វា រាជានំ មាគធំ សេនិយំ ពិម្ពិសារំ ឯតទវោច អាពាធំ តេ ទេវ បស្សាមីតិ[១] ។ អថខោ ជីវកោ កោមារភច្ចោ រញ្ញោ មាគធស្ស សេនិយស្ស ពិម្ពិសារស្ស ភគន្ទលាពាធំ ឯកេនេវ អាលេបេន អបកឌ្ឍិ ។ អថខោ រាជា មាគធោ សេនិយោ ពិម្ពិសារោ

១ ន. អាពាធំ ទេវ បស្សាមាតិ ។



ដល់ព្រះសម្មតិទេពហើយ មិនយូរប៉ុន្មានទេ ព្រះសម្មតិទេពមុខជានឹងប្រសូត (បុត្រ) មិនខាន នែនាយអភ័យ បើដូច្នោះអ្នកចូរស្គាល់ពេទ្យណា ដែលអាចព្យាបាលយើងបាន ។ អភយរាជកុមារក្រាបទូលថា បពិត្រព្រះសម្មតិទេព ពេទ្យរបស់ខ្ញុំព្រះអង្គឈ្មោះជីវកៈនៅក្មេងជាមនុស្សកំពុងចំរើន ពេទ្យនោះនឹងព្យាបាលព្រះសម្មតិទេពបាន ។ ព្រះបាទពិម្ពិសារត្រាស់ថា នែនាយអភ័យ បើដូច្នោះចូរអ្នកបង្គាប់ពេទ្យជីវកឲ្យគេមកព្យាបាលអញចុះ ។ លំដាប់នោះ អភយរាជកុមារក៏បានបង្គាប់ជីវកកោមារភច្ចថា នែនាយជីវកៈ ចូរអ្នកឯងទៅព្យាបាលរោគថ្វាយព្រះមហាក្សត្រ ។ ជីវកកោមារភច្ចបានទទួលបង្គាប់អភយរាជកុមារដោយពាក្យថា ករុណាវិសេស ហើយក៏នាំយកថ្នាំចំនួនមួយក្រចកចូលទៅគាល់ព្រះបាទមាគធសេនិយពិម្ពិសារ លុះចូលទៅដល់ហើយក៏ក្រាបទូលព្រះបាទមាគធសេនិយពិម្ពិសារដូច្នេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គសូមមើលជម្ងឺព្រះអង្គ ។ វេលានោះ ជីវកកោមារភច្ចក៏បានរំងាប់រោគឫសដូងបាតរបស់ព្រះបាទមាគធសេនិយពិម្ពិសារដោយលាបថ្នាំតែម្តង ។ គ្រានោះ ព្រះបាទមាគធសេនិយពិម្ពិសារ

អរោគោ សមានោ បញ្ច ឥត្ថីសតានិ សព្វាលង្ការំ វិភូសាបេត្វា(១) ឱមុញ្ចាបេត្វា បុញ្ជំ ការាបេត្វា ជីវកំ កោមារភច្ចំ ឯតទវោច ឯតំ ភណេ ជីវក បញ្ចន្នំ ឥត្ថីសតានំ សព្វាលង្ការំ តុយ្ហំ ហោតូតិ ។ អលំ ទេវ អធិការំ មេ ទេវោ សរតូតិ ។ តេនហិ ភណេ ជីវក មំ ឧបដ្ឋហ ឥត្ថាគារញ្ច ពុទ្ធប្បមុខញ្ច ភិក្ខុសង្ឃន្តិ ។ ឯវំ ទេវាតិ ខោ ជីវកោ កោមារភច្ចោ រញ្ញោ មាគធស្ស សេនិយស្ស ពិម្ពិសារស្ស បច្ចស្សោសិ ។

(៣៨) តេន ខោ បន សមយេន រាជគហកស្ស សេដ្ឋិស្ស សត្តវស្សិកោ សីសាពាធោ ហោតិ ។ ពហូ មហន្តា មហន្តា ទិសាបាមោក្ខា វេជ្ជា អាគន្ត្វា នាសក្ខឹសុ អរោគំ កាតុំ ពហុំ ហិរញ្ញំ អាទាយ អគមំសុ ។ អបិច វេជ្ជេហិ បច្ចក្ខាតោ ហោតិ ។ ឯកច្ចេ វេជ្ជា ឯវមាហំសុ បញ្ចមេ ទិវសេ សេដ្ឋី គហបតិ កាលំ ករិស្សតីតិ ។ ឯកច្ចេ វេជ្ជា ឯវមាហំសុ សត្តមេ ទិវសេ សេដ្ឋី គហបតិ កាលំ ករិស្សតីតិ ។

១ ម. ភូសាបេត្វា ។

៧៦

វិនយបិដក មហាវគ្គ

ទ្រង់បានសះជារោគហើយ ទើបទ្រង់ឲ្យពួកស្រីតាំងប្រាំរយស្អិតស្អាងគ្រឿងអលង្ការតាំងពួងហើយឲ្យដោះចេញ ទ្រង់ឲ្យធ្វើជាគំនររួចទ្រង់ត្រាស់ទៅនឹងជីវកកោមារភច្ចដូច្នេះថា នែនាយជីវកៈ គ្រឿងអលង្ការតាំងពួងរបស់ស្រីតាំងប្រាំរយនេះត្រូវបានអ្នកឯងហើយ ។ ជីវកៈកោមារភច្ចក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស កុំត្រូវព្រះករុណាចុះចំយឡើយ សូមព្រះសម្មតិទេពទ្រង់ត្រាស់រំលឹកនូវឧបការរបស់ខ្ញុំព្រះអង្គចុះ ។ ព្រះបាទពិម្ពិសារត្រាស់ថា នែនាយជីវកៈ បើដូច្នោះចូរអ្នកឯងបម្រើយើងផង ស្រីស្នំផង ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានផង ។ ជីវកកោមារភច្ចបានទទួលស្ដាប់ព្រះរាជឱង្ការព្រះបាទមាគធសេនិយពិម្ពិសារដោយពាក្យថា បពិត្រព្រះសម្មតិទេព ព្រះករុណាវិសេស ។

(៣៨) សម័យនោះឯង សេដ្ឋីនៅក្រុងរាជគ្រឹះកើតរោគឈឺក្បាល ៧ ឆ្នាំហើយ ។ ពួកពេទ្យដែលជាទិសាបាមោក្ខ ៗ ច្រើននាក់មកព្យាបាលក៏មិនអាចនឹងធ្វើរោគឲ្យសះជាបាន នាំយកនូវប្រាក់ជាច្រើនទៅ ។ មួយទៀត សេដ្ឋីនោះពួកពេទ្យក៏បោះបង់ចោលហើយ ។ មានពួកពេទ្យខ្លះនិយាយយ៉ាងនេះថា សេដ្ឋីគហបតីមុខជានឹងធ្វើមរណកាលក្នុងថ្ងៃទី ៥ ។ ពួកពេទ្យខ្លះនិយាយយ៉ាងនេះថា សេដ្ឋីគហបតីមុខជានឹងធ្វើមរណកាលក្នុងថ្ងៃទី ៧ ។

រាជតោ ភទ្ទវតិកស្ស ឧទេនស្ស ឯតទវោចសិ អយំ តោ សេដ្ឋី គហបតិ ពហុបការោ រញ្ញោ ចេវ ឧទេនស្ស ច អម្ហាកញ្ច ... បច្ឆាភត្តេ ឯកាហេ ... សុ បញ្ចមំ ទិវសំ សេដ្ឋី គហបតិ ភត្តំ ករិស្សតិ ឯកាហេ ... សត្តមំ ទិវសំ សេដ្ឋី គហបតិ ភត្តំ ករិស្សតិ អយំ ច រញ្ញោ ... ... យាចយាម សេដ្ឋី គហបតិ តិកិច្ឆតុ ។ អថខោ ភទ្ទវតិកោ ឧទេនោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ ឯតទវោច សេដ្ឋី គហបតិ ពហុបការោ ទេវស្ស ទេវ ឧទេនស្ស ច អម្ហាកញ្ច បច្ឆាភត្តេ ឯកាហេ ... សុ បញ្ចមំ ទិវសំ សេដ្ឋី គហបតិ ភត្តំ ករិស្សតិ ឯកាហេ ... សត្តមំ ទិវសំ សេដ្ឋី គហបតិ ភត្តំ ករិស្សតិ សាធុ ទេវ ... យាចាម សេដ្ឋី គហបតិ តិកិច្ឆតុ ។



លំដាប់នោះពួកកុក្កុដមិត្តៈនៅក្នុងក្រុងកោសម្ពី មានសេចក្ដីរិះគិតដូច្នេះថា សេដ្ឋីគហបតិនេះឯងមានឧបការៈច្រើនដល់ស្ដេចផង ដល់ពួកកុក្កុដមិត្តៈផង ម្យ៉ាងទៀត សេដ្ឋីនោះគួរគោរពរាប់អានហើយ ពួកពេទ្យទាំងនិយាយយ៉ាងនេះថា សេដ្ឋីគហបតិមុខជានឹងស្លាប់ក្នុងថ្ងៃទី ៥ ពួកពេទ្យខ្លះនិយាយយ៉ាងនេះថា សេដ្ឋីគហបតិមុខជានឹងស្លាប់ក្នុងថ្ងៃទី ៧ ម្យ៉ាងទៀត ពេទ្យជីវកៈរបស់ព្រះមហាក្សត្រនេះនៅក្មេង ជាមនុស្សកំពុងនៅវ័យ បើដូច្នោះ គួរតែយើងទូលសូមពេទ្យជីវកៈអំពីព្រះមហាក្សត្រ ដើម្បីព្យាបាលរោគសេដ្ឋីគហបតិ ។ គ្រានោះ ពួកកុក្កុដមិត្តៈនៅក្នុងក្រុងកោសម្ពីបានចូលទៅ គាល់ព្រះបាទមាគធរាជសេនិយ ពិម្ពិសារ លុះចូលទៅដល់ហើយក៏បានក្រាបទូលព្រះបាទមាគធរាជសេនិយ ពិម្ពិសារថា សូមទ្រង់ព្រះមេត្តាប្រោស សេដ្ឋីគហបតិនេះមានឧបការៈច្រើនដល់ព្រះសម្មតិទេពផង ដល់ពួកកុក្កុដមិត្តៈផង ម្យ៉ាងទៀត ពួកពេទ្យក៏បោះបង់ហើយ ពួកពេទ្យខ្លះនិយាយយ៉ាងនេះថា សេដ្ឋីគហបតិមុខជានឹងស្លាប់ក្នុងថ្ងៃទី ៥ ពួកពេទ្យខ្លះនិយាយយ៉ាងនេះថា សេដ្ឋីគហបតិមុខជានឹងស្លាប់ក្នុងថ្ងៃទី ៧ យើងខ្ញុំសូមអង្វរសូមព្រះសម្មតិទេពទ្រង់បង្គាប់ពេទ្យជីវកឲ្យព្យាបាលរោគសេដ្ឋីគហបតិ ។

អថខោ ភគវា មាគធោ សេនិយោ ពិម្ពិសារោ ជីវកំ កោមារភច្ចំ អាណាបេសិ គច្ឆ ភណេ ជីវក សេដ្ឋឹ គហបតឹ តិកិច្ឆាហីតិ ។ ឯវំ ទេវាតិ ខោ ជីវកោ កោមារភច្ចោ រញ្ញោ មាគធស្ស សេនិយស្ស ពិម្ពិសារស្ស បដិស្សុណិត្វា យេន សេដ្ឋី គហបតិ តេនុបសង្កមិ ឧបសង្កមិត្វា សេដ្ឋិស្ស គហបតិស្ស វិការំ សល្លក្ខេត្វា សេដ្ឋឹ គហបតឹ ឯតទវោច សចាហន្តំ គហបតិ អរោគំ ករេយ្យំ[1] កឹ មេ អស្ស ទេយ្យធម្មោតិ ។ សព្វំ សាបតេយ្យញ្ច តេ អាចរិយ ហោតុ អហញ្ច តេ ទាសោតិ ។ សក្ខិស្សសិ[2] បន ត្វំ គហបតិ ឯកេន បស្សេន សត្ត មាសេ និបជ្ជិតុន្តិ ។ សក្កោមហំ អាចរិយ ឯកេន បស្សេន សត្ត មាសេ និបជ្ជិតុន្តិ ។ សក្ខិស្សសិ បន ត្វំ គហបតិ ទុតិយេន បស្សេន សត្ត មាសេ និបជ្ជិតុន្តិ ។ សក្កោមហំ អាចរិយ ទុតិយេន បស្សេន សត្ត មាសេ និបជ្ជិតុន្តិ ។ សក្ខិស្សសិ បន ត្វំ គហបតិ ឧត្តានោ សត្ត មាសេ និបជ្ជិតុន្តិ ។ សក្កោមហំ អាចរិយ ឧត្តានោ

១ ឱ. អរោគាបេយ្យំ ។ ២ ឱ. សក្ខិស្សសិ ។



ខណៈនោះ ព្រះបាទមាគធសេនិយពិម្ពិសារក៏ទ្រង់បង្គាប់ជីវកកោមារភច្ចថា នែនាយជីវកៈ អ្នកឯងចូរទៅព្យាបាលសេដ្ឋីគហបតីចុះ ។ ជីវកកោមារភច្ចទទួលស្តាប់ព្រះរាជឱង្ការព្រះបាទមាគធសេនិយពិម្ពិសារ ដោយពាក្យថា បពិត្រព្រះសម្មតិទេព ព្រះករុណាវិសេស រួចចូលទៅរកសេដ្ឋីគហបតី លុះចូលទៅដល់ហើយក៏សង្កេតជំងឺវិការៈរបស់សេដ្ឋីគហបតី រួចហើយនិយាយនឹងសេដ្ឋីគហបតីដូច្នេះថា នែគហបតី ប្រសិនបើខ្ញុំធ្វើលោកឲ្យសះជាហើយ តើខ្ញុំនឹងត្រូវបានរង្វាន់ដូចម្តេច ។ សេដ្ឋីគហបតីតបថា លោកអាចារ្យ សម្បត្តិរបស់ខ្ញុំទាំងអស់ក៏ត្រូវបានលោក ខ្លួនខ្ញុំក៏ធ្វើជាខ្ញុំរបស់លោក ។ ជីវកកោមារភច្ចសួរថា នែគហបតី លោកអាចនឹងសម្រាន្តផ្អៀងតែម្ខាងអស់ ៧ ខែបានឬទេ ។ សេដ្ឋីគហបតីតបថា លោកអាចារ្យ ខ្ញុំអាចនឹងដេកផ្អៀងតែម្ខាងអស់ ៧ ខែបាន ។ ជីវកកោមារភច្ចសួរថា នែគហបតី លោកអាចនឹងសម្រាន្តផ្អៀងម្ខាងទៀតអស់ ៧ ខែបានឬទេ ។ សេដ្ឋីគហបតីតបថា លោកអាចារ្យ ខ្ញុំអាចនឹងដេកផ្អៀងម្ខាងទៀតអស់ ៧ ខែបាន ។ ជីវកកោមារភច្ចសួរថា នែគហបតី លោកអាចនឹងសម្រាន្តផ្ងារអស់ ៧ ខែបានឬទេ ។ សេដ្ឋីគហបតីប្រាប់ថា លោកអាចារ្យ ខ្ញុំអាចនឹងដេកផ្ងារ

សត្ត ទាសោ ចិបដ្ឋិតុំ ។ អថខោ ជីវកោ កោមារ-ភច្ចោ សេដ្ឋី គហបតឹ មញ្ចកេ និបជ្ជាបេត្វា(១) មញ្ច-កេ ពន្ធិត្វា សីសច្ឆវឹ ឧប្បាដេត្វា(២) សិព្វិនឹ វិនាមេ-ត្វា ទ្វេ បាណកេ នីហរិត្វា មហាជនស្ស ទស្សេសិ បស្ស-ថ(៣) ឥមេ ទ្វេ បាណកេ ឯកំ ខុទ្ទកំ ឯកំ មហល្ល-កំ យេ តេ អាចរិយា ឯវមាហំសុ បញ្ចមំ ទិវសំ សេ-ដ្ឋី គហបតិ កាលំ ករិស្សតីតិ តេហាយំ មហល្លកោ បាណកោ ទិដ្ឋោ បញ្ចមំ ទិវសំ សេដ្ឋិស្ស គហបតិស្ស មត្ថលុង្គំ បរិយាទិយិស្សតិ មត្ថលុង្គស្ស បរិយាទានា សេដ្ឋី គហបតិ កាលំ ករិស្សតិ សុទិដ្ឋោ តេហិ អាចរិយេហិ យេ តេ អាចរិយា ឯវមាហំសុ សត្តមំ ទិវសំ សេដ្ឋី គហបតិ កាលំ ករិស្សតីតិ តេហាយំ ខុទ្ទកោ បាណកោ ទិដ្ឋោ សត្តមំ ទិវសំ សេដ្ឋិស្ស គហបតិស្ស មត្ថលុង្គំ បរិយាទិយិស្សតិ មត្ថលុង្គស្ស បរិយាទានា សេដ្ឋី គហបតិ កាលំ ករិស្សតិ សុទិដ្ឋោ តេហិ អាចរិយេហីតិ សិព្វិនឹ សម្បដិបាទេត្វា

១. និបាជេត្វាតិបិ បាឋោ ។ ២. ឧប្បាលេត្វា ។ ៣. បស្សថយ្យោ ។



គប់ ៧ ខែបាន ។ ខណៈនោះ ជីវកកោមារភច្ចក៏ឲ្យសេដ្ឋីគហបតីដេកលើគ្រែ ហើយចងសេដ្ឋីភ្ជាប់លើគ្រែ ហើយវះស្បែកក្បាលរបកឡើង(ហែកក្បាល) បញ្ចេញក៏នាំយកបាណកជាតិ(១) ទាំងពីរ ហើយបង្ហាញដល់ជនជាច្រើនថា ចូរអ្នកទាំងឡាយមើលបាណកជាតិទាំងពីរនេះចុះ បាណកជាតិតូចមួយ បាណកជាតិធំមួយ ពួកអាចារ្យណានិយាយយ៉ាងនេះថា សេដ្ឋីគហបតីនឹងធ្វើមរណកាលក្នុងថ្ងៃទី ៥ (ព្រោះ) ពួកអាចារ្យទាំងនោះបានឃើញបាណកជាតិធំនេះ ដល់ថ្ងៃទី ៥ វានឹងផ្តាច់យកខួរក្នុងក្បាលរបស់សេដ្ឋីគហបតី ៗ នឹងធ្វើមរណកាល ព្រោះវាផ្តាច់យកខួរក្នុងក្បាល អាចារ្យទាំងនោះគេឃើញត្រូវ (របស់គេមិនខុសទេ) ចំណែកខាងពួកអាចារ្យណានិយាយយ៉ាងនេះថា សេដ្ឋីគហបតីនឹងធ្វើមរណកាលក្នុងថ្ងៃទី ៧ (ព្រោះ) អាចារ្យទាំងនោះបានឃើញបាណកជាតិតូចនេះ ដល់ថ្ងៃទី ៧ វានឹងផ្តាច់ខួរក្នុងក្បាលសេដ្ឋីគហបតី ៗ នឹងធ្វើមរណកាល ព្រោះវាផ្តាច់ខួរក្នុងក្បាល អាចារ្យទាំងនោះគេឃើញត្រូវ (របស់គេមិនខុសទេ) រួចហើយទើបបិទថ្នេរ

១ បាណកជាតិ ១ (មេរោគ) ។

សីសច្ឆវឹ សិព្វិត្វា អាលេបំ អទាសិ ។ អថ ខោ សេដ្ឋី គហបតិ សត្តាហស្ស អច្ចយេន ជីវកំ កោមារភច្ចំ ឯតទវោច នាហំ អាចរិយ សក្កោមិ ឯកេន បស្សេន សត្ត មាសេ និបជ្ជិតុន្តិ ។ ននុ មេ ត្វំ គហបតិ បដិស្សុណិ សក្កោមហំ អាចរិយ ឯកេន បស្សេន សត្ត មាសេ និបជ្ជិតុន្តិ ។ សច្ចាហំ អាចរិយ បដិស្សុណឹ អបិចាហំ មរិស្សាមិ នាហំ សក្កោមិ ឯកេន បស្សេន សត្ត មាសេ និបជ្ជិតុន្តិ ។ តេនហិ ត្វំ គហបតិ ទុតិយេន បស្សេន សត្ត មាសេ និបជ្ជាហីតិ ។ អថ ខោ សេដ្ឋី គហបតិ សត្តាហស្ស អច្ចយេន ជីវកំ កោមារភច្ចំ ឯតទវោច នាហំ អាចរិយ សក្កោមិ ទុតិយេន បស្សេន សត្ត មាសេ និបជ្ជិតុន្តិ ។ ននុ មេ ត្វំ គហបតិ បដិស្សុណិ សក្កោមហំ អាចរិយ ទុតិយេន បស្សេន សត្ត មាសេ និបជ្ជិតុន្តិ ។ សច្ចាហំ អាចរិយ បដិស្សុណឹ អបិចាហំ មរិស្សាមិ នាហំ សក្កោមិ ទុតិយេន បស្សេន សត្ត មាសេ និបជ្ជិតុន្តិ ។ តេនហិ ត្វំ គហបតិ ឧត្តានោ សត្ត មាសេ និបជ្ជាហីតិ ។



(លេបថ្នាំ) ហើយដេរស្បែកក្បាលរួចលាបថ្នាំឲ្យ ។ វេលានោះ លុះកន្លងទៅ៧ថ្ងៃទៅ សេដ្ឋីគហបតីក៏និយាយទៅនឹងជីវកកោមារភច្ចយ៉ាងនេះថា ថាលោកអាចារ្យ ខ្ញុំមិនអាចនឹងដេកផ្អៀងម្ខាងអស់៧ខែបានទេ ។ ជីវកកោមារភច្ចតបថា ម្នាលគហបតី ក្រែងលោកបានទទួលប្តេជ្ញានឹងខ្ញុំថា លោកអាចារ្យ ខ្ញុំអាចនឹងដេកផ្អៀងតែម្ខាងឲ្យអស់ ៧ ខែបាន មិនដូច្នោះឬ ។ សេដ្ឋីតបថា លោកអាចារ្យ ខ្ញុំបានទទួលប្តេជ្ញាពិតមែនហើយ ប៉ុន្តែថាខ្ញុំមុខជានឹងស្លាប់ ( មិនខានព្រោះ ) ខ្ញុំមិនអាចនឹងដេកផ្អៀងតែម្ខាងឲ្យអស់៧ ខែបាន ។ ជីវកកោមារភច្ចនិយាយថា ម្នាលគហបតី បើដូច្នោះ ចូរលោកដេកផ្អៀងទៅម្ខាងទៀតអស់៧ខែចុះ ។ វេលានោះ លុះកន្លង ៧ ថ្ងៃទៅ សេដ្ឋីគហបតីបាននិយាយនឹងជីវកកោមារភច្ចយ៉ាងនេះថា លោកអាចារ្យ ខ្ញុំមិនអាចនឹងដេកផ្អៀងម្ខាងទៀតអស់ ៧ ខែបានឡើយ ។ ជីវកកោមារភច្ចតបថា ម្នាលគហបតី ក្រែងលោកបានទទួលប្តេជ្ញានឹងខ្ញុំថា លោកអាចារ្យ ខ្ញុំអាចនឹងដេកផ្អៀងទៅម្ខាងទៀតអស់ ៧ ខែបាន មិនដូច្នោះឬ ។ សេដ្ឋីនិយាយថា លោកអាចារ្យ ខ្ញុំបានទទួលប្តេជ្ញាពិតមែនហើយ ប៉ុន្តែថាខ្ញុំមុខជានឹងស្លាប់ ( មិនខានព្រោះ ) ខ្ញុំមិនអាចនឹងដេកផ្អៀងទៅម្ខាងទៀតអស់៧ខែបានទេ ។ ជីវកកោមារភច្ចតបថា ម្នាលគហបតី បើដូច្នោះចូរលោកដេកផ្ងារឲ្យអស់៧ខែវិញចុះ ។

អថខោ សេដ្ឋី គហបតិ សត្តាហស្ស អច្ចយេន ជីវកំ កោមារភច្ចំ ឯតទវោច នាហំ អាចរិយ សក្កោមិ ឧត្តានោ សត្ត មាសេ និបជ្ជិតុន្តិ ។ ននុ មេ ត្វំ គហបតិ បដិស្សុណី សក្កោមហំ អាចរិយ ឧត្តានោ សត្ត មាសេ និបជ្ជិតុន្តិ ។ សច្ចាហំ អាចរិយ បដិស្សុណឹ អបាហំ មរិស្សាមិ នាហំ សក្កោមិ ឧត្តានោ សត្ត មាសេ និបជ្ជិតុន្តិ ។ អហញ្ចេ តំ គហបតិ ន វទេយ្យំ ឯត្តកម្បិ ត្វំ ន និបជ្ជេយ្យាសិ អបិច បដិគច្ចេវ[1] មយា ញាតោ តីហិ សត្តាហេហិ សេដ្ឋី គហបតិ អរោគោ ភវិស្សតីតិ ឧដ្ឋេហិ គហបតិ អរោគោសិ ជានាសិ កឹ មេ ទេយ្យធម្មោតិ ។ សព្វំ សាបតេយ្យំ តវ ហោតុ អាចរិយ អហញ្ច តេ ទាសោតិ ។ អលំ គហបតិ មា មេ ត្វំ សព្វំ សាបតេយ្យំ អទាសិ មា ច មេ ទាសោ រញ្ញោ សតសហស្សំ ទេហិ មយ្ហំ សតសហស្សន្តិ ។

១ ម, បដិកច្ចេវ ។



លំដាប់នោះ លុះកន្លង ៧ ថ្ងៃទៅ សេដ្ឋីគហបតីបាននិយាយទៅនឹងជីវកកោមារភច្ចយ៉ាងនេះថា លោកអាចារ្យ ខ្ញុំមិនអាចនឹងដេកផ្ងារអស់ ៧ ខែបានទេ ។ ជីវកកោមារភច្ចតបថា ម្នាលគហបតី ក្រែងលោកបានទទួលប្ដេជ្ញានឹងខ្ញុំថា លោកអាចារ្យ ខ្ញុំអាចនឹងដេកផ្ងារអស់ ៧ ខែបាន មិនដូច្នោះទេឬ ។ សេដ្ឋីនិយាយថា លោកអាចារ្យ ខ្ញុំបានទទួលប្ដេជ្ញាពិតមែនហើយ ប៉ុន្តែថាខ្ញុំមុខជានឹងស្លាប់ (មិនខាន) ព្រោះ ខ្ញុំមិនអាចនឹងដេកផ្ងារអស់ ៧ ខែបានទេ ។ ជីវកកោមារភច្ចតបវិញថា ម្នាលគហបតី បើខ្ញុំមិនបាននិយាយនឹងលោក (យ៉ាងនេះទេ) អ្នកមុខជាមិនដេកអស់កាលមានប្រមាណប៉ុណ្ណោះឡើយ មួយវិញទៀត យើងបានដឹងពីមុនហើយថាដល់ ៧ ថ្ងៃ ៣ ដង សេដ្ឋីគហបតីមុខជានឹងសះស្បើយរោគជាប្រាកដ (មិនខាន) ម្នាលគហបតី ចូរអ្នកក្រោកឡើង ព្រោះលោកបានសះជារោគហើយ ចូរលោកដឹងថាលោកត្រូវឲ្យរង្វាន់ខ្ញុំដូចម្ដេចខ្លះ ។ សេដ្ឋីគហបតីនិយាយថា លោកអាចារ្យ សម្បត្តិទ្រព្យទាំងអស់ក៏ត្រូវបានលោក ខ្លួនខ្ញុំក៏សូមធ្វើជាខ្ញុំលោក ។ ជីវកកោមារភច្ចតបថា ម្នាលគហបតី ល្មមហើយ លោកកុំឲ្យសម្បត្តិទាំងអស់មកខ្ញុំឡើយ មួយវិញទៀត លោកកុំធ្វើជាខ្ញុំរបស់ខ្ញុំ លោកចូរថ្វាយទ្រព្យ ១ សែនកហាបណៈទៅស្ដេច ឲ្យទ្រព្យ ១ សែនកហាបណៈមកខ្ញុំចុះ ។

អថខោ សេដ្ឋី គហបតិ អរោគោ សមានោ រញ្ញោ សតសហស្សំ អទាសិ ជីវកស្ស កោមារភច្ចស្ស សតសហស្សំ ។

[៣៩] តេន ខោ បន សមយេន ពារាណសេយ្យកស្ស សេដ្ឋិបុត្តស្ស មោក្ខចិកាយ កីឡន្តស្ស អន្តគណ្ឋាពាធោ ហោតិ ។ តេន យាគុបិ បីតា ន សម្មាបរិណាមំ គច្ឆតិ ភត្តំបិ ភុត្តំ ន សម្មាបរិណាមំ គច្ឆតិ ឧច្ចារោបិ បស្សាវោបិ ន បគុណោ ។ សោ តេន កិសោ ហោតិ លូខោ ទុព្វណ្ណោ ឧប្បណ្ឌុប្បណ្ឌុកជាតោ ធមនិសន្ថតគត្តោ ។ អថខោ ពារាណសេយ្យកស្ស សេដ្ឋិស្ស ឯតទហោសិ មយ្ហំ ខោ បុត្តស្ស តាទិសោ អាពាធោ យេន យាគុបិ បីតា ន សម្មាបរិណាមំ គច្ឆតិ ភត្តំបិ ភុត្តំ ន សម្មាបរិណាមំ គច្ឆតិ ឧច្ចារោបិ បស្សាវោបិ ន បគុណោ សោ តេន កិសោ លូខោ ទុព្វណ្ណោ ឧប្បណ្ឌុប្បណ្ឌុកជាតោ ធមនិសន្ថតគត្តោ យន្នូនាហំ រាជគហំ គន្ត្វា រាជានំ ជីវកំ យាចេយ្យំ បុត្តំ មេ តិកិច្ឆិតុំ ។ អថខោ ពារាណសេយ្យកោ សេដ្ឋី



គ្រានោះ សេដ្ឋីគហបតិបានសះជារោគហើយ ក៏បានថ្វាយទ្រព្យ ១ សែនកហាបណៈទៅស្តេចផង ទ្រព្យ ១ សែនកហាបណៈទៅជីវកកោមារភច្ច ។

[៣៩] សម័យនោះឯង មានសេដ្ឋីបុត្តនៅក្នុងក្រុងពារាណសី លេងល្បែងដាំដូង ក៏កើតរោគដុំក្នុងពោះវៀនធំ ។ បបរដែលសេដ្ឋីបុត្តបានផឹកក្តី ក៏មិនបានរលួយស្រួល បាយដែលសេដ្ឋីបុត្តបានបរិភោគក្តី ក៏មិនបានរលួយស្រួល ឧច្ចារៈក្តី បស្សាវៈក្តី ក៏មិនបានស្រួលសោះ ។ ព្រោះរោគនោះ សេដ្ឋីបុត្តនោះក៏ទៅជាស្គមសៅហ្មងមានសម្បុរអាក្រក់ កើតរោគលឿងស្លេកស្លាំងមានខ្លួនពេញដោយសរសៃ ។ វេលានោះ សេដ្ឋីនៅក្នុងក្រុងពារាណសីមានសេចក្តីរំពឹងដូច្នេះថា ជម្ងឺកូនអញប្រាកដដូច្នោះ ទឹកបបរ (ដែលកូនអញ) ផឹកទៅក្តី ក៏មិនបានរលួយស្រួល បាយដែលបរិភោគក្តី ក៏មិនបានរលួយស្រួល ឧច្ចារៈក្តី បស្សាវៈក្តី ក៏មិនបានស្រួលសោះ ព្រោះរោគនោះ បានជាកូនអញទៅជាស្គមសៅហ្មងមានសម្បុរអាក្រក់ កើតរោគលឿងស្លេកស្លាំងមានខ្លួនពេញដោយសរសៃ បើដូច្នោះគួរតែអញទៅកាន់ក្រុងរាជគ្រឹះ ហើយសូមយកពេទ្យជីវកៈពីស្តេចមក ដើម្បីឲ្យមកព្យាបាលកូនអញ ។ លំដាប់នោះ សេដ្ឋីនៅក្នុងក្រុងពារាណសី

រាជគហំ គន្ត្វា យេន រាជា មាគធោ សេនិយោ ពិម្ពិ-
សារោ តេនុបសង្កមិ ឧបសង្កមិត្វា រាជានំ មាគធំ សេ-
និយំ ពិម្ពិសារំ ឯតទវោច មយ្ហំ ខោ ទេវ បុត្តស្ស តាទិ-
សោ អាពាធោ យាគុបិ បីតា ន សម្មាបរិណាមំ គច្ឆតិ
ភត្តំបិ ភុត្តំ ន សម្មាបរិណាមំ គច្ឆតិ ឧច្ចារោបិ បស្សា-
វោបិ ន បគុណោ សោ តេន កិសោ លូខោ ទុព្វណ្ណោ
ឧប្បណ្ឌុប្បណ្ឌុកជាតោ ធមនិសន្ថតគត្តោ សាធុ ទេវ
ជីវកំ វេជ្ជំ អាណាបេហិ បុត្តំ មេ តិកិច្ឆតូតិ ។ អថខោ
រាជា មាគធោ សេនិយោ ពិម្ពិសារោ ជីវកំ កោមារ-
ភច្ចំ អាណាបេសិ គច្ឆ ភណេ ជីវក ពារាណសឹ គន្ត្វា
ពារាណសេយ្យកំ សេដ្ឋិបុត្តំ តិកិច្ឆាហីតិ ។ ឯវំ ទេវាតិ
ខោ ជីវកោ កោមារភច្ចោ រញ្ញោ មាគធស្ស សេនិយស្ស
ពិម្ពិសារស្ស បដិស្សុណិត្វា ពារាណសឹ គន្ត្វា យេន
ពារាណសេយ្យកោ សេដ្ឋិបុត្តោ តេនុបសង្កមិ ឧប-
សង្កមិត្វា ពារាណសេយ្យកស្ស សេដ្ឋិបុត្តស្ស វិការំ
សល្លក្ខេត្វា ជនំ ឧស្សារេត្វា តិរោករណឹ បរិក្ខិបិត្វា



បានទៅឯក្រុងរាជគ្រឹះហើយចូលទៅគាល់ព្រះបាទមាគធរាជសេនិយពិម្ពិសារ
លុះចូលទៅដល់ហើយក៏ក្រាបទូលព្រះបាទមាគធរាជសេនិយពិម្ពិសារដូច្នេះ
ថា សូមទ្រង់ព្រះមេត្តាប្រោស ដ្បិតកូនខ្ញុំព្រះអង្គប្រកបដូច្នោះ ទឹកបបរ
ដែលកូនខ្ញុំព្រះអង្គបរិភោគទៅក្តី ក៏មិនបានរលួយស្រួល បាយដែលបរិភោគ
ទៅហើយក្តី ក៏មិនបានរលួយស្រួល ឧច្ចារៈក្តី បស្សាវៈក្តី ក៏មិនដែលបាន
ស្រួលសោះ ព្រោះរោគនោះ កូនខ្ញុំព្រះអង្គទៅជាស្គមសៅហ្មងមានសម្បុរ
អាក្រក់កើតរោគលឿងស្លេកស្លាំង មានខ្លួនពេញដោយសរសៃ ខ្ញុំព្រះអង្គ
សូមអង្វរ សូមព្រះសម្មតិទេពទ្រង់បង្គាប់ពេទ្យជីវកៈឲ្យព្យាបាលកូនខ្ញុំ
ព្រះអង្គ ។ ខណៈនោះ ព្រះបាទមាគធរាជសេនិយពិម្ពិសារទ្រង់បង្គាប់ជីវកកោ-
មារភច្ចថា ម្នាលជីវកៈ ចូរអ្នកឯងទៅក្រុងពារាណសីហើយព្យាបាល
កូនសេដ្ឋីនៅក្នុងក្រុងពារាណសីផង ។ ជីវកកោមារភច្ចទទួលព្រះរាជ-
ឱង្ការព្រះបាទមាគធរាជសេនិយពិម្ពិសារដោយពាក្យថា បពិត្រព្រះសម្មតិ-
ទេពករុណាវិសេស ហើយទៅកាន់ក្រុងពារាណសី ចូលទៅរកកូនសេដ្ឋីនៅ
ក្រុងពារាណសី លុះចូលទៅដល់ហើយក៏សង្កេតមើលវិការរបស់កូនសេដ្ឋីនៅក្រុង
ពារាណសី រួចបណ្តេញជនឲ្យចេញ ហើយបិទបាំងរនាំងជុំវិញក្រៅ

ថម្ភេ ឧបនិពន្ធិត្វា(១) ភរិយំ បុរតោ ឋបេត្វា ឧទរច្ឆវឹ ឧប្បាដេត្វា(២) អន្តគណ្ឋឹ នីហរិត្វា ភរិយាយ ទស្សេសិ បស្ស តេ សាមិកស្ស អាពាធំ ឥមិនា យាគុបិ បីតា ន សម្មា បរិណាមំ គច្ឆតិ ភត្តំបិ ភុត្តំ ន សម្មា បរិណាមំ គច្ឆតិ ឧច្ចារោបិ បស្សាវោបិ ន បគុណោ ឥមិនាយំ កិសោ លូខោ ទុព្វណ្ណោ ឧប្បណ្ឌុប្បណ្ឌុកជាតោ ធមនិសន្ថតគត្តោតិ អន្តគណ្ឋឹ វិនិវេឋេត្វា អន្តានិ បដិប្បវេសេត្វា ឧទរច្ឆវឹ សិព្វិត្វា អាលេបំ អទាសិ ។ អថខោ ពារាណសេយ្យកោ សេដ្ឋិបុត្តោ នចិរស្សេវ អរោគោ អហោសិ ។ អថខោ ពារាណសេយ្យកោ សេដ្ឋី បុត្តោ មេ អរោគោ ឋិតោតិ ជីវកស្ស កោមារភច្ចស្ស សោឡសសហស្សានិ អទាសិ ។ អថខោ ជីវកោ កោមារភច្ចោ តានិ សោឡស សហស្សានិ អាទាយ បុនទេវ រាជគហំ បច្ចាគច្ឆិ ។

១ ម. ឧព្ពន្ធិត្វា ។ ២ ម. ឧប្បាលេត្វា ។



ហើយចងខ្លួនសេដ្ឋីភ្ជាប់នឹងសសរ រួចឲ្យភរិយា (នៃសេដ្ឋីបុត្ត) ឈរនៅពីខាងមុខរួចវះស្បែកពោះទាញយកដុំក្ដួនពោះវៀនចេញបង្ហាញដល់ភរិយា (សេដ្ឋីបុត្តនោះ) ថា នាងចូរមើលអាពាធរបស់ស្វាមីនាង បបរដែលផឹកទៅហើយក្ដី ក៏មិនបានរលួយស្រួល បាយដែលបរិភោគទៅហើយក្ដី ក៏មិនបានរលួយស្រួល ឧច្ចារៈក្ដី បស្សាវៈក្ដី ក៏មិនដែលបានស្រួល ព្រោះតែអាពាធនេះហើយ បានជាស្វាមីរបស់នាងនេះទៅជាស្គមសៅហ្មង មានសម្បុរអាក្រក់ កើតរោគស្លេកស្លាំង មានខ្លួនពេញដោយសរសៃ (ជាហើយក៏) ស្រាយដុំពកក្ដួនពោះវៀនចេញ ហើយបញ្ចូលពោះវៀនទៅវិញ ដេរស្បែកពោះហើយលាបថ្នាំឲ្យ ។ វេលានោះ មិនយូរប៉ុន្មានកូនសេដ្ឋីនៅក្រុងពារាណសីក៏បានសះជារោគនោះទៅ ។ គ្រានោះ សេដ្ឋីនៅក្រុងពារាណសីគិតថា កូនរបស់អាត្មាអញបានសះជារោគហើយ ក៏បានឲ្យរង្វាន់ទ្រព្យ ១៦ ពាន់កហាបណៈដល់ជីវកកោមារភច្ច ។ គ្រានោះ ជីវកកោមារភច្ចបានទទួលទ្រព្យទាំង ១៦ ពាន់កហាបណៈនោះ ហើយក៏ត្រឡប់មកក្រុងរាជគ្រឹះវិញ ។

[៦០] តេន ខោ បន សមយេន ឧជ្ជេនិយំ(១) រញ្ញោ បជ្ជោតស្ស បណ្ឌុរោគាពាធោ ហោតិ ។ ពហូ មហន្តា មហន្តា ទិសាបាមោក្ខា វេជ្ជា អាគន្ត្វា ន ស-ក្ខឹសុ អរោគំ កាតុំ ពហុំ ហិរញ្ញំ អាទាយ អគមំសុ ។ អថ ខោ រាជា បជ្ជោតោ រញ្ញោ មាគធស្ស សេនិយស្ស ពិម្ពិសារស្ស សន្តិកេ ទូតំ បាហេសិ មយ្ហំ ខោ ទេវ(២) តាទិសោ អាពាធោ សាធុ ទេវោ ជីវកំ វេជ្ជំ អាណាបេតុ សោ មំ តិកិច្ឆិស្សតីតិ ។ អថ ខោ រាជា មាគធោ សេនិយោ ពិម្ពិសារោ ជីវកំ កោមារភច្ចំ អាណាបេសិ គច្ឆ ភណេ ជីវក ឧជ្ជេនឹ គន្ត្វា រាជានំ បជ្ជោតំ តិ-កិច្ឆាហីតិ ។ ឯវំ ទេវាតិ ខោ ជីវកោ កោមារភច្ចោ រញ្ញោ មាគធស្ស សេនិយស្ស ពិម្ពិសារស្ស បដិស្សុណិ-ត្វា ឧជ្ជេនឹ គន្ត្វា យេន រាជា បជ្ជោតោ តេនុបសង្កមិ ឧបសង្កមិត្វា រញ្ញោ បជ្ជោតស្ស វិការំ សល្លក្ខេត្វា រាជានំ បជ្ជោតំ ឯតទវោច សប្បឹ ទេវ និប្បចិស្សាមិ

១ សោធិតបោត្ថកេ អយំ បាឋោ ន ហោតិ ។ ២ ឥទំ បទំ ... ទិស្សតិ ។



[៦០] សម័យនោះឯង ព្រះបាទបជ្ជោតក្នុងក្រុងឧជ្ជេនី ទ្រង់ការពាធដោយរោគស្លេក ។ ពួកពេទ្យដែលជាទិសាបាមោក្ខ ធំ ៗ ច្រើននាក់មកព្យាបាល ក៏មិនអាចនឹងធ្វើរោគនោះឲ្យស្រះជាបាន នាំយកតែប្រាក់ទៅជាច្រើន ។ គ្រានោះ ព្រះបាទបជ្ជោតក៏បានបញ្ជូនព្រះរាជបម្រើឲ្យទៅកាន់សំណាក់ស្តេចមាគធសេនិយពិម្ពិសារ ដោយព្រះបន្ទូលថា សូមទ្រង់ព្រះមេត្តាប្រោស ជម្ងឺខ្ញុំប្រាកដដូច្នោះ ខ្ញុំសូមអង្វរ សូមព្រះសម្មតិទេព ទ្រង់ត្រាស់បង្គាប់ទៅជីវកពេទ្យ ឲ្យនាត់ទៅព្យាបាលរោគខ្ញុំ ។ ខណៈនោះ ព្រះបាទមាគធសេនិយពិម្ពិសារ ទ្រង់បង្គាប់ទៅជីវកកោមារភច្ចថា នែនាយជីវកៈ ចូរអ្នកទៅក្រុងឧជ្ជេនី ហើយព្យាបាលព្រះបាទបជ្ជោតចុះ ។ ជីវកកោមារភច្ចទទួលស្តាប់ព្រះរាជឱង្ការព្រះបាទមាគធសេនិយពិម្ពិសារ ដោយពាក្យថា បពិត្រព្រះសម្មតិទេព ព្រះករុណាវិសេស ហើយទៅកាន់ក្រុងឧជ្ជេនី ក៏ចូលទៅគាល់ព្រះបាទបជ្ជោត លុះចូលទៅគាល់ហើយ ក៏សង្កេតស្គាល់វិការៈរបស់ព្រះបាទបជ្ជោត ហើយក៏ក្រាបបង្គំទូលព្រះបាទបជ្ជោតយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គនឹងស្ងោសប្បិថ្វាយ

តំ ទេវោ បិវិស្សតីតិ ។ អលំ ភណេ ជីវក យន្តេ សក្កា វិនា សប្បិនា អរោគំ កាតុំ តំ ករោហិ ជេគុច្ឆំ មេ សប្បិ បដិក្កូលន្តិ ។ អថខោ ជីវកស្ស កោមារភច្ចស្ស ឯតទហោសិ ឥមស្ស ខោ រញ្ញោ តាទិសោ អាពាធោ ន សក្កា មយា[១] វិនា សប្បិនា អរោគំ កាតុំ យន្នូនាហំ សប្បិំ និបច្ចេយ្យំ កសាវវណ្ណំ កសាវគន្ធំ កសាវរសន្តិ ។ អថខោ ជីវកោ កោមារភច្ចោ នានាភេសជ្ជេហិ សប្បិំ និបចិ កសាវវណ្ណំ កសាវគន្ធំ កសាវរសំ ។ អថខោ ជីវកស្ស កោមារភច្ចស្ស ឯតទហោសិ ឥមស្ស ខោ រញ្ញោ សប្បិ បីតំ បរិណាមេន្តំ ឧទ្ទេកំ ទស្សតិ ចណ្ឌោយំ រាជា ឃាតាបេយ្យាបិ មំ យន្នូនាហំ បដិកច្ចេវ អាបុច្ឆេយ្យន្តិ ។ អថខោ ជីវកោ កោមារភច្ចោ យេន រាជា បជ្ជោតោ តេនុបសង្កមិ ឧបសង្កមិត្វា រាជានំ បជ្ជោតំ ឯតទវោច មយំ ខោ ទេវ វេជ្ជា នាម តាទិសេន មុហុត្តេន មូលានិ ឧទ្ធរាម ភេសជ្ជានិ

១ ឧភយបោត្ថកេ អយំ បាឋោ ន បញ្ញាយតិ ។



ព្រះសម្មតិទេពនឹងសោយសប្បិនោះបានដែរឬ ។ ព្រះមហាក្សត្រត្រាស់ថា នែនាយជីវកៈ មិនបានទេ អ្នកឯងអាចនឹងរក្សារោគឲ្យបានសះជាដោយថ្នាំណាមួយវិញ វៀរលែងតែសប្បិចេញ ព្រោះអញខ្ពើមណាស់ ព្រោះសប្បិជាទីខ្ពើមរអើមរបស់អញ ។ លំដាប់នោះ ជីវកកោមារភច្ចមានសេចក្តីរិះគិតដូច្នេះថា អាពាធរបស់ស្តេចនេះប្រាកដដូច្នោះ តែវៀរលែងសប្បិចេញហើយ អាត្មាអញមិនអាចនឹងធ្វើឲ្យសះជាបានឡើយ ។ បើដូច្នោះគួរអាត្មាអញនឹងស្លសប្បិ (នោះ) ឲ្យមានពណ៌ដូចទឹកចត់ ឲ្យមានក្លិនដូចក្លិនទឹកចត់ ឲ្យមានរសដូចរសទឹកចត់វិញ ។ លំដាប់នោះ ជីវកកោមារភច្ចស្លសប្បិឲ្យមានពណ៌ដូចជាពណ៌ទឹកចត់ មានក្លិនដូចជាក្លិនទឹកចត់ មានរសដូចជារសទឹកចត់ ជាមួយនឹងថ្នាំទាំងឡាយផ្សេងៗ ។ លំដាប់នោះ ជីវកកោមារភច្ចមានសេចក្តីរិះគិតដូច្នេះថា សប្បិដែលស្តេចនេះសោយហើយដល់ប្រែប្រួលទៅមុខជានឹងចង្អោរចេញ ហើយស្តេចកំណាចនេះនឹងបង្គាប់មនុស្សឲ្យសម្លាប់អាត្មាអញមិនខានឡើយ បើដូច្នោះគួរអាត្មាអញសូមលាជាមុនឲ្យហើយ ។ វេលានោះ ជីវកកោមារភច្ចបានចូលទៅគាល់ព្រះបាទបជ្ជោត លុះចូលទៅដល់ហើយក៏បានក្រាបបង្គំទូលសេចក្តីនេះនឹងព្រះបាទបជ្ជោតថា បពិត្រព្រះសម្មតិទេព ធម្មតាពួកខ្ញុំជាពេទ្យតែងគាស់យកឫសឈើមកផ្សំថ្នាំដោយការរហ័សយ៉ាងនោះ

សំហរាម សាធុ ទេវ វាហនាគារេសុ ច ទ្វារេសុ ច អាណាបេតុ យេន វាហនេន ជីវកោ ឥច្ឆតិ តេន វាហនេន គច្ឆតុ យេន ទ្វារេន ឥច្ឆតិ តេន ទ្វារេន គច្ឆតុ យំ កាលំ ឥច្ឆតិ តំ កាលំ គច្ឆតុ យំ កាលំ ឥច្ឆតិ តំ កាលំ បវិសតូតិ ។ អថខោ រាជា បជ្ជោតោ វាហនាគារេសុ ច ទ្វារេសុ ច អាណាបេសិ យេន វាហនេន ជីវកោ ឥច្ឆតិ តេន វាហនេន គច្ឆតុ យេន ទ្វារេន ឥច្ឆតិ តេន ទ្វារេន គច្ឆតុ យំ កាលំ ឥច្ឆតិ តំ កាលំ គច្ឆតុ យំ កាលំ ឥច្ឆតិ តំ កាលំ បវិសតូតិ ។ តេន ខោ បន សមយេន រញ្ញោ បជ្ជោតស្ស ភទ្ទវតិកា នាម ហត្ថិនិកា បញ្ញាសយោជនិកា ហោតិ ។ អថខោ ជីវកោ កោមារភច្ចោ រញ្ញោ បជ្ជោតស្ស សប្បឹ ឧបនាមេសិ កសាវំ ទេវ បិវតូតិ ។ អថខោ ជីវកោ កោមារភច្ចោ រាជានំ បជ្ជោតំ សប្បឹ បាយេត្វា ហត្ថិសាលំ គន្ត្វា ភទ្ទវតិកាយ ហត្ថិនិកាយ នគរម្ហា និយ្យាសិ ។



សូមអម្ចាស់ សូមព្រះសម្មតិទេពទ្រង់ត្រាស់បង្គាប់ពួកអ្នកដែលនៅចាំរោងសម្រាប់ដាក់យានៈ ហើយនិងពួកអ្នករក្សាទ្វារថា (បើ) ជីវកៈប្រាថ្នាទៅដោយយានៈណា ចូរឲ្យទៅដោយយានៈនោះ ជីវកៈប្រាថ្នាទៅតាមទ្វារណា ចូរឲ្យទៅតាមទ្វារនោះ ជីវកៈប្រាថ្នាចង់ទៅក្នុងកាលណា ត្រូវឲ្យទៅក្នុងកាលនោះ ជីវកៈប្រាថ្នាចង់ចូលមកក្នុងក្រុងកាលណា ត្រូវឲ្យចូលមកក្នុងកាលនោះចុះ ។ ខណៈនោះ ព្រះបាទបជ្ជោតក៏បានត្រាស់បង្គាប់ទៅពួកអ្នកនៅចាំរោងសម្រាប់ដាក់យានៈនិងពួកអ្នករក្សាទ្វារថា (បើ) ជីវកៈប្រាថ្នាទៅដោយយានៈណា ចូរឲ្យទៅដោយយានៈនោះ ជីវកៈប្រាថ្នាទៅតាមទ្វារណា ចូរឲ្យទៅតាមទ្វារនោះ ជីវកៈប្រាថ្នាទៅក្នុងកាលណា ចូរឲ្យទៅក្នុងកាលនោះ ជីវកៈប្រាថ្នាចូលមកក្នុងក្រុងកាលណា ចូរឲ្យចូលមកក្នុងកាលនោះចុះ ។ សម័យនោះ ព្រះបាទបជ្ជោតមានមេដំរីមួយឈ្មោះភទ្ទវតិកា អាចដើរទៅបាន ៥០ យោជន៍ (ក្នុង ១ ថ្ងៃ) ។ វេលានោះ ជីវកកោមារភច្ចក៏បានបង្អោនថ្វាយសប្បិនោះទៅព្រះបាទបជ្ជោតថា សូមព្រះសម្មតិទេពទ្រង់សោយទឹកចត់ (នេះ) ។ លំដាប់នោះ ជីវកកោមារភច្ចបានឲ្យព្រះបាទបជ្ជោត សោយសប្បិរួចហើយ ក៏ទៅកាន់រោងដំរី (ឡើងជិះ) លើមេដំរីឈ្មោះភទ្ទវតិកា ហើយក៏ចេញពីក្រុងទៅ ។

អថខោ រញ្ញោ បជ្ជោតស្ស តំ សប្បឹ បីតំ បរិណាមេន្តំ ឧទ្ទេកំ អទាសិ ។ អថខោ រាជា បជ្ជោតោ មនុស្សេ អាណាបេសិ ទុដ្ឋេន ភណេ ជីវកេន សប្បឹ បាយិតោម្ហិ តេនហិ ភណេ ជីវកំ វេជ្ជំ វិចិនថាតិ ។ ភទ្ទវតិកាយ ទេវ ហត្ថិនិកាយ នគរម្ហា និយ្យាតោតិ ។ តេន ខោ បន សមយេន រញ្ញោ បជ្ជោតស្ស កាកោ នាម ទាសោ សដ្ឋិយោជនិកោ ហោតិ អមនុស្សេន បដិច្ច ជាតោ ។ អថខោ រាជា បជ្ជោតោ កាកំ ទាសំ អាណាបេសិ គច្ឆ ភណេ កាក ជីវកំ វេជ្ជំ និវត្តេហិ រាជា តំ អាចរិយ និវត្តាបេតីតិ ឯតេ ខោ ភណេ កាក វេជ្ជា នាម ពហុមាយា មា ចស្ស កិញ្ចិ បដិគ្គហេសីតិ ។ អថខោ កាកោ ទាសោ ជីវកំ កោមារភច្ចំ អន្តរាមគ្គេ កោសម្ពិយំ សម្ភាវេសិ បាតរាសំ ករោន្តំ ។ អថខោ កាកោ ទាសោ ជីវកំ កោមារភច្ចំ ឯតទវោច រាជា តំ អាចរិយ និវត្តាបេតីតិ ។ អាគមេហិ ភណេ កាក



គ្រានោះ សប្បិដែលព្រះបាទបជ្ជោតបានសោយហើយ ដែលប្រែប្រួលទៅក៏បង្ហូរចេញមក ។ វេលានោះ ព្រះបាទបជ្ជោតទ្រង់មានបន្ទូលទៅនឹងមនុស្សទាំងឡាយថា នែនាយ (ឥឡូវនេះ) ជីវកៈកំណាចបានឱ្យអញផឹកសប្បិទៅហើយ នែនាយ បើដូច្នោះ ចូរអ្នកទាំងឡាយទៅតាមរកមើលពេទ្យជីវកៈ ។ មនុស្សទាំងនោះក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស (ឯពេទ្យជីវកៈនោះ) គាត់ជិះដំរីឈ្មោះភទ្ទវតិកាបរចេញអំពីក្រុងបាត់ទៅហើយ ។ សម័យនោះឯង មានខ្ញុំម្នាក់របស់ព្រះបាទបជ្ជោតឈ្មោះកាកៈ អាចដើរទៅបានចំនួន ៦០ យោជន៍ (ក្នុង ១ ថ្ងៃ) ព្រោះអាស្រ័យដោយអមនុស្ស ។ គ្រានោះ ព្រះបាទបជ្ជោតទ្រង់បង្គាប់ទៅខ្ញុំឈ្មោះកាកៈថា នែនាយកាកៈ ចូរឯងទៅ ឱ្យពេទ្យជីវកៈត្រឡប់មកវិញថា លោកអាចារ្យ ព្រះមហាក្សត្រឱ្យលោកត្រឡប់ទៅវិញ (កុំឱ្យនៅ) នែនាយកាកៈ ធម្មតាពួកពេទ្យនេះតែងមានឧបាយច្រើន ម្យ៉ាងទៀត ឯងកុំទទួលយករបស់បន្តិចបន្តួចរបស់ពេទ្យនោះឡើយ ។ លំដាប់នោះ ខ្ញុំឈ្មោះកាកៈក៏បានតាមទៅទាន់ជីវកកោមារភច្ចកំពុងបរិភោគបាយព្រឹក គឺនៅកាត់កណ្តាលផ្លូវ ជិតក្រុងកោសម្ពី ។ វេលានោះ ខ្ញុំឈ្មោះកាកៈបាននិយាយទៅនឹងជីវកកោមារភច្ចដូច្នេះថា លោកអាចារ្យ ព្រះមហាក្សត្រឱ្យលោកត្រឡប់ទៅវិញ ។ ជីវកកោមារភច្ចតបថា នែនាយកាកៈ

យាវ ភុញ្ជាមិ(១) ហន្ទ ភណេ កាក ភុញ្ជស្សូតិ ។ អលំ អាចរិយ រញ្ញាម្ហិ អាណត្តោ ឯតេ ភណេ កាក វេជ្ជា នាម ពហុមាយា មា ចស្ស កិញ្ចិ បដិគ្គហេសីតិ ។ តេន ខោ បន សមយេន ជីវកោ កោមារភច្ចោ នខេន ភេសជ្ជំ ឱលុម្បេត្វា អាមលកញ្ច ខាទតិ បានីយញ្ច បិវតិ ។ អថខោ ជីវកោ កោមារភច្ចោ កាកំ ទាសំ ឯតទវោច ហន្ទ ភណេ កាក អាមលកញ្ច ខាទ បានីយញ្ច បិវស្សូតិ ។ អថខោ កាកោ ទាសោ អយំ ខោ វេជ្ជោ អាមលកញ្ច ខាទតិ បានីយញ្ច បិវតិ ន អរហតិ កិញ្ចិ បាបកំ ហោតុន្តិ ឧបឌ្ឍាមលកញ្ច ខាទិ បានីយញ្ច អបាយិ ។ តស្ស តំ ឧបឌ្ឍាមលកំ ខាទិតំ តត្ថេវ និច្ឆារេសិ ។ អថខោ កាកោ ទាសោ ជីវកំ កោមារភច្ចំ ឯតទវោច អត្ថិ មេ អាចរិយ ជីវិតន្តិ ។ មា ភណេ កាក ភាយិ ត្វញ្ចេវ អរោគោ ភវិស្សសិ រាជា ច ចណ្ឌោ សោ រាជា ឃាតាបេយ្យ មំ តេនាហំ ន និវត្តាមីតិ ហត្ថិនឹ

១ ម. ភុញ្ជាមិ ។



ចូរអ្នកឯងចាំទាល់តែយើងបរិភោគរួចសិន នែនាយកាកៈ បើដូច្នោះចូរអ្នកបរិភោគបាយសិន ។ កាកៈតបថា លោកអាចារ្យ កុំព្រួយ ដ្បិតខ្ញុំព្រះមហាក្សត្រទ្រង់ត្រាស់បង្គាប់ថា នែនាយកាកៈ ពួកពេទ្យទាំងនេះតែងតែមានមាយាច្រើន ម្យ៉ាងទៀត អ្នកឯងកុំទទួលរបស់បន្តិចបន្តួចរបស់ពេទ្យនោះឡើយ ។ សម័យនោះឯង ជីវកកោមារភច្ចបានបិទថ្នាំដោយក្រចក ហើយទំពាស៊ីផ្លែកន្ទួតព្រៃផង ផឹកទឹកផង ។ វេលានោះ ជីវកកោមារភច្ចក៏និយាយទៅនឹងខ្ញុំឈ្មោះកាកៈដូច្នេះថា នែនាយកាកៈ បើដូច្នោះ អ្នកចូរទំពាស៊ីផ្លែកន្ទួតព្រៃផង ផឹកទឹកផងចុះ ។ លំដាប់នោះ ខ្ញុំឈ្មោះកាកៈគិតថា ពេទ្យនេះឯងហ្ន៎ ទំពាស៊ីផ្លែកន្ទួតព្រៃផង ផឹកទឹកផង ពេទ្យនេះមិនគួរនឹងមានអំពើអាក្រក់តិចតួចឡើយ ហើយក៏ទំពាស៊ីផ្លែកន្ទួតព្រៃមួយចំហៀងផង ផឹកទឹកផង ។ ផ្លែកន្ទួតព្រៃមួយចំហៀងដែលខ្ញុំឈ្មោះកាកៈទំពាស៊ីហើយនោះ ក៏ចុះរាគក្នុងទីនោះឯង ។ ខណៈនោះ ខ្ញុំឈ្មោះកាកៈបាននិយាយទៅនឹងជីវកកោមារភច្ចដូច្នេះថា លោកអាចារ្យ ខ្ញុំនៅមានជីវិត (រស់នៅទៀតឬទេ) ។ ជីវកកោមារភច្ចប្រាប់ថា នែនាយកាកៈ អ្នកឯងកុំភ័យឡើយ ខ្លួនអ្នកឯងក្ដី ស្ដេចកំណាចក្ដី នឹងបានសះជារោគហើយ ស្ដេចនោះនឹងឲ្យគេសម្លាប់ខ្ញុំមិនខាន ព្រោះហេតុនោះ បានជាខ្ញុំមិនត្រឡប់ទៅវិញជាដូច្នោះ ហើយក៏ប្រគល់ដំរីឈ្មោះភទ្ទវតិកា

ហត្ថិនិកំ កាកស្ស និយ្យាតេត្វា យេន រាជគហំ តេន បក្កាមិ អនុបុព្វេន យេន រាជគហំ យេន រាជា មាគធោ សេនិយោ ពិម្ពិសារោ តេនុបសង្កមិ ឧបសង្កមិត្វា រញ្ញោ មាគធស្ស សេនិយស្ស ពិម្ពិសារស្ស ឯតមត្ថំ អារោចេសិ ។ សុដ្ឋុ ភណេ ជីវក អកាសិ យម្បិ ន អាគតោ ចណ្ឌោ សោ រាជា ឃាតេយ្យាបិ តន្តិ ។ អថខោ រាជា បជ្ជោតោ អរោគោ សមានោ ជីវកស្ស កោមារភច្ចស្ស សន្តិកេ ទូតំ បាហេសិ អាគច្ឆតុ ជីវកោ វរំ ទស្សាមីតិ ។ អលំ ទេវ[១] អធិការំ មេ ទេវោ សរតូតិ ។ តេន ខោ បន សមយេន រញ្ញោ បជ្ជោតស្ស សិវេយ្យកំ ទុស្សយុគំ ឧប្បន្នំ ហោតិ ពហូនំ ទុស្សានំ ពហូនំ ទុស្សយុគានំ ពហូនំ ទុស្សយុគសតានំ ពហូនំ ទុស្សយុគសហស្សានំ ពហូនំ ទុស្សយុគសតសហស្សានំ អគ្គញ្ច សេដ្ឋញ្ច មោក្ខញ្ច ឧត្តមញ្ច បវរញ្ច ។ អថខោ រាជា បជ្ជោតោ តំ សិវេយ្យកំ ទុស្សយុគំ

១ ឱ. អយ្យោ ។



ទៅវិញឈ្មោះកាកវិញ ហើយចៀសចេញទៅកាន់ក្រុងរាជគ្រឹះ ចូលទៅគាល់ព្រះបាទមាគធសេនិយពិម្ពិសារ ក្នុងក្រុងរាជគ្រឹះដោយលំដាប់ លុះចូលទៅដល់ហើយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះបាទមាគធសេនិយពិម្ពិសារ ។ ស្តេចទ្រង់ត្រាស់តបថា នែជីវកៈ អ្នកឯងមិនបានវិលត្រឡប់ទៅវិញដោយហេតុណា ឈ្មោះថាបានធ្វើនូវហេតុនោះដោយល្អហើយ ស្តេចនោះមុខជានឹងប្រហារជីវិតអ្នកឯងមិនខាន ។ គ្រានោះ ព្រះបាទបជ្ជោតបានសះជាពីរោគហើយក៏បញ្ជូនទូតឲ្យទៅក្នុងសំណាក់ជីវកកោមារភច្ចថា សូមឲ្យជីវកៈមក ( ខ្ញុំនឹង ) យើងនឹងឲ្យពរ ។ ជីវកកោមារភច្ចតបថា សូមទ្រង់ព្រះមេត្តាប្រោស កុំព្រួយព្រះទ័យ សូមព្រះសម្មតិទេពគ្រាន់តែទ្រង់រលឹកនូវឧបការៈរបស់ខ្ញុំព្រះអង្គចុះ ។ សម័យនោះ សំពត់សិវេយ្យកៈ ១ គូ កើតឡើងដល់ព្រះបាទបជ្ជោត ជាសំពត់ដ៏លើសលុបប្រសើរជាប្រធានខ្ពង់ខ្ពស់ថ្លៃវិសេសជាងសំពត់ដ៏ច្រើន ជាងគូនៃសំពត់ដ៏ច្រើន ជាងរយនៃគូសំពត់ដ៏ច្រើន ជាងពាន់នៃគូសំពត់ដ៏ច្រើន ជាងសែននៃគូសំពត់ដ៏ច្រើន ។ លំដាប់នោះ ព្រះបាទបជ្ជោតបានបញ្ជូនសំពត់សិវេយ្យកៈ ១ គូនោះ

ជីវកស្ស កោមារភច្ចស្ស បាហេសិ ។ អថខោ ជីវកស្ស កោមារភច្ចស្ស ឯតទហោសិ ឥទំ ខោ មេ សិវេយ្យកំ ទុស្សយុគំ រញ្ញា បជ្ជោតេន បហិតំ ពហូនំ ទុស្សានំ ពហូនំ ទុស្សយុគានំ ពហូនំ ទុស្សយុគសតានំ ពហូនំ ទុស្សយុគសហស្សានំ ពហូនំ ទុស្សយុគសតសហស្សានំ អគ្គញ្ច សេដ្ឋញ្ច មោក្ខញ្ច ឧត្តមញ្ច បវរញ្ច នយិមំ អញ្ញោ កោចិ អរហតិ បដិគ្គហេតុំ អញ្ញត្រ តេន ភគវតា អរហតា សម្មាសម្ពុទ្ធេន រញ្ញោ វា មាគធេន សេនិយេន ពិម្ពិសារេនាតិ ។

[៦០] តេន ខោ បន សមយេន ភគវតោ កាយោ ទោសាភិសន្នោ ហោតិ ។ អថខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ ទោសាភិសន្នោ ខោ អានន្ទ តថាគតស្ស កាយោ ឥច្ឆតិ តថាគតោ វិរេចំ បាតុន្តិ ។ អថខោ អាយស្មា អានន្ទោ យេន ជីវកោ កោមារភច្ចោ តេនុបសង្កមិ ឧបសង្កមិត្វា ជីវកំ កោមារភច្ចំ ឯតទវោច ទោសាភិសន្នោ ខោ អាវុសោ ជីវក តថាគតស្ស កាយោ ឥច្ឆតិ តថាគតោ វិរេចំ បាតុន្តិ ។



ទៅជីវកកោមារភច្ច ។ លំដាប់នោះ ជីវកកោមារភច្ចបានសេចក្តីរិះគិតដូច្នេះថា ជាសំពត់សិវេយ្យកៈ ១ គូដែលព្រះបាទបជ្ជោតបញ្ជូនមកឲ្យអាត្មាអញនេះ ជាសំពត់ដ៏ល្អវិសេសលើសលុបប្រសើរជាប្រធានខ្ពង់ខ្ពស់ក្រៃលែង ជាងសំពត់ដ៏ច្រើន ជាងគូនៃសំពត់ដ៏ច្រើន ជាងរយនៃគូសំពត់ដ៏ច្រើន ជាងពាន់នៃគូសំពត់ដ៏ច្រើន ជាងសែននៃគូសំពត់ដ៏ច្រើន អ្នកដទៃណាមួយមិនគួរនឹងប្រើប្រាស់សំពត់សិវេយ្យកៈនេះឡើយ វៀរលែងតែព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធនោះចេញ ឬវៀរលែងតែព្រះបាទមាគធសេនិយពិម្ពិសារចេញ ។

[៦១] សម័យនោះឯង ព្រះកាយរបស់ព្រះមានព្រះភាគក្រាស់ដោយទោស (កង្វល់) ។ វេលានោះ ព្រះមានព្រះភាគត្រាស់ហៅព្រះអានន្ទដ៏មានអាយុមកថា ម្នាលអានន្ទ កាយរបស់តថាគតក្រាស់ដោយទោសហើយ តថាគតត្រូវការនឹងឆាន់ថ្នាំបញ្ចុះ ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុក៏ចូលទៅរកជីវកកោមារភច្ច លុះចូលទៅដល់ហើយ ក៏និយាយនឹងជីវកកោមារភច្ចដូច្នេះថា នែជីវកៈដ៏មានអាយុ កាយរបស់ព្រះតថាគតក្រាស់ដោយទោសហើយ ព្រះតថាគតត្រូវការនឹងឆាន់ថ្នាំបញ្ចុះ ។

តេនហិ ភន្តេ អានន្ទ ភគវតោ កាយំ កតិបាហំ
សិនេហេថាតិ ។ អថខោ អាយស្មា អានន្ទោ ភគ-
វតោ កាយំ កតិបាហំ សិនេហេត្វា យេន ជីវកោ
កោមារភច្ចោ តេនុបសង្កមិ ឧបសង្កមិត្វា ជីវកំ កោ-
មារភច្ចំ ឯតទវោច សិនិទ្ធោ ខោ អាវុសោ ជីវក
តថាគតស្ស កាយោ យស្សទានិ កាលំ មញ្ញសីតិ ។
អថខោ ជីវកស្ស កោមារភច្ចស្ស ឯតទហោសិ ន
ខោ មេ តំ បតិរូបំ យោហំ ភគវតោ ឱឡារិកំ
វិរេចនំ ទទេយ្យំ យន្នូនាហំ តីណិ ឧប្បលហត្ថានិ
នានាភេសជ្ជេហិ បរិភាវេត្វា តថាគតស្ស ឧបនា-
មេយ្យន្តិ ។ អថខោ ជីវកោ កោមារភច្ចោ តីណិ
ឧប្បលហត្ថានិ នានាភេសជ្ជេហិ បរិភាវេត្វា យេន
ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ឯកំ ឧប្បលហត្ថំ
ភគវតោ ឧបនាមេសិ ឥមំ ភន្តេ ភគវា បឋមំ ឧប្ប-
លហត្ថំ ឧបសិង្ឃតុ ឥទំ ភគវន្តំ ទសក្ខត្តុំ វិរេចេស្សតីតិ
ទុតិយំ ឧប្បលហត្ថំ ភគវតោ ឧបនាមេសិ ឥមំ ភន្តេ



ជីវកកោមារភច្ចតបថា បពិត្រព្រះអានន្ទដ៏ចំរើន បើដូច្នោះសូមឲ្យ
លោកស្រឡាបព្រះកាយរបស់ព្រះដ៏មានព្រះភាគបាន ២ ៣ ថ្ងៃសិន ។
លំដាប់នោះ ព្រះអានន្ទដ៏មានអាយុបានស្រឡាបព្រះកាយរបស់ព្រះដ៏មាន
ព្រះភាគ ២ ៣ ថ្ងៃ រួចហើយក៏ចូលទៅរកជីវកកោមារភច្ច លុះចូល
ទៅដល់ហើយក៏និយាយនឹងជីវកកោមារភច្ចដូច្នេះថា ម្នាលអាវុសោជីវកៈ
ព្រះកាយរបស់ព្រះតថាគតបានស្រួលខ្លួនហើយ អ្នកសំគាល់នូវកាល
គួរក្នុងកាលឥឡូវនេះចុះ ។ គ្រានោះ ជីវកកោមារភច្ចមានសេចក្តីរិះគិតដូច្នេះ
ថា ការអាត្មាអញថ្វាយថ្នាំបញ្ចុះដ៏គ្រោតគ្រាតដល់ព្រះដ៏មានព្រះភាគ អំពើ
នេះមិនសមគួរដល់អាត្មាអញឡើយ ណ្ហើយចុះ គួរអាត្មាអញអប់ផ្កា
ឧប្បលទាំងឡាយបាន ៣ ក្តាប់ ដោយថ្នាំទាំងឡាយផ្សេងៗ ហើយ
សឹមបង្អោនថ្វាយដល់ព្រះតថាគត ។ គ្រានោះ ជីវកកោមារភច្ចបានអប់
ផ្កាឧប្បល ៣ ក្តាប់ ដោយថ្នាំទាំងឡាយផ្សេងៗ រួចហើយចូលទៅ
គាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយក៏បង្អោនថ្វាយផ្កាឧប្បល
១ ក្តាប់ដល់ព្រះដ៏មានព្រះភាគដោយពាក្យថា សូមទ្រង់ព្រះមេត្តាប្រោស
សូមព្រះដ៏មានព្រះភាគទ្រង់ហិតផ្កាឧប្បល ១ ក្តាប់ដំបូងនេះ ផ្កាឧប្បលនេះ
នឹងបញ្ចុះព្រះដ៏មានព្រះភាគបាន ១០ ដង រួចបង្អោនថ្វាយផ្កាឧប្បលក្តាប់
ទី ២ ដល់ព្រះដ៏មានព្រះភាគដោយពាក្យថា សូមទ្រង់ព្រះមេត្តាប្រោស

ភគវា ទុតិយំ ឧប្បលហត្ថំ ឧបសិង្ឃតុ ឥទំ ភគវន្តំ ទសក្ខត្តុំ វិរេចេស្សតីតិ តតិយំ ឧប្បលហត្ថំ ភគវតោ ឧបនាមេសិ ឥមំ ភន្តេ ភគវា តតិយំ ឧប្បលហត្ថំ ឧបសិង្ឃតុ ឥទំ ភគវន្តំ ទសក្ខត្តុំ វិរេចេស្សតិ ឯវំ ភគវតោ សមតឹសាយ វិរេចនំ ភវិស្សតីតិ ។ អថខោ ជីវកោ កោមារភច្ចោ ភគវតោ សមតឹសាយ វិរេចនំ ទត្វា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ ជីវកស្ស កោមារភច្ចស្ស ពហិទ្វារកោដ្ឋកា និក្ខន្តស្ស ឯតទហោសិ មយា ខោ ភគវតោ សមតឹសាយ វិរេចនំ ទិន្នំ ទោសាភិសន្នោ តថាគតស្ស កាយោ ន ភគវន្តំ សមតឹសក្ខត្តុំ វិរេចេស្សតិ ឯកូនតឹសក្ខត្តុំ ភគវន្តំ វិរេចេស្សតិ អបិច ភគវា វិរិត្តោ នហាយិស្សតិ នហាតំ ភគវន្តំ សកឹ វិរេចេស្សតិ ឯវំ ភគវតោ សមតឹសាយ វិរេចនំ ភវិស្សតីតិ ។ អថ(១) ខោ ភគវា ជីវកស្ស កោមារភច្ចស្ស ចេតសា ចេតោបរិវិតក្កមញ្ញាយ អាយស្មន្តំ អានន្ទំ អាមន្តេសិ

១ អថខោតិ ទិស្សតិ ។





សូមព្រះដ៏មានព្រះភាគទ្រង់ហិតផ្កាឧប្បលក្តាប់ទី ២ នេះ ផ្កាឧប្បលនេះនឹងបញ្ចុះព្រះដ៏មានព្រះភាគបាន ១០ ដង រួចបង្អោនថ្វាយផ្កាឧប្បលក្តាប់ទី ៣ ដល់ព្រះដ៏មានព្រះភាគដោយពាក្យថា សូមទ្រង់មេត្តាប្រោស សូមព្រះដ៏មានព្រះភាគទ្រង់ហិតផ្កាឧប្បលក្តាប់ទី ៣ នេះ ផ្កាឧប្បលនេះនឹងបញ្ចុះព្រះដ៏មានព្រះភាគបាន ១០ ដង រួមក្តីថាផលបញ្ចុះថ្នាំព្រះដ៏មានព្រះភាគគ្រប់ ៣០ ដងគត់ដោយអាការយ៉ាងនេះ ។ លំដាប់នោះ ជីវកកោមារភច្ចបានថ្វាយថ្នាំបញ្ចុះ ៣០ ដងគត់ចំពោះព្រះដ៏មានព្រះភាគ រួចថ្វាយបង្គំព្រះដ៏មានព្រះភាគធ្វើប្រទក្សិណហើយចេញទៅ ។ លំដាប់នោះ ជីវកកោមារភច្ចលុះចេញទៅដល់ក្រៅខ្លោងទ្វារហើយ ក៏មានសេចក្តីរិះគិតដូច្នេះថា ថ្នាំបញ្ចុះចំនួន ៣០ ដងគត់អាត្មាអញបានថ្វាយដល់ព្រះដ៏មានព្រះភាគហើយ ព្រះកាយរបស់ព្រះតថាគតដែលក្រាស់ដោយទោស ថ្នាំនោះនឹងបញ្ចុះព្រះដ៏មានព្រះភាគគ្រប់ ៣០ ដងគត់ទេ មុខជានឹងបញ្ចុះព្រះដ៏មានព្រះភាគត្រឹមតែ២៩ដង ម្យ៉ាងទៀត ព្រះដ៏មានព្រះភាគបានបញ្ចុះថ្នាំហើយ មុខជានឹងស្រង់ទឹក ថ្នាំនោះនឹងបញ្ចុះព្រះដ៏មានព្រះភាគដែលបានស្រង់ទឹកហើយម្តងទៀត រួមជាការបញ្ចុះថ្នាំរបស់ព្រះដ៏មានព្រះភាគ ៣០ ដងគត់ដោយអាការយ៉ាងនេះ ។ ព្រះដ៏មានព្រះភាគបានជ្រាបសេចក្តីរិះគិតនៃចិត្តរបស់ជីវកកោមារភច្ចដោយព្រះទ័យហើយទើបទ្រង់ត្រាស់ហៅព្រះអានន្ទ

ឥធានន្ទ ជីវកស្ស កោមារភច្ចស្ស ពហិទ្វារកោដ្ឋ-
កា និក្ខន្តស្ស ឯតទហោសិ មយា ខោ ភគវតោ
សមត្តិំសាយ វិរេចនំ ទិន្នំ ទោសាភិសន្នោ តថាគតស្ស
កាយោ ន ភគវន្តំ សមត្តិំសក្ខត្តុំ វិរេចេស្សតិ ឯកូន-
តិំសក្ខត្តុំ ភគវន្តំ វិរេចេស្សតិ អបិច ភគវា វិរិត្តោ
នហាយិស្សតិ នហាតំ ភគវន្តំ សកិំ វិរេចេស្សតិ ឯវំ
ភគវតោ សមត្តិំសាយ វិរេចនំ ភវិស្សតីតិ តេនហានន្ទ
ឧណ្ហោទកំ បដិយាទេហីតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា
អានន្ទោ ភគវតោ បដិស្សុណិត្វា ឧណ្ហោទកំ បដិ-
យាទេសិ ។ អថខោ ជីវកោ កោមារភច្ចោ យេន
ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា
ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ជីវកោ
កោមារភច្ចោ ភគវន្តំ ឯតទវោច វិរិត្តោ ភន្តេ ភគវាតិ ។



ដ៏មានអាយុមកត្រាស់ថា ម្នាលអានន្ទ កាលជីវកកោមារភច្ចចេញ
ទៅដល់ក្រៅទ្វារកោដ្ឋហើយក៏មានសេចក្តីគិតដូច្នេះថា ថ្នាំបញ្ចុះ ៣០
ដងគត់ អាត្មាអញបានថ្វាយដល់ព្រះមានព្រះភាគរួចហើយ កាយរបស់
ព្រះតថាគតក្រាស់ដោយទោស ថ្នាំនោះនឹងបញ្ចុះព្រះមានព្រះភាគ
ពេញ ៣០ ដងគត់ពុំបាន មុខជាថ្នាំនឹងបញ្ចុះព្រះមានព្រះភាគបានត្រឹម
តែ ២៩ ដង ម្យ៉ាងទៀត ព្រះមានព្រះភាគបានបញ្ចុះហើយមុខជា
នឹងស្រង់ទឹក ថ្នាំនោះនឹងបញ្ចុះព្រះមានព្រះភាគដែលបានស្រង់ទឹក
ហើយម្តងទៀត រួមជាការបញ្ចុះថ្នាំរបស់ព្រះមានព្រះភាគ ៣០ ដងគត់
ដោយការយ៉ាងនេះ ម្នាលអានន្ទ បើដូច្នោះអ្នកចូរទៅតែងទឹកក្តៅឡើង ។
ព្រះអានន្ទដ៏មានអាយុបានទទួលស្តាប់ព្រះពុទ្ធដីកាព្រះមានព្រះភាគ
ដោយពាក្យថា សូមទ្រង់ព្រះមេត្តាប្រោស ព្រះករុណាម្ចាស់ ហើយក៏បាន
តាក់តែងទឹកក្តៅ ។ គ្រានោះ ជីវកកោមារភច្ចបានចូលទៅគាល់ព្រះ
មានព្រះភាគ លុះចូលទៅដល់ហើយក៏ក្រាបថ្វាយបង្គំព្រះមានព្រះ
ភាគ រួចហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ ជីវកកោមារភច្ចអង្គុយនៅក្នុង
ទីដ៏សមគួរហើយក៏ក្រាបទូលព្រះមានព្រះភាគដោយពាក្យដូច្នេះថា សូម
ទ្រង់ព្រះមេត្តាប្រោស ព្រះមានព្រះភាគទ្រង់បានបញ្ចុះថ្នាំហើយឬនៅ ។

វិរិត្តោម្ហិ ជីវកាតិ ។ ឥធ មយ្ហំ ភន្តេ ពហិទ្វារកោដ្ឋកា និក្ខន្តស្ស ឯតទហោសិ មយា ខោ ភគវតោ សមត្តិំសាយ វិរេចនំ ទិន្នំ ទោសាភិសន្នោ តថាគតស្ស កាយោ ន ភគវន្តំ សមត្តិំសក្ខត្តុំ វិរេចេស្សតិ ឯកូនតិំសក្ខត្តុំ ភគវន្តំ វិរេចេស្សតិ អបិច ភគវា វិរិត្តោ នហាយិស្សតិ នហាតំ ភគវន្តំ សកឹ វិរេចេស្សតិ ឯវំ ភគវា សមត្តិំសាយ វិរេចនំ ភវិស្សតីតិ នហាយតុ ភន្តេ ភគវា នហាយតុ សុគតោតិ ។ អថខោ ភគវា ឧណ្ហោទកំ នហាយិ នហាតំ ភគវន្តំ សកឹ វិរេចេសិ ឯវំ ភគវា សមត្តិំសាយ វិរេចនំ អហោសិ ។ អថខោ ជីវកោ កោមារភច្ចោ ភគវន្តំ ឯតទវោច យាវ ភន្តេ ភគវតោ កាយោ បកតត្តោ ហោតិ អលំ[១] យូសបិណ្ឌបាតេនាតិ ។ អថខោ

១ អលំ ពាក់ ទិស្សតិ ។



ព្រះមានព្រះភាគទ្រង់ត្រាស់តបថា នែជីវក. តថាគតបានបញ្ចុះថ្នាំហើយ ។ ជីវកកោមារភច្ច ក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស កាលខ្ញុំព្រះអង្គចេញទៅដល់ក្លោងទ្វារហើយ ក៏មានសេចក្តីរិះគិត ដូច្នេះថា ថ្នាំបញ្ចុះចំនួន ៣០ ដងគត់ អាត្មាអញបានថ្វាយដល់ព្រះមានព្រះភាគរួចហើយ កាយរបស់ព្រះតថាគត ក្រាស់ដោយទោស ថ្នាំនោះនឹងបញ្ចុះព្រះមានព្រះភាគ ៣០ ដងគត់ក៏ទេ មុខជានឹងបញ្ចុះព្រះមានព្រះភាគបានត្រឹមតែ ២៩ ដង ម្យ៉ាងទៀត ព្រះដ៏មានព្រះភាគទ្រង់បញ្ចុះថ្នាំរួចហើយមុខជានឹងស្រង់ទឹក ថ្នាំនោះនឹងបញ្ចុះព្រះដ៏មានព្រះភាគដែលស្រង់ទឹករួចហើយម្តងទៀត រួមជាការបញ្ចុះថ្នាំរបស់ព្រះដ៏មានព្រះភាគ ៣០ ដងគត់ដោយអាការយ៉ាងនេះ សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះដ៏មានព្រះភាគទ្រង់ស្រង់ទឹកចុះ សូមព្រះសុគតទ្រង់ស្រង់ទឹកចុះ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ស្រង់ទឹកក្តៅហើយ ថ្នាំនោះក៏បានបញ្ចុះព្រះដ៏មានព្រះភាគដែលបានស្រង់ទឹកហើយម្តងទៀត រួមជាការបញ្ចុះថ្នាំរបស់ព្រះដ៏មានព្រះភាគ ៣០ ដងគត់យ៉ាងនេះ ។ វេលានោះ ជីវកកោមារភច្ចបានក្រាបទូលព្រះដ៏មានព្រះភាគដោយពាក្យដូច្នេះថា សូមទ្រង់ព្រះមេត្តាប្រោស កាយរបស់ព្រះមានព្រះភាគ គាំងនៅជាប្រក្រតីដរាបណាហើយ នឹងមិនបាច់សោយដោយដុំព្រះបិណ្ឌបាតនោះ ។ វេលានោះ

ភគវតោ កាយោ នចិរស្សេវ បកតត្តោ អហោសិ ។

អថខោ ជីវកោ កោមារភច្ចោ តំ សិវេយ្យកំ ទុស្សយុគំ

អាទាយ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា

ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ

និសិន្នោ ខោ ជីវកោ កោមារភច្ចោ ភគវន្តំ ឯតទវោច

ឯកាហំ ភន្តេ ភគវន្តំ វរំ យាចាមីតិ ។ អតិក្កន្តវរា

ខោ ជីវក តថាគតាតិ ។ យញ្ច ភន្តេ កប្បតិ យញ្ច

អនវជ្ជន្តិ ។ វទេហិ ជីវកាតិ ។ ភគវា ភន្តេ បំសុកូ-

លិកោ ភិក្ខុសង្ឃោ ច ឥទំ មេ ភន្តេ សិវេយ្យកំ

ទុស្សយុគំ រញ្ញា បជ្ជោតេន បហិតំ ពហូនំ ទុស្សានំ



មិនយូរប៉ុន្មាន កាយរបស់ព្រះមានព្រះភាគក៏បានជាប្រក្រតីវិញ ។ គ្រានោះ ជីវកកោមារភច្ចបាននាំយកសំពត់សិវេយ្យកៈ(១) ១ គូនោះចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគហើយ អង្គុយនៅក្នុងទីសមគួរ ។ ជីវកកោមារភច្ចអង្គុយនៅ ក្នុងទីសមគួរហើយ ក៏ក្រាបទូលព្រះមានព្រះភាគដោយពាក្យថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គសូមពរ ១ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ជីវកៈ ព្រះតថាគតទាំងឡាយមានពរកន្លងហើយ ។ ជីវកកោមារភច្ចទូលថា សូមទ្រង់ព្រះមេត្តាប្រោស អំពើណាគួរដែរ មិនមានទោសផង (ខ្ញុំព្រះអង្គសូមពរគឺអំពើនោះ) ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ជីវកៈ អ្នកចូរនិយាយមកចុះ ។ ជីវកកោមារភច្ចទូលថា សូមទ្រង់ព្រះមេត្តាប្រោស ព្រះមានព្រះភាគក្តី ភិក្ខុសង្ឃក្តី តែងតែទ្រទ្រង់សំពត់បង្សុកូល សូមទ្រង់ព្រះមេត្តាប្រោស សំពត់សិវេយ្យកៈ ១ គូនេះហើយដែលព្រះបាទបជ្ជោតបញ្ជូនមកឲ្យខ្ញុំព្រះអង្គ ជាសំពត់លើសលុបប្រសើរជាប្រធាន

១ អដ្ឋកថាថា បានដល់សំពត់ដែលគេបោះចោលនៅព្រៃខ្មោច ក្នុងដែនសិវិ ។ បានឮមកថា ពួកមនុស្សក្នុងដែនសិវិរុំសាកសពដោយសំពត់នោះឯងហើយយកទៅបោះ ។ មានសត្វ [illegible] ហើយ [illegible] ។ វេលានោះ ពួកអ្នកដើរព្រៃបានឃើញសំពត់នោះហើយក៏នាំយកមកថ្វាយស្តេច ។ សំពត់នេះហើយដែលព្រះបាទបជ្ជោតបញ្ជូន [illegible] ។

ពហុន្នំ ទុស្សយុគានំ ពហុន្នំ ទុស្សយុគសតានំ ពហុន្នំ ទុស្សយុគសហស្សានំ ពហុន្នំ ទុស្សយុគសតសហស្សានំ អគ្គញ្ច សេដ្ឋញ្ច មោក្ខញ្ច ឧត្តមញ្ច បវរញ្ច បដិគ្គណ្ហាតុ មេ ភន្តេ ភគវា សិវេយ្យកំ ទុស្សយុគំ ភិក្ខូនញ្ច គហបតិចីវរំ អនុជានាតូតិ ។ បដិគ្គហេសិ ភគវា សិវេយ្យកំ ទុស្សយុគំ ។ អថខោ ភគវា ជីវកំ កោមារភច្ចំ ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ។ អថខោ ជីវកោ កោមារភច្ចោ ភគវតា ធម្មិយា កថាយ សន្ទស្សិតោ សមាទបិតោ សមុត្តេជិតោ សម្បហំសិតោ ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ គហបតិចីវរំ យោ ឥច្ឆតិ បំសុកូលិកោ ហោតុ យោ ឥច្ឆតិ គហបតិចីវរំ សាទិយតុ ឥតរីតរេនបាហំ ភិក្ខវេ សន្តុដ្ឋឹ វណ្ណេមីតិ ។



ខ្ពង់ខ្ពស់ក្រៃលែងជាងសំពត់ដ៏ច្រើន ជាងគូនៃសំពត់ដ៏ច្រើន ជាងរយនៃគូសំពត់ដ៏ច្រើន ជាងពាន់នៃគូសំពត់ដ៏ច្រើន ជាងសែននៃគូសំពត់ដ៏ច្រើន សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះមានព្រះភាគទ្រង់ទទួលយកសំពត់សិវេយ្យកៈ ១ គូរបស់ខ្ញុំព្រះអង្គ សូមទ្រង់អនុញ្ញាតគហបតិចីវរ ដល់ភិក្ខុសង្ឃផង ។ ព្រះមានព្រះភាគ ទ្រង់ទទួលយកសំពត់សិវេយ្យកៈ ១ គូ ។ វេលានោះ ព្រះមានព្រះភាគទ្រង់ពន្យល់ជីវកកោមារភច្ច ឲ្យឃើញ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថា ។ លំដាប់នោះ ជីវកកោមារភច្ចកាលដែលព្រះមានព្រះភាគទ្រង់ពន្យល់ ឲ្យឃើញ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថាហើយក៏ក្រោកចាកអាសនៈ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយថយចេញទៅ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះមានព្រះភាគទ្រង់ធ្វើធម្មីកថាក្នុងវេលានោះ រួចទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវគហបតិចីវរ ភិក្ខុណាប្រាថ្នា (បង្សុកូល) ភិក្ខុនោះចូរទ្រទ្រង់សំពត់បង្សុកូលចុះ ភិក្ខុណាប្រាថ្នា (គហបតិចីវរ) ភិក្ខុនោះចូរត្រេកអរចំពោះគហបតិចីវរចុះ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត តថាគតតែងពោលសរសើរសេចក្តីសន្តោសដោយបច្ច័យណាមួយ (តាមមានតាមបាន) ។

[៦៦] អស្សោសុំ ខោ រាជគហេ មនុស្សា ភគវតា កិរ ភិក្ខូនំ គហបតិចីវរំ អនុញ្ញាតន្តិ ។ តេ ច មនុស្សា ហដ្ឋា អហេសុំ ឧទគ្គា ឥទានិ ខោ មយំ ទានានិ ទស្សាម បុញ្ញានិ ករិស្សាម យតោ ភគវតា ភិក្ខូនំ គហបតិចីវរំ អនុញ្ញាតន្តិ ។ ឯកាហេនេវ រាជគហេ ពហូនិ ចីវរសហស្សានិ ឧប្បជ្ជឹសុ ។ អស្សោសុំ ខោ ជានបទា មនុស្សា ភគវតា កិរ ភិក្ខូនំ គហបតិចីវរំ អនុញ្ញាតន្តិ ។ តេ ច មនុស្សា ហដ្ឋា អហេសុំ ឧទគ្គា ឥទានិ ខោ មយំ ទានានិ ទស្សាម បុញ្ញានិ ករិស្សាម យតោ ភគវតា ភិក្ខូនំ គហបតិចីវរំ អនុញ្ញាតន្តិ ។ ឯកាហេនេវ ជនបទេបិ ពហូនិ ចីវរសហស្សានិ ឧប្បជ្ជឹសុ ។

[៦៧] តេន ខោ បន សមយេន សង្ឃស្ស បាវារោ ឧប្បន្នោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។



(៦៦) ពួកមនុស្ស ក្នុងក្រុងរាជគ្រឹះ បានឮដំណឹងថា ព្រះមានព្រះភាគទ្រង់អនុញ្ញាតនូវគហបតិចីវរដល់ភិក្ខុទាំងឡាយហើយ ។ មនុស្សទាំងនោះក៏មានចិត្តរីករាយស្រស់ស្រាយឡើងថា យើងមុខជានឹងបានឲ្យទាន មុខជានឹងបានធ្វើបុណ្យក្នុងកាលនេះឯង ចាប់ដើមតាំងពីព្រះមានព្រះភាគទ្រង់បានអនុញ្ញាតនូវគហបតិចីវរដល់ភិក្ខុទាំងឡាយ ។ ក្នុងក្រុងរាជគ្រឹះមានចីវរច្រើនពាន់កើតឡើងតែក្នុង ១ ថ្ងៃប៉ុណ្ណោះ ។ ពួកមនុស្សដែលនៅក្នុងជនបទបានឮដំណឹងថា គហបតិចីវរព្រះមានព្រះភាគទ្រង់បានអនុញ្ញាតដល់ភិក្ខុទាំងឡាយហើយ ។ មនុស្សទាំងនោះក៏មានចិត្តរីករាយស្រស់ស្រាយឡើងថា យើងមុខជានឹងបានឲ្យទាន មុខជានឹងបានធ្វើបុណ្យក្នុងកាលនេះឯង ចាប់ដើមតាំងពីព្រះមានព្រះភាគទ្រង់បានអនុញ្ញាតគហបតិចីវរដល់ភិក្ខុទាំងឡាយ ។ សូម្បីតែក្នុងជនបទក៏មានចីវរច្រើនពាន់កើតឡើងតែក្នុង១ថ្ងៃប៉ុណ្ណោះ ។

(៦៧) សម័យនោះឯង សំពត់បាវារ[១] កើតឡើងដល់សង្ឃ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្ដីនុ៎ះចំពោះព្រះមានព្រះភាគ ។

---

១ សំពត់ដែលយកសំឡីមកធ្វើមានលាយរោមសត្វជាដើម ។

អនុជានាមិ ភិក្ខវេ បាវារន្តិ ។ កោសេយ្យបាវារោ ឧប្បន្នោ ហោតិ ។ អនុជានាមិ ភិក្ខវេ កោសេយ្យបាវារន្តិ ។ កោជវំ ឧប្បន្នំ ហោតិ ។ អនុជានាមិ ភិក្ខវេ កោជវន្តិ ។

បឋមភាណវារំ និដ្ឋិតំ ។

[៤៤] តេន ខោ បន សមយេន កាសិរាជា ជីវកស្ស កោមារភច្ចស្ស អឌ្ឍកាសិយំ[១] កម្ពលំ បាហេសិ ឧឌ្ឍកាសិកំ ខមមានំ[២] ។ អថ ខោ ជីវកោ កោមារភច្ចោ តំ អឌ្ឍកាសិយំ កម្ពលំ អាទាយ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ជីវកោ កោមារភច្ចោ ភគវន្តំ ឯតទវោច អយំ មេ ភន្តេ អឌ្ឍកាសិយោ កម្ពលោ កាសិរញ្ញា បហិតោ ឧឌ្ឍកាសិកំ ខមមានោ បដិគ្គណ្ហាតុ មេ ភន្តេ ភគវា

១ ឱ. អឌ្ឍកាសិកំ ។ ២ ខមមានំ ។





ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសំពត់ប៉ាវារៈ ។ សំពត់ប៉ាវារធ្វើពីសូត្របានកើតឡើង ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសំពត់ប៉ាវារដែលធ្វើពីសូត្រ ។ សំពត់កោជវៈ[១] បានកើតឡើង ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសំពត់កោជវៈ ។

ចប់ ភាណវារៈ ទីមួយ ។

[៤៤] សម័យនោះឯង ស្តេចក្រុងកាសី បានបញ្ជូនសំពត់កម្ពលមានដំឡៃកន្លះកាសី(ថ្លៃ ១០០០ កហាបណៈ)គឺប្រហែលនឹងវត្ថុទាំងឡាយដែលមានដំឡៃកន្លះកាសីដែរ ទៅឲ្យជីវកកោមារភច្ច ។ គ្រានោះ ជីវកកោមារភច្ចក៏បាននាំយកសំពត់កម្ពលមានដំឡៃកន្លះកាសីនោះ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ ជីវកកោមារភច្ចលុះអង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា សូមទ្រង់មេត្តាប្រោស សំពត់កម្ពលមានដំឡៃកន្លះកាសីរបស់ខ្ញុំព្រះអង្គនេះ ប្រហែលនឹងវត្ថុទាំងឡាយដែលមានដំឡៃកន្លះកាសីដែរ ស្តេចកាសីបានបញ្ជូនមកប្រទាន សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះដ៏មានព្រះភាគ

១ (អដ្ឋកថា) សំពត់នេះប្រហែលគ្នានឹងសំពត់ប៉ាវារៈ សំពត់នេះគេធ្វើពីរោមសត្វ ។

កម្ពលំ យំ មម អស្ស ទីឃរត្តំ ហិតាយ សុខាយាតិ ។ បដិគ្គហេសិ ភគវា កម្ពលំ ។ អថខោ ភគវា ជីវកំ កោមារភច្ចំ ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ។ អថខោ ជីវកោ កោមារភច្ចោ ភគវតា ធម្មិយា កថាយ សន្ទស្សិតោ សមាទបិតោ សមុត្តេជិតោ សម្បហំសិតោ ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ កម្ពលន្តិ ។

(៤៩) តេន ខោ បន សមយេន សង្ឃស្ស ឧច្ចាវចានិ ចីវរានិ ឧប្បន្នានិ ហោន្តិ ។ អថខោ ភិក្ខូនំ ឯតទហោសិ កឹ នុខោ ភគវតា ចីវរំ អនុញ្ញាតំ កឹ អននុញ្ញាតន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ



ទ្រង់ទទួលយកសំពត់កម្ពលរបស់ខ្ញុំព្រះអង្គ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ខ្ញុំព្រះអង្គអស់កាលជាអង្វែង (តទៅ) ។ ព្រះមានព្រះភាគក៏ទ្រង់ទទួលយកសំពត់កម្ពល ។ វេលានោះ ព្រះមានព្រះភាគទ្រង់ពន្យល់ ជីវកកោមារភច្ច ឲ្យឃើញ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថាហើយ ។ លំដាប់នោះ ជីវកកោមារភច្ចកាលដែលព្រះមានព្រះភាគទ្រង់ពន្យល់ ឲ្យឃើញ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏ក្រោកចាកអាសនៈ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយចៀសចេញទៅ ។ គ្រានោះឯង ព្រះមានព្រះភាគក៏ទ្រង់ធ្វើធម្មីកថាក្នុងហេតុនោះហើយ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវសំពត់កម្ពល ។

(៤៩) សម័យនោះឯង មានចីវរល្អនិងមិនល្អ កើតឡើងដល់សង្ឃ ។ ភិក្ខុទាំងឡាយមានសេចក្តីរំពឹងគិតដូច្នេះថា ចីវរដូចម្តេចដែលព្រះមានព្រះភាគ ទ្រង់អនុញ្ញាតហើយ ចីវរដូចម្តេច ដែលព្រះមានព្រះភាគមិនអនុញ្ញាត ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត

ភិក្ខវេ ឆ ចីវរានិ ខោមំ កប្បាសិកំ កោសេយ្យំ កម្ពលំ សាណំ ភង្គន្តិ ។ តេន ខោ បន សមយេន យេ តេ ភិក្ខូ គហបតិចីវរំ សាទិយន្តិ តេ កុក្កុច្ចាយន្តា បំសុកូលំ ន សាទិយន្តិ ឯកំយេវ ភគវតា ចីវរំ អនុញ្ញាតំ ន ទ្វេតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ គហបតិចីវរំ សាទិយន្តេន បំសុកូលម្បិ សាទិតុំ តទុភយេន បាហំ ភិក្ខវេ សន្តុដ្ឋឹ វណ្ណេមីតិ ។

[៤៦] តេន ខោ បន សមយេន សម្ពហុលា ភិក្ខូ កោសលេសុ ជនបទេសុ អទ្ធានមគ្គប្បដិបន្នា ហោន្តិ ។ ឯកច្ចេ ភិក្ខូ សុសានំ ឱក្កមឹសុ បំសុកូលាយ ឯកច្ចេ ភិក្ខូ នាគមេសុំ ។ យេ តេ ភិក្ខូ សុសានំ ឱក្កមឹសុ បំសុកូលាយ តេ បំសុកូលានិ លភឹសុ ។ យេ តេ ភិក្ខូ នាគមេសុំ តេ ឯវមាហំសុ អម្ហាកម្បិ អាវុសោ



ចីវរ ៦ យ៉ាង គឺ ចីវរដែលធ្វើដោយសម្បកឈើ ១ ចីវរដែលធ្វើដោយកប្បាស ១ ចីវរដែលធ្វើដោយសូត្រ ១ ចីវរដែលធ្វើដោយរោមសត្វ (វៀរលែងតែសក់ឬរោមមនុស្សចេញ) ១ សំពត់ដែលធ្វើដោយសម្បកធ្មៃ ១ សំពត់ដែលធ្វើលាយដោយវត្ថុ ៥ យ៉ាងនោះរួម ១ ។ សម័យនោះឯង ពួកភិក្ខុណា ត្រេកអរនឹងគហបតិចីវរ ភិក្ខុទាំងនោះក៏រង្កៀសមិនត្រេកអរនឹងសំពត់បង្សុកូលឡើយ ព្រោះគិតថា ព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតតែចីវរ ១ មិនបានអនុញ្ញាតចីវរពីរទេ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលត្រេកអរនឹងគហបតិចីវរហើយ ត្រេកអរនឹងសំពត់បង្សុកូលផងក៏បាន ម្នាលភិក្ខុទាំងឡាយ មួយទៀត តថាគតសរសើរសេចក្តីសន្តោសដោយចីវរទាំងពីរយ៉ាងនោះ ។

(៤៦) សម័យនោះឯង មានភិក្ខុច្រើនរូបដើរទៅកាន់ផ្លូវឆ្ងាយក្នុងកោសលជនបទ ។ ភិក្ខុពួកខ្លះដើរទៅកាន់ព្រៃស្មសានដើម្បីនឹងបង្សុកូល ភិក្ខុពួកខ្លះមិនបានទៅចាំឡើយ ។ ពួកភិក្ខុណាដើរទៅកាន់ព្រៃស្មសានដើម្បីនឹងបង្សុកូល ភិក្ខុទាំងនោះក៏បានសំពត់បង្សុកូលទាំងឡាយ ។ ពួកភិក្ខុណាដែលមិនបានទៅចាំ ភិក្ខុទាំងនោះក៏និយាយយ៉ាងនេះថា នែអាវុសោ

ភាគំ ទេថាតិ ។ តេ ឯវមាហំសុ ន មយំ អាវុសោ តុម្ហាកំ ភាគំ ទស្សាម កិស្ស តុម្ហេ នាគមិត្ថាតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ នាគមេន្តានំ នាកាមា ភាគំ ទាតុន្តិ ។ តេន ខោ បន សមយេន សម្ពហុលា ភិក្ខូ កោសលេសុ ជនបទេសុ អទ្ធានមគ្គប្បដិបន្នា ហោន្តិ ។ ឯកច្ចេ ភិក្ខូ សុសានំ ឱក្កមិំសុ បំសុកូលាយ ឯកច្ចេ ភិក្ខូ អាគមេសុំ ។ យេ តេ ភិក្ខូ សុសានំ ឱក្កមិំសុ បំសុកូលាយ តេ បំសុកូលានិ លភិំសុ ។ យេ តេ ភិក្ខូ អាគមេសុំ តេ ឯវមាហំសុ អម្ហាកម្បិ អាវុសោ ភាគំ ទេថាតិ ។ តេ ឯវមាហំសុ ន មយំ អាវុសោ តុម្ហាកំ ភាគំ ទស្សាម កិស្ស តុម្ហេ ន ឱក្កមិត្ថាតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ អាគមេន្តានំ អកាមា ភាគំ ទាតុន្តិ ។ តេន ខោ បន សមយេន សម្ពហុលា



ចូរលោកទាំងឡាយឲ្យចំណែកមកយើងខ្លះ ។ ភិក្ខុទាំងនោះក៏និយាយយ៉ាងនេះវិញថា នែអាវុសោ យើងមិនឲ្យចំណែកដល់លោកទាំងឡាយទេ (បើលោកទាំងឡាយបានទាន់សំពត់បង្សុកូល) ហេតុដូចម្តេចបានជាលោកទាំងឡាយមិនរង់ចាំយើង ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលមិនប្រាថ្នានឹងឲ្យក៏គួរឲ្យនូវចំណែកដល់ភិក្ខុទាំងឡាយដែលមិនរង់ចាំបាន ។ សម័យនោះឯង មានភិក្ខុច្រើនរូបដើរទៅកាន់ផ្លូវឆ្ងាយក្នុងកោសលជនបទ ។ ភិក្ខុពួកខ្លះដើរទៅកាន់ព្រៃស្មសាន ដើម្បីនឹងបង្សុកូល ភិក្ខុពួកខ្លះបានរង់ចាំ ។ ពួកភិក្ខុណាចូលទៅកាន់ព្រៃស្មសានដើម្បីនឹងបង្សុកូល ភិក្ខុទាំងនោះក៏បានសំពត់បង្សុកូល ។ ពួកភិក្ខុណាដែលរង់ចាំ ភិក្ខុទាំងនោះក៏និយាយយ៉ាងនេះថា នែអាវុសោ ចូរលោកទាំងឡាយឲ្យចំណែកមកយើងខ្លះ ។ ភិក្ខុទាំងនោះពោលតបវិញយ៉ាងនេះថា នែអាវុសោ យើងមិនឲ្យចំណែកដល់លោកទាំងឡាយទេ ហេតុដូចម្តេចបានជាលោកទាំងឡាយមិនចូលទៅ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលទុកជាមិនចង់ឲ្យក៏ត្រូវឲ្យចំ-ណែកដល់ភិក្ខុទាំងឡាយដែលរង់ចាំ ។ សម័យនោះឯង មានពួកភិក្ខុច្រើនរូប

ភិក្ខូ កោសលេសុ ជនបទេសុ អទ្ធានមគ្គប្បដិបន្នា
ហោន្តិ ។ ឯកច្ចេ ភិក្ខូ បឋមំ សុសានំ ឱក្កមិំសុ
បំសុកូលាយ ឯកច្ចេ ភិក្ខូ បច្ឆា ឱក្កមិំសុ ។ យេ
តេ ភិក្ខូ បឋមំ សុសានំ ឱក្កមិំសុ បំសុកូលាយ តេ
បំសុកូលានិ លភិំសុ ។ យេ តេ ភិក្ខូ បច្ឆា ឱក្ក-
មិំសុ តេ ន លភិំសុ ។ តេ ឯវមាហំសុ អម្ហាកម្បិ
អាវុសោ ភាគំ ទេថាតិ ។ តេ ឯវមាហំសុ ន មយំ អាវុសោ
តុម្ហាកំ ភាគំ ទស្សាម កិស្ស តុម្ហេ បច្ឆា ឱក្កន្តា-
តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ
ភិក្ខវេ បច្ឆា ឱក្កន្តានំ អកាមា ភាគំ ទាតុន្តិ ។
តេន ខោ បន សមយេន សម្ពហុលា ភិក្ខូ កោ-
សលេសុ ជនបទេសុ អទ្ធានមគ្គប្បដិបន្នា ហោន្តិ ។
តេ សទិសា សុសានំ ឱក្កមិំសុ បំសុកូលាយ ។ ឯ-
កច្ចេ ភិក្ខូ បំសុកូលានិ លភិំសុ ឯកច្ចេ ភិក្ខូ ន
លភិំសុ ។ យេ តេ ភិក្ខូ ន លភិំសុ តេ ឯវមាហំសុ
អម្ហាកម្បិ អាវុសោ ភាគំ ទេថាតិ ។ តេ ឯវមាហំសុ
ន មយំ អាវុសោ តុម្ហាកំ ភាគំ ទស្សាម កិស្ស



ដើរទៅកាន់ផ្លូវឆ្ងាយ ក្នុងកោសលជនបទ ។ ភិក្ខុពួកខ្លះ ដើរចូលទៅ
កាន់ព្រៃស្មសានជាមុន ដើម្បីបង្សុកូល ភិក្ខុពួកខ្លះដើរចូលទៅជាខាង
ក្រោយ ។ ពួកភិក្ខុណាដែលដើរចូលទៅព្រៃស្មសានមុន ដើម្បីបង្សុកូល
ភិក្ខុទាំងនោះក៏បានសំពត់បង្សុកូល ។ ពួកភិក្ខុណាចូលទៅក្រោយ ភិក្ខុ
ទាំងនោះក៏អត់បានឡើយ ។ ភិក្ខុទាំងនោះក៏និយាយយ៉ាងនេះថា នែអា-
វុសោ លោកទាំងឡាយចូរឲ្យចំណែកដល់យើងខ្លះ ។ ភិក្ខុទាំងនោះនិ-
យាយយ៉ាងនេះវិញថា នែអាវុសោ យើងមិនបានឲ្យចំណែកដល់លោកទេ
ហេតុអ្វីបានជាលោកទាំងឡាយដើរចូលទៅក្រោយគេ ។ ភិក្ខុទាំងនោះ
ក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាត
ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលមិនចង់ឲ្យ ក៏ត្រូវចែក
ឲ្យនូវចំណែកដល់ភិក្ខុទាំងឡាយដែលដើរចូលទៅក្រោយគេ ។ សម័យ
នោះឯង មានពួកភិក្ខុច្រើនរូបដើរទៅកាន់ផ្លូវឆ្ងាយ ក្នុងកោសលជនបទ ។
ភិក្ខុទាំងនោះបានដើរចូលទៅកាន់ព្រៃស្មសាន ដើម្បីបង្សុកូលព្រមគ្នា ។
ភិក្ខុពួកខ្លះបានសំពត់បង្សុកូល ភិក្ខុពួកខ្លះមិនបាន ។ ពួកភិក្ខុណា
ដែលមិនបាន ភិក្ខុទាំងនោះក៏និយាយយ៉ាងនេះថា នែអាវុសោ លោកទាំង
ឡាយចូរឲ្យចំណែកមកយើងខ្លះ ។ ភិក្ខុទាំងនោះនិយាយយ៉ាងនេះវិញថា
នែអាវុសោ យើងមិនឲ្យចំណែកដល់លោកទាំងឡាយទេ ហេតុអ្វីបានជា

តុម្ហេ ន លភិត្ថាតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ សធិសានំ ឱក្កមន្តានំ អកាមា ភាគំ ទាតុន្តិ ។ តេន ខោ បន សមយេន សម្ពហុលា ភិក្ខូ កោសលេសុ ជនបទេសុ អទ្ធានមគ្គប្បដិបន្នា ហោន្តិ ។ តេ កតិកំ កត្វា សុសានំ ឱក្កមិំសុ បំសុកូលាយ ។ ឯកច្ចេ ភិក្ខូ បំសុកូលានិ លភិំសុ ឯកច្ចេ ភិក្ខូ ន លភិំសុ ។ យេ តេ ភិក្ខូ ន លភិំសុ តេ ឯវមាហំសុ អម្ហាកម្បិ អាវុសោ ភាគំ ទេថាតិ ។ តេ ឯវមាហំសុ ន មយំ អាវុសោ តុម្ហាកំ ភាគំ ទស្សាម កិស្ស តុម្ហេ ន លភិត្ថាតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ កតិកំ កត្វា ឱក្កមន្តានំ អកាមា ភាគំ ទាតុន្តិ ។

[៤៧] តេន ខោ បន សមយេន មនុស្សា ចីវរំ អាទាយ អារាមំ អាគច្ឆន្តិ ។ តេ បដិគ្គាហកំ អលភមានា បដិហរន្តិ ។ ចីវរំ បរិត្តំ ឧប្បជ្ជតិ ។ ភគវតោ



លោកមិនបានចំណែក ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្ដីនុះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុដែលទុកជាមិនចង់ឱ្យក៏ត្រូវឱ្យចំណែកដល់ភិក្ខុទាំងឡាយដែលចូលទៅកាន់ព្រៃស្មសានព្រមគ្នា ។ សម័យនោះឯង ពួកភិក្ខុច្រើនរូបដើរទៅកាន់ផ្លូវឆ្ងាយក្នុងកោសលជនបទ ។ ភិក្ខុទាំងនោះធ្វើកតិកា(ព្រមព្រៀង)នឹងគ្នាស្រេចហើយ ក៏ចូលទៅកាន់ព្រៃស្មសានដើម្បីបង្សុកូល ។ ភិក្ខុពួកខ្លះបានសំពត់បង្សុកូល ភិក្ខុពួកខ្លះមិនបាន ។ ពួកភិក្ខុណាដែលមិនបាន ភិក្ខុទាំងនោះក៏និយាយយ៉ាងនេះថា នែអាវុសោ លោកទាំងឡាយចូរឱ្យចំណែកមកយើងខ្ញុំ ។ ភិក្ខុទាំងនោះនិយាយយ៉ាងនេះវិញថា នែអាវុសោ យើងមិនឱ្យចំណែកដល់លោកទាំងឡាយទេ ហេតុអ្វីបានជាលោកមិនបានចំណែក ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្ដីនុះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុដែលទុកជាមិនចង់ឱ្យ ក៏ត្រូវឱ្យចំណែកដល់ភិក្ខុទាំងឡាយដែលធ្វើកតិកា (ព្រមព្រៀង)គ្នាហើយចូលទៅកាន់ព្រៃស្មសាន ។

(៤៧) សម័យនោះឯង ពួកមនុស្សបាននាំយកចីវរមកកាន់អារាម ។ មនុស្សទាំងនោះកាលមិនបានភិក្ខុណាមួយទទួលចីវរ ក៏ត្រឡប់នាំយកចីវរទៅវិញ ។ ចីវរកើតកើតតិច ៗ ទៅ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្ដីនុះ

ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតំ ភិក្ខុំ ចីវរប្បដិគ្គាហកំ សម្មន្និតុំ យោ ន ឆន្ទាគតិំ គច្ឆេយ្យ ន ទោសាគតិំ គច្ឆេយ្យ ន មោហាគតិំ គច្ឆេយ្យ ន ភយាគតិំ គច្ឆេយ្យ គហិតាគហិតញ្ច ជានេយ្យ ។ ឯវញ្ច បន ភិក្ខវេ សម្មន្និតព្វោ ។ បឋមំ ភិក្ខុ យាចិតព្វោ យាចិត្វា ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមំ ភិក្ខុំ ចីវរប្បដិគ្គាហកំ សម្មន្នេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ សង្ឃោ ឥត្ថន្នាមំ ភិក្ខុំ ចីវរប្បដិគ្គាហកំ សម្មន្នតិ ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស ភិក្ខុនោ ចីវរប្បដិគ្គាហកស្ស សម្មុតិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ សម្មតោ សង្ឃេន ឥត្ថន្នាមោ ភិក្ខុ ចីវរប្បដិគ្គាហកោ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។





ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសន្មតភិក្ខុដែលប្រកបដោយអង្គ ៥ ឲ្យជាអ្នកទទួលចីវរ គឺ ភិក្ខុមិនបានលុះឆន្ទាគតិ ១ មិនបានលុះទោសាគតិ ១ មិនបានលុះមោហាគតិ ១ មិនបានលុះភយាគតិ ១ ដឹងនូវចីវរដែលខ្លួនបានទទួលហើយនិងមិនបានទទួល ១ ។ ម្នាលភិក្ខុទាំងឡាយ គប្បីសង្ឃសន្មតយ៉ាងនេះ ។ សង្ឃគប្បីអង្វរភិក្ខុជាមុន លុះអង្វររួចហើយ ភិក្ខុដែលឈ្លាសប្រតិពលគប្បីញ៉ាំងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ បើកម្មមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីសន្មតភិក្ខុឈ្មោះនេះ ឲ្យជាអ្នកទទួលចីវរចុះ ។ នេះជាពាក្យផ្តៀងសង្ឃឲ្យដឹង ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ សង្ឃសន្មតភិក្ខុឈ្មោះនេះ ឲ្យជាអ្នកទទួលចីវរ ។ ការសន្មតភិក្ខុឈ្មោះនេះ ឲ្យជាអ្នកទទួលចីវរ គួរដល់លោកដ៏មានអាយុអង្គណាហើយ លោកដ៏មានអាយុអង្គនោះគប្បីស្ងៀម (បើ) មិនគួរដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះគប្បីពោលឡើង ។ ភិក្ខុឈ្មោះនេះ សង្ឃបានសន្មតឲ្យជាអ្នកទទួលចីវរហើយ ។ ការសន្មតនេះសមគួរដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវសេចក្តីនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ ។

[៦៨] តេន ខោ បន សមយេន ចីវរប្បដិគ្គាហកា
ភិក្ខូ ចីវរំ បដិគ្គហេត្វា តត្ថេវ ឧជ្ឈិត្វា បក្កមន្តិ ។ ចី-
វរំ នស្សតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជា-
នាមិ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតំ ភិក្ខុំ ចីវរនិទ-
ហកំ សម្មន្និតុំ យោ ន ឆន្ទាគតឹ គច្ឆេយ្យ ន ទោ-
សាគតឹ គច្ឆេយ្យ ន មោហាគតឹ គច្ឆេយ្យ ន ភយាគតឹ
គច្ឆេយ្យ និគហិតានិគហិតញ្ច[១] ជានេយ្យ ។ ឯវញ្ច
បន ភិក្ខវេ សម្មន្និតព្វោ ។ បឋមំ ភិក្ខុ យាចិតព្វោ
យាចិត្វា ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញា-
បេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស
បត្តកល្លំ សង្ឃោ ឥត្ថន្នាមំ ភិក្ខុំ ចីវរនិទហកំ
សម្មន្នេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ
សង្ឃោ សង្ឃោ ឥត្ថន្នាមំ ភិក្ខុំ ចីវរនិទហកំ សម្មន្នតិ ។
យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស ភិក្ខុនោ ចីវរនិ-
ទហកស្ស សម្មតិ សោ តុណ្ហស្ស យស្ស នក្ខមតិ

១ ឱ. និហិតានិហិតញ្ច ។



[៦៨] សម័យនោះឯង ពួកភិក្ខុអ្នកទទួលចីវរ បានទទួលចីវរទុក
ចោលក្នុងទីនោះឯង ហើយចៀសចេញទៅ ។ ចីវរក៏វិនាសទៅ ។ ភិក្ខុ
ទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គ
ទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសង្ឃសន្មតភិក្ខុ
ដែលប្រកបដោយអង្គ៥ ឲ្យជាអ្នកទុកដាក់ចីវរ គឺភិក្ខុដែលមិនលុះឆន្ទាគតិ១
មិនលុះទោសាគតិ១ មិនលុះមោហាគតិ១ មិនលុះភយាគតិ១ ដឹងនូវចីវរ
ដែលខ្លួនបានទុកដាក់ហើយនិងមិនទាន់បានទុកដាក់ហើយ១ ។ ម្នាលភិក្ខុ
ទាំងឡាយ ត្រូវសង្ឃសន្មតយ៉ាងនេះ ត្រូវសង្ឃអង្វរភិក្ខុជាមុន លុះ
អង្វររួចហើយ ភិក្ខុអ្នកឈ្លាសប្រតិពលត្រូវញុំាងសង្ឃឲ្យដឹងថា បពិត្រ
ព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ បើកម្មមានកាលដ៏សមគួរដល់
សង្ឃហើយ គួរសង្ឃសន្មតភិក្ខុឈ្មោះនេះ ឲ្យជាអ្នកទុកដាក់ចីវរ ។ នេះជា
ពាក្យផ្តៀងសង្ឃឲ្យដឹង ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ
សង្ឃសន្មតភិក្ខុឈ្មោះនេះ ឲ្យជាអ្នកទុកដាក់ចីវរ ។ ការសន្មតភិក្ខុឈ្មោះនេះ
ឲ្យជាអ្នកទុកដាក់ចីវរសមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មាន
អាយុអង្គនោះត្រូវស្ងៀម (បើ) មិនសមគួរដល់លោកដ៏មានអាយុអង្គណា ។

សោ ការេយ្យ ។ សម្មតោ សង្ឃេន ឥត្ថន្នាមោ ភិក្ខុ
ចីវរបដិគ្គាហកោ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។
ឯវមេតំ ធារយាមីតិ ។

(៤៩) តេន ខោ បន សមយេន ចីវរបដិគ្គាហកា
ភិក្ខូ មណ្ឌបេបិ រុក្ខមូលេបិ និម្ពកោសេបិ អគុត្តំ
ចីវរំ និក្ខិបិត្វា គច្ឆន្តិ ។ ឧន្ទុរេហិបិ ឧបចិកាហិបិ ខជ្ជន្តិ ។
ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ
ភណ្ឌាគារំ សម្មន្និតុំ យំ សង្ឃោ អាកង្ខតិ វិហារំ វា
អឌ្ឍយោគំ វា បាសាទំ វា ហម្មិយំ វា គុហំ វា ។ ឯវញ្ច
បន ភិក្ខវេ សម្មន្និតព្វោ ។ ព្យត្តេន ភិក្ខុនា បដិពលេន
សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ យទិ
សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមំ វិហារំ ភណ្ឌាគារំ
សម្មន្នេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ
សង្ឃោ សង្ឃោ ឥត្ថន្នាមំ វិហារំ ភណ្ឌាគារំ សម្មន្ន-
តិ ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស វិហារស្ស



លោកដ៏មានអាយុអង្គនោះគប្បីពោលឡើង ។ ភិក្ខុឈ្មោះនេះសង្ឃបាន
សន្មតឲ្យជាអ្នកទទួលចីវរហើយ ។ ការសន្មតិនេះគួរដល់សង្ឃ
ព្រោះហេតុនោះបានជាសង្ឃស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវសេចក្តីនេះដោយ
អាការស្ងៀមនៅយ៉ាងនេះ ។

(៤៩) សម័យនោះឯង ពួកភិក្ខុអ្នកទទួលចីវរ ទុកចីវរក្នុង
មណ្ឌប (ស្នាក់) ខ្លះ ក្រោមម្លប់ឈើខ្លះ ទៀបជាយស្បូវខ្លះ ក្នុងទីកណ្តាល
វាលខ្លះ ។ ពួកសត្វកណ្តុរខ្លះ ពួកសត្វកណ្តៀរខ្លះ ក៏កាត់ចីវរទាំងនោះ ។
ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គ
ទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ (បើ) សង្ឃប្រាថ្នានូវទីណា គឺ
វិហារក្តី ប្រាសាទមានសណ្ឋានដូចស្លាបត្រដក្តី ប្រាសាទវែងក្តី
ប្រាសាទមានដំបូលត្រពិលក្តី គុហាក្តី ក៏តថាគតអនុញ្ញាតឲ្យសង្ឃសន្មត
នូវទីនោះឲ្យជាឃ្លាំងបាន ។ ម្នាលភិក្ខុទាំងឡាយ គួរសង្ឃសន្មតយ៉ាង
នេះ ។ ត្រូវភិក្ខុអ្នកឈ្លាសប្រតិពលញ៉ាំងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃ
ដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ បើកម្មមានកាលដ៏សមគួរដល់សង្ឃហើយ
សង្ឃគួរសន្មតវិហារឈ្មោះនេះ ឲ្យជាឃ្លាំងបាន ។ នេះជាពាក្យញ៉ាំង
សង្ឃឲ្យដឹង ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ សង្ឃ
សន្មតវិហារឈ្មោះនេះ ឲ្យជាឃ្លាំងហើយ ។ ការសន្មតវិហារឈ្មោះនេះ

ភណ្ឌាគារស្ស សម្មុតិ សោ តុណ្ហស្ស យស្ស នក្ខ-មតិ សោ ភាសេយ្យ ។ សម្មតោ សង្ឃេន ឥត្ថន្នាមោ វិហារោ ភណ្ឌាគារំ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

[៤០] តេន ខោ បន សមយេន សង្ឃស្ស ភណ្ឌា-គារេ ចីវរំ អគុត្តំ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេ-សុំ ។ អនុជានាមិ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតំ ភិក្ខុំ ភណ្ឌាគារិកំ សម្មន្និតុំ យោ ន ឆន្ទាគតឹ គច្ឆេយ្យ ន ទោសាគតឹ គច្ឆេយ្យ ន មោហាគតឹ គច្ឆេយ្យ ន ភ-យាគតឹ គច្ឆេយ្យ គុត្តាគុត្តញ្ច ជានេយ្យ ។ ឯវញ្ច បន ភិក្ខវេ សម្មន្និតព្វោ ។ បឋមំ ភិក្ខុ យាចិតព្វោ យាចិត្វា ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមំ ភិក្ខុំ ភណ្ឌាគារិកំ សម្មន្នេយ្យ ។



ឲ្យជាឃ្លាំង គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គួរស្ងៀម (បើ) មិនគួរដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះគប្បីពោលឡើង ។ វិហារឈ្មោះនេះ សង្ឃបានសន្មតឲ្យជាឃ្លាំងហើយ ។ ការសន្មតគួរដល់សង្ឃហើយ ព្រោះហេតុនោះបានជាសង្ឃស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវរឿងនេះដោយអាការស្ងៀមនៅយ៉ាងនេះ ។

[៤០] សម័យនោះឯង ចីវរក្នុងឃ្លាំងរបស់សង្ឃឥតមានលោកណាគ្រប់គ្រងឡើយ ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសន្មតភិក្ខុដែលប្រកបដោយអង្គ ៥ ឲ្យជាអ្នករក្សាឃ្លាំង គឺភិក្ខុដែលមិនលុះឆន្ទាគតិ ១ មិនលុះទោសាគតិ ១ មិនលុះមោហាគតិ ១ មិនលុះភយាគតិ ១ ដឹងនូវរបស់ដែលខ្លួនបានគ្រប់គ្រងហើយនិងមិនទាន់បានគ្រប់គ្រង ១ ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវសន្មតយ៉ាងនេះ ។ សង្ឃត្រូវអង្វរភិក្ខុជាមុន លុះអង្វររួចហើយ ភិក្ខុឆ្លាសប្រតិពល ត្រូវញុំាងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ បើកម្មមានកាលសមគួរដល់សង្ឃហើយ សង្ឃគួរសន្មតភិក្ខុឈ្មោះនេះ ឲ្យជាអ្នករក្សាឃ្លាំង ។

ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ សង្ឃោ ឥត្ថន្នាមំ ភិក្ខុំ ភណ្ឌាគារិកំ សម្មន្នតិ ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស ភិក្ខុនោ ភណ្ឌាគារិកស្ស សម្មុតិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ សម្មតោ សង្ឃេន ឥត្ថន្នាមោ ភិក្ខុ ភណ្ឌាគារិកោ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

[៨១] តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ភណ្ឌាគារិកំ វុដ្ឋាបេន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ភណ្ឌាគារិកោ វុដ្ឋាបេតព្វោ យោ វុដ្ឋាបេយ្យ អាបត្តិ ទុក្កដស្សាតិ ។



នេះជាពាក្យផ្ដៀងសង្ឃឲ្យដឹង ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្ដាប់ខ្ញុំ សង្ឃសន្មតភិក្ខុឈ្មោះនេះ ឲ្យជាអ្នករក្សាឃ្លាំង ។ ការសន្មតភិក្ខុឈ្មោះនេះឲ្យជាអ្នករក្សាឃ្លាំង គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀម (បើ) មិនគួរដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះគប្បីពោលឡើង ។ ភិក្ខុឈ្មោះនេះ សង្ឃបានសន្មតឲ្យជាអ្នករក្សាឃ្លាំងហើយ ។ ការសន្មតនេះគួរដល់សង្ឃហើយ ព្រោះហេតុនោះបានជាសង្ឃស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវរឿងនេះដោយអាការស្ងៀមនៅយ៉ាងនេះ ។

(៨១) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុបណ្ដេញភិក្ខុអ្នករក្សាឃ្លាំងឲ្យចៀសចេញ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវបណ្ដេញ(*) ភិក្ខុអ្នករក្សាឃ្លាំងចេញទេ ភិក្ខុណាបណ្ដេញ ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។

---

* បុគ្គលដែលមិនត្រូវបណ្ដេញចេញចាកទីកន្លែងមាន ៤ ពួក គឺភិក្ខុចាស់ជាង ១ ភិក្ខុជាអ្នករក្សាឃ្លាំង ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុដែលបានសេនាសនៈអំពីសង្ឃ ១ ។ ភិក្ខុចាស់មិនត្រូវបណ្ដេញភិក្ខុចាស់ចេញ ព្រោះលោកចាស់ជាងខ្លួន ។ ភិក្ខុជាអ្នករក្សាឃ្លាំង ភិក្ខុមិនត្រូវបណ្ដេញចេញ ព្រោះសង្ឃបានសន្មតឲ្យជាអ្នករក្សាឃ្លាំង ។ ភិក្ខុមានជម្ងឺ ភិក្ខុមិនត្រូវបណ្ដេញចេញ ព្រោះលោកឈឺ ។ ភិក្ខុដែលបានសេនាសនៈអំពីសង្ឃ ភិក្ខុមិនត្រូវបណ្ដេញចេញ ព្រោះសង្ឃបានឲ្យទីកន្លែងជាទីសប្បាយដល់លោកដែលជាពហុស្សុត មានឧបការៈដល់សង្ឃដោយកិច្ចមានការបង្រៀនធម៌ជាដើម (អដ្ឋកថា) ។

[៨២] តេន ខោ បន សមយេន សង្ឃស្ស ភណ្ឌាគារេ ចីវរំ ឧស្សន្នំ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ សម្មុខីភូតេន សង្ឃេន ភាជេតុន្តិ ។ តេន ខោ បន សមយេន សព្វោ សង្ឃោ ចីវរំ ភាជេន្តោ កោលាហលំ អកាសិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតំ ភិក្ខុំ ចីវរភាជកំ សម្មន្និតុំ យោ ន ឆន្ទាគតឹ គច្ឆេយ្យ ន ទោសាគតឹ គច្ឆេយ្យ ន មោហាគតឹ គច្ឆេយ្យ ន ភយាគតឹ គច្ឆេយ្យ ភាជិតាភាជិតញ្ច ជានេយ្យ ។ ឯវញ្ច បន ភិក្ខវេ សម្មន្និតព្វោ ។ បឋមំ ភិក្ខុ យាចិតព្វោ យាចិត្វា ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមំ ភិក្ខុំ ចីវរភាជកំ សម្មន្នេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ



[៨២] សម័យនោះឯង ចីវរក្នុងឃ្លាំងរបស់សង្ឃក៏សម្បូណ៌ឡើង ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសង្ឃដែលនៅជួបជុំគ្នា[១]ចែកចីវរបាន ។ គ្រានោះឯង សង្ឃទាំងអស់កាលចែកចីវរក៏បានធ្វើឲ្យសេចក្តីកោលាហលឡើង ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសង្ឃសន្មតភិក្ខុដែលប្រកបដោយអង្គ ៥ ឲ្យជាអ្នកចែកចីវរបាន គឺ ភិក្ខុដែលមិនលុះឆន្ទាគតិ ១ មិនលុះទោសាគតិ ១ មិនលុះមោហាគតិ ១ មិនលុះភយាគតិ ១ ដឹងនូវរបស់ដែលខ្លួនបានចែកហើយ នឹងមិនទាន់បានចែក ១ ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវសន្មតយ៉ាងនេះ ។ សង្ឃត្រូវអង្វរករភិក្ខុជាមុន លុះអង្វរករួចហើយ ភិក្ខុអ្នកឈ្លាសប្រតិពលត្រូវញ៉ាំងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ បើកម្មមានកាលសមគួរដល់សង្ឃហើយ សង្ឃគួរសន្មតភិក្ខុឈ្មោះនេះឲ្យជាអ្នកចែកចីវរ ។ នេះជាពាក្យញៀងសង្ឃឲ្យដឹង ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ

១ បានដល់សង្ឃដែលនៅក្នុងខណ្ឌសីមាតែមួយ (អដ្ឋកថា) ។

សង្ឃោ សង្ឃោ ឥត្ថន្នាមំ ភិក្ខុំ ចីវរភាជកំ សម្មន្នតិ ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស ភិក្ខុនោ ចីវរភាជកស្ស សម្មតិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ សម្មតោ សង្ឃេន ឥត្ថន្នាមោ ភិក្ខុ ចីវរភាជកោ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។ អថខោ ចីវរភាជកានំ ភិក្ខូនំ ឯតទហោសិ កថំ នុ ខោ ចីវរំ ភាជេតព្ពន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ បឋមំ ឧច្ចិនិត្វា តុលយិត្វា វណ្ណាវណ្ណំ កត្វា ភិក្ខូ គណេត្វា វគ្គំ ពន្ធិត្វា ចីវរបដិវំសំ ឋបេតុន្តិ ។ អថខោ ចីវរភាជកានំ ភិក្ខូនំ ឯតទហោសិ កថំ នុ ខោ សាមណេរានំ ចីវរបដិវំសោ ទាតព្ពោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ សាមណេរានំ ឧបឌ្ឍបដិវំសំ ទាតុន្តិ ។



សង្ឃសន្មតភិក្ខុឈ្មោះនេះឲ្យជាអ្នកចែកចីវរ ។ ការសន្មតភិក្ខុឈ្មោះនេះឲ្យជាអ្នកចែកចីវរគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះនៅស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីពោលឡើង ។ ភិក្ខុឈ្មោះនេះសង្ឃបានសន្មតឲ្យជាអ្នកចែកចីវរហើយ ។ ការសន្មតនេះគួរដល់សង្ឃហើយ ព្រោះហេតុនោះបានជាសង្ឃស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវកិរិយានេះ ដោយអាការស្ងៀមនៅយ៉ាងនេះ ។ វេលានោះ ពួកភិក្ខុអ្នកចែកចីវរ មានសេចក្តីរិះគិតដូច្នេះថា យើងគួរចែកចីវរដូចម្តេចហ្ន៎ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុជ្រើសរើស ( ចីវរ ) ជាមុន ហើយស្ទង់មើល ( ដម្លៃ ) ហើយលៃលកចីវរដែលមានសណ្ឋានគួរដល់ថ្លៃច្រើនតិច ( ឲ្យមានចំណែកស្មើគ្នា ) ហើយរាប់ភិក្ខុ ហើយចងចីវរឲ្យជាពួក ៗ រួច សឹមដាក់ទុកនូវចំណែកនៃចីវរ ។ វេលានោះ ពួកភិក្ខុអ្នកចែកចីវរមានសេចក្តីរិះគិតដូច្នេះថា យើងត្រូវឲ្យចំណែកចីវរដល់ពួកសាមណេរដូចម្តេចហ្ន៎ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុទាំងឡាយឲ្យចំណែកពាក់កណ្តាលដល់ពួកសាមណេរ ។

តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ សកេន ភាគេន ឧត្តរិតុកាមោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ឧត្តរន្តស្ស សកំ ភាគំ ទាតុន្តិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ អតិរេកភាគេន ឧត្តរិតុកាមោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ អនុក្ខេបេ ទិន្នេ អតិរេកភាគំ ទាតុន្តិ ។ អថ ខោ ចីវរភាជកានំ ភិក្ខូនំ ឯតទហោសិ កថំ នុ ខោ ចីវរប្បដិវីសោ ទាតព្វោ អាគតប្បដិបាដិយា នុ ខោ ឧទាហុ យថាវុឌ្ឍន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ វិកលកេ តោសេត្វា កុសបាតំ កាតុន្តិ ។

(៥៣) តេន ខោ បន សមយេន ភិក្ខូ ឆកណេនបិ បណ្ឌុមត្តិកាយបិ ចីវរំ រជន្តិ ។ ចីវរំ ទុព្ពណ្ណំ



សម័យនោះឯង ភិក្ខុ១រូប មានសេចក្តីប្រាថ្នានឹងចូលស្ទឹងឬចូលផ្លូវឆ្ងាយ ហើយចង់បានចំណែករបស់ខ្លួន (ជាមុនគេ) ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឲ្យចំណែករបស់ខ្លួន (គឺរបស់ភិក្ខុអ្នកចូលស្ទឹង) ដល់ភិក្ខុអ្នកចូល (ស្ទឹងឬផ្លូវឆ្ងាយ) នុះ ។ សម័យនោះឯង ភិក្ខុ១រូប មានសេចក្តីប្រាថ្នានឹងចូលស្ទឹងឬចូលផ្លូវឆ្ងាយ ចង់បានចំណែកឲ្យច្រើនជាងគេ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលបើគេឲ្យយកណ្ណូវគេបានឲ្យហើយ តថាគតអនុញ្ញាតឲ្យភិក្ខុឲ្យចំណែកដ៏ច្រើននុះ ។ គ្រានោះ ពួកភិក្ខុអ្នកចែកចីវរ មានសេចក្តីរិះគិតដូច្នេះថា យើងត្រូវឲ្យចំណែកចីវរដូចម្តេចហ្ន៎ យើងត្រូវឲ្យចំណែកចីវរតាមលំដាប់ភិក្ខុដែលមកឬ ឬក៏ត្រូវឲ្យចំណែកចីវរតាមលំដាប់ភិក្ខុចាស់ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលបើចីវរខ្វះហើយ តថាគតអនុញ្ញាតឲ្យអ្នកទាំងឡាយញុំាងភិក្ខុឲ្យត្រេកអរសិន ហើយសឹមធ្វើការបោះស្លាក ។

(៥៣) សម័យនោះឯង ភិក្ខុទាំងឡាយ ដែលជ្រលក់ចីវរដោយអាចម៍គោខ្លះ ដោយដីស្អិតមានពណ៌លឿងខ្លះ ។ ចីវរនោះក៏មានពណ៌មិនល្អ ។

ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ៦ រជនានិ មូលរជនំ ខន្ធរជនំ តចរជនំ បត្តរជនំ បុប្ផរជនំ ផលរជនន្តិ ។ តេន ខោ បន សមយេន ភិក្ខូ សីតុទកាយ(១)ចីវរំ រជន្តិ ។ ចីវរំ ទុគ្គន្ធំ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ រជនំ បចិតុំ ចុល្លរជនកុម្ភិន្តិ ។ រជនំ ឧត្តរិ យតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ឧត្តរាឡុម្បំ(២)ពន្ធិតុន្តិ ។ តេន ខោ បន សមយេន ភិក្ខូ ន ជានន្តិ រជនំ បក្កំ វា អបក្កំ វា ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ឧទកេ

១ ឱ. សីតុន្ទកាយ ។ ២ ឱ. វត្តកឡុម្បំ ។



ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្ដីនុះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទឹកជ្រលក់ ៦ យ៉ាង គឺ ទឹកជ្រលក់កើតពីឫស ១ ទឹកជ្រលក់កើតពីដើម ១ ទឹកជ្រលក់កើតពីសម្បក ១ ទឹកជ្រលក់កើតពីស្លឹក ១ ទឹកជ្រលក់កើតពីផ្កា ១ ទឹកជ្រលក់កើតពីផ្លែ ១ ។ សម័យនោះឯង ភិក្ខុទាំងឡាយជ្រលក់ចីវរដោយទឹកត្រជាក់ ។ ចីវរនោះក៏មានក្លិនមិនល្អ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្ដីនុះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឆ្នាំងដែលតូច ដើម្បីដាំទឹកជ្រលក់ ។ ទឹកជ្រលក់ក៏ពុះលើឡើង ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្ដីនុះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យចងទ្រដាស(១) ។ សម័យនោះឯង ភិក្ខុទាំងឡាយមិនដឹងទឹកជ្រលក់ឆ្អិនហើយឬនៅមិនទាន់ឆ្អិន ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្ដីនុះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យបន្តក់(២)ដំណក់ទឹក

១ គឺដាក់ឈើកាងនៅមាត់ឆ្នាំង ដើម្បីកុំឲ្យគ្រឿងជ្រលក់មានចំណាំងឈើជាដើមធ្លុះឡើងបាន ។ ២ បើទឹកដែលឆ្អិនស្រុះហើយយកទៅបន្តក់លើភាជនៈទឹក (ដៃ) ក៏ចុះសាយដេញរហ័ស ឬបន្តក់លើខ្នងក្រចកក៏ខ្វះជ្រោះរោះ (អដ្ឋកថា) ។

វា នខបិដ្ឋិកាយ វា ថេវកំ ទាតុន្តិ ។ តេន ខោ បន សមយេន ភិក្ខូ រជនំ ឱរោបេន្តា កុម្ភឹ អាវិញ្ឆន្តិ កុម្ភី ភិជ្ជតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ រជនុឡុង្កំ ទណ្ឌកថាលិកន្តិ ។ តេន ខោ បន សមយេន ភិក្ខូនំ រជនភាជនំ ន សំវិជ្ជតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ រជនកោលម្ពំ រជនឃដន្តិ ។ តេន ខោ បន សមយេន ភិក្ខូ បាតិយាបិ បត្តេបិ ចីវរំ មទ្ទន្តិ[១] ។ ចីវរំ បរិភិជ្ជតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ រជនទោណិកន្តិ ។ តេន ខោ បន សមយេន ភិក្ខូ ឆមាយ ចីវរំ បត្ថរន្តិ ចីវរំ បំសុកិតំ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ តិណសន្ថារកន្តិ ។ តិណសន្ថារកោ ឧបចិកាហិ ខជ្ជតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ

១ ម. សម្មទ្ទន្តិ ។



លើទឹកក៏បាន លើខ្នងក្រចកក៏បាន ៗ សម័យនោះឯង ភិក្ខុទាំងឡាយកាលដាក់ទឹកជ្រលក់ក៏ផ្អៀងឆ្នាំង ៗ ក៏បែកទៅ ៗ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្ដីនុះចំពោះព្រះដ៏មានព្រះភាគ ៗ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវវែកឬចានសម្រាប់ដួសទឹកជ្រលក់ដែលមានដង ៗ សម័យនោះឯង ភាជន៍សម្រាប់ដាក់ទឹកជ្រលក់របស់ភិក្ខុទាំងឡាយមិនគ្រប់គ្រាន់ ៗ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្ដីនុះចំពោះព្រះមានព្រះភាគ ៗ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវឆ្នាំងសម្រាប់ដាក់ទឹកជ្រលក់និងក្អមសម្រាប់ដាក់ទឹកជ្រលក់ ៗ សម័យនោះឯង ភិក្ខុទាំងឡាយគក់ចីវរក្នុងថាសខ្លះក្នុងបាត្រខ្លះ ៗ ចីវរក៏ដាច់ដាចអស់ ៗ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្ដីនុះចំពោះព្រះមានព្រះភាគ ៗ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវស្នូកសម្រាប់ជ្រលក់ ៗ សម័យនោះឯង ភិក្ខុទាំងឡាយក្រាលចីវរលើផែនដី ចីវរក៏ប្រឡាក់ដោយធូលីដី ៗ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្ដីនុះចំពោះព្រះដ៏មានព្រះភាគ ៗ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវកម្រាលស្មៅ ៗ កម្រាលស្មៅពួកសត្វកណ្ដៀរស៊ីអស់ទៅ ៗ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្ដីនុះចំពោះព្រះដ៏មានព្រះភាគ ៗ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ

ចីវរំ ចីវរពន្ធិ ។ មជ្ឈេ លុជ្ជតិ វជ្ជំ ទុគតោ គលតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ កណ្ណា ពន្ធិតុន្តិ ។ កណ្ណា ជីរតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ កណ្ណសុត្តកន្តិ ។ រជំ បតតិ គលតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ សម្បារិកំ សម្បារិកំ កាតុំ ២ ៥ អង្គុលេ ផេរំ បត្តមត្តិ ។ តេន ខោ បន សមយេន ចីវរំ បត្តុំ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ខុទ្ទកោ ខុសាធេតុន្តិ ។ តេន ខោ បន សមយេន ចីវរំ ជុរសំ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ចាណិកា អាលោបេតុន្តិ ។



តថាគតអនុញ្ញាតឲ្យ[illegible] [ដោយហោលប៉ារមីនីខ្សែស្បែក]ទ ។ ភិក្ខុទាំងឡាយ [illegible] ទឹក[ដែលគេ[illegible]] [illegible]ទាំងពីរ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើត្រង់ជាយចីវរ ។ ជាយចីវរគំរក់ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យខ្សែ[សម្រាប់ចងជាយចីវរ] ។ ទឹក[ដែលគេ[illegible]]ហៀរហូរទៅតាមជាយម្ខាង ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យ[illegible] [illegible] [illegible] កាលបើ[illegible] [illegible] ភិក្ខុកាលបើ[illegible]ឡើយ ។ សម័យនោះឯង ចីវរ[illegible] ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យ[illegible] ចីវរ[illegible] (៦២) ។ សម័យនោះឯង ចីវរមានសាច់ក្រាស់ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យកាត់ចីវរដោយកាំបិត ។

[៤៦] តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ អច្ឆិន្នកានិ ចីវរានិ ធារេន្តិ ផលកាសាវានិ ធារេន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ(១) ។ ភិក្ខូ(២) ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ អច្ឆិន្នកានិ ចីវរានិ ធារេតព្វានិ យោ ធារេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(៤៧) អថខោ ភគវា រាជគហេ យថាភិរន្តំ វិហរិត្វា យេន ទក្ខិណាគិរិ តេន ចារិកំ បក្កាមិ ។ អទ្ទសា ខោ ភគវា មគធខេត្តំ(៣) អច្ឆិពទ្ធំ បាលិពទ្ធំ មរិយាទពទ្ធំ សិង្ឃាដកពទ្ធំ(៤) ទិស្វាន អាយស្មន្តំ អានន្ទំ អាមន្តេសិ បស្សសិ នោ ត្វំ អានន្ទ មគធខេត្តំ អច្ឆិពទ្ធំ បាលិពទ្ធំ មរិយាទពទ្ធំ សិង្ឃាដកពទ្ធន្តិ ។

១ ឱកោ បរំ ឧជ្ឈាយមានា សេយ្យថាបិ នាម គិហី កាមភោគិនោតិ ទិស្សតិ ។ ២ ភគវតោ បាឋោ ន ហោតិ ។ ៣ ម. មគធខេត្តំ ។ ៤ អច្ឆិពទ្ធំ បាលិពទ្ធំ មរិយាទពទ្ធំ សិង្ឃាដកពទ្ធំ ។



[៤៦] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុប្រើប្រាស់ចីវរមិនបានកាត់ ទុកទាំងចីវរដែលត្រាំដោយទឹកចត់មានពណ៌ដូចក្ដារ ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយមិនត្រូវប្រើប្រាស់ចីវរដែលមិនបានកាត់ទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ។

[៤៧] គ្រានោះ ព្រះមានព្រះភាគគង់នៅក្នុងក្រុងរាជគ្រឹះដោយសមគួរដល់ព្រះអធ្យាស្រ័យ ហើយក៏ទ្រង់យាងចេញទៅ កាន់ចារិកក្នុងទក្ខិណាគិរីជនបទ ។ ព្រះមានព្រះភាគទ្រង់ឃើញស្រែក្នុងដែនមគធៈ មានសណ្ឋានជាស្រែមានជ្រុងបួន មានសណ្ឋានជាស្រែមានភ្លឺវែងដោយបណ្ដោយនិងទទឹង មានសណ្ឋានជាស្រែមានភ្លឺខ្លីកណ្ដាលចន្លោះៗ មានសណ្ឋានជាបួនជ្រុងដោយមានភ្លឺច្បាញ់គ្នា លុះទ្រង់ទតឃើញហើយ ក៏ត្រាស់ហៅព្រះអានន្ទដ៏មានអាយុថា នែអានន្ទ អ្នកឃើញស្រែក្នុងដែនមគធៈ មានសណ្ឋានជាស្រែមានជ្រុងបួន មានសណ្ឋានជាស្រែមានភ្លឺវែងដោយបណ្ដោយនិងទទឹង មានសណ្ឋានជាស្រែមានភ្លឺខ្លីកណ្ដាលចន្លោះៗ មានសណ្ឋានជាបួនជ្រុងដោយមានភ្លឺច្បាញ់គ្នាឬទេ ។

ឃរំ កាតុន្តិ ។ ឧស្សហសិ ត្វំ អានន្ទ ភិក្ខូនំ ឯវរូបានិ ចីវរានិ សំវិទហិតុន្តិ ។ ឧស្សហាមិ ភគវាតិ ។ អថខោ ភគវា ទក្ខិណាគិរិស្មឹ យថាភិរន្តំ វិហរិត្វា បុនទេវ រាជគហំ បច្ចាគញ្ឆិ ។ អថខោ អាយស្មា អានន្ទោ សម្ពហុលានំ ភិក្ខូនំ ចីវរានិ សំវិទហិត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ ឯតទវោច បស្សតុ[១] មេ ភន្តេ ភគវា ចីវរានិ សំវិទហិតានីតិ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ បណ្ឌិតោ ភិក្ខវេ អានន្ទោ មហាបញ្ញោ ភិក្ខវេ អានន្ទោ យត្រ ហិ នាម មយា សង្ខិត្តេន ភាសិតស្ស វិត្ថារេន អត្ថំ អាជានិស្សតិ កុសិម្បិ នាម ករិស្សតិ អឌ្ឍកុសិម្បិ នាម ករិស្សតិ មណ្ឌលម្បិ នាម ករិស្សតិ អឌ្ឍមណ្ឌលម្បិ នាម ករិស្សតិ វិវដ្ដម្បិ នាម ករិស្សតិ

១ បស្សថ ឥតិ ទិស្សតិ ។



ព្រះអានន្ទក្រាបបង្គំទូលថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរថា នែអានន្ទ អ្នកអាចកាត់ចែងចីវរថ្វាយនេះដល់ភិក្ខុទាំងឡាយបានឬទេ ។ ព្រះអានន្ទក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គអាចធ្វើបាន ។ វេលានោះ ព្រះដ៏មានព្រះភាគទ្រង់គង់ក្នុងទក្ខិណាគិរីជនបទ គួរដល់ព្រះហឫទ័យហើយក៏ទ្រង់យាងត្រឡប់មកក្រុងរាជគ្រឹះវិញ ។ ខណៈនោះ ព្រះអានន្ទដ៏មានអាយុក៏បានកាត់ចែងចីវរដល់ភិក្ខុទាំងឡាយជាច្រើនរូប រួចហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគទ្រង់ទតចីវរដែលខ្ញុំព្រះអង្គបានកាត់ចែងហើយចុះ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគក៏ធ្វើនូវធម្មីកថាគួរដល់វេលានោះ រួចទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ អានន្ទជាបណ្ឌិត ម្នាលភិក្ខុទាំងឡាយ អានន្ទមានប្រាជ្ញាច្រើន ព្រោះថាពាក្យដែលតថាគតពោលហើយដោយសង្ខេប អានន្ទអាចដឹងសេចក្ដីដោយពិស្ដារបាន ហើយនេះធ្វើសំពត់ឈ្មោះកុសិផង ធ្វើសំពត់ឈ្មោះអឌ្ឍកុសិផង ធ្វើសំពត់ឈ្មោះមណ្ឌលៈផង ធ្វើសំពត់ឈ្មោះអឌ្ឍមណ្ឌលៈផង ធ្វើសំពត់ឈ្មោះវិវដ្ដៈផង

អនុវិវដ្ដម្បិ នាម ករិស្សតិ គីវេយ្យកម្បិ នាម ករិស្សតិ, ជង្ឃេយ្យកម្បិ នាម ករិស្សតិ ពាហន្តម្បិ នាម ករិស្សតិ ឆិន្នកញ្ច ភវិស្សតិ សត្ថលូខំ សមណសារុប្បំ, បច្ចត្ថិកានញ្ច អនភិច្ឆិតំ អនុជានាមិ ភិក្ខវេ ឆិន្នកំ សង្ឃាដឹ ឆិន្នកំ ឧត្តរាសង្គំ ឆិន្នកំ អន្តរវាសកន្តិ ។

[៨៦] អថខោ ភគវា រាជគហេ យថាភិរន្តំ វិហរិត្វា យេន វេសាលី តេន ចារិកំ បក្កាមិ ។ អទ្ទសា ខោ ភគវា អន្តរា ច រាជគហំ អន្តរា ច វេសាលឹ អទ្ធានមគ្គប្បដិបន្នោ សម្ពហុលេ ភិក្ខូ ចីវរេហិ ឧព្ភណ្ឌិតេ(១) សីសេបិ ចីវរភិសឹ ករិត្វា ខន្ធេបិ ចីវរភិសឹ ករិត្វា កដិយាបិ ចីវរភិសឹ ករិត្វា អាគច្ឆន្តេ ទិស្វាន ភគវតោ ឯតទហោសិ អតិលហុំ ខោ ឥមេ មោឃបុរិសា ចីវរេ ពាហុល្លាយ អាវត្តា យន្នូនាហំ ភិក្ខូនំ ចីវរេ សីមំ ពន្ធេយ្យំ មរិយាទំ ឋបេយ្យន្តិ ។ អថខោ ភគវា អនុបុព្វេន ចារិកំ ចរមានោ យេន វេសាលី តទវសរិ ។

១ 1. ឧព្ភណ្ឌិតេ ។



ធ្វើសំពត់ឈ្មោះអនុវិវដ្ដៈផង ធ្វើសំពត់ឈ្មោះគីវេយ្យកៈផង ធ្វើសំពត់ឈ្មោះជង្ឃេយ្យកៈផង ធ្វើសំពត់ឈ្មោះពាហន្តៈផង ហើយសំពត់នោះជាឆ្នូតក៏បានកាត់ដាច់ឲ្យសៅហ្មងដោយមុខកាំបិតឲ្យសមគួរដល់សមណៈ ឲ្យជារបស់មិនគួរប្រាថ្នា ដល់ពួកចោរជាសត្រូវ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសង្ឃាដិកាត់ ឧត្តរាសង្គៈកាត់ អន្តរវាសកៈកាត់ ។

[៨៦] គ្រានោះ ព្រះមានព្រះភាគគង់ក្នុងក្រុងរាជគ្រឹះតាមដល់ពុទ្ធអធ្យាស្រ័យ ហើយក៏ទ្រង់ចៀសទៅកាន់ចារិកក្រុងវេសាលី ។ ព្រះមានព្រះភាគទ្រង់យាងទៅកាន់ផ្លូវឆ្ងាយ ជាចន្លោះក្រុងរាជគ្រឹះនឹងចន្លោះក្រុងវេសាលី ក៏បានទតឃើញភិក្ខុទាំងឡាយច្រើនរូប មានចីវរបេបជាសំពាយ ខ្លះដាក់ផ្នត់ចីវរលើក្បាលខ្លះ ដាក់ផ្នត់ចីវរលើស្មាខ្លះ ដាក់ផ្នត់ចីវរលើចង្កេះខ្លះដើរមក លុះទតឃើញហើយ ព្រះដ៏មានព្រះភាគទ្រង់ត្រិះរិះយ៉ាងនេះថា ពួកមោឃបុរសទាំងនេះវិលមករកសេចក្ដីលោភក្នុងចីវរឆាប់ពេកណាស់ បើដូច្នោះគួរតថាគតចងសីមាតាំងនូវកន្លងខេត្តនៃកន្លងចីវរដល់ភិក្ខុទាំងឡាយ ។ វេលានោះ ព្រះដ៏មានព្រះភាគទ្រង់យាងទៅកាន់ចារិកដោយលំដាប់ ទើបបានដល់ទៅក្រុងវេសាលី ។

តត្រ សុទំ ភគវា វេសាលិយំ វិហរតិ គោតមកេ ចេតិ-យេ ។ តេន ខោ បន សមយេន ភគវា សីតាសុ ហេ-មន្តិកាសុ រត្តីសុ អន្តរដ្ឋកាសុ ហិមបាតសមយេ រត្តិំ អជ្ឈោកាសេ ឯកចីវរោ និសីទិ ន ភគវន្តំ សីតំ អហោសិ(១) និក្ខន្តេ បឋមេ យាមេ សីតំ ភគវន្តំ អហោសិ ទុតិយំ ភគវា ចីវរំ បារុបិ ន ភគវន្តំ សីតំ អហោសិ និក្ខន្តេ មជ្ឈិមេ យាមេ សីតំ ភគវន្តំ អហោសិ តតិយំ ភគវា ចីវរំ បារុបិ ន ភគវន្តំ សីតំ អហោសិ និក្ខន្តេ បច្ឆិមេ យាមេ ឧទ្ធស្តេ អរុណេ នន្ទិមុខិយា រត្តិយា សីតំ ភគវន្តំ អហោសិ ចតុត្ថំ ភគវា ចីវរំ បារុបិ ន ភគវន្តំ សីតំ អហោសិ ។ អថខោ ភគវតោ ឯតទហោសិ យេបិ ខោ តេ កុលបុត្តា ឥមស្មិំ ធម្មវិនយេ សីតាលុកា សីតភីរុកា តេបិ សក្កោន្តិ តិចីវរេន យាបេតុំ យន្នូនា-ហំ ភិក្ខូនំ ចីវរេ សីមំ ពន្ធេយ្យំ មរិយាទំ ឋបេយ្យំ តិចីវរំ អនុជានេយ្យន្តិ ។ អថខោ ភគវា ឯតស្មិំ និទានេ

១ ន ភគវន្តំ សីតំ អហោសីតិ ភគវតោ សីតំ នាហោសីតិ (អដ្ឋកថា) ។



បានឮថា ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅគោតមកចេតិយ ទៀបក្រុងវេសា-លីនោះ ។ សម័យនោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ចីវរតែមួយ គង់នៅក្នុងទីវាលក្នុងវេលាយប់ ក្នុងសម័យមានទឹកសន្សើមធ្លាក់ចុះ ក្នុងរាត្រីជាន់ត្រជាក់ ដែលត្រជាក់នៅក្នុងហេមន្តរដូវ ឋិតនៅជាចន្លោះនៃខែមាឃនិងខែផល្គុណ(១) ព្រះអង្គក៏មិនរងាឡើយ លុះបឋមយាមកន្លងទៅហើយ ទើបព្រះអង្គរងា ហើយព្រះអង្គទ្រង់ចីវរជាគំរប់ពីរ ព្រះអង្គក៏បាត់រងាទៅ លុះមជ្ឈិមយាមកន្លងទៅហើយ ទើបព្រះអង្គរងា ហើយព្រះអង្គទ្រង់ដណ្តប់ចីវរជាគំរប់បី ព្រះអង្គក៏បាត់រងាទៀត លុះបច្ឆិមយាមកន្លងទៅហើយ កាលអរុណរះឡើង រាត្រីក៏ភ្លឺព្រាង ៗ ទើបព្រះអង្គរងា ព្រះអង្គទ្រង់ដណ្តប់ចីវរជាគំរប់បួន ព្រះអង្គក៏បាត់រងាទៅ ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់រំពឹងដូច្នេះថា ក្នុងធម្មវិន័យនេះ កុលបុត្តទាំងឡាយណាដែលជាអ្នករងាជាប្រក្រតី ជាអ្នកខ្លាចរងា កុលបុត្តទាំងនោះក៏អាចញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយចីវរ ៣ បាន បើដូច្នេះគួរតថាគតបង់សីមា ហើយកំណត់ទុកនូវខណ្ឌដែនក្នុងចីវរ ហើយអនុញ្ញាតចីវរ ៣ ដល់ភិក្ខុទាំងឡាយ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថាក្នុងវេលានោះ រួចទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា

១ អដ្ឋកថាថា ក្នុងរាត្រី ៨ គឺខាងចុងខែមាឃ ៤ រាត្រី ខាងដើមខែផល្គុណ ៤ រាត្រី ហៅថាចន្លោះនៃខែមាឃនិងខែផល្គុណ ។

ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ ឥធាហំ ភិក្ខវេ អន្តរា ច រាជគហំ អន្តរា ច វេសាលឹ អទ្ធានមគ្គប្បដិបន្នោ អទ្ទសំ សម្ពហុលេ ភិក្ខូ ចីវរេហិ ឧព្ភណ្ឌិតេ សីសេបិ ចីវរភិសឹ ករិត្វា ខន្ធេបិ ចីវរភិសឹ ករិត្វា កដិយាបិ ចីវរភិសឹ ករិត្វា អាគច្ឆន្តេ ទិស្វាន មេ ឯតទហោសិ អតិលហុំ ខោ ឥមេ មោឃបុរិសា ចីវរេ ពាហុល្លាយ អាវត្តា យន្នូនាហំ ភិក្ខូនំ ចីវរេ សីមំ ពន្ធេយ្យំ មរិយាទំ ឋបេយ្យន្តិ ។ ឥធាហំ ភិក្ខវេ សីតាសុ ហេមន្តិកាសុ រត្តីសុ អន្តរដ្ឋកាសុ ហិមបាតសមយេ រត្តឹ អជ្ឈោកាសេ ឯកចីវរោ និសីទឹ ន មំ សីតំ អហោសិ និក្ខន្តេ បឋមេ យាមេ សីតំ មំ អហោសិ ទុតិយាហំ ចីវរំ បារុបឹ ន មំ សីតំ អហោសិ និក្ខន្តេ មជ្ឈិមេ យាមេ សីតំ មំ អហោសិ តតិយាហំ ចីវរំ បារុបឹ ន មំ សីតំ អហោសិ និក្ខន្តេ បច្ឆិមេ យាមេ ឧទ្ធស្តេ អរុណេ នន្ទិមុខិយា រត្តិយា សីតំ មំ អហោសិ ចតុត្ថាហំ ចីវរំ បារុបឹ ន មំ សីតំ អហោសិ តស្ស មយ្ហំ ភិក្ខវេ ឯតទហោសិ យេបិ ខោ តេ កុលបុត្តា



ម្នាលភិក្ខុទាំងឡាយ ក្នុងកាលនេះតថាគត បានដើរទៅកាន់ផ្លូវឆ្ងាយ ជាចន្លោះក្រុងរាជគ្រឹះនឹងចន្លោះក្រុងវេសាលី ហើយឃើញភិក្ខុច្រើនរូប មានចីវរច្រើនធ្វើជាសំពាយដាក់ធ្វើជាចីវរលើក្បាលខ្លះ ដាក់ធ្វើជាចីវរលើ-កខ្លះ ដាក់ធ្វើចីវរលើចង្កេះខ្លះដើរមក លុះឃើញហើយ តថាគតក៏មានសេចក្តីត្រិះរិះដូច្នេះថា ពួកមោឃបុរសទាំងនេះវិលមករកសេចក្តីលោភក្នុងចីវរឆាប់ពេកណាស់ បើដូច្នេះគួរតថាគតចងសីមាកំណត់ទុកនូវព្រំដែនក្នុងចីវរដល់ភិក្ខុទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលនេះតថាគតគ្រងចីវរតែមួយ អង្គុយនៅក្នុងទីវាលក្នុងពេលយប់ក្នុងសម័យមានទឹកសន្សើមធ្លាក់ចុះក្នុងរាត្រីទាំងឡាយដែលត្រជាក់ នៅក្នុងហេមន្តរដូវ ចំណែកនៅចន្លោះនៃខែមាឃនឹងខែផល្គុន តថាគតក៏មិនរងាឡើយ លុះបឋមយាមកន្លងទៅហើយ ទើបតថាគតរងា តថាគតបានដណ្តប់ចីវរជាគំរប់ពីរ តថាគតក៏បាត់រងាទៅ លុះមជ្ឈិមយាមកន្លងទៅហើយ ទើបតថាគតរងា តថាគតបានដណ្តប់ចីវរជាគំរប់បី ទើបតថាគតបាត់រងាទៅ លុះបច្ឆិមយាមកន្លងទៅហើយ អរុណរះឡើងក្រហមក្រាលៗ ទើបតថាគតរងា តថាគតបានដណ្តប់ចីវរជាគំរប់បួន តថាគតក៏បាត់រងាទៅ ម្នាលភិក្ខុទាំងឡាយ តថាគតក៏មានសេចក្តីរំពឹងដូច្នេះថា ក្នុងធម្មវិន័យនេះ កុលបុត្តទាំងឡាយណា

ឥមស្មឹ ធម្មវិនយេ សីតាលុកា សីតភីរុកា តេបិ សក្កោន្តិ តិចីវរេន យាបេតុំ យន្នូនាហំ ភិក្ខូនំ ចីវរេ សីមំ ពន្ធេយ្យំ មរិយាទំ ឋបេយ្យំ តិចីវរំ អនុជានេយ្យន្តិ អនុជានាមិ ភិក្ខវេ តិចីវរំ ទ្វិគុណំ(១) សង្ឃាដឹ ឯកច្ចិយំ ឧត្តរាសង្គំ ឯកច្ចិយំ អន្តរវាសកន្តិ ។

(៨៧) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ភគវតា តិចីវរំ អនុញ្ញាតន្តិ អញ្ញេនេវ តិចីវរេន គាមំ បវិសន្តិ អញ្ញេនេវ តិចីវរេន អារាមេ អច្ឆន្តិ អញ្ញេនេវ តិចីវរេន នហានំ ឱតរន្តិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ អតិរេកចីវរំ ធារេស្សន្តីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ ន ភិក្ខវេ អតិរេកចីវរំ ធារេតព្វំ យោ ធារេយ្យ យថាធម្មោ ការេតព្វោ ។ តេន ខោ បន

១ ម. ទិគុណំ ។





ដែលជាអ្នករងាជាប្រក្រតី ជាអ្នកខ្លាចរងា កុលបុត្តទាំងនោះអាចញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយចីវរ ៣ បើដូច្នោះ គួរតថាគតចងសីមាតាំងខុកខ្ទង់ដែនក្នុងចីវរ គួរអនុញ្ញាតចីវរ ៣ ដល់ភិក្ខុទាំងឡាយ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតចីវរ ៣ គឺ សង្ឃាដិពីរជាន់ ឧត្តរាសង្គៈ (ចីវរ) ១ ជាន់ ស្បង់ ១ ជាន់ ។

(៨៧) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុដឹងថា ចីវរ ៣ ព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតរួចហើយ ។ ក៏នាំគ្នាចូលទៅកាន់ស្រុកដោយចីវរ ៣ ដទៃទៀត នៅក្នុងវត្តដោយចីវរ ៣ ដទៃទៀត ចុះទៅកាន់កំពង់ជាទីស្រង់ទឹកដោយចីវរ ៣ ដទៃទៀត ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនសមបើនឹងទ្រទ្រង់អតិរេកចីវរសោះ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថាក្នុងពេលនោះរួច ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទ្រទ្រង់អតិរេកចីវរទេ ភិក្ខុណាទ្រទ្រង់ ភិក្ខុនោះត្រូវឲ្យធ្វើតាមធម៌ ។ សម័យនោះ

សមយេន អាយស្មតោ អានន្ទស្ស អតិរេកចីវរំ ឧប្បន្នំ ហោតិ ។ អាយស្មា ច អានន្ទោ តំ ចីវរំ អាយស្មតោ សារីបុត្តស្ស ទាតុកាមោ ហោតិ ។ អាយស្មា ច សារីបុត្តោ សាកេតេ វិហរតិ ។ អថខោ អាយស្មតោ អានន្ទស្ស ឯតទហោសិ ភគវតា បញ្ញត្តំ ន អតិរេកចីវរំ ធារេតព្វន្តិ ឥទញ្ច មេ អតិរេកចីវរំ ឧប្បន្នំ អហញ្ចិមំ ចីវរំ អាយស្មតោ សារីបុត្តស្ស ទាតុកាមោ អាយស្មា ច សារីបុត្តោ សាកេតេ វិហរតិ កថំ នុ ខោ មយា បដិបជ្ជិតព្វន្តិ ។ អថខោ អាយស្មា អានន្ទោ ភគវតោ ឯតមត្ថំ អារោចេសិ ។ កីវចិរំ បនានន្ទ សារីបុត្តោ អាគច្ឆិស្សតីតិ ។ នវមំ វា ភគវា ទិវសំ ទសមំ វាតិ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ ទសាហបរមំ អតិរេកចីវរំ ធារេតុំ ។ តេន ខោ បន សមយេន ភិក្ខូនំ អតិរេកចីវរំ ឧប្បន្នំ ហោតិ ។ អថខោ ភិក្ខូនំ ឯតទហោសិ កថំ



អតិរេកចីវរបានកើតឡើងដល់ព្រះអានន្ទដ៏មានអាយុ ។ ឯព្រះអានន្ទដ៏មានអាយុប្រាថ្នាប្រគេនចីវរនោះទៅព្រះសារីបុត្តដ៏មានអាយុ ។ ព្រះសារីបុត្តដ៏មានអាយុគង់នៅឯក្រុងសាកេត ។ វេលានោះ ព្រះអានន្ទដ៏មានអាយុមានសេចក្តីរិះគិតដូច្នេះថា ព្រះមានព្រះភាគ បានបញ្ញត្តភិក្ខុមិនត្រូវទ្រទ្រង់អតិរេកចីវរទេ ក៏ឯអតិរេកចីវរនេះកើតឡើងដល់អាត្មាអញហើយ តែថាអាត្មាអញចង់ប្រគេនចីវរនេះទៅព្រះសារីបុត្តដ៏មានអាយុ ឥឡូវព្រះសារីបុត្តដ៏មានអាយុគង់នៅឯក្រុងសាកេត តើអាត្មាអញត្រូវប្រតិបត្តិដូចម្តេច ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់សួរថា នែអានន្ទ ចុះសារីបុត្តនៅយូរប៉ុន្មានថ្ងៃទៀតទើបបានមក ។ ព្រះអានន្ទក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ព្រះសារីបុត្តមុខជានឹងមកក្នុងថ្ងៃទី៩ ឬក្នុងថ្ងៃទី១០ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថាក្នុងវេលានោះ រួចទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុទាំងឡាយទ្រទ្រង់អតិរេកចីវរកំណត់ត្រឹម ១០ ថ្ងៃ ។ សម័យនោះ អតិរេកចីវរកើតឡើងដល់ភិក្ខុទាំងឡាយ ។ វេលានោះ ភិក្ខុទាំងឡាយមានសេចក្តីត្រិះរិះដូច្នេះថា

នុ ខោ អម្ហេហិ(១) អតិរេកចីវរេ បដិបជ្ជិតព្វន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ អតិរេកចីវរំ វិកប្បេតុន្តិ ។

(៨៨) អថខោ ភគវា វេសាលិយំ យថាភិរន្តំ វិហរិត្វា យេន ពារាណសី តេន ចារិកំ បក្កាមិ អនុបុព្វេន ចារិកំ ចរមានោ យេន ពារាណសី តទវសរិ ។ តត្រ សុទំ ភគវា ពារាណសិយំ វិហរតិ ឥសិបតនេ មិគទាយេ ។ តេន ខោ បន សមយេន អញ្ញតរស្ស ភិក្ខុនោ អន្តរវាសកោ ឆិទ្ទោ ហោតិ ។ អថខោ តស្ស ភិក្ខុនោ ឯតទហោសិ ភគវតា ខោ តិចីវរំ អនុញ្ញាតំ ទិគុណា សង្ឃាដិ ឯកច្ចិយោ ឧត្តរាសង្គោ ឯកច្ចិយោ អន្តរវាសកោ អយញ្ច មេ អន្តរវាសកោ ឆិទ្ទោ យន្នូនាហំ អគ្គឡំ អច្ឆុបេយ្យំ សមន្តតោ ទុបដ្ដំ ភវិស្សតិ មជ្ឈេ ឯកច្ចិយន្តិ ។ អថខោ សោ ភិក្ខុ អគ្គឡំ អច្ឆុបេសិ ។ អទ្ទសា ខោ ភគវា សេនាសនចារិកំ អាហិណ្ឌន្តោ តំ ភិក្ខុំ អគ្គឡំ អច្ឆុបេន្តំ ទិស្វាន

១ ឱភាធិយរដ្ឋកេ អយំ បាឋោ ន ហោតិ ។



យើងទាំងឡាយត្រូវប្រតិបត្តិក្នុងអតិរេកចីវរដូចម្តេចហ្ន៎ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យវិកប្បអតិរេកចីវរចុះបាន ។

[៨៨] គ្រានោះ ព្រះដ៏មានព្រះភាគគង់ក្នុងក្រុងវេសាលីគួរដល់ពុទ្ធអធ្យាស្រ័យហើយក៏ទ្រង់យាងទៅកាន់ចារិកក្នុងក្រុងពារាណសី កាលទ្រង់យាងទៅកាន់ចារិកដោយលំដាប់ ក៏បានដល់ទៅក្រុងពារាណសី ។ បានឮមកថា ព្រះដ៏មានព្រះភាគទ្រង់គង់ក្នុងឥសិបតនមិគទាយវន ទៀបក្រុងពារាណសីនោះ ។ សម័យនោះ ភិក្ខុ ១ រូបមានស្បង់ធ្លុះ ។ វេលានោះ ភិក្ខុនោះមានសេចក្តីត្រិះរិះដូច្នេះថា ចីវរ ៣ គឺ សង្ឃាដិ ២ ជាន់ ឧត្តរាសង្គ ១ ជាន់ ស្បង់ ១ ជាន់ ព្រះដ៏មានព្រះភាគបានអនុញ្ញាតរួចហើយ ឯស្បង់របស់អាត្មាអញធ្លុះ បើដូច្នោះគួរអាត្មាអញប៉ះខ្ទប់មួយ កាលបើដូច្នោះ ស្បង់នោះនឹងទៅជា ២ ជាន់ដោយជុំវិញ កណ្តាល ១ ជាន់ ។ វេលានោះ ភិក្ខុនោះក៏បានប៉ះខ្ទប់មួយ ។ ព្រះដ៏មានព្រះភាគបានយាងទៅកាន់សេនាសនចារិកក៏បានទតឃើញភិក្ខុនោះកំពុងប៉ះខ្ទប់មួយ លុះទតឃើញ

យេន សោ ភិក្ខុ តេនុបសង្កមិ ឧបសង្កមិត្វា តំ ភិក្ខុំ ឯតទវោច កឹ ត្វំ ភិក្ខុ ករោសីតិ ។ អគ្គឡំ ភគវា អគ្គុបេមីតិ ។ សាធុ សាធុ ភិក្ខុ សាធុ ខោ ត្វំ ភិក្ខុ អគ្គឡំ អគ្គុបេសីតិ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ អហតានំ ទុស្សានំ អហតកប្បានំ ទិគុណំ សង្ឃាដឹ ឯកច្ចិយំ ឧត្តរាសង្គំ ឯកច្ចិយំ អន្តរវាសកំ ឧតុកតានំ ទុស្សានំ ចតុគ្គុណំ សង្ឃាដឹ ទិគុណំ ឧត្តរាសង្គំ ទិគុណំ អន្តរវាសកំ បំសុកូលេ យាវទត្ថំ បាបណិកេ ឧស្សាហោ ករណីយោ អនុជានាមិ ភិក្ខវេ អគ្គឡំ តុន្នំ ឱវដ្ដិកំ កណ្ឌុសកំ ទឡ្ហីកម្មន្តិ ។



ហើយក៏ទ្រង់យាងចូលទៅរកភិក្ខុនោះ លុះចូលទៅដល់ហើយ ទ្រង់ត្រាស់នឹងភិក្ខុនោះដូច្នេះថា នែភិក្ខុ អ្នកធ្វើអ្វី ។ ភិក្ខុនោះក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គប៉ះខ្ទូវបម្ពះ ។ ព្រះដ៏មានព្រះភាគទ្រង់តបថា ប្រពៃហើយៗ ភិក្ខុ ប្រពៃហើយភិក្ខុ អ្នកបានប៉ះខ្ទូវបម្ពះ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគក៏ទ្រង់ធ្វើធម្មីកថាក្នុងវេលានោះ រួចទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ កាលបើសំពត់នៅថ្មីឬសំពត់ដែលគេបោកលាងម្ដងហើយ តថាគតអនុញ្ញាត (ឲ្យអ្នកទាំងឡាយធ្វើ) សង្ឃាដី ២ ជាន់ ឧត្តរាសង្គៈ ១ ជាន់ ស្បង់ ១ ជាន់ (បើ) សំពត់ដែលគេប្រើរៀងរាល់ថ្ងៃ (គឺសំពត់ចាស់) តថាគតអនុញ្ញាតឲ្យអ្នកទាំងឡាយធ្វើសង្ឃាដី ៤ ជាន់ ឧត្តរាសង្គៈ ២ ជាន់ ស្បង់ ២ ជាន់ អ្នកទាំងឡាយគួរធ្វើច្រើនប្រែនស្មើរកសំពត់បង្សុកូល សំពត់ធ្លាក់ចុះក្នុងរានផ្សារតាមត្រូវការ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតខ្ទូវបម្ពះ[1] ខ្ទូវការដុល ខ្ទូវត្រលែកណ្ដុំ ខ្ទូវកណ្ដុំ ខ្ទូវការធ្វើឲ្យមាំ[2]

---

១ បានដល់សំពត់ដែលភិក្ខុប៉ះត្រង់កន្លែងធ្លុះឬត្រង់កន្លែងដែលខូចកាត់ចេញ ។ ២ បានដល់សំពត់ដែលភិក្ខុប៉ះត្រង់កន្លែងដែលមិនបានកាត់ចេញ ។

[៨៩] អថខោ ភគវា ពារាណសិយំ យថាភិរន្តំ វិហរិត្វា យេន សាវត្ថី តេន ចារិកំ បក្កាមិ អនុបុព្វេន ចារិកំ ចរមានោ យេន សាវត្ថី តទវសរិ ។ តត្រ សុទំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ វិសាខា មិគារមាតា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ វិសាខំ មិគារមាតរំ ភគវា ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ។ អថខោ វិសាខា មិគារមាតា ភគវតា ធម្មិយា កថាយ សន្ទស្សិតា សមាទបិតា សមុត្តេជិតា សម្បហំសិតា ភគវន្តំ ឯតទវោច អធិវាសេតុ មេ ភន្តេ ភគវា ស្វាតនាយ ភត្តំ សទ្ធឹ ភិក្ខុសង្ឃេនាតិ ។ អធិវាសេសិ ភគវា តុណ្ហីភាវេន ។ អថខោ វិសាខា មិគារមាតា ភគវតោ អធិវាសនំ





[៨៩] គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្រុងពារាណសីគួរដល់ព្រះអធ្យាស្រ័យហើយ ក៏ទ្រង់យាងទៅកាន់ចារិកក្រុងសាវត្ថី កាលទ្រង់យាងទៅកាន់ចារិកដោយលំដាប់ ក៏បានដល់នៅក្រុងសាវត្ថីនោះ ។ បានឮមកថា ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងព្រះជេតពនរបស់អនាថបិណ្ឌិកសេដ្ឋីទៀបក្រុងសាវត្ថីនោះ ។ វេលានោះ នាងវិសាខាមិគារមាតាបានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ អង្គុយនៅក្នុងទីដ៏សមគួរ ។ កាលនាងវិសាខាមិគារមាតាអង្គុយនៅក្នុងទីដ៏សមគួរហើយ ព្រះដ៏មានព្រះភាគទ្រង់ពន្យល់នាងវិសាខាមិគារមាតាដែលអង្គុយនៅក្នុងទីដ៏សមគួរហើយ ឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថា ។ លំដាប់នោះ នាងវិសាខាមិគារមាតា លុះព្រះដ៏មានព្រះភាគទ្រង់ពន្យល់ឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថាហើយ ក៏ក្រាបបង្គំទូលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគទ្រង់ទទួលភត្តរបស់ខ្ញុំព្រះអង្គ ដើម្បីឆាន់ក្នុងថ្ងៃស្អែកជាមួយនឹងភិក្ខុសង្ឃ ។ ព្រះដ៏មានព្រះភាគទ្រង់ទទួលនិមន្តដោយតុណ្ហីភាព ។ លំដាប់នោះ នាងវិសាខាមិគារមាតាបានដឹងច្បាស់ថា ព្រះដ៏មានព្រះភាគទ្រង់ទទួលនិមន្តហើយ

វិទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ
កត្វា បក្កាមិ ។ តេន ខោ បន សមយេន តស្សា
រត្តិយា អច្ចយេន ចាតុទ្ទីបិកោ មហាមេឃោ បាវស្សិ ។
អថខោ ភគវា ភិក្ខូ អាមន្តេសិ យថា ភិក្ខវេ ជេតវនេ
វស្សតិ ឯវំ ចតូសុ ទីបេសុ វស្សតិ ឱវស្សាបេថ ភិក្ខ-
វេ កាយំ អយំ បច្ឆិមកោ ចាតុទ្ទីបិកោ មហាមេ-
ឃោតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បដិស្សុណិត្វា
និក្ខិត្តចីវរា កាយំ ឱវស្សាបេន្តិ ។ អថខោ វិសាខា
មិគារមាតា បណីតំ ខាទនីយំ ភោជនីយំ បដិយាទា-
បេត្វា ទាសឹ អាណាបេសិ គច្ឆ ជេ អារាមំ គន្ត្វា
កាលំ អារោចេហិ កាលោ ភន្តេ និដ្ឋិតំ ភត្តន្តិ ។ ឯវំ
អយ្យេតិ ខោ សា ទាសី វិសាខាយ មិគារមាតុយា
បដិស្សុណិត្វា អារាមំ គន្ត្វា អទ្ទស ភិក្ខូ និក្ខិត្តចីវរេ



ក៏ក្រោកចាកអាសនៈថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយ
ចៀសចេញទៅ ។ សម័យនោះឯង លុះកន្លងរាត្រីនោះទៅហើយមានភ្លៀង
ធំធ្លាក់ចុះសព្វទ្វីបទាំង ៤ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់
ហៅពួកភិក្ខុមកថា ម្នាលភិក្ខុទាំងឡាយ ភ្លៀងធ្លាក់ចុះក្នុងវត្តជេតពន
យ៉ាងណា ភ្លៀងធ្លាក់ចុះក្នុងទ្វីបទាំង ៤ ក៏យ៉ាងនោះដែរ ម្នាលភិក្ខុទាំង
ឡាយ អ្នកទាំងឡាយចូរទ្រាំដំណក់កាយផង ១ ព្រោះទៅចុះ (ព្រោះ) ភ្លៀង
ធំដែលធ្លាក់សព្វទ្វីបទាំង ៤ នេះជាចុងក្រោយនេះហើយ ។ ភិក្ខុទាំងនោះ
ទទួលស្តាប់ព្រះពុទ្ធដីការបស់ព្រះដ៏មានព្រះភាគដោយពាក្យថា បពិត្រ
ព្រះអង្គដ៏ចំរើន ព្រះករុណាព្រះអង្គ ហើយក៏នាំគ្នាដាក់ចីវរចេញឲ្យទឹក
ភ្លៀងដំរេកាយ[១] ។ គ្រានោះ នាងវិសាខាមិគារមាតាបានឲ្យជនតាក់
តែងខាទនីយភោជនីយាហារដ៏ឧត្តមហើយបង្គាប់ទាសីថា នែហន ហន
ចូរទៅកាន់អារាមហើយក្រាបបង្គំទូលកត្តកាល[២] ថា បពិត្រព្រះអង្គ
ដ៏ចំរើន កាលនេះជាកាលគួរហើយ ភត្តក៏សម្រេចហើយ ។ ទាសី
នោះទទួលស្តាប់ពាក្យរបស់នាងវិសាខាមិគារមាតាដោយពាក្យថា ចា៎ះអ្នក
ជាម្ចាស់ ហើយទៅកាន់អារាមក៏បានឃើញពួកភិក្ខុដែលដាក់ចីវរចេញ

---

១ ភិក្ខុទាំងនោះងូតទឹកភ្លៀងឲ្យស៊ប់ពេញខ្លួន (សំរាក) ។ ២ ពេលគួរឆាន់ចង្ហាន់ ។

កាយំ ឱវស្សាបេន្តេ ទិស្វាន នត្ថិ អារាមេ ភិក្ខូ អាជីវកា កាយំ ឱវស្សាបេន្តីតិ យេន វិសាខា មិគារមាតា តេនុបសង្កមិ ឧបសង្កមិត្វា វិសាខំ មិគារមាតរំ ឯតទវោច នត្ថយ្យេ អារាមេ ភិក្ខូ អាជីវកា កាយំ ឱវស្សាបេន្តីតិ ។ អថខោ វិសាខាយ មិគារមាតុយា បណ្ឌិតាយ វិយត្តាយ មេធាវិនិយា ឯតទហោសិ និស្សំសយំ ខោ អយ្យា និក្ខិត្តចីវរា កាយំ ឱវស្សាបេន្តិ សាយំ ពាលា មញ្ញិ នត្ថិ អារាមេ ភិក្ខូ អាជីវកា កាយំ ឱវស្សាបេន្តីតិ ។ ទាសឹ អាណាបេសិ គច្ឆ ជេ អារាមំ គន្ត្វា កាលំ អារោចេហិ កាលោ ភន្តេ និដ្ឋិតំ ភត្តន្តិ ។ អថខោ តេ ភិក្ខូ គត្តានិ សីតិករិត្វា កល្លកាយា ចីវរានិ គហេត្វា យថាវិហារំ បវិសិំសុ ។ អថខោ សា ទាសី អារាមំ គន្ត្វា ភិក្ខូ អបស្សន្តី នត្ថិ អារាមេ ភិក្ខូ សុញ្ញោ អារាមោតិ យេន វិសាខា មិគារមាតា តេនុបសង្កមិ ឧបសង្កមិត្វា វិសាខំ មិគារមាតរំ ឯតទ-



ភិក្ខុងងូតទឹកភ្លៀងជំរះកាយ លុះឃើញហើយក៏គិតថា ក្នុងអារាមនេះគ្មានពួកភិក្ខុទេ មានតែពួកអាជីវកងូតទឹកភ្លៀងជំរះកាយ រួចហើយក៏ត្រឡប់ចូលទៅកាន់សំណាក់នាងវិសាខាមិគារមាតាវិញ លុះចូលទៅដល់ហើយ ក៏និយាយពាក្យនេះនឹងនាងវិសាខាមិគារមាតាថា បពិត្រអ្នកម្ចាស់ ក្នុងអារាមនេះគ្មានពួកភិក្ខុទេ មានសុទ្ធតែពួកអាជីវកងូតទឹកភ្លៀងជំរះកាយ ។ លំដាប់នោះ នាងវិសាខាមិគារមាតាជាបណ្ឌិត ជាស្រីឈ្លាស ជាអ្នកប្រាជ្ញ បានរិះគិតយ៉ាងនេះថា ច្បាស់ជាលោកម្ចាស់ទាំងឡាយដាក់ចីវរចេញហើយនាំគ្នាងូតទឹកភ្លៀងជំរះកាយ តែតាសីនេះជាស្រីល្ងង់សំគាល់ថាក្នុងអារាមគ្មានភិក្ខុទេ មានសុទ្ធតែពួកអាជីវកកំពុងនាំគ្នាងូតទឹកភ្លៀងជំរះកាយ ។ នាងវិសាខាមិគារមាតាបង្គាប់ទាសីជាថ្មីទៀត ថាឯងចូរទៅកាន់អារាមហើយក្រាបបង្គំទូលភត្តកាលថា បពិត្រព្រះអង្គដ៏ចំរើន កាលនេះជាកាលគួរហើយ ភត្តក៏សម្រេចហើយ ។ កាលនោះ ភិក្ខុទាំងនោះងូតទឹកឲ្យត្រជាក់ខ្លួន មានកាយដ៏ស្រួល ហើយក៏នាំគ្នាយកចីវរទាំងឡាយចូលទៅកាន់លំនៅដូចដែលវិញ ។ ឯទាសីនោះទៅកាន់អារាមមិនឃើញពួកភិក្ខុក៏គិតថា ក្នុងអារាមគ្មានភិក្ខុសោះ មានតែអារាមទទេ ហើយក៏ត្រឡប់ចូលទៅកាន់សំណាក់នាងវិសាខាមិគារមាតាវិញ លុះចូលទៅដល់ហើយបាននិយាយពាក្យនេះនឹងនាងវិសាខាមិគារមាតាថា

វោច នត្ថយ្យេ អារាមេ ភិក្ខូ សុញ្ញោ អារាមោតិ ។ អថខោ វិសាខាយ មិគារមាតុយា បណ្ឌិតាយ វិយត្តាយ មេធាវិនិយា ឯតទហោសិ និស្សំសយំ ខោ អយ្យា គត្តានិ សីតីករិត្វា កល្លកាយា ចីវរានិ គហេត្វា យថាវិហារំ បវិដ្ឋា សាយំ ពាលា មញ្ញិត្ថ នត្ថិ អារាមេ ភិក្ខូ សុញ្ញោ អារាមោតិ ។ បុន ទាសិំ អាណាបេសិ គច្ឆ ជេ អារាមំ គន្ត្វា កាលំ អារោចេហិ កាលោ ភន្តេ និដ្ឋិតំ ភត្តន្តិ ។ អថខោ ភគវា ភិក្ខូ អាមន្តេសិ សន្ទហថ ភិក្ខវេ បត្តចីវរំ កាលោ ភត្តស្សាតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សេយ្យថាបិ នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ ជេតវនេ អន្តរហិតោ វិសាខាយ មិគារមាតុយា កោដ្ឋកេ បាតុរហោសិ ។ និសីទិ ភគវា បញ្ញត្តេ អាសនេ សទ្ធិំ ភិក្ខុសង្ឃេន ។ អថខោ



បពិត្រអ្នកម្ចាស់ ក្នុងអារាមគ្មានភិក្ខុសោះ មានតែអារាមទទេ ។ លំដាប់នោះ នាងវិសាខាមិគារមាតាជាបណ្ឌិត ជាស្រីឈ្លាស ជាអ្នកប្រាជ្ញ បានរិះគិតយ៉ាងនេះថា ច្បាស់ណាស់លោកម្ចាស់ទាំងឡាយជ្រួតទឹកឲ្យត្រជាក់ខ្លួនមានកាយជាស្រួល ហើយនាំយកចីវរទាំងឡាយចូលទៅកាន់លំនៅដូចដែល ទាសីនេះជាស្រីល្ងង់សំគាល់ថាក្នុងអារាមគ្មានពួកភិក្ខុសោះ មានតែអារាមទទេ ។ នាងវិសាខាក៏បង្គាប់ទាសីទៀតថា នែនាង ឯងចូរទៅកាន់អារាមហើយក្រាបបង្គំទូលភត្តកាលថា បពិត្រព្រះអង្គដ៏ចំរើន កាលនេះជាកាលគួរហើយ ភត្តក៏សម្រេចហើយ ។ គ្រានោះ ព្រះមានព្រះភាគត្រាស់ហៅពួកភិក្ខុមកថា ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយរៀបចំបាត្រនិងចីវរចុះ (ព្រោះ)ដល់ពេលចង្ហាន់ហើយ ។ ភិក្ខុទាំងនោះទទួលស្តាប់ព្រះបន្ទូលរបស់ព្រះមានព្រះភាគដោយពាក្យថា ព្រះករុណាព្រះអង្គ ។ លុះវេលាព្រឹកឡើង ព្រះមានព្រះភាគទ្រង់ស្លៀកស្បង់ប្រដាប់ដោយបាត្រនិងចីវរហើយទ្រង់បាត់ព្រះអង្គអំពីវត្តជេតពនទៅប្រាកដទៀបក្លោងទ្វាររបស់នាងវិសាខាមិគារមាតា (ដោយឆាប់ហ័ស) ប្រៀបដូចបុរសមានកំឡាំងលាដៃដែលខ្ទប់ចូល ឬបត់ដៃដែលលាចេញ ។ ព្រះមានព្រះភាគទ្រង់គង់លើអាសនៈដែលគេតាក់តែងថ្វាយជាមួយនឹងព្រះភិក្ខុសង្ឃ ។ គ្រានោះ

វិសាខា មិគារមាតា អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ តថាគតស្ស មហិទ្ធិកតា មហានុភាវតា យត្រ ហិ នាម ជណ្ណុកមត្តេសុបិ ឱឃេសុ វត្តមានេសុ[1] កដិមត្តេសុបិ ឱឃេសុ វត្តមានេសុ ន ហិ នាម ឯកភិក្ខុស្សបិ បាទា វា ចីវរានិ វា អល្លានិ ភវិស្សន្តីតិ ហដ្ឋា ឧទគ្គា ពុទ្ធប្បមុខំ ភិក្ខុសង្ឃំ បណីតេន ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេត្វា សម្បវារេត្វា ភគវន្តំ ភុត្តាវឹ ឱនីតបត្តបាណឹ ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នា ខោ វិសាខា មិគារមាតា ភគវន្តំ ឯតទវោច អដ្ឋាហំ ភន្តេ ភគវន្តំ វរានិ យាចាមីតិ ។ អតិក្កន្តវរា ខោ វិសាខេ តថាគតាតិ ។ យានិ ច ភន្តេ កប្បិយានិ យានិ ច អនវជ្ជានីតិ ។ វទេហិ វិសាខេតិ ។ ឥច្ឆាមហំ ភន្តេ សង្ឃស្ស យាវជីវំ វស្សិកសាដិកំ ទាតុំ អាគន្តុកភត្តំ ទាតុំ

១ ម. បវត្តមានេសុ ។



នាងវិសាខាមិគារមាតាគិតថា អើហ្ន៎ (ហេតុនេះ) អស្ចារ្យពេកណាស់ អើហ្ន៎ (ហេតុនេះ) ចំឡែកពេកណាស់ ព្រះតថាគតមានឫទ្ធិច្រើន មានអានុភាពច្រើន ព្រោះថាទឹកជំនន់ប្រមាណត្រឹមជង្គង់ខ្លះ ត្រឹមចង្កេះខ្លះកំពុងហូរទៅ ។ សូម្បីតែជើងឬចីវររបស់ភិក្ខុ ១ អង្គក៏គ្មានទទឹកឡើយ ហើយក៏មានចិត្តរីករាយខ្ពស់ឡើង ប្រគេនភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានដោយខាទនីយៈនឹងភោជនីយាហារដ៏ឧត្តមដោយដៃរបស់ខ្លួន ត្រាតែព្រះភិក្ខុសង្ឃ ហាមឃាត់ លុះតែណាត់ដឹងថា ព្រះមានព្រះភាគឆាន់ហើយ ដាក់ព្រះហស្តចុះចាកបាត្រហើយ នាងក៏អង្គុយនៅក្នុងទីសមគួរ ។ នាងវិសាខាមិគារមាតាអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គសូមពរ ៨ ប្រការអំពីព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលនាងវិសាខា ធម្មតាព្រះតថាគតទាំងឡាយគ្មានពរទេ ។ នាងវិសាខាក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គសូមតែពរណាដែលគួរ និងពរណាដែលឥតទោស ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលនាងវិសាខា ចូរនាងនិយាយមកចុះ ។ នាងវិសាខាក៏ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គចង់ប្រគេនវស្សិកសាដក (សំពត់សម្រាប់ងូតទឹកភ្លៀង) ចង់ប្រគេនអាគន្តុកភត្ត (ភត្តដែលប្រគេនដល់ភិក្ខុទើបមកដល់ថ្មី)

គមិកភត្តំ ទាតុំ គិលានភត្តំ ទាតុំ គិលានុបដ្ឋាកភត្តំ ទាតុំ គិលានភេសជ្ជំ ទាតុំ ធុវយាគុំ ទាតុំ ភិក្ខុនីសង្ឃស្ស ឧទកសាដិកំ ទាតុន្តិ ។ កឹ បន ត្វំ វិសាខេ អត្ថវសំ សម្បស្សមានា តថាគតំ អដ្ឋ វរានិ យាចសីតិ ។ ឥធាហំ ភន្តេ ទាសឹ អាណាបេសឹ គច្ឆ ជេ អារាមំ គន្ត្វា កាលំ អារោចេហិ កាលោ ភន្តេ និដ្ឋិតំ ភត្តន្តិ អថខោ សា ភន្តេ ទាសី អារាមំ គន្ត្វា អទ្ទស ភិក្ខូ ឱវដ្ឋិកាយ នគ្គា កាយំ ឱវស្សាបេន្តេ ទិស្វាន នត្ថិ អារាមេ ភិក្ខូ អាជីវកា កាយំ ឱវស្សាបេន្តីតិ យេនាហំ តេនុបសង្កមិ ឧបសង្កមិត្វា មំ ឯតទវោច នត្ថយ្យេ អារាមេ ភិក្ខូ



ចង់ប្រគេនគមិកភត្ត (ភត្តដែលប្រគេនដល់ភិក្ខុអ្នកមានដំណើរទៅ) ចង់ប្រគេនគិលានភត្ត (ភត្តដែលប្រគេនដល់ភិក្ខុមានជម្ងឺ) ចង់ប្រគេនគិលានុបដ្ឋាកភត្ត (ភត្តដែលប្រគេនដល់ភិក្ខុអ្នកបម្រើជម្ងឺ) ចង់ប្រគេនគិលានភេសជ្ជៈ (ថ្នាំដែលប្រគេនដល់ភិក្ខុមានជម្ងឺ) ចង់ប្រគេនធុវយាគូ (បបរដែលត្រូវប្រគេនជានិច្ច) ដល់ព្រះសង្ឃ និងចង់ប្រគេនឧទកសាដក (សំពត់សម្រាប់ងូតទឹក) ដល់ភិក្ខុនីសង្ឃដរាបដល់អស់ជីវិត ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលនាងវិសាខា នាងឃើញអំណាចប្រយោជន៍ដូចម្តេច បានជាសូមពរ ៨ ប្រការអំពីតថាគត ។ នាងវិសាខាក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ក្នុងវេលាព្រឹកមិញនេះ ខ្ញុំព្រះអង្គបង្គាប់ទាសីថា នែនាង នាងចូរទៅកាន់អារាម ហើយក្រាបបង្គំទូលកាលថា បពិត្រព្រះអង្គដ៏ចំរើន កាលនេះជាកាលគួរហើយ ភត្តក៏សម្រេចហើយ បពិត្រព្រះអង្គដ៏ចំរើន ទាសីនោះក៏ទៅកាន់អារាម ហើយបានឃើញពួកភិក្ខុ ដាក់ចីវរចេញហើយ កំពុងតាំងខ្លួនទទួលទឹកភ្លៀងដោយកាយ លុះឃើញហើយក៏សំគាល់ថា ក្នុងអារាមគ្មានពួកភិក្ខុទេ មានសុទ្ធតែពួកអាជីវក កំពុងទទួលទឹកភ្លៀងដោយកាយ រួចក៏ត្រឡប់ចូលមកកាន់សំណាក់ខ្ញុំព្រះអង្គ លុះចូលមកដល់ហើយ បាននិយាយពាក្យនេះនឹងខ្ញុំព្រះអង្គថា បពិត្រអ្នកម្ចាស់ ក្នុងអារាមគ្មានពួកភិក្ខុទេ

...អសុចិ ភន្តេ នគ្គិយំ ជេគុច្ឆំ បដិក្កូលំ ឥមាហំ ភន្តេ អត្ថវសំ សម្បស្សមានា ឥច្ឆាមិ សង្ឃស្ស យាវជីវំ វស្សិកសាដិកំ ទាតុំ ។ បុន ចបរំ ភន្តេ អាគន្តុកោ ភិក្ខុ ន វីថិកុសលោ ន គោចរកុសលោ កិលន្តោ បិណ្ឌាយ ចរតិ សោ មេ អាគន្តុកភត្តំ ភុញ្ជិត្វា វីថិកុសលោ គោចរកុសលោ អកិលន្តោ បិណ្ឌាយ ចរិស្សតិ ឥមាហំ ភន្តេ អត្ថវសំ សម្បស្សមានា ឥច្ឆាមិ សង្ឃស្ស យាវជីវំ អាគន្តុកភត្តំ ទាតុំ ។ បុន ចបរំ ភន្តេ គមិកោ ភិក្ខុ អត្តនោ ភត្តំ បរិយេសមានោ សត្ថា វា វិហាយិស្សតិ យត្ថ វា គន្តុកាមោ ភវិស្សតិ តត្ថ វិកាលេ ឧបគច្ឆិស្សតិ កិលន្តោ អទ្ធានំ គមិស្សតិ សោ មេ គមិកភត្តំ ភុញ្ជិត្វា សត្ថា ន វិហាយិស្សតិ យត្ថ វា គន្តុកាមោ ភវិស្សតិ តត្ថ វិកាលេ ន ឧបគច្ឆិស្សតិ អកិលន្តោ អទ្ធានំ គមិស្សតិ ឥមាហំ ភន្តេ អត្ថវសំ សម្បស្សមានា ឥច្ឆាមិ សង្ឃស្ស យាវជីវំ...



មានសុទ្ធតែពួកអាជីវកទទឹកភ្លៀងជំរះកាយ បពិត្រព្រះអង្គដ៏ចំរើន កិរិយាអាក្រាតកាយមិនស្អាត គួរខ្ពើមរអើម បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គឃើញអំណាចប្រយោជន៍នេះហើយ បានជាចង់ប្រគេនវស្សិកសាដិកដល់សង្ឃអស់មួយជីវិត ។ បពិត្រព្រះអង្គដ៏ចំរើន ការដទៃមានតទៅទៀត ភិក្ខុជាអាគន្តុកៈ (ទើបមកដល់ថ្មី) មិនទាន់ឈ្លាសក្នុងផ្លូវ មិនទាន់ឈ្លាសក្នុងគោចរ លំបាកនឹងត្រាច់ទៅបិណ្ឌបាត ភិក្ខុជាអាគន្តុកៈនោះនឹងឆាន់អាគន្តុកភត្តរបស់ខ្ញុំព្រះអង្គហើយ មុខជានឹងឈ្លាសក្នុងផ្លូវ ឈ្លាសក្នុងគោចរ មិនលំបាកនឹងត្រាច់ទៅបិណ្ឌបាត បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គឃើញអំណាចប្រយោជន៍នេះហើយ បានជាចង់ប្រគេនអាគន្តុកភត្ត ដល់សង្ឃអស់មួយជីវិត ។ បពិត្រព្រះអង្គដ៏ចំរើន ការដទៃមានតទៅទៀត ភិក្ខុអ្នកដំណើរ បើរវល់តែស្វែងរកភត្តរបស់ខ្លួន មុខជានឹងបែកខ្ញែកចាកគ្នីគ្នា ឬបើចង់ទៅកាន់លំនៅក្នុងប្រទេសណា នឹងចូលទៅដល់ប្រទេសនោះខុសកាលវេលា នាំឲ្យលំបាកនឹងទៅកាន់ផ្លូវឆ្ងាយ កាលបើភិក្ខុអ្នកដំណើរនោះបានឆាន់គមិកភត្តរបស់ខ្ញុំព្រះអង្គហើយ មុខជាមិនបែកខ្ញែកចាកគ្នីគ្នាទេ ឬបើចង់ទៅកាន់លំនៅក្នុងប្រទេសណា នឹងបានចូលទៅដល់ប្រទេសនោះមិនខុសកាលវេលា ឃើញជាមិនលំបាកនឹងទៅកាន់ផ្លូវឆ្ងាយ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គឃើញអំណាចប្រយោជន៍នេះហើយ បានជាចង់

គិលានភត្តំ ទាតុំ ។ បុន ចបរំ ភន្តេ គិលានស្ស ភិក្ខុនោ សប្បាយានិ ភោជនានិ អលភន្តស្ស អាពាធោ វា អភិវឌ្ឍិស្សតិ កាលកិរិយា វា ភវិស្សតិ តស្ស មេ គិលានភត្តំ ភុត្តស្ស អាពាធោ នាភិវឌ្ឍិស្សតិ កាលកិរិយា ន ភវិស្សតិ ឥមាហំ ភន្តេ អត្ថវសំ សម្បស្សមានា ឥច្ឆាមិ សង្ឃស្ស យាវជីវំ គិលានភត្តំ ទាតុំ ។ បុន ចបរំ ភន្តេ គិលានុបដ្ឋាកោ ភិក្ខុ អត្តនោ ភត្តំ បរិយេសមានោ គិលានស្ស ឧស្សូរេ ភត្តំ នីហរិស្សតិ ភត្តច្ឆេទំ ករិស្សតិ សោ មេ គិលានុបដ្ឋាកភត្តំ ភុញ្ជិត្វា គិលានស្ស កាលេន ភត្តំ នីហរិស្សតិ ភត្តច្ឆេទំ ន ករិស្សតិ ឥមាហំ ភន្តេ អត្ថវសំ សម្បស្សមានា ឥច្ឆាមិ សង្ឃស្ស យាវជីវំ គិលានុបដ្ឋាកភត្តំ ទាតុំ ។ បុន ចបរំ ភន្តេ គិលានស្ស ភិក្ខុនោ សប្បាយានិ ភេសជ្ជានិ អលភន្តស្ស អាពាធោ វា អភិវឌ្ឍិស្សតិ កាលកិរិយា វា ភវិស្សតិ តស្ស មេ គិលានភេសជ្ជំ បរិភុត្តស្ស អាពាធោ នាភិវឌ្ឍិស្សតិ កាលកិរិយា



ប្រគេនគិលានភត្តដល់សង្ឃអស់មួយជីវិត ។ បពិត្រព្រះអង្គដ៏ចំរើន ពរដទៃមានតទៅទៀត ភិក្ខុមានជម្ងឺកាលបើមិនបានភោជនជាទីសប្បាយទេ អាពាធក៏នឹងរីកចំរើនឡើង ឬនឹងធ្វើមរណកាលទៅក៏សឹងមាន កាលបើភិក្ខុមានជម្ងឺនោះបានឆាន់គិលានភត្តរបស់ខ្ញុំព្រះអង្គហើយ អាពាធក៏មិនចំរើនឡើង មរណកាលក៏គ្មាន បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គឃើញអំណាចប្រយោជន៍នេះហើយ បានជាចង់ប្រគេនគិលានភត្តដល់ព្រះសង្ឃអស់មួយជីវិត ។ បពិត្រព្រះអង្គដ៏ចំរើន ពរដទៃមានតទៅទៀត ភិក្ខុអ្នកបម្រើភិក្ខុឈឺកាលបើរវល់តែនឹងស្វែងរកភត្តសម្រាប់ខ្លួនហើយ មុខជានឹងនាំយកភត្តមកឲ្យភិក្ខុឈឺក្នុងវេលាថ្ងៃពេក ហើយក៏នឹងធ្វើភិក្ខុឈឺឲ្យដាច់បង្អត់ បើភិក្ខុអ្នកបម្រើភិក្ខុឈឺនោះបានឆាន់គិលានុបដ្ឋាកភត្តរបស់ខ្ញុំព្រះអង្គហើយនឹងបាននាំយកភត្តមកឲ្យភិក្ខុឈឺក្នុងកាលគួរ ហើយនឹងមិនធ្វើភិក្ខុឈឺឲ្យដាច់បង្អត់ឡើយ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គឃើញអំណាចប្រយោជន៍នេះហើយ បានជាចង់ប្រគេនគិលានុបដ្ឋាកភត្តដល់សង្ឃអស់មួយជីវិត ។ បពិត្រព្រះអង្គដ៏ចំរើន ពរដទៃមានតទៅទៀត ភិក្ខុមានជម្ងឺកាលបើមិនបានភេសជ្ជៈជាទីសប្បាយទេ អាពាធក៏នឹងរីកចំរើនឡើង ឬនឹងធ្វើមរណកាលទៅក៏សឹងមាន កាលបើភិក្ខុមានជម្ងឺនោះបានឆាន់គិលានភេសជ្ជៈរបស់ខ្ញុំព្រះអង្គហើយ អាពាធក៏មិនចំរើនឡើង មិនធ្វើមរណកាលទេ

ភវិស្សតិ ឥមាហំ ភន្តេ អត្ថវសំ សម្បស្សមានា ឥច្ឆាមិ សង្ឃស្ស យាវជីវំ គិលានភេសជ្ជំ ទាតុំ ។ បុន ចបរំ ភន្តេ ភគវតា អន្ធកវិន្ទេ ទសានិសំសេ សម្បស្សមានេន យាគុ អនុញ្ញាតា ត្យាហំ ភន្តេ អានិសំសេ សម្បស្សមានា ឥច្ឆាមិ សង្ឃស្ស យាវជីវំ ធុវយាគុំ ទាតុំ ។ ឥធ ភន្តេ ភិក្ខុនិយោ អចិរវតិយា នទិយា វេសិយាហិ សទ្ធឹ នគ្គា ឯកតិត្ថេ នហាយន្តិ តា ភន្តេ វេសិយា ភិក្ខុនិយោ ឧប្បណ្ឌេសុំ កិន្នុ ខោ នាម តុម្ហាកំ អយ្យេ ទហរានំ ព្រហ្មចរិយំ ចិណ្ណេន ននុ នាម កាមា បរិភុញ្ជិតព្វា យទា ជិណ្ណា ភវិស្សថ តទា ព្រហ្មចរិយំ ចរិស្សថ ឯវំ តុម្ហាកំ ឧភោ អត្ថា[១] បរិគ្គហិតា ភវិស្សន្តីតិ តា ភន្តេ ភិក្ខុនិយោ វេសិយាហិ ឧប្បណ្ឌិយមានា មង្កុ អហេសុំ អសុចិ ភន្តេ មាតុគាមស្ស នគ្គិយំ

១ ឧភោ អន្តាតិបិ បាឋោ ។



បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គឃើញអំណាចប្រយោជន៍នេះហើយបាន ជាចង់ប្រគេនគិលានភេសជ្ជៈដល់សង្ឃអស់មួយជីវិត ។ បពិត្រព្រះអង្គ ដ៏ចំរើន ភាពដទៃមានតទៅទៀត ព្រះដ៏មានព្រះភាគទ្រង់យល់ឃើញ អានិសង្សទាំង ១០ យ៉ាងហើយ បានជាទ្រង់អនុញ្ញាតបបរក្នុងអន្ធកវិន្ទ ប្រទេស បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានឃើញអានិសង្សទាំងនោះ ដែរ បានជាចង់ប្រគេនធុវយាគូដល់សង្ឃអស់មួយជីវិត ។ បពិត្រព្រះអង្គ ដ៏ចំរើន ពួកភិក្ខុនីក្នុងសាសនានេះ មានកាយអាក្រាតងូតទឹកក្នុងកំពង់មួយ ជាមួយនឹងពួកស្រីពេស្យា (ស្រីមាស) ក្នុងស្ទឹងអចិរវតី បពិត្រព្រះអង្គដ៏ចំរើន ពួកស្រីពេស្យាទាំងនោះនាំគ្នាចំអកចំអន់ឲ្យពួកភិក្ខុនីថា បពិត្រលោកម្ចាស់ លោកម្ចាស់ទាំងឡាយនៅក្មេងនៅឡើយ ប្រព្រឹត្តព្រហ្មចរិយធម៌ធ្វើអ្វី លោកម្ចាស់ទាំងឡាយនៅបរិភោគកាមគុណសិន បើលោកម្ចាស់ ទាំងឡាយចាស់ជរាវេលាណា សឹមនាំគ្នាប្រព្រឹត្តព្រហ្មចរិយធម៌វេលានោះ ចុះ យ៉ាងនេះទើបឈ្មោះថាលោកម្ចាស់ទាំងឡាយបានកាន់ប្រយោជន៍ ទាំងពីរទុក បពិត្រព្រះអង្គដ៏ចំរើន កាលបើពួកស្រីពេស្យានិយាយចំអក ចំអន់ ( ឲ្យថ្កោះ ) ហើយ ភិក្ខុនីទាំងនោះក៏មានសេចក្តីអៀនខ្មាស បពិត្រព្រះអង្គដ៏ចំរើន មាតុគ្រាមមានកាយអាក្រាត ជាការមិនស្អាត ។

ជេគុច្ឆំ បដិកូលំ ឥមាហំ ភន្តេ អត្ថវសំ សម្បស្សមានា ឥច្ឆាមិ ភិក្ខុនីសង្ឃស្ស យាវជីវំ ឧទកសាដិកំ ទាតុំ ។ កឹ បន ត្វំ វិសាខេ អត្ថវសំ សម្បស្សមានា តថាគតំ អដ្ឋ វរានិ យាចសីតិ ។ ឥធ ភន្តេ ទិសាសុ វស្សំ វុដ្ឋា ភិក្ខូ សាវត្ថឹ អាគច្ឆន្តិ ភគវន្តំ ទស្សនាយ តេ ភគវន្តំ ឧបសង្កមិត្វា បុច្ឆន្តិ ឥត្ថន្នាមោ ភន្តេ ភិក្ខុ កាលកតោ តស្ស កា គតិ កោ អភិសម្បរាយោតិ តំ ភគវា ព្យាករិស្សតិ សោតាបត្តិផលេ វា សកទាគាមិផលេ វា អនាគាមិផលេ វា អរហត្តេ(១) វា ត្យាហំ ឧបសង្កមិត្វា បុច្ឆិស្សាមិ អាគតបុព្វា នុ ខោ ភន្តេ តេន អយ្យេន សាវត្ថីតិ សចេ មេ វក្ខន្តិ អាគតបុព្វា តេន ភិក្ខុនា សាវត្ថីតិ និដ្ឋមេត្ថ គច្ឆិស្សាមិ និស្សំសយំ បរិភុត្តា តេន អយ្យេន វស្សិកសាដិកា វា

១ ម. អរហត្តផលេ ។



គួរខ្ពើមរអើមពេកណាស់ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គឃើញអំណាចប្រយោជន៍នេះហើយ ទើបចង់ប្រគេនឧទកសាដិកៈ(១)ដល់ភិក្ខុនីសង្ឃអស់មួយជីវិត ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលនាងវិសាខា ចុះនាងយល់ឃើញអានិសង្សដូចម្តេច ទើបនាងសូមពរ ៨ ប្រការអំពីតថាគត ។ នាងវិសាខាក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ក្នុងភិក្ខុទាំងឡាយក្នុងសាសនានេះនៅចាំវស្សាក្នុងទិសទាំងឡាយ លុះចេញវស្សាហើយនឹងមកកាន់ក្រុងសាវត្ថីដើម្បីគាល់ព្រះអង្គ ភិក្ខុទាំងនោះនឹងចូលមកគាល់ព្រះអង្គហើយសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុឈ្មោះនេះធ្វើមរណកាលហើយ ភិក្ខុនោះមានគតិដូចម្តេច មានបរលោកដូចម្តេច ព្រះដ៏មានព្រះភាគមុខជានឹងទ្រង់ព្យាករណ៍បញ្ហានោះក្នុងសោតាបត្តិផលក្តី សកទាគាមិផលក្តី អនាគាមិផលក្តី អរហត្តផលក្តី ខ្ញុំព្រះអង្គនឹងចូលទៅរកភិក្ខុទាំងនោះហើយនឹងសួរថា បពិត្រលោកម្ចាស់ទាំងឡាយដ៏ចំរើន លោកម្ចាស់នោះធ្លាប់និមន្តមកក្រុងសាវត្ថីដែរឬ បើប្រសិនជាពួកភិក្ខុនិយាយប្រាប់ខ្ញុំព្រះអង្គថា ភិក្ខុនោះធ្លាប់មកក្រុងសាវត្ថីដែរ ខ្ញុំព្រះអង្គនឹងដល់នូវសេចក្តីចូលចិត្តក្នុងរឿងនេះថា ច្បាស់ជាលោកម្ចាស់នោះធ្លាប់បានបរិភោគសំពត់វស្សិកសាដិកក្តី

១ សំពត់សម្រាប់ងូតទឹក ឬដែលហៅថា[illegible] ។

អាគន្តុកភត្តំ វា គមិកភត្តំ វា គិលានភត្តំ វា គិលានុបដ្ឋាកភត្តំ វា គិលានភេសជ្ជំ វា ធុវយាគុ វាតិ តស្សា មេ តទនុស្សរន្តិយា បាមុជ្ជំ ជាយិស្សតិ បមុទិតាយ បីតិ ជាយិស្សតិ បីតិមនាយ កាយោ បស្សម្ភិស្សតិ បស្សទ្ធកាយា សុខំ វេទយិស្សាមិ សុខិនិយា ចិត្តំ សមាធិយិស្សតិ សា មេ ភវិស្សតិ ឥន្ទ្រិយភាវនា ពលភាវនា ពោជ្ឈង្គភាវនា ឥមាហំ ភន្តេ អានិសំសំ សម្បស្សមានា តថាគតំ អដ្ឋ វរានិ យាចាមីតិ ។ សាធុ សាធុ វិសាខេ សាធុ ខោ ត្វំ វិសាខេ ឥមំ អានិសំសំ សម្បស្សមានា តថាគតំ អដ្ឋ វរានិ យាចសិ អនុជានាមិ តេ វិសាខេ អដ្ឋ វរានីតិ ។ អថខោ ភគវា វិសាខំ មិគារមាតរំ ឥមាហិ គាថាហិ អនុមោទិ



អាគន្តុកភត្ត គមិកភត្ត គិលានភត្ត គិលានុបដ្ឋាកភត្ត គិលានភេសជ្ជៈភត្ត ធុវយាគុភត្ត (ទំនាន) កាលខ្ញុំព្រះអង្គនោះរលឹកតាមនោះរឿយៗ ហើយសេចក្តីត្រេកអរនឹងកើតឡើង កាលបើសេចក្តីត្រេកអរមានកើតឡើងហើយ ចិត្តប្រកបដោយបីតិនឹងកើតឡើង កាលបើចិត្តប្រកបដោយបីតិកើតឡើងហើយ កាយក៏នឹងស្ងប់រម្ងាប់ លុះខ្ញុំព្រះអង្គមានកាយស្ងប់រម្ងាប់ហើយ នឹងទទួលសេចក្តីសុខ កាលបើខ្ញុំព្រះអង្គបានទទួលសេចក្តីសុខហើយ ចិត្តក៏នឹងដំកល់មាំ ឥន្ទ្រិយភាវនា ពលភាវនា ពោជ្ឈង្គភាវនានោះ នឹងមានដល់ខ្ញុំព្រះអង្គ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានឃើញអានិសង្សនេះហើយ ទើបបានជាសូមពរ ៨ ប្រការអំពីព្រះតថាគត ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលនាងវិសាខា ល្អហើយ ល្អហើយ ម្នាលនាងវិសាខា នាងបានឃើញអានិសង្សនេះ ហើយបានសូមពរ ៨ ប្រការអំពីតថាគតជាការប្រពៃពេក ម្នាលនាងវិសាខា (យើងខ្ញុំ) តថាគតអនុញ្ញាតពរ ៨ ប្រការដល់នាង ។ គ្រានោះ ព្រះមានព្រះភាគទ្រង់អនុមោទនាចំពោះនាងវិសាខាដោយគាថាទាំងឡាយនេះថា

(៦០) យា អន្នបានំ ទទតិ បមោទិតា
សីលូបបន្នា សុគតស្ស សាវិកា
ទានំ ទទាតិ អភិភុយ្យ មច្ឆរំ
សោវគ្គិកំ សោកនុទំ សុខាវហំ
ទិព្វំ ពលំ សា លភតេ ច អាយុំ
អាគម្ម មគ្គំ វិរជំ អនង្គណំ
សា បុញ្ញកាមា សុខិនី អនាមយា
សគ្គម្ហិ កាយម្ហិ ចិរំ បមោទតីតិ ។

(៦១) អថខោ ភគវា វិសាខំ មិគារមាតរំ ឥមាហិ គាថាហិ អនុមោទិត្វា ឧដ្ឋាយាសនា បក្កាមិ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ វស្សិកសាដិកំ អាគន្តុកភត្តំ គមិកភត្តំ គិលានភត្តំ គិលានុបដ្ឋាកភត្តំ គិលានភេសជ្ជំ ធុវយាគុំ ភិក្ខុនីសង្ឃស្ស ឧទកសាដិកន្តិ ។

វិសាខាភាណវារំ និដ្ឋិតំ ។



(៦០) ស្រីណាជាអ្នកឲ្យបាយនិងទឹក មានចិត្តរីករាយ មានសីលបរិបូណ៌ ជាសាវិការបស់ព្រះសុគត គ្របសង្កត់នូវសេចក្តីកំណាញ់បាន ហើយឲ្យនូវទាន ស្រីនោះឯង តែងបាននូវផល គឺការឲ្យទានដ៏ប្រសើរដោយប្រពៃ មានសួគ៌ជាដើម បានបន្ទោបង់នូវសេចក្តីសោក ដ៏នាំមកនូវសេចក្តីសុខ មានកំឡាំងនិងអាយុជាទិព្វ ស្រីនោះជាស្រីមានសេចក្តីប្រាថ្នានូវបុណ្យ មានសេចក្តីសុខ ឥតមានទុក្ខ តែងរីករាយក្នុងស្ថានសួគ៌អស់កាលជាអង្វែង ព្រោះអាស្រ័យនូវមគ្គចិត្ត ដ៏ប្រាសចាកធូលី មិនមានកិលេស (គ្រោះឯង) ។

(៦១) គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់អនុមោទនាចំពោះនាងវិសាខាមិគារមាតា ដោយគាថាទាំងនេះហើយ ទ្រង់ក្រោកចាកអាសនៈ យាងចៀសចេញទៅ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះមានព្រះភាគទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកក្នុងវេលានោះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតវស្សិកសាដិកៈ អាគន្តុកភត្ត គមិកភត្ត គិលានភត្ត គិលានុបដ្ឋាកភត្ត គិលានភេសជ្ជៈ ធុវយាគូ និងឧទកសាដិកៈដល់ភិក្ខុនីសង្ឃ ។

ចប់ វិសាខាភាណវារៈ ។

[៦៦] តេន ខោ បន សមយេន ភិក្ខូ បណីតានិ ភោជនានិ ភុញ្ជិត្វា មុដ្ឋស្សតី អសម្បជានា និទ្ទំ ឱក្កមន្តិ ។ តេសំ មុដ្ឋស្សតីនំ អសម្បជានានំ និទ្ទំ ឱក្កមន្តានំ សុបិនន្តេន អសុចិ មុច្ចតិ សេនាសនំ អសុចិនា មក្ខិយតិ ។ អថខោ ភគវា អាយស្មតា អានន្ទេន បច្ឆាសមណេន សេនាសនចារិកំ អាហិណ្ឌន្តោ អទ្ទស សេនាសនំ អសុចិនា មក្ខិតំ ទិស្វាន អាយស្មន្តំ អានន្ទំ អាមន្តេសិ កិមេតំ អានន្ទ សេនាសនំ មក្ខិតន្តិ ។ ឯតរហិ ភន្តេ ភិក្ខូ បណីតានិ ភោជនានិ ភុញ្ជិត្វា មុដ្ឋស្សតី អសម្បជានា និទ្ទំ ឱក្កមន្តិ តេសំ មុដ្ឋស្សតីនំ អសម្បជានានំ និទ្ទំ ឱក្កមន្តានំ សុបិនន្តេន អសុចិ មុច្ចតិ តយិទំ ភគវា សេនាសនំ អសុចិនា មក្ខិតន្តិ ។ ឯវមេតំ អានន្ទ ឯវមេតំ អានន្ទ មុច្ចតិ ហិ អានន្ទ តេសំ មុដ្ឋស្សតីនំ អសម្បជានានំ និទ្ទំ ឱក្កមន្តានំ សុបិនន្តេន អសុចិ យេ តេ អានន្ទ ភិក្ខូ ឧបដ្ឋិតស្សតី សម្បជានា និទ្ទំ ឱក្កមន្តិ តេសំ អសុចិ ន មុច្ចតិ យេបិ តេ អានន្ទ បុថុជ្ជនា



[៦៦] សម័យនោះឯង ភិក្ខុបានឆាន់ភោជនទាំងឡាយដ៏ឧត្តម ក៏ភ្លេចស្មារតីមិនដឹងខ្លួន សិងលក់ទៅ ។ កាលបើភិក្ខុទាំងនោះភ្លេចស្មារតីមិនដឹងខ្លួន ក៏ដេកសិងលក់ អសុចិក៏ឃ្លាតចេញដោយយល់សប្តិ សេនាសនៈក៏ប្រឡាក់ដោយអសុចិ ។ កាលនោះ ព្រះមានព្រះភាគមានព្រះអានន្ទដ៏មានអាយុជាបច្ឆាសមណៈ(១) ទ្រង់ត្រាច់ទៅកាន់សេនាសនចារិក ហើយទតឃើញសេនាសនៈប្រឡាក់ដោយអសុចិ លុះទតឃើញ ហើយត្រាស់ហៅព្រះអានន្ទដ៏មានអាយុមកថា ម្នាលអានន្ទ សេនាសនៈនេះប្រឡាក់ដោយវត្ថុអ្វី ។ អានន្ទក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ក្នុងកាលនេះ ភិក្ខុបានឆាន់ភោជនទាំងឡាយដ៏ឧត្តម ក៏ភ្លេចស្មារតីមិនដឹងខ្លួនហើយសិងលក់ទៅ កាលបើភិក្ខុទាំងនោះ ភ្លេចស្មារតីមិនដឹងខ្លួន ក៏ដេកសិងលក់ អសុចិក៏ឃ្លាតចេញដោយយល់សប្តិ បពិត្រព្រះមានព្រះភាគ សេនាសនៈនោះប្រឡាក់ដោយអសុចិ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ យ៉ាងហ្នឹងហើយ ម្នាលអានន្ទ យ៉ាងហ្នឹងហើយ ម្នាលអានន្ទ ព្រោះភិក្ខុទាំងនោះភ្លេចស្មារតីមិនដឹងខ្លួន បានដេកលក់ទៅ អសុចិឃ្លាតចេញដោយយល់សប្តិ ម្នាលអានន្ទ ភិក្ខុណាដំកល់ស្មារតីខ្ជាប់ដឹងខ្លួនហើយដេកលក់ទៅ អសុចិរបស់ភិក្ខុទាំងនោះមិនឃ្លាតចេញទេ ម្នាលអានន្ទ មួយទៀត ភិក្ខុណាជាបុថុជ្ជនមែន

១ សមណៈដើរតាមក្រោយព្រះអង្គ ។

កាមេសុ វីតរាគា តេសំ អសុចិ ន មុច្ចតិ អដ្ឋា-
នមេតំ ភិក្ខវេ អនវកាសោ យំ អរហតោ អសុចិ
មុច្ចេយ្យាតិ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ
បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ សន្តាយំ
ភិក្ខវេ អានន្ទេន បច្ឆាសមណេន សេនាសនចារិកំ អា-
ហិណ្ឌន្តោ អទ្ទសំ សេនាសនំ អសុចិនា មក្ខិតំ ទិស្វាន
អានន្ទំ អាមន្តេសិ កិមេតំ អានន្ទ សេនាសនំ មក្ខិ-
តន្តិ ឯតរហិ ភន្តេ ភិក្ខូ បណីតានិ ភោជនានិ ភុញ្ជន្តិ
មុដ្ឋស្សតី អសម្បជានា និទ្ទំ ឱក្កមន្តិ តេសំ មុដ្ឋស្ស-
តីនំ អសម្បជានានំ និទ្ទំ ឱក្កមន្តានំ សុបិនន្តេន
អសុចិ មុច្ចតិ ឥយិទំ ភគវា សេនាសនំ អសុចិនា
មក្ខិតន្តិ ។ ឯវមេតំ អានន្ទ ឯវមេតំ អានន្ទ មុច្ចតិ ហិ
អានន្ទ តេសំ មុដ្ឋស្សតីនំ អសម្បជានានំ និទ្ទំ ឱក្ក-
មន្តានំ សុបិនន្តេន អសុចិ យេ តេ អានន្ទ ភិក្ខូ
ឧបដ្ឋិតស្សតី សម្បជានា និទ្ទំ ឱក្កមន្តិ តេសំ អសុចិ
ន មុច្ចតិ យេបិ តេ អានន្ទ បុថុជ្ជនា កាមេសុ វីតរាគា



តែគ្មានតម្រេក ក្នុងកាមទាំងឡាយ អសុចិរបស់ពួកភិក្ខុនោះក៏មិនឃ្លាត
ចេញដែរ ម្នាលអានន្ទ ឯភាពដែលអសុចិរបស់ព្រះអរហន្តឃ្លាតចេញនេះ
មិនសមហេតុ មិនសមកាលទេ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏
មានព្រះភាគទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅពួកភិក្ខុមកក្នុងវេលានោះថា
ម្នាលភិក្ខុទាំងឡាយ តថាគតមានអានន្ទជាបច្ឆាសមណៈ ដើរទៅកាន់
សេនាសនចារិកក្នុងទីនេះ បានឃើញសេនាសនៈប្រឡាក់ដោយអសុចិ
លុះឃើញហើយក៏ហៅអានន្ទមកសួរថា ម្នាលអានន្ទ សេនាសនៈនេះ
ប្រឡាក់ដោយវត្ថុអ្វី អានន្ទឆ្លើយថា បពិត្រព្រះអង្គដ៏ចំរើន ក្នុងវេលា
នេះ ពួកភិក្ខុបានឆាន់ភោជនទាំងឡាយដ៏ឆ្ងាញ់ ហើយភ្លេចស្មារតីមិនដឹងខ្លួន
ដេកលក់ទៅ កាលបើភិក្ខុទាំងនោះភ្លេចស្មារតីមិនដឹងខ្លួន ក៏ចូលដេកលក់
អសុចិក៏ឃ្លាតចេញដោយយល់សប្តិ បពិត្រព្រះមានព្រះភាគ សេនាសនៈ
នោះប្រឡាក់ដោយអសុចិ តថាគតក៏ពោលថា ម្នាលអានន្ទ យ៉ាងហ្នឹង
ហើយ ម្នាលអានន្ទ យ៉ាងហ្នឹងហើយ ម្នាលអានន្ទ ព្រោះតែភិក្ខុទាំងនោះ
ភ្លេចស្មារតីមិនដឹងខ្លួន បានជាដេកលក់ទៅ អសុចិឃ្លាតចេញដោយយល់
សប្តិ ម្នាលអានន្ទ ភិក្ខុទាំងឡាយណា ដំកល់ស្មារតីខ្ជាប់ដឹងខ្លួនហើយ
ដេកលក់ទៅ អសុចិរបស់ភិក្ខុទាំងនោះមិនឃ្លាតចេញទេ ម្នាលអានន្ទ ម្យ៉ាង
ទៀត ពួកភិក្ខុណាជាបុថុជ្ជនមែន តែគ្មានតម្រេក ក្នុងកាមទាំងឡាយ

តេសំ អសុចិ ន មុច្ចតិ អដ្ឋានមេតំ អានន្ទ អនវកាសោ យំ អរហតោ អសុចិ មុច្ចេយ្យាតិ ។ បញ្ចិមេ ភិក្ខវេ អាទីនវា មុដ្ឋស្សតិស្ស អសម្បជានស្ស និទ្ទំ ឱក្កមតោ ទុក្ខំ សុបតិ ទុក្ខំ បដិពុជ្ឈតិ បាបកំ សុបិនំ បស្សតិ ទេវតា ន រក្ខន្តិ អសុចិ មុច្ចតិ ឥមេ ខោ ភិក្ខវេ បញ្ច អាទីនវា មុដ្ឋស្សតិស្ស អសម្បជានស្ស និទ្ទំ ឱក្កមតោ ។ បញ្ចិមេ ភិក្ខវេ អានិសំសា ឧបដ្ឋិតស្សតិស្ស សម្បជានស្ស និទ្ទំ ឱក្កមតោ សុខំ សុបតិ សុខំ បដិពុជ្ឈតិ ន បាបកំ សុបិនំ បស្សតិ ទេវតា រក្ខន្តិ អសុចិ ន មុច្ចតិ ឥមេ ខោ ភិក្ខវេ បញ្ច អានិសំសា ឧបដ្ឋិតស្សតិស្ស សម្បជានស្ស និទ្ទំ ឱក្កមតោ ។ អនុជានាមិ ភិក្ខវេ កាយគុត្តិយា ចីវរគុត្តិយា សេនាសនគុត្តិយា និសីទនន្តិ ។ តេន ខោ បន សមយេន អតិខុទ្ទកំ និសីទនំ ន សព្វំ សេនាសនំ គោបេតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ យាវមហន្តំ បច្ចត្ថរណំ អាកង្ខតិ តាវមហន្តំ បច្ចត្ថរណំ កាតុន្តិ ។



អសុចិរបស់ពួកភិក្ខុនោះក៏មិនឃ្លាតចេញដែរ ម្នាលអានន្ទ ឯពាក្យថា អសុចិរបស់ព្រះអរហន្តឃ្លាតចេញនេះ មិនសមហេតុ មិនសមផលទេ ។ ម្នាលភិក្ខុទាំងឡាយ ទោសរបស់ភិក្ខុភ្លេចស្មារតីមិនដឹងខ្លួនដេកលក់ទៅនេះ មាន៥ យ៉ាង គឺ ភិក្ខុនោះលក់លំបាក ១ ភ្ញាក់លំបាក ១ ឃើញសុបិនអាក្រក់ ១ ទេវតាមិនរក្សា ១ អសុចិឃ្លាតចេញ ១ ម្នាលភិក្ខុទាំងឡាយ ទោសរបស់ភិក្ខុភ្លេចស្មារតីមិនដឹងខ្លួនហើយដេកលក់ទៅមាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សរបស់ភិក្ខុដែលបានដំកល់ស្មារតីខ្ជាប់ដឹងខ្លួនហើយដេកលក់ទៅនេះមាន៥យ៉ាង គឺ ភិក្ខុនោះដេកលក់ស្រួល ១ ភ្ញាក់ស្រួល ១ មិនឃើញសុបិនអាក្រក់ ១ ទេវតារក្សា ១ អសុចិមិនឃ្លាតចេញ ១ ម្នាលភិក្ខុទាំងឡាយ អានិសង្សរបស់ភិក្ខុបានដំកល់ស្មារតីខ្ជាប់ដឹងខ្លួនហើយដេកលក់ទៅមាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនិសីទនៈ (សំពត់ក្រាលអង្គុយ) ដើម្បីរក្សាកាយ ដើម្បីរក្សាចីវរ ដើម្បីរក្សាសេនាសនៈ ។ សម័យនោះឯង និសីទនៈតូចពេក រក្សាសេនាសនៈទាំងអស់មិនបាន ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុចង់បានកម្រាលធំប៉ុន្មាន តថាគតអនុញ្ញាតឲ្យធ្វើធំប៉ុណ្ណោះ ។

(៦៣) តេន ខោ បន សមយេន អាយស្មតោ អានន្ទស្ស ឧបជ្ឈាយស្ស អាយស្មតោ ពេលដ្ឋសីសស្ស ថុល្លកច្ឆាពាធោ ហោតិ ។ តស្ស លសិកាយ ចីវរានិ កាយេ លគ្គន្តិ ។ តានិ ភិក្ខូ ឧទកេន តេមេត្វា តេមេត្វា អបកឌ្ឍន្តិ ។ អទ្ទសា ខោ ភគវា សេនាសនចារិកំ អាហិណ្ឌន្តោ តេ ភិក្ខូ តានិ ចីវរានិ ឧទកេន តេមេត្វា តេមេត្វា អបកឌ្ឍន្តេ ទិស្វាន យេន តេ ភិក្ខូ តេនុបសង្កមិ ឧបសង្កមិត្វា តេ ភិក្ខូ ឯតទវោច កឹ ឥមស្ស ភិក្ខវេ ភិក្ខុនោ អាពាធោតិ ។ ឥមស្ស ភន្តេ អាយស្មតោ ថុល្លកច្ឆាពាធោ លសិកាយ ចីវរានិ កាយេ លគ្គន្តិ តានិ មយំ ឧទកេន តេមេត្វា តេមេត្វា អបកឌ្ឍាមាតិ ។ អថ ខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ យស្ស កណ្ឌុ វា បិឡកា វា អស្សាវោ វា ថុល្លកច្ឆុ វា អាពាធោ កណ្ឌុបដិច្ឆាទិន្តិ ។

(៦៤) អថ ខោ វិសាខា មិគារមាតា មុខបុញ្ឆនចោឡំ អាទាយ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា



(៦៣) សម័យនោះឯង ព្រះវេលដ្ឋសីសៈដ៏មានអាយុជាឧបជ្ឈាយ៍របស់ព្រះអានន្ទដ៏មានអាយុកើតឫសដំ ។ ចីវរទាំងឡាយរបស់ព្រះវេលដ្ឋសីសៈនោះជាប់ស្អិតនឹងកាយដោយទឹករងើល ។ ពួកភិក្ខុយកទឹកទៅផ្សើមចីវរទាំងនោះឲ្យជោគហើយទើបបកចេញបាន ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ពុទ្ធដំណើរទៅកាន់សេនាសនចារិក ទ្រង់ទតឃើញភិក្ខុទាំងនោះកំពុងយកទឹកទៅផ្សើមចីវរទាំងនោះឲ្យជោគហើយបកចេញ ក៏ទ្រង់ពុទ្ធដំណើរចូលទៅកាន់សំណាក់ភិក្ខុទាំងនោះ លុះចូលទៅដល់ហើយទ្រង់មានព្រះពុទ្ធដីកានេះនឹងភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះមានអាពាធដូចម្តេច ។ ភិក្ខុទាំងនោះក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន លោកដ៏មានអាយុនេះកើតឫសដំ ចីវរទាំងឡាយជាប់ស្អិតនឹងកាយដោយទឹករងើល យើងខ្ញុំទាំងឡាយយកទឹកមកផ្សើមចីវរទាំងនោះឲ្យជោគហើយបកចេញ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅពួកភិក្ខុមកក្នុងវេលានោះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាមានអាពាធ គឺកមរមាស់ក្តី ឫសតូចក្តី ទឹករងៃក្តី ឫសធំក្តី តថាគតអនុញ្ញាតសំពត់សម្រាប់គ្របកម ( ជារបើម ) ដល់ភិក្ខុនោះ ។

(៦៤) គ្រានោះ នាងវិសាខាមិគារមាតានាំយកសំពត់សម្រាប់ជូតមុខចូលទៅកាន់សំណាក់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ

ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និ-
សិន្នា ខោ វិសាខា មិគារមាតា ភគវន្តំ ឯតទវោច
បដិគ្គណ្ហាតុ មេ ភន្តេ មុខបុញ្ឆនចោលំ យំ មម អស្ស
ទីឃរត្តំ ហិតាយ សុខាយាតិ ។ បដិគ្គហេសិ ភគវា
មុខបុញ្ឆនចោលំ ។ អថខោ ភគវា វិសាខំ មិគារមាតរំ
ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេ-
ជេសិ សម្បហំសេសិ ។ អថខោ វិសាខា មិគារមាតា
ភគវតា ធម្មិយា កថាយ សន្ទស្សិតា សមាទបិតា
សមុត្តេជិតា សម្បហំសិតា ឧដ្ឋាយាសនា ភគវន្តំ អ-
ភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ ភគវា
ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ
អាមន្តេសិ អនុជានាមិ ភិក្ខវេ មុខបុញ្ឆនចោលកន្តិ ។

(២៩) តេន ខោ បន សមយេន រោជោ មល្លោ
អាយស្មតោ អានន្ទស្ស សហាយោ ហោតិ ។ រោជស្ស
មល្លស្ស ខោមបិលោតិកា អាយស្មតោ អានន្ទស្ស
ហត្ថេ និក្ខិត្តា ហោតិ ។ អាយស្មតោ ច អានន្ទស្ស



ថ្វាយបង្គំព្រះដ៏មានព្រះភាគរួចអង្គុយក្នុងទីសមគួរ ។ លុះនាងវិសាខាមិគា-
រមាតាអង្គុយក្នុងទីសមគួរហើយក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា
បពិត្រព្រះអង្គដ៏ចំរើន សូមព្រះអង្គទ្រង់ទទួលសំពត់សម្រាប់ជូតមុខរបស់
ខ្ញុំព្រះអង្គ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខអស់កាលជាអង្វែង ។
ព្រះដ៏មានព្រះភាគក៏បានទទួលសំពត់សម្រាប់ជូតមុខ(នោះ) ។ វេលានោះ
ព្រះដ៏មានព្រះភាគទ្រង់ពន្យល់នាងវិសាខាមិគារមាតាឲ្យឃើញច្បាស់ ឲ្យ
កាន់យកតាម ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ។ ឯនាងវិសាខា
មិគារមាតាកាលដែលព្រះដ៏មានព្រះភាគទ្រង់ពន្យល់ឲ្យឃើញច្បាស់ ឲ្យ
កាន់យកតាម ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏ក្រោក
ចាកអាសនៈថ្វាយបង្គំព្រះមានព្រះភាគធ្វើប្រទក្សិណ(១) ហើយចៀស
ចេញទៅ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើ
ធម្មីកថាហើយត្រាស់ហៅពួកភិក្ខុមកក្នុងពេលនោះថា ម្នាលភិក្ខុទាំងឡាយ
តថាគតអនុញ្ញាតសំពត់សម្រាប់ជូតមុខ ។

(២៩) សម័យនោះឯង មល្លក្សត្រឈ្មោះរោជៈជាសំឡាញ់របស់ព្រះ
អានន្ទដ៏មានអាយុ ។ មល្លក្សត្រឈ្មោះរោជៈ (នោះ) បានទុកដាក់សំពត់
សម្បកឈើក្នុងដៃនៃព្រះអានន្ទដ៏មានអាយុ ។ ឯព្រះអានន្ទដ៏មានអាយុ

១ ដើរវៀលខាងស្តាំ ។

ខោមបិលោតិកាយ អត្ថោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតស្ស វិស្សាសំ គហេតុំ សន្ទិដ្ឋោ ច ហោតិ សម្ភត្តោ ច អាលបិតោ ច ជីវតិ ច ជានាតិ ច គហិតេ មេ អត្តមនោ ភវិស្សតីតិ អនុជានាមិ ភិក្ខវេ ឥមេហិ បញ្ចហង្គេហិ សមន្នាគតស្ស វិស្សាសំ គហេតុន្តិ ។

(៦៦) តេន ខោ បន សមយេន ភិក្ខូនំ បរិបុណ្ណំ ហោតិ តិចីវរំ អត្ថោ ច ហោតិ បរិស្សាវនេហិបិ ថវិកាហិបិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ បរិក្ខារចោឡកន្តិ[១] ។ អថខោ ភិក្ខូនំ ឯតទហោសិ យានិ តានិ ភគវតា អនុញ្ញាតានិ តិចីវរន្តិ វា វស្សិកសាដិកាតិ វា និសីទនន្តិ វា បច្ចត្ថរណន្តិ វា កណ្ឌុបដិច្ឆាទីតិ វា មុខបុញ្ឆនចោឡកន្តិ[២] វា បរិក្ខារចោឡកន្តិ វា

១ ម. បរិក្ខារចោឡកន្តិ ។ ២ មុខបុញ្ឆនចោឡកន្តិ ។



ត្រូវការនឹងសំពត់សម្បកឈើ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុកាន់យកដោយសេចក្ដីស្និទ្ធស្នាលរបស់មិត្រប្រកបដោយអង្គ ៥ គឺ មិត្រដែលគ្រាន់តែបានឃើញគ្នាម្ដងមួយគ្រា ១ មិត្រដែលស្និទ្ធស្នាលនឹងគ្នាជាមួយ ១ មិត្រដែលបាននិយាយបើកឱកាសគ្នាតាមត្រូវការ ១ មិត្រនោះមានជីវិតរស់នៅ ១ ភិក្ខុដឹងថា បើគាត់អញកាន់យកវត្ថុណាមួយហើយ មិត្រនោះមានសេចក្ដីត្រេកអរ ១ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុកាន់យកដោយសេចក្ដីស្និទ្ធស្នាលរបស់មិត្រប្រកបដោយអង្គទាំង ៥ នេះបាន ។

(៦៦) សម័យនោះឯង ពួកភិក្ខុមានត្រៃចីវរបរិបូណ៌ហើយ តែត្រូវការដោយសំពត់តម្រងទឹកផង ដោយថង់បាត្រផង ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសំពត់បរិក្ខារ ។ គ្រានោះ ពួកភិក្ខុមានសេចក្ដីត្រិះរិះដូច្នេះថា សំពត់ទាំងឡាយណា គឺ ត្រៃចីវរក្ដី សំពត់សម្រាប់ងូតទឹកភ្លៀងក្ដី សំពត់សម្រាប់ក្រាលអង្គុយក្ដី សំពត់ក្រាលក្ដី សំពត់សម្រាប់គ្របកមក្ដី សំពត់សម្រាប់ជូតមុខក្ដី សំពត់បរិក្ខារក្ដី ដែលព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតហើយ សំពត់ទាំងអស់នោះតើយើង

សព្វានិ តានិ អធិដ្ឋាតព្វានិ នុ ខោ ឧទាហុ វិកប្បេតព្វានីតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ តិចីវរំ អធិដ្ឋាតុំ ន វិកប្បេតុំ វស្សិកសាដិកំ វស្សានំ ចាតុម្មាសំ អធិដ្ឋាតុំ តតោ បរំ វិកប្បេតុំ និសីទនំ អធិដ្ឋាតុំ ន វិកប្បេតុំ បច្ចត្ថរណំ អធិដ្ឋាតុំ ន វិកប្បេតុំ កណ្ឌុប្បដិច្ឆាទឹ យាវ អាពាធា អធិដ្ឋាតុំ តតោ បរំ វិកប្បេតុំ មុខបុញ្ឆនចោឡំ អធិដ្ឋាតុំ ន វិកប្បេតុំ បរិក្ខារចោឡំ អធិដ្ឋាតុំ ន វិកប្បេតុន្តិ ។ អថ ខោ ភិក្ខូនំ ឯតទហោសិ កិត្តកំ នុ ខោ បច្ឆិមំ ចីវរំ វិកប្បេតព្វន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ អាយាមេន អដ្ឋង្គុលំ សុគតង្គុលេន ចតុរង្គុលវិត្ថតំ បច្ឆិមំ ចីវរំ វិកប្បេតុន្តិ ។ តេន ខោ បន សមយេន អាយស្មតោ មហាកស្សបស្ស បំសុកូលកតោ[១] គរុកោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ សុត្តលូខំ កាតុន្តិ ។

១ ម. បំសុកូលកតោ ។



ត្រូវអធិដ្ឋានឬត្រូវវិកប្បទុក ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុអធិដ្ឋាននូវត្រៃចីវរមិនឲ្យវិកប្បទេ ឲ្យអធិដ្ឋាននូវសំពត់សម្រាប់ងូតទឹកភ្លៀងអស់ ៤ ខែនៃរដូវភ្លៀង តាំងពីកាល ៤ ខែនោះទៅត្រូវវិកប្បទុក ឲ្យអធិដ្ឋាននូវសំពត់សម្រាប់ក្រាលអង្គុយមិនឲ្យវិកប្បទេ ឲ្យអធិដ្ឋាននូវសំពត់កម្រាលមិនឲ្យវិកប្បទេ ឲ្យអធិដ្ឋាននូវសំពត់សម្រាប់បិទកមរមាស់ត្រឹមមានអាពាធ រួចអំពីអាពាធនោះទៅត្រូវវិកប្បទុក ឲ្យអធិដ្ឋាននូវសំពត់សម្រាប់ជូតមុខមិនឲ្យវិកប្បទេ ឲ្យអធិដ្ឋាននូវសំពត់បរិក្ខារមិនឲ្យវិកប្បទេ ។ គ្រានោះ ពួកភិក្ខុមានសេចក្ដីត្រិះរិះដូច្នេះថា ចុះចីវរយ៉ាងតូចបំផុតត្រឹមប៉ុន្មាន ដែលត្រូវវិកប្បបាន ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុវិកប្បចីវរយ៉ាងតូចបំផុតបណ្ដោយត្រឹម ៨ ធ្នាប់ ទទឹងត្រឹម ៤ ធ្នាប់ ដោយធ្នាប់ព្រះសុគត ។ សម័យនោះឯង ព្រះមហាកស្សបដ៏មានអាយុជាអ្នកធ្វើសេចក្ដីនោះធ្ងន់ព្រោះសំពត់បង្សុកូល[១] ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុធ្វើចីវរឲ្យសៅហ្មងដោយដេស ( គឺដេរប៉ះដោយដេស ) ។

១ អដ្ឋកថា ថា ព្រះមហាកស្សបលោកជាអ្នកគោរពក្នុងការរើសយកបង្សុកូលក្នុងសែ្បកដែលក្រាស់ ។

វិកណ្ណោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ វិកណ្ណំ ឧទ្ធរិតុន្តិ ។ សុត្តា ឱកិរិយន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ អនុវាតំ បរិភណ្ឌំ អារោបេតុន្តិ ។ តេន ខោ បន សមយេន សង្ឃាដិយា បត្តា លុជ្ជន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ អដ្ឋបទកំ កាតុន្តិ ។

[២៧] តេន ខោ បន សមយេន អញ្ញតរស្ស ភិក្ខុនោ ចីវរេ កយិរមានេ សព្វំ ឆិន្នកំ នប្បហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ទ្វេ ឆិន្នកានិ ឯកំ អច្ឆិន្នកន្តិ ។ ទ្វេ ឆិន្នកានិ ឯកំ អច្ឆិន្នកំ នប្បហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។



ចីវរមានជាយមិនស្មើគ្នា ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុកាត់ចីវរដែលមានជាយមិនស្មើគ្នា (គឺកាត់ជាយដែលវែងជាងគេចេញ) ។ សរសៃអំបោះទាំងឡាយក៏រវើករសាត់ចេញ ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុលើករឡូង (គឺបះ) អនុវាតទទឹងនិងអនុវាតចំពោះ ។ សម័យនោះឯង ជាយទាំងឡាយនៃសង្ឃាដិដាច់ចេញពីគ្នា ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុធ្វើឲ្យមានសណ្ឋានដូចជាក្រឡាចត្រង្គ ។

[២៧] សម័យនោះឯង ពួកភិក្ខុកំពុងធ្វើចីវរ (ឲ្យ) ភិក្ខុ១រូប លុះភិក្ខុកាត់ចីវរទាំងអស់ទៅ ហើយក៏មិនគ្រប់គ្រាន់ ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យកាត់តែចីវរពីរ ចីវរមួយមិនបាច់កាត់ក៏បាន ។ ដល់កាត់ចីវរពីរ ចីវរមួយមិនកាត់ក៏នៅតែមិនគ្រប់គ្រាន់ ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។

អនុជានាមិ ភិក្ខវេ ទ្វេ អច្ឆិន្នកានិ ឯកំ ឆិន្នកន្តិ ។ ទ្វេ អច្ឆិន្នកានិ ឯកំ ឆិន្នកំ នប្បហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ អន្វាធិកំបិ អារោបេតុំ ។ ន ច ភិក្ខវេ សព្វំ អច្ឆិន្នកំ ធារេតព្វំ យោ ធារេយ្យ អាបត្តិ ទុក្កដស្សាតិ ។

[៦៨] តេន ខោ បន សមយេន អញ្ញតរស្ស ភិក្ខុនោ ពហុំ ចីវរំ ឧប្បន្នំ ហោតិ ។ សោ ច តំ ចីវរំ មាតាបិតូនំ ទាតុកាមោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ មាតាបិតរោតិ ខោ ភិក្ខវេ ទទមានេ កឹ វទេយ្យាម[១] អនុជានាមិ ភិក្ខវេ មាតាបិតូនំ ទាតុំ ។ ន ច ភិក្ខវេ សទ្ធាទេយ្យំ វិនិបាតេតព្វំ យោ វិនិបាតេយ្យ អាបត្តិ ទុក្កដស្សាតិ ។

[៦៩] តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ អន្ធវនេ ចីវរំ និក្ខិបិត្វា សន្តរុត្តរេន គាមំ បិណ្ឌាយ បាវិសិ ។ ចោរា តំ ចីវរំ អវហរឹសុ ។ សោ ភិក្ខុ

១ វទេយ្យុម ។



ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតចីវរពីរមិនបាច់កាត់ នឹងកាត់តែចីវរមួយបាន ។ ភិក្ខុមិនកាត់ចីវរពីរ កាត់តែចីវរមួយ ក៏នៅតែមិនគ្រប់គ្រាន់ទៀត ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុលើកឡើង (តំណ) សំពត់អាគន្តុកៈ (សំពត់ថ្មី) ទៀត ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទ្រទ្រង់ចីវរដែលមិនកាត់ទាំងអស់នោះទេ ភិក្ខុណាទ្រទ្រង់ (ស្លៀកដណ្តប់) ត្រូវអាបត្តិទុក្កដ ។

(៦៨) សម័យនោះឯង ចីវរកើតឡើងជាច្រើនដល់ភិក្ខុមួយរូប ។ ឯភិក្ខុនោះចង់ឲ្យចីវរនោះដល់មាតានិងបិតា ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុឲ្យចីវរដោយគិតថាមាតានិងបិតាដូច្នេះ តថាគតនឹងថាដូចម្តេចបាន ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឲ្យចីវរដល់មាតានិងបិតាបាន ម្នាលភិក្ខុទាំងឡាយ តែថាភិក្ខុមិនត្រូវធ្វើទានដែលគេឲ្យដោយសទ្ធាឲ្យធ្លាក់ចុះឡើយ ភិក្ខុណាឲ្យធ្លាក់ចុះ ត្រូវអាបត្តិទុក្កដ ។

(៦៩) សម័យនោះឯង ភិក្ខុមួយរូបទុកចីវរក្នុងអន្ធវន (ព្រៃងងឹត) ហើយមានតែស្បង់និងឧត្តរាសង្គៈ (ចីពរ) ចូលទៅស្រុកដើម្បីបិណ្ឌបាត ។ ពួកចោរក៏លួចយកចីវរនោះទៅ ។ ភិក្ខុនោះមានសំពត់កាក្រក់

ទុព្ពលោ ហោតិ លូខចីវរោ ។ ភិក្ខូ ឯវមាហំសុ កិស្ស ត្វំ ទុព្ពលោ លូខចីវរោសិ ។ ឥធាហំ អាវុសោ អន្តរេ ចីវរំ និក្ខិបិត្វា សន្តរុត្តរេន គាមំ បិណ្ឌាយ បាវិសិំ ចោរា តំ ចីវរំ អវហរិំសុ តេនាហំ ទុព្ពលោ លូខចីវរោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ សន្តរុត្តរេន គាមោ បវិសិតព្វោ យោ បវិសេយ្យ អាបត្តិ ទុក្កដស្សាតិ ។ តេន ខោ បន សមយេន អាយស្មា អានន្ទោ អសតិយា សន្តរុត្តរេន គាមំ បិណ្ឌាយ បាវិសិ ។ ភិក្ខូ អាយស្មន្តំ អានន្ទំ ឯតទវោចុំ ននុ អាវុសោ អានន្ទ ភគវតា បញ្ញត្តំ ន សន្តរុត្តរេន គាមោ បវិសិតព្វោតិ កិស្ស ត្វំ អាវុសោ សន្តរុត្តរេន គាមំ បវិដ្ឋោតិ ។ សច្ចំ អាវុសោ ភគវតា បញ្ញត្តំ ន សន្តរុត្តរេន គាមោ បវិសិតព្វោតិ អបិចាហំ អាវុសោ អសតិយា បវិដ្ឋោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។



មានចីវរសៅហ្មង ។ ពួកភិក្ខុនិយាយយ៉ាងនេះថា ម្នាលអាវុសោ ហេតុអ្វីអ្នកមានសំពត់សាក្រក់ មានចីវរសៅហ្មង ។ ភិក្ខុនោះនិយាយនឹងភិក្ខុទាំងនោះថា ម្នាលអាវុសោ ខ្ញុំទុកចីវរក្នុងទីនេះ ហើយមានតែស្បង់នឹងឧត្តរាសង្គៈចូលទៅស្រុកដើម្បីបិណ្ឌបាត ពួកចោរលួចយកចីវរនោះទៅ ព្រោះហេតុនោះ បានជាខ្ញុំមានសំពត់សាក្រក់ មានចីវរសៅហ្មង ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានតែស្បង់នឹងឧត្តរាសង្គៈមិនត្រូវចូលទៅស្រុកទេ ភិក្ខុណាចូលទៅ ត្រូវអាបត្តិទុក្កដ ។ សម័យនោះឯង ព្រះអានន្ទដ៏មានអាយុ មានតែស្បង់នឹងឧត្តរាសង្គៈចូលទៅស្រុកដើម្បីបិណ្ឌបាតដោយភ្លេចស្មារតី ។ ពួកភិក្ខុបាននិយាយយ៉ាងនេះនឹងព្រះអានន្ទដ៏មានអាយុថា ម្នាលអាវុសោអានន្ទ ព្រះមានព្រះភាគទ្រង់បញ្ញត្តថា ភិក្ខុមានតែស្បង់នឹងឧត្តរាសង្គៈ មិនត្រូវចូលទៅស្រុក មិនមែនទេឬ ម្នាលអាវុសោ ចុះហេតុអ្វីបានជាអ្នកមានតែស្បង់នឹងឧត្តរាសង្គៈចូលទៅស្រុក ។ ព្រះអានន្ទឆ្លើយថា ម្នាលអាវុសោ ព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ភិក្ខុមានតែស្បង់នឹងឧត្តរាសង្គៈមិនត្រូវចូលទៅស្រុកទេ ពិតមែនហើយ ម្នាលអាវុសោ តែថាខ្ញុំចូលទៅហើយដោយភ្លេចស្មារតី ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។

អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ បញ្ចិមេ ភិក្ខវេ បច្ចយា សង្ឃាដិយា និក្ខេបាយ គិលានោ វា ហោតិ វស្សិកសង្កេតំ វា ហោតិ នទីបារំ គន្តុំ វា ហោតិ អគ្គឡគុត្តិវិហារោ វា ហោតិ អត្ថតកឋិនំ វា ហោតិ ឥមេ ខោ ភិក្ខវេ បញ្ច បច្ចយា សង្ឃាដិយា និក្ខេបាយ ។ បញ្ចិមេ ភិក្ខវេ បច្ចយា ឧត្តរាសង្គស្ស និក្ខេបាយ គិលានោ វា ហោតិ វស្សិកសង្កេតំ វា ហោតិ នទីបារំ គន្តុំ វា ហោតិ អគ្គឡគុត្តិវិហារោ វា ហោតិ អត្ថតកឋិនំ វា ហោតិ ឥមេ ខោ ភិក្ខវេ បញ្ច បច្ចយា ឧត្តរាសង្គស្ស និក្ខេបាយ ។ បញ្ចិមេ ភិក្ខវេ បច្ចយា អន្តរវាសកស្ស និក្ខេបាយ គិលានោ វា ហោតិ វស្សិកសង្កេតំ វា ហោតិ នទីបារំ គន្តុំ វា ហោតិ អគ្គឡគុត្តិវិហារោ វា ហោតិ អត្ថតកឋិនំ វា ហោតិ ឥមេ ខោ ភិក្ខវេ បញ្ច បច្ចយា អន្តរវាសកស្ស និក្ខេបាយ ។ បញ្ចិមេ ភិក្ខវេ បច្ចយា វស្សិកសាដិកាយ និក្ខេបាយ គិលានោ វា ហោតិ និស្សីមំ គន្តុំ វា ហោតិ នទីបារំ គន្តុំ វា ហោតិ



ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកក្នុងពេលនោះថា ម្នាលភិក្ខុទាំងឡាយ ឯហេតុគួរទុកដាក់សង្ឃាដិមាន ៥ យ៉ាង គឺ ភិក្ខុមានជម្ងឺ ១ មានកំណត់ដោយរដូវភ្លៀង ៤ ខែ ១ ភិក្ខុទៅកាន់ត្រើយស្ទឹងខាងនាយ ១ វិហារមានការរក្សាទ្វារមាំមួន ១ ភិក្ខុបានក្រាលកឋិនហើយ ១ ម្នាលភិក្ខុទាំងឡាយ ហេតុទាំង ៥ យ៉ាងនេះឯង ជាហេតុគួរទុកដាក់សង្ឃាដិបាន ។ ម្នាលភិក្ខុទាំងឡាយ ឯហេតុគួរទុកដាក់សំពត់ឧត្តរាសង្គៈមាន ៥ យ៉ាង គឺ ភិក្ខុមានជម្ងឺ ១ មានកំណត់ដោយរដូវភ្លៀង ៤ ខែ ១ ភិក្ខុទៅកាន់ត្រើយស្ទឹងខាងនាយ ១ វិហារមានការរក្សាទ្វារមាំមួន ១ ភិក្ខុបានក្រាលកឋិនហើយ ១ ម្នាលភិក្ខុទាំងឡាយ ហេតុទាំង ៥ យ៉ាងនេះឯង ជាហេតុគួរទុកដាក់សំពត់ឧត្តរាសង្គៈបាន ។ ម្នាលភិក្ខុទាំងឡាយ ឯហេតុគួរទុកដាក់ស្បង់មាន ៥ យ៉ាង គឺ ភិក្ខុមានជម្ងឺ ១ មានកំណត់ដោយរដូវភ្លៀង ៤ ខែ ១ ភិក្ខុទៅកាន់ត្រើយស្ទឹងខាងនាយ ១ វិហារមានការរក្សាទ្វារមាំមួន ១ ភិក្ខុបានក្រាលកឋិនហើយ ១ ម្នាលភិក្ខុទាំងឡាយ ហេតុទាំង ៥ យ៉ាងនេះឯង ជាហេតុគួរទុកដាក់ស្បង់បាន ។ ម្នាលភិក្ខុទាំងឡាយ ឯហេតុគួរទុកដាក់សំពត់សម្រាប់ស្លៀកទឹកភ្លៀងមាន ៥ យ៉ាង គឺ ភិក្ខុមានជម្ងឺ ១ ភិក្ខុទៅកាន់ទីឥតមានសីមា ១ ភិក្ខុទៅកាន់ត្រើយស្ទឹងខាងនាយ ១

អគ្គឡគុត្តិវិហារោ វា ហោតិ វស្សិកសាដិកា អកតា វា ហោតិ វិប្បកតា វា ។ ឥមេ ខោ ភិក្ខវេ បញ្ច បច្ចយា វស្សិកសាដិកាយ និក្ខេបាយាតិ ។

(៧០) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ ឯកកោ វស្សំ វសិ ។ តត្ថ មនុស្សា សង្ឃស្ស ទេមាតិ ចីវរានិ អទំសុ ។ អថ ខោ តស្ស ភិក្ខុនោ ឯតទហោសិ ភគវតា បញ្ញត្តំ ចតុវគ្គោ បច្ឆិមោ សង្ឃោតិ អហញ្ចម្ហិ ឯកកោ ឥមេ ច មនុស្សា សង្ឃស្ស ទេមាតិ ចីវរានិ អទំសុ យន្នូនាហំ ឥមានិ សង្ឃិកានិ ចីវរានិ សាវត្ថឹ ហរេយ្យន្តិ ។ អថ ខោ សោ ភិក្ខុ តានិ ចីវរានិ អាទាយ សាវត្ថឹ គន្ត្វា ភគវតោ ឯតមត្ថំ អារោចេសិ ។ តុយ្ហេវ ភិក្ខុ តានិ ចីវរានិ យាវ កឋិនស្ស ឧព្ភារាយាតិ ។ ឥធ បន ភិក្ខវេ ភិក្ខុ ឯកកោ វស្សំ វសតិ ។ តត្ថ មនុស្សា សង្ឃស្ស ទេមាតិ ចីវរានិ ទេន្តិ ។ អនុជានាមិ ភិក្ខវេ តស្សេវ តានិ ចីវរានិ យាវ កឋិនស្ស ឧព្ភារាយាតិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ



វិហារមានការរក្សាទ្វារទាំងផ្ទះ ១ សំពត់ស្រោចទឹកភ្លៀងដែលភិក្ខុមិនទាន់បានធ្វើ ឬធ្វើមិនទាន់ស្រេច ១ ម្នាលភិក្ខុទាំងឡាយ ហេតុទាំង ៥ យ៉ាងនេះឯង ជាហេតុគួរទុកដាក់សំពត់ស្រោចទឹកភ្លៀងបាន ។

(៧០) សម័យនោះឯង ភិក្ខុមួយរូបនៅចាំវស្សាតែម្នាក់ឯង ។ មនុស្សទាំងឡាយនាំគ្នាប្រគេនចីវរក្នុងវិហារនោះដោយពាក្យថា យើងទាំងឡាយប្រគេនចំពោះសង្ឃ ។ ភិក្ខុនោះក៏មានសេចក្តីត្រិះរិះដូច្នេះថា ព្រះដ៏មានព្រះភាគបានបញ្ញត្តថា ដែលហៅថាសង្ឃ យ៉ាងតិចបំផុតត្រឹមភិក្ខុ ៤ រូប ចំណែកអាត្មាអញតែម្នាក់ឯង ក៏មនុស្សទាំងនេះប្រគេនចីវរទាំងឡាយ ដោយពាក្យថា យើងទាំងឡាយប្រគេនចំពោះសង្ឃ បើដូច្នោះ មានតែអាត្មាអញនាំយកចីវររបស់សង្ឃទាំងនេះទៅកាន់ក្រុងសាវត្ថី ។ ភិក្ខុនោះក៏នាំយកចីវរទាំងនោះទៅកាន់ក្រុងសាវត្ថី ហើយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ ចីវរទាំងនោះជាចីវររបស់អ្នកតែម្នាក់ ត្រឹមកឋិនដោះ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើភិក្ខុក្នុងសាសនានេះនៅចាំវស្សាតែម្នាក់ឯង ។ ក្នុងទីនោះ ពួកមនុស្សប្រគេនចីវរទាំងឡាយដោយពាក្យថា យើងទាំងឡាយប្រគេនចីវរចំពោះសង្ឃ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតចីវរទាំងនោះដល់ភិក្ខុនោះឯង កំណត់ត្រឹមកឋិនដោះ ។ សម័យនោះឯង ភិក្ខុមួយរូប

ឧតុកាលំ ឯកោ វសិ ។ តត្ថ មនុស្សា សង្ឃស្ស ទេមាតិ ចីវរានិ អទំសុ ។ អថខោ តស្ស ភិក្ខុនោ ឯត-ទហោសិ ភគវតា បញ្ញត្តំ ចតុវគ្គោ បច្ឆិមោ សង្ឃោតិ អហញ្ចម្ហិ ឯកកោ ឥមេ ច មនុស្សា សង្ឃស្ស ទេមាតិ ចីវរានិ អទំសុ យន្នូនាហំ ឥមានិ សង្ឃិកានិ ចីវរានិ សាវត្ថឹ ហរេយ្យន្តិ ។ អថខោ សោ ភិក្ខុ តានិ ចីវរានិ អាទាយ សាវត្ថឹ គន្ត្វា ភិក្ខូនំ ឯតមត្ថំ អារោចេសិ ។ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ សម្មុខីភូតេន សង្ឃេន ភាជេតុំ ។ ឥធ បន ភិក្ខវេ ភិក្ខុ ឧតុកាលំ ឯកោ វសតិ ។ តត្ថ មនុស្សា សង្ឃស្ស ទេមាតិ ចីវរានិ ទេន្តិ ។ អនុជានាមិ ភិក្ខវេ តេន ភិក្ខុនា តានិ ចីវរានិ អធិដ្ឋាតុំ មយ្ហិមានិ ចីវរានីតិ ។



នៅតែម្នាក់ឯងអស់កាលនៃរដូវ(១) ។ ក្នុងទីនោះពួកមនុស្សបានប្រគេនចីវរទាំងឡាយដោយពាក្យថា យើងទាំងឡាយប្រគេនចីវរចំពោះសង្ឃ ។ ភិក្ខុនោះក៏មានសេចក្ដីត្រិះរិះដូច្នេះថា ព្រះដ៏មានព្រះភាគបានបញ្ញត្តថា ដែលហៅសង្ឃ លើយ៉ាងតិចបំផុតត្រឹមភិក្ខុ ៤ រូប ក៏តែអាត្មាអញតែម្នាក់ឯង ចំណែកខាងពួកមនុស្សនេះបានប្រគេនចីវរទាំងឡាយដោយពាក្យថា យើងទាំងឡាយប្រគេនចីវរចំពោះសង្ឃ បើដូច្នោះគួរអាត្មាអញនាំយកចីវររបស់សង្ឃនេះទៅកាន់ក្រុងសាវត្ថី ។ ភិក្ខុនោះក៏បាននាំយកចីវរទាំងនោះទៅកាន់ក្រុងសាវត្ថី ហើយបានក្រាបទូលសេចក្ដីនុ៎ះដល់ភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសង្ឃដែលមានក្នុងទីចំពោះមុខ(២)ចែកគ្នាបាន ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះបើមានភិក្ខុនៅតែម្នាក់ឯងអស់កាលនៃរដូវ ។ ក្នុងទីនោះពួកមនុស្សប្រគេនចីវរទាំងឡាយដោយពាក្យថា យើងទាំងឡាយប្រគេនចីវរចំពោះសង្ឃ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុនោះអធិដ្ឋានចីវរទាំងនោះដូច្នេះថា ចីវរទាំងនេះជារបស់អាត្មាអញ ។

---

១ សំដៅយកកាលដទៃពីព្រះវស្សា ។ ២ អដ្ឋកថា ថា ក្រុមសង្ឃដែលឋិតនៅក្នុងឧបចារសីមាក្រោយនៃការប្រាប់ហៅហើយសឹមចែកគ្នា ។

តស្ស ចេ ភិក្ខវេ ភិក្ខុនោ តំ ចីវរំ អនធិដ្ឋិតេ អញ្ញោ ភិក្ខុ អាគច្ឆតិ សមកោ នាកាមា ភាគោ ទេយ្យោ ។ តស្ស ចេ ភិក្ខវេ ភិក្ខុនោ តំ ចីវរំ ភាជិយមានេ(១) អបាតិតេ កុសេ អញ្ញោ ភិក្ខុ អាគច្ឆតិ សមកោ នាកាមា ភាគោ ទេយ្យោ ។ តស្ស ចេ ភិក្ខវេ ភិក្ខុនោ តំ ចីវរំ ភាជិយមានេ បាតិតេ កុសេ អញ្ញោ ភិក្ខុ អាគច្ឆតិ ឩនកតរោ នាកាមា ភាគោ ទេយ្យោ ។ តេន ខោ បន សមយេន ទ្វេ ភាតុកា ថេរា អាយស្មា ច ឥសិទាសោ អាយស្មា ច ឥសិភត្តោ សាវត្ថិយំ វស្សំវុត្ថា អញ្ញតរំ គាមកាវាសំ អគមំសុ ។ មនុស្សា ចិរស្សាបិ ថេរា អាគតាតិ សចីវរានិ ភត្តានិ អទំសុ ។ អាវាសិកា ភិក្ខូ ថេរេ បុច្ឆិំសុ ឥមានិ ភន្តេ សង្ឃិកានិ ចីវរានិ ថេរេ អាគម្ម ឧប្បន្នានិ សាទិយិស្សថ ថេរា ភាគន្តិ ។ ថេរា ឯវមាហំសុ យថា ខោ មយំ អាវុសោ ភគវតា ធម្មំ ទេសិតំ អាជានាម

១ ភាជិយមានេតិបិ បាឋោ សោ យុត្តតរោ ។



ម្នាលភិក្ខុទាំងឡាយ បើភិក្ខុនោះមិនទាន់អធិដ្ឋានចីវរនោះទេ ស្រាប់តែមានភិក្ខុឯទៀតមកដល់ ត្រូវភិក្ខុនោះចែកចំណែកស្មើ (ដល់ភិក្ខុដែលទើបមកដល់នោះ) ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទាំងនោះកំពុងចែកចីវរនោះ ហើយស្លាកមិនទាន់ធ្លាក់ផង ស្រាប់តែមានភិក្ខុឯទៀតមកដល់ ត្រូវភិក្ខុនោះចែកចំណែកស្មើ (ដល់ភិក្ខុដែលទើបមកដល់នោះ) ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុទាំងនោះចែកចីវរនោះ ស្លាកធ្លាក់អស់ទៅហើយ ទើបមានភិក្ខុឯទៀតមកដល់ មិនបាច់ចែកឲ្យទេ ។ សម័យនោះឯង មានព្រះថេរៈពីររូបជាបងប្អូននឹងគ្នា គឺព្រះថេរៈឈ្មោះឥសិទាសៈដ៏មានអាយុ ១ ព្រះថេរៈឈ្មោះឥសិភត្តដ៏មានអាយុ ១ នៅចាំវស្សាក្នុងក្រុងសាវត្ថី លុះចេញវស្សាហើយក៏នាំគ្នាទៅកាន់គាមាវាសក្នុងស្រុកតូចមួយ ។ ពួកមនុស្សនិយាយគ្នាថា ព្រះថេរៈទាំងឡាយចាកយូរណាស់ហើយទើបឃើញនិមន្តមក ជាដូច្នោះហើយក៏នាំគ្នាប្រគេនចង្ហាន់ព្រមទាំងចីវរ ។ ពួកភិក្ខុអ្នកនៅក្នុងអាវាសសួរព្រះថេរៈទាំងឡាយថា បពិត្រព្រះថេរៈដ៏ចំរើន ចីវររបស់សង្ឃទាំងនេះកើតឡើងក៏ព្រោះតែព្រះថេរៈទាំងឡាយ តើព្រះថេរៈទាំងឡាយនឹងត្រេកអរនឹងចំណែកដែរឬទេ ។ ព្រះថេរៈទាំងឡាយក៏និយាយយ៉ាងនេះថា ម្នាលអាវុសោ ធម៌(១)ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយយ៉ាងណា យើងទាំងឡាយក៏ជ្រាបនូវ

១ ច្បាប់ដែលព្រះដ៏មានព្រះភាគទ្រង់បញ្ញត្ត ។

តុម្ហាកំ យេវ តាវ ជីវិតំ យាវ កាមិតស្ស ឧក្កាកយា-
តិ ។ តេន ខោ បន សមយេន ឯកោ ភិក្ខុ កដក-
ហេ វស្សំ វសន្តិ ។ តត្ថ មនុស្សា សព្វស្ស ទេមាតិ
ជីវិតំ ទេន្តិ ។ អថខោ តេសំ ភិក្ខូនំ ឯតទហោសិ
ភគវតា បញ្ញត្តំ ចតុវគ្គោ បច្ឆិមោ សង្ឃោតិ មយញ្ហិ
តយោ ជនា ឥមេ ច មនុស្សា សព្វស្ស ទេមាតិ
ជីវិតំ ទេន្តិ កថំ នុ ខោ អម្ហេហិ បដិបជ្ជិតព្វន្តិ ។ តេន
ខោ បន សមយេន សម្ពហុលា ថេរា អាយស្មា ច នីល-
វាសី អាយស្មា ច សាណវាសី អាយស្មា ច គោបកោ
អាយស្មា ច ភគុ អាយស្មា ច ផលិកសន្ទានោ បាតលិ-
បុត្តេ វិហរន្តិ កុក្កុដារាមេ ។ អថខោ តេ ភិក្ខូ បាតលិ-
បុត្តំ គន្ត្វា ថេរេ បុច្ឆិំសុ ។ ថេរា ឯវមាហំសុ យថា
ខោ មយំ អាវុសោ ភគវតា ធម្មំ ទេសិតំ អាជានាម
តុម្ហាកំ យេវ តាវ ជីវិតំ យាវ កាមិតស្ស ឧក្កាកយាតិ ។



ឲ្យរស់ហើយថា ជីវិតទាំងនោះជាជីវិតរបស់លោកទាំងឡាយកំណត់តែត្រឹម
កប់នឹងដោះ ។ សម័យនោះឯង ភិក្ខុ ៣ រូបនៅចាំវស្សាក្នុងស្រុកកដកជនៈ ។ ពួក
មនុស្សក្នុងទីនោះប្រគេនជីវិតទាំងឡាយដោយពាក្យថា យើងទាំងឡាយ
ប្រគេនជីវិតលោកសង្ឃ ។ ភិក្ខុទាំងនោះក៏មានសេចក្តីត្រិះរិះដូច្នេះថា
ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តថា ដែលហៅថា សង្ឃបើយើងគិតចំនុក
ត្រឹមភិក្ខុ ៤ រូប តែឡូវយើងទាំងឡាយជាជន ៣ រូប តែមនុស្សទាំងនេះប្រ-
គេនជីវិតទាំងឡាយដោយពាក្យថា យើងទាំងឡាយប្រគេនជីវិតលោក
សង្ឃ តើយើងទាំងឡាយត្រូវប្រតិបត្តិដូចម្តេច ។ សម័យនោះឯង ព្រះ
ថេរច្រើនអង្គ គឺព្រះថេរឈ្មោះនីលវាសីដ៏មានអាយុ ១ ព្រះថេរឈ្មោះ
សាណវាសីដ៏មានអាយុ ១ ព្រះថេរឈ្មោះគោបកៈដ៏មានអាយុ ១ ព្រះថេរ
ឈ្មោះភគុដ៏មានអាយុ ១ ព្រះថេរឈ្មោះផលិកសន្ទានៈដ៏មានអាយុ ១
នៅកុក្កុដារាម ទៀបក្រុងបាតលិបុត្ត ។ គ្រានោះ ភិក្ខុទាំងនោះ
នាំគ្នាទៅកាន់ក្រុងបាតលិបុត្តហើយសួរព្រះថេរៈទាំងឡាយ ។ ព្រះថេរៈ
ទាំងឡាយនិយាយយ៉ាងនេះថា ម្នាលអាវុសោ ធម៌ដែលព្រះដ៏មានព្រះ
ភាគទ្រង់សំដែងហើយយ៉ាងណា យើងទាំងឡាយក៏បានដឹងច្បាស់ថា
ជីវិតទាំងឡាយនោះជាជីវិតរបស់អ្នកទាំងឡាយកំណត់តែត្រឹមកប់នឹងដោះ ។

(៧១) តេន ខោ បន សមយេន អាយស្មា ឧបនន្ទោ សក្យបុត្តោ សាវត្ថិយំ វស្សំ វុត្ថោ អញ្ញតរំ គាមកាវាសំ អគមាសិ ។ តត្ថ ច ភិក្ខូ ចីវរំ ភាជេតុកាមា សន្និបតឹសុ ។ តេ ឯវមាហំសុ ឥមានិ ខោ អាវុសោ សង្ឃិកានិ ចីវរានិ ភាជិយិស្សន្តិ សាទិយិស្សសិ ភាគន្តិ ។ អាមាវុសោ សាទិយិស្សាមីតិ តតោ ចីវរភាគំ គហេត្វា អញ្ញំ អាវាសំ អគមាសិ ។ តត្ថបិ ភិក្ខូ ចីវរំ ភាជេតុកាមា សន្និបតឹសុ ។ តេបិ ឯវមាហំសុ ឥមានិ ខោ អាវុសោ សង្ឃិកានិ ចីវរានិ ភាជិយិស្សន្តិ សាទិយិស្សសិ ភាគន្តិ ។ អាមាវុសោ សាទិយិស្សាមីតិ តតោបិ ចីវរភាគំ គហេត្វា អញ្ញំ អាវាសំ អគមាសិ ។ តត្ថបិ ភិក្ខូ ចីវរំ ភាជេតុកាមា សន្និបតឹសុ ។ តេបិ ឯវមាហំសុ ឥមានិ ខោ អាវុសោ សង្ឃិកានិ ចីវរានិ ភាជិយិស្សន្តិ សាទិយិស្សសិ ភាគន្តិ ។ អាមាវុសោ សាទិយិស្សាមីតិ តតោបិ



[៧១] សម័យនោះឯង ព្រះឧបនន្ទសក្យបុត្តដ៏មានអាយុនៅចាំវស្សាក្នុងក្រុងសាវត្ថី លុះចេញវស្សាហើយក៏បានទៅកាន់អាវាសក្នុងស្រុកតូចមួយ ។ ពួកភិក្ខុមានសេចក្តីប្រាថ្នានឹងចែកចីវរ ក៏ប្រជុំគ្នាក្នុងអាវាសនោះ ។ ភិក្ខុទាំងនោះនិយាយយ៉ាងនេះថា ម្នាលអាវុសោ ចីវររបស់សង្ឃទាំងនេះ យើងនឹងចែកគ្នា តើលោកត្រេកអរនឹងចំណែកដែរឬ ។ ព្រះឧបនន្ទសក្យបុត្តឆ្លើយថា អើអាវុសោ ខ្ញុំត្រេកអរដែរ ជាដូច្នោះហើយ ក៏ទទួលយកចំណែកចីវរអំពីអាវាសនោះទៅកាន់អាវាសឯទៀត ។ ឯពួកភិក្ខុមានសេចក្តីប្រាថ្នានឹងចែកចីវរ ក៏ប្រជុំគ្នាក្នុងអាវាសនោះទៀត ។ ភិក្ខុទាំងនោះបាននិយាយយ៉ាងនេះថា ម្នាលអាវុសោ ចីវររបស់សង្ឃទាំងនេះ យើងនឹងចែកគ្នា តើលោកត្រេកអរនឹងចំណែកដែរឬ ។ ព្រះឧបនន្ទសក្យបុត្តឆ្លើយថា អើអាវុសោ ខ្ញុំត្រេកអរដែរ ជាដូច្នោះហើយក៏ទទួលយកចំណែកចីវរអំពីអាវាសនោះទៅកាន់អាវាសឯទៀត ។ ពួកភិក្ខុមានសេចក្តីប្រាថ្នានឹងចែកចីវរ ក៏ប្រជុំគ្នាក្នុងអាវាសនោះទៀត ។ ភិក្ខុទាំងនោះបាននិយាយយ៉ាងនេះថា ម្នាលអាវុសោ ចីវររបស់សង្ឃទាំងនេះ យើងនឹងចែកគ្នា តើលោកត្រេកអរនឹងចំណែកដែរឬ ។ ព្រះឧបនន្ទសក្យបុត្តឆ្លើយថា អើអាវុសោ ខ្ញុំត្រេកអរដែរ ជាដូច្នោះហើយក៏ទទួលយកចំណែកចីវរអំពីអាវាសនោះ

ចីវរភាគំ គហេត្វា មហន្តំ ចីវរភណ្ឌិកំ អាទាយ បុនទេវ សាវត្ថឹ បច្ចាគច្ឆិ ។ ភិក្ខូ ឯវមាហំសុ មហាបុញ្ញោសិ ត្វំ អាវុសោ ឧបនន្ទ ពហុំ តេ ចីវរំ ឧប្បន្នន្តិ ។ កុតោ មេ អាវុសោ បុញ្ញំ ឥធាហំ សាវត្ថិយំ វស្សំ វុត្ថោ អញ្ញតរំ គាមកាវាសំ អគមាសឹ តត្ថ ភិក្ខូ ចីវរំ ភាជេតុកាមា សន្និបតឹសុ តេ មំ ឯវមាហំសុ ឥមានិ ខោ អាវុសោ សង្ឃិកានិ ចីវរានិ ភាជិយិស្សន្តិ សាទិយិស្សសិ ភាគន្តិ អាមាវុសោ សាទិយិស្សាមីតិ តតោ ចីវរភាគំ គហេត្វា អញ្ញំ អាវាសំ អគមាសឹ តត្ថបិ ភិក្ខូ ចីវរំ ភាជេតុកាមា សន្និបតឹសុ តេបិ មំ ឯវមាហំសុ ឥមានិ ខោ អាវុសោ សង្ឃិកានិ ចីវរានិ ភាជិយិស្សន្តិ សាទិយិស្សសិ ភាគន្តិ អាមាវុសោ សាទិយិស្សាមីតិ តតោបិ ចីវរភាគំ គហេត្វា អញ្ញំ អាវាសំ អគមាសឹ តត្ថបិ ភិក្ខូ ចីវរំ ភាជេតុកាមា សន្និបតឹសុ តេបិ មំ ឯវមាហំសុ ឥមានិ ខោ អាវុសោ សង្ឃិកានិ ចីវរានិ ភាជិយិស្សន្តិ



ហើយក៏ស្ពាយសំពាយចីវរធំ វិលត្រឡប់មកកាន់ក្រុងសាវត្ថីវិញដដែល ។ ពួកភិក្ខុនិយាយយ៉ាងនេះថា ម្នាលអាវុសោឧបនន្ទ លោកជាអ្នកមានបុណ្យធំ បានជាលោកបានចីវរច្រើន ។ ព្រះឧបនន្ទសក្យបុត្តឆ្លើយថា ម្នាលអាវុសោ ខ្ញុំមានបុណ្យមកពីណា ដោយសារតែខ្ញុំនៅចាំវស្សក្នុងក្រុងសាវត្ថីនេះ លុះចេញវស្សាហើយខ្ញុំបានទៅកាន់អាវាសក្បែរស្រុកតូចមួយ ពួកភិក្ខុមានសេចក្តីប្រាថ្នានឹងចែកចីវរក៏ប្រជុំគ្នាក្នុងអាវាសនោះ ភិក្ខុទាំងនោះបាននិយាយយ៉ាងនេះនឹងខ្ញុំថា ម្នាលអាវុសោ ចីវររបស់សង្ឃទាំងនេះ យើងនឹងចែកគ្នា តើលោកត្រេកអរនឹងចំណែកដែរឬ ខ្ញុំឆ្លើយថា អើអាវុសោ ខ្ញុំត្រេកអរដែរ ថាដូច្នោះហើយ ខ្ញុំក៏ទទួលយកចំណែកចីវរអំពីអាវាសនោះរួចបានទៅកាន់អាវាសឯទៀត ពួកភិក្ខុមានសេចក្តីប្រាថ្នានឹងចែកចីវរ ក៏ប្រជុំគ្នាក្នុងអាវាសនោះទៀត ភិក្ខុទាំងនោះបាននិយាយយ៉ាងនេះនឹងខ្ញុំថា ម្នាលអាវុសោ ចីវររបស់សង្ឃទាំងនេះ យើងនឹងចែកគ្នា តើលោកត្រេកអរនឹងចំណែកដែរឬ ខ្ញុំបាននិយាយថា អើអាវុសោ ខ្ញុំត្រេកអរដែរ ថាដូច្នោះហើយ ខ្ញុំក៏ទទួលយកចំណែកចីវរអំពីអាវាសនោះទៅកាន់អាវាសឯទៀត ពួកភិក្ខុមានសេចក្តីប្រាថ្នានឹងចែកចីវរ ក៏ប្រជុំគ្នាក្នុងអាវាសនោះទៀត ភិក្ខុទាំងនោះបាននិយាយយ៉ាងនេះនឹងខ្ញុំថា ម្នាលអាវុសោ ចីវររបស់សង្ឃទាំងនេះ

សាទិយិស្សសិ ភាគន្តិ អាមាវុសោ សាទិយិស្សាមីតិ តតោបិ ចីវរភាគំ អគ្គហេសិំ ឯវំ មេ ពហុំ ចីវរំ ឧប្បន្នន្តិ ។ កិំ បន ត្វំ អាវុសោ ឧបនន្ទ អញ្ញត្រ វស្សំ វុត្ថោ អញ្ញត្រ ចីវរភាគំ សាទិយីតិ ។ ឯវមាវុសោតិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អាយស្មា ឧបនន្ទោ សក្យបុត្តោ អញ្ញត្រ វស្សំ វុត្ថោ អញ្ញត្រ ចីវរភាគំ សាទិយិស្សតីតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ សច្ចំ កិរ ត្វំ ឧបនន្ទ អញ្ញត្រ វស្សំ វុត្ថោ អញ្ញត្រ ចីវរភាគំ សាទិយីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ត្វំ មោឃបុរិស អញ្ញត្រ វស្សំ វុត្ថោ អញ្ញត្រ ចីវរភាគំ សាទិយិស្សសិ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ ។បេ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ



ទើបនឹងនិយាយថា តើលោកត្រេកអរនឹងទទួលចំណែកដែរឬ ខ្ញុំនិយាយថា អើ អាវុសោ ខ្ញុំត្រេកអរដែរ ដូច្នោះហើយ ខ្ញុំក៏ទទួលយកចំណែកចីវរ អំពីអាវាសនោះមក, យ៉ាងនេះបានជាខ្ញុំបានចីវរច្រើន ។ ពួកភិក្ខុសួរថា ម្នាលអាវុសោឧបនន្ទ លោកនៅចាំវស្សាក្នុងអាវាសដទៃ ហើយលោកត្រេកអរនឹងចំណែកចីវរក្នុងអាវាសដទៃ មែនឬ ។ ព្រះឧបនន្ទសក្យបុត្រឆ្លើយថា ម្នាលអាវុសោ មែនហើយ ។ ពួកភិក្ខុណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ព្រះឧបនន្ទសក្យបុត្រមានអាយុមិនគួរបើនឹងនៅចាំវស្សាក្នុងអាវាសដទៃ ហើយត្រេកអរនឹងចំណែកចីវរក្នុងអាវាសដទៃសោះ ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបនន្ទ ឮថាអ្នកឯងនៅចាំវស្សាក្នុងអាវាសដទៃ ហើយត្រេកអរនឹងចំណែកចីវរក្នុងអាវាសដទៃ ពិតមែនឬ ។ ព្រះឧបនន្ទសក្យបុត្រឆ្លើយថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលមោឃបុរស អ្នកឯងមិនគួរបើនឹងនៅចាំវស្សាក្នុងអាវាសដទៃ ហើយត្រេកអរនឹងចំណែកចីវរក្នុងអាវាសដទៃសោះ នែមោឃបុរស អំពើនេះមិនមែននាំពួកជនដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើយទេ ។បេ។ លុះទ្រង់តិះដៀលហើយទ្រង់ធ្វើធម្មីកថា រួចត្រាស់ហៅភិក្ខុទាំងឡាយមកថា

ន ភិក្ខវេ អញ្ញត្រ វស្សំវុដ្ឋេន អញ្ញត្រ ចីវរភាគោ សាទិ-
តព្វោ យោ សាទិយេយ្យ អាបត្តិ ទុក្កដស្សាតិ ។ តេន
ខោ បន សមយេន អាយស្មា ឧបនន្ទោ សក្យបុត្តោ
ឯកោ ទ្វីសុ អាវាសេសុ វស្សំ វសិ ឯវំ មេ ពហុំ ចីវរំ
ឧប្បជ្ជិស្សតីតិ ។ អថខោ តេសំ ភិក្ខូនំ ឯតទហោសិ
កថំ នុ ខោ អាយស្មតោ ឧបនន្ទស្ស សក្យបុត្តស្ស
ចីវរបដិវីសោ ទាតព្វោតិ ។ ភគវតោ ឯតមត្ថំ អារោចេ-
សុំ ។ ទេថ ភិក្ខវេ មោឃបុរិសស្ស ឯកាធិប្បាយំ ។
ឥធ បន ភិក្ខវេ ភិក្ខុ ឯកោ ទ្វីសុ អាវាសេសុ វស្សំ
វសតិ ឯវំ មេ ពហុំ ចីវរំ ឧប្បជ្ជិស្សតីតិ ។ សចេ អ-
មុត្រ ឧបឌ្ឍំ អមុត្រ ឧបឌ្ឍំ វសតិ អមុត្រ ឧបឌ្ឍោ
អមុត្រ ឧបឌ្ឍោ ចីវរបដិវីសោ ទាតព្វោ យត្ថ វា បន
ពហុតរំ វសតិ តតោ ចីវរបដិវីសោ ទាតព្វោតិ ។



ម្នាលភិក្ខុទាំងឡាយ ភិក្ខុនៅចាំវស្សាក្នុងអាវាសឯទៀត មិនត្រូវត្រេកអរ
ចំពោះចំណែកចីវរក្នុងអាវាសឯទៀតទេ ភិក្ខុណាត្រេកអរ ត្រូវអាបត្តិទុក្កដ ។
សម័យនោះឯង ព្រះឧបនន្ទសក្យបុត្តមានអាយុនៅចាំវស្សាក្នុងអាវាសពីរ
តែម្នាក់ឯងដោយគិតថា ចីវរមុខជានឹងកើតឡើងដល់អាត្មាច្រើនដូច្នេះ ។
ក្នុងពេលនោះភិក្ខុទាំងនោះមានសេចក្តីត្រិះរិះដូច្នេះថា យើងទាំងឡាយត្រូវ
ឲ្យចំណែកចីវរដល់ព្រះឧបនន្ទសក្យបុត្តមានអាយុដូចម្តេច ។ ភិក្ខុទាំងឡាយ
ក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា
ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរឲ្យចីវរតែមួយចំណែកដល់មោឃបុ-
រសចុះ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុក្នុងសាសនានេះនៅចាំវស្សាក្នុងអា-
វាសពីរតែម្នាក់ឯងដោយគិតថា ចីវរមុខជានឹងកើតឡើងដល់អាត្មាច្រើន
ដូច្នេះ ។ បើភិក្ខុនោះនៅចាំវស្សាក្នុងអាវាសឯណោះបានពាក់កណ្តាល ចាំ
វស្សាក្នុងអាវាសឯណោះបានពាក់កណ្តាល ភិក្ខុទាំងឡាយត្រូវឲ្យចំណែក
ចីវរក្នុងអាវាសឯណោះពាក់កណ្តាល ក្នុងអាវាសឯណោះពាក់កណ្តាលទៅ
ភិក្ខុនោះចុះ ម្យ៉ាងទៀតបើភិក្ខុនៅចាំវស្សាក្នុងអាវាសណាច្រើនជាង ភិក្ខុទាំង
ឡាយត្រូវឲ្យចំណែកចីវរទៅភិក្ខុនោះតាមកំណត់ថ្ងៃដែលច្រើននោះចុះ ។

[៩៦] តេន ខោ បន សមយេន អញ្ញតរស្ស ភិក្ខុនោ កុច្ឆិវិការាពាធោ ហោតិ ។ សោ សកេ មុត្តករីសេ បលិបន្នោ សេតិ ។ អថខោ ភគវា អាយស្មតា អានន្ទេន បច្ឆាសមណេន សេនាសនចារិកំ អាហិណ្ឌន្តោ យេន តស្ស ភិក្ខុនោ វិហារោ តេនុបសង្កមិ ។ អទ្ទសា ខោ ភគវា តំ ភិក្ខុំ សកេ មុត្តករីសេ បលិបន្នំ សយមានំ ទិស្វាន យេន សោ ភិក្ខុ តេនុបសង្កមិ ឧបសង្កមិត្វា តំ ភិក្ខុំ ឯតទវោច កិន្តេ ភិក្ខុ អាពាធោតិ ។ កុច្ឆិវិការោ មេ ភគវាតិ ។ អត្ថិ បន តេ ភិក្ខុ ឧបដ្ឋាកោតិ ។ នត្ថិ ភគវាតិ ។ កិស្ស តំ ភិក្ខូ ន ឧបដ្ឋេន្តីតិ ។ អហំ ខោ ភន្តេ ភិក្ខូនំ អការកោ តេន មំ ភិក្ខូ ន ឧបដ្ឋេន្តីតិ ។ អថខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ គច្ឆានន្ទ ឧទកំ អាហរ ឥមំ ភិក្ខុំ នហាបេស្សាមាតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បដិស្សុណិត្វា



[៩៦] សម័យនោះឯង ភិក្ខុ១រូបមានរោគឈឺពោះ ។ ភិក្ខុនោះដេកត្រាំនៅលើមូត្រនិងករីសរបស់ខ្លួន ។ គ្រានោះ ព្រះដ៏មានព្រះភាគ មានព្រះអានន្ទដ៏មានអាយុជាបច្ឆាសមណៈ ទ្រង់ត្រាច់ដើរទៅកាន់សេនាសនចារិក ហើយចូលទៅកាន់លំនៅនៃភិក្ខុនោះ ។ ព្រះដ៏មានព្រះភាគបានទតឃើញភិក្ខុនោះដេកត្រាំនៅលើមូត្រនិងករីសរបស់ខ្លួន លុះទតឃើញហើយក៏ទ្រង់ចូលទៅកាន់សំណាក់ភិក្ខុនោះ លុះចូលទៅដល់ហើយទ្រង់មានព្រះតម្រាស់យ៉ាងនេះនឹងភិក្ខុនោះថា ម្នាលភិក្ខុ អ្នកមានរោគអ្វី ។ ភិក្ខុនោះក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គឈឺពោះ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងមានភិក្ខុជាអ្នកបម្រើដែរឬទេ ។ ភិក្ខុនោះក្រាបបង្គំទូលថា សូមទ្រង់មេត្តាប្រោស គ្មានទេ ។ ព្រះអង្គទ្រង់ត្រាស់ថា ចុះពួកភិក្ខុហេតុអ្វីក៏មិនបម្រើអ្នក ។ ភិក្ខុនោះក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស (ដ្បិត) ខ្ញុំព្រះអង្គមិនដែលធ្វើ (ឧបការៈ) ដល់ពួកភិក្ខុសោះ ព្រោះហេតុនោះបានជាពួកភិក្ខុមិនបម្រើខ្ញុំព្រះអង្គ ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅព្រះអានន្ទដ៏មានអាយុថា ម្នាលអានន្ទ អ្នកចូរទៅនាំយកទឹកមក យើងនឹងឲ្យភិក្ខុនេះងូត ។ ព្រះអានន្ទដ៏មានអាយុទទួលព្រះបន្ទូលព្រះដ៏មានព្រះភាគដោយពាក្យថា ព្រះករុណាព្រះអង្គ

ឧទកំ អាហរ ។ ភគវា ឧទកំ អាសិញ្ចិ អាយស្មា អា-
នន្ទោ បរិធោវិ ភគវា សីសតោ អគ្គហេសិ អាយស្មា អា-
នន្ទោ បាទតោ ឧច្ចារេត្វា មញ្ចកេ និបាតេសុំ ។ អថខោ
ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ភិក្ខុសង្ឃំ
សន្និបាតាបេត្វា ភិក្ខូ បដិបុច្ឆិ អត្ថិ ភិក្ខវេ អមុកស្មឹ
វិហារេ ភិក្ខុ គិលានោតិ ។ អត្ថិ ភគវាតិ ។ កិន្តស្ស
ភិក្ខវេ ភិក្ខុនោ អាពាធោតិ ។ តស្ស ភន្តេ អាយស្មតោ
កុច្ឆិវិការាពាធោតិ ។ អត្ថិ បន ភិក្ខវេ តស្ស ភិក្ខុនោ
ឧបដ្ឋាកោតិ ។ នត្ថិ ភគវាតិ ។ កិស្ស តំ ភិក្ខូ ន ឧ-
បដ្ឋេន្តីតិ ។ ឯសោ ភន្តេ ភិក្ខុ ភិក្ខូនំ អការកោ តេន
តំ ភិក្ខូ ន ឧបដ្ឋេន្តីតិ ។ នត្ថិ វោ ភិក្ខវេ មាតា នត្ថិ
បិតា យេ វោ ឧបដ្ឋហេយ្យុំ តុម្ហេ ចេ ភិក្ខវេ អញ្ញ-
មញ្ញំ ន ឧបដ្ឋហិស្សថ អថ កោ ចរហិ ឧបដ្ឋហិស្សតិ





ហើយនាំយកទឹកមក ។ ព្រះដ៏មានព្រះភាគទ្រង់ស្រោចទឹក ព្រះអា-
នន្ទដ៏មានអាយុដុសលាង ព្រះដ៏មានព្រះភាគចាប់ខាងក្បាល ព្រះអានន្ទ
ដ៏មានអាយុចាប់ខាងជើង សែងលើកយកទៅដាក់ផ្តេកលើគ្រែតូច ។
ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ
ហើយសួរបញ្ជាក់ភិក្ខុទាំងឡាយក្នុងវេលានោះថា ម្នាលភិក្ខុទាំងឡាយ
ក្នុងវិហារឯណោះ មានភិក្ខុឈឺដែរឬ ។ ពួកភិក្ខុក្រាបបង្គំទូលថា សូម
ទ្រង់ព្រះមេត្តាប្រោស មាន ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំង
ឡាយ ភិក្ខុនោះមានរោគអ្វី ។ ពួកភិក្ខុក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តា
ប្រោស លោកដ៏មានអាយុនោះមានរោគពោះ ។ ព្រះអង្គទ្រង់ត្រាស់ថា
ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុអ្នកបម្រើភិក្ខុនោះមានដែរឬ ។ ពួកភិក្ខុក្រាប
បង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស គ្មានទេ ។ ព្រះអង្គទ្រង់ត្រាស់
ថា ចុះហេតុអ្វីបានជាពួកភិក្ខុមិនបម្រើភិក្ខុនោះ ។ ភិក្ខុទាំងឡាយក្រាបបង្គំ
ទូលថា សូមទ្រង់ព្រះមេត្តាប្រោស ដ្បិតភិក្ខុនោះមិនដែលធ្វើ (ឧបការៈ)
ដល់ភិក្ខុទាំងឡាយ ព្រោះហេតុនោះ បានជាភិក្ខុទាំងឡាយមិនបម្រើ
ភិក្ខុនោះ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ
គ្មានមាតាបិតាទេ បានអ្នកណាបម្រើអ្នករាល់គ្នា ម្នាលភិក្ខុទាំងឡាយ
បើអ្នកទាំងឡាយមិនបម្រើគ្នានឹងគ្នាហើយ តើបានអ្នកណានឹងបម្រើវិញ

យោ ភិក្ខវេ មំ ឧបដ្ឋហេយ្យ សោ គិលានំ ឧបដ្ឋហេយ្យ ។ សចេ ឧបជ្ឈាយោ ហោតិ ឧបជ្ឈាយេន យាវជីវំ ឧបដ្ឋាតព្វោ វុដ្ឋានស្ស អាគមេតព្វំ ។ សចេ អាចរិយោ ហោតិ អាចរិយេន យាវជីវំ ឧបដ្ឋាតព្វោ វុដ្ឋានស្ស អាគមេតព្វំ ។ សចេ សទ្ធិវិហារិកោ ហោតិ សទ្ធិវិហារិកេន យាវជីវំ ឧបដ្ឋាតព្វោ វុដ្ឋានស្ស អាគមេតព្វំ ។ សចេ អន្តេវាសិកោ ហោតិ អន្តេវាសិកេន យាវជីវំ ឧបដ្ឋាតព្វោ វុដ្ឋានស្ស អាគមេតព្វំ ។ សចេ សមានុបជ្ឈាយកោ ហោតិ សមានុបជ្ឈាយកេន យាវជីវំ ឧបដ្ឋាតព្វោ វុដ្ឋានស្ស អាគមេតព្វំ ។ សចេ សមានាចរិយកោ ហោតិ សមានាចរិយកេន យាវជីវំ ឧបដ្ឋាតព្វោ វុដ្ឋានស្ស អាគមេតព្វំ ។ សចេ ន ហោតិ ឧបជ្ឈាយោ វា អាចរិយោ វា សទ្ធិវិហារិកោ វា អន្តេវាសិកោ វា សមានុបជ្ឈាយកោ វា សមានាចរិយកោ វា សង្ឃេន ឧបដ្ឋាតព្វោ ។ នោ ចេ ឧបដ្ឋហេយ្យ អាបត្តិ ទុក្កដស្ស ។ បញ្ចហិ ភិក្ខវេ អង្គេហិ សមន្នាគតោ គិលានោ ទុបដ្ឋោ ហោតិ អសប្បាយការី ហោតិ



ម្នាលភិក្ខុទាំងឡាយ អ្នកណាបម្រើតថាគត អ្នកនោះឈ្មោះថាបម្រើភិក្ខុឈឺ ។ បើមានឧបជ្ឈាយ៍ ឧបជ្ឈាយ៍ត្រូវបម្រើភិក្ខុនោះអស់១ជីវិត ឧបជ្ឈាយ៍ត្រូវរង់ចាំទំរាំភិក្ខុនោះសះជា ។ បើមានអាចារ្យ អាចារ្យត្រូវបម្រើភិក្ខុនោះអស់១ជីវិត អាចារ្យត្រូវរង់ចាំទំរាំភិក្ខុនោះសះជា ។ បើមានសទ្ធិវិហារិក សទ្ធិវិហារិកត្រូវបម្រើភិក្ខុនោះអស់១ជីវិត សទ្ធិវិហារិកត្រូវរង់ចាំទំរាំភិក្ខុនោះសះជា ។ បើមានអន្តេវាសិក (កូនសិស្ស) អន្តេវាសិកត្រូវបម្រើភិក្ខុនោះអស់១ជីវិត អន្តេវាសិកត្រូវរង់ចាំទំរាំភិក្ខុនោះសះជា ។ បើមានភិក្ខុមានឧបជ្ឈាយ៍ស្មើគ្នា ត្រូវភិក្ខុមានឧបជ្ឈាយ៍ស្មើគ្នាបម្រើភិក្ខុនោះអស់១ជីវិត ភិក្ខុមានឧបជ្ឈាយ៍ស្មើគ្នាត្រូវរង់ចាំទំរាំភិក្ខុនោះសះជា ។ បើមានភិក្ខុមានអាចារ្យស្មើគ្នា ភិក្ខុមានអាចារ្យស្មើគ្នាត្រូវបម្រើភិក្ខុនោះអស់១ជីវិត ភិក្ខុមានអាចារ្យស្មើគ្នាត្រូវរង់ចាំទំរាំភិក្ខុនោះសះជា ។ បើឧបជ្ឈាយ៍ក្តី អាចារ្យក្តី សទ្ធិវិហារិកក្តី អន្តេវាសិកក្តី ភិក្ខុមានឧបជ្ឈាយ៍ស្មើគ្នាក្តី ភិក្ខុមានអាចារ្យស្មើគ្នាក្តី មិនមានទេ សង្ឃត្រូវបម្រើភិក្ខុមានជម្ងឺនោះ ។ បើសង្ឃមិនបម្រើទេ ត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានជម្ងឺប្រកបដោយអង្គ៥ ជាបុគ្គលលំបាកគេបម្រើ គឺបុគ្គលមិនធ្វើខ្លួនឲ្យសប្បាយ ១

សប្បាយេ មត្តំ ន ជានាតិ ភេសជ្ជំ ន បដិសេវិតា ហោតិ អត្តកាមស្ស គិលានុបដ្ឋាកស្ស យថាភូតំ អាពាធំ នាវិកត្តា ហោតិ អភិក្កមន្តំ វា អភិក្កមតីតិ បដិក្កមន្តំ វា បដិក្កមតីតិ ឋិតំ វា ឋិតោតិ ឧប្បន្នានំ សារីរិកានំ វេទនានំ ទុក្ខានំ តិព្វានំ ខរានំ កដុកានំ អសាតានំ អមនាបានំ បាណហរានំ អនធិវាសកជាតិកោ ហោតិ ឥមេហិ ខោ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតោ គិលានោ ទុបដ្ឋាកោ ហោតិ ។ បញ្ចហិ ភិក្ខវេ អង្គេហិ សមន្នាគតោ គិលានោ សុបដ្ឋាកោ ហោតិ សប្បាយការី ហោតិ សប្បាយេ មត្តំ ជានាតិ ភេសជ្ជំ បដិសេវិតា ហោតិ អត្តកាមស្ស គិលានុបដ្ឋាកស្ស យថាភូតំ អាពាធំ អាវិកត្តា ហោតិ អភិក្កមន្តំ វា អភិក្កមតីតិ បដិក្កមន្តំ វា បដិក្កមតីតិ ឋិតំ វា ឋិតោតិ ឧប្បន្នានំ សារីរិកានំ វេទនានំ ទុក្ខានំ តិព្វានំ ខរានំ កដុកានំ អសាតានំ អមនាបានំ បាណហរានំ អធិវាសកជាតិកោ ហោតិ ឥមេហិ ខោ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតោ គិលានោ



មិនដឹងប្រមាណក្នុងការសប្បាយ ១ មិនឆាន់ថ្នាំប្រើថ្នាំ ១ មិនប្រាប់អាពាធដែលចំរើនថាចំរើនក្តី មិនប្រាប់អាពាធដែលធូរថយថាធូរថយក្តី មិនប្រាប់អាពាធដែលនៅទីដដែលថានៅទីដដែលក្តី ឲ្យច្បាស់តាមពិតដល់បុគ្គលអ្នកបម្រើជម្ងឺ ដែលជាអ្នកប្រាថ្នាប្រយោជន៍ ១ មិនអត់សង្កត់នូវទុក្ខវេទនាដ៏ទីក្លាផ្សាក្តៅ ដែលកើតឡើងក្នុងប្រដាប់នៃសរីរៈមិនពេញពីសា មិនគាប់ចិត្ត ជាទីនាំឲ្យខូចជីវិត ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានជម្ងឺប្រកបដោយអង្គទាំង ៥ នេះឯង តែងលំបាកគេបម្រើ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានជម្ងឺប្រកបដោយអង្គ ៥ ងាយគេបម្រើ គឺបុគ្គលនោះធ្វើខ្លួនឲ្យសប្បាយ ១ ដឹងប្រមាណក្នុងការសប្បាយ ១ ឆាន់ថ្នាំប្រើថ្នាំ ១ ប្រាប់អាពាធដែលចំរើនឡើងថាចំរើនឡើងក្តី ប្រាប់អាពាធដែលធូរថយថាធូរថយក្តី ប្រាប់អាពាធដែលនៅទីដដែលថានៅទីដដែលឲ្យច្បាស់តាមពិតដល់បុគ្គលអ្នកបម្រើជម្ងឺ ដែលជាអ្នកប្រាថ្នាប្រយោជន៍ ១ ជាអ្នកអត់សង្កត់នូវទុក្ខវេទនាដ៏ទីក្លាផ្សាក្តៅ ដែលកើតឡើងក្នុងប្រដាប់នៃសរីរៈមិនពេញពីសា មិនគាប់ចិត្ត ជាទីនាំឲ្យខូចជីវិត ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានជម្ងឺប្រកបព្រមដោយអង្គទាំង ៥ នេះឯង

ស្វុបដ្ឋាកោ ហោតិ ។ បញ្ចហិ ភិក្ខវេ អង្គេហិ សមន្នា-
គតោ គិលានុបដ្ឋាកោ នាលំ គិលានំ ឧបដ្ឋាតុំ ន បដិ-
ពលោ ហោតិ ភេសជ្ជំ សំវិធាតុំ សប្បាយាសប្បាយំ ន
ជានាតិ អសប្បាយំ ឧបនាមេតិ សប្បាយំ អបនាមេតិ
អាមិសន្តរោ គិលានំ ឧបដ្ឋេតិ នោ មេត្តចិត្តោ ជេគុច្ឆី
ហោតិ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា វន្តំ វា នីហាតុំ
ន បដិពលោ ហោតិ គិលានំ កាលេន កាលំ ធម្មិយា
កថាយ សន្ទស្សេតុំ សមាទបេតុំ សមុត្តេជេតុំ សម្ប-
ហំសេតុំ ឥមេហិ ខោ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគ-
តោ គិលានុបដ្ឋាកោ នាលំ គិលានំ ឧបដ្ឋាតុំ ។ បញ្ច-
ហិ ភិក្ខវេ អង្គេហិ សមន្នាគតោ គិលានុបដ្ឋាកោ អលំ
គិលានំ ឧបដ្ឋាតុំ បដិពលោ ហោតិ ភេសជ្ជំ សំវិធាតុំ
សប្បាយាសប្បាយំ ជានាតិ អសប្បាយំ អបនាមេតិ
សប្បាយំ ឧបនាមេតិ មេត្តចិត្តោ គិលានំ ឧបដ្ឋេតិ នោ
អាមិសន្តរោ អជេគុច្ឆី ហោតិ ឧច្ចារំ វា បស្សាវំ វា





ដ៏ងាយនឹងបម្រើ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកបម្រើជម្ងឺប្រកប
ដោយអង្គ ៥ មិនគួរនឹងបម្រើគិលានទេ គឺបុគ្គលមិនប្រសប់ពាត់តែងថ្នាំ ១
មិនស្គាល់ហេតុសប្បាយនិងមិនសប្បាយ ១ នាំរបស់ដែលមិនសប្បាយ
ចូលទៅ នាំរបស់ដែលសប្បាយចេញមក ១ បម្រើអ្នកជម្ងឺព្រោះតែ
អាមិសៈ ឥតមានចិត្តមេត្តា មានតែខ្ពើមរអើមនឹងការនាំចេញនូវឧច្ចារៈក្តី
បស្សាវៈក្តី ទឹកមាត់ក្តី កំអួតក្តី ១ មិនអាចនឹងពន្យល់អ្នកមានជម្ងឺឲ្យឃើញ
ច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថាសព្វៗ
កាល ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកបម្រើជម្ងឺប្រកបដោយអង្គ ៥ នេះ
ឯង មិនគួរបម្រើជម្ងឺទេ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកបម្រើជម្ងឺបើ
ប្រកបដោយអង្គ ៥ ទើបគួរបម្រើជម្ងឺបាន គឺបុគ្គលប្រសប់ពាត់តែងថ្នាំ ១
ស្គាល់ហេតុសប្បាយនិងមិនសប្បាយ ១ នាំរបស់ដែលមិនសប្បាយ
ចេញទៅ នាំរបស់ដែលសប្បាយចូលមក ១ មានចិត្តមេត្តា មិនប្រាថ្នា
អាមិសៈ ហើយបម្រើជម្ងឺ មិនខ្ពើមរអើមនឹងការនាំចេញនូវឧច្ចារៈក្តី បស្សាវៈក្តី

ខេឡំ វា វន្តំ វា នីហរិតុំ បដិពលោ ហោតិ គិលានំ កាលេន កាលំ ធម្មិយា កថាយ សន្ទស្សេតុំ សមាទបេតុំ សមុត្តេជេតុំ សម្បហំសេតុំ ឥមេហិ ខោ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតោ គិលានុបដ្ឋាកោ អលំ គិលានំ ឧបដ្ឋាតុន្តិ ។

[៧៣] តេន ខោ បន សមយេន ទ្វេ ភិក្ខូ កោសលេសុ ជនបទេសុ អទ្ធានមគ្គប្បដិបន្នា ហោន្តិ ។ តេ អញ្ញតរំ អាវាសំ ឧបគច្ឆិំសុ ។ តត្ថ អញ្ញតរោ ភិក្ខុ គិលានោ ហោតិ ។ អថខោ តេសំ ភិក្ខូនំ ឯតទហោសិ ភគវតា ខោ អាវុសោ គិលានុបដ្ឋានំ វណ្ណិតំ ហន្ទ មយំ អាវុសោ ឥមំ ភិក្ខុំ ឧបដ្ឋហាមាតិ ។ តេ តំ ឧបដ្ឋហិំសុ ។ សោ តេហិ ឧបដ្ឋិយមានោ កាលមកាសិ ។ អថខោ តេ ភិក្ខូ តស្ស ភិក្ខុនោ បត្តចីវរមាទាយ សាវត្ថឹ គន្ត្វា ភគវតោ ឯតមត្ថំ អារោចេសុំ ។ ភិក្ខុស្ស ភិក្ខវេ កាលកតេ សង្ឃោ សាមី បត្តចីវរេ



ទឹកមាត់ក្តី កំអួតក្តី ១ តាមនឹងពេលវេលាអ្នកមានជម្ងឺឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថាសព្វៗកាល ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកបម្រើជម្ងឺប្រកបព្រមដោយអង្គទាំង ៥ នេះឯង ទើបគួរបម្រើជម្ងឺបាន ។

[៧៣] សម័យនោះឯង មានភិក្ខុពីររូបដើរទៅតាមផ្លូវឆ្ងាយក្នុងកោសលជនបទ ។ ភិក្ខុទាំងពីររូបនោះចូលទៅកាន់អាវាស ១ ។ ក្នុងអាវាសនោះមានភិក្ខុមួយរូបឈឺ ។ ភិក្ខុទាំងនោះក៏មានសេចក្តីត្រិះរិះដូច្នេះថា ម្នាលអាវុសោ ព្រះដ៏មានព្រះភាគទ្រង់សរសើរការបម្រើជម្ងឺពេកណាស់ អាវុសោ បើដូច្នោះមានតែយើងទាំងឡាយនឹងបម្រើភិក្ខុនេះ ។ ភិក្ខុទាំងនោះក៏នាំគ្នាបម្រើភិក្ខុឈឺនោះ ។ កាលដែលភិក្ខុទាំងនោះកំពុងបម្រើ ភិក្ខុឈឺក៏ធ្វើមរណកាលទៅ ។ គ្រានោះ ភិក្ខុទាំងនោះក៏នាំយកបាត្រនិងចីវររបស់ភិក្ខុឈឺនោះទៅឯក្រុងសាវត្ថី ហើយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើមានភិក្ខុ(ណាមួយ)ធ្វើមរណកាលទៅហើយ ត្រូវសង្ឃជាម្ចាស់លើបាត្រ

អបិច គិលានុបដ្ឋាកា ពហូបការា ។ អនុជានាមិ ភិក្ខវេ សង្ឃេន តិចីវរញ្ច បត្តញ្ច គិលានុបដ្ឋាកានំ ទាតុំ ។ ឯវញ្ច បន ភិក្ខវេ ទាតព្វំ ។ តេន គិលានុបដ្ឋាកេន ភិក្ខុនា សង្ឃំ ឧបសង្កមិត្វា ឯវមស្ស វចនីយោ ឥត្ថន្នាមោ ភន្តេ ភិក្ខុ កាលកតោ ឥទំ តស្ស តិចីវរញ្ច បត្តោ ចាតិ ។ ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ ឥត្ថន្នាមោ ភិក្ខុ កាលកតោ ឥទំ តស្ស តិចីវរញ្ច បត្តោ ច ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥមំ តិចីវរញ្ច បត្តញ្ច គិលានុបដ្ឋាកានំ ទទេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ ឥត្ថន្នាមោ ភិក្ខុ កាលកតោ ឥទំ តស្ស តិចីវរញ្ច បត្តោ ច ។ សង្ឃោ ឥមំ តិចីវរញ្ច បត្តញ្ច គិលានុបដ្ឋាកានំ ទេតិ ។ យស្សាយស្មតោ ខមតិ ឥមស្ស តិចីវរស្ស ច បត្តស្ស ច គិលានុបដ្ឋាកានំ ទានំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទិន្នំ ឥទំ សង្ឃេន តិចីវរញ្ច



និងចីវរ (របស់ភិក្ខុនោះ) តែថាពួកភិក្ខុអ្នកបម្រើជម្ងឺមានឧបការៈច្រើនផង នេះ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសង្ឃឲ្យត្រៃចីវរនិងបាត្រ ដល់ភិក្ខុអ្នកបម្រើជម្ងឺ ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យយ៉ាងនេះ ។ ភិក្ខុអ្នកបម្រើជម្ងឺនោះត្រូវចូលទៅរកសង្ឃ ហើយនិយាយយ៉ាងនេះនឹងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន ភិក្ខុឈ្មោះនេះធ្វើមរណកាលទៅហើយ ត្រៃចីវរនិងបាត្រនេះជារបស់ភិក្ខុនោះ ។ ភិក្ខុដែលឆ្លាសប្រតិពលត្រូវផ្ទៀងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ ភិក្ខុឈ្មោះនេះធ្វើមរណកាលទៅហើយ ត្រៃចីវរនិងបាត្រនេះ ជារបស់ភិក្ខុនោះ ។ បើការឲ្យត្រៃចីវរនិងបាត្រមានកាលសមគួរដល់សង្ឃហើយ សង្ឃគួរឲ្យត្រៃចីវរនិងបាត្រនេះដល់ពួកភិក្ខុអ្នកបម្រើជម្ងឺ ។ នេះជាពាក្យផ្ទៀងសង្ឃ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ ភិក្ខុឈ្មោះនេះធ្វើមរណកាលទៅហើយ ត្រៃចីវរនេះនិងបាត្រនេះ ជារបស់ភិក្ខុនោះ ។ ឥឡូវសង្ឃបានឲ្យត្រៃចីវរនិងបាត្រនេះដល់ពួកភិក្ខុអ្នកបម្រើជម្ងឺហើយ ។ ការឲ្យត្រៃចីវរនិងបាត្រដល់ពួកភិក្ខុអ្នកបម្រើជម្ងឺនេះ (បើ) គាប់ចិត្តដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម (បើ) មិនគាប់ចិត្តដល់លោកដ៏មានអាយុអង្គណាទេ ត្រូវលោកដ៏មានអាយុអង្គនោះនិយាយឡើង ។ សង្ឃបានឲ្យត្រៃចីវរនិងបាត្រនេះ ដល់ពួកភិក្ខុ

ឋបេត្វា ឆ គិលានុបដ្ឋាកានំ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។ តេន ខោ បន សមយេន អញ្ញតរោ សាមណេរោ កាលកតោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ សាមណេរស្ស ភិក្ខវេ កាលកតេ សង្ឃោ សាមី បត្តចីវរេ អបិច គិលានុបដ្ឋាកា ពហូបការា ។ អនុជានាមិ ភិក្ខវេ សង្ឃេន ចីវរញ្ច បត្តញ្ច គិលានុបដ្ឋាកានំ ទាតុំ ។ ឯវញ្ច បន ភិក្ខវេ ទាតព្វំ ។ តេន គិលានុបដ្ឋាកេន ភិក្ខុនា សង្ឃំ ឧបសង្កមិត្វា ឯវមស្ស វចនីយោ អញ្ញតរោ ភន្តេ សាមណេរោ កាលកតោ ឥទំ តស្ស ចីវរញ្ច បត្តោ ចាតិ ។ ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ អញ្ញតរោ សាមណេរោ កាលកតោ ឥទំ តស្ស ចីវរញ្ច បត្តោ ច ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥមំ ចីវរញ្ច បត្តញ្ច គិលានុបដ្ឋាកានំ ទទេយ្យ ។ ឯសា ញត្តិ ។



អ្នកបម្រើជម្ងឺហើយ ។ ការឲ្យត្រៃចីវរនិងបាត្រដល់ពួកភិក្ខុអ្នកបម្រើជម្ងឺប្រកបដោយគាប់ចិត្តដល់សង្ឃហើយ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកនូវសេចក្តីនេះដោយអាការស្ងៀមយ៉ាងនេះ ។ សម័យនោះឯង មានសាមណេរមួយរូបធ្វើមរណកាល ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលបើសាមណេរ (ណាមួយ) ធ្វើមរណកាលទៅហើយ ត្រូវសង្ឃជាម្ចាស់លើបាត្រនិងចីវរ (របស់សាមណេរនោះ) តែថាភិក្ខុអ្នកបម្រើជម្ងឺមានឧបការៈច្រើនជាង ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសង្ឃឲ្យចីវរនិងបាត្រដល់ពួកភិក្ខុអ្នកបម្រើជម្ងឺ ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យយ៉ាងនេះ ។ ភិក្ខុអ្នកបម្រើជម្ងឺនោះត្រូវចូលទៅរកសង្ឃហើយនិយាយយ៉ាងនេះនឹងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សាមណេរឈ្មោះនេះធ្វើមរណកាលទៅហើយ ចីវរនិងបាត្រនេះជារបស់សាមណេរនោះ ។ ភិក្ខុដែលឈ្លាសប្រតិពលត្រូវផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ សាមណេរឈ្មោះនេះធ្វើមរណកាលទៅហើយ ចីវរនិងបាត្រនេះជារបស់សាមណេរនោះ ។ បើការឲ្យចីវរនិងបាត្រមានកាលសមគួរដល់សង្ឃហើយ សង្ឃត្រូវឲ្យចីវរនិងបាត្រនេះដល់ពួកភិក្ខុអ្នកបម្រើជម្ងឺចុះ ។ នេះជាពាក្យផ្តៀងសង្ឃ ។

សុណាតុ មេ ភន្តេ សង្ឃោ ឥត្ថន្នាមោ សាមណេរោ កាលកតោ ឥទំ តស្ស ចីវរញ្ច បត្តោ ច ។ សង្ឃោ ឥមំ ចីវរញ្ច បត្តញ្ច គិលានុបដ្ឋាកានំ ទេតិ ។ យស្សាយស្មតោ ខមតិ ឥមស្ស ចីវរស្ស ច បត្តស្ស ច គិលានុបដ្ឋាកានំ ទានំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទិន្នំ ឥទំ សង្ឃេន ចីវរញ្ច បត្តោ ច គិលានុបដ្ឋាកានំ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ ច សាមណេរោ ច គិលានំ ឧបដ្ឋហិំសុ ។ សោ តេហិ ឧបដ្ឋហិយមានោ កាលមកាសិ ។ អថខោ តស្ស គិលានុបដ្ឋាកស្ស ភិក្ខុនោ ឯតទហោសិ កថំ នុ ខោ គិលានុបដ្ឋាកស្ស សាមណេរស្ស ចីវរប្បដិវីសោ ទាតព្វោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ គិលានុបដ្ឋាកស្ស សាមណេរស្ស សមកំ បដិវីសំ ទាតុន្តិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ ពហុភណ្ឌោ ពហុបរិក្ខារោ



បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ ។ សាមណេរឈ្មោះនេះធ្វើមរណកាលទៅហើយ ចីវរនិងបាត្រនេះជារបស់សាមណេរនោះ ។ ឥឡូវសង្ឃឲ្យចីវរនិងបាត្រនេះដល់ពួកភិក្ខុអ្នកបម្រើជម្ងឺហើយ ។ ការឲ្យចីវរនិងបាត្រដល់ពួកភិក្ខុអ្នកបម្រើជម្ងឺនេះ (បើ) គាប់ចិត្តដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម (បើ) មិនគាប់ចិត្តដល់លោកដ៏មានអាយុអង្គណាទេ ត្រូវលោកដ៏មានអាយុអង្គនោះនិយាយឡើង ។ ចីវរនិងបាត្រនេះសង្ឃបានឲ្យដល់ពួកភិក្ខុអ្នកបម្រើជម្ងឺហើយ ។ ការឲ្យចីវរនិងបាត្រដល់ពួកភិក្ខុអ្នកបម្រើជម្ងឺ ត្រូវហើយជាគាប់ចិត្តដល់សង្ឃហើយ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុករឿងនេះដោយការស្ងៀមនៅយ៉ាងនេះ ។ សម័យនោះឯង មានភិក្ខុ១រូបនឹងសាមណេរ១រូបបម្រើភិក្ខុឈឺ ។ កាលបើភិក្ខុនឹងសាមណេរទាំងនោះកំពុងបម្រើ ភិក្ខុឈឺនោះក៏ធ្វើមរណកាលទៅ ។ ឯភិក្ខុអ្នកបម្រើជម្ងឺនោះក៏មានសេចក្តីត្រិះរិះថា គួរអញត្រូវឲ្យចំណែកចីវរទៅសាមណេរដែលជាអ្នកបម្រើជម្ងឺដែរឬ ។ ភិក្ខុទាំងឡាយក៏ក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឲ្យចំណែកស្មើគ្នាទៅសាមណេរដែលជាអ្នកបម្រើជម្ងឺផង ។ សម័យនោះឯង មានភិក្ខុ១រូបមានទ្រព្យច្រើន មានបរិក្ខារច្រើន

កាលកតោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោ-
ចេសុំ ។ ភិក្ខុស្ស ភិក្ខវេ កាលកតេ សង្ឃោ
សាមី បត្តចីវរេ អបិច គិលានុបដ្ឋាកា ពហូបការា ។
អនុជានាមិ ភិក្ខវេ សង្ឃេន តិចីវរញ្ច បត្តញ្ច គិលា-
នុបដ្ឋាកានំ ទាតុំ ។ យំ តត្ថ លហុភណ្ឌំ លហុបរិក្ខារំ
តំ សម្មុខីភូតេន សង្ឃេន ភាជេតុំ ។ យំ តត្ថ គរុភណ្ឌំ
គរុបរិក្ខារំ តំ អាគតានាគតស្ស ចាតុទ្ទិសស្ស សង្ឃស្ស
អវិស្សជ្ជិកំ អវេភង្គិកន្តិ ។

[៧៤] តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ
នគ្គោ ហុត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា
ភគវន្តំ ឯតទវោច ភគវា ភន្តេ អនេកបរិយាយេន
អប្បិច្ឆស្ស សន្តុដ្ឋស្ស សល្លេខស្ស ធុតស្ស បាសាទិ-
កស្ស អបចយស្ស វីរិយារម្ភស្ស វណ្ណវាទី ឥទំ ភន្តេ



ធ្វើមរណកាលទៅ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះ
មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើមានភិក្ខុ
(ណាមួយ) ធ្វើមរណកាលទៅហើយ ត្រូវសង្ឃជាម្ចាស់លើបាត្រនិងចីវរ
(របស់ភិក្ខុនោះ) តែថា ពួកភិក្ខុអ្នកបម្រើមានឧបការៈច្រើនជាងគេ ។
ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសង្ឃឲ្យត្រៃចីវរនិងបាត្រដល់ពួក
ភិក្ខុអ្នកបម្រើភិក្ខុឈឺ ។ បើមានវត្ថុណាមួយជាគ្រឿងលហុភណ្ឌ(១) ឬជាគ្រឿង
លហុបរិក្ខារ(២) នៅក្នុងទីនោះ តថាគតអនុញ្ញាតឲ្យសង្ឃដែលមានក្នុងទី
ចំពោះមុខ ( ព្រមព្រៀង ) ចែកគ្រឿងលហុភណ្ឌនិងគ្រឿងលហុប-
រិក្ខារនោះចុះ ។ បើមានគ្រឿងគរុភណ្ឌឬគ្រឿងគរុបរិក្ខារណា នៅក្នុងទីនោះ
គ្រឿងគរុភណ្ឌនិងគ្រឿងគរុបរិក្ខារនោះ ត្រូវទុកសម្រាប់សង្ឃដែលមកក្តី
មិនទាន់បានមកក្តីអំពីទិសទាំង៤ ភិក្ខុមិនត្រូវលះ មិនត្រូវចែកគ្នាទេ ។

(៧៤) សម័យនោះឯង មានភិក្ខុ១រូបមានកាយអាក្រាតហើយ
ចូលទៅកាន់សំណាក់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយក៏ក្រាប
បង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ព្រះអង្គ
តែងទ្រង់សរសើរគុណរបស់បុគ្គលអ្នកប្រាថ្នាតិច មានចិត្តសន្តោស មាន
ចិត្តខ្ជាប់ខ្ជួន កំចាត់បង់កិលេស នាំឲ្យកើតសេចក្តីជ្រះថ្លា មិនសន្សំកិលេស-
វដ្ត ប្រារព្ធព្យាយាម ដោយបរិយាយជាច្រើន បពិត្រព្រះអង្គដ៏ចំរើន

១-២ គឺរបស់តូចតាច ក្រៅពីគរុភណ្ឌទាំង ២៥ ។

នគ្គិយំ អនេកបរិយាយេន អប្បិច្ឆតាយ សន្តុដ្ឋតាយ សល្លេខាយ ធុតត្តាយ បាសាទិកតាយ អបចយាយ វីរិយារម្ភាយ សំវត្តតិ ហន្ទ ភន្តេ ភគវា ភិក្ខូនំ នគ្គិយំ អនុជានាតូតិ ។ វិគរហិ ពុទ្ធោ ភគវា អននុច្ឆវិកំ មោឃបុរិស ។ បេ ។ កថំ ហិ នាម ត្វំ មោឃបុរិស នគ្គិយំ តិត្ថិយសមាទានំ សមាទិយិស្សសិ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ ។ បេ ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ ន ភិក្ខវេ នគ្គិយំ តិត្ថិយសមាទានំ សមាទិយិតព្វំ យោ សមាទិយេយ្យ អាបត្តិ ថុល្លច្ចយស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ កុសចីរំ និវាសេត្វា ។ បេ ។ វាកចីរំ និវាសេត្វា ។ បេ ។ ផលកចីរំ និវាសេត្វា ។ បេ ។ កេសកម្ពលំ និវាសេត្វា ។ បេ ។ វាលកម្ពលំ និវាសេត្វា ។ បេ ។ ឧលូកបក្ខំ និវាសេត្វា ។ បេ ។



ការអាក្រាតនេះនាំឲ្យមានសេចក្តីប្រាថ្នាតិច សេចក្តីសន្តោស សេចក្តីខ្ជះផង់ គំពាក់បង់កិលេស នាំឲ្យកើតសេចក្តីជ្រះថ្លា មិនសន្សំកិលេសផ្ទុះ និងនាំឲ្យមានសេចក្តីប្រារព្ធព្យាយាម ដោយបរិយាយជាច្រើន បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគទ្រង់អនុញ្ញាតការអាក្រាតដល់ពួកភិក្ខុជាការស្រួលពេកណាស់ ។ ព្រះពុទ្ធមានព្រះភាគបន្ទោសថា នែមោឃបុរស អំពើនេះមិនសមគួរទេ ។ បេ ។ ម្នាលមោឃបុរស អ្នកមិនសមបើនឹងសមាទានខ្លួនការអាក្រាតជាតិត្ថិយសមាទាន[១] (ដូច្នេះ) សោះ ម្នាលមោឃបុរស អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ទ្រង់បន្ទោសហើយទ្រង់ធ្វើធម្មីកថាប្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ការអាក្រាតជាតិត្ថិយសមាទាន ភិក្ខុមិនត្រូវសមាទានទេ ភិក្ខុណាសមាទាន ត្រូវអាបត្តិថុល្លច្ច័យ ។ សម័យនោះឯងមានភិក្ខុ ១ រូបស្លៀកសំពត់ដែលគេធ្វើពីស្បូវក្បាំង ។ បេ ។ ស្លៀកសំពត់ដែលគេធ្វើពីសម្បកឈើ ។ បេ ។ ស្លៀកសំពត់ដែលគេធ្វើពីផែនក្តារ ។ បេ ។ ស្លៀកសំពត់កម្ពលដែលគេធ្វើពីសក់ ។ បេ ។ ស្លៀកសំពត់កម្ពលដែលគេធ្វើពីរោមកន្ទុយសត្វ ។ បេ ។ ស្លៀកសំពត់ដែលគេធ្វើពីស្លាបមៀម ។ បេ ។

១ ទ្រង់ហាមព្រោះធ្វើប្រព្រឹត្តដូចពួកតិត្ថិយ ព្រោះតិត្ថិយខ្លះអាក្រាតកាយមិនស្លៀកសំពត់ មិនដណ្តប់សំពត់ ។

អជិនក្ខិបំ និក្ខិបេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ ឯតទវោច ភគវា អនេកបរិយាយេន អប្បិច្ឆស្ស សន្តុដ្ឋស្ស សល្លេខស្ស ធុតស្ស បាសាទិកស្ស អបចយស្ស វីរិយារម្ភស្ស វណ្ណវាទី ឥទំ ភន្តេ អជិនក្ខិបំ អនេកបរិយាយេន អប្បិច្ឆតាយ សន្តុដ្ឋតាយ សល្លេខាយ ធុតតាយ បាសាទិកតាយ អបចយាយ វីរិយារម្ភាយ សំវត្តតិ សាធុ ភន្តេ ភគវា ភិក្ខូនំ អជិនក្ខិបំ អនុជានាតូតិ ។ វិគរហិ ពុទ្ធោ ភគវា អននុច្ឆវិកំ មោឃបុរិស ។បេ។ កថំ ហិ នាម ត្វំ មោឃបុរិស អជិនក្ខិបំ តិត្ថិយធជំ ធារេស្សសិ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ ។បេ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ ន ភិក្ខវេ អជិនក្ខិបំ តិត្ថិយធជំ ធារេតព្វំ យោ ធារេយ្យ អាបត្តិ ថុល្លច្ចយស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ អក្កនាលំ និវាសេត្វា ។បេ។



ស្លៀកសំពត់ដែលគេធ្វើពីស្បែកខ្លា ហើយចូលទៅគាល់សំណាក់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបបង្គំទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ព្រះអង្គតែងទ្រង់សរសើរគុណរបស់បុគ្គលអ្នកប្រាថ្នាតិច មានចិត្តសន្ដោស មានចិត្តផូរផង់ កំចាត់បង់កិលេស នាំឲ្យកើតសេចក្ដីជ្រះថ្លា មិនសន្សំកិលេសវដ្ដៈ ប្រារព្ធព្យាយាម ដោយបរិយាយជាច្រើន បពិត្រព្រះអង្គដ៏ចំរើន ស្បែកខ្លានេះនាំឲ្យមានសេចក្ដីប្រាថ្នាតិច សេចក្ដីសន្ដោស សេចក្ដីផូរផង់ កំចាត់បង់កិលេស នាំឲ្យកើតសេចក្ដីជ្រះថ្លា មិនសន្សំកិលេសវដ្ដៈ និងនាំឲ្យមានសេចក្ដីប្រារព្ធព្យាយាម ដោយបរិយាយជាច្រើន បពិត្រព្រះអង្គដ៏ចំរើន សូមព្រះអង្គទ្រង់អនុញ្ញាតឲ្យពួកភិក្ខុស្លៀកសណ្ដប់សំពត់ស្បែកខ្លា ជាការប្រសើរពេកណាស់ ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលមោឃបុរស អំពើនេះមិនសមទេ ។បេ។ ម្នាលមោឃបុរស អ្នកមិនសមបើនឹងទ្រទ្រង់សំពត់ស្បែកខ្លាជាទង់ជ័យនៃតិរ្ថិយទេ ម្នាលមោឃបុរស អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ទ្រង់បន្ទោសរួចទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទ្រទ្រង់ស្បែកខ្លាជាទង់ជ័យរបស់តិរ្ថិយទេ ភិក្ខុណាទ្រទ្រង់ ត្រូវអាបត្តិថុល្លច្ច័យ ។ សម័យនោះឯង មានភិក្ខុ ១ រូប ស្លៀកសំពត់ដែលគេធ្វើពីដើមរក់ ។បេ។

ពោត្ថកំ និវាសេត្វា យេន ភគវា តេនុបសង្កមិ, ឧបសង្កមិត្វា ភគវន្តំ ឯតទវោច ភគវា ភន្តេ អនេកបរិយាយេន អប្បិច្ឆស្ស សន្តុដ្ឋស្ស សល្លេខស្ស ធុតស្ស បាសាទិកស្ស អបចយស្ស វីរិយារម្ភស្ស វណ្ណវាទី អយំ ភន្តេ ពោត្ថកោ អនេកបរិយាយេន អប្បិច្ឆតាយ សន្តុដ្ឋតាយ សល្លេខាយ ធុតតាយ បាសាទិកតាយ អបចយាយ វីរិយារម្ភាយ សំវត្តតិ សាធុ ភន្តេ ភគវា ភិក្ខូនំ ពោត្ថកំ អនុជានាតុ ។ វិគរហិ ពុទ្ធោ ភគវា អននុច្ឆវិកំ មោឃបុរិស ។បេ។ កថំ ហិ នាម ត្វំ មោឃបុរិស ពោត្ថកំ និវាសេស្សសិ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ ។បេ។ វិគរហិត្វា ធម្មិំ កថំ កត្វា ភិក្ខូ អាមន្តេសិ ន ភិក្ខវេ ពោត្ថកោ និវាសេតព្វោ យោ និវាសេយ្យ អាបត្តិ ទុក្កដស្សាតិ ។



ស្លៀកសំពត់ដែលគេធ្វើពីសម្បកព្រលៅ ហើយចូលទៅគាល់សំណាក់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ព្រះអង្គតែងទ្រង់សរសើរគុណរបស់បុគ្គលអ្នកមានសេចក្តីប្រាថ្នាតិច មានចិត្តសន្តោស មានចិត្តផូរផង់ កំចាត់បង់កិលេស នាំឲ្យកើតសេចក្តីជ្រះថ្លា មិនសន្សំកិលេសផ្គះ ប្រារព្ធព្យាយាម ដោយបរិយាយជាច្រើន បពិត្រព្រះអង្គដ៏ចំរើន សំពត់សម្បកព្រលៅនេះនាំឲ្យមានសេចក្តីប្រាថ្នាតិច សេចក្តីសន្តោស សេចក្តីផូរផង់ កំចាត់បង់កិលេស នាំឲ្យកើតសេចក្តីជ្រះថ្លា មិនសន្សំកិលេសផ្គះ និងនាំឲ្យមានសេចក្តីប្រារព្ធព្យាយាម ដោយបរិយាយជាច្រើន បពិត្រព្រះអង្គដ៏ចំរើន សូមព្រះអង្គទ្រង់អនុញ្ញាតឲ្យពួកភិក្ខុ (ទ្រទ្រង់) សំពត់សម្បកព្រលៅ ជាការប្រសើរពេកណាស់ ។ ព្រះពុទ្ធមានព្រះភាគទ្រង់បន្ទោសថា ម្នាលមោឃបុរស អំពើនេះមិនសមទេ ។បេ។ ម្នាលមោឃបុរស អ្នកមិនសមបើនឹងស្លៀកសំពត់សម្បកព្រលៅនោះ ម្នាលមោឃបុរស អំពើនេះមិនមែននាំពួកជនដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើងទេ ។បេ។ ទ្រង់បន្ទោសហើយទ្រង់ធ្វើធម្មីកថាត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវស្លៀកសំពត់សម្បកព្រលៅទេ ភិក្ខុណាស្លៀក ត្រូវអាបត្តិទុក្កដ ។

[៣៥៨] តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ សព្វនីលកានិ ចីវរានិ ធារេន្តិ សព្វបីតកានិ ចីវរានិ ធារេន្តិ សព្វលោហិតកានិ ចីវរានិ ធារេន្តិ សព្វមញ្ជេដ្ឋកានិ ចីវរានិ ធារេន្តិ សព្វកណ្ហានិ ចីវរានិ ធារេន្តិ សព្វមហារង្គរត្តានិ ចីវរានិ ធារេន្តិ សព្វមហានាមរត្តានិ ចីវរានិ ធារេន្តិ អច្ឆិន្នទសានិ ចីវរានិ ធារេន្តិ ទីឃទសានិ ចីវរានិ ធារេន្តិ បុប្ផទសានិ ចីវរានិ ធារេន្តិ ផលទសានិ(១) ចីវរានិ ធារេន្តិ កញ្ចុកំ ធារេន្តិ តិរីដកំ ធារេន្តិ វេឋនំ ធារេន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ សេយ្យថាបិ គិហី កាមភោគិនោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ សព្វនីលកានិ ចីវរានិ ធារេតព្វានិ ន សព្វបីតកានិ ចីវរានិ ធារេតព្វានិ ន សព្វលោហិតកានិ ចីវរានិ ធារេតព្វានិ ន សព្វមញ្ជេដ្ឋកានិ ចីវរានិ ធារេតព្វានិ ន សព្វកណ្ហានិ ចីវរានិ ធារេតព្វានិ ន សព្វមហារង្គរត្តានិ ចីវរានិ ធារេតព្វានិ

១ ផលកទសានិ ។ បោត្ថកេ ទិស្សតិ ។





[៣៥៨] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុទ្រទ្រង់(១) ចីវរខៀវសុទ្ធ ទ្រទ្រង់ចីវរលឿងសុទ្ធ ទ្រទ្រង់ចីវរក្រហមសុទ្ធ ទ្រទ្រង់ចីវរពណ៌ហង្សបាទសុទ្ធ ទ្រទ្រង់ចីវរខ្មៅសុទ្ធ ទ្រទ្រង់ចីវរក្រហមក្រមៅសុទ្ធ (ពណ៌ខ្ទឹក្ដួច) ទ្រទ្រង់ចីវរលឿងទុំសុទ្ធ (ពណ៌ដូចផ្កាឈូក) ទ្រទ្រង់ចីវរមានជាយមិនបានកាត់ចេញ ទ្រទ្រង់ចីវរមានជាយវែង ទ្រទ្រង់ចីវរមានជាយជាផ្កាឈើ ទ្រទ្រង់ចីវរមានជាយជាផ្លែឈើ ទ្រទ្រង់អាវ ទ្រទ្រង់មួក ទ្រទ្រង់សំពត់ឈ្នួត ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្ទុះបង្អាប់ថា ដូចជាពួកគ្រហស្ថអ្នកបរិភោគកាម ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្ដីនុះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទ្រទ្រង់ចីវរខៀវសុទ្ធ មិនត្រូវទ្រទ្រង់ចីវរលឿងសុទ្ធ មិនត្រូវទ្រទ្រង់ចីវរក្រហមសុទ្ធ មិនត្រូវទ្រទ្រង់ចីវរពណ៌ហង្សបាទសុទ្ធ មិនត្រូវទ្រទ្រង់ចីវរខ្មៅសុទ្ធ មិនត្រូវទ្រទ្រង់ចីវរក្រហមក្រមៅសុទ្ធ

១ នេះជាពាក្យសាធារណៈ នឹងហៅថាស្លៀកឬហៅថាដណ្ដប់ឬហៅថា ពាក់ក៏តាមគួរជាដើម ក៏បាន ហៅតាមសមគួរដល់របស់ដែលត្រូវប្រើប្រាស់ ។

ន សព្វមហានាមរត្តានិ ចីវរានិ ធារេតព្វានិ ន អច្ឆិន្ន-
ទសានិ ចីវរានិ ធារេតព្វានិ ន ទីឃទសានិ ចីវរានិ
ធារេតព្វានិ ន បុប្ផទសានិ ចីវរានិ ធារេតព្វានិ ន ផណ-
ទសានិ ចីវរានិ ធារេតព្វានិ ន កញ្ចុកំ ធារេតព្វំ ន
តិរីដកំ ធារេតព្វំ ន វេឋនំ ធារេតព្វំ យោ ធារេយ្យ
អាបត្តិ ទុក្កដស្សាតិ ។

[៧៦] តេន ខោ បន សមយេន វស្សំវុដ្ឋា ភិក្ខូ
អនុប្បន្នេ ចីវរេ បក្កមន្តិបិ វិព្ភមន្តិបិ កាលំបិ ករោន្តិ
សាមណេរាបិ បដិជានន្តិ សិក្ខំ បច្ចក្ខាតកាបិ បដិ-
ជានន្តិ អន្តិមវត្ថុំ អជ្ឈាបន្នកាបិ បដិជានន្តិ ឧម្មត្តកា-
បិ បដិជានន្តិ ខិត្តចិត្តាបិ បដិជានន្តិ វេទនដ្ដាបិ បដិ-
ជានន្តិ អាបត្តិយា អទស្សនេ ឧក្ខិត្តកាបិ បដិជានន្តិ
អាបត្តិយា អប្បដិកម្មេ ឧក្ខិត្តកាបិ បដិជានន្តិ បា-
បិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខិត្តកាបិ បដិជា-
នន្តិ បណ្ឌកាបិ បដិជានន្តិ ថេយ្យសំវាសកាបិ បដិ-
ជានន្តិ តិត្ថិយបក្កន្តកាបិ បដិជានន្តិ តិរច្ឆានគតាបិ
បដិជានន្តិ មាតុឃាតកាបិ បដិជានន្តិ បិតុឃាតកាបិ



មិនត្រូវទ្រទ្រង់ចីវរពេលៀងទុំស្រស់ មិនត្រូវទ្រទ្រង់ចីវរមានជាយមិនបានកាត់
ចេញ មិនត្រូវទ្រទ្រង់ចីវរមានជាយវែង មិនត្រូវទ្រទ្រង់ចីវរមានជាយជា
ផ្កាឈើ មិនត្រូវទ្រទ្រង់ចីវរមានជាយជាផ្លែឈើ មិនត្រូវទ្រទ្រង់អាវ មិន
ត្រូវទ្រទ្រង់ធ្នង់មួក មិនត្រូវទ្រទ្រង់សំពត់ឈ្នួត ភិក្ខុណាទ្រទ្រង់ត្រូវអាបត្តិ
ទុក្កដ ។

[៧៦] សម័យនោះឯង ភិក្ខុទាំងឡាយនៅចាំវស្សារួចហើយ តែចីវរ
មិនទាន់កើតឡើង[១] ក៏នាំគ្នាចៀសចេញទៅខ្លះ សឹកចេញទៅខ្លះ ស្លាប់ទៅ
ខ្លះ ប្តេជ្ញាខ្លួនជាសាមណេរខ្លះ ប្តេជ្ញាខ្លួនជាបុគ្គលពោលលាសិក្ខាខ្លះ ប្តេជ្ញា
ខ្លួនជាបុគ្គលត្រូវអន្តិមវត្ថុខ្លះ ប្តេជ្ញាខ្លួនជាបុគ្គលឆ្កួតខ្លះ ប្តេជ្ញាខ្លួនជាបុគ្គល
មានចិត្តរវើរវាយខ្លះ ប្តេជ្ញាខ្លួនជាបុគ្គលដែលវេទនាគ្របសង្កត់ខ្លះ ប្តេជ្ញា
ខ្លួនជាបុគ្គលដែលសង្ឃលើកវត្តព្រោះមិនឃើញអាបត្តិខ្លះ ប្តេជ្ញាខ្លួនជាបុគ្គល
ដែលសង្ឃលើកវត្តព្រោះមិនបានសំដែងអាបត្តិខ្លះ ប្តេជ្ញាខ្លួនជាបុគ្គលដែលសង្ឃ
លើកវត្តព្រោះមិនបានលះបង់ទិដ្ឋិអាក្រក់ខ្លះ ប្តេជ្ញាខ្លួនជាខ្ទើយខ្លះ ប្តេជ្ញា
ខ្លួនជាមនុស្សលួចសំវាសខ្លះ ប្តេជ្ញាខ្លួនជាអ្នកចូលពួកតិរ្ថិយខ្លះ ប្តេជ្ញាខ្លួនជាសត្វ
តិរច្ឆានខ្លះ ប្តេជ្ញាខ្លួនជាអ្នកសម្លាប់មាតាខ្លះ ប្តេជ្ញាខ្លួនជាអ្នកសម្លាប់បិតាខ្លះ

១ បានសេចក្តីថា ភិក្ខុទាំងនោះនៅចាំវស្សារួចហើយ មិនទាន់បានចីវរកឋិននៅឡើយ ។

បដិជានន្តិ អរហន្តឃាតកោបិ បដិជានន្តិ ភិក្ខុនិទូសកោបិ បដិជានន្តិ សង្ឃភេទកោបិ បដិជានន្តិ លោហិតុប្បាទកោបិ បដិជានន្តិ ឧភតោព្យញ្ជនកោបិ បដិជានន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ឥធ បន ភិក្ខវេ វស្សំ វុត្ថោ ភិក្ខុ អនុប្បន្នេ ចីវរេ បក្កមតិ ។ សន្តេ បដិរូបេ គាហកេ ទាតព្វំ ។ ឥធ បន ភិក្ខវេ វស្សំ វុត្ថោ ភិក្ខុ អនុប្បន្នេ ចីវរេ វិព្ភមតិ កាលំ ករោតិ សាមណេរោ បដិជានាតិ សិក្ខំ បច្ចក្ខាតកោ បដិជានាតិ អន្តិមវត្ថុំ អជ្ឈាបន្នកោ បដិជានាតិ ។ សង្ឃោ សាមី ។ ឥធ បន ភិក្ខវេ វស្សំ វុត្ថោ ភិក្ខុ អនុប្បន្នេ ចីវរេ ឧម្មត្តកោ បដិជានាតិ ខិត្តចិត្តោ បដិជានាតិ វេទនាដ្ដោ បដិជានាតិ អាបត្តិយា អទស្សនេ ឧក្ខិត្តកោ បដិជានាតិ អាបត្តិយា អប្បដិកម្មេ ឧក្ខិត្តកោ បដិជានាតិ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខិត្តកោ បដិជានាតិ ។ សន្តេ បដិរូបេ គាហកេ



ប្តេជ្ញាខ្លួនជាអ្នកសម្លាប់ព្រះអរហន្តខ្លះ ប្តេជ្ញាខ្លួនជាអ្នកប្រទូស្តភិក្ខុនីខ្លះ ប្តេជ្ញាខ្លួនជាអ្នកបំបែកសង្ឃខ្លះ ប្តេជ្ញាខ្លួនជាអ្នកបង្ហូរលោហិត (ព្រះបរមគ្រូឲ្យពុះពោងឡើងខ្លះ ប្តេជ្ញាខ្លួនជាឧភតោព្យញ្ជនក (មនុស្សមានភេទពីរ) ខ្លះ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុនៅចាំវស្សារួចហើយ កាលបើចីវរមិនទាន់កើតឡើង ក៏ចៀសចេញទៅ ។ កាលបើមានភិក្ខុអ្នកទទួលយកចីវរដ៏សមគួរ សង្ឃត្រូវឲ្យចីវរ (នោះទៅ) ចុះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះបើមានភិក្ខុនៅចាំវស្សារួចហើយ កាលបើចីវរមិនទាន់កើតឡើង ក៏សឹកទៅក្តី ស្លាប់ទៅក្តី ប្តេជ្ញាខ្លួនជាសាមណេរក្តី ប្តេជ្ញាខ្លួនជាអ្នកបោលលាសិក្ខាក្តី ប្តេជ្ញាខ្លួនជាអ្នកត្រូវអន្តិមវត្ថុក្តី ។ សង្ឃត្រូវជាម្ចាស់ (ចីវរនោះឯង) ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះបើមានភិក្ខុនៅចាំវស្សារួចហើយ កាលបើចីវរមិនទាន់កើតឡើង ក៏ប្តេជ្ញាខ្លួនជាមនុស្សឆ្កួតក្តី ប្តេជ្ញាខ្លួនជាមនុស្សមានចិត្តរវើរវាយក្តី ប្តេជ្ញាខ្លួនជាមនុស្សមានវេទនាគ្របសង្កត់ក្តី ប្តេជ្ញាខ្លួនជាភិក្ខុដែលសង្ឃលើកវត្តព្រោះមិនឃើញអាបត្តិក្តី ប្តេជ្ញាខ្លួនជាភិក្ខុដែលសង្ឃលើកវត្តព្រោះមិនធ្វើសំដែងអាបត្តិក្តី ប្តេជ្ញាខ្លួនជាភិក្ខុដែលសង្ឃលើកវត្តព្រោះមិនលះបង់ទិដ្ឋិអាក្រក់ក្តី ។ កាលបើមានភិក្ខុជាអ្នកទទួលយកចីវរដ៏សមគួរ

ទាតព្វំ ។ ឥធ បន ភិក្ខវេ វស្សំវុត្ថោ ភិក្ខុ អនុប្បន្នេ ចីវរេ បណ្ឌកោ បដិជានាតិ ។បេ។ ឧភតោព្យញ្ជនកោ បដិជានាតិ ។ សង្ឃោ សាមី ។ ឥធ បន ភិក្ខវេ វស្សំវុត្ថោ ភិក្ខុ ឧប្បន្នេ ចីវរេ អភាជិតេ បក្កមតិ ។ សន្តេ បតិរូបេ គាហកេ ទាតព្វំ ។ ឥធ បន ភិក្ខវេ វស្សំវុត្ថោ ភិក្ខុ ឧប្បន្នេ ចីវរេ អភាជិតេ វិព្ភមតិ កាលំ ករោតិ សាមណេរោ បដិជានាតិ សិក្ខំ បច្ចក្ខាតកោ បដិជានាតិ អន្តិមវត្ថុំ អជ្ឈាបន្នកោ បដិជានាតិ ។ សង្ឃោ សាមី ។ ឥធ បន ភិក្ខវេ វស្សំវុត្ថោ ភិក្ខុ ឧប្បន្នេ ចីវរេ អភាជិតេ ឧម្មត្តកោ បដិជានាតិ ខិត្តចិត្តោ បដិជានាតិ វេទនដ្ដោ បដិជានាតិ អាបត្តិយា អទស្សនេ ឧក្ខិត្តកោ បដិជានាតិ អាបត្តិយា អប្បដិកម្មេ ឧក្ខិត្តកោ បដិជានាតិ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខិត្តកោ បដិជានាតិ ។



ត្រូវសង្ឃឲ្យចីវរ (នោះទៅ) ចុះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះបើមានភិក្ខុនៅចាំវស្សារួចហើយ កាលបើចីវរមិនទាន់កើតឡើងក៏ប្តេជ្ញាខ្លួនជាមនុស្សខ្ទើយក្តី ។បេ។ ប្តេជ្ញាខ្លួនជាឧភតោព្យញ្ជនកក្តី ។ សង្ឃត្រូវជាម្ចាស់ (ចីវរនោះឯង) ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះបើមានភិក្ខុនៅចាំវស្សារួចហើយ កាលបើចីវរកើតឡើងហើយ តែសង្ឃមិនទាន់បានចែក ខ្លួនក៏ចៀសចេញទៅ ។ កាលបើមានភិក្ខុជាអ្នកទទួលចីវរដ៏សមគួរ ត្រូវសង្ឃឲ្យចីវរ (នោះទៅ) ចុះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះបើមានភិក្ខុនៅចាំវស្សារួចហើយ កាលបើចីវរកើតឡើងហើយ តែសង្ឃមិនទាន់បានចែក ខ្លួនក៏សឹកទៅក្តី ស្លាប់ទៅក្តី ប្តេជ្ញាខ្លួនជាសាមណេរក្តី ប្តេជ្ញាខ្លួនជាអ្នកពោលលាសិក្ខាក្តី ប្តេជ្ញាខ្លួនជាបុគ្គលត្រូវអន្តិមវត្ថុក្តី ។ សង្ឃត្រូវជាម្ចាស់ (ចីវរនោះ) ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុនៅចាំវស្សារួចហើយ កាលបើចីវរកើតឡើង តែសង្ឃមិនទាន់បានចែក ក៏ប្តេជ្ញាខ្លួនជាមនុស្សឆ្កួតក្តី ប្តេជ្ញាខ្លួនជាបុគ្គលមានចិត្តអណ្តែតអណ្តូងក្តី ប្តេជ្ញាខ្លួនជាបុគ្គលមានវេទនាគ្របសង្កត់ក្តី ប្តេជ្ញាខ្លួនជាភិក្ខុដែលសង្ឃលើកវត្តព្រោះមិនឃើញអាបត្តិក្តី ប្តេជ្ញាខ្លួនជាភិក្ខុដែលសង្ឃលើកវត្តព្រោះមិនបានសំដែងអាបត្តិក្តី ប្តេជ្ញាខ្លួនជាភិក្ខុដែលសង្ឃលើកវត្តព្រោះមិនលះបង់នូវទិដ្ឋិអាក្រក់ក្តី ។

ចិត្តយមកោ ឋិតំ ភង្គំ អនុប្បន្នវារោ

សព្វេ ចវិស្សម ការណោ ជានន្តិ ។ ឥធ បន កិច្ចេ វស្សំ ឋត្វា កិច្ចំ ឧប្បជ្ជ ចិត្ត អភាជិតេ បណ្ណាសោ បដិដាជាតិ ។ បេ ។ ខុភកោព្យញ្ជនកោ បដិជាជាតិ ។ សព្វេ សាម ។ ឥធ បន កិច្ចេ វស្សំ ឋិតាំ កិច្ចំ អនុប្បន្នំ ចិត្តំ សព្វេ កិច្ចំ ។ តត្ថ មនុស្សា ឯកច្ចេ ចត្តា ខុទ្ទកំ ទេត្តិ ឯកច្ចេ ចត្តា ចិត្តំ ទេត្តិ សព្វស្ស ទេយ្យតិ ។ សព្វស្សេយ្យតំ ។ ឥធ បន កិច្ចេ វស្សំ ឋិតាំ កិច្ចំ អនុប្បន្នំ ចិត្តំ សព្វេ កិច្ចំ ។ តត្ថ មនុស្សា ឯកច្ចេ ចត្តា ខុទ្ទកំ ទេត្តិ ឯកច្ចេយំ ចត្តា ចិត្តំ ទេត្តិ សព្វស្ស ទេយ្យតិ ។ សព្វស្សេយ្យតំ ។ ឥធ បន កិច្ចេ វស្សំ ឋិតាំ កិច្ចំ អនុប្បន្នំ ចិត្តំ សព្វេ កិច្ចំ ។



ចិត្តយមកៈ និយាយអំពីចិត្តដែលមិនទាន់កើតឡើងនិងចិត្តដែលនៅតាំងស្ថិតហើយ

កាលបើមានកិច្ចជាអ្នកទទួលបដិសន្ធិសមង្គី (គ្រប់សត្វទាំងឡាយ(នោះ)ទុះ ។ ម្នាលភិក្ខុទាំងឡាយ គួរសាសនានេះបើមានកិច្ចនៅតាំងស្ថិតហើយ កាលបើចិត្តកើតឡើងហើយ តែសត្វមិនទាន់បានតែក កំរោជាខ្នងជា មនុស្សត្រើយក្តី ។ បេ ។ ខ្លះជាខ្នងជាកោព្យញ្ជនកក្តី ។ សត្វត្រូវជាម្ចាស់(ចិត្តនោះឯង) ។ ម្នាលភិក្ខុទាំងឡាយ គួរសាសនានេះ បើមានពួកកិច្ចនៅតាំងស្ថិតហើយ កាលបើចិត្តមិនទាន់កើតឡើង សត្វក៏បែកធ្លាយទៅ[១] ។ មនុស្សទាំងឡាយគួរតែនោះក៏នាំគ្នាប្រគេនទឹកចំពោះភិក្ខុមួយពួក ប្រគេនចីវរចំពោះភិក្ខុមួយពួក ដោយពាក្យថា យើងទាំងឡាយប្រគេនចំពោះសង្ឃ ។ ទឹកនិងចីវរនេះក៏នៅជារបស់សង្ឃដដែល ។ ម្នាលភិក្ខុទាំងឡាយ គួរសាសនានេះ បើមានពួកភិក្ខុនៅតាំងស្ថិតហើយ កាលបើចិត្តមិនទាន់កើតឡើង សត្វក៏បែកធ្លាយទៅ ។ មនុស្សទាំងឡាយគួរតែនោះក៏នាំគ្នាប្រគេនទឹកចំពោះភិក្ខុមួយពួក ប្រគេនចីវរចំពោះភិក្ខុមួយពួក ដោយពាក្យថា យើងទាំងឡាយប្រគេនចំពោះសង្ឃ ។ ទឹកនិងចីវរនេះក៏នៅជារបស់សង្ឃដដែល ។ ម្នាលភិក្ខុទាំងឡាយ គួរសាសនានេះ បើមានពួកភិក្ខុនៅតាំងស្ថិតហើយ កាលបើចិត្តមិនទាន់កើតឡើង សត្វក៏បែកធ្លាយទៅ ។

១ សង្ឃបែកធ្លាយពីរពួក ខ្ទង់ភ្នាក់ភិក្ខុនៅក្រុងកោសម្ពី (អដ្ឋកថា) ។

តត្ថ មនុស្សា ឯកស្មឹ បក្ខេ ឧទកំ ទេន្តិ ឯកស្មឹ បក្ខេ ចីវរំ ទេន្តិ បក្ខស្ស ទេមាតិ ។ បក្ខស្សេវេតំ ។ ឥធ បន ភិក្ខវេ វស្សំ វុត្ថានំ ភិក្ខូនំ អនុប្បន្នេ ចីវរេ សង្ឃោ ភិជ្ជតិ ។ តត្ថ មនុស្សា ឯកស្មឹ បក្ខេ ឧទកំ ទេន្តិ តស្មឹយេវ បក្ខេ ចីវរំ ទេន្តិ បក្ខស្ស ទេមាតិ ។ បក្ខស្សេវេតំ ។ ឥធ បន ភិក្ខវេ វស្សំ វុត្ថានំ ភិក្ខូនំ ឧប្បន្នេ ចីវរេ អភាជិតេ សង្ឃោ ភិជ្ជតិ ។ សព្ពេសំ សមកំ ភាជេតព្ពន្តិ ។

[៨៩] តេន ខោ បន សមយេន អាយស្មា រេវតោ អញ្ញតរស្ស ភិក្ខុនោ ហត្ថេ អាយស្មតោ សារិបុត្តស្ស ចីវរំ បាហេសិ ឥមំ ចីវរំ ថេរស្ស ទេហីតិ ។ អថ ខោ សោ ភិក្ខុ អន្តរាមគ្គេ អាយស្មតោ រេវតស្ស វិស្សាសា តំ ចីវរំ អគ្គហេសិ ។ អថ ខោ អាយស្មា រេវតោ អាយស្មតា សារិបុត្តេន សមាគន្ត្វា បុច្ឆិ អហំ ភន្តេ



មនុស្សទាំងឡាយក្នុងទីនោះក៏នាំគ្នាប្រគេនទឹកចំពោះភិក្ខុមួយពួក ប្រគេនចីវរចំពោះភិក្ខុមួយពួក ដោយពាក្យថា យើងទាំងឡាយប្រគេនចំពោះពួក ។ ទឹកនិងចីវរនេះក៏នៅជារបស់ពួកដដែល ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានពួកភិក្ខុនៅចាំវស្សារួចហើយ កាលបើចីវរមិនទាន់កើតឡើង សង្ឃក៏បែកគ្នាទៅ ។ មនុស្សទាំងឡាយក្នុងទីនោះក៏នាំគ្នាប្រគេនទឹកចំពោះភិក្ខុមួយពួក ប្រគេនចីវរចំពោះភិក្ខុមួយពួកនោះឯង ដោយពាក្យថា យើងទាំងឡាយប្រគេនចំពោះពួក ។ ទឹកនិងចីវរនេះក៏នៅជារបស់ពួកដដែល ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានពួកភិក្ខុនៅចាំវស្សារួចហើយ កាលបើចីវរកើតឡើងហើយ តែសង្ឃមិនទាន់ចែក សង្ឃក៏បែកគ្នាទៅ ។ ចីវរនោះ សង្ឃត្រូវចែកដល់ពួកភិក្ខុទាំងអស់ឲ្យស្មើគ្នា ។

[៨៩] សម័យនោះឯង ព្រះរេវតដ៏មានអាយុបានផ្ញើចីវរទៅប្រគេនព្រះសារីបុត្តដ៏មានអាយុនឹងដៃភិក្ខុ ១ រូប ដោយពាក្យថា ចូរលោកប្រគេនចីវរនេះដល់ព្រះថេរៈផងចុះ ។ គ្រានោះឯង លុះដល់ពាក់កណ្តាលផ្លូវ ភិក្ខុនោះក៏យកចីវរនោះ (មកប្រើប្រាស់ជារបស់ខ្លួនវិញ) ដោយការស្និទ្ធស្នាលនឹងព្រះរេវតដ៏មានអាយុ ។ គ្រាក្រោយ ព្រះរេវតដ៏មានអាយុបានមកជួបនឹងព្រះសារីបុត្តដ៏មានអាយុហើយសួរថា បពិត្រព្រះថេរៈដ៏ចំរើន

ថេរស្ស ចីវរំ បាហេសិ សម្បត្តំ តំ ចីវរន្តិ ។ នាហំ អាវុសោ ចីវរំ បស្សាមីតិ ។ អថខោ អាយស្មា រេវតោ តំ ភិក្ខុំ ឯតទវោច អហំ អាវុសោ អាយស្មតោ ហត្ថេ ថេរស្ស ចីវរំ បាហេសឹ កហន្តំ ចីវរន្តិ ។ អហំ ភន្តេ អាយស្មតោ វិស្សាសា តំ ចីវរំ អត្តនោ អកាសិន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ឥធ បន ភិក្ខវេ ភិក្ខុ ភិក្ខុស្ស ហត្ថេ ចីវរំ បហិណតិ ឥមំ ចីវរំ ឥត្ថន្នាមស្ស ទេហីតិ ។ សោ អន្តរាមគ្គេ យោ បហិណតិ តស្ស វិស្សាសំ គណ្ហាតិ សុគ្គហិតំ ។ យស្ស បហីយតិ តស្ស វិស្សាសំ គណ្ហាតិ ទុគ្គហិតំ ។ ឥធ បន ភិក្ខវេ ភិក្ខុ ភិក្ខុស្ស ហត្ថេ ចីវរំ បហិណតិ ឥមំ ចីវរំ ឥត្ថន្នាមស្ស ទេហីតិ ។



ខ្ញុំករុណាបានផ្ញើចីវរមកប្រគេនព្រះថេរៈ តើចីវរនោះបានដល់មកហើយឬ ។ ព្រះសារីបុត្តឆ្លើយថា ម្នាលអាវុសោ ខ្ញុំមិនឃើញចីវរនោះទេ ។ ទើបព្រះរេវតៈមានអាយុបាននិយាយទៅនឹងភិក្ខុនោះថា ម្នាលអាវុសោ ខ្ញុំបានផ្ញើចីវរមកប្រគេនព្រះថេរៈនឹងដៃលោកដ៏មានអាយុ តើចីវរនោះនៅឯណា ។ ភិក្ខុនោះឆ្លើយថា បពិត្រព្រះថេរៈដ៏ចំរើន ខ្ញុំបានយកចីវរនោះ (មកប្រើប្រាស់ដោយខ្លួនឯងទៅហើយ) ដោយការសេចក្តីស្និទ្ធស្នាលនឹងលោកដ៏មានអាយុ ។ ភិក្ខុទាំងឡាយក៏ក្រាបបង្គំទូលសេចក្តីនុះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុផ្ញើចីវរទៅនឹងដៃភិក្ខុផងគ្នាដោយពាក្យថា ចូរលោកប្រគេនចីវរនេះដល់ភិក្ខុឈ្មោះនេះផង ។ លុះដល់ពាក់កណ្តាលផ្លូវ ភិក្ខុអ្នកទទួលបញ្ញើនោះក៏យកចីវរ (មកប្រើប្រាស់ដោយខ្លួនឯងវិញ) ដោយការសេចក្តីស្និទ្ធស្នាលនឹងភិក្ខុអ្នកផ្ញើនោះ (យ៉ាងនេះ) ហៅថា កាន់យកល្អ ។ បើភិក្ខុអ្នកទទួលបញ្ញើយកចីវរ (មកប្រើប្រាស់ដោយខ្លួនឯងវិញ) ដោយការសេចក្តីស្និទ្ធស្នាលនឹងភិក្ខុអ្នកត្រូវទទួលយកចីវរនោះ (យ៉ាងនេះ) ហៅថាកាន់យកមិនល្អទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះបើមានភិក្ខុផ្ញើចីវរទៅនឹងដៃភិក្ខុផងគ្នា ដោយពាក្យថា ចូរលោកប្រគេនចីវរនេះដល់ភិក្ខុឈ្មោះនេះផង ។

សោ អន្តរាមគ្គេ យស្ស បហីយតិ តស្ស វិស្សាសា គណ្ហាតិ ទុគ្គហិតំ ។ យោ បហិណាតិ តស្ស វិស្សាសា គណ្ហាតិ សុគ្គហិតំ ។ ឥធ បន ភិក្ខវេ ភិក្ខុ ភិក្ខុស្ស ហត្ថេ ចីវរំ បហិណាតិ ឥមំ ចីវរំ ឥត្ថន្នាមស្ស ទេហីតិ ។ សោ អន្តរាមគ្គេ សុណាតិ យោ បហិណាតិ សោ កាលង្កតោតិ តស្ស មតកចីវរំ អធិដ្ឋាតិ ស្វាធិដ្ឋិតំ ។ យស្ស បហីយតិ តស្ស វិស្សាសា គណ្ហាតិ ទុគ្គហិតំ ។ ឥធ បន ភិក្ខវេ ភិក្ខុ ភិក្ខុស្ស ហត្ថេ ចីវរំ បហិណាតិ ឥមំ ចីវរំ ឥត្ថន្នាមស្ស ទេហីតិ ។ សោ អន្តរាមគ្គេ សុណាតិ យស្ស បហីយតិ សោ កាលង្កតោតិ តស្ស មតកចីវរំ អធិដ្ឋាតិ ទុរធិដ្ឋិតំ ។ យោ បហិណាតិ តស្ស



លុះដល់កាក់កណ្ដាលផ្លូវ ភិក្ខុអ្នកទទួលបញ្ញើនោះក៏យកចីវរ (មកប្រើប្រាស់ដោយខ្លួនឯងវិញ) ដោយកាន់សេចក្ដីស្និទ្ធស្នាលនឹងភិក្ខុអ្នកចាំទទួលយកចីវរនោះ (យ៉ាងនេះ) ហៅថា កាន់យកមិនល្អទេ ។ បើភិក្ខុអ្នកទទួលបញ្ញើយកចីវរ (មកប្រើប្រាស់ដោយខ្លួនឯងវិញ) ដោយកាន់សេចក្ដីស្និទ្ធស្នាលនឹងភិក្ខុអ្នកផ្ញើនោះ (យ៉ាងនេះ) ហៅថា កាន់យកល្អ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ក្នុងសាសនានេះ បើមានភិក្ខុផ្ញើចីវរទៅនឹងដៃភិក្ខុឯទៀត ដោយពាក្យថា ចូរលោកប្រគេនចីវរនេះដល់ភិក្ខុឈ្មោះនេះផងចុះ ។ លុះដល់កាក់កណ្ដាលផ្លូវ ភិក្ខុអ្នកទទួលបញ្ញើនោះឮដំណឹងថា ភិក្ខុដែលផ្ញើចីវរមកនោះស្លាប់ទៅហើយ ។ ក៏អធិដ្ឋានមតកចីវរ[១]របស់ភិក្ខុអ្នកផ្ញើនោះ (យ៉ាងនេះ) ហៅថា អធិដ្ឋានល្អ ។ បើភិក្ខុអ្នកទទួលបញ្ញើយកចីវរ (មកប្រើប្រាស់ដោយខ្លួនឯងវិញ) ដោយកាន់សេចក្ដីស្និទ្ធស្នាលនឹងភិក្ខុអ្នកចាំទទួលយកចីវរនោះ (យ៉ាងនេះ) ហៅថា កាន់យកមិនល្អទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុផ្ញើចីវរទៅនឹងដៃភិក្ខុឯទៀត ដោយពាក្យថា ចូរលោកប្រគេនចីវរនេះដល់ភិក្ខុឈ្មោះនេះផងចុះ ។ លុះដល់កាក់កណ្ដាលផ្លូវ ភិក្ខុអ្នកទទួលបញ្ញើនោះឮដំណឹងថា ភិក្ខុដែលចាំទទួលចីវរនោះស្លាប់ទៅហើយ ។ ក៏អធិដ្ឋានមតកចីវររបស់ភិក្ខុនោះ (យ៉ាងនេះ) ហៅថា អធិដ្ឋានមិនល្អ (អធិដ្ឋានមិនឡើង) ។ បើភិក្ខុអ្នកទទួលបញ្ញើ

១ ចីវររបស់ភិក្ខុដែលស្លាប់ ។

វិស្សាសា គណ្ហាតិ សុគ្គហិតំ ។ ឥធ បន ភិក្ខវេ ភិក្ខុ ភិក្ខុស្ស ហត្ថេ ចីវរំ បហិណាតិ ឥមំ ចីវរំ ឥត្ថន្នាមស្ស ទេហីតិ ។ សោ អន្តរាមគ្គេ សុណាតិ ឧភោ កាលកតាតិ ។ យោ បហិណតិ តស្ស មតកចីវរំ អធិដ្ឋាតិ ស្វាធិដ្ឋិតំ ។ យស្ស បហីយតិ តស្ស មតកចីវរំ អធិដ្ឋាតិ ទុរធិដ្ឋិតំ ។ ឥធ បន ភិក្ខវេ ភិក្ខុ ភិក្ខុស្ស ហត្ថេ ចីវរំ បហិណាតិ ឥមំ ចីវរំ ឥត្ថន្នាមស្ស ទម្មីតិ ។ សោ អន្តរាមគ្គេ យោ បហិណាតិ តស្ស វិស្សាសា គណ្ហាតិ ទុគ្គហិតំ ។ យស្ស បហីយតិ តស្ស វិស្សាសា គណ្ហាតិ សុគ្គហិតំ ។ ឥធ បន ភិក្ខវេ ភិក្ខុ ភិក្ខុស្ស ហត្ថេ



យកចីវរ (មកប្រើប្រាស់ដោយខ្លួនឯងវិញ) ដោយអាងសេចក្តីស្និទ្ធស្នាលនឹងភិក្ខុអ្នកផ្ញើនោះ (យ៉ាងនេះ) ហៅថា កាន់យកល្អ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុក្នុងសាសនានេះបើមានភិក្ខុផ្ញើចីវរទៅនឹងដៃភិក្ខុឯទៀត ដោយពាក្យថា ចូរលោកប្រគេនចីវរនេះដល់ភិក្ខុឈ្មោះនេះផងចុះ ។ លុះដល់ពាក់កណ្តាលផ្លូវ ភិក្ខុអ្នកទទួលបញ្ញើនោះឮដំណឹងថា ភិក្ខុទាំងពីររូប[១]ស្លាប់ទៅហើយ ។ តាំងអធិដ្ឋានមតកចីវររបស់ភិក្ខុអ្នកផ្ញើនោះ (យ៉ាងនេះ) ហៅថា អធិដ្ឋានល្អ ។ បើភិក្ខុអ្នកទទួលបញ្ញើអធិដ្ឋានមតកចីវររបស់ភិក្ខុដែលចាំទទួលចីវរវិញ (យ៉ាងនេះ) ហៅថា អធិដ្ឋានមិនល្អទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុផ្ញើចីវរទៅនឹងដៃភិក្ខុឯទៀត ដោយពាក្យថា ខ្ញុំករុណាប្រគេនចីវរនេះដល់ភិក្ខុឈ្មោះនេះ ។ លុះដល់ពាក់កណ្តាលផ្លូវ ភិក្ខុអ្នកទទួលបញ្ញើក៏យកចីវរ (មកប្រើប្រាស់ដោយខ្លួនឯងវិញ) ដោយអាងសេចក្តីស្និទ្ធស្នាលនឹងភិក្ខុអ្នកផ្ញើនោះ (យ៉ាងនេះ) ហៅថា កាន់យកមិនល្អទេ ។ បើភិក្ខុអ្នកទទួលបញ្ញើយកចីវរ (មកប្រើប្រាស់ដោយខ្លួនឯងវិញ) ដោយអាងសេចក្តីស្និទ្ធស្នាលនឹងភិក្ខុអ្នកចាំទទួលចីវរវិញ (យ៉ាងនេះ) ហៅថា កាន់យកល្អ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុផ្ញើចីវរទៅនឹងដៃភិក្ខុឯទៀត

១ សំដៅយកភិក្ខុអ្នកផ្ញើចីវរ ១ រូប ភិក្ខុអ្នកចាំទទួលយកចីវរ ១ រូប ។

ចីវរំ បហិណាតិ ឥទំ ចីវរំ ឥត្ថន្នាមស្ស ទេហីតិ ។ សោ អន្តរាមគ្គេ យស្ស បហីយតិ តស្ស វិស្សាសា គណ្ហាតិ សុគ្គហិតំ ។ យោ បហិណាតិ តស្ស វិស្សាសា គណ្ហាតិ ទុគ្គហិតំ ។ ឥធ បន ភិក្ខវេ ភិក្ខុ ភិក្ខុស្ស ហត្ថេ ចីវរំ បហិណាតិ ឥទំ ចីវរំ ឥត្ថន្នាមស្ស ទេហីតិ ។ សោ អន្តរាមគ្គេ សុណាតិ យោ បហិណាតិ សោ កាលកតោតិ តស្ស មតកចីវរំ អធិដ្ឋាតិ ទុរធិដ្ឋិតំ ។ យស្ស បហីយតិ តស្ស វិស្សាសា គណ្ហាតិ សុគ្គហិតំ ។ ឥធ បន ភិក្ខវេ ភិក្ខុ ភិក្ខុស្ស ហត្ថេ ចីវរំ បហិណាតិ ឥទំ ចីវរំ ឥត្ថន្នាមស្ស ទេហីតិ ។ សោ អន្តរាមគ្គេ សុណាតិ យស្ស បហីយតិ សោ កាលកតោតិ តស្ស មតកចីវរំ



ដោយពាក្យថា ខ្ញុំករុណាប្រគេនចីវរនេះដល់ភិក្ខុឈ្មោះនេះ ។ លុះដល់ពាក់កណ្តាលផ្លូវ ភិក្ខុអ្នកទទួលបញ្ញើនោះក៏យកចីវរ (មកប្រើប្រាស់ដោយខ្លួនឯងវិញ) ដោយអាងសេចក្តីស្និទ្ធស្នាលនឹងភិក្ខុអ្នកចាំទទួលយកចីវរនោះ (យ៉ាងនេះ) ហៅថា កាន់យកល្អ ។ បើភិក្ខុអ្នកទទួលបញ្ញើយកចីវរ (មកប្រើប្រាស់ដោយខ្លួនឯងវិញ) ដោយអាងសេចក្តីស្និទ្ធស្នាលនឹងភិក្ខុអ្នកផ្ញើនោះ (យ៉ាងនេះ) ហៅថា កាន់យកមិនល្អទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុផ្ញើចីវរទៅនឹងដៃភិក្ខុផងគ្នា ដោយពាក្យថា ខ្ញុំករុណាប្រគេនចីវរនេះដល់ភិក្ខុឈ្មោះនេះ ។ លុះដល់ពាក់កណ្តាលផ្លូវ ភិក្ខុអ្នកទទួលបញ្ញើក៏ឮដំណឹងថា ភិក្ខុដែលផ្ញើចីវរមកនោះស្លាប់ទៅហើយ ហើយក៏អធិដ្ឋានមតកចីវររបស់ភិក្ខុអ្នកផ្ញើនោះ (យ៉ាងនេះ) ហៅថា អធិដ្ឋានមិនល្អទេ ។ បើភិក្ខុអ្នកទទួលបញ្ញើយកចីវរ (មកប្រើប្រាស់ដោយខ្លួនឯងវិញ) ដោយអាងសេចក្តីស្និទ្ធស្នាលនឹងភិក្ខុអ្នកចាំទទួលយកចីវរនោះ (យ៉ាងនេះ) ហៅថា កាន់យកល្អ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុផ្ញើចីវរទៅនឹងដៃភិក្ខុផងគ្នា ដោយពាក្យថា ខ្ញុំករុណាប្រគេនចីវរនេះដល់ភិក្ខុឈ្មោះនេះ ។ លុះដល់ពាក់កណ្តាលផ្លូវ ភិក្ខុអ្នកទទួលបញ្ញើនោះឮដំណឹងថា ភិក្ខុអ្នកចាំទទួលយកចីវរនោះស្លាប់ទៅហើយ ។ ក៏អធិដ្ឋានមតកចីវររបស់ភិក្ខុអ្នកចាំទទួលយកចីវរនោះ

អធិដ្ឋាតិ ស្វាធិដ្ឋិតំ ។ យោ បហិណតិ តស្ស វិស្សា-សា គណ្ហាតិ ទុគ្គហិតំ ។ ឥធ បន ភិក្ខវេ ភិក្ខុ ភិក្ខុស្ស ហត្ថេ ចីវរំ បហិណតិ ឥមំ ចីវរំ ឥត្ថន្នាមស្ស ទេហីតិ ។ សោ អន្តរាមគ្គេ សុណាតិ ទាតា កាលក-តោតិ ។ យោ បហិណតិ តស្ស មតកចីវរំ អធិដ្ឋាតិ ទុរ-ធិដ្ឋិតំ ។ យស្ស បហីយតិ តស្ស មតកចីវរំ អធិដ្ឋាតិ ស្វាធិដ្ឋិតំ ។

[៧៨] អដ្ឋិមា ភិក្ខវេ មាតិកា ចីវរស្ស ឧប្បាទា-យ សីមាយ ទេតិ កតិកាយ ទេតិ ភិក្ខាបញ្ញត្តិយា ទេតិ សង្ឃស្ស ទេតិ ឧភតោសង្ឃស្ស ទេតិ វស្សំវុត្ថស្ស សង្ឃស្ស ទេតិ អាទិស្ស ទេតិ បុគ្គលស្ស ទេតិ ។ សីមាយ ទេតិ យាវតិកា ភិក្ខូ អន្តោសីមគតា តេហិ ភាជេតព្វំ ។ កតិកាយ ទេតិ សម្ពហុលា អាវាសា



(យ៉ាងនេះ) ហៅថា អធិដ្ឋានល្អ ។ បើភិក្ខុអ្នកទទួលបញ្ញើយកចីវរ (មកប្រើប្រាស់ដោយខ្លួនឯងវិញ) ដោយការស្រឡាញ់ស្និទ្ធស្នាលនឹងភិក្ខុអ្នកផ្ញើនោះ (យ៉ាងនេះ) ហៅថា កាន់យកមិនល្អទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុផ្ញើចីវរទៅនឹងដៃភិក្ខុដទៃ ដោយពាក្យថា ចូរលោកប្រគេនចីវរនេះដល់ភិក្ខុឈ្មោះនេះ ។ លុះដល់ពាក់កណ្ដាលផ្លូវ ភិក្ខុអ្នកទទួលបញ្ញើនោះឮដំណឹងថា ភិក្ខុទាំងពីររូបស្លាប់ទៅហើយ ។ កាន់អធិដ្ឋានមតកចីវររបស់ភិក្ខុអ្នកផ្ញើទៅនោះ (យ៉ាងនេះ) ហៅថា អធិដ្ឋានមិនល្អ ។ បើភិក្ខុអ្នកទទួលបញ្ញើអធិដ្ឋានមតកចីវររបស់ភិក្ខុអ្នកត្រូវទទួលចីវរនោះ (យ៉ាងនេះ) ហៅថា អធិដ្ឋានល្អ ។

(៧៨) ម្នាលភិក្ខុទាំងឡាយ មាតិកា (ហេតុ) ដែលនាំឲ្យកើតចីវរឡើងមាន ៨ យ៉ាងគឺ គេឲ្យចីវរក្នុងសីមា១ គេឲ្យចីវរដោយសេចក្ដីប្ដេជ្ញា១ គេឲ្យចីវរដោយសេចក្ដីបញ្ញត្តិនៃភិក្ខា (ទីបរិច្ចាគទានរបស់ខ្លួន)១ គេឲ្យចីវរចំពោះសង្ឃ១ គេឲ្យចីវរចំពោះឧភតោសង្ឃ១ គេឲ្យចីវរចំពោះសង្ឃដែលនៅចាំវស្សា ១ គេចំពោះវត្ថុកំណត់ហើយទើបឲ្យចីវរ ១ គេឲ្យចីវរចំពោះបុគ្គល១ ។ ដែលហៅថា គេឲ្យចីវរក្នុងសីមានុ៎ះ (សំដៅយក) ភិក្ខុមានចំនួនប៉ុន្មានរូបដែលនៅខាងក្នុងសីមា ត្រូវភិក្ខុទាំងនោះចែកចីវរគ្នាចុះ ។ ដែលហៅថា គេឲ្យចីវរដោយសេចក្ដីប្ដេជ្ញានុ៎ះ (សំដៅយក) អាវាសច្រើន

សមានលាភា ហោន្តិ ឯកស្មឹ អាវាសេ ទិន្នេ សព្វត្ថ ទិន្នំ ហោតិ ។ ភិក្ខាបញ្ញត្តិយា ទេតិ យត្ថ សង្ឃស្ស ធុវការា ករីយន្តិ តត្ថ ទេតិ(១) ។ សង្ឃស្ស ទេតិ សម្មុខីភូតេន សង្ឃេន ភាជេតព្វំ ។ ឧភតោសង្ឃស្ស ទេតិ ពហុកាបិ ភិក្ខូ ហោន្តិ ឯកា ភិក្ខុនី ហោតិ ឧបឌ្ឍំ ទាតព្វំ ។ ពហុកាបិ ភិក្ខុនិយោ ហោន្តិ ឯកោ ភិក្ខុ ហោតិ ឧបឌ្ឍំ ទាតព្វំ ។ វស្សំ វុត្ថស្ស សង្ឃស្ស ទេតិ យាវតិកា ភិក្ខូ តស្មឹ អាវាសេ វស្សំ វុត្ថា តេហិ ភាជេតព្វំ ។ អាទិស្ស ទេតិ យាគុយា វា ភត្តេ វា ខាទនីយេ វា ចីវរេ វា សេនាសនេ វា ភេសជ្ជេ វា ។ បុគ្គលស្ស ទេតិ ឥមំ ចីវរំ ឥត្ថន្នាមស្ស ទម្មីតិ ។

ចីវរក្ខន្ធកំ និដ្ឋិតំ អដ្ឋមំ ។

ឥមម្ហិ ខន្ធកេ វត្ថូ ឆន្នវុតិ ។

១ ឱ. ទេមាតិ ។



ជាកតិកាសមានលាភស្មើគ្នា កាលបើគេឲ្យចីវរក្នុងអាវាសតែ ១ ទុកដូចជាបានឲ្យចីវរក្នុងអាវាសទាំងអស់ ។ ដែលហៅថា គេឲ្យចីវរដោយសេចក្តីបញ្ញត្តិនៃភិក្ខា គឺ (សំដៅយក) ការបូជាជានិច្ចដែលគេធ្វើចំពោះសង្ឃក្នុងទីណា គេក៏ឲ្យចីវរក្នុងទីនោះ ។ ដែលហៅថា គេឲ្យចីវរចំពោះសង្ឃ គឺ (សំដៅយក) សង្ឃដែលមកជួបជុំមុខគ្នាហើយត្រូវចែកចីវរចុះ ។ ដែលហៅថា គេឲ្យចីវរចំពោះឧភតោសង្ឃ (សំដៅយក) ភិក្ខុសង្ឃច្រើនរូប ភិក្ខុនីតែ ១ រូប សង្ឃគឺត្រូវឲ្យចីវរពាក់កណ្តាល (ស្មើគ្នា) ។ ភិក្ខុនីសង្ឃច្រើនរូប ភិក្ខុតែ ១ រូប សង្ឃគឺត្រូវឲ្យចីវរពាក់កណ្តាល (ស្មើគ្នា) ។ ដែលហៅថា គេឲ្យចីវរចំពោះសង្ឃដែលនៅចាំវស្សា (សំដៅយក) ភិក្ខុមានកំណត់ប៉ុន្មានរូប នៅចាំវស្សាក្នុងអាវាសនោះ ភិក្ខុទាំងនោះត្រូវចែកចីវរគ្នាចុះ ។ ដែលហៅថា ចំពោះវត្ថុកំណត់ហើយ ទើបគេឲ្យចីវរគឺ (សំដៅយកត្រង់ហេតុ) ដែលគេឲ្យបបរហើយ គេឲ្យចីវរផង ជួនកាលគេឲ្យភត្តហើយគេឲ្យចីវរផង ជួនកាលគេឲ្យខាទនីយៈហើយគេឲ្យចីវរផង ជួនកាលគេឲ្យចីវរតែម្តង ជួនកាលគេឲ្យសេនាសនៈហើយគេឲ្យទាំងចីវរផង ពុំនោះសោតគេឲ្យភេសជ្ជៈព្រមទាំងចីវរផង ។ ដែលហៅថាគេឲ្យចីវរចំពោះបុគ្គលគឺ (សំដៅយកត្រង់ហេតុ) ដែលគេឲ្យដោយពាក្យថា ខ្ញុំឲ្យចីវរនេះចំពោះភិក្ខុឈ្មោះនេះ ។

ចប់ ចីវរក្ខន្ធកៈ ទី ៨ ។

ក្នុងខន្ធកៈនេះមាន ៩៦ រឿង ។

តស្សុទ្ទានំ

(៧៨) រាជគហកោ នេគមោ
ទិស្វា វេសាលិយំ គណឹ
បុន រាជគហំ គន្ត្វា
រញ្ញោ តំ បដិវេទយិ ៗ
បុត្តោ សាលវតិកាយ
អភយស្ស ហិ អត្រជោ
ជីវតីតិ កុមារេន
សង្ខាតោ ជីវកោ ឥតិ ៗ
សោ ហិ តក្កសិលំ គន្ត្វា
ឧគ្គហេត្វា មហាភិសោ
សត្តវស្សិកអាពាធំ
នត្ថុកម្មេន នាសយិ ៗ
រញ្ញោ ភគន្ទលាពាធំ
អាលេបេន អបាកឌ្ឍិ ៗ
មមញ្ច ឥត្ថាគារញ្ច
ពុទ្ធសង្ឃញ្ចុបដ្ឋហ ៗ



ឧទ្ទានរបស់ចីវរក្ខន្ធកៈនោះគឺ

(៧៨) រឿងនិគមកុដុម្ពិកៈនៅក្នុងក្រុងរាជគ្រឹះ ឃើញស្ត្រីជាគណិកានៅក្នុងក្រុងវេសាលី ហើយទៅក្រុងរាជគ្រឹះវិញ ក៏បានក្រាបទូលសេចក្ដីនុះដល់ស្ដេច ១ រឿងកូនប្រុសនៃស្ត្រីជាគណិកាឈ្មោះសាលវតី ត្រូវបានមកជាកូនអភយរាជកុមារវិញ ព្រោះរាជកុមារបានចិញ្ចឹមទុកឲ្យឈ្មោះថា ជីវកៈ ព្រោះហេតុតែពាក្យសួរថា កូននោះមានជីវិតរស់នៅឬស្លាប់ ១ រឿងជីវកកោមារភច្ចៈទៅក្រុងតក្កសិលា រៀនធ្វើពេទ្យបានជាមហាពេទ្យ ហើយមើលជម្ងឺក្នុងក្បាលអស់រយៈ របស់សេដ្ឋី ដែលឈឺ ៧ ឆ្នាំ ឲ្យសះជាដោយនត្ថុកម្ម គឺការបញ្ចូលថ្នាំទៅតាមច្រមុះ ១ រឿងជីវកកោមារភច្ចពេទ្យពិនិត្យ (មើលជា) អាពាធឫសដូងបាតនៃព្រះបាទពិម្ពិសារ ដោយថ្នាំលាប ១ ព្រះរាជាទ្រង់មានបន្ទូលនឹងជីវកកោមារភច្ចថា អ្នកឯងចូរបម្រើអាត្មាអញ ពួកស្ត្រីក្នុងរាជវាំង ព្រះពុទ្ធនិងព្រះសង្ឃផង ១

រាជគហកោ ច សេដ្ឋី
អន្តគណ្ឋិតិកិច្ឆិតំ
បជ្ជោតស្ស មហារោគំ
ឃតបានេន នាសយិ ។
អធិការញ្ច សិវេយ្យំ
អភិសន្នំ សិនេហយិ(១)
តីហិ ឧប្បលហត្ថេហិ
សមត្តិំសវិរេចនំ
បកតត្តំ វរំ យាចិ
សិវេយ្យញ្ច បដិគ្គហិ
ចីវរញ្ច គិហិទានំ
អនុញ្ញាសិ តថាគតោ ។
រាជគហេ ជនបទេ
ពហុំ ឧប្បជ្ជិ ចីវរំ ។
បាវារោ កោសិយញ្ចេវ
កោជវោ អឌ្ឍកាសិកំ

១ ឆ. សិនេហេសិ ។



រឿងសេដ្ឋីនៅក្នុងក្រុងរាជគ្រឹះ ១ រឿងជីវកកោមារភច្ច មើលតាំងពកក្នុងពោះវៀន ១ រឿងជីវកកោមារភច្ចញុំាង មហារោគនៃព្រះបាទបជ្ជោតឲ្យស្រះជាទៅ ព្រោះសោយទឹក ដោះរាវ ១ ជីវកកោមារភច្ចក្រាបទូលថា សូមឲ្យព្រះបាទ បជ្ជោតរឭកអធិការរបស់ខ្ញុំព្រះអង្គបានធ្វើសំពត់សិវេយ្យកៈ មួយគូមកជីវកកោមារភច្ច ១ រឿងជីវកកោមារភច្ចញុំាង កាយព្រះមានព្រះភាគដែលមានទោសទល់ឲ្យស្រួល ហើយ បានថ្វាយថ្នាំបញ្ចុះ ៣០ ដងដោយផ្កាឧប្បល ៣ ក្តាប់ ព្រះ មានព្រះភាគក៏មានព្រះកាយជាប្រក្រតី រឿងទ្រង់ទទួល សំពត់សិវេយ្យកៈដែលជីវកកោមារភច្ចសុំពរហើយថ្វាយព្រះ អង្គ ១ រឿងព្រះតថាគតអនុញ្ញាតគហបតិចីវរ ១ រឿងចីវរ កើតឡើងជាច្រើនក្នុងក្រុងរាជគ្រឹះ ១ ក្នុងជនបទ ១ រឿងព្រះ មានព្រះភាគអនុញ្ញាតសំពត់ឈ្មោះបាវារៈធ្វើដោយសូត្រ ១ សំពត់កោជវៈធ្វើដោយរោម ១ រឿងស្តេចក្នុងដែនកាសី បញ្ជូនសំពត់កម្ពលមានដំឡៃកន្លះកាសីមកជីវកកោមារភច្ច ១

ទុក្ខាវហា ច សន្ធិ

ជាតរមេសាគមេសុ ច

បឋមំ បច្ចា សនិសា

គតិគតា ច បដិហារុំ

តណ្ហាគារំ អគុត្តញ្ច

វុឌ្ឍាបេន្តិ គជេវ ច

ទស្សន្នំ គោលាហលញ្ច

គជំ ការជេ គជំ ឆនេ

សគាតិរគាភាគេន





រឿងចីវរក្រាស់ទីងវាយកើតឡើងដល់សង្ឃ ហើយព្រះអង្គទ្រង់សរសើរសេចក្ដីសន្ដោស ១ រឿងព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតឲ្យភិក្ខុឲ្យចំណែកចីវរដល់ភិក្ខុដែលមិនបានឈប់ចាំគ្នា ១ រឿងព្រះដ៏មានព្រះភាគអនុញ្ញាតឲ្យភិក្ខុឲ្យចំណែកចីវរដល់ភិក្ខុដែលឈប់ចាំគ្នា ១ រឿងភិក្ខុចូលទៅកាន់ព្រៃស្មសានមុន នឹងចូលទៅកាន់ព្រៃស្មសានក្រោយ ១ រឿងភិក្ខុចូលទៅក្នុងព្រៃស្មសានដំណាលគ្នា ១ រឿងភិក្ខុធ្វើសេចក្ដីព្រមព្រៀងនឹងគ្នា ហើយចូលទៅក្នុងព្រៃស្មសានដើម្បីបង្សុកូល ១ រឿងពួកមនុស្សនាំយកចីវរមកកាន់អារាម លុះភិក្ខុអ្នកទទួលមិនបានកំណត់ត្រឡប់ទៅវិញ ១ រឿងព្រះសាស្ដាអនុញ្ញាតឲ្យភិក្ខុសន្មតឃ្លាំងដាក់ចីវរ ១ រឿងចីវរក្នុងឃ្លាំងឥតមានអ្នកណាថែរក្សា ១ រឿងព្រះអង្គទ្រង់ឲ្យភិក្ខុបណ្ដេញភិក្ខុអ្នករក្សាឃ្លាំង ១ រឿងចីវរកើតឡើងច្រើនក្រៃលែង ១ រឿងសង្ឃចែកចីវរធ្វើឲ្យកោលាហល ១ រឿងភិក្ខុអ្នកចែកចីវរគិតថា យើងត្រូវចែកចីវរដូចម្ដេច ១ រឿងភិក្ខុអ្នកចែកចីវរគិតថា យើងត្រូវឲ្យចំណែកចីវរដល់សាមណេរដូចម្ដេច ១ រឿងភិក្ខុមានសេចក្ដីប្រាថ្នានឹងឆ្លងបឹងឬស្ទឹងផ្ទាល់បានយកចំណែកចីវររបស់ខ្លួនទៅផង ១

បដិក្កោសា គារំ ជនេ

ឆកណេន សីតុណ្ហំ ច

ឧត្តរិតុំ ន ជានេ

ឱរោបេន្តា ភាជនញ្ច

បាតិយា ច ឆមាយ ច

ឧបចិកា មជ្ឈេ ជីរន្តិ

ឯកតោ បត្ថិនេន ច

ផរុសាច្ឆិន្នចីវរា

អទ្ទសាសិ ឧព្ភណ្ឌិតេ

វីមំសិត្វា សក្យមុនិ

អនុញ្ញាសិ តិចីវរំ



រឿងភិក្ខុមានសេចក្តីប្រាថ្នានឹងឆ្លងស្ទឹងឬផ្លូវលំបាកយកកាំងចំ-ណោកចីវរដែលមានដំឡៃប្រសើរជាងគេ១ រឿងភិក្ខុអ្នកចែកចីវររះគិតជាមុនឲ្យស្រេចចំណែកចីវរជូនមុខ ១ រឿងភិក្ខុដែលគក់ចីវរដោយអាចម៍គោ១ រឿងភិក្ខុដែលគក់ចីវរដោយទឹកត្រជាក់នឹងទឹកក្តៅ ១ រឿងទឹកដែលគក់ពុះផុលកំពប់១ រឿងភិក្ខុមិនដឹងថាទឹកដែលគក់ឆ្អិនឬមិនឆ្អិន១ រឿងភិក្ខុសិកទឹកដែលគក់ ធ្លាក់បែកទៅ ១ រឿងភិក្ខុគ្មានភាជនសម្រាប់ដាក់ទឹកដែលគក់១ រឿងភិក្ខុដែលគក់ចីវរក្នុងថាស១ រឿងភិក្ខុហាលចីវរលើផែនដី១ រឿងសត្វកណ្តៀរកាត់កម្រាលស្មៅ ១ រឿងភិក្ខុហាលចីវរបត់ចំពាក់កណ្តាល១ រឿងចីវររេច១ រឿងទឹកដែលគក់ហូរទៅតែម្ខាង១ រឿងភិក្ខុដែលគក់ចីវរជិតរោក១ រឿងចីវរតាក្រក់១ រឿងឆព្វគ្គិយភិក្ខុទ្រទ្រង់ចីវរមិនកាត់ ១ រឿងស្រែអ្នកមគធៈមានសណ្ឋានជាប្លុកដែរ ១ រឿងព្រះមានព្រះភាគជាម្ចាស់ទតឃើញភិក្ខុទាំងឡាយ វេចចីវរៈច្រើនបង្អើត ១ រឿងព្រះសក្យមុនីទ្រង់ល្បងមើលត្រជាក់ក្នុងវេលាយប់ហើយទ្រង់អនុញ្ញាតត្រៃចីវរ ១

អញ្ញេន អតិរេកេន
ឧប្បជ្ជិ ឆិន្នមេវ ច
ជាតុទ្ធិយោ ភាំ យាចិ
ទាតុំ វស្សិកសាដិកំ
អាគន្តុគមិគិលានំ
ឧបដ្ឋាកញ្ច ភេសជ្ជំ
ធុវំ ឧទកសាដី ច
បណីតំ អតិខុទ្ទកំ
ថុល្លកច្ឆុ មុខំ ខោមំ
បរិបុណ្ណំ អធិដ្ឋានំ
បច្ឆិមំ កតោ គរុកោ
វិកណ្ណោ សុត្តមោកិរិ
លុជ្ជន្តិ នប្បហោន្តិ ច
អន្វាធិកំ ពហូនំ ច





រឿងឆព្វគ្គិយភិក្ខុទ្រទ្រង់អតិរេកចីវរដទៃៗ ១ រឿងព្រះអានន្ទបានអតិរេកចីវរ ១ រឿងភិក្ខុសង្ស័យ ១ រឿងភ្លៀងធ្លាក់សព្វទ្វីបទាំងបួន ១ រឿងនាងវិសាខាសុំពរដើម្បីប្រគេនវស្សិកសាដិកៈ អាគន្តុកភត្ត គមិកភត្ត គិលានភត្ត ឧបដ្ឋាកភត្ត ភេសជ្ជៈ ធុវយាគុ និងឧទកសាដិកៈ ១ រឿងភិក្ខុឆាន់បណីតភោជន ១ រឿងសំពត់និសីទនៈតូចពេក ១ រឿងព្រះបេលដ្ឋសីសៈកើតបូសធំ ១ រឿងព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតសំពត់ជូតមុខ ១ រឿងរោជមល្លផ្ញើសំពត់សម្បកឈើទុកនឹងព្រះអានន្ទ ១ រឿងត្រៃចីវរបរិបូណ៌កើតឡើងដល់ភិក្ខុ ១ រឿងព្រះអង្គទ្រង់អនុញ្ញាតឲ្យភិក្ខុអធិដ្ឋានត្រៃចីវរជាដើម ១ រឿងព្រះអង្គទ្រង់អនុញ្ញាតឲ្យវិកប្បចីវរយ៉ាងតូចបំផុត ១ រឿងព្រះកស្សបធ្វើសេចក្តីគោរពក្នុងការដេរចំណែកសំពត់បង្សុកូល ១ រឿងចីវរមានជាយមិនស្មើគ្នា ១ រឿងអំបោះរសាត់ចេញ ១ រឿងស្រទាប់សង្ឃាដិដាច់ចេញពីគ្នា ១ រឿងភិក្ខុកាត់ចីវរសំពត់មិនគ្រាន់ ព្រះអង្គទ្រង់អនុញ្ញាតឲ្យលើកឡើងនូវអាគន្តុកបដៈ ១ រឿងចីវរច្រើនកើត

អជ្ឈារេ អសន្តិយា
យានា វយ្ហំ ឧគ្គម្ហិ ច
ចេឡ កាតុកា ភជ្ជរោ
ឧបធេ្លា មុច ទ្វិសុ
តុច្ឆិតាកោ គិលានោ
ធុកោ ចេវ គិលាយនា
ឧគ្គា តុសា កោជវំ
ផលកំ(១) កោសេយ្យកម្ពលំ
វាលឧលូកបក្ខញ្ច
អជិនំ អក្កនាលកំ
មោច្ឆកំ ចិលបិតញ្ច

១ ឱ. ជលកោ ។



រឿងដល់កិច្ច ១ រឿងភិក្ខុកាច់កន្ទុយមេគោ (ក្រវិនិក) ១ រឿងព្រះអានន្ទមានតែស្បែកជើង ត្រូវសន្និះ ចូលទៅបិណ្ឌបាត ក្នុងស្រុកដោយក្រោធក្សាក់ ១ រឿងភិក្ខុពាក់ស្បែកជើងតែម្នាក់ឯង ១ រឿងភិក្ខុទៅតែម្នាក់ឯងជាតស់មួយរយជូរ ១ រឿងព្រះថេរៈពីររូបជា បងប្អូននឹងគ្នាទៅពាក់ស្បែកជើងក្រវិសាក់ ១ រឿងភិក្ខុពីររូបទៅ ពាក់ស្បែកជើងក្រវិកសើរ ១ រឿងព្រះឧបនន្ទទៅពាក់ស្បែកជើង ក្រវិសាក់ ១ រឿងព្រះឧបនន្ទទៅពាក់ស្បែកតែម្នាក់ឯងក្នុង អាកាសចាំទីពី ១ រឿងភិក្ខុមានអាពាធរការក្នុងពោះ ១ រឿង ភិក្ខុមួយរូបមានជម្ងឺ ១ រឿងជនចាំទីពីរ គឺភិក្ខុមួយរូបសាម-ណេរមួយរូបបម្រើភិក្ខុមានជម្ងឺ ១ រឿងភិក្ខុតាក្រាត ១ រឿងភិក្ខុស្លៀកសំពត់ធ្វើពីស្មៅក្លាំង ១ រឿងភិក្ខុស្លៀកសំ-ពត់ធ្វើពីសម្បកឈើ ១ រឿងភិក្ខុស្លៀកសំពត់ធ្វើពីផែនក្តារ ១ រឿងភិក្ខុស្លៀកសំពត់កម្ពលធ្វើពីសក់ ១ រឿងភិក្ខុស្លៀក សំពត់ធ្វើពីរោមកន្ទុយសេះ ១ រឿងភិក្ខុស្លៀកសំពត់ធ្វើពី ស្លាបមៀម ១ រឿងភិក្ខុស្លៀកសំពត់ធ្វើពីស្បែកខ្លា ១ រឿងភិក្ខុ ស្លៀកសំពត់ធ្វើពីដើមភក់ ១ រឿងភិក្ខុស្លៀកសំពត់ធ្វើពីសម្បក ក្រពៅ ១ រឿងឆព្វគ្គិយភិក្ខុប្រើប្រាស់មានពណ៌ខៀវពណ៌លឿង

លោហិតំ មញ្ញមេជ្ជ ច

កណ្ហា មហាវត្ថបាស-

អដ្ឋិទន្តសិខា ធជា

នីឃ បុប្ផផលនសា(១)

កាកុត្តិជេបធំ

អនុប្បន្ន បញ្ញមតិ

សម្ផុ គិជ្ឈតិ ការេន

បក្ខោ ធនន្តិ សព្វស្ស

អាយស្មា បរេតា បហិ

វិសម្ពសកាមាជិជ្ជាតិ

អដ្ឋ ចរិមាគិកាតិ ។

---

១ ឥលេបសាតំ ម. បោត្ថកា ទិស្សតិ ។



គណៈក្រោម គណៈខាងត្បូង គណៈជើង គណៈ
ក្រោមក្រមៅផ្ទុខខ្នងក្តួយ គណៈល្មើចុំផ្លូវផ្កាឈូក មាន
ជាយមិនកាត់ មានជាយវែង មានជាយមានផ្កាផ្កាឈើ មាន
ជាយមានផ្កាផ្លែឈើ ៣ ។ មួក ខ្ពង់សំពត់ឈ្មួត ១ ព្រឹទ្ធិបរ
មិនពាក់កើតឡើង កិច្ចមៀសចេញទៅ ១ ព្រឹទ្ធិសឡែកគ្នា ១
ព្រឹទ្ធិពួកជនប្រទេសទាំងមួយចំណែកនឹងចេរមួយចំណែកចំពោះ
សន្យ ១ ព្រឹទ្ធិព្រះរាជនឹមានអាយុលើបរ ១ ព្រឹទ្ធិកិច្ចកាន់យក
ចំណែតយ សេចក្តីសុទ្ធ ស្នាល ១ ព្រឹទ្ធិកិច្ចអធិដ្ឋានមិនគបរ ១
ព្រឹទ្ធិមាគិកានាំឲ្យកើតចំណាច ព្រហ្មយាននិង ១ ។

(៨០) តេន សមយេន ពុទ្ធោ ភគវា ចម្បាយំ វិហរតិ គគ្គរាយ បោក្ខរណិយា តីរេ ។ តេន ខោ បន សមយេន កាសីសុ ជនបទេសុ វាសភគាមោ នាម ហោតិ ។ តត្ថ កស្សបគោត្តោ នាម ភិក្ខុ អាវាសិកោ ហោតិ តន្តិពទ្ធោ ឧស្សុក្កំ អាបន្នោ កិន្តិ អនាគតា ច បេសលា ភិក្ខូ អាគច្ឆេយ្យុំ អាគតា ច បេសលា ភិក្ខូ ផាសុំ វិហរេយ្យុំ អយញ្ច អាវាសោ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជេយ្យាតិ ។ តេន ខោ បន សមយេន សម្ពហុលា ភិក្ខូ កាសីសុ ចារិកំ ចរមានា យេន វាសភគាមោ តទសរឹសុ[1] ។ អទ្ទសា ខោ កស្សបគោត្តោ ភិក្ខុ តេ ភិក្ខូ ទូរតោវ អាគច្ឆន្តេ ទិស្វាន អាសនំ បញ្ញាបេសិ បាទោទកំ បាទបីឋំ បាទកឋលិកំ ឧបនិក្ខិបិ បច្ចុគ្គន្ត្វា បត្តចីវរំ បដិគ្គហេសិ បានីយេន អាបុច្ឆិ នហានេ ឧស្សុក្កំ អកាសិ ឧស្សុក្កំបិ អកាសិ យាគុយា ខាទនីយេ ភត្តស្មឹ ។ អថខោ តេសំ

[1] ម. តទវសរុំ ។



(៨០) សម័យនោះ ព្រះពុទ្ធមានព្រះភាគ គង់នៅក្បែរស្រះបោក្ខរណីឈ្មោះគគ្គរា ទៀបក្រុងចម្បា ។ សម័យនោះឯង ក្នុងកាសីជនបទ មានស្រុក ១ ឈ្មោះវាសភៈ ។ ភិក្ខុឈ្មោះកស្សបគោត្តជាម្ចាស់អាវាស ក្នុងស្រុកឈ្មោះវាសភៈនោះ មានចិត្តជាប់ចំពាក់ដោយការរៀបចំក្នុងការវាសនោះ ដល់នូវសេចក្តីខ្វល់ខ្វាយដូច្នេះថា ធ្វើដូចម្តេច ភិក្ខុទាំងឡាយមានសីលជាទីស្រឡាញ់ដែលមិនទាន់មកដល់គប្បីឱ្យមកផង ភិក្ខុមានសីលជាទីស្រឡាញ់ដែលមកដល់ហើយគប្បីនៅជាសុខផង មួយទៀតអាវាសនេះគប្បីដល់នូវសេចក្តីចំរើនសេចក្តីលូតលាស់នឹងការទូលំទូលាយ ។ សម័យនោះឯង ពួកភិក្ខុច្រើនរូប ត្រាច់ទៅកាន់ចារិក ក្នុងកាសីជនបទ ក៏ចូលទៅដល់ស្រុកឈ្មោះវាសភៈ ។ ភិក្ខុឈ្មោះកស្សបគោត្ត បានឃើញពួកភិក្ខុនោះកំពុងដើរមកអំពីចម្ងាយ លុះឃើញហើយក៏ក្រាលអាសនៈ ដាក់ទឹកសម្រាប់លាងជើង ជាន់សម្រាប់កល់ជើង នឹងកំសម្រាប់ជូតជើង ហើយក្រោកទទួលបាត្រនឹងចីវរ អើពើដោយទឹកឆាន់ ធ្វើសេចក្តីខ្វល់ខ្វាយក្នុងការងូត ធ្វើសេចក្តីខ្វល់ខ្វាយក្នុងបបរនឹងខាទនីយៈ នឹងភត្តទៀត ។ ពួកភិក្ខុជាអាគន្តុកទាំងនោះបានប្រឹក្សាគ្នាដូច្នេះថា

អាគន្តុកានំ ភិក្ខូនំ ឯតទហោសិ ភទ្ទកោ ខោ អយំ អាវុសោ អាវាសិកោ ភិក្ខុ នហានេ ឧស្សុក្កំ ករោតិ ឧស្សុក្កំបិ ករោតិ យាគុយា ខាទនីយេ ភត្តេ ហន្ទ មយំ អាវុសោ ឥធេវ ភិក្ខាគាមេ និវាសំ កប្បេមាតិ ។ អថខោ តេ អាគន្តុកា ភិក្ខូ តត្ថេវ ភិក្ខាគាមេ និវាសំ កប្បេសុំ ។ អថខោ កស្សបគោត្តស្ស ភិក្ខុនោ ឯតទហោសិ យោ ខោ ឥមេសំ អាគន្តុកានំ ភិក្ខូនំ អាគន្តុកកិលមថោ សោ បដិប្បស្សទ្ធោ យេបិមេ គោចរេ អប្បកតញ្ញុនោ តេទានិមេ គោចរេ បកតញ្ញុនោ ទុក្ករំ ខោ បន បរកុលេសុ យាវជីវំ ឧស្សុក្កំ កាតុំ វិញ្ញត្តិ ច មនុស្សានំ អមនាបា យន្នូនាហំ ន ឧស្សុក្កំ ករេយ្យំ យាគុយា ខាទនីយេ ភត្តេតិ ។ សោ ន ឧស្សុក្កំ អកាសិ យាគុយា ខាទនីយេ ភត្តេ ។ អថខោ តេសំ អាគន្តុកានំ ភិក្ខូនំ ឯតទហោសិ បុព្វេ ខ្វាយំ អាវុសោ អាវាសិកោ ភិក្ខុ នហានេ ឧស្សុក្កំ ករោតិ ឧស្សុក្កំបិ ករោតិ យាគុយា ខាទនីយេ ភត្តេ សោទានាយំ ន ឧស្សុក្កំ ករោតិ



ម្នាលអាវុសោទាំងឡាយ ភិក្ខុជាម្ចាស់អាវាសនេះល្អណាស់ ធ្វើសេចក្តីខ្វល់ខ្វាយក្នុងការងូត ធ្វើសេចក្តីខ្វល់ខ្វាយ ក្នុងបបរ និងខាទនីយៈ និងភត្តទៀត ម្នាលអាវុសោទាំងឡាយ បើដូច្នេះ យើងនឹងនៅសម្រេចការនៅក្នុងភិក្ខាគ្រាមនេះចុះ ។ គ្រានោះ ពួកអាគន្តុកភិក្ខុនោះក៏នៅសម្រេចការនៅក្នុងភិក្ខាគ្រាមនោះឯង ។ ភិក្ខុឈ្មោះកស្សបគោត្តមានសេចក្តីត្រិះរិះក្នុងកាលនោះដូច្នេះថា សេចក្តីលំបាកដោយក្តីជាអាគន្តុករបស់អាគន្តុកភិក្ខុទាំងនេះ ក៏ស្ងប់រម្ងាប់ទៅហើយ ពួកភិក្ខុទាំងឡាយនោះដែលមិនស្គាល់ទីគោចរជាប្រក្រតី ក៏ត្រឡប់ស្គាល់ហើយ ឯការធ្វើសេចក្តីខ្វល់ខ្វាយក្នុងត្រកូលដទៃបុគ្គលដទៃ អស់មួយជីវិត ជាការក្រៃពេកណាស់ មួយវិញទៀត ការសូមមិនជាទីគាប់ចិត្តដល់មនុស្សទាំងឡាយ បើដូច្នោះ គួរតែអាត្មាអញកុំធ្វើសេចក្តីខ្វល់ខ្វាយ ក្នុងបបរ និងខាទនីយៈ និងភត្តទៀត ។ ភិក្ខុឈ្មោះកស្សបគោត្តនោះ ក៏លែងធ្វើសេចក្តីខ្វល់ខ្វាយ ក្នុងបបរ និងខាទនីយៈ និងភត្ត ។ សេចក្តីត្រិះរិះដូច្នេះ ក៏កើតមានដល់ពួកអាគន្តុកភិក្ខុនោះថា ម្នាលអាវុសោទាំងឡាយ ពីដើម ភិក្ខុជាម្ចាស់អាវាសនេះ ធ្វើសេចក្តីខ្វល់ខ្វាយក្នុងការងូត ធ្វើសេចក្តីខ្វល់ខ្វាយ ក្នុងបបរ និងខាទនីយៈ និងភត្តទៀត ឥឡូវនេះ ភិក្ខុជាម្ចាស់អាវាសនោះ លែងធ្វើសេចក្តីខ្វល់ខ្វាយ

យាគុយា ខាទនីយេ ភត្តស្មឹ ទុដ្ឋោទានាយំ អាវុសោ
អាវាសិកោ ភិក្ខុ ហន្ទ មយំ អាវុសោ ឥមំ[១] អាវា
សិកំ ភិក្ខុំ ឧក្ខិបាមាតិ ។ អថខោ តេ អាគន្តុកា
ភិក្ខូ សន្និបតិត្វា កស្សបគោត្តំ ភិក្ខុំ ឯតទវោចុំ បុព្វេ
ខោ ត្វំ អាវុសោ នហានេ ឧស្សុក្កំ ករោសិ ឧស្សុក្កម្
បិ ករោសិ យាគុយា ខាទនីយេ ភត្តស្មឹ ឥទានិ ត្វំ
ន ឧស្សុក្កំ ករោសិ យាគុយា ខាទនីយេ ភត្តស្មឹ
អាបត្តឹ ត្វំ អាវុសោ អាបន្នោ បស្សសេតំ អាបត្តិន្តិ ។
នត្ថិ មេ អាវុសោ អាបត្តិ យមហំ បស្សេយ្យន្តិ ។ អថខោ
តេ អាគន្តុកា ភិក្ខូ កស្សបគោត្តំ ភិក្ខុំ អាបត្តិយា អ-
ទស្សនេ ឧក្ខិបឹសុ ។ អថខោ កស្សបគោត្តស្ស ភិក្ខុនោ
ឯតទហោសិ អហំ ខោ ឯតំ ន ជានាមិ អាបត្តិ វា ឯសា
អនាបត្តិ វា អាបន្នោ វម្ហិ អនាបន្នោ វា ឧក្ខិត្តោ វម្ហិ
អនុក្ខិត្តោ វា ធម្មិកេន វា អធម្មិកេន វា កុប្បេន វា
អកុប្បេន វា ឋានារហេន វា អដ្ឋានារហេន វា យន្នូនាហំ

១. បោត្ថកេ អយំ បាឋោ ន ហោតិ ។



ក្នុងបបរ និងខាទនីយៈ និងភត្តហើយ ម្នាលអាវុសោទាំងឡាយ ឥឡូវនេះ
ភិក្ខុជាម្ចាស់អាវាសនេះ ក្រឡប់ទៅជាកាចវិញហើយ ម្នាលអាវុសោទាំង
ឡាយ បើដូច្នោះគួរយើងទាំងឡាយលើកវត្តភិក្ខុជាម្ចាស់អាវាសនេះ ។
គ្រានោះឯង ពួកភិក្ខុជាអាគន្តុកនោះប្រជុំគ្នាហើយបាននិយាយពាក្យនេះ
នឹងភិក្ខុឈ្មោះកស្សបគោត្តថា ម្នាលអាវុសោ ពីដើមលោកធ្វើសេចក្ដីខ្វល់
ខ្វាយក្នុងការងូត ធ្វើសេចក្ដីខ្វល់ខ្វាយក្នុងបបរ និងខាទនីយៈ និងភត្ត ឥឡូវ
នេះលោកលែងធ្វើសេចក្ដីខ្វល់ខ្វាយ ក្នុងបបរ និងខាទនីយៈ និងភត្ត ម្នាល
អាវុសោ លោកត្រូវអាបត្តិហើយ លោកឃើញអាបត្តិនុះឬទេ ។ ភិក្ខុ
ជាម្ចាស់អាវាសនោះឆ្លើយថា ម្នាលអាវុសោ អាបត្តិដែលខ្ញុំគប្បីឃើញ
នោះមិនមានទេ ។ លំដាប់នោះ ពួកភិក្ខុជាអាគន្តុកនោះលើកវត្តភិក្ខុ
ឈ្មោះកស្សបគោត្ត ព្រោះមិនឃើញអាបត្តិ ។ ភិក្ខុឈ្មោះកស្សបគោត្ត
មានសេចក្ដីត្រិះរិះក្នុងវេលានោះថា អាត្មាអញមិនដឹងនូវហេតុនេះថា នេះ
ជាអាបត្តិឬមិនមែនជាអាបត្តិ ម្យ៉ាងទៀត អញត្រូវអាបត្តិហើយឬមិនទាន់
ត្រូវ សង្ឃ (គួរ) លើកវត្តអញឬមិន (គួរ) លើកវត្តទេ ដោយកម្ម
ប្រកបដោយធម៌ឬមិនប្រកបដោយធម៌ទេ ដោយកម្មដ៏កម្រើក ឬមិនកម្រើក
ទេ ដោយកម្មគួរដល់ហេតុឬមិនគួរដល់ហេតុទេ បើដូច្នោះមានតែអញ

ចម្បំ គន្ត្វា ភគវន្តំ ឯតមត្ថំ បុច្ឆេយ្យន្តិ ។ អថខោ
កស្សបគោត្តោ ភិក្ខុ សេនាសនំ សំសាមេត្វា បត្តចីវ-
រមាទាយ យេន ចម្បា តេន បក្កាមិ អនុបុព្វេន យេន
ចម្បា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគ-
វន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ អាចិណ្ណំ ខោ ប-
នេតំ ពុទ្ធានំ ភគវន្តានំ អាគន្តុកេហិ ភិក្ខូហិ សទ្ធឹ បដិ-
សម្មោទិតុំ ។ អថខោ ភគវា កស្សបគោត្តំ ភិក្ខុំ ឯតទ-
វោច កច្ចិ ភិក្ខុ ខមនីយំ កច្ចិ យាបនីយំ កច្ចិសិ
អប្បកិលមថេន អទ្ធានំ អាគតោ កុតោ ច ត្វំ ភិក្ខុ
អាគច្ឆសីតិ ។ ខមនីយំ ភគវា យាបនីយំ ភគវា
អប្បកិលមថេន ចាហំ ភន្តេ អទ្ធានំ អាគតោ អត្ថិ
ភន្តេ កាសីសុ ជនបទេសុ វាសភគាមោ នាម តត្ថា-
ហំ អាវាសិកោ តន្តិពទ្ធោ ឧស្សុក្កំ អាបន្នោ កិត្តិ



គប្បីទៅកាន់ក្រុងចម្បា ហើយក្រាបបង្គំទូលសួរសេចក្តីនេះនឹងព្រះដ៏មាន
ព្រះភាគ ។ គ្រានោះឯង ភិក្ខុឈ្មោះកស្សបគោត្ត រៀបចំទុកដាក់
សេនាសនៈ ហើយកាន់យកបាត្រនិងចីវរ ចេញទៅកាន់ក្រុងចម្បា
ហើយចូលទៅគាល់ព្រះដ៏មានព្រះភាគ ក្នុងក្រុងចម្បាដោយលំដាប់ លុះ
ចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយនៅក្នុងទីដ៏
សមគួរ ។ ការរាក់ទាក់មួយអន្លើដោយភិក្ខុទាំងឡាយជាអាគន្តុកៈនេះជាប-
វេណីរបស់ព្រះពុទ្ធទាំងឡាយដ៏មានព្រះភាគ ។ គ្រានោះឯង ព្រះដ៏
មានព្រះភាគទ្រង់មានព្រះបន្ទូលនេះនឹងភិក្ខុឈ្មោះកស្សបគោត្តថា ម្នាល
ភិក្ខុ អ្នកឯងអាចអត់ទ្រាំសេចក្តីទុក្ខបានឬទេ អាចញុំាងអត្តភាពឲ្យប្រព្រឹត្ត
ទៅបានឬទេ អ្នកឯងមកកាន់ផ្លូវឆ្ងាយមិនលំបាកទេឬ ម្នាលភិក្ខុ ម្យ៉ាង
ទៀត អ្នកមកពីណា ។ ភិក្ខុឈ្មោះកស្សបគោត្តក្រាបបង្គំទូលថា បពិត្រ
ព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គអាចអត់ធន់សេចក្តីទុក្ខបាន បពិត្រព្រះ
មានព្រះភាគ ខ្ញុំព្រះអង្គអាចញុំាងអត្តភាពឲ្យប្រព្រឹត្តទៅបាន បពិត្រ
ព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមកកាន់ផ្លូវឆ្ងាយដោយមិនមានសេចក្តីលំបាក
ទេ បពិត្រព្រះអង្គដ៏ចំរើន ស្រុកឈ្មោះវាសភៈ មានក្នុងកាសីជនបទ
ខ្ញុំព្រះអង្គជាម្ចាស់អាវាសក្នុងស្រុកឈ្មោះវាសភៈនោះ ជាប់ចំពាក់ដោយ
ការរៀបចំក្នុងអាវាសនោះ ដល់នូវសេចក្តីខ្វល់ខ្វាយថា ធ្វើដូចម្តេច

អនាគតា ច បេសលា ភិក្ខូ អាគច្ឆេយ្យុំ អាគតា ច បេ-
សលា ភិក្ខូ ផាសុំ វិហរេយ្យុំ អយញ្ច អាវាសោ វុឌ្ឍឹ
វិរូឡ្ហឹ វេបុល្លំ អាបជ្ជេយ្យាតិ អថខោ ភន្តេ សម្ពហុលា ភិក្ខូ
កាសីសុ ចារិកំ ចរមានា យេន វាសភគាមោ តទវស-
រុំ អទ្ទសំ ខោ អហំ ភន្តេ តេ ភិក្ខូ ទូរតោវ អា-
គច្ឆន្តេ ទិស្វាន អាសនំ បញ្ញបេសឹ បាទោទកំ បាទបីឋំ
បាទកឋលិកំ ឧបនិក្ខិបឹ បច្ចុគ្គន្ត្វា បត្តចីវរំ បដិគ្គហេសឹ
បានីយេន អាបុច្ឆឹ នហានេ ឧស្សុក្កំ អកាសឹ ឧស្សុក្កម្បិ
អកាសឹ យាគុយា ខាទនីយេ ភត្តស្មឹ អថខោ តេសំ
ភន្តេ អាគន្តុកានំ ភិក្ខូនំ ឯតទហោសិ ភទ្ទកោ ខោ
អយំ អាវុសោ អាវាសិកោ ភិក្ខុ នហានេ ឧស្សុក្កំ
ករោតិ ឧស្សុក្កម្បិ ករោតិ យាគុយា ខាទនីយេ ភត្ត-
ស្មឹ ហន្ទ មយំ អាវុសោ ឥធេវ វាសភគាមេ និវាសំ
កប្បេមាតិ អថខោ តេ ភន្តេ អាគន្តុកា ភិក្ខូ តត្ថេវ
វាសភគាមេ និវាសំ កប្បេសុំ តស្ស មយ្ហំ ភន្តេ



ភិក្ខុទាំងឡាយដែលមានសីលជាទីស្រឡាញ់ដែលមិនទាន់មក គប្បីឲ្យមក
ផង ភិក្ខុដែលមានសីលជាទីស្រឡាញ់មកដល់ហើយ គប្បីនៅសប្បាយ
ផង មួយវិញទៀត អាវាសនេះគប្បីដល់នូវសេចក្តីចំរើនលូតលាស់ទូលំ-
ទូលាយ បពិត្រព្រះអង្គដ៏ចំរើន ពេលនោះមានពួកភិក្ខុជាច្រើនរូប
ត្រាច់ទៅកាន់ចារិកក្នុងកាសីជនបទ ក៏បានទៅដល់វាសភគ្រាម បពិត្រព្រះ
អង្គដ៏ចំរើន ខ្ញុំព្រះអង្គបានឃើញពួកភិក្ខុទាំងនោះមកពីចម្ងាយ លុះឃើញ
ហើយក៏ក្រាលអាសនៈ ដាក់ទឹកលាងជើង តាំងសម្រាប់ទ្រជើង និងក្តារ
សម្រាប់ជូតជើង ហើយក្រោកទទួលនូវបាត្រនិងចីវរ សាកសួរដោយទឹក
ផឹក បានធ្វើសេចក្តីខ្វល់ខ្វាយក្នុងការងូត បានធ្វើសេចក្តីខ្វល់ខ្វាយក្នុង
បបរនិងខាទនីយៈនិងភត្តទៀត បពិត្រព្រះអង្គដ៏ចំរើន សេចក្តីប្រកបដូច្នេះ
បានដល់ភិក្ខុទាំងឡាយជាអាគន្តុកៈនោះក្នុងពេលនោះថា ម្នាលអាវុសោ
ទាំងឡាយ ភិក្ខុជាម្ចាស់អាវាសនេះល្អណាស់ ធ្វើសេចក្តីខ្វល់ខ្វាយក្នុង
ការងូត ធ្វើសេចក្តីខ្វល់ខ្វាយក្នុងបបរនិងខាទនីយៈនិងភត្តទៀត ម្នាល
អាវុសោទាំងឡាយ បើដូច្នោះមានតែយើងទាំងឡាយនឹងសម្រេចការនៅ
ក្នុងវាសភគ្រាមនេះឯង បពិត្រព្រះអង្គដ៏ចំរើន គ្រានោះឯង ពួកភិក្ខុជា
អាគន្តុកៈនោះសម្រេចការនៅក្នុងវាសភគ្រាមនោះ បពិត្រព្រះអង្គដ៏ចំរើន

[illegible]





[illegible]

យាគុយា ទានិយេ គត្តស្មឹ អាបត្តិ ត្វំ អាវុសោ អាបន្នោ
បស្សេតំ អាបត្តិន្តិ នត្ថិ មេ អាវុសោ អាបត្តិ យមហំ
បស្សេយ្យន្តិ អធម្មា តេ ភន្តេ សាកុត្តកា ភិក្ខុំ អាបត្តិ-
យា អទស្សនេ ឧក្ខិបិសុ តស្ស មយ្ហំ ភន្តេ ឯតទហោសិ
អយំ ខោ ឯតំ ន ជានាមិ អាបត្តិ វា ឯសា
អនាបត្តិ វា អាបន្នោ ចម្ហិ អនាបន្នោ វា ឧក្ខិត្តោ
ចម្ហិ អនុក្ខិត្តោ វា ធម្មិកេន វា អធម្មិកេន វា
កុប្បេន វា អកុប្បេន វា ឋានារហេន វា អដ្ឋានា-
រហេន វា យន្នូនាហំ ចម្បំ គន្ត្វា ភគវន្តំ ឯតមត្ថំ
បុច្ឆេយ្យន្តិ តតោ អហំ ភគវា អាគច្ឆាមីតិ ។ អនា-
បត្តិ ឯសា ភិក្ខុ នេសា អាបត្តិ អនាបន្នោសិ នសិ
អាបន្នោ អនុក្ខិត្តោសិ នសិ ឧក្ខិត្តោ អធម្មិកេនាសិ
កម្មេន ឧក្ខិត្តោ កុប្បេន អដ្ឋានារហេន គច្ឆ ត្វំ ភិក្ខុ



សេចក្ដីទូលទាយកនិយមបរិសុទ្ធទាចទិយៈនឹងកត្តហើយ ម្នាលអាវុសោ អ្នក
ត្រូវអាបត្តិហើយ អ្នកឃើញអាបត្តិឬទេ ខ្ញុំព្រះអង្គឆ្លើយថា ម្នាលអាវុសោ
អាបត្តិដែលខ្ញុំគប្បីឃើញនោះមិនមានទេ បពិត្រព្រះអង្គដ៏ចំរើន ពួកភិក្ខុ
ជាកានុក្ករនោះលើកវត្តខ្ញុំព្រះអង្គ ព្រោះមិនឃើញអាបត្តិក្នុងកាលនោះ
បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមានសេចក្ដីត្រិះរិះដូច្នេះថា អាត្មាអញមិន
ដឹងហេតុនេះថា នេះជាអាបត្តិឬមិនមែនជាអាបត្តិ មួយវិញទៀតអញត្រូវ
អាបត្តិហើយឬមិនទាន់ត្រូវទេ មួយវិញទៀតសង្ឃ (គួរ) លើកវត្តអញឬមិន
(គួរ) លើកវត្តទេ ដោយកម្មប្រកបដោយធម៌ ឬមិនប្រកបដោយធម៌ទេ
ដោយកម្មដ៏កម្រើក ឬមិនកម្រើកទេ ដោយកម្មគួរដល់ហេតុ ឬមិនគួរដល់
ហេតុទេ បើដូច្នោះមានតែអញគប្បីទៅកាន់ក្រុងចម្បា ហើយក្រាបបង្គំទូល
សួរសេចក្ដីនុះចំពោះព្រះដ៏មានព្រះភាគ បពិត្រព្រះដ៏មានព្រះភាគ ព្រោះ
ហេតុនោះបានជាខ្ញុំព្រះអង្គមក ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ នេះជា
អនាបត្តិ នេះមិនមែនជាអាបត្តិទេ អ្នកជាភិក្ខុដែលមិនត្រូវអាបត្តិ អ្នកជាភិក្ខុ
មិនត្រូវអាបត្តិ (ក្ដីទេ) អ្នកជាភិក្ខុដែលសង្ឃមិនគួរលើកវត្ត ជាភិក្ខុដែលសង្ឃ
លើកវត្តមិនបានទេ អ្នកបរិស័ទ្ធបានលើកវត្តហើយដោយកម្មមិនប្រកបដោយ
ធម៌ ដោយកម្មដ៏កម្រើក ដោយកម្មមិនគួរតាមហេតុទេ ម្នាលភិក្ខុ អ្នកចូរ

តត្ថេវ វាសភគាមេ និវាសំ កប្បេហីតិ ។ ឯវំ ភន្តេតិ សោ កស្សបគោត្តោ ភិក្ខុ ភគវតោ បដិស្សុណិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា យេន វាសភគាមោ តេន បក្កាមិ ។ អថ ខោ តេសំ អាវាសិកានំ ភិក្ខូនំ អហុទេវ កុក្កុច្ចំ អហុ វិប្បដិសារោ អលាភា វត នោ ន វត នោ លាភា ទុល្លទ្ធំ វត នោ ន វត នោ សុលទ្ធំ យេ មយំ សុទ្ធំ ភិក្ខុំ អនាបត្តិកំ អវត្ថុស្មិំ អការណេ ឧក្ខិបិម្ហា ហន្ទ មយំ អាវុសោ ចម្បំ គន្ត្វា ភគវតោ សន្តិកេ អច្ចយំ អច្ចយតោ ទេសេមាតិ ។ អថ ខោ តេ អាវាសិកា ភិក្ខូ សេនាសនំ សំសាមេត្វា បត្តចីវរមាទាយ យេន ចម្បា តេន បក្កមិំសុ អនុបុព្វេន យេន ចម្បា យេន ភគវា តេនុបសង្កមិំសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិំសុ ។ អាចិណ្ណំ ខោ បនេតំ ពុទ្ធានំ ភគវន្តានំ អាគន្តុកេហិ ភិក្ខូហិ សទ្ធិំ បដិសម្មោទិតុំ ។ អថ ខោ ភគវា តេ ភិក្ខូ ឯតទវោច កច្ចិ ភិក្ខវេ ខមនីយំ កច្ចិ



នៅអាស្រ័យនៅក្នុងវាសភគ្រាមនោះចុះ ។ ភិក្ខុឈ្មោះកស្សបគោត្ត ទទួលស្តាប់ព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគដោយពាក្យថា ព្រះករុណាព្រះអង្គ ហើយក៏ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយចៀសចេញទៅកាន់វាសភគ្រាមនោះ ។ គ្រាលំដាប់នោះ ពួកភិក្ខុជាអាគន្តុកៈនោះកើតសេចក្តីរង្កៀសក្តៅក្រហាយថា មិនមែនជាលាភរបស់យើងហើយ យើងឈ្មោះជាឥតលាភហើយ អត្តភាពជាមនុស្សយើងបានដោយក្រ មិនមែនយើងបានដោយងាយទេ (ព្រោះ) យើងលើកវត្តភិក្ខុបរិសុទ្ធមិនមានអាបត្តិ ដោយឥតរឿងឥតហេតុ ម្នាលអាវុសោទាំងឡាយ យើងគួរតែយើងទាំងឡាយនឹងទៅក្រុងចម្បា ហើយសំដែងនូវទោសតាមទោស ក្នុងសំណាក់ព្រះដ៏មានព្រះភាគ ។ គ្រានោះឯង ពួកភិក្ខុជាអាគន្តុកៈនោះក៏រៀបចំទុកដាក់សេនាសនៈហើយ កាន់យកបាត្រនិងចីវរចៀសចេញទៅកាន់ក្រុងចម្បា ចូលទៅគាល់ព្រះដ៏មានព្រះភាគឯក្រុងចម្បាដោយលំដាប់ លុះចូលទៅដល់ហើយក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ សេចក្តីរីករាយនឹងភិក្ខុជាអាគន្តុកៈនេះជាប្រពៃណីរបស់ព្រះពុទ្ធទាំងឡាយមានព្រះភាគ ។ គ្រានោះឯង ព្រះដ៏មានព្រះភាគទ្រង់មានព្រះបន្ទូលនេះនឹងពួកភិក្ខុនោះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយអាចអត់ទ្រាំ

យាបនីយំ កច្ចិ អប្បកិលមថេន អទ្ធានំ អាគតា
កុតោ ច តុម្ហេ ភិក្ខវេ អាគច្ឆថាតិ ។ ខមនីយំ
ភគវា យាបនីយំ ភគវា អប្បកិលមថេន ច មយំ
ភន្តេ អទ្ធានំ អាគតា អត្ថិ ភន្តេ កាសីសុ ជនបទេ-
សុ វាសភគាមោ នាម តតោ មយំ ភគវា អាគច្ឆា-
មាតិ ។ តុម្ហេ ភិក្ខវេ អាវាសិកំ ភិក្ខុំ ឧក្ខិបិត្ថាតិ ។
ឯវំ ភគវាតិ ។ កិស្មិំ ភិក្ខវេ វត្ថុស្មិំ កិស្មិំ[1] ការណេតិ ។
អវត្ថុស្មិំ ភគវា អការណេតិ ។ វិគរហិ ពុទ្ធោ ភគវា
អននុច្ឆវិកំ ភិក្ខវេ អននុលោមិកំ អប្បតិរូបំ អស្សា-
មណកំ អកប្បិយំ អករណីយំ កថំ ហិ នាម
តុម្ហេ មោឃបុរិសា សុទ្ធំ ភិក្ខុំ អនាបត្តិកំ អវត្ថុស្មិំ

---
១ ម. បោត្ថកេ អយំ បាឋោ នត្ថិ ។



សេចក្តីសុខក្សេមបានឬទេ ការញុំាងអត្តភាពឲ្យប្រព្រឹត្តទៅបានឬទេ អ្នកទាំងឡាយមកកាន់ផ្លូវឆ្ងាយដោយការមិនលំបាកទេឬ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត អ្នកទាំងឡាយមកអំពីទីណា ។ ពួកភិក្ខុទាំងនោះក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គអាចអត់ទ្រាំបាន បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គអាចញុំាងអត្តភាពឲ្យប្រព្រឹត្តទៅបាន បពិត្រព្រះអង្គដ៏ចំរើន ម្យ៉ាងទៀត យើងខ្ញុំទាំងឡាយមកកាន់ផ្លូវឆ្ងាយដោយការមិនលំបាកទេ បពិត្រព្រះអង្គដ៏ចំរើន មានស្រុកមួយឈ្មោះវាសភៈនៅក្នុងកាសីជនបទ បពិត្រព្រះមានព្រះភាគ យើងខ្ញុំទាំងឡាយ មកអំពីស្រុកឈ្មោះវាសភៈនោះ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយលើកវត្តភិក្ខុជាអាវាសិកឬទេ ។ ពួកភិក្ខុក្រាបបង្គំទូលថា ព្រះករុណាព្រះអង្គ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយលើកវត្តព្រោះវត្ថុដូចម្តេច ព្រោះហេតុដូចម្តេច ។ ពួកភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គទាំងឡាយលើកវត្តដោយគ្មានវត្ថុ គ្មានហេតុទេ ។ ព្រះពុទ្ធមានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ការនេះមិនសមគួរ មិនទំនង មិនត្រូវបែប មិនមែនជារបស់សមណៈ មិនគប្បី មិនត្រូវធ្វើទេ ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយ មិនគួរនឹងលើកវត្តភិក្ខុដ៏ស្អាតគ្មានអាបត្តិ ដោយគ្មានវត្ថុ

អការណេ ទុដ្ឋចិត្តស្ស ចេតំ មោឃបុរិសា អប្ប-
សន្នានំ វា បសាទាយ ។ បេ ។ វិគរហិត្វា ធម្មឹ កថំ
កត្វា ភិក្ខូ អាមន្តេសិ ន ភិក្ខវេ សុទ្ធោ ភិក្ខុ អនា-
បត្តិកោ អវត្ថុស្មឹ អការណេ ទុដ្ឋចិត្តេន ឧក្ខិ-
បេយ្យ អាបត្តិ ទុក្កដស្សាតិ ។ អថខោ តេ ភិក្ខូ
ឧដ្ឋាយាសនា ឯកំសំ ឧត្តរាសង្គំ ករិត្វា ភគវតោ
បាទេសុ សិរសា និបតិត្វា ភគវន្តំ ឯតទវោចុំ អច្ចយោ
នោ ភន្តេ អច្ចគ្គមា យថាពាលេ យថាមូឡ្ហេ យថា-
អកុសលេ យេ មយំ សុទ្ធំ ភិក្ខុំ អនាបត្តិកំ អវត្ថុស្មឹ
អការណេ ឧក្ខិបិម្ហា តេសំ នោ ភន្តេ ភគវា អច្ចយំ
អច្ចយតោ បដិគ្គណ្ហាតុ អាយតឹ សំវរាយាតិ ។ តគ្ឃ
តុម្ហេ ភិក្ខវេ អច្ចយោ អច្ចគ្គមា យថាពាលេ យថា-
មូឡ្ហេ យថាអកុសលេ យេ តុម្ហេ សុទ្ធំ ភិក្ខុំ អនាបត្តិកំ
អវត្ថុស្មឹ អការណេ ឧក្ខិបិត្ថ យតោ ច ខោ តុម្ហេ
ភិក្ខវេ អច្ចយំ អច្ចយតោ ទិស្វា យថាធម្មំ បដិករោថ



គ្មានហេតុទេ ម្នាលមោឃបុរសទាំងឡាយ ការនេះមិនមែនឲ្យជ្រះថ្លាដល់
ពួកជនដែលមិនទាន់ជ្រះថ្លា ។ បេ ។ ទ្រង់តិះដៀលហើយទ្រង់ធ្វើធម្មីក-
ថាប្រាស្រ័យហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវ
លើកវត្តភិក្ខុដ៏បរិសុទ្ធគ្មានអាបត្តិដោយគ្មានវត្ថុគ្មានហេតុទេ ភិក្ខុណាលើក
វត្ត ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។ គ្រានោះ ពួកភិក្ខុនោះក្រោកចាកអាសនៈ
ហើយធ្វើសំពត់ឆៀងស្មាម្ខាង ហើយក្រាបចុះទៀបព្រះបាទទាំង
ឡាយនៃព្រះដ៏មានព្រះភាគដោយសិរសា ហើយទូលពាក្យនេះនឹងព្រះ
ដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន យើងខ្ញុំទាំងឡាយត្រូវទោស
ព្រោះជាបុគ្គលពាលយ៉ាងណា ជាបុគ្គលវង្វេងយ៉ាងណា ជាបុគ្គលមិន
ឈ្លាសយ៉ាងណា (ដោយហេតុ) យើងខ្ញុំទាំងឡាយលើកវត្តភិក្ខុដ៏ស្អាត
មិនមានអាបត្តិដោយគ្មានវត្ថុគ្មានហេតុ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏
មានព្រះភាគទទួលនូវទោសតាមទោសនៃយើងខ្ញុំទាំងឡាយដើម្បីសង្រួម
តទៅ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវ
ទោសព្រោះជាបុគ្គលពាល ជាបុគ្គលវង្វេង ជាបុគ្គលមិនឈ្លាសយ៉ាងណា
(ដោយហេតុ) អ្នកទាំងឡាយបានលើកវត្តភិក្ខុដ៏ស្អាតមិនមានអាបត្តិដោយ
គ្មានវត្ថុគ្មានហេតុ ម្នាលភិក្ខុទាំងឡាយ កាលណាបើអ្នកទាំងឡាយ
ឃើញទោសតាមទោសហើយធ្វើតាមធម៌ (សំដែង) នូវទោសតាមធម៌ពុះ

តំ តេ មយំ បដិគ្គណ្ហាម វុឌ្ឍិ ហេសា ភិក្ខុ អរិយស្ស វិនយេ យោ អច្ចយំ អច្ចយតោ ទិស្វា យថាធម្មំ បដិករោតិ អាយតិំ សំវរំ អាបជ្ជតីតិ ។

[៨១] តេន ខោ បន សមយេន ចម្បាយំ ភិក្ខូ ឯវរូបានិ កម្មានិ ករោន្តិ អធម្មេន វគ្គកម្មំ[1] ករោន្តិ អធម្មេន សមគ្គកម្មំ[2] ករោន្តិ ធម្មេន វគ្គកម្មំ ករោន្តិ ធម្មប្បតិរូបកេន វគ្គកម្មំ ករោន្តិ ធម្មប្បតិរូបកេន សមគ្គកម្មំ ករោន្តិ ឯកោបិ ឯកំ ឧក្ខិបតិ ឯកោបិ ទ្វេ ឧក្ខិបតិ ឯកោបិ សម្ពហុលេ ឧក្ខិបតិ ឯកោបិ សង្ឃំ ឧក្ខិបតិ ទ្វេបិ ឯកំ ឧក្ខិបន្តិ ទ្វេបិ ទ្វេ ឧក្ខិបន្តិ ទ្វេបិ សម្ពហុលេ ឧក្ខិបន្តិ ទ្វេបិ សង្ឃំ ឧក្ខិបន្តិ សម្ពហុលាបិ ឯកំ ឧក្ខិបន្តិ សម្ពហុលាបិ ទ្វេ ឧក្ខិបន្តិ សម្ពហុលាបិ សម្ពហុលេ ឧក្ខិបន្តិ សម្ពហុលាបិ សង្ឃំ ឧក្ខិបន្តិ សង្ឃោបិ សង្ឃំ ឧក្ខិបតិ ។ យេ តេ ភិក្ខូ

១-២ សព្វត្ថ វគ្គកម្មន្តិ ច សមគ្គកម្មន្តិ ច ទិស្សន្តិ ។ ពាមំ ៥៥ ឧបោសថក្ខន្ធកេ បាលិយា ៩ សមេន្តិ ។ តត្ថ ហិ ចត្តារិមានិ ភិក្ខវេ ឧបោសថកម្មានិ អធម្មេន វគ្គំ ឧបោសថកម្មន្តិអាទិកា បាលិ ទិស្សតិ ។



តថាគតទទួលអត់ទោសនោះរបស់អ្នកទាំងឡាយ ម្នាលភិក្ខុទាំងឡាយ សេចក្តីគឺថា ភិក្ខុណាឃើញទោសតាមពិតហើយធ្វើតបទោសនោះ តាមធម៌ ដល់នូវសេចក្តីសង្រួមតទៅ នេះជាសេចក្តីចំរើនរបស់ភិក្ខុនោះ ក្នុងអរិយវិន័យ ។

[៨១] សម័យនោះឯង ភិក្ខុទាំងឡាយនៅក្នុងក្រុងចម្បា ធ្វើកម្មទាំងឡាយមានសភាពយ៉ាងនេះ គឺធ្វើកម្មជាពួកព្រមទាំងមិនប្រកបដោយធម៌ខ្លះ ធ្វើកម្មព្រមព្រៀងតែមិនប្រកបដោយធម៌ខ្លះ ធ្វើកម្មជាពួកតែប្រកបដោយធម៌ខ្លះ ធ្វើកម្មជាពួកព្រមទាំងប្រកបដោយធម្មប្បដិរូបខ្លះ ធ្វើកម្មព្រមព្រៀងតែប្រកបដោយធម្មប្បដិរូបខ្លះ ភិក្ខុមួយរូបលើកវត្តភិក្ខុមួយរូបក៏មាន ភិក្ខុមួយរូបលើកវត្តភិក្ខុពីររូបក៏មាន ភិក្ខុមួយរូបលើកវត្តភិក្ខុច្រើនរូបក៏មាន ភិក្ខុមួយរូបលើកវត្តសង្ឃក៏មាន ភិក្ខុពីររូបលើកវត្តភិក្ខុមួយរូបក៏មាន ភិក្ខុពីររូបលើកវត្តភិក្ខុពីររូបក៏មាន ភិក្ខុពីររូបលើកវត្តភិក្ខុច្រើនរូបក៏មាន ភិក្ខុពីររូបលើកវត្តសង្ឃក៏មាន ភិក្ខុច្រើនរូបលើកវត្តភិក្ខុមួយរូបក៏មាន ភិក្ខុច្រើនរូបលើកវត្តភិក្ខុពីររូបក៏មាន ភិក្ខុច្រើនរូបលើកវត្តភិក្ខុច្រើនរូបក៏មាន ភិក្ខុច្រើនរូបលើកវត្តសង្ឃក៏មាន សង្ឃលើកវត្តសង្ឃក៏មាន ។ ភិក្ខុទាំងឡាយណា

អព្ភេន្តិ ។ បេ ។ តេ ឧក្ខិបន្តិ ចិយន្តិ វិនាចេន្តិ ករិ យាំ ឋាន ចប្បាយំ ភិក្ខុ បដិក្ខារេតិ ករណំ ករិស្សន្តិ អធម្មេន វគ្គកម្មំ ករិស្សន្តិ ។ បេ ។ សម្មោហំ សង្ឃំ ឧក្ខិបិស្សន្តិ ។ អធម្មោ តេ ភិក្ខុ គណភេទ បវត្តន្តិ អាវេទេ-សុំ ។ សច្ចំ កិរ ភិក្ខវេ ចប្បាយំ ភិក្ខុ បដិក្ខារេតិ ករណំ ករោន្តិ អធម្មេន វគ្គកម្មំ ករោន្តិ ។ បេ ។ សម្មោហំ សង្ឃំ ឧក្ខិបន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា ។ បេ ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ ។

(៨២) អធម្មេន ចេ ភិក្ខវេ វគ្គកម្មំ អកម្មំ ន ច ករណីយំ ។ អធម្មេន ចេ ភិក្ខវេ សមគ្គកម្មំ អកម្មំ ន ច ករណីយំ ។ ធម្មេន ចេ ភិក្ខវេ វគ្គកម្មំ អកម្មំ ន ច ករណីយំ ។ ធម្មប្បដិរូបកេន ចេ ភិក្ខវេ



មានសេចក្ដីព្រមព្រៀងគ្នា ។ បេ ។ ភិក្ខុទាំងឡាយនោះតោលតោស តិះ-ដៀល បន្ទោសថា ភិក្ខុគណៈនេះ ធ្វើកម្មទាំងឡាយមាន សភាពយ៉ាងនេះ ទីធ្វើកម្មជាពួកព្រមទាំងមិនប្រកបដោយធម៌ ។ បេ ។ សង្ឃលើកវត្តសង្ឃក៏មាន ។ គ្រានោះ ពួកភិក្ខុនោះក្រាបបង្គំទូលសេចក្ដី នុះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឮថា ពួកភិក្ខុចប្បាយំធ្វើកម្មទាំងឡាយមានសភាពយ៉ាងនេះ គឺធ្វើកម្មជាពួកព្រមទាំងមិនប្រកបដោយធម៌ ។ បេ ។ សង្ឃលើកវត្តសង្ឃក៏មាន ពិតមែនឬ ។ ពួកភិក្ខុក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់បន្ទោស ។ បេ ។ លុះទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថាទូន្មានពួកភិក្ខុទាំងឡាយមកថា ។

(៨២) ម្នាលភិក្ខុទាំងឡាយ បើកម្មជាពួកទាំងមិនប្រកបដោយធម៌ ក៏ឈ្មោះថាមិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ ។ ម្នាលភិក្ខុទាំងឡាយ បើកម្មព្រមព្រៀងតែមិនប្រកបដោយធម៌ក៏ឈ្មោះថាមិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ ។ ម្នាលភិក្ខុទាំងឡាយ បើកម្មជាពួកតែប្រកបដោយធម៌ ក៏ឈ្មោះថាមិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ ។ ម្នាលភិក្ខុទាំងឡាយ

វគ្គកម្មំ អកម្មំ ន ច ករណីយំ ។ ធម្មប្បតិរូបកេន ចេ ភិក្ខវេ សមគ្គកម្មំ អកម្មំ ន ច ករណីយំ ។ ឯកោបិ ឯកំ ឧក្ខិបតិ អកម្មំ ន ច ករណីយំ ។ ឯកោបិ ទ្វេ ឧក្ខិបតិ អកម្មំ ន ច ករណីយំ ។ ឯកោបិ សម្ពហុលេ ឧក្ខិបតិ អកម្មំ ន ច ករណីយំ ។ ឯកោបិ សង្ឃំ ឧក្ខិបតិ អកម្មំ ន ច ករណីយំ ។ ទ្វេបិ ឯកំ ឧក្ខិបន្តិ អកម្មំ ន ច ករណីយំ ។ ទ្វេបិ ទ្វេ ឧក្ខិបន្តិ អកម្មំ ន ច ករណីយំ ។ ទ្វេបិ សម្ពហុលេ ឧក្ខិបន្តិ អកម្មំ ន ច ករណីយំ ។ ទ្វេបិ សង្ឃំ ឧក្ខិបន្តិ អកម្មំ ន ច ករណីយំ ។ សម្ពហុលាបិ ឯកំ ឧក្ខិបន្តិ អកម្មំ ន ច ករណីយំ ។ សម្ពហុលាបិ ទ្វេ ឧក្ខិបន្តិ អកម្មំ ន ច ករណីយំ ។ សម្ពហុលាបិ សម្ពហុលេ ឧក្ខិបន្តិ អកម្មំ ន ច ករណីយំ ។ សម្ពហុលាបិ សង្ឃំ ឧក្ខិបន្តិ អកម្មំ ន ច ករណីយំ ។ សង្ឃោបិ សង្ឃំ ឧក្ខិបតិ អកម្មំ ន ច ករណីយំ ។



បើកម្មជាវគ្គតាំងនៅប្រកបដោយធម្មប្បតិរូប ក៏ឈ្មោះថាមិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ ។ ម្នាលភិក្ខុទាំងឡាយ បើកម្មព្រមព្រៀងតាំងនៅប្រកបដោយធម្មប្បតិរូប ក៏ឈ្មោះថាមិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ ។ ភិក្ខុមួយរូបលើកវត្តភិក្ខុមួយរូប ក៏ឈ្មោះថាមិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ ភិក្ខុមួយរូបលើកវត្តភិក្ខុពីររូប ក៏ឈ្មោះថាមិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ ។ ភិក្ខុមួយរូបលើកវត្តភិក្ខុច្រើនរូប ក៏ឈ្មោះថាមិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ ។ ភិក្ខុមួយរូបលើកវត្តសង្ឃ ក៏ឈ្មោះថាមិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ ។ ភិក្ខុពីររូបលើកវត្តភិក្ខុមួយរូប ក៏ឈ្មោះថាមិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ ។ ភិក្ខុពីររូបលើកវត្តភិក្ខុពីររូប ក៏ឈ្មោះថាមិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ ។ ភិក្ខុពីររូបលើកវត្តភិក្ខុច្រើនរូប ក៏ឈ្មោះថាមិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ ។ ភិក្ខុពីររូបលើកវត្តសង្ឃ ក៏ឈ្មោះថាមិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ ។ ភិក្ខុច្រើនរូបលើកវត្តចំពោះភិក្ខុមួយរូប ក៏ឈ្មោះថាមិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ ។ ភិក្ខុច្រើនរូបលើកវត្តភិក្ខុពីររូប ក៏ឈ្មោះថាមិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ ។ ភិក្ខុច្រើនរូបលើកវត្តភិក្ខុច្រើនរូប ក៏ឈ្មោះថាមិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ ។ ភិក្ខុច្រើនរូបលើកវត្តសង្ឃ ក៏ឈ្មោះថាមិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ ។ សង្ឃលើកវត្តសង្ឃ ក៏ឈ្មោះថាមិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ ។

(៨៣) ចត្តារីមានិ ភិក្ខវេ កម្មានិ អធម្មេន វគ្គកម្មំ អធម្មេន សមគ្គកម្មំ ធម្មេន វគ្គកម្មំ ធម្មេន សមគ្គកម្មំ ។ តត្រ ភិក្ខវេ យមិទំ(១) អធម្មេន វគ្គកម្មំ ឥទំ ភិក្ខវេ កម្មំ អធម្មត្តា វគ្គត្តា កុប្បំ អដ្ឋានារហំ ន ភិក្ខវេ ឯវរូបំ កម្មំ កាតព្វំ ន ច មយា ឯវរូបំ កម្មំ អនុញ្ញាតំ ។ តត្រ ភិក្ខវេ យមិទំ អធម្មេន សមគ្គកម្មំ ឥទំ ភិក្ខវេ កម្មំ អធម្មត្តា កុប្បំ អដ្ឋានារហំ ន ភិក្ខវេ ឯវរូបំ កម្មំ កាតព្វំ ន ច មយា ឯវរូបំ កម្មំ អនុញ្ញាតំ ។ តត្រ ភិក្ខវេ យមិទំ ធម្មេន វគ្គកម្មំ ឥទំ ភិក្ខវេ កម្មំ វគ្គត្តា កុប្បំ អដ្ឋានារហំ ន ភិក្ខវេ ឯវរូបំ កម្មំ កាតព្វំ ន ច មយា ឯវរូបំ កម្មំ អនុញ្ញាតំ ។

១ ម. យទិទំ ។



(៨៣) ម្នាលភិក្ខុទាំងឡាយ ឯកម្មនេះមាន ៤ យ៉ាង គឺ កម្មជាពួកទាំងមិនប្រកបដោយធម៌ ១ កម្មព្រមព្រៀងតែមិនប្រកបដោយធម៌ ១ កម្មជាពួកតែប្រកបដោយធម៌ ១ កម្មព្រមព្រៀងទាំងប្រកបដោយធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាកម្មទាំង ៤ យ៉ាងនោះ កម្មណា ជាពួកទាំងមិនប្រកបដោយធម៌ ម្នាលភិក្ខុទាំងឡាយ កម្មនេះឈ្មោះថាកម្មកំរើក (ខូច) មិនគួរដល់ហេតុ ព្រោះជាកម្មមិនប្រកបដោយធម៌ផង ជាពួកផង ម្នាលភិក្ខុទាំងឡាយ កម្មមានសភាពយ៉ាងនេះ ភិក្ខុមិនត្រូវធ្វើទេ កម្មមានសភាពយ៉ាងនេះ តថាគតមិនបានអនុញ្ញាតទេ ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាកម្មទាំងឡាយនោះ កម្មណាព្រមព្រៀងតែមិនប្រកបដោយធម៌ ម្នាលភិក្ខុទាំងឡាយ កម្មនេះជាកម្មកំរើក មិនគួរដល់ហេតុ ព្រោះជាកម្មនោះមិនប្រកបដោយធម៌ ម្នាលភិក្ខុទាំងឡាយ កម្មមានសភាពយ៉ាងនេះ ភិក្ខុមិនត្រូវធ្វើទេ កម្មមានសភាពយ៉ាងនេះ តថាគតមិនបានអនុញ្ញាតទេ ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាកម្មទាំងឡាយនោះ កម្មណាជាពួកតែប្រកបដោយធម៌ ម្នាលភិក្ខុទាំងឡាយ កម្មនេះឈ្មោះថាកម្មកំរើក មិនគួរដល់ហេតុ ព្រោះជាកម្មនោះជាពួក ម្នាលភិក្ខុទាំងឡាយ កម្មមានសភាពយ៉ាងនេះ ភិក្ខុមិនត្រូវធ្វើទេ កម្មមានសភាពយ៉ាងនេះ តថាគតមិនបានអនុញ្ញាតទេ ។

តត្រ ភិក្ខវេ យទិទំ ធម្មេន សមគ្គកម្មំ ឥទំ ភិក្ខវេ កម្មំ ធម្មត្តា សមគ្គត្តា អកុប្បំ ឋានារហំ ឯវរូបំ ភិក្ខវេ កម្មំ កាតព្វំ ឯវរូបញ្ច មយា កម្មំ អនុញ្ញាតំ ។ តស្មាតិហ ភិក្ខវេ ឯវរូបំ កម្មំ ករិស្សាម យទិទំ ធម្មេន សមគ្គន្តិ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។

[៨៦] តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ឯវរូបានិ កម្មានិ ករោន្តិ អធម្មេន វគ្គកម្មំ ករោន្តិ អធម្មេន សមគ្គកម្មំ ករោន្តិ ធម្មេន វគ្គកម្មំ ករោន្តិ ធម្មប្បតិរូបកេន វគ្គកម្មំ ករោន្តិ ធម្មប្បតិរូបកេន សមគ្គកម្មំ ករោន្តិ ញត្តិវិបន្នម្បិ កម្មំ ករោន្តិ អនុស្សាវនសម្បន្នំ(១) អនុស្សាវនវិបន្នម្បិ កម្មំ ករោន្តិ ញត្តិសម្បន្នំ ញត្តិវិបន្នម្បិ អនុស្សាវនវិបន្នម្បិ កម្មំ ករោន្តិ អញ្ញត្រាបិ ធម្មា កម្មំ ករោន្តិ អញ្ញត្រាបិ វិនយា

១ អនុស្សាវនសម្បន្នន្តិ បាឋោ ។



ម្នាលភិក្ខុទាំងឡាយ បណ្ដាកម្មទាំងឡាយនោះ កម្មណាព្រមព្រៀងទាំងប្រកបដោយធម៌ ម្នាលភិក្ខុទាំងឡាយ កម្មនេះឯង ជាកម្មមិនកំរើក ជាកម្មគួរដល់ហេតុ ព្រោះថាកម្មនោះប្រកបដោយធម៌ផង ព្រមព្រៀងផង ម្នាលភិក្ខុទាំងឡាយ កម្មមានសភាពយ៉ាងនេះ ភិក្ខុត្រូវធ្វើចុះ កម្មមានសភាពយ៉ាងនេះតថាគតក៏អនុញ្ញាត ។ ព្រោះហេតុដូច្នោះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសិក្សាក្នុងសាសនានេះថា យើងទាំងឡាយនឹងធ្វើកម្មមានសភាពយ៉ាងនេះ គឺកម្មព្រមព្រៀងគ្នាទាំងប្រកបដោយធម៌ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសិក្សាដោយប្រការដូច្នេះឯង ។

[៨៦] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុធ្វើកម្មទាំងឡាយមានសភាពយ៉ាងនេះ គឺ ធ្វើកម្មជាពួកទាំងមិនប្រកបដោយធម៌ខ្លះ ធ្វើកម្មព្រមព្រៀងតែមិនប្រកបដោយធម៌ខ្លះ ធ្វើកម្មជាពួកតែប្រកបដោយធម៌ខ្លះ ធ្វើកម្មជាពួកទាំងប្រកបដោយធម៌ប្លមខ្លះ ធ្វើកម្មព្រមព្រៀងតែប្រកបដោយធម៌ប្លមខ្លះ ធ្វើកម្មវិបត្តិដោយញត្តិ តែបរិបូណ៌ដោយអនុស្សាវនាខ្លះ ធ្វើកម្មវិបត្តិដោយអនុស្សាវនា តែបរិបូណ៌ដោយញត្តិខ្លះ ធ្វើកម្មវិបត្តិដោយញត្តិនឹងវិបត្តិដោយអនុស្សាវនាខ្លះ ធ្វើកម្មខុសចាកធម៌ខ្លះ ធ្វើកម្មខុសចាកវិន័យខ្លះ

កម្មំ ករោន្តិ អញ្ញត្រាបិ សត្ថុ សាសនា កម្មំ ករោន្តិ បដិក្កុដ្ឋកតម្បិ កម្មំ ករោន្តិ អធម្មិកំ កុប្បំ អដ្ឋានារហំ ។ បេ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ចម្បេយ្យកា ភិក្ខូ ឯវរូបានិ កម្មានិ ករិស្សន្តិ អធម្មេន វគ្គកម្មំ ករិស្សន្តិ ។បេ។ បដិក្កុដ្ឋកតម្បិ កម្មំ ករិស្សន្តិ អធម្មិកំ កុប្បំ អដ្ឋានារហន្តិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ សច្ចំ កិរ ភិក្ខវេ ចម្បេយ្យកា ភិក្ខូ ឯវរូបានិ កម្មានិ ករោន្តិ អធម្មេន វគ្គកម្មំ ករោន្តិ ។បេ។ បដិក្កុដ្ឋកតម្បិ កម្មំ ករោន្តិ អធម្មិកំ កុប្បំ អដ្ឋានារហន្តិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា ។បេ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ ។

(៨៥) អធម្មេន ចេ ភិក្ខវេ វគ្គកម្មំ អកម្មំ ន ច ករណីយំ ។ អធម្មេន ចេ ភិក្ខវេ សមគ្គកម្មំ អកម្មំ





ធ្វើកម្មខុសសាសនាសត្ថុ ។បេ។ ធ្វើកម្មដែលព្រះពុទ្ធតិះដៀលហើយ ជាកម្មមិនប្រកបដោយធម៌ ជាកម្មកំរើក មិនគួរដល់ហេតុនុះ ។ ពួកភិក្ខុណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ពួកភិក្ខុទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកចម្បេយ្យកភិក្ខុមិនគួរនឹងធ្វើកម្មទាំងឡាយមានសភាពយ៉ាងនេះសោះ គឺធ្វើកម្មជាពួកទាំងមិនប្រកបដោយធម៌នុះ ។បេ។ ធ្វើកម្មដែលព្រះពុទ្ធទ្រង់តិះដៀលហើយ ជាកម្មមិនប្រកបដោយធម៌ ជាកម្មកំរើក ជាកម្មមិនគួរដល់ហេតុនុះ ។ គ្រានោះ ពួកភិក្ខុនោះក្រាបបង្គំទូលសេចក្តីនុះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកចម្បេយ្យកភិក្ខុធ្វើកម្មទាំងឡាយមានសភាពយ៉ាងនេះ គឺធ្វើកម្មជាពួកទាំងមិនប្រកបដោយធម៌នុះ ។បេ។ ធ្វើកម្មដែលព្រះពុទ្ធទ្រង់តិះដៀល ជាកម្មមិនប្រកបដោយធម៌ ជាកម្មកំរើក ជាកម្មមិនគួរដល់ហេតុនុះ ពិតមែនឬ ។ ពួកភិក្ខុក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀល ។បេ។ លុះទ្រង់តិះដៀលហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ។

(៨៥) ម្នាលភិក្ខុទាំងឡាយ បើកម្មជាពួកទាំងមិនប្រកបដោយធម៌ ឈ្មោះថាមិនមែនជាកម្ម មិនគួរធ្វើទេ ។ ម្នាលភិក្ខុទាំងឡាយ បើកម្មព្រមព្រៀងតែមិនប្រកបដោយធម៌ ក៏ឈ្មោះថាមិនមែនជាកម្ម មិន

ន ច ករណីយំ ។ ធម្មេន ចេ ភិក្ខវេ វគ្គកម្មំ អកម្មំ ន ច ករណីយំ ។ ធម្មប្បដិរូបកេន ចេ ភិក្ខវេ វគ្គកម្មំ អកម្មំ ន ច ករណីយំ ។ ធម្មប្បដិរូបកេន ចេ ភិក្ខវេ សមគ្គកម្មំ អកម្មំ ន ច ករណីយំ ។ ញត្តិវិបន្នញ្ចេ ភិក្ខវេ កម្មំ អនុស្សាវនសម្បន្នំ អកម្មំ ន ច ករណីយំ ។ អនុស្សាវនវិបន្នញ្ចេ ភិក្ខវេ កម្មំ ញត្តិសម្បន្នំ អកម្មំ ន ច ករណីយំ ។ ញត្តិវិបន្នញ្ចេ ភិក្ខវេ កម្មំ អនុស្សាវនវិបន្នំ អកម្មំ ន ច ករណីយំ ។ អញ្ញត្រាបិ ភិក្ខវេ ធម្មា កម្មំ អកម្មំ ន ច ករណីយំ ។ អញ្ញត្រាបិ ភិក្ខវេ វិនយា កម្មំ អកម្មំ ន ច ករណីយំ ។ អញ្ញត្រាបិ ភិក្ខវេ សត្ថុសាសនា កម្មំ អកម្មំ ន ច ករណីយំ ។ បដិក្កុដ្ឋកតំ ចេ ភិក្ខវេ កម្មំ អកតំ កុប្បំ អដ្ឋានារហំ អកម្មំ ន ច ករណីយំ ។



ត្រូវធ្វើទេ ។ ម្នាលភិក្ខុទាំងឡាយ បើកម្មជាពួកតែប្រកបដោយធម៌ ក៏ឈ្មោះថាមិនមែនជាកម្ម មិនត្រូវធ្វើទេ ។ ម្នាលភិក្ខុទាំងឡាយ បើកម្មជាពួកតាំងប្រកបដោយធម៌ប្លម ក៏ឈ្មោះថាមិនមែនជាកម្ម មិនត្រូវធ្វើទេ ។ ម្នាលភិក្ខុទាំងឡាយ បើកម្មព្រមព្រៀងតែប្រកបដោយធម៌ប្លម ក៏ឈ្មោះថាមិនមែនជាកម្ម មិនត្រូវធ្វើទេ ។ ម្នាលភិក្ខុទាំងឡាយ បើកម្មវិបត្តិដោយញត្តិ តែបរិបូណ៌ដោយអនុស្សាវនា ក៏ឈ្មោះថាមិនមែនជាកម្ម មិនត្រូវធ្វើទេ ។ ម្នាលភិក្ខុទាំងឡាយ បើកម្មវិបត្តិដោយអនុស្សាវនា តែបរិបូណ៌ដោយញត្តិ ក៏ឈ្មោះថាមិនមែនជាកម្ម មិនត្រូវធ្វើទេ ។ ម្នាលភិក្ខុទាំងឡាយ បើកម្មវិបត្តិដោយញត្តិផង វិបត្តិដោយអនុស្សាវនាផង ក៏ឈ្មោះថាមិនមែនជាកម្ម មិនត្រូវធ្វើទេ ។ ម្នាលភិក្ខុទាំងឡាយ កម្មខុសចាកធម៌ ក៏ឈ្មោះថាមិនមែនជាកម្ម មិនត្រូវធ្វើទេ ។ ម្នាលភិក្ខុទាំងឡាយ កម្មខុសចាកវិន័យ ក៏ឈ្មោះថាមិនមែនជាកម្ម មិនត្រូវធ្វើទេ ។ ម្នាលភិក្ខុទាំងឡាយ កម្មខុសចាកសត្ថុសាសនៈ ក៏ឈ្មោះថាមិនមែនជាកម្ម មិនត្រូវធ្វើទេ ។ ម្នាលភិក្ខុទាំងឡាយ បើកម្មដែលព្រះភគវន្តទ្រង់តិះដៀល ជាកម្មមិនប្រកបដោយធម៌ ជាកម្មកំរើក ជាកម្មមិនគួរដល់ហេតុ ក៏ឈ្មោះថាមិនមែនជាកម្ម មិនត្រូវធ្វើទេ ។

(៨៦) ឆយិមានិ ភិក្ខវេ កម្មានិ អធម្មកម្មំ វគ្គកម្មំ សមគ្គកម្មំ ធម្មប្បតិរូបកេន វគ្គកម្មំ ធម្មប្បតិរូបកេន សមគ្គកម្មំ ធម្មេន សមគ្គកម្មំ ។

(៨៧) កតមញ្ច ភិក្ខវេ អធម្មកម្មំ ។ ញត្តិទុតិយេ ចេ ភិក្ខវេ កម្មេ ឯកាយ ញត្តិយា កម្មំ ករោតិ ន ច កម្មវាចំ អនុស្សាវេតិ អធម្មកម្មំ ។ ញត្តិទុតិយេ ចេ ភិក្ខវេ កម្មេ ទ្វីហិ ញត្តីហិ កម្មំ ករោតិ ន ច កម្មវាចំ អនុស្សាវេតិ អធម្មកម្មំ ។ ញត្តិទុតិយេ ចេ ភិក្ខវេ កម្មេ ឯកាយ កម្មវាចាយ កម្មំ ករោតិ ន ច ញត្តិំ ឋបេតិ អធម្មកម្មំ ។ ញត្តិទុតិយេ ចេ ភិក្ខវេ កម្មេ ទ្វីហិ កម្មវាចាហិ កម្មំ ករោតិ ន ច ញត្តិំ ឋបេតិ អធម្មកម្មំ ។ ញត្តិចតុត្ថេ ចេ ភិក្ខវេ កម្មេ ឯកាយ ញត្តិយា កម្មំ ករោតិ ន ច កម្មវាចំ អនុស្សាវេតិ អធម្មកម្មំ ។ ញត្តិចតុត្ថេ ចេ ភិក្ខវេ កម្មេ ទ្វីហិ ញត្តីហិ តីហិ ញត្តីហិ ចតូហិ ញត្តីហិ កម្មំ ករោតិ ន ច កម្មវាចំ អនុស្សាវេតិ អធម្មកម្មំ ។



(៨៦) ម្នាលភិក្ខុទាំងឡាយ កម្មនេះមាន ៦ យ៉ាង គឺកម្មមិនប្រកបដោយធម៌ ១ កម្មជាពួក ១ កម្មព្រមព្រៀង ១ កម្មជាពួកទាំងប្រកបដោយធម៌ប្លម ១ កម្មព្រមព្រៀងតែប្រកបដោយធម៌ប្លម ១ កម្មព្រមព្រៀងទាំងប្រកបដោយធម៌ ១ ។

(៨៧) ម្នាលភិក្ខុទាំងឡាយ កម្មមិនប្រកបដោយធម៌តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់ពីរ (សង្ឃ) ធ្វើកម្មដោយញត្តិមួយ តែមិនសូត្រកម្មវាចា ហៅថាកម្មមិនប្រកបដោយធម៌ ។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់ពីរ (សង្ឃ) ធ្វើកម្មដោយញត្តិពីរផង តែមិនសូត្រកម្មវាចា ហៅថាកម្មមិនប្រកបដោយធម៌ ។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់ពីរ (សង្ឃ) ធ្វើកម្មដោយកម្មវាចា ១ តែមិនតាំងញត្តិ ហៅថាកម្មមិនប្រកបដោយធម៌ ។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់ពីរ (សង្ឃ) ធ្វើកម្មដោយកម្មវាចាពីរ តែមិនតាំងញត្តិ ហៅថាកម្មមិនប្រកបដោយធម៌ ។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់ ៤ (សង្ឃ) ធ្វើកម្មដោយញត្តិ ១ តែមិនសូត្រកម្មវាចា ហៅថាកម្មមិនប្រកបដោយធម៌ ។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់ ៤ (សង្ឃ) ធ្វើកម្មដោយញត្តិពីរក្ដី ដោយញត្តិបីក្ដី ដោយញត្តិបួនក្ដី តែមិនសូត្រកម្មវាចា ហៅថាកម្មមិនប្រកបដោយធម៌ ។

ញត្តិចតុត្ថេ ចេ ភិក្ខវេ កម្មេ ឯកាយ កម្មវាចាយ កម្មំ ករោតិ ន ច ញត្តឹ ឋបេតិ អធម្មកម្មំ ។ ញត្តិចតុត្ថេ ចេ ភិក្ខវេ កម្មេ ទ្វីហិ កម្មវាចាហិ តីហិ កម្មវាចាហិ ចតូហិ កម្មវាចាហិ កម្មំ ករោតិ ន ច ញត្តឹ ឋបេតិ អធម្មកម្មំ ។ ឥទំ វុច្ចតិ ភិក្ខវេ អធម្មកម្មំ ។

(៨៨) កតមញ្ច ភិក្ខវេ វគ្គកម្មំ ។ ញត្តិទុតិយេ ចេ ភិក្ខវេ កម្មេ យាវតិកា ភិក្ខូ កម្មប្បត្តា តេ អនាគតា ហោន្តិ ឆន្ទារហានំ ឆន្ទោ អនាហដោ ហោតិ សម្មុខីភូតា បដិក្កោសន្តិ វគ្គកម្មំ ។ ញត្តិទុតិយេ ចេ ភិក្ខវេ កម្មេ យាវតិកា ភិក្ខូ កម្មប្បត្តា តេ អាគតា ហោន្តិ ឆន្ទារហានំ ឆន្ទោ អនាហដោ ហោតិ សម្មុខីភូតា បដិក្កោសន្តិ វគ្គកម្មំ ។ ញត្តិទុតិយេ ចេ ភិក្ខវេ កម្មេ យាវតិកា ភិក្ខូ កម្មប្បត្តា តេ អាគតា ហោន្តិ ឆន្ទារហានំ ឆន្ទោ អាហដោ ហោតិ សម្មុខីភូតា



ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់៤ (សង្ឃ) ធ្វើកម្មដោយកម្មវាចា១ តែមិនតាំងញត្តិ ហៅថាកម្មមិនប្រកបដោយធម៌ ។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់៤ (សង្ឃ) ធ្វើកម្មដោយកម្មវាចាពីរក្តី ដោយកម្មវាចាបីក្តី ដោយកម្មវាចាបួនក្តី តែមិនបានតាំងញត្តិ ហៅថាកម្មមិនប្រកបដោយធម៌ ។ ម្នាលភិក្ខុទាំងឡាយ កម្មនេះតថាគតហៅថាកម្មមិនប្រកបដោយធម៌ ។

(៨៨) ម្នាលភិក្ខុទាំងឡាយ កម្មជាពួក (នោះ) តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់ពីរ ភិក្ខុប៉ុន្មានរូបគួរដល់កម្ម ភិក្ខុទាំងឡាយនោះមិនបានមកជួបជុំគ្នាក្តី ឆន្ទរបស់ភិក្ខុទាំងឡាយដែលគួរដល់ឆន្ទភិក្ខុក៏មិនបាននាំមកក្តី ភិក្ខុទាំងឡាយដែលមានកន្លែងចំពោះមុខ ក៏ហាមឃាត់ក្តី ហៅថាកម្មជាពួក ។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់ពីរ ភិក្ខុប៉ុន្មានរូបដែលគួរដល់កម្ម ភិក្ខុទាំងឡាយនោះមកជួបជុំគ្នាហើយ តែឆន្ទរបស់ភិក្ខុទាំងឡាយដែលគួរដល់ឆន្ទភិក្ខុក៏មិនបាននាំមកក្តី ភិក្ខុទាំងឡាយដែលមានកន្លែងចំពោះមុខ ក៏ហាមឃាត់ក្តី ហៅថាកម្មជាពួក ។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់ពីរ ភិក្ខុដែលគួរដល់កម្មទាំងប៉ុន្មាន ភិក្ខុទាំងនោះក៏មកជួបជុំគ្នាហើយក្តី ឆន្ទរបស់ភិក្ខុទាំងឡាយដែលគួរដល់ឆន្ទភិក្ខុក៏បាននាំមកក្តី តែភិក្ខុទាំងឡាយដែលមានកន្លែងចំពោះមុខ

បដិក្កោសន្តិ វគ្គកម្មំ ។ ញត្តិចតុត្ថេ ចេ ភិក្ខវេ កម្មេ យាវតិកា ភិក្ខូ កម្មប្បត្តា តេ អនាគតា ហោន្តិ ឆន្ទារហានំ ឆន្ទោ អនាហដោ ហោតិ សម្មុខីភូតា បដិក្កោសន្តិ វគ្គកម្មំ ។ ញត្តិចតុត្ថេ ចេ ភិក្ខវេ កម្មេ យាវតិកា ភិក្ខូ កម្មប្បត្តា តេ អាគតា ហោន្តិ ឆន្ទារហានំ ឆន្ទោ អនាហដោ ហោតិ សម្មុខីភូតា បដិក្កោសន្តិ វគ្គកម្មំ ។ ញត្តិចតុត្ថេ ចេ ភិក្ខវេ កម្មេ យាវតិកា ភិក្ខូ កម្មប្បត្តា តេ អាគតា ហោន្តិ ឆន្ទារហានំ ឆន្ទោ អាហដោ ហោតិ សម្មុខីភូតា បដិក្កោសន្តិ វគ្គកម្មំ ។ ឥទំ វុច្ចតិ ភិក្ខវេ វគ្គកម្មំ ។

[៨៩] កតមញ្ច ភិក្ខវេ សមគ្គកម្មំ ។ ញត្តិទុតិយេ ចេ ភិក្ខវេ កម្មេ យាវតិកា ភិក្ខូ កម្មប្បត្តា តេ អាគតា ហោន្តិ ឆន្ទារហានំ ឆន្ទោ អាហដោ ហោតិ



ក៏ហាមឃាត់កម្ម ហៅថាកម្មជាពួក ។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់ ៤ ភិក្ខុដែលគួរផ្សំកម្មទាំងប៉ុន្មាន ភិក្ខុទាំងនោះក៏មិនបានមកជួបជុំគ្នាក្តី ឆន្ទៈរបស់ភិក្ខុទាំងឡាយដែលគួរផ្សំឆន្ទៈ ក៏ភិក្ខុមិនបាននាំមកក្តី ភិក្ខុទាំងឡាយដែលមានក្នុងទីចំពោះមុខ ក៏ហាមឃាត់កម្មក្តី ហៅថាកម្មជាពួក ។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់ ៤ ភិក្ខុដែលគួរផ្សំកម្មទាំងប៉ុន្មាន ភិក្ខុទាំងនោះក៏បានមកជួបជុំគ្នាហើយ តែឆន្ទៈរបស់ភិក្ខុដែលគួរផ្សំឆន្ទៈ ភិក្ខុមិនបាននាំមក ភិក្ខុទាំងឡាយដែលមានក្នុងទីចំពោះមុខ ក៏ហាមឃាត់កម្មក្តី ហៅថាកម្មជាពួក ។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់ ៤ ភិក្ខុដែលគួរផ្សំកម្មទាំងប៉ុន្មាន ភិក្ខុទាំងនោះក៏បានមកជួបជុំគ្នាហើយ ឆន្ទៈរបស់ភិក្ខុដែលគួរផ្សំឆន្ទៈ ភិក្ខុបាននាំមកហើយ តែភិក្ខុដែលមានក្នុងទីចំពោះមុខហាមឃាត់កម្ម ហៅថាកម្មជាពួក ។ ម្នាលភិក្ខុទាំងឡាយ កម្មនេះឯងតថាគតហៅថា កម្មជាពួក ។

(៨៩) ម្នាលភិក្ខុទាំងឡាយ កម្មព្រមព្រៀង (នោះ) តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់ពីរ ភិក្ខុទាំងឡាយមានប៉ុន្មានរូបដែលគួរផ្សំកម្ម ភិក្ខុទាំងឡាយនោះបានមកជួបជុំគ្នាហើយផង ឆន្ទៈរបស់ភិក្ខុទាំងឡាយដែលគួរផ្សំឆន្ទៈ ភិក្ខុបាននាំមកហើយផង ភិក្ខុ

សម្មុខីភូតា នប្បដិក្កោសន្តិ សមគ្គកម្មំ ។ ញត្តិចតុត្ថេ ចេ ភិក្ខវេ កម្មេ យាវតិកា ភិក្ខូ កម្មប្បត្តា តេ អាគតា ហោន្តិ ឆន្ទារហានំ ឆន្ទោ អាហដោ ហោតិ សម្មុខីភូតា នប្បដិក្កោសន្តិ សមគ្គកម្មំ ។ ឥទំ វុច្ចតិ ភិក្ខវេ សមគ្គកម្មំ ។

[៩០] កតមញ្ច ភិក្ខវេ ធម្មប្បដិរូបកេន វគ្គកម្មំ ។ ញត្តិទុតិយេ ចេ ភិក្ខវេ កម្មេ បឋមំ កម្មវាចំ អនុស្សាវេតិ បច្ឆា ញត្តឹ ឋបេតិ យាវតិកា ភិក្ខូ កម្មប្បត្តា តេ អនាគតា ហោន្តិ ឆន្ទារហានំ ឆន្ទោ អនាហដោ ហោតិ សម្មុខីភូតា បដិក្កោសន្តិ ធម្មប្បដិរូបកេន វគ្គកម្មំ ។ ញត្តិទុតិយេ ចេ ភិក្ខវេ កម្មេ បឋមំ កម្មវាចំ អនុស្សាវេតិ បច្ឆា ញត្តឹ ឋបេតិ យាវតិកា ភិក្ខូ កម្មប្បត្តា តេ អាគតា ហោន្តិ ឆន្ទារហានំ ឆន្ទោ អនាហដោ



ទាំងឡាយដែលមានក្នុងទីចំពោះមុខ មិនហាមឃាត់កម្មផង ហៅថាកម្មព្រមព្រៀង ។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់ ៤ ភិក្ខុទាំងឡាយមានចំនួនប៉ុន្មានរូបដែលគួរដល់កម្ម ភិក្ខុទាំងឡាយនោះបានមកជួបជុំគ្នាហើយផង ឆន្ទៈរបស់ភិក្ខុទាំងឡាយដែលគួរដល់ឆន្ទៈ ភិក្ខុបាននាំមកហើយផង ភិក្ខុទាំងឡាយមានក្នុងទីចំពោះមុខ មិនហាមឃាត់កម្មផង ហៅថាកម្មព្រមព្រៀង ។ ម្នាលភិក្ខុទាំងឡាយ កម្មនេះតថាគតហៅថា កម្មព្រមព្រៀង ។

(៩០) ម្នាលភិក្ខុទាំងឡាយ កម្មជាពួកព្រមទាំងប្រែកប្រួលដោយធម៌បម តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់ពីរ (ភិក្ខុ) សូត្រកម្មវាចាជាមុន ទើបតាំងញត្តិជាខាងក្រោយវិញ ភិក្ខុទាំងឡាយមានចំនួនប៉ុន្មានរូបដែលគួរដល់កម្ម ភិក្ខុទាំងនោះមិនបានមកជួបជុំគ្នាក៏ឆន្ទៈរបស់ភិក្ខុទាំងឡាយដែលគួរដល់ឆន្ទៈ ភិក្ខុមិនបាននាំមកហើយក្តី ភិក្ខុទាំងឡាយដែលមានក្នុងទីចំពោះមុខ ហាមឃាត់កម្មក្តី ហៅថាកម្មជាពួកព្រមទាំងប្រែកប្រួលដោយធម៌បម ។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់ពីរ ភិក្ខុសូត្រកម្មវាចាជាមុន ទើបតាំងញត្តិជាខាងក្រោយវិញ ភិក្ខុទាំងឡាយមានចំនួនប៉ុន្មានរូបដែលគួរដល់កម្ម ភិក្ខុទាំងនោះបានមកជួបជុំគ្នាហើយ តែឆន្ទៈរបស់ភិក្ខុទាំងឡាយដែលគួរដល់ឆន្ទៈ ភិក្ខុមិនបាននាំមកក្តី ភិក្ខុទាំងឡាយ

ហោតិ សម្មុខីភូតា បដិក្កោសន្តិ ធម្មប្បតិរូបកេន វគ្គកម្មំ ។ ញត្តិទុតិយេ ចេ ភិក្ខវេ កម្មេ បឋមំ កម្មវាចំ អនុស្សាវេតិ បច្ឆា ញត្តិំ ឋបេតិ យាវតិកា ភិក្ខូ កម្មប្បត្តា តេ អាគតា ហោន្តិ ឆន្ទារហានំ ឆន្ទោ អាហដោ ហោតិ សម្មុខីភូតា បដិក្កោសន្តិ ធម្មប្បតិរូបកេន វគ្គកម្មំ ។ ញត្តិចតុត្ថេ ចេ ភិក្ខវេ កម្មេ បឋមំ កម្មវាចំ អនុស្សាវេតិ បច្ឆា ញត្តិំ ឋបេតិ យាវតិកា ភិក្ខូ កម្មប្បត្តា តេ អនាគតា ហោន្តិ ឆន្ទារហានំ ឆន្ទោ អនាហដោ ហោតិ សម្មុខីភូតា បដិក្កោសន្តិ ធម្មប្បតិរូបកេន វគ្គកម្មំ ។ ញត្តិចតុត្ថេ ចេ ភិក្ខវេ កម្មេ បឋមំ កម្មវាចំ អនុស្សាវេតិ បច្ឆា ញត្តិំ ឋបេតិ យាវតិកា ភិក្ខូ កម្មប្បត្តា តេ អាគតា ហោន្តិ ឆន្ទារហានំ ឆន្ទោ អនាហដោ ហោតិ សម្មុខីភូតា បដិក្កោសន្តិ ធម្មប្បតិរូបកេន វគ្គកម្មំ ។ ញត្តិចតុត្ថេ ចេ ភិក្ខវេ





ដែលមានខ្លួនចំពោះមុខ ហាមឃាត់កម្មក្តី ហៅថាកម្មជាពួកក្រុមតាំងប្រែកចេញដោយធម៌ប្លោម ។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់ពីរ ភិក្ខុសូត្រកម្មវាចាជាមុន ទើបតាំងញត្តិជាខាងក្រោយវិញ ភិក្ខុទាំងឡាយមានចំនួនគ្រប់ដែលគួរដល់កម្ម ភិក្ខុទាំងនោះបានមកជួបជុំគ្នាហើយក្តី ឆន្ទៈរបស់ភិក្ខុទាំងឡាយដែលគួរដល់ឆន្ទៈ ភិក្ខុបាននាំមកហើយក្តី តែភិក្ខុទាំងឡាយដែលមានខ្លួនចំពោះមុខ ហាមឃាត់កម្ម ហៅថាកម្មជាពួកក្រុមតាំងប្រែកចេញដោយធម៌ប្លោម ។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់ ៤ ភិក្ខុសូត្រកម្មវាចាជាមុន ទើបតាំងញត្តិជាខាងក្រោយវិញ ភិក្ខុទាំងឡាយមានចំនួនគ្រប់ដែលគួរដល់កម្ម ភិក្ខុទាំងនោះមិនបានមកជួបជុំគ្នាក្តី ឆន្ទៈរបស់ភិក្ខុទាំងឡាយដែលគួរដល់ឆន្ទៈ ភិក្ខុមិនបាននាំមកក្តី ភិក្ខុទាំងឡាយដែលមានខ្លួនចំពោះមុខ ហាមឃាត់កម្មក្តី ហៅថាកម្មជាពួកក្រុមតាំងប្រែកដោយធម៌ប្លោម ។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់ ៤ ភិក្ខុសូត្រកម្មវាចាជាមុន ទើបតាំងញត្តិជាខាងក្រោយវិញ ភិក្ខុទាំងឡាយមានចំនួនគ្រប់ដែលគួរដល់កម្ម ភិក្ខុទាំងនោះមកជួបជុំគ្នាហើយ តែឆន្ទៈរបស់ភិក្ខុទាំងឡាយដែលគួរដល់ឆន្ទៈ ភិក្ខុមិនបាននាំមកហើយក្តី ភិក្ខុទាំងឡាយដែលមានខ្លួនចំពោះមុខ ហាមឃាត់កម្មក្តី ហៅថាកម្មជាពួកក្រុមតាំងប្រែកដោយធម៌ប្លោម ។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់ ៤

កម្មេ បឋមំ កម្មវាចំ អនុស្សាវេតិ បច្ឆា ញត្តឹ ឋបេតិ យាវតិកា ភិក្ខូ កម្មប្បត្តា តេ អាគតា ហោន្តិ ឆន្ទារហានំ ឆន្ទោ អាហដោ ហោតិ សម្មុខីភូតា បដិក្កោសន្តិ ធម្មប្បដិរូបកេន វគ្គកម្មំ ។ ឥទំ វុច្ចតិ ភិក្ខវេ ធម្មប្បដិរូបកេន វគ្គកម្មំ ។

(៩១) កតមញ្ច ភិក្ខវេ ធម្មប្បដិរូបកេន សមគ្គកម្មំ ។ ញត្តិទុតិយេ ចេ ភិក្ខវេ កម្មេ បឋមំ កម្មវាចំ អនុស្សាវេតិ បច្ឆា ញត្តឹ ឋបេតិ យាវតិកា ភិក្ខូ កម្មប្បត្តា តេ អាគតា ហោន្តិ ឆន្ទារហានំ ឆន្ទោ អាហដោ ហោតិ សម្មុខីភូតា នប្បដិក្កោសន្តិ ធម្មប្បដិរូបកេន សមគ្គកម្មំ ។ ញត្តិចតុត្ថេ ចេ ភិក្ខវេ កម្មេ បឋមំ កម្មវាចំ អនុស្សាវេតិ បច្ឆា ញត្តឹ ឋបេតិ យាវតិកា ភិក្ខូ កម្មប្បត្តា តេ អាគតា ហោន្តិ ឆន្ទារហានំ ឆន្ទោ អាហដោ ហោតិ សម្មុខីភូតា នប្បដិក្កោសន្តិ



ភិក្ខុសូត្រកម្មវាចាជាមុន ទើបតាំងញត្តិជាខាងក្រោយវិញ ភិក្ខុទាំងឡាយមានចំនួនប៉ុន្មានរូបដែលគួរដល់កម្ម ភិក្ខុទាំងនោះបានមកជួបជុំគ្នាហើយក្តី ឆន្ទៈរបស់ភិក្ខុទាំងឡាយដែលគួរដល់ឆន្ទៈ ភិក្ខុបាននាំមកហើយក្តី តែភិក្ខុទាំងឡាយដែលមានក្នុងទីចំពោះមុខ ហាមឃាត់កម្ម ហៅថាកម្មជាពួកព្រមទាំងប្រកបដោយធម៌ប្លម ។ ម្នាលភិក្ខុទាំងឡាយ កម្មនេះតថាគតហៅជាកម្មជាពួកព្រមទាំងប្រកបដោយធម៌ប្លម ។

(៩១) ម្នាលភិក្ខុទាំងឡាយ ឯកម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម (នោះ) ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់ពីរ ភិក្ខុសូត្រកម្មវាចាជាមុន ហើយទើបតាំងសូត្រញត្តិជាខាងក្រោយ ភិក្ខុទាំងឡាយដែលគួរដល់កម្មមានចំនួនប៉ុន្មានរូប ភិក្ខុទាំងនោះក៏បានមកហើយ តាំងបាននាំឆន្ទៈរបស់ភិក្ខុទាំងឡាយដែលគួរដល់ឆន្ទៈមកហើយ ភិក្ខុទាំងឡាយមកជួបជុំគ្នាហើយ ក៏មិនឃាត់ហាម កម្មនោះឈ្មោះថាកម្មរបស់ភិក្ខុដែលព្រមព្រៀងគ្នាដែរ តែប្រកបដោយធម៌ប្លម ។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់បួន ភិក្ខុសូត្រកម្មវាចាជាមុន ហើយទើបតាំងញត្តិជាខាងក្រោយ ភិក្ខុទាំងឡាយដែលគួរដល់កម្មមានប៉ុន្មានរូប ភិក្ខុទាំងនោះក៏បានមកហើយ តាំងបាននាំឆន្ទៈរបស់ភិក្ខុដែលគួរដល់ឆន្ទៈមកហើយ ភិក្ខុទាំងឡាយមកជួបជុំគ្នាហើយ ក៏មិនឃាត់ហាម

ធម្មប្បដិរូបកេន សមគ្គកម្មំ ។ ឥទំ វុច្ចតិ ភិក្ខវេ ធម្មប្បដិរូបកេន សមគ្គកម្មំ ។

(៩៦) កតមញ្ច ភិក្ខវេ ធម្មេន សមគ្គកម្មំ ។ ញត្តិទុតិយេ ចេ ភិក្ខវេ កម្មេ បឋមំ ញត្តិំ ឋបេតិ បច្ឆា ឯកាយ កម្មវាចាយ កម្មំ ករោតិ យាវតិកា ភិក្ខូ កម្មប្បត្តា តេ អាគតា ហោន្តិ ឆន្ទារហានំ ឆន្ទោ អាហដោ ហោតិ សម្មុខីភូតា នប្បដិក្កោសន្តិ ធម្មេន សមគ្គកម្មំ ។ ញត្តិចតុត្ថេ ចេ ភិក្ខវេ កម្មេ បឋមំ ញត្តិំ ឋបេតិ បច្ឆា តីហិ កម្មវាចាហិ កម្មំ ករោតិ យាវតិកា ភិក្ខូ កម្មប្បត្តា តេ អាគតា ហោន្តិ ឆន្ទារហានំ ឆន្ទោ អាហដោ ហោតិ សម្មុខីភូតា នប្បដិក្កោសន្តិ ធម្មេន សមគ្គកម្មំ ។ ឥទំ វុច្ចតិ ភិក្ខវេ ធម្មេន សមគ្គកម្មំ ។





កម្មនោះឈ្មោះថាកម្មរបស់ភិក្ខុដែលព្រមព្រៀងគ្នាដែរ តែប្រកបដោយធម៌បំប្លម ។ ម្នាលភិក្ខុទាំងឡាយ កម្មនេះគេហៅថាកម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌បំប្លម ។

(៩៦) ម្នាលភិក្ខុទាំងឡាយ ឯកម្មរបស់ភិក្ខុព្រមព្រៀងគ្នា ទាំងប្រកបដោយធម៌ (នោះ) ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់ពីរ ភិក្ខុតាំងញត្តិមុនហើយ ទើបធ្វើកម្ម (នោះ) ដោយកម្មវាចាតែមួយជាខាងក្រោយ ភិក្ខុទាំងឡាយដែលគួរដល់កម្មមានប៉ុន្មានរូប ភិក្ខុទាំងនោះក៏បានមកហើយ ទាំងបាននាំឆន្ទៈរបស់ភិក្ខុទាំងឡាយដែលគួរដល់ឆន្ទៈមកហើយ ភិក្ខុទាំងឡាយមកជួបជុំគ្នា ក៏មិនឃាត់ឃាម កម្មនោះឈ្មោះថាកម្មរបស់ភិក្ខុដែលព្រមព្រៀងគ្នា ទាំងប្រកបដោយធម៌ ។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់ ៤ ភិក្ខុតាំងញត្តិមុនហើយ ទើបធ្វើកម្ម (នោះ) ដោយកម្មវាចាបីដងជាខាងក្រោយ ភិក្ខុទាំងឡាយដែលគួរដល់កម្មមានប៉ុន្មានរូប ភិក្ខុទាំងនោះក៏បានមកហើយ ទាំងបាននាំឆន្ទៈរបស់ភិក្ខុទាំងឡាយដែលគួរដល់ឆន្ទៈមកហើយ ភិក្ខុទាំងឡាយមកជួបជុំគ្នាក៏មិនឃាត់ឃាម កម្មនោះឈ្មោះថាកម្មរបស់ភិក្ខុដែលព្រមព្រៀងគ្នា ទាំងប្រកបដោយធម៌ ។ ម្នាលភិក្ខុទាំងឡាយ កម្មនេះគេហៅថា កម្មរបស់ភិក្ខុព្រមព្រៀងគ្នា ទាំងប្រកបដោយធម៌ ។

[៤៣] បញ្ច សង្ឃា ចតុវគ្គោ ភិក្ខុសង្ឃោ បញ្ចវគ្គោ ភិក្ខុសង្ឃោ ទសវគ្គោ ភិក្ខុសង្ឃោ វីសតិវគ្គោ ភិក្ខុសង្ឃោ អតិរេកវីសតិវគ្គោ ភិក្ខុសង្ឃោតិ(១) ។ តត្រ ភិក្ខវេ យ្វាយំ ចតុវគ្គោ ភិក្ខុសង្ឃោ ឋបេត្វា តីណិ កម្មានិ ឧបសម្បទំ បវារណំ អព្ភានំ ធម្មេន សមគ្គោ សព្វកម្មេសុ កម្មប្បត្តោ ។ តត្រ ភិក្ខវេ យ្វាយំ បញ្ចវគ្គោ ភិក្ខុសង្ឃោ ឋបេត្វា ទ្វេ កម្មានិ មជ្ឈិមេសុ ជនបទេសុ ឧបសម្បទំ អព្ភានំ ធម្មេន សមគ្គោ សព្វកម្មេសុ កម្មប្បត្តោ ។ តត្រ ភិក្ខវេ យ្វាយំ ទសវគ្គោ ភិក្ខុសង្ឃោ ឋបេត្វា ឯកំ កម្មំ អព្ភានំ ធម្មេន សមគ្គោ សព្វកម្មេសុ កម្មប្បត្តោ ។ តត្រ ភិក្ខវេ យ្វាយំ វីសតិវគ្គោ ភិក្ខុសង្ឃោ ធម្មេន សមគ្គោ សព្វកម្មេសុ កម្មប្បត្តោ ។ តត្រ ភិក្ខវេ យ្វាយំ អតិរេកវីសតិវគ្គោ ភិក្ខុសង្ឃោ ធម្មេន សមគ្គោ សព្វកម្មេសុ កម្មប្បត្តោ ។

---

១ ម. ឥតិ សទ្ទោ ន ទិស្សតិ ។



(៤៣) ពួកសង្ឃមាន ៥ ពួក គឺ ភិក្ខុសង្ឃចតុវគ្គ (សង្ឃមានភិក្ខុ ៤ រូប) ១ ភិក្ខុសង្ឃបញ្ចវគ្គ (សង្ឃមានភិក្ខុ ៥ រូប) ១ ភិក្ខុសង្ឃទសវគ្គ (សង្ឃមានភិក្ខុ ១០ រូប) ១ ភិក្ខុសង្ឃវីសតិវគ្គ (សង្ឃមានភិក្ខុ ២០ រូប) ១ ភិក្ខុសង្ឃអតិរេកវីសតិវគ្គ (សង្ឃមានភិក្ខុលើសពី ២០ រូប) ១ ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាភិក្ខុសង្ឃទាំង ៥ ពួកនោះ ឯភិក្ខុសង្ឃចតុវគ្គនេះ បើព្រមព្រៀងគ្នាដោយធម៌ហើយ ឈ្មោះថាគួរដល់កម្មក្នុងកម្មទាំងពួង វៀរលែងតែកម្ម ៣ យ៉ាងគឺ ឧបសម្បទាកម្ម ១ បវារណាកម្ម ១ អព្ភានកម្ម ១ ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាភិក្ខុសង្ឃទាំង ៥ ពួកនោះ ឯភិក្ខុសង្ឃបញ្ចវគ្គនេះ បើព្រមព្រៀងគ្នាដោយធម៌ហើយ ឈ្មោះថាគួរដល់កម្មក្នុងកម្មទាំងពួង វៀរលែងតែកម្ម ២ យ៉ាងគឺ ឧបសម្បទាកម្មក្នុងមជ្ឈិមជនបទ ១ អព្ភានកម្ម ១ ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាភិក្ខុសង្ឃទាំង ៥ ពួកនោះ ឯភិក្ខុសង្ឃទសវគ្គនេះ បើព្រមព្រៀងគ្នាដោយធម៌ហើយ ឈ្មោះថាគួរដល់កម្មក្នុងកម្មទាំងពួង វៀរលែងតែកម្ម ១ គឺ អព្ភានកម្ម ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាភិក្ខុសង្ឃទាំង ៥ ពួកនោះ ឯភិក្ខុសង្ឃវីសតិវគ្គនេះ បើព្រមព្រៀងគ្នាដោយធម៌ហើយ ឈ្មោះថាគួរដល់កម្មក្នុងកម្មទាំងពួង ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាភិក្ខុសង្ឃទាំង ៥ ពួកនោះ ឯភិក្ខុសង្ឃអតិរេកវីសតិវគ្គនេះ បើព្រមព្រៀងគ្នាដោយធម៌ហើយ ឈ្មោះថាគួរដល់កម្មក្នុងកម្មទាំងពួង ។

(៩៦) ចតុវគ្គករណញ្ចេ ភិក្ខវេ កម្មំ ភិក្ខុនីចតុត្ថោ កម្មំ ករេយ្យ អកម្មំ ន ច ករណីយំ ។ ចតុវគ្គករណញ្ចេ ភិក្ខវេ កម្មំ សិក្ខមានចតុត្ថោ ។ បេ ។ សាមណេរចតុត្ថោ សាមណេរីចតុត្ថោ សិក្ខំ បច្ចក្ខាតកចតុត្ថោ អន្តិមវត្ថុំ អជ្ឈាបន្នកចតុត្ថោ អាបត្តិយា អទស្សនេ ឧក្ខិត្តកចតុត្ថោ អាបត្តិយា អប្បដិកម្មេ ឧក្ខិត្តកចតុត្ថោ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខិត្តកចតុត្ថោ បណ្ឌកចតុត្ថោ ថេយ្យសំវាសកចតុត្ថោ តិត្ថិយបក្កន្តកចតុត្ថោ តិរច្ឆានគតចតុត្ថោ មាតុឃាតកចតុត្ថោ បិតុឃាតកចតុត្ថោ អរហន្តឃាតកចតុត្ថោ ភិក្ខុនិទូសកចតុត្ថោ សង្ឃភេទកចតុត្ថោ លោហិតុប្បាទកចតុត្ថោ ឧភតោព្យញ្ជនកចតុត្ថោ នានាសំវាសកចតុត្ថោ នានាសីមាយ ឋិតចតុត្ថោ



(៩៦) ម្នាលភិក្ខុទាំងឡាយ បើកម្មសម្រាប់ធ្វើដោយសង្ឃចតុវគ្គ សង្ឃមានភិក្ខុនីជាគំរប់ ៤ ហើយធ្វើកម្ម (កម្មនោះ) មិនហៅថាកម្មផង សង្ឃក៏មិនត្រូវធ្វើផង ។ ម្នាលភិក្ខុទាំងឡាយ បើកម្មសម្រាប់ធ្វើដោយសង្ឃចតុវគ្គ សង្ឃមានសិក្ខមានាជាគំរប់ ៤ ។ បេ ។ មានសាមណេរជាគំរប់ ៤ មានសាមណេរីជាគំរប់ ៤ មានភិក្ខុដែលបោលលាសិក្ខាជាគំរប់ ៤ មានភិក្ខុដែលត្រូវអន្តិមវត្ថុជាគំរប់ ៤ មានភិក្ខុដែលសង្ឃលើកវត្តព្រោះមិនឃើញអាបត្តិជាគំរប់ ៤ មានភិក្ខុដែលសង្ឃលើកវត្តព្រោះមិនសំដែងអាបត្តិជាគំរប់ ៤ មានភិក្ខុដែលសង្ឃលើកវត្តព្រោះមិនលះបង់ទិដ្ឋិអាក្រក់ជាគំរប់ ៤ មានមនុស្សខ្ទើយជាគំរប់ ៤ មានបុគ្គលដែលលួចសំវាសជាគំរប់ ៤ មានភិក្ខុដែលចូលទៅកាន់ពួកតិរ្ថិយជាគំរប់ ៤ មានសត្វតិរច្ឆានជាគំរប់ ៤ មានបុគ្គលដែលសម្លាប់មាតាជាគំរប់ ៤ មានបុគ្គលដែលសម្លាប់បិតាជាគំរប់ ៤ មានបុគ្គលដែលសម្លាប់ព្រះអរហន្តជាគំរប់ ៤ មានបុគ្គលដែលប្រទូស្តភិក្ខុនីជាគំរប់ ៤ មានភិក្ខុដែលបំបែកសង្ឃជាគំរប់ ៤ មានបុគ្គលដែលធ្វើព្រះលោហិត (ព្រះសាស្តា) ឲ្យពុះពងឡើងជាគំរប់ ៤ មានឧភតោព្យញ្ជនកជាគំរប់ ៤ មានភិក្ខុដែលមានសំវាសផ្សេងៗ គ្នាជាគំរប់ ៤ មានភិក្ខុដែលឋិតនៅក្នុងសីមាផ្សេងៗ គ្នាជាគំរប់ ៤

ឥទ្ធិយា វេហាសេ ឋិតចតុត្ថោ យស្ស សង្ឃោ កម្មំ ករោតិ តំចតុត្ថោ កម្មំ ករេយ្យ អកម្មំ ន ច ករណីយំ ។

ចតុវគ្គករណំ ។

[៤៥] បញ្ចវគ្គករណញ្ចេ ភិក្ខវេ កម្មំ ភិក្ខុនិបញ្ចមោ កម្មំ ករេយ្យ អកម្មំ ន ច ករណីយំ ។ បញ្ចវគ្គករណញ្ចេ ភិក្ខវេ កម្មំ សិក្ខមានបញ្ចមោ ។ បេ ។ សាមណេរបញ្ចមោ សាមណេរីបញ្ចមោ សិក្ខំ បច្ចក្ខាតកបញ្ចមោ អន្តិមវត្ថុំ អជ្ឈាបន្នកបញ្ចមោ អាបត្តិយា អទស្សនេ ឧក្ខិត្តកបញ្ចមោ អាបត្តិយា អប្បដិកម្មេ ឧក្ខិត្តកបញ្ចមោ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខិត្តកបញ្ចមោ បណ្ឌកបញ្ចមោ ថេយ្យសំវាសកបញ្ចមោ តិត្ថិយបក្កន្តកបញ្ចមោ តិរច្ឆានគតបញ្ចមោ មាតុឃាតកបញ្ចមោ បិតុឃាតកបញ្ចមោ អរហន្ត-



មានភិក្ខុដែលឋិតនៅលើអាកាសដោយឫទ្ធិជាគំរប់ ៤ សង្ឃធ្វើកម្មដល់បុគ្គលណា សង្ឃមានបុគ្គលនោះជាគំរប់បួន ហើយធ្វើកម្ម (កម្មនោះ) មិនហៅជាកម្មផង សង្ឃក៏មិនត្រូវធ្វើផង ។

ចប់កម្មសម្រាប់ធ្វើដោយសង្ឃចតុវគ្គ ។

[៤៥] ម្នាលភិក្ខុទាំងឡាយ បើកម្មសម្រាប់ធ្វើដោយសង្ឃបញ្ចវគ្គ សង្ឃមានភិក្ខុនីជាគំរប់ ៥ ហើយធ្វើកម្ម (កម្មនោះ) មិនហៅជាកម្មផង សង្ឃក៏មិនត្រូវធ្វើផង ។ ម្នាលភិក្ខុទាំងឡាយ បើកម្មសម្រាប់ធ្វើដោយសង្ឃបញ្ចវគ្គ សង្ឃមានសិក្ខមានាជាគំរប់ ៥ ។ បេ ។ មានសាមណេរជាគំរប់ ៥ មានសាមណេរីជាគំរប់ ៥ មានភិក្ខុដែលបោះបង់សិក្ខាជាគំរប់ ៥ មានភិក្ខុត្រូវអន្តិមវត្ថុជាគំរប់ ៥ មានភិក្ខុដែលសង្ឃលើកវត្តព្រោះមិនឃើញអាបត្តិជាគំរប់ ៥ មានភិក្ខុដែលសង្ឃលើកវត្តព្រោះមិនសំដែងអាបត្តិជាគំរប់ ៥ មានភិក្ខុដែលសង្ឃលើកវត្តព្រោះមិនលះបង់ទិដ្ឋិអាក្រក់ជាគំរប់ ៥ មានមនុស្សខ្ទើយជាគំរប់ ៥ មានបុគ្គលដែលលួចសំវាសជាគំរប់ ៥ មានភិក្ខុដែលចូលទៅកាន់ពួកតិរ្ថិយជាគំរប់ ៥ មានសត្វតិរច្ឆានជាគំរប់ ៥ មានបុគ្គលដែលសម្លាប់មាតាជាគំរប់ ៥ មានបុគ្គលដែលសម្លាប់បិតាជាគំរប់ ៥ មានបុគ្គលដែលសម្លាប់

ឃាតកបញ្ចមោ ភិក្ខុនីទូសកបញ្ចមោ សង្ឃភេទកបញ្ចមោ លោហិតុប្បាទកបញ្ចមោ ឧភតោព្យញ្ជនកបញ្ចមោ នានាសំវាសកបញ្ចមោ នានាសីមាយ ឋិតបញ្ចមោ ឥទ្ធិយា វេហាសេ ឋិតបញ្ចមោ យស្ស សង្ឃោ កម្មំ ករោតិ តំបញ្ចមោ កម្មំ ករេយ្យ អកម្មំ ន ច ករណីយំ ។

បញ្ចវគ្គករណំ ។

(៩៦) ទសវគ្គករណញ្ចេ ភិក្ខវេ កម្មំ ភិក្ខុនីទសមោ កម្មំ ករេយ្យ អកម្មំ ន ច ករណីយំ ។ ទសវគ្គករណញ្ចេ ភិក្ខវេ កម្មំ សិក្ខមានាទសមោ ។ បេ ។ សាមណេរទសមោ សាមណេរីទសមោ សិក្ខំ បច្ចក្ខាតកទសមោ អន្តិមវត្ថុំ អជ្ឈាបន្នកទសមោ អាបត្តិយា អទស្សនេ ឧក្ខិត្តកទសមោ អាបត្តិយា អប្បដិកម្មេ ឧក្ខិត្តកទសមោ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ



ព្រះអរហន្តជាគំរប់ ៥ មានបុគ្គលដែលប្រទុស្តភិក្ខុនីជាគំរប់ ៥ មានភិក្ខុដែលបំបែកសង្ឃជាគំរប់ ៥ មានបុគ្គលដែលធ្វើព្រះលោហិត (ព្រះសាស្តា) ឲ្យពុះពងឡើងជាគំរប់ ៥ មានឧភតោព្យញ្ជនកជាគំរប់ ៥ មានភិក្ខុដែលមានសំវាសផ្សេង ៗ គ្នាជាគំរប់ ៥ មានភិក្ខុដែលស្ថិតនៅក្នុងសីមាផ្សេង ៗ គ្នាជាគំរប់ ៥ មានភិក្ខុដែលស្ថិតនៅលើអាកាសដោយឫទ្ធិជាគំរប់ ៥ សង្ឃធ្វើកម្មដល់បុគ្គលណា សង្ឃមានបុគ្គលនោះជាគំរប់ ៥ ហើយធ្វើកម្ម (កម្មនោះ) មិនហៅថាកម្មផង សង្ឃក៏មិនត្រូវធ្វើផង ។

ចប់កម្មសម្រាប់ធ្វើដោយសង្ឃបញ្ចវគ្គ ។

(៩៦) ម្នាលភិក្ខុទាំងឡាយ បើកម្មសម្រាប់ធ្វើដោយសង្ឃទសវគ្គ សង្ឃមានភិក្ខុនីជាគំរប់ ១០ ហើយធ្វើកម្ម (កម្មនោះ) មិនហៅថាកម្មផង សង្ឃក៏មិនត្រូវធ្វើផង ។ ម្នាលភិក្ខុទាំងឡាយ បើកម្មសម្រាប់ធ្វើដោយសង្ឃទសវគ្គ សង្ឃមានសិក្ខមានាជាគំរប់ ១០ ។ បេ ។ មានសាមណេរជាគំរប់ ១០ មានសាមណេរីជាគំរប់ ១០ មានភិក្ខុដែលពោលលាសិក្ខាជាគំរប់ ១០ មានភិក្ខុដែលត្រូវអន្តិមវត្ថុជាគំរប់ ១០ មានភិក្ខុដែលសង្ឃលើកវត្តព្រោះមិនឃើញអាបត្តិជាគំរប់ ១០ មានភិក្ខុដែលសង្ឃលើកវត្តព្រោះមិនសំដែងអាបត្តិជាគំរប់ ១០ មានភិក្ខុដែលសង្ឃលើកវត្តព្រោះមិនលះបង់

ឧក្ខិត្តកានសមោ បណ្ឌកានសមោ ថេយ្យសំវាសកានសមោ តិត្ថិយបក្កន្តកានសមោ តិរច្ឆានគតានសមោ មាតុឃាតកានសមោ បិតុឃាតកានសមោ អរហន្តឃាតកានសមោ ភិក្ខុនិទូសកានសមោ សង្ឃភេទកានសមោ លោហិតុប្បាទកានសមោ ឧភតោព្យញ្ជនកានសមោ នានាសំវាសកានសមោ នានាសីមាយ ឋិតកានសមោ ឥទ្ធិយា វេហាសេ ឋិតកានសមោ យស្ស សង្ឃោ កម្មំ ករោតិ តេនសមោ កម្មំ ការេយ្យ អកម្មំ ន ច ករណីយំ ។

ទសវគ្គករណំ ។

(៩៧) វីសតិវគ្គករណោ ចេ ភិក្ខវេ កម្មំ ភិក្ខុនីវីសោ កម្មំ ការេយ្យ អកម្មំ ន ច ករណីយំ ។ វីសតិវគ្គករណោ ចេ ភិក្ខវេ កម្មំ សិក្ខមានាវីសោ ។បេ។



ទិដ្ឋិអាក្រក់ជាគំរប់ ១០ មានមនុស្សខ្ទើយជាគំរប់ ១០ មានបុគ្គលដែលលួចសំវាសជាគំរប់ ១០ មានភិក្ខុដែលចូលទៅកាន់ពួកតិរ្ថិយជាគំរប់ ១០ មានសត្វតិរច្ឆានជាគំរប់ ១០ មានបុគ្គលដែលសម្លាប់មាតាជាគំរប់ ១០ មានបុគ្គលដែលសម្លាប់បិតាជាគំរប់ ១០ មានបុគ្គលដែលសម្លាប់ព្រះអរហន្តជាគំរប់ ១០ មានបុគ្គលដែលប្រទូស្តភិក្ខុនីជាគំរប់ ១០ មានភិក្ខុដែលបំបែកសង្ឃជាគំរប់ ១០ មានបុគ្គលដែលធ្វើព្រះលោហិត (ព្រះសាស្តា) ឲ្យពុះពោងឡើងជាគំរប់ ១០ មានមនុស្សឧភតោព្យញ្ជនកជាគំរប់ ១០ មានភិក្ខុដែលមានសំវាសផ្សេងៗគ្នាជាគំរប់ ១០ មានភិក្ខុដែលស្ថិតនៅក្នុងសីមាផ្សេងៗគ្នាជាគំរប់ ១០ មានភិក្ខុដែលស្ថិតនៅលើអាកាសដោយឫទ្ធិជាគំរប់ ១០ សង្ឃធ្វើកម្មដល់បុគ្គលណា សង្ឃមានបុគ្គលនោះជាគំរប់ ១០ ហើយធ្វើកម្ម (កម្មនោះ) មិនហៅថាកម្មផង សង្ឃក៏មិនត្រូវធ្វើផង ។

ចប់កម្មសម្រាប់ធ្វើដោយសង្ឃទសវគ្គ ។

(៩៧) ម្នាលភិក្ខុទាំងឡាយ បើកម្មសម្រាប់ធ្វើដោយសង្ឃវីសតិវគ្គ សង្ឃមានភិក្ខុនីជាគំរប់ ២០ ហើយធ្វើកម្ម (កម្មនោះ) មិនហៅថាកម្មផង សង្ឃក៏មិនត្រូវធ្វើផង ។ ម្នាលភិក្ខុទាំងឡាយ បើកម្មសម្រាប់ធ្វើដោយសង្ឃវីសតិវគ្គ សង្ឃមានសិក្ខមានាជាគំរប់ ២០ ។បេ។

ចម្បេយ្យក្ខន្ធកេ បញ្ចសង្ឃកម្មវីសតិវគ្គសង្ឃកម្មំ

សាមណេរវីសោ សាមណេរីវីសោ សិក្ខំ បច្ចក្ខាតកវីសោ អន្តិមវត្ថុំ អជ្ឈាបន្នកវីសោ អាបត្តិយា អទស្សនេ ឧក្ខិត្តកវីសោ អាបត្តិយា អប្បដិកម្មេ ឧក្ខិត្តកវីសោ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខិត្តកវីសោ បណ្ឌកវីសោ ថេយ្យសំវាសកវីសោ តិត្ថិយបក្កន្តកវីសោ តិរច្ឆានគតវីសោ មាតុឃាតកវីសោ បិតុឃាតកវីសោ អរហន្តឃាតកវីសោ ភិក្ខុនីទូសកវីសោ សង្ឃភេទកវីសោ លោហិតុប្បាទកវីសោ ឧភតោព្យញ្ជនកវីសោ នានាសំវាសកវីសោ នានាសីមាយ ឋិតវីសោ យស្ស សង្ឃោ កម្មំ ករោតិ តវីសោ កម្មំ ការេយ្យ អកម្មំ ន ច ករណីយំ ។

វីសតិវគ្គោ ចប់ ។



ចម្បេយ្យក្ខន្ធកៈ និយាយអំពីជំនុំសង្ឃមាន ៥ ពួក និងកម្មសម្រាប់ធ្វើដោយសង្ឃវីសតិវគ្គ

មានសាមណេរជាគំរប់ ២០ មានសាមណេរីជាគំរប់ ២០ មានភិក្ខុដែលបោលលាសិក្ខាជាគំរប់២០ មានភិក្ខុដែលត្រូវអន្តិមវត្ថុជាគំរប់ ២០ មានភិក្ខុដែលសង្ឃលើកវត្តព្រោះមិនឃើញអាបត្តិជាគំរប់ ២០ មានភិក្ខុដែលសង្ឃលើកវត្តព្រោះមិនសំដែងអាបត្តិជាគំរប់ ២០ មានភិក្ខុដែលសង្ឃលើកវត្តព្រោះមិនលះបង់ទិដ្ឋិអាក្រក់ជាគំរប់ ២០ មានមនុស្សខ្ទើយជាគំរប់២០ មានបុគ្គលដែលលួចសំវាសជាគំរប់ ២០ មានភិក្ខុដែលចូលទៅកាន់ពួកតិរ្ថិយជាគំរប់ ២០ មានសត្វតិរច្ឆានជាគំរប់២០ មានបុគ្គលដែលសម្លាប់មាតាជាគំរប់២០ មានបុគ្គលដែលសម្លាប់បិតាជាគំរប់២០ មានបុគ្គលដែលសម្លាប់ព្រះអរហន្តជាគំរប់ ២០ មានបុគ្គលដែលប្រទូស្តភិក្ខុនីជាគំរប់ ២០ មានភិក្ខុដែលបំបែកសង្ឃជាគំរប់ ២០ មានភិក្ខុដែលធ្វើព្រះលោហិត (ព្រះសាស្តា) ឲ្យពុះពោរឡើងជាគំរប់ ២០ មានឧភតោព្យញ្ជនកជាគំរប់ ២០ មានភិក្ខុដែលមានសំវាសផ្សេង ៗ គ្នាជាគំរប់ ២០ មានភិក្ខុដែលស្ថិតនៅក្នុងសីមាផ្សេង ៗ គ្នាជាគំរប់ ២០ សង្ឃធ្វើកម្មដល់បុគ្គលណា សង្ឃមានបុគ្គលនោះជាគំរប់ ២០ ហើយធ្វើកម្ម (កម្មនោះ) មិនហៅថាកម្មផង សង្ឃក៏មិនត្រូវធ្វើផង ។

ចប់កម្មសម្រាប់ធ្វើដោយសង្ឃវីសតិវគ្គ ។

[៩៨] បារិវាសិកចតុត្ថោ ចេ ភិក្ខវេ បរិវាសំ ទទេយ្យ មូលាយ បដិកស្សេយ្យ មានត្តំ ទទេយ្យ វីសោ អព្ភេយ្យ អកម្មំ ន ច ករណីយំ ។ មូលាយបដិកស្សនារហចតុត្ថោ ចេ ភិក្ខវេ បរិវាសំ ទទេយ្យ មូលាយ បដិកស្សេយ្យ មានត្តំ ទទេយ្យ វីសោ អព្ភេយ្យ អកម្មំ ន ច ករណីយំ ។ មានត្តារហចតុត្ថោ ចេ ភិក្ខវេ បរិវាសំ ទទេយ្យ មូលាយ បដិកស្សេយ្យ មានត្តំ ទទេយ្យ វីសោ អព្ភេយ្យ អកម្មំ ន ច ករណីយំ ។ មានត្តចារិកចតុត្ថោ ចេ ភិក្ខវេ បរិវាសំ ទទេយ្យ មូលាយ បដិកស្សេយ្យ មានត្តំ ទទេយ្យ វីសោ អព្ភេយ្យ អកម្មំ ន ច ករណីយំ ។ អព្ភានារហចតុត្ថោ ចេ ភិក្ខវេ



[៩៨] ម្នាលភិក្ខុទាំងឡាយ បើសង្ឃមានភិក្ខុអ្នកនៅបរិវាសជាគំរប់៤ ហើយឲ្យបរិវាស ទាញអន្តរាបត្តិមកដាក់ក្នុងមូលាបត្តិ ហើយឲ្យមានត្ត (បើ) សង្ឃមានភិក្ខុអ្នកនៅបរិវាសនោះជាគំរប់២០ ហើយឲ្យអព្ភាន (យ៉ាងនេះ) មិនហៅថាកម្មផង សង្ឃក៏មិនត្រូវធ្វើផង ។ ម្នាលភិក្ខុទាំងឡាយ បើសង្ឃមានភិក្ខុដែលគួរដល់ការទាញអន្តរាបត្តិមកដាក់ក្នុងមូលាបត្តិជាគំរប់៤ ហើយឲ្យបរិវាស ទាញអន្តរាបត្តិមកដាក់ក្នុងមូលាបត្តិ ហើយឲ្យមានត្ត (បើ) សង្ឃមានភិក្ខុនោះជាគំរប់២០ ហើយឲ្យអព្ភាន (យ៉ាងនេះ) មិនហៅថាកម្មផង សង្ឃក៏មិនត្រូវធ្វើផង ។ ម្នាលភិក្ខុទាំងឡាយ បើសង្ឃមានភិក្ខុដែលគួរដល់មានត្តជាគំរប់៤ ហើយឲ្យបរិវាស ទាញអន្តរាបត្តិមកដាក់ក្នុងមូលាបត្តិ ហើយឲ្យមានត្ត (បើ) សង្ឃមានភិក្ខុដែលគួរដល់មានត្តនោះជាគំរប់២០ ហើយឲ្យអព្ភាន (យ៉ាងនេះ) មិនហៅថាកម្មផង សង្ឃមិនត្រូវធ្វើផង ។ ម្នាលភិក្ខុទាំងឡាយ បើសង្ឃមានភិក្ខុអ្នកប្រព្រឹត្តមានត្តជាគំរប់៤ ហើយឲ្យបរិវាស ទាញអន្តរាបត្តិមកដាក់ក្នុងមូលាបត្តិ ហើយឲ្យមានត្ត បើសង្ឃមានភិក្ខុអ្នកប្រព្រឹត្តមានត្តនោះជាគំរប់២០ ហើយឲ្យអព្ភាន (យ៉ាងនេះ) មិនហៅថាកម្មផង សង្ឃក៏មិនត្រូវធ្វើផង ។ ម្នាលភិក្ខុទាំងឡាយ បើសង្ឃមានភិក្ខុដែលគួរដល់អព្ភាន

បរិវាសំ ទទេយ្យ មូលាយ បដិកស្សេយ្យ មានត្តំ ទ- ទេយ្យ តីសោ អព្ភេយ្យ អកម្មំ ន ច ករណីយំ ។

(៨៨) ឯកច្ចស្ស ភិក្ខវេ សង្ឃមជ្ឈេ បដិក្កោសនា រូហតិ ឯកច្ចស្ស ន រូហតិ ។ កស្ស ច ភិក្ខវេ សង្ឃមជ្ឈេ បដិក្កោសនា ន រូហតិ ។ ភិក្ខុនិយា ភិក្ខវេ សង្ឃមជ្ឈេ បដិក្កោសនា ន រូហតិ ។ សិក្ខមានាយ ភិក្ខវេ ។ បេ ។ សាមណេរស្ស ភិក្ខវេ សាមណេរិយា ភិក្ខវេ សិក្ខំ បច្ចក្ខាតកស្ស ភិក្ខវេ អន្តិមវត្ថុំ អជ្ឈាបន្នកស្ស ភិក្ខវេ ឧម្មត្តកស្ស ភិក្ខវេ ខិត្តចិត្តស្ស ភិក្ខវេ វេទនដ្ដស្ស ភិក្ខវេ អាបត្តិយា អទស្សនេ ឧក្ខិត្តកស្ស ភិក្ខវេ អាបត្តិយា អប្បដិកម្មេ ឧក្ខិត្តកស្ស ភិក្ខវេ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខិត្តកស្ស ភិក្ខវេ បណ្ឌកស្ស ភិក្ខវេ





ជាគំរប់៦ ហើយឲ្យបរិវាស ទាញអន្តរាបត្តិមកដាក់ក្នុងមូលាបត្តិ ហើយឲ្យមានត្ត បើសង្ឃមានភិក្ខុដែលត្រូវដាក់គេក្នុងនោះជាគំរប់ ២០ ហើយឲ្យអព្ភាន (ហៅចេញ) មិនហៅថាកម្មផង សង្ឃក៏មិនត្រូវធ្វើផង ។

(៨៨) ម្នាលភិក្ខុទាំងឡាយ ការហាមឃាត់ក្នុងកណ្តាលជំនុំសង្ឃ របស់បុគ្គលខ្លះឡើង របស់បុគ្គលខ្លះមិនឡើង ។ ម្នាលភិក្ខុទាំងឡាយ ឯការហាមឃាត់ក្នុងកណ្តាលជំនុំសង្ឃរបស់នរណា ដែលមិនឡើង ។ ម្នាលភិក្ខុទាំងឡាយ ការហាមឃាត់ក្នុងកណ្តាលជំនុំសង្ឃរបស់ភិក្ខុនីមិនឡើង ។ ម្នាលភិក្ខុទាំងឡាយ របស់សិក្ខមានា ។ បេ ។ ម្នាលភិក្ខុទាំងឡាយ របស់សាមណេរ ម្នាលភិក្ខុទាំងឡាយ របស់សាមណេរី ម្នាលភិក្ខុទាំងឡាយ របស់ភិក្ខុអ្នកលះបង់សិក្ខា ម្នាលភិក្ខុទាំងឡាយ របស់ភិក្ខុអ្នកត្រូវអន្តិមវត្ថុ ម្នាលភិក្ខុទាំងឡាយ របស់ភិក្ខុដែលឆ្កួត ម្នាលភិក្ខុទាំងឡាយ របស់ភិក្ខុដែលមានចិត្តរវើរវាយ ម្នាលភិក្ខុទាំងឡាយ របស់ភិក្ខុដែលមានវេទនាគ្របសង្កត់ ម្នាលភិក្ខុទាំងឡាយ របស់ភិក្ខុដែលសង្ឃលើកវត្តព្រោះមិនឃើញអាបត្តិ ម្នាលភិក្ខុទាំងឡាយ របស់ភិក្ខុដែលសង្ឃលើកវត្តព្រោះមិនសំដែងអាបត្តិ ម្នាលភិក្ខុទាំងឡាយ របស់ភិក្ខុដែលសង្ឃលើកវត្តព្រោះមិនលះបង់នូវទិដ្ឋិដ៏អាក្រក់ ម្នាលភិក្ខុទាំងឡាយ របស់បណ្ឌក

ថេយ្យសំវាសកស្ស ភិក្ខវេ តិត្ថិយបក្កន្តកស្ស ភិក្ខវេ តិរច្ឆានគតស្ស ភិក្ខវេ មាតុឃាតកស្ស ភិក្ខវេ បិតុឃាតកស្ស ភិក្ខវេ អរហន្តឃាតកស្ស ភិក្ខវេ ភិក្ខុនិទូសកស្ស ភិក្ខវេ សង្ឃភេទកស្ស ភិក្ខវេ លោហិតុប្បាទកស្ស ភិក្ខវេ ឧភតោព្យញ្ជនកស្ស ភិក្ខវេ នានាសំវាសកស្ស ភិក្ខវេ នានាសីមាយ ឋិតស្ស ភិក្ខវេ ឥទ្ធិយា វេហាសេ ឋិតស្ស ភិក្ខវេ យស្ស សង្ឃោ កម្មំ ករោតិ តស្ស ភិក្ខវេ សង្ឃមជ្ឈេ បដិក្កោសនា ន រុហតិ ។ ឥមេសំ ខោ ភិក្ខវេ សង្ឃមជ្ឈេ បដិក្កោសនា ន រុហតិ ។ កតមស្ស ច ភិក្ខវេ សង្ឃមជ្ឈេ បដិក្កោសនា រុហតិ ។ ភិក្ខុស្ស ភិក្ខវេ បកតត្តស្ស សមានសំវាសកស្ស សមានសីមាយ ឋិតស្ស



ម្នាលភិក្ខុទាំងឡាយ របស់បុគ្គលដែលលួចសំវាស ម្នាលភិក្ខុទាំងឡាយ របស់ភិក្ខុដែលចូលទៅកាន់ពួកតិរ្ថិយ ម្នាលភិក្ខុទាំងឡាយ របស់សត្វតិរច្ឆាន ម្នាលភិក្ខុទាំងឡាយ របស់បុគ្គលដែលសម្លាប់មាតា ម្នាលភិក្ខុទាំងឡាយ របស់បុគ្គលដែលសម្លាប់បិតា ម្នាលភិក្ខុទាំងឡាយ របស់បុគ្គលដែលសម្លាប់ព្រះអរហន្ត ម្នាលភិក្ខុទាំងឡាយ របស់បុគ្គលដែលប្រទូស្តភិក្ខុនី ម្នាលភិក្ខុទាំងឡាយ របស់ភិក្ខុដែលបំបែកសង្ឃ ម្នាលភិក្ខុទាំងឡាយ របស់បុគ្គលដែលធ្វើព្រះលោហិត (ព្រះសាស្តា) ឲ្យពុះពងឡើង ម្នាលភិក្ខុទាំងឡាយ របស់ឧភតោព្យញ្ជនកៈ ម្នាលភិក្ខុទាំងឡាយ របស់ភិក្ខុដែលមានសំវាសផ្សេងគ្នា ម្នាលភិក្ខុទាំងឡាយ របស់ភិក្ខុដែលស្ថិតនៅក្នុងសីមាផ្សេង គ្នា ម្នាលភិក្ខុទាំងឡាយ របស់ភិក្ខុដែលស្ថិតនៅលើអាកាសដោយឫទ្ធិ ជំនុំសង្ឃធ្វើកម្មដល់បុគ្គលណា ម្នាលភិក្ខុទាំងឡាយ ការហាមឃាត់ក្នុងកណ្តាលជំនុំសង្ឃ របស់បុគ្គលនោះមិនឡើងទេ ។ ម្នាលភិក្ខុទាំងឡាយ ការហាមឃាត់ក្នុងកណ្តាលជំនុំសង្ឃ របស់បុគ្គលទាំងអម្បាលនេះឯងមិនឡើងទេ ។ ម្នាលភិក្ខុទាំងឡាយ ឯការហាមឃាត់ក្នុងកណ្តាលជំនុំសង្ឃ របស់នរណាទើបឡើង ។ ម្នាលភិក្ខុទាំងឡាយ ការហាមឃាត់ក្នុងកណ្តាលជំនុំសង្ឃ របស់ភិក្ខុជាបកតត្តមានសំវាសស្មើគ្នា ស្ថិត

អទ្ធមាសោ អបត្តិកស្សាបិ ភិក្ខុនោ វិញ្ញាបេន្តស្ស សង្ឃមជ្ឈេ ឧជ្ឈាយនា ហោតិ ។ តេសម្បិ ភោ ភិក្ខវេ សង្ឃមជ្ឈេ ឧជ្ឈាយនា ហោតិ ។

(១០០) ចតស្សោ ភិក្ខវេ និស្សារណា អត្ថិ ភិក្ខវេ បុគ្គលោ អប្បត្តោ និស្សារណំ តំ ចេ សង្ឃោ និស្សារេតិ ឯកច្ចោ សុនិស្សារិតោ ឯកច្ចោ ទុន្និស្សារិតោ ។ កតមោ ច ភិក្ខវេ បុគ្គលោ អប្បត្តោ និស្សារណំ តំ ចេ សង្ឃោ និស្សារេតិ ទុន្និស្សារិតោ ។ ឥធ ភិក្ខវេ ភិក្ខុ សុទ្ធោ ហោតិ អនាបត្តិកោ តំ ចេ សង្ឃោ និស្សារេតិ ទុន្និស្សារិតោ ។ អយំ វុច្ចតិ ភិក្ខវេ បុគ្គលោ អប្បត្តោ និស្សារណំ តំ ចេ សង្ឃោ និស្សារេតិ ទុន្និស្សារិតោ ។ កតមោ ច ភិក្ខវេ បុគ្គលោ អប្បត្តោ និស្សារណំ តំ ចេ សង្ឃោ និស្សារេតិ សុនិស្សារិតោ ។ ឥធ[១] ភិក្ខវេ ភិក្ខុ

១ ម. ឥធ បន ។



នៅកន្លះខែជាមួយគ្នា ដោយហេតុនោះ សូម្បីភិក្ខុដែលឥតមានទោស ដ៏ជាក់ ដែលញ៉ាំងសង្ឃឲ្យដឹង ក៏ឡើងដែរ ។ ម្នាលភិក្ខុទាំងឡាយ ការចោមយាត់កណ្តាលជំនុំសង្ឃរបស់ភិក្ខុនេះឯង កើតឡើង ។

(១០០) ម្នាលភិក្ខុទាំងឡាយ និស្សារណកម្ម(ការបណ្តេញចេញ) នេះមាន៤យ៉ាង ម្នាលភិក្ខុទាំងឡាយ មានបុគ្គលគឺភិក្ខុដែលមិនទាន់ដល់នូវនិស្សារណកម្មនៅឡើយ បើសង្ឃបណ្តេញបុគ្គលនោះចេញ បុគ្គលពួកខ្លះ ឈ្មោះថា សង្ឃបណ្តេញចេញដោយល្អ(ត្រូវ)បុគ្គលពួកខ្លះឈ្មោះថាសង្ឃបណ្តេញចេញដោយអាក្រក់(ខុស) ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដូចម្តេចដែលមិនទាន់ដល់នូវនិស្សារណកម្ម បើសង្ឃបណ្តេញបុគ្គលនោះចេញ ឈ្មោះថា សង្ឃបណ្តេញចេញដោយអាក្រក់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះជាអ្នកស្អាតបរិសុទ្ធគ្មានអាបត្តិ បើសង្ឃបណ្តេញភិក្ខុនោះចេញ ឈ្មោះថា សង្ឃបណ្តេញចេញដោយអាក្រក់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះតថាគតហៅថា បុគ្គលដែលមិនទាន់ដល់នូវនិស្សារណកម្ម បើសង្ឃបណ្តេញបុគ្គលនោះចេញ ឈ្មោះថា សង្ឃបណ្តេញចេញដោយអាក្រក់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដូចម្តេច ដែលមិនទាន់ដល់នូវនិស្សារណកម្ម បើសង្ឃបណ្តេញបុគ្គលនោះចេញ ឈ្មោះថា សង្ឃបណ្តេញចេញដោយល្អ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ

ពាលោ ហោតិ អព្យត្តោ អាបត្តិពហុលោ អនបទានោ គិហិសំសដ្ឋោ វិហរតិ អននុលោមិកេហិ គិហិសំសគ្គេហិ តំ ចេ សង្ឃោ និស្សារេតិ សុនិស្សារិតោ ។ អយំ វុច្ចតិ ភិក្ខវេ បុគ្គលោ អប្បត្តោ និស្សារណំ តំ ចេ សង្ឃោ និស្សារេតិ សុនិស្សារិតោ ។

(១៨១) ទ្វេមា ភិក្ខវេ ឱសារណា អត្ថិ ភិក្ខវេ បុគ្គលោ អប្បត្តោ ឱសារណំ តំ ចេ សង្ឃោ ឱសារេតិ ឯកច្ចោ សោសារិតោ ឯកច្ចោ ទោសារិតោ ។ កតមោ ច ភិក្ខវេ បុគ្គលោ អប្បត្តោ ឱសារណំ តំ ចេ សង្ឃោ ឱសារេតិ ទោសារិតោ ។ បណ្ឌកោ ភិក្ខវេ អប្បត្តោ ឱសារណំ តញ្ចេ សង្ឃោ ឱសារេតិ ទោសារិតោ ។ ថេយ្យសំវាសកោ ភិក្ខវេ ។បេ។



ក្នុងសាសនានេះ ល្ងង់មិនឈ្លាស មានអាបត្តិច្រើន មិនមានការកំណត់អាបត្តិ នៅច្រឡូកច្រឡំដោយគ្រហស្ថ ដោយការច្រឡូកច្រឡំមិនសមគួរ បើសង្ឃបណ្តេញភិក្ខុនោះចេញ ឈ្មោះថា សង្ឃបណ្តេញចេញដោយល្អ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះតថាគតហៅថា បុគ្គលដែលមិនទាន់ដល់នូវនិស្សារណកម្ម បើសង្ឃបណ្តេញបុគ្គលនោះចេញ ឈ្មោះថា បណ្តេញចេញដោយល្អ ។

(១៨១) ម្នាលភិក្ខុទាំងឡាយ ឱសារណកម្ម[១] មាន ២ យ៉ាង ម្នាលភិក្ខុទាំងឡាយ មានបុគ្គលដែលមិនទាន់ដល់នូវឱសារណកម្មនៅឡើយ បើសង្ឃហៅបុគ្គលនោះចូលមក បុគ្គលពួកខ្លះ ឈ្មោះថា សង្ឃហៅចូលមកដោយល្អ បុគ្គលពួកខ្លះ ឈ្មោះថា សង្ឃហៅចូលមកដោយអាក្រក់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដូចម្តេចដែលមិនទាន់ដល់នូវឱសារណកម្ម បើសង្ឃហៅបុគ្គលនោះចូលមក ឈ្មោះថា សង្ឃហៅចូលមកដោយអាក្រក់ ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌកៈមិនដល់នូវឱសារណកម្មទេ បើសង្ឃហៅបណ្ឌកៈនោះចូលមក ឈ្មោះថា សង្ឃហៅចូលមកដោយអាក្រក់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលលួចសំវាស ។បេ។

១ ការហៅចូលក្នុងពួក ដោយអំណាចនៃកម្ម មានសេចក្តីឲ្យចូលមកវិញ ហៅថា ឱសារណកម្ម ។

តិត្ថិយបក្កន្តកោ ភិក្ខវេ តិរច្ឆានគតោ ភិក្ខវេ មាតុឃាតកោ ភិក្ខវេ បិតុឃាតកោ ភិក្ខវេ អរហន្តឃាតកោ ភិក្ខវេ ភិក្ខុនិទូសកោ ភិក្ខវេ សង្ឃភេទកោ ភិក្ខវេ លោហិតុប្បាទកោ ភិក្ខវេ ឧភតោព្យញ្ជនកោ ភិក្ខវេ អប្បត្តោ ឱសារណំ តំ ចេ សង្ឃោ ឱសារេតិ ទោសារិតោ ។ អយំ វុច្ចតិ ភិក្ខវេ បុគ្គលោ អប្បត្តោ ឱសារណំ តំ ចេ សង្ឃោ ឱសារេតិ ទោសារិតោ[១] ។ កតមោ ច ភិក្ខវេ បុគ្គលោ អប្បត្តោ ឱសារណំ តំ ចេ សង្ឃោ ឱសារេតិ សោសារិតោ ។ ហត្ថច្ឆិន្នោ ភិក្ខវេ អប្បត្តោ ឱសារណំ តំ ចេ សង្ឃោ ឱសារេតិ សោសារិតោ ។ បាទច្ឆិន្នោ ភិក្ខវេ ។បេ។ ហត្ថបាទច្ឆិន្នោ ភិក្ខវេ

---

១ ម. យុ. វុច្ចតិ ភិក្ខវេ បុគ្គលោ អប្បត្តោ ឱសារណំ តំ ចេ សង្ឃោ ឱសារេតិ ទោសារិតោ ។



ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលចូលទៅកាន់ពួកតិរ្ថិយ ម្នាលភិក្ខុទាំងឡាយ សត្វតិរច្ឆាន ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលសម្លាប់មាតា ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលសម្លាប់បិតា ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលសម្លាប់ព្រះអរហន្ត ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលប្រទូស្តភិក្ខុនី ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលបំបែកសង្ឃ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលធ្វើលោហិតុប្បាទ ម្នាលភិក្ខុទាំងឡាយ ឧភតោព្យញ្ជនកៈ មិនដល់នូវឱសារណកម្មទេ បើសង្ឃហៅបុគ្គលនោះបញ្ចូល ឈ្មោះថាសង្ឃហៅបញ្ចូលដោយមិនត្រូវ ១ ម្នាលភិក្ខុទាំងឡាយ តថាគតហៅបុគ្គលនេះឯងថាមិនដល់នូវឱសារណកម្ម បើសង្ឃហៅបុគ្គលនោះបញ្ចូល ឈ្មោះថាសង្ឃហៅបញ្ចូលដោយមិនត្រូវ ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលដូចម្តេចដែលមិនដល់នូវឱសារណកម្ម បើសង្ឃហៅបុគ្គលនោះបញ្ចូល ឈ្មោះថាសង្ឃហៅបញ្ចូលដោយល្អ ១ ម្នាលភិក្ខុទាំងឡាយ មនុស្សកំបុតដៃមិនដល់នូវឱសារណកម្មទេ បើសង្ឃហៅបុគ្គលនោះបញ្ចូល ឈ្មោះថាសង្ឃហៅបញ្ចូលដោយល្អ ១ ម្នាលភិក្ខុទាំងឡាយ មនុស្សកំបុតជើង ១ បេ ១ ម្នាលភិក្ខុទាំងឡាយ មនុស្សកំបុតទាំងដៃទាំងជើង

កណ្ណច្ឆិន្នោ ភិក្ខវេ នាសច្ឆិន្នោ ភិក្ខវេ កណ្ណនាសច្ឆិន្នោ ភិក្ខវេ អង្គុលិច្ឆិន្នោ ភិក្ខវេ អឡច្ឆិន្នោ ភិក្ខវេ កណ្ឌរច្ឆិន្នោ ភិក្ខវេ ផណហត្ថកោ ភិក្ខវេ ខុជ្ជោ ភិក្ខវេ វាមនោ ភិក្ខវេ គលគណ្ឌី ភិក្ខវេ លក្ខណាហតោ ភិក្ខវេ កសាហតោ ភិក្ខវេ លិខិតកោ ភិក្ខវេ សីបទី ភិក្ខវេ បាបរោគី ភិក្ខវេ បរិសទូសកោ ភិក្ខវេ កាណោ ភិក្ខវេ កុណី ភិក្ខវេ ខញ្ជោ ភិក្ខវេ បក្ខហតោ



ម្នាលភិក្ខុទាំងឡាយ មនុស្សកំបុតត្រចៀក ម្នាលភិក្ខុទាំងឡាយ មនុស្សកំបុតច្រមុះ ម្នាលភិក្ខុទាំងឡាយ មនុស្សកំបុតទាំងត្រចៀកទាំងច្រមុះ ម្នាលភិក្ខុទាំងឡាយ មនុស្សកំបុតម្រាមដៃ ម្នាលភិក្ខុទាំងឡាយ មនុស្សកំបុតមេដៃមេជើង ម្នាលភិក្ខុទាំងឡាយ មនុស្សដាច់សរសៃ (សរសៃក្នុងជើង) ម្នាលភិក្ខុទាំងឡាយ មនុស្សមានដៃក្រែក (មានម្រាមដៃជាប់គ្នាដូចស្លាបប្រចៀវ) ម្នាលភិក្ខុទាំងឡាយ មនុស្សគម ម្នាលភិក្ខុទាំងឡាយ មនុស្សតឿ ម្នាលភិក្ខុទាំងឡាយ មនុស្សពកកបូកក (កើតអំពើឯណាមួយ) ម្នាលភិក្ខុទាំងឡាយ មនុស្សដែលគេបៀតបៀនឲ្យមានស្លាកស្នាម ម្នាលភិក្ខុទាំងឡាយ មនុស្សដែលគេវាយឲ្យមានស្នាមរំពាត់ ម្នាលភិក្ខុទាំងឡាយ មនុស្សដែលគេកត់ឈ្មោះទុក (ក្បួនតាមរក) ម្នាលភិក្ខុទាំងឡាយ មនុស្សដែលមានជើងហើមស្ពក ម្នាលភិក្ខុទាំងឡាយ មនុស្សដែលមានរោគអាក្រក់ (មានឫសដូងបាតជាដើម) ម្នាលភិក្ខុទាំងឡាយ មនុស្សដែលមានរូបទ្រុស្តបរិសទ្យ (គឺមានរូបអាក្រក់ខុសគេ ឬខ្ពស់ពេកទាបពេកជាដើម) ម្នាលភិក្ខុទាំងឡាយ មនុស្សដែលវៀចភ្នែកទីទ្វាក់ ឬខ្វាក់ម្ខាង ម្នាលភិក្ខុទាំងឡាយ មនុស្សកោងកង្កែងដៃជាដើម ម្នាលភិក្ខុទាំងឡាយ មនុស្សខ្វិនជើង ម្នាលភិក្ខុទាំងឡាយ មនុស្សដែលស្លាប់១ចំហៀងខ្លួន

ភិក្ខវេ ឆិន្នីរិយាបថោ ភិក្ខវេ ជរាទុព្ពលោ ភិក្ខវេ អន្ធោ ភិក្ខវេ មូគោ ភិក្ខវេ ពធិរោ ភិក្ខវេ អន្ធមូគោ ភិក្ខវេ អន្ធពធិរោ ភិក្ខវេ មូគពធិរោ ភិក្ខវេ អន្ធមូគពធិរោ ភិក្ខវេ អប្បត្តោ ឱសារណំ តំ ចេ សង្ឃោ ឱសារេតិ សោសារិតោ ។ អយំ វុច្ចតិ ភិក្ខវេ បុគ្គលោ អប្បត្តោ ឱសារណំ តំ ចេ សង្ឃោ ឱសារេតិ សោសារិតោ(១) ។

វាសភគាមភាណវារំ បឋមំ ។

[១០៥] ឥធ បន ភិក្ខវេ ភិក្ខុស្ស ន ហោតិ អាបត្តិ ទដ្ឋព្វា ។ តមេនំ ចោទេតិ សង្ឃោ វា សម្ពហុលា វា ឯកបុគ្គលោ វា អាបត្តឹ ត្វំ អាវុសោ អាបន្នោ បស្សសេ-តំ អាបត្តិន្តិ ។ សោ ឯវំ វទេតិ នត្ថិ មេ អាវុសោ

១. ម. ឥមេ វុច្ចន្តិ ភិក្ខវេ បុគ្គលា អប្បត្តា ឱសារណំ តំ ចេ សង្ឃោ ឱសារេតិ សោសារិតា ។





ម្នាលភិក្ខុទាំងឡាយ មនុស្សខ្វិន ម្នាលភិក្ខុទាំងឡាយ មនុស្សចាស់គ្រាំ-គ្រា ម្នាលភិក្ខុទាំងឡាយ មនុស្សដែលខ្វាក់ពីកំណើត ម្នាលភិក្ខុទាំងឡាយ មនុស្សគ ម្នាលភិក្ខុទាំងឡាយ មនុស្សថ្លង់ ម្នាលភិក្ខុទាំងឡាយ មនុស្សទាំងខ្វាក់ទាំងគ ម្នាលភិក្ខុទាំងឡាយ មនុស្សទាំងខ្វាក់ទាំងថ្លង់ ម្នាលភិក្ខុទាំងឡាយ មនុស្សទាំងគទាំងថ្លង់ ម្នាលភិក្ខុទាំងឡាយ មនុស្សទាំងខ្វាក់ទាំងគទាំងថ្លង់ មិនដល់នូវឱសារណកម្មទេ បើសង្ឃហៅបុគ្គលនោះបញ្ចូល ឈ្មោះថាសង្ឃហៅបញ្ចូលដោយល្អ ។ ម្នាលភិក្ខុទាំងឡាយ គឺថាគេហៅបុគ្គលនេះឯងថា មិនដល់នូវឱសារណកម្មទេ បើសង្ឃហៅបុគ្គលនោះបញ្ចូល ឈ្មោះថា សង្ឃហៅបញ្ចូលដោយល្អ ។

ចប់ វាសភគាមភាណវារៈ ទី ១ ។

[១០៥] ម្នាលភិក្ខុទាំងឡាយ បើអាបត្តិដែលភិក្ខុត្រូវឃើញមិនមាន ដល់ភិក្ខុក្នុងសាសនានេះទេ ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គល (គឺភិក្ខុ) ១ រូបក្តី ចោទភិក្ខុនោះថា ម្នាលអាវុសោ លោកត្រូវអាបត្តិហើយ លោកឃើញអាបត្តិនុ៎ះទេ ។ ភិក្ខុនោះពោលតបវិញយ៉ាងនេះថា ម្នាលអាវុសោ

អាបត្តិ យមហំ បស្សេយ្យន្តិ ។ តំ សង្ឃោ អាបត្តិយា អទស្សនេ ឧក្ខិបតិ អធម្មកម្មំ ។ ឥធ បន ភិក្ខវេ ភិក្ខុស្ស ន ហោតិ អាបត្តិ បដិកាតព្វា ។ តមេនំ ចោទេតិ សង្ឃោ វា សម្ពហុលា វា ឯកបុគ្គលោ វា អាបត្តិំ ត្វំ អាវុសោ អាបន្នោ បដិករោហិ តំ អាបត្តិន្តិ ។ សោ ឯវំ វទេតិ នត្ថិ មេ អាវុសោ អាបត្តិ យមហំ បដិករេយ្យន្តិ ។ តំ សង្ឃោ អាបត្តិយា អប្បដិកម្មេ ឧក្ខិបតិ អធម្មកម្មំ ។ ឥធ បន ភិក្ខវេ ភិក្ខុស្ស ន ហោតិ បាបិកា ទិដ្ឋិ បដិនិស្សជ្ជេតព្វា ។ តមេនំ ចោទេតិ សង្ឃោ វា សម្ពហុលា វា ឯកបុគ្គលោ វា បាបិកា តេ អាវុសោ ទិដ្ឋិ បដិនិស្សជ្ជេតំ បាបិកំ ទិដ្ឋិន្តិ ។ សោ ឯវំ វទេតិ នត្ថិ មេ អាវុសោ បាបិកា ទិដ្ឋិ យមហំ បដិនិស្សជ្ជេយ្យន្តិ ។ តំ សង្ឃោ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខិបតិ អធម្មកម្មំ ។ ឥធ បន ភិក្ខវេ ភិក្ខុស្ស ន ហោតិ អាបត្តិ ទដ្ឋព្វា ន ហោតិ អាបត្តិ បដិកាតព្វា ។ តមេនំ ចោទេតិ សង្ឃោ វា សម្ពហុលា វា ឯកបុគ្គលោ វា



អាបត្តិដែលខ្ញុំគួរឃើញនោះ មិនមានដល់ខ្ញុំទេ ។ សង្ឃក៏លើកវត្តភិក្ខុនោះ ព្រោះមិនឃើញអាបត្តិ (យ៉ាងនេះ) ឈ្មោះថាកម្មមិនប្រកបដោយធម៌ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត អាបត្តិដែលភិក្ខុត្រូវសំដែងមិនមានដល់ភិក្ខុក្នុងសាសនានេះទេ ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គល ១ រូបក្តី ចោទភិក្ខុនោះថា ម្នាលអាវុសោ លោកត្រូវអាបត្តិហើយ ចូរលោកសំដែងអាបត្តិនោះចេញ ។ ភិក្ខុនោះពោលតបវិញយ៉ាងនេះថា ម្នាលអាវុសោ អាបត្តិដែលខ្ញុំត្រូវសំដែងនោះមិនមានដល់ខ្ញុំទេ ។ សង្ឃក៏លើកវត្តភិក្ខុនោះ ព្រោះមិនសំដែងអាបត្តិចេញ (យ៉ាងនេះ) ឈ្មោះថាកម្មមិនប្រកបដោយធម៌ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ទិដ្ឋិអាក្រក់ដែលត្រូវលះបង់មិនមានដល់ភិក្ខុក្នុងសាសនានេះ ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គល ១ រូបក្តី ចោទភិក្ខុនោះថា ម្នាលអាវុសោ លោកមានទិដ្ឋិអាក្រក់ហើយ ចូរលោកលះបង់ទិដ្ឋិអាក្រក់នោះចេញ ។ ភិក្ខុនោះពោលតបវិញយ៉ាងនេះថា ម្នាលអាវុសោ ទិដ្ឋិអាក្រក់ដែលខ្ញុំត្រូវលះបង់មិនមានដល់ខ្ញុំទេ ។ សង្ឃក៏លើកវត្តភិក្ខុនោះ ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ (យ៉ាងនេះ) ឈ្មោះថាកម្មមិនប្រកបដោយធម៌ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត អាបត្តិដែលត្រូវឃើញក៏មិនមាន អាបត្តិដែលត្រូវសំដែងក៏មិនមានដល់ភិក្ខុក្នុងសាសនានេះទេ ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គល ១ រូបក្តី

អាបត្តឹ ត្វំ អាវុសោ អាបន្នោ បស្សសេតំ អាបត្តឹ បដិករោហិ តំ អាបត្តិន្តិ ។ សោ ឯវំ វទតិ នត្ថិ មេ អាវុសោ អាបត្តិ យមហំ បស្សេយ្យំ នត្ថិ មេ អាវុសោ អាបត្តិ យមហំ បដិករេយ្យន្តិ ។ តំ សង្ឃោ អទស្សនេ វា អប្បដិកម្មេ វា ឧក្ខិបតិ អធម្មកម្មំ ។ ឥធ បន ភិក្ខវេ ភិក្ខុស្ស ន ហោតិ អាបត្តិ ទដ្ឋព្វា ន ហោតិ បាបិកា ទិដ្ឋិ បដិនិស្សជ្ជេតព្វា ។ តមេនំ ចោទេតិ សង្ឃោ វា សម្ពហុលា វា បុគ្គលោ វា អាបត្តឹ ត្វំ អាវុសោ អាបន្នោ បស្សសេតំ អាបត្តឹ អត្ថិ តេ បាបិកា ទិដ្ឋិ បដិនិស្សជ្ជេតំ បាបិកំ ទិដ្ឋិន្តិ ។ សោ ឯវំ វទតិ នត្ថិ មេ អាវុសោ អាបត្តិ យមហំ បស្សេយ្យំ នត្ថិ មេ បាបិកា ទិដ្ឋិ យមហំ បដិនិស្សជ្ជេយ្យន្តិ ។ តំ សង្ឃោ អទស្សនេ វា អប្បដិនិស្សគ្គេ វា ឧក្ខិបតិ អធម្មកម្មំ ។ ឥធ បន ភិក្ខវេ ភិក្ខុស្ស ន ហោតិ អាបត្តិ បដិកាតព្វា ន ហោតិ បាបិកា ទិដ្ឋិ បដិនិស្សជ្ជេតព្វា ។ តមេនំ ចោទេតិ សង្ឃោ វា សម្ពហុលា វា បុគ្គលោ វា អាបត្តឹ ត្វំ អាវុសោ



ចោទភិក្ខុនោះថា ម្នាលអាវុសោ លោកត្រូវអាបត្តិហើយ លោកឃើញអាបត្តិនុះទេ ចូរលោកសំដែងអាបត្តិនោះចេញ ។ ភិក្ខុនោះពោលតបយ៉ាងនេះថា ម្នាលអាវុសោ អាបត្តិដែលខ្ញុំត្រូវឃើញមិនមានដល់ខ្ញុំទេ ម្នាលអាវុសោ អាបត្តិដែលខ្ញុំត្រូវសំដែងក៏មិនមានដល់ខ្ញុំដែរ ។ សង្ឃលើកវត្តភិក្ខុនោះ ព្រោះមិនឃើញ (អាបត្តិ) ក្តី ព្រោះមិនសំដែងក្តី (យ៉ាងនេះ) ឈ្មោះជាកម្មមិនប្រកបដោយធម៌ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត អាបត្តិដែលត្រូវឃើញក៏មិនមាន ទិដ្ឋិអាក្រក់ដែលត្រូវលះបង់ក៏មិនមានដល់ភិក្ខុក្នុងសាសនានេះទេ ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គល១រូបក្តី ចោទភិក្ខុនោះថា ម្នាលអាវុសោ លោកត្រូវអាបត្តិហើយ លោកឃើញអាបត្តិនុះទេ លោកមានទិដ្ឋិអាក្រក់ហើយ ចូរលោកលះបង់ទិដ្ឋិអាក្រក់នុះចេញ ។ ភិក្ខុនោះពោលតបយ៉ាងនេះថា ម្នាលអាវុសោ អាបត្តិដែលខ្ញុំត្រូវឃើញមិនមានដល់ខ្ញុំទេ ទិដ្ឋិអាក្រក់ដែលខ្ញុំត្រូវលះបង់ក៏មិនមានដល់ខ្ញុំដែរ ។ សង្ឃលើកវត្តភិក្ខុនោះ ព្រោះមិនឃើញ (អាបត្តិ) ក្តី ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ក្តី (យ៉ាងនេះ) ឈ្មោះជាកម្មមិនប្រកបដោយធម៌ ។ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត អាបត្តិដែលត្រូវសំដែងក៏មិនមាន ទិដ្ឋិអាក្រក់ដែលត្រូវលះបង់ក៏មិនមានដល់ភិក្ខុក្នុងសាសនានេះទេ ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គលមួយរូបក្តី ចោទភិក្ខុនោះថា ម្នាលអាវុសោ

អាបន្នោ បដិករោហិ តំ អាបត្តឹ បាបិកា តេ ទិដ្ឋិ បដិនិស្សជ្ជេតំ បាបិកំ ទិដ្ឋិន្តិ ។ សោ ឯវំ វទតិ នត្ថិ មេ អាវុសោ អាបត្តិ យមហំ បដិករេយ្យំ នត្ថិ មេ អាវុសោ បាបិកា ទិដ្ឋិ យមហំ បដិនិស្សជ្ជេយ្យន្តិ ។ តំ សង្ឃោ អប្បដិកម្មេ ច អប្បដិនិស្សគ្គេ ច ឧក្ខិបតិ អធម្មកម្មំ ។ ឥធ បន ភិក្ខវេ ភិក្ខុស្ស ន ហោតិ អាបត្តិ ទដ្ឋព្វា ន ហោតិ អាបត្តិ បដិកាតព្វា ន ហោតិ បាបិកា ទិដ្ឋិ បដិនិស្សជ្ជេតព្វា ។ តមេនំ ចោទេតិ សង្ឃោ វា គណោ វា បុគ្គលោ វា អាបត្តឹ ត្វំ អាវុសោ អាបន្នោ បស្សសេតំ អាបត្តឹ បដិករោហិ តំ អាបត្តឹ បាបិកា តេ ទិដ្ឋិ បដិនិស្សជ្ជេតំ បាបិកំ ទិដ្ឋិន្តិ ។ សោ ឯវំ វទតិ នត្ថិ មេ អាវុសោ អាបត្តិ យមហំ បស្សេយ្យំ នត្ថិ មេ អាវុសោ អាបត្តិ យមហំ បដិករេយ្យំ នត្ថិ មេ អាវុសោ បាបិកា ទិដ្ឋិ យមហំ បដិនិស្សជ្ជេយ្យន្តិ ។ តំ សង្ឃោ អទស្សនេ ច អប្បដិកម្មេ ច អប្បដិនិស្សគ្គេ ច ឧក្ខិបតិ អធម្មកម្មំ ។



លោកត្រូវអាបត្តិហើយ ចូរលោកសំដែងអាបត្តិនោះចេញ លោកមានទិដ្ឋិអាក្រក់ហើយ ចូរលោកលះបង់ទិដ្ឋិអាក្រក់នុ៎ះចេញ ។ ភិក្ខុនោះពោលតបវិញយ៉ាងនេះថា ម្នាលអាវុសោ អាបត្តិដែលខ្ញុំត្រូវសំដែងមិនមានដល់ខ្ញុំទេ ម្នាលអាវុសោ ទិដ្ឋិអាក្រក់ដែលខ្ញុំត្រូវលះបង់ក៏មិនមានដល់ខ្ញុំដែរ ។ សង្ឃលើកវត្តភិក្ខុនោះ ព្រោះមិនសំដែងអាបត្តិក្តី ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញក្តី (យ៉ាងនេះ) ឈ្មោះថាកម្មមិនប្រកបដោយធម៌ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត អាបត្តិដែលត្រូវឃើញក៏មិនមាន អាបត្តិដែលត្រូវសំដែងក៏មិនមាន ទិដ្ឋិអាក្រក់ដែលត្រូវលះបង់ក៏មិនមាន ដល់ភិក្ខុក្នុងសាសនានេះ ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គលម្នាក់ក្តី ចោទភិក្ខុនោះថា ម្នាលអាវុសោ លោកត្រូវអាបត្តិហើយ លោកឃើញអាបត្តិនុ៎ះទេ ចូរលោកសំដែងអាបត្តិនោះចេញ លោកមានទិដ្ឋិអាក្រក់ហើយ ចូរលោកលះបង់ទិដ្ឋិអាក្រក់នោះចេញ ។ ភិក្ខុនោះពោលតបយ៉ាងនេះថា ម្នាលអាវុសោ អាបត្តិដែលខ្ញុំត្រូវឃើញមិនមានដល់ខ្ញុំទេ ម្នាលអាវុសោ អាបត្តិដែលខ្ញុំត្រូវសំដែងក៏មិនមានដល់ខ្ញុំដែរ ម្នាលអាវុសោ ទាំងទិដ្ឋិអាក្រក់ដែលខ្ញុំត្រូវលះបង់ក៏មិនមានដល់ខ្ញុំដែរ ។ សង្ឃលើកវត្តភិក្ខុនោះ ព្រោះមិនឃើញអាបត្តិក្តី ព្រោះមិនសំដែងក្តី ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ក្តី (យ៉ាងនេះ) ឈ្មោះថាកម្មមិនប្រកបដោយធម៌ ។

(៣០៣) ឥធ បន ភិក្ខវេ ភិក្ខុស្ស ហោតិ អាបត្តិ ទដ្ឋព្វា ។ តមេនំ ចោទេតិ សង្ឃោ វា សម្ពហុលា វា ឯកបុគ្គលោ វា អាបត្តឹ ត្វំ អាវុសោ អាបន្នោ បស្សសេតំ អាបត្តិន្តិ ។ សោ ឯវំ វទេតិ អាមាវុសោ បស្សាមីតិ ។ តំ សង្ឃោ អាបត្តិយា អទស្សនេ ឧក្ខិបតិ អធម្មកម្មំ ។ ឥធ បន ភិក្ខវេ ភិក្ខុស្ស ហោតិ អាបត្តិ បដិកាតព្វា ។ តមេនំ ចោទេតិ សង្ឃោ វា សម្ពហុលា វា ឯកបុគ្គលោ វា អាបត្តឹ ត្វំ អាវុសោ អាបន្នោ បដិករោហិ តំ អាបត្តិន្តិ ។ សោ ឯវំ វទេតិ អាមាវុសោ បដិករិស្សាមីតិ ។ តំ សង្ឃោ អាបត្តិយា អប្បដិកម្មេ ឧក្ខិបតិ អធម្មកម្មំ ។ ឥធ បន ភិក្ខវេ ភិក្ខុស្ស ហោតិ បាបិកា ទិដ្ឋិ បដិនិស្សជ្ជេតា ។ តមេនំ ចោទេតិ សង្ឃោ វា សម្ពហុលា វា ឯកបុគ្គលោ វា បាបិកា តេ អាវុសោ ទិដ្ឋិ បដិនិស្សជ្ជេតំ បាបិកំ ទិដ្ឋិន្តិ ។ សោ ឯវំ វទេតិ អាមាវុសោ បដិនិស្សជ្ជិស្សាមីតិ ។ តំ សង្ឃោ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខិបតិ



(១០៣) ម្នាលភិក្ខុទាំងឡាយ មួយទៀត អាបត្តិដែលត្រូវឃើញ មានដល់ភិក្ខុក្នុងសាសនានេះ ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គលមួយរូបក្តី ចោទភិក្ខុនោះថា ម្នាលអាវុសោ លោកត្រូវអាបត្តិហើយ លោកឃើញអាបត្តិនុ៎ះទេ ។ ភិក្ខុនោះនិយាយតបយ៉ាងនេះថា អើអាវុសោ ខ្ញុំឃើញដែរ ។ សង្ឃលើកវត្តភិក្ខុនោះ ព្រោះមិនឃើញអាបត្តិ (យ៉ាងនេះ) ឈ្មោះថាកម្មមិនប្រកបដោយធម៌ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត អាបត្តិដែលត្រូវសំដែងមានដល់ភិក្ខុ ក្នុងសាសនានេះ ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គលមួយរូបក្តី ចោទភិក្ខុនោះថា ម្នាលអាវុសោ លោកត្រូវអាបត្តិហើយ ចូរលោកសំដែងអាបត្តិនោះចេញ ។ ភិក្ខុនោះនិយាយតបយ៉ាងនេះថា អើអាវុសោ ចាំខ្ញុំសំដែង ។ សង្ឃលើកវត្តភិក្ខុនោះ ព្រោះមិនសំដែងអាបត្តិ (យ៉ាងនេះ) ឈ្មោះថាកម្មមិនប្រកបដោយធម៌ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ទិដ្ឋិអាក្រក់ដែលត្រូវលះបង់ មានដល់ភិក្ខុក្នុងសាសនានេះ ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គលមួយរូបក្តី ចោទភិក្ខុនោះថា ម្នាលអាវុសោ លោកមានទិដ្ឋិអាក្រក់ហើយ ចូរលោកលះបង់ទិដ្ឋិអាក្រក់នុ៎ះចេញ ។ ភិក្ខុនោះនិយាយតបយ៉ាងនេះថា អើអាវុសោ ចាំខ្ញុំលះបង់ ។ សង្ឃលើកវត្តភិក្ខុនោះ ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ

អធម្មកម្មំ ។ ឥធ បន ភិក្ខវេ ភិក្ខុស្ស ហោតិ អាបត្តិ ទដ្ឋព្វា ហោតិ អាបត្តិ បដិកាតព្វា ។ ហោតិ អាបត្តិ ទដ្ឋព្វា ហោតិ បាបិកា ទិដ្ឋិ បដិនិស្សជ្ជេតា ។ ហោតិ អាបត្តិ បដិកាតព្វា ហោតិ បាបិកា ទិដ្ឋិ បដិនិស្សជ្ជេតា ។ ហោតិ អាបត្តិ ទដ្ឋព្វា ហោតិ អាបត្តិ បដិកាតព្វា ហោតិ បាបិកា ទិដ្ឋិ បដិនិស្សជ្ជេតា ។ តមេនំ ចោទេតិ សង្ឃោ វា សម្ពហុលា វា ឯកបុគ្គលោ វា អាបត្តឹ ត្វំ អាវុសោ អាបន្នោ បស្សសេតំ អាបត្តឹ បដិករោហិ តំ អាបត្តឹ បាបិកា តេ ទិដ្ឋិ បដិនិស្សជ្ជេតំ បាបិកំ ទិដ្ឋិន្តិ ។ សោ ឯវំ វទេតិ អាមាវុសោ បស្សាមិ អាម បដិករិស្សាមិ អាម បដិនិស្សជ្ជិស្សាមីតិ ។ តំ សង្ឃោ អទស្សនេ វា អប្បដិកម្មេ វា អប្បដិនិស្សគ្គេ វា ឧក្ខិបតិ អធម្មកម្មំ ។

[១០៤] ឥធ បន ភិក្ខវេ ភិក្ខុស្ស ហោតិ អាបត្តិ ទដ្ឋព្វា ។ តមេនំ ចោទេតិ សង្ឃោ វា សម្ពហុលា វា ឯកបុគ្គលោ វា អាបត្តឹ ត្វំ អាវុសោ អាបន្នោ បស្សសេតំ អាបត្តិន្តិ ។ សោ ឯវំ វទេតិ នត្ថិ មេ អាវុសោ អាបត្តិ





(យ៉ាងនេះ) ឈ្មោះថាកម្មមិនប្រកបដោយធម៌ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត អាបត្តិដែលត្រូវឃើញក៏មាន អាបត្តិដែលត្រូវសំដែងក៏មាន ដល់ភិក្ខុណាសមួយនេះ ។ អាបត្តិដែលត្រូវឃើញក៏មាន ទិដ្ឋិអាក្រក់ដែលត្រូវលះបង់ក៏មាន ។ អាបត្តិដែលត្រូវសំដែងក៏មាន ទិដ្ឋិអាក្រក់ដែលត្រូវលះបង់ក៏មាន ។ អាបត្តិដែលត្រូវឃើញក៏មាន អាបត្តិដែលត្រូវសំដែងក៏មាន (ទាំង) ទិដ្ឋិអាក្រក់ដែលត្រូវលះបង់ក៏មាន ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គលមួយរូបក្តី ចោទភិក្ខុនោះថា ម្នាលអាវុសោ លោកត្រូវអាបត្តិហើយ លោកឃើញអាបត្តិនុ៎ះទេ ចូរលោកសំដែងអាបត្តិនោះចេញ លោកមានទិដ្ឋិអាក្រក់ហើយ ចូរលោកលះទិដ្ឋិអាក្រក់នោះចេញ ។ ភិក្ខុនោះនិយាយតបយ៉ាងនេះថា អើអាវុសោ ខ្ញុំឃើញដែរ អើខ្ញុំសំដែងចេញ អើខ្ញុំលះបង់ចេញ ។ សង្ឃលើកវត្តភិក្ខុនោះ ព្រោះមិនឃើញអាបត្តិក្តី ព្រោះមិនសំដែងក្តី ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញក្តី (យ៉ាងនេះ) ឈ្មោះថាកម្មមិនប្រកបដោយធម៌ ។

(១០៤) ម្នាលភិក្ខុទាំងឡាយ អាបត្តិដែលត្រូវឃើញ មានដល់ភិក្ខុណាសមួយនេះ ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គលមួយរូបក្តី ចោទភិក្ខុនោះថា ម្នាលអាវុសោ លោកត្រូវអាបត្តិហើយ លោកឃើញអាបត្តិនុ៎ះទេ ។ ភិក្ខុនោះនិយាយតបយ៉ាងនេះថា ម្នាលអាវុសោ អាបត្តិដែល

យមហំ បស្សេយ្យន្តិ ។ តំ សង្ឃោ អាបត្តិយា អទស្សនេ ឧក្ខិបតិ អធម្មកម្មំ ។ ឥធ បន ភិក្ខវេ ភិក្ខុស្ស ហោតិ អាបត្តិ បដិកាតព្វា ។ តមេនំ ចោទេតិ សង្ឃោ វា សម្ពហុលា វា ឯកបុគ្គលោ វា អាបត្តឹ ត្វំ អាវុសោ អាបន្នោ បដិករោហិ តំ អាបត្តិន្តិ ។ សោ ឯវំ វទេតិ នត្ថិ មេ អាវុសោ អាបត្តិ យមហំ បដិករេយ្យន្តិ ។ តំ សង្ឃោ អាបត្តិយា អប្បដិកម្មេ ឧក្ខិបតិ អធម្មកម្មំ ។ ឥធ បន ភិក្ខវេ ភិក្ខុស្ស ហោតិ បាបិកា ទិដ្ឋិ បដិនិស្សជ្ជេតព្វា ។ តមេនំ ចោទេតិ សង្ឃោ វា សម្ពហុលា វា ឯកបុគ្គលោ វា បាបិកា តេ អាវុសោ ទិដ្ឋិ បដិនិស្សជ្ជេតំ បាបិកំ ទិដ្ឋិន្តិ ។ សោ ឯវំ វទេតិ នត្ថិ មេ អាវុសោ បាបិកា ទិដ្ឋិ យមហំ បដិនិស្សជ្ជេយ្យន្តិ ។ តំ សង្ឃោ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខិបតិ អធម្មកម្មំ ។ ឥធ បន ភិក្ខវេ ភិក្ខុស្ស ហោតិ អាបត្តិ អទដ្ឋព្វា ហោតិ អាបត្តិ បដិកាតព្វា ។ ហោតិ អាបត្តិ អទដ្ឋព្វា ហោតិ បាបិកា ទិដ្ឋិ បដិនិស្សជ្ជេតព្វា ។ ហោតិ អាបត្តិ បដិកាតព្វា ហោតិ បាបិកា ទិដ្ឋិ បដិនិស្សជ្ជេតព្វា ។ ហោតិ អាបត្តិ





ខ្ញុំត្រូវឃើញមិនមានដល់ខ្ញុំទេ ។ សង្ឃលើកវត្តភិក្ខុនោះ ព្រោះមិនឃើញអាបត្តិ (យ៉ាងនេះ) ហៅថាកម្មប្រកបដោយធម៌ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត អាបត្តិដែលត្រូវសំដែង មានដល់ភិក្ខុក្នុងសាសនានេះ ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គលមួយរូបក្តី ចោទភិក្ខុនោះថា ម្នាលអាវុសោ លោកត្រូវអាបត្តិហើយ ចូរលោកសំដែងអាបត្តិនុះចេញ ។ ភិក្ខុនោះនិយាយតបយ៉ាងនេះថា ម្នាលអាវុសោ អាបត្តិដែលខ្ញុំត្រូវសំដែងមិនមានដល់ខ្ញុំទេ ។ សង្ឃលើកវត្តភិក្ខុនោះ ព្រោះមិនសំដែងអាបត្តិ (យ៉ាងនេះ) ហៅថាកម្មប្រកបដោយធម៌ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ទិដ្ឋិអាក្រក់ដែលត្រូវលះបង់ មានដល់ភិក្ខុក្នុងសាសនានេះ ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គលមួយរូបក្តី ចោទភិក្ខុនោះថា ម្នាលអាវុសោ លោកមានទិដ្ឋិអាក្រក់ហើយ ចូរលោកលះបង់ទិដ្ឋិអាក្រក់នុះចេញ ។ ភិក្ខុនោះនិយាយតបយ៉ាងនេះថា ម្នាលអាវុសោ ទិដ្ឋិអាក្រក់ដែលខ្ញុំត្រូវលះបង់មិនមានដល់ខ្ញុំទេ ។ សង្ឃលើកវត្តភិក្ខុនោះ ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ (យ៉ាងនេះ) ហៅថាកម្មប្រកបដោយធម៌ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត អាបត្តិដែលត្រូវឃើញក៏មាន អាបត្តិដែលត្រូវសំដែងក៏មាន ដល់ភិក្ខុក្នុងសាសនានេះ ។ អាបត្តិដែលត្រូវឃើញក៏មាន ទិដ្ឋិអាក្រក់ដែលត្រូវលះបង់ក៏មាន ។ អាបត្តិដែលត្រូវសំដែងក៏មាន ទិដ្ឋិអាក្រក់ដែលត្រូវលះបង់ក៏មាន ។ អាបត្តិដែល

ទដ្ឋព្វា ហោតិ អាបត្តិ បដិកាតព្វា ហោតិ បាបិកា ទិដ្ឋិ
បដិនិស្សជ្ជិតា ។ តមេនំ ចោទេតិ សង្ឃោ វា សម្ពហុ-
លា វា ឯកបុគ្គលោ វា អាបត្តឹ ត្វំ អាវុសោ អាបន្នោ
បស្សសេតំ អាបត្តឹ បដិករោហិ តំ អាបត្តឹ បាបិកា តេ
អាវុសោ ទិដ្ឋិ បដិនិស្សជ្ជេតំ បាបិកំ ទិដ្ឋិន្តិ ។ សោ
ឯវំ វទេតិ នត្ថិ មេ អាវុសោ អាបត្តិ យមហំ បស្សេយ្យំ
នត្ថិ មេ អាបត្តិ យមហំ បដិករេយ្យំ នត្ថិ មេ បា-
បិកា ទិដ្ឋិ យមហំ បដិនិស្សជ្ជេយ្យន្តិ ។ តំ សង្ឃោ
អទស្សនេ វា អប្បដិកម្មេ វា អប្បដិនិស្សគ្គេ វា ឧក្ខិបតិ
អធម្មកម្មំ ។

(៤០៨) អថខោ អាយស្មា ឧបាលិ យេន ភគវា
តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ
និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា ឧបាលិ
ភគវន្តំ ឯតទវោច យោ នុ ខោ ភន្តេ សមគ្គោ សង្ឃោ
សម្មុខាករណីយំ កម្មំ អសម្មុខា ករោតិ ធម្មកម្មំ
នុ ខោ តំ ភន្តេ វិនយកម្មន្តិ ។ អធម្មកម្មំ តំ ឧបាលិ



ត្រូវឃើញក៏មាន អាបត្តិដែលត្រូវសំដែងក៏មាន ទិដ្ឋិអាក្រក់ដែលត្រូវ
លះបង់ក៏មាន ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គលមួយរូបក្តី ចោទភិក្ខុនោះថា
ម្នាលអាវុសោ លោកត្រូវអាបត្តិហើយ លោកឃើញអាបត្តិនុ៎ះទេ ចូរលោក
សំដែងអាបត្តិនោះចេញ ម្នាលអាវុសោ លោកមានទិដ្ឋិអាក្រក់ហើយ
ចូរលោកលះបង់ទិដ្ឋិអាក្រក់នោះចេញ ។ ភិក្ខុនោះនិយាយតបយ៉ាងនេះថា
ម្នាលអាវុសោ អាបត្តិដែលខ្ញុំត្រូវឃើញមិនមានដល់ខ្ញុំទេ អាបត្តិដែលខ្ញុំត្រូវ
សំដែងក៏មិនមានដល់ខ្ញុំ ចំណែកទិដ្ឋិអាក្រក់ដែលខ្ញុំត្រូវលះបង់ក៏មិនមានដល់
ខ្ញុំដែរ ។ សង្ឃលើកវត្តភិក្ខុនោះ ព្រោះមិនឃើញអាបត្តិក្តី ព្រោះមិន
សំដែងក្តី ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញក្តី (យ៉ាងនេះ) ហៅថាកម្ម
ប្រកបដោយអធម៌ ។

(៤០៨) គ្រានោះឯង ព្រះឧបាលិដ៏មានអាយុចូលទៅគាល់ព្រះដ៏មាន
ព្រះភាគ លុះចូលទៅដល់ហើយក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយ
នៅក្នុងទីសមគួរ ។ លុះព្រះឧបាលិដ៏មានអាយុអង្គុយនៅក្នុងទីសមគួរហើយ
ក៏ក្រាបបង្គំទូលសួរពាក្យនេះចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គ
ដ៏ចំរើន កម្មដែលត្រូវធ្វើក្នុងទីចំពោះមុខ សង្ឃណាមួយព្រមព្រៀងគ្នា
ធ្វើក្នុងទីកំបាំងមុខទៅវិញ បពិត្រព្រះអង្គដ៏ចំរើន កម្មនោះជាកម្មត្រូវតាម
ធម៌ ជាកម្មត្រូវតាមវិន័យដែរឬ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ

អវិនយកម្មន្តិ ។ យោ នុ ខោ ភន្តេ សមគ្គោ សង្ឃោ បដិបុច្ឆាករណីយំ កម្មំ អប្បដិបុច្ឆា ករោតិ បដិញ្ញាយករណីយំ កម្មំ អប្បដិញ្ញាយ ករោតិ សតិវិនយារហស្ស អមូឡ្ហវិនយំ ទេតិ អមូឡ្ហវិនយារហស្ស តស្សបាបិយសិកាកម្មំ ករោតិ តស្សបាបិយសិកាកម្មារហស្ស តជ្ជនីយកម្មំ ករោតិ តជ្ជនីយកម្មារហស្ស និយស្សកម្មំ ករោតិ និយស្សកម្មារហស្ស បព្វាជនីយកម្មំ ករោតិ បព្វាជនីយកម្មារហស្ស បដិសារណីយកម្មំ ករោតិ បដិសារណីយកម្មារហស្ស ឧក្ខេបនីយកម្មំ ករោតិ ឧក្ខេបនីយកម្មារហស្ស បរិវាសំ ទេតិ បរិវាសារហំ មូលាយ បដិកស្សតិ មូលាយបដិកស្សនារហស្ស មានត្តំ ទេតិ មានត្តារហំ អព្ភេតិ អព្ភានារហំ ឧបសម្បាទេតិ ធម្មកម្មំ នុ ខោ តំ ភន្តេ វិនយកម្មន្តិ ។ អធម្មកម្មំ តំ ឧបាលិ អវិនយកម្មំ ។ យោ ខោ ឧបាលិ សមគ្គោ សង្ឃោ សម្មុខាករណីយំ កម្មំ អសម្មុខា



កម្មនោះជាកម្មមិនត្រូវតាមធម៌ ជាកម្មមិនត្រូវតាមវិន័យទេ ។ ព្រះឧបាលិថេរទូលសួរ ក្រោយបន្ទំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន កម្មដែលត្រូវធ្វើដោយការសាកសួរ សង្ឃណាមួយព្រមព្រៀងគ្នាធ្វើដោយការមិនសាកសួរវិញ កម្មដែលត្រូវធ្វើដោយការប្តេជ្ញា សង្ឃធ្វើដោយមិនបានប្តេជ្ញាវិញ ឲ្យអមូឡ្ហវិន័យដល់ភិក្ខុដែលគួរដល់សតិវិន័យវិញ ធ្វើតស្សបាបិយសិកាកម្មដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យវិញ ធ្វើតជ្ជនីយកម្មដល់ភិក្ខុដែលគួរដល់តស្សបាបិយសិកាកម្មវិញ ធ្វើនិយស្សកម្មដល់ភិក្ខុដែលគួរដល់តជ្ជនីយកម្មវិញ ធ្វើបព្វាជនីយកម្មដល់ភិក្ខុដែលគួរដល់និយស្សកម្មវិញ ធ្វើបដិសារណីយកម្មដល់ភិក្ខុដែលគួរដល់បព្វាជនីយកម្មវិញ ធ្វើឧក្ខេបនីយកម្មដល់ភិក្ខុដែលគួរដល់បដិសារណីយកម្មវិញ ឲ្យបរិវាសដល់ភិក្ខុដែលគួរដល់ឧក្ខេបនីយកម្មវិញ ឲ្យមូលាយបដិកស្សនដល់ភិក្ខុដែលគួរដល់បរិវាសវិញ ឲ្យមានត្តដល់ភិក្ខុដែលគួរដល់មូលាយបដិកស្សនៈវិញ ឲ្យអព្ភានដល់ភិក្ខុដែលគួរដល់មានត្តវិញ ឲ្យឧបសម្បទាដល់ភិក្ខុដែលគួរដល់អព្ភានវិញ បពិត្រព្រះអង្គដ៏ចំរើន កម្មនោះជាកម្មត្រូវតាមធម៌ ជាកម្មត្រូវតាមវិន័យដែរឬ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ កម្មនោះមិនមែនជាកម្មត្រូវតាមធម៌ មិនមែនជាកម្មត្រូវតាមវិន័យទេ ម្នាលឧបាលិ សង្ឃណាមួយព្រមព្រៀងគ្នា ធ្វើកម្មដែលត្រូវធ្វើក្នុងទីចំពោះមុខ (គឺឡប់ជាធ្វើ) ក្នុងទីកំបាំងមុខវិញ

ករោតិ ឯវំ ខោ ឧបាលិ អធម្មកម្មំ ហោតិ អវិនយកម្ម-
ញ្ច បន សង្ឃោ សាតិសារោ ហោតិ យោ ខោ ឧបាលិ
សមគ្គោ សង្ឃោ បដិបុច្ឆាករណីយំ កម្មំ អប្បដិបុច្ឆា
ករោតិ បដិញ្ញាយ ករណីយំ កម្មំ អប្បដិញ្ញាយ
ករោតិ សតិវិនយារហស្ស អមូឡ្ហវិនយំ ទេតិ អមូឡ្ហ-
វិនយារហស្ស តស្សបាបិយសិកាកម្មំ ករោតិ តស្ស-
បាបិយសិកាកម្មារហស្ស តជ្ជនីយកម្មំ ករោតិ តជ្ជ-
នីយកម្មារហស្ស និយស្សកម្មំ ករោតិ និយស្សកម្មា-
រហស្ស បព្វាជនីយកម្មំ ករោតិ បព្វាជនីយកម្មារហស្ស
បដិសារណីយកម្មំ ករោតិ បដិសារណីយកម្មារហស្ស
ឧក្ខេបនីយកម្មំ ករោតិ ឧក្ខេបនីយកម្មារហស្ស
បរិវាសំ ទេតិ បរិវាសារហំ មូលាយ បដិកស្សតិ
មូលាយបដិកស្សនារហស្ស មានត្តំ ទេតិ មានត្តារហំ
អព្ភេតិ អព្ភានារហំ ឧបសម្បាទេតិ ឯវំ ខោ ឧបាលិ
អធម្មកម្មំ ហោតិ អវិនយកម្មំ ឯវញ្ច បន សង្ឃោ
សាតិសារោ ហោតិ ។



ម្នាលឧបាលិ កម្មយ៉ាងនេះឯង ឈ្មោះថាអធម្មកម្ម (កម្មមិនត្រូវតាមធម៌) ឈ្មោះថាអវិនយកម្ម (កម្មមិនត្រូវតាមវិន័យ) ឯសង្ឃសោតក៏ជាសង្ឃប្រកបដោយទោស ដោយប្រការដូច្នេះ ម្នាលឧបាលិ កម្មដែលត្រូវធ្វើដោយការសាកសួរ សង្ឃណាមួយព្រមព្រៀងគ្នាធ្វើដោយមិនបានសាកសួរ កម្មដែលត្រូវធ្វើដោយសេចក្ដីប្ដេជ្ញា សង្ឃធ្វើដោយមិនបានប្ដេជ្ញាវិញ ឲ្យអមូឡ្ហវិន័យដល់ភិក្ខុដែលគួរដល់សតិវិន័យ ធ្វើតស្សបាបិយសិកាកម្មដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ ធ្វើតជ្ជនីយកម្មដល់ភិក្ខុដែលគួរដល់តស្សបាបិយសិកាកម្ម ធ្វើនិយស្សកម្មដល់ភិក្ខុដែលគួរដល់តជ្ជនីយកម្ម ធ្វើបព្វាជនីយកម្មដល់ភិក្ខុដែលគួរដល់និយស្សកម្ម ធ្វើបដិសារណីយកម្មដល់ភិក្ខុដែលគួរដល់បព្វាជនីយកម្ម ធ្វើឧក្ខេបនីយកម្មដល់ភិក្ខុដែលគួរដល់បដិសារណីយកម្ម ឲ្យបរិវាសដល់ភិក្ខុដែលគួរដល់ឧក្ខេបនីយកម្ម ឲ្យមូលាយបដិកស្សនៈដល់ភិក្ខុដែលគួរដល់បរិវាស ឲ្យមានត្តដល់ភិក្ខុដែលគួរដល់មូលាយបដិកស្សនៈ ឲ្យអព្ភានដល់ភិក្ខុដែលគួរដល់មានត្ត ឲ្យឧបសម្បទាដល់ភិក្ខុដែលគួរដល់អព្ភាន ម្នាលឧបាលិ កម្មយ៉ាងនេះឯង ឈ្មោះថាជាអធម្មកម្ម ជាអវិនយកម្ម ឯសង្ឃសោតក៏ជាសង្ឃប្រកបដោយទោស ដោយប្រការយ៉ាងនេះ ។

[១០៦] យោ នុ ខោ ភន្តេ សមគ្គោ សង្ឃោ សម្មុខាករណីយំ កម្មំ សម្មុខា ករោតិ ធម្មកម្មំ នុ ខោ តំ ភន្តេ វិនយកម្មន្តិ ។ ធម្មកម្មំ តំ ឧបាលិ វិនយកម្មន្តិ ។ យោ នុ ខោ ភន្តេ សមគ្គោ សង្ឃោ បដិបុច្ឆាករណីយំ កម្មំ បដិបុច្ឆា ករោតិ បដិញ្ញាយ ករណីយំ កម្មំ បដិញ្ញាយ ករោតិ សតិវិនយារហស្ស សតិវិនយំ ទេតិ អមូឡ្ហវិនយារហស្ស អមូឡ្ហវិនយំ ទេតិ តស្សបាបិយសិកាកម្មារហស្ស តស្សបាបិយសិកាកម្មំ ករោតិ តជ្ជនីយកម្មារហស្ស តជ្ជនីយកម្មំ ករោតិ និយស្សកម្មារហស្ស និយស្សកម្មំ ករោតិ បព្វាជនីយកម្មារហស្ស បព្វាជនីយកម្មំ ករោតិ បដិសារណីយកម្មារហស្ស បដិសារណីយកម្មំ ករោតិ ឧក្ខេបនីយកម្មារហស្ស ឧក្ខេបនីយកម្មំ ករោតិ បរិវាសារហស្ស បរិវាសំ ទេតិ មូលាយ បដិកស្សនារហំ មូលាយ បដិកស្សតិ មានត្តារហស្ស មានត្តំ ទេតិ អព្ភានារហំ អព្ភេតិ ឧបសម្បទារហំ ឧបសម្បាទេតិ



(១០៦) ព្រះឧបាលិត្ថេរក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន កម្មដែលត្រូវធ្វើ ក្នុងទីចំពោះមុខ សង្ឃណាមួយព្រមព្រៀងគ្នា ធ្វើក្នុងទីចំពោះមុខ បពិត្រព្រះអង្គដ៏ចំរើន កម្មរបស់សង្ឃនោះតើ ហៅថាធម្មកម្ម (កម្មត្រូវតាមធម៌) ជាវិនយកម្ម (កម្មត្រូវតាមវិន័យ) ដែរឬ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ កម្មនោះហៅថាធម្មកម្ម ជាវិនយកម្ម ។ ព្រះឧបាលិត្ថេរក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន កម្មដែលត្រូវធ្វើដោយការសាកសួរ សង្ឃណាមួយព្រមព្រៀងគ្នាធ្វើដោយការសាកសួរ កម្មដែលត្រូវធ្វើដោយសេចក្តីប្តេជ្ញា សង្ឃធ្វើដោយសេចក្តីប្តេជ្ញា ឲ្យសតិវិន័យដល់ភិក្ខុដែលគួរដល់សតិវិន័យ ឲ្យអមូឡ្ហវិន័យដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ ធ្វើតស្សបាបិយសិកាកម្ម ដល់ភិក្ខុដែលគួរដល់តស្សបាបិយសិកាកម្ម ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុដែលគួរដល់តជ្ជនីយកម្ម ធ្វើនិយស្សកម្ម ដល់ភិក្ខុដែលគួរដល់និយស្សកម្ម ធ្វើបព្វាជនីយកម្ម ដល់ភិក្ខុដែលគួរដល់បព្វាជនីយកម្ម ធ្វើបដិសារណីយកម្មដល់ភិក្ខុដែលគួរដល់បដិសារណីយកម្ម ធ្វើឧក្ខេបនីយកម្មដល់ភិក្ខុដែលគួរដល់ឧក្ខេបនីយកម្ម ឲ្យបរិវាសដល់ភិក្ខុដែលគួរដល់បរិវាស ឲ្យមូលាយបដិកស្សនៈដល់ភិក្ខុដែលគួរដល់មូលាយបដិកស្សនៈ ឲ្យមានត្តដល់ភិក្ខុដែលគួរដល់មានត្ត ឲ្យអព្ភានដល់ភិក្ខុដែលគួរដល់អព្ភាន ឲ្យឧបសម្បទាដល់កុលបុត្រដែលគួរដល់ឧបសម្បទា

ធម្មកម្មំ នុ ខោ តំ ភន្តេ វិនយកម្មន្តិ ។ ធម្មកម្មំ តំ ឧបាលិ វិនយកម្មំ យោ ខោ ឧបាលិ សមគ្គោ សង្ឃោ សម្មុខាករណីយំ កម្មំ សម្មុខា ករោតិ ឯវំ ខោ ឧបាលិ ធម្មកម្មំ ហោតិ វិនយកម្មំ ឯវញ្ច បន សង្ឃោ អនតិសារោ ហោតិ យោ ខោ ឧបាលិ សមគ្គោ សង្ឃោ បដិបុច្ឆាករណីយំ កម្មំ បដិបុច្ឆា ករោតិ បដិញ្ញាយ ករណីយំ កម្មំ បដិញ្ញាយ ករោតិ សតិវិនយារហស្ស សតិវិនយំ ទេតិ អមូឡ្ហវិនយារហស្ស អមូឡ្ហវិនយំ ទេតិ តស្សបាបិយសិកាកម្មារហស្ស តស្សបាបិយសិកាកម្មំ ករោតិ តជ្ជនីយកម្មារហស្ស តជ្ជនីយកម្មំ ករោតិ និយស្សកម្មារហស្ស និយស្សកម្មំ ករោតិ បព្វាជនីយកម្មារហស្ស បព្វាជនីយកម្មំ ករោតិ បដិសារណីយកម្មារហស្ស បដិសារណីយកម្មំ ករោតិ ឧក្ខេបនីយកម្មារហស្ស ឧក្ខេបនីយកម្មំ ករោតិ បរិវាសារហស្ស បរិវាសំ ទេតិ មូលាយ បដិកស្សនារហំ មូលាយ បដិកស្សតិ



បពិត្រព្រះអង្គដ៏ចំរើន កម្មរបស់សង្ឃនោះ ជាធម្មកម្ម ជាវិន័យកម្មដែរឬ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ កម្មនោះ ជាធម្មកម្ម ជាវិន័យកម្ម ម្នាលឧបាលិ កម្មដែលត្រូវធ្វើក្នុងទីចំពោះមុខ សង្ឃណាមួយព្រមព្រៀងគ្នាធ្វើក្នុងទីចំពោះមុខ ម្នាលឧបាលិ កម្មយ៉ាងនេះឯង ឈ្មោះថាជាធម្មកម្ម ជាវិន័យកម្ម ឯសង្ឃសោតក៏ឈ្មោះថាជាសង្ឃមិនប្រកបដោយទោស ដោយប្រការយ៉ាងនេះ ម្នាលឧបាលិ កម្មដែលត្រូវធ្វើដោយការសាកសួរ សង្ឃណាមួយព្រមព្រៀងគ្នាធ្វើដោយការសាកសួរ កម្មដែលត្រូវធ្វើដោយសេចក្តីប្តេជ្ញា សង្ឃធ្វើដោយសេចក្តីប្តេជ្ញា ឲ្យសតិវិន័យដល់ភិក្ខុដែលគួរដល់សតិវិន័យ ឲ្យអមូឡ្ហវិន័យដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ ធ្វើតស្សបាបិយសិកាកម្ម ដល់ភិក្ខុដែលគួរដល់តស្សបាបិយសិកាកម្ម ធ្វើតជ្ជនីយកម្មដល់ភិក្ខុដែលគួរដល់តជ្ជនីយកម្ម ធ្វើនិយស្សកម្មដល់ភិក្ខុដែលគួរដល់និយស្សកម្ម ធ្វើបព្វាជនីយកម្មដល់ភិក្ខុដែលគួរដល់បព្វាជនីយកម្ម ធ្វើបដិសារណីយកម្មដល់ភិក្ខុដែលគួរដល់បដិសារណីយកម្ម ធ្វើឧក្ខេបនីយកម្មដល់ភិក្ខុដែលគួរដល់ឧក្ខេបនីយកម្ម ឲ្យបរិវាសដល់ភិក្ខុដែលគួរដល់បរិវាស ឲ្យមូលាយបដិកស្សនៈ

មានត្តារហស្ស មានត្តំ ទេតិ អព្ភានារហំ អព្ភេតិ ឧបសម្បទារហំ ឧបសម្បាទេតិ ឯវំ ខោ ឧបាលិ ធម្មកម្មំ ហោតិ វិនយកម្មំ ។ ឯវញ្ច បន សង្ឃោ អនតិសារោ ហោតីតិ ។

(១១៧) យោ នុ ខោ ភន្តេ សមគ្គោ សង្ឃោ សតិវិនយារហស្ស អមូឡ្ហវិនយំ ទេតិ អមូឡ្ហវិនយារហស្ស សតិវិនយំ ទេតិ ធម្មកម្មំ នុ ខោ តំ ភន្តេ វិនយកម្មន្តិ ។ អធម្មកម្មំ តំ ឧបាលិ អវិនយកម្មន្តិ ។ យោ នុ ខោ ភន្តេ សមគ្គោ សង្ឃោ អមូឡ្ហវិនយារហស្ស តស្សបាបិយសិកាកម្មំ ករោតិ តស្សបាបិយសិកាកម្មារហស្ស អមូឡ្ហវិនយំ ទេតិ តស្សបាបិយសិកាកម្មារហស្ស តជ្ជនីយកម្មំ ករោតិ តជ្ជនីយកម្មារហស្ស តស្សបាបិយសិកាកម្មំ ករោតិ តជ្ជនីយកម្មារហស្ស និយស្សកម្មំ ករោតិ និយស្សកម្មារហស្ស តជ្ជនីយកម្មំ ករោតិ និយស្សកម្មារហស្ស បព្វាជនីយកម្មំ ករោតិ បព្វាជនីយកម្មារហស្ស និយស្សកម្មំ ករោតិ



ដល់ភិក្ខុដែលគួរដល់មូលាយបដិកស្សនៈ ឲ្យមានត្តដល់ភិក្ខុដែលគួរដល់មានត្ត ឲ្យអព្ភានដល់ភិក្ខុដែលគួរដល់អព្ភាន ឲ្យឧបសម្បទាដល់កុលបុត្តដែលគួរដល់ឧបសម្បទា ម្នាលឧបាលិ កម្មយ៉ាងនេះឯង ឈ្មោះថាជាធម្មកម្ម ជាវិនយកម្ម ។ ឯសង្ឃរមែងឈ្មោះថាជាសង្ឃមិនប្រកបដោយទោស ដោយប្រការយ៉ាងនេះ ។

(១១៧) ព្រះឧបាលិត្ថេរក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន សង្ឃណាមួយព្រមព្រៀងគ្នា ឲ្យអមូឡ្ហវិន័យដល់ភិក្ខុដែលគួរដល់សតិវិន័យ ឲ្យសតិវិន័យដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ បពិត្រព្រះអង្គដ៏ចំរើន កម្មនោះជាធម្មកម្មជាវិនយកម្មឬ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ កម្មនោះជាអធម្មកម្ម ជាអវិនយកម្ម ។ ព្រះឧបាលិត្ថេរក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន សង្ឃណាមួយព្រមព្រៀងគ្នាធ្វើតស្សបាបិយសិកាកម្មដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ ឲ្យអមូឡ្ហវិន័យដល់ភិក្ខុដែលគួរដល់តស្សបាបិយសិកាកម្ម ធ្វើតជ្ជនីយកម្មដល់ភិក្ខុដែលគួរដល់តស្សបាបិយសិកាកម្ម ធ្វើតស្សបាបិយសិកាកម្មដល់ភិក្ខុដែលគួរដល់តជ្ជនីយកម្ម ធ្វើនិយស្សកម្មដល់ភិក្ខុដែលគួរដល់តជ្ជនីយកម្ម ធ្វើតជ្ជនីយកម្មដល់ភិក្ខុដែលគួរដល់និយស្សកម្ម ធ្វើបព្វាជនីយកម្មដល់ភិក្ខុដែលគួរដល់និយស្សកម្ម ធ្វើនិយស្សកម្មដល់ភិក្ខុដែលគួរដល់បព្វាជនីយកម្ម

បព្វាជនីយកម្មារហស្ស បដិសារណីយកម្មំ ករោតិ ប-
ដិសារណីយកម្មារហស្ស បព្វាជនីយកម្មំ ករោតិ បដិ-
សារណីយកម្មារហស្ស ឧក្ខេបនីយកម្មំ ករោតិ ឧក្ខេ-
បនីយកម្មារហស្ស បដិសារណីយកម្មំ ករោតិ ឧក្ខេប-
នីយកម្មារហស្ស បរិវាសំ ទេតិ បរិវាសារហស្ស ឧក្ខេ-
បនីយកម្មំ ករោតិ បរិវាសារហំ មូលាយ បដិកស្សតិ
មូលាយ បដិកស្សនារហស្ស បរិវាសំ ទេតិ មូលាយ
បដិកស្សនារហស្ស មានត្តំ ទេតិ មានត្តារហំ មូលាយ
បដិកស្សតិ មានត្តារហំ អព្ភេតិ អព្ភានារហស្ស មានត្តំ
ទេតិ អព្ភានារហំ ឧបសម្បាទេតិ ឧបសម្បទារហំ អព្ភេតិ
ធម្មកម្មំ នុ ខោ តំ ភន្តេ វិនយកម្មន្តិ ។ អធម្មកម្ម-
តំ ឧបាលិ អវិនយកម្មំ ។ យោ ខោ ឧបាលិ សមគ្គោ
សង្ឃោ សតិវិនយារហស្ស អមូឡ្ហវិនយំ ទេតិ អមូឡ្ហ-
វិនយារហស្ស សតិវិនយំ ទេតិ ឯវំ ខោ ឧបាលិ អធម្ម-
កម្មំ ហោតិ អវិនយកម្មំ ឯវញ្ច បន សង្ឃោ សាតិ-
សារោ ហោតិ ។ យោ ខោ ឧបាលិ សមគ្គោ
សង្ឃោ អមូឡ្ហវិនយារហស្ស តស្សបាបិយសិកាកម្មំ



ធ្វើបដិសារណីយកម្មដល់ភិក្ខុដែលគួរដល់បព្វាជនីយកម្ម ធ្វើបព្វាជនីយ-
កម្ម ដល់ភិក្ខុដែលគួរដល់បដិសារណីយកម្ម ធ្វើឧក្ខេបនីយកម្មដល់ភិក្ខុ
ដែលគួរដល់បដិសារណីយកម្ម ធ្វើបដិសារណីយកម្ម ដល់ភិក្ខុដែលគួរ
ដល់ឧក្ខេបនីយកម្ម ឲ្យបរិវាសដល់ភិក្ខុដែលគួរដល់ឧក្ខេបនីយកម្ម ធ្វើ
ឧក្ខេបនីយកម្មដល់ភិក្ខុដែលគួរដល់បរិវាស ឲ្យមូលាយបដិកស្សនៈដល់
ភិក្ខុដែលគួរដល់បរិវាស ឲ្យបរិវាសដល់ភិក្ខុដែលគួរ ដល់មូលាយបដិ-
កស្សនៈ ឲ្យមានត្តដល់ភិក្ខុដែលគួរដល់មូលាយបដិកស្សនៈ ឲ្យមូលាយ-
បដិកស្សនៈ ដល់ភិក្ខុដែលគួរដល់មានត្ត ឲ្យអព្ភានដល់ភិក្ខុដែលគួរដល់
មានត្ត ឲ្យមានត្តដល់ភិក្ខុដែលគួរដល់អព្ភាន ឲ្យឧបសម្បទាដល់ភិក្ខុដែល
គួរដល់អព្ភាន ឲ្យអព្ភានដល់ភិក្ខុដែលគួរដល់ឧបសម្បទា បពិត្រ
ព្រះអង្គដ៏ចំរើន កម្មនោះជាធម្មកម្ម ជាវិនយកម្មដែរឬ ។ ព្រះអង្គទ្រង់
ត្រាស់ថា ម្នាលឧបាលិ កម្មនោះមិនមែនជាធម្មកម្ម ជាវិនយកម្មទេ ។
ម្នាលឧបាលិ សង្ឃណាមួយព្រមព្រៀងគ្នា ឲ្យអមូឡ្ហវិន័យដល់ភិក្ខុ
ដែលគួរដល់សតិវិន័យ ឲ្យសតិវិន័យ ដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ
ម្នាលឧបាលិ កម្មយ៉ាងនេះឯង ឈ្មោះថាជាអធម្មកម្ម ជាអវិនយ-
កម្ម ឯសង្ឃនោះក៏ជាសង្ឃប្រកបដោយទោសដោយប្រការដូច្នេះ ។
ម្នាលឧបាលិ សង្ឃណាមួយព្រមព្រៀងគ្នា ធ្វើតស្សបាបិយសិកាកម្ម

ករោតិ តស្សបាបិយសិកាកម្មារហស្ស អមូឡ្ហវិនយំ ទេតិ តស្សបាបិយសិកាកម្មារហស្ស តជ្ជនីយកម្មំ ករោតិ តជ្ជនីយកម្មារហស្ស តស្សបាបិយសិកាកម្មំ ករោតិ តជ្ជនីយកម្មារហស្ស និយស្សកម្មំ ករោតិ និយស្សកម្មារហស្ស តជ្ជនីយកម្មំ ករោតិ និយស្សកម្មារហស្ស បព្វាជនីយកម្មំ ករោតិ បព្វាជនីយកម្មារហស្ស និយស្សកម្មំ ករោតិ បព្វាជនីយកម្មារហស្ស បដិសារណីយកម្មំ ករោតិ បដិសារណីយកម្មារហស្ស បព្វាជនីយកម្មំ ករោតិ បដិសារណីយកម្មារហស្ស ឧក្ខេបនីយកម្មំ ករោតិ ឧក្ខេបនីយកម្មារហស្ស បដិសារណីយកម្មំ ករោតិ ឧក្ខេបនីយកម្មារហស្ស បរិវាសំ ទេតិ បរិវាសារហស្ស ឧក្ខេបនីយកម្មំ ករោតិ បរិវាសារហំ មូលាយ បដិកស្សតិ មូលាយ បដិកស្សនារហស្ស បរិវាសំ ទេតិ មូលាយ បដិកស្សនារហស្ស មានត្តំ ទេតិ មានត្តារហំ មូលាយ បដិកស្សតិ មានត្តារហំ អព្ភេតិ អព្ភានារហស្ស មានត្តំ ទេតិ អព្ភានារហំ ឧបសម្បាទេតិ ឧបសម្បទារហំ អព្ភេតិ



ដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ ឲ្យអមូឡ្ហវិន័យ ដល់ភិក្ខុដែលគួរដល់តស្សបាបិយសិកាកម្ម ធ្វើតជ្ជនីយកម្មដល់ភិក្ខុដែលគួរដល់តស្សបាបិយសិកាកម្ម ធ្វើតស្សបាបិយសិកាកម្មដល់ភិក្ខុដែលគួរដល់តជ្ជនីយកម្ម ធ្វើនិយស្សកម្មដល់ភិក្ខុដែលគួរដល់តជ្ជនីយកម្ម ធ្វើតជ្ជនីយកម្មដល់ភិក្ខុដែលគួរដល់និយស្សកម្ម ធ្វើបព្វាជនីយកម្ម ដល់ភិក្ខុដែលគួរដល់និយស្សកម្ម ធ្វើនិយស្សកម្មដល់ភិក្ខុដែលគួរដល់បព្វាជនីយកម្ម ធ្វើបដិសារណីយកម្ម ដល់ភិក្ខុដែលគួរដល់បព្វាជនីយកម្ម ធ្វើបព្វាជនីយកម្មដល់ភិក្ខុដែលគួរដល់បដិសារណីយកម្ម ធ្វើឧក្ខេបនីយកម្មដល់ភិក្ខុដែលគួរដល់បដិសារណីយកម្ម ធ្វើបដិសារណីយកម្មដល់ភិក្ខុដែលគួរដល់ឧក្ខេបនីយកម្ម ឲ្យបរិវាស ដល់ភិក្ខុដែលគួរដល់ឧក្ខេបនីយកម្ម ធ្វើឧក្ខេបនីយកម្មដល់ភិក្ខុដែលគួរដល់បរិវាស ឲ្យមូលាយបដិកស្សនៈដល់ភិក្ខុដែលគួរដល់បរិវាស ឲ្យបរិវាស ដល់ភិក្ខុដែលគួរដល់មូលាយបដិកស្សនៈ ឲ្យមានត្តដល់ភិក្ខុដែលគួរដល់មូលាយបដិកស្សនៈ ឲ្យមូលាយបដិកស្សនៈដល់ភិក្ខុដែលគួរដល់មានត្ត ឲ្យអព្ភានដល់ភិក្ខុដែលគួរដល់មានត្ត ឲ្យមានត្តដល់ភិក្ខុដែលគួរដល់អព្ភាន ឲ្យឧបសម្បទា ដល់ភិក្ខុដែលគួរដល់អព្ភាន ឲ្យអព្ភានដល់ភិក្ខុដែលគួរ

ឯវំ ខោ ឧបាលិ អធម្មកម្មំ ហោតិ អវិនយកម្មំ ។ ឯវញ្ច បន សង្ឃោ សាតិសារោ ហោតីតិ ។

[១០៨] យោ នុ ខោ ភន្តេ សមគ្គោ សង្ឃោ សតិវិនយារហស្ស សតិវិនយំ ទេតិ អមូឡ្ហវិនយារហស្ស អមូឡ្ហវិនយំ ទេតិ ធម្មកម្មំ នុ ខោ តំ ភន្តេ វិនយ-កម្មន្តិ ។ ធម្មកម្មំ តំ ឧបាលិ វិនយកម្មន្តិ ។ យោ នុ ខោ ភន្តេ សមគ្គោ សង្ឃោ អមូឡ្ហវិនយារហស្ស អមូឡ្ហវិនយំ ទេតិ តស្សបាបិយសិកាកម្មារហស្ស តស្សបាបិយសិកាកម្មំ ករោតិ តជ្ជនីយកម្មារហស្ស តជ្ជនីយកម្មំ ករោតិ និយស្សកម្មារហស្ស និយស្ស-កម្មំ ករោតិ បព្វាជនីយកម្មារហស្ស បព្វាជនីយកម្មំ ករោតិ បដិសារណីយកម្មារហស្ស បដិសារណីយ-កម្មំ ករោតិ ឧក្ខេបនីយកម្មារហស្ស ឧក្ខេបនីយកម្មំ ករោតិ បរិវាសារហស្ស បរិវាសំ ទេតិ មូលាយ បដិ-កស្សនារហំ មូលាយ បដិកស្សតិ មានត្តារហស្ស មានត្តំ ទេតិ អព្ភានារហំ អព្ភេតិ ឧបសម្បទារហំ ឧបសម្បាទេតិ ធម្មកម្មំ នុ ខោ តំ ភន្តេ វិនយកម្មន្តិ ។



ដល់ឧបសម្បទា ម្នាលឧបាលិ កម្មយ៉ាងនេះឯងជាអធម្មកម្ម ជាអវិនយ-កម្ម ។ ឯសង្ឃនោះ ក៏ជាសង្ឃប្រកបដោយទោសដោយប្រការដូច្នេះ ។

[១០៨] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន សង្ឃណាមួយព្រមព្រៀងគ្នាឲ្យសតិវិន័យ ដល់ភិក្ខុដែលគួរដល់សតិវិន័យ ឲ្យអមូឡ្ហវិន័យដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ បពិត្រព្រះអង្គដ៏ចំរើន កម្ម-នោះជាធម្មកម្មជាវិនយកម្មដែរឬ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ កម្មនោះជាធម្មកម្ម ជាវិនយកម្មហើយ ។ ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន សង្ឃណាមួយព្រមព្រៀងគ្នាឲ្យអមូឡ្ហវិន័យ ដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ ធ្វើតស្សបាបិយសិកាកម្មដល់ភិក្ខុដែលគួរដល់តស្សបាបិយសិកាកម្ម ធ្វើតជ្ជនីយកម្មដល់ភិក្ខុដែលគួរដល់តជ្ជនីយកម្ម ធ្វើនិយស្សកម្មដល់ភិក្ខុដែលគួរដល់និយស្សកម្ម ធ្វើបព្វាជនីយកម្មដល់ភិក្ខុដែលគួរដល់បព្វាជនីយកម្ម ធ្វើបដិសារណីយកម្មដល់ភិក្ខុដែលគួរដល់បដិសារណីយកម្ម ធ្វើឧក្ខេបនីយកម្មដល់ភិក្ខុដែលគួរដល់ឧក្ខេបនីយកម្ម ឲ្យបរិវាសដល់ភិក្ខុដែលគួរដល់បរិវាស ឲ្យមូលាយបដិកស្សនៈដល់ភិក្ខុដែលគួរដល់មូលាយបដិកស្សនៈ ឲ្យមានត្តដល់ភិក្ខុដែលគួរដល់មានត្ត ឲ្យអព្ភានដល់ភិក្ខុដែលគួរដល់អព្ភាន ឲ្យឧបសម្បទាដល់បុគ្គលដែលគួរដល់ឧប-សម្បទា បពិត្រព្រះអង្គដ៏ចំរើន កម្មនោះជាធម្មកម្មជាវិនយកម្មដែរឬ ។

ធម្មកម្មំ តំ ឧបាលិ វិនយកម្មំ ។ យោ ចោ ឧបាលិ សមគ្គោ សង្ឃោ សតិវិនយារហស្ស សតិវិនយំ ទេតិ អមូឡ្ហវិនយារហស្ស អមូឡ្ហវិនយំ ទេតិ ឯវំ ខោ ឧបាលិ ធម្មកម្មំ ហោតិ វិនយកម្មំ ។ ឯវញ្ច បន សង្ឃោ អនតិសារោ ហោតិ ។ យោ ចោ ឧបាលិ សមគ្គោ សង្ឃោ អមូឡ្ហវិនយារហស្ស អមូឡ្ហវិនយំ ទេតិ តស្សបាបិយសិកាកម្មារហស្ស តស្សបាបិយសិកាកម្មំ ករោតិ តជ្ជនីយកម្មារហស្ស តជ្ជនីយកម្មំ ករោតិ និយស្សកម្មារហស្ស និយស្សកម្មំ ករោតិ បព្វាជនីយកម្មារហស្ស បព្វាជនីយកម្មំ ករោតិ បដិសារណីយកម្មារហស្ស បដិសារណីយកម្មំ ករោតិ ឧក្ខេបនីយកម្មារហស្ស ឧក្ខេបនីយកម្មំ ករោតិ បរិវាសារហស្ស បរិវាសំ ទេតិ មូលាយ បដិកស្សនារហំ មូលាយ បដិកស្សតិ មានត្តារហស្ស មានត្តំ ទេតិ អព្ភានារហំ អព្ភេតិ ឧបសម្បទារហំ ឧបសម្បាទេតិ ឯវំ ខោ ឧបាលិ ធម្មកម្មំ ហោតិ វិនយកម្មំ ។ ឯវញ្ច បន សង្ឃោ អនតិសារោ ហោតីតិ ។



ព្រះអង្គត្រាស់តបថា ម្នាលឧបាលិ កម្មនោះជាធម្មកម្ម ជាវិនយកម្ម ហើយ ។ ម្នាលឧបាលិ សង្ឃណាមួយព្រមព្រៀងគ្នា ឲ្យសតិវិន័យដល់ភិក្ខុដែលគួរដល់សតិវិន័យ ឲ្យអមូឡ្ហវិន័យដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ ម្នាលឧបាលិ កម្មយ៉ាងនេះឯង ឈ្មោះថាជាធម្មកម្ម ជាវិនយកម្ម ។ ឯសង្ឃសោតក៏ជាសង្ឃមិនប្រកបដោយទោស ដោយប្រការយ៉ាងនេះ ។ ម្នាលឧបាលិ សង្ឃណាមួយព្រមព្រៀងគ្នា ឲ្យអមូឡ្ហវិន័យដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ ធ្វើតស្សបាបិយសិកាកម្មដល់ភិក្ខុដែលគួរដល់តស្សបាបិយសិកាកម្ម ធ្វើតជ្ជនីយកម្មដល់ភិក្ខុដែលគួរដល់តជ្ជនីយកម្ម ធ្វើនិយស្សកម្មដល់ភិក្ខុដែលគួរដល់និយស្សកម្ម ធ្វើបព្វាជនីយកម្មដល់ភិក្ខុដែលគួរដល់បព្វាជនីយកម្ម ធ្វើបដិសារណីយកម្មដល់ភិក្ខុដែលគួរដល់បដិសារណីយកម្ម ធ្វើឧក្ខេបនីយកម្មដល់ភិក្ខុដែលគួរដល់ឧក្ខេបនីយកម្ម ឲ្យបរិវាសដល់ភិក្ខុដែលគួរដល់បរិវាស ឲ្យមូលាយបដិកស្សនៈដល់ភិក្ខុដែលគួរដល់មូលាយបដិកស្សនៈ ឲ្យមានត្តដល់ភិក្ខុដែលគួរដល់មានត្ត ឲ្យអព្ភានដល់ភិក្ខុដែលគួរដល់អព្ភាន ឲ្យឧបសម្បទាដល់កុលបុត្តដែលគួរដល់ឧបសម្បទា ម្នាលឧបាលិ កម្មយ៉ាងនេះឯង ឈ្មោះថាជាធម្មកម្ម ជាវិនយកម្ម ។ ឯសង្ឃសោតក៏ជាសង្ឃមិនប្រកបដោយទោស ដោយប្រការយ៉ាងនេះ ។

[១០៩] អថខោ ភគវា ភិក្ខូ អាមន្តេសិ យោ ខោ ភិក្ខវេ សមគ្គោ សង្ឃោ សតិវិនយារហស្ស អមូឡ្ហវិនយំ ទេតិ ឯវំ ខោ ភិក្ខវេ អធម្មកម្មំ ហោតិ អវិនយកម្មំ ឯវញ្ច បន សង្ឃោ សាតិសារោ ហោតិ ។ យោ ខោ ភិក្ខវេ សមគ្គោ សង្ឃោ សតិវិនយារហស្ស តស្សបាបិយសិកាកម្មំ ករោតិ សតិវិនយារហស្ស តជ្ជនីយកម្មំ ករោតិ សតិវិនយារហស្ស និយស្សកម្មំ ករោតិ សតិវិនយារហស្ស បព្វាជនីយកម្មំ ករោតិ សតិវិនយារហស្ស បដិសារណីយកម្មំ ករោតិ សតិវិនយារហស្ស ឧក្ខេបនីយកម្មំ ករោតិ សតិវិនយារហស្ស បរិវាសំ ទេតិ សតិវិនយារហំ មូលាយ បដិកស្សតិ សតិវិនយារហស្ស មានត្តំ ទេតិ សតិវិនយារហំ អព្ភេតិ សតិវិនយារហំ ឧបសម្បាទេតិ ឯវំ ខោ ភិក្ខវេ អធម្មកម្មំ ហោតិ អវិនយកម្មំ ឯវញ្ច បន សង្ឃោ សាតិសារោ ហោតិ ។ យោ ខោ ភិក្ខវេ សមគ្គោ សង្ឃោ អមូឡ្ហវិនយារហស្ស តស្សបាបិយសិកាកម្មំ ករោតិ



[១០៩] គ្រានោះឯង ព្រះដ៏មានព្រះភាគទ្រង់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ សង្ឃណាមួយព្រមព្រៀងគ្នាឲ្យអមូឡ្ហវិន័យដល់ភិក្ខុដែលគួរដល់សតិវិន័យ ម្នាលភិក្ខុទាំងឡាយ កម្មយ៉ាងនេះឯង ជាអធម្មកម្ម ជាអវិនយកម្ម ឯសង្ឃរមែងគឺជាសង្ឃប្រកបដោយទោស ដោយប្រការយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ សង្ឃណាមួយព្រមព្រៀងគ្នាធ្វើតស្សបាបិយសិកាកម្មដល់ភិក្ខុដែលគួរដល់សតិវិន័យ ធ្វើតជ្ជនីយកម្មដល់ភិក្ខុដែលគួរដល់សតិវិន័យ ធ្វើនិយស្សកម្មដល់ភិក្ខុដែលគួរដល់សតិវិន័យ ធ្វើបព្វាជនីយកម្មដល់ភិក្ខុដែលគួរដល់សតិវិន័យ ធ្វើបដិសារណីយកម្មដល់ភិក្ខុដែលគួរដល់សតិវិន័យ ធ្វើឧក្ខេបនីយកម្មដល់ភិក្ខុដែលគួរដល់សតិវិន័យ ឲ្យបរិវាសដល់ភិក្ខុដែលគួរដល់សតិវិន័យ ឲ្យមូលាយបដិកស្សនៈដល់ភិក្ខុដែលគួរដល់សតិវិន័យ ឲ្យមានត្តដល់ភិក្ខុដែលគួរដល់សតិវិន័យ ឲ្យអព្ភានដល់ភិក្ខុដែលគួរដល់សតិវិន័យ ឲ្យឧបសម្បទាដល់ភិក្ខុដែលគួរដល់សតិវិន័យ ម្នាលភិក្ខុទាំងឡាយ កម្មយ៉ាងនេះឯង ជាអធម្មកម្ម ជាអវិនយកម្ម ឯសង្ឃរមែងគឺប្រកបដោយទោស ដោយប្រការយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ សង្ឃឯណាមួយព្រមព្រៀងគ្នាធ្វើតស្សបាបិយសិកាកម្មដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ

ឥទំ ខោ ភិក្ខវេ អធម្មកម្មំ ហោតិ អវិនយកម្មំ តញ្ច សង្ឃោ សាតិសារោ ហោតិ ។ បុន ចបរំ ភិក្ខវេ សមគ្គោ សង្ឃោ អមូឡ្ហវិនយារហស្ស តជ្ជនីយកម្មំ ករោតិ អមូឡ្ហវិនយារហស្ស និយស្សកម្មំ ករោតិ អមូឡ្ហវិនយារហស្ស បព្វាជនីយកម្មំ ករោតិ អមូឡ្ហវិនយារហស្ស បដិសារណីយកម្មំ ករោតិ អមូឡ្ហវិនយារហស្ស ឧក្ខេបនីយកម្មំ ករោតិ អមូឡ្ហវិនយារហស្ស បរិវាសំ ទេតិ អមូឡ្ហវិនយារហំ មូលាយ បដិកស្សតិ អមូឡ្ហវិនយារហស្ស មានត្តំ ទេតិ អមូឡ្ហវិនយារហំ អព្ភេតិ អមូឡ្ហវិនយារហំ ឧបសម្បាទេតិ អមូឡ្ហវិនយារហស្ស សតិវិនយំ ទេតិ ឥទំ ខោ ភិក្ខវេ អធម្មកម្មំ ហោតិ អវិនយកម្មំ តញ្ច សង្ឃោ សាតិសារោ ហោតិ ។ បុន ចបរំ ភិក្ខវេ សមគ្គោ សង្ឃោ តស្សបាបិយសិការហស្ស តជ្ជនីយកម្មំ ករោតិ តស្សបាបិយសិការហស្ស និយស្សកម្មំ ករោតិ តស្សបាបិយសិការហស្ស បព្វាជនីយកម្មំ ករោតិ តស្សបាបិយសិការហស្ស បដិសារណីយកម្មំ ករោតិ



ម្នាលភិក្ខុទាំងឡាយ កម្មយ៉ាងនេះឯង ជាអធម្មកម្ម អវិនយកម្ម ឯសង្ឃ ក៏ប្រកបដោយទោស ដោយប្រការយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ សង្ឃណាមួយព្រមព្រៀងគ្នា ធ្វើតជ្ជនីយកម្មដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ ធ្វើនិយស្សកម្មដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ ធ្វើបព្វាជនីយកម្មដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ ធ្វើបដិសារណីយកម្មដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ ធ្វើឧក្ខេបនីយកម្មដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ ឲ្យបរិវាសដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ ឲ្យមូលាយបដិកស្សនៈដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ ឲ្យមានត្តដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ ឲ្យអព្ភានដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ ឲ្យឧបសម្បទាដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ ឲ្យសតិវិន័យដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ ម្នាលភិក្ខុទាំងឡាយ កម្មយ៉ាងនេះឯង ជាអធម្មកម្ម អវិនយកម្ម ឯសង្ឃ ក៏ប្រកបដោយទោស ដោយប្រការយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ សង្ឃណាមួយព្រមព្រៀងគ្នា ធ្វើតជ្ជនីយកម្មដល់ភិក្ខុដែលគួរដល់តស្សបាបិយសិកាកម្ម ធ្វើនិយស្សកម្មដល់ភិក្ខុដែលគួរដល់តស្សបាបិយសិកាកម្ម ធ្វើបព្វាជនីយកម្មដល់ភិក្ខុដែលគួរដល់តស្សបាបិយសិកាកម្ម ធ្វើបដិសារណីយកម្មដល់ភិក្ខុដែលគួរដល់តស្សបាបិយសិកាកម្ម

តស្សបាបិយសិកាកម្មារហស្ស ឧក្ខេបនីយកម្មំ ករោតិ តស្សបាបិយសិកាកម្មារហស្ស បរិវាសំ ទេតិ ។បេ។ តស្សបាបិយសិកាកម្មារហស្ស សតិវិនយំ ទេតិ តស្សបាបិយសិកាកម្មារហស្ស អមូឡ្ហវិនយំ ទេតិ ។ ឯវំ ខោ ភិក្ខវេ អធម្មកម្មំ ហោតិ អវិនយកម្មំ ឯវញ្ច បន សង្ឃោ សាតិសារោ ហោតិ ។ ឥធ បន ភិក្ខវេ សមគ្គោ សង្ឃោ តជ្ជនីយកម្មារហស្ស ។បេ។ និយស្សកម្មារហស្ស បព្វាជនីយកម្មារហស្ស បដិសារណីយកម្មារហស្ស ឧក្ខេបនីយកម្មារហស្ស បរិវាសារហស្ស មូលាយ បដិកស្សនារហស្ស មានត្តារហស្ស អព្ភានារហស្ស ឧបសម្បទារហស្ស សតិវិនយំ ទេតិ ឧបសម្បទារហស្ស អមូឡ្ហវិនយំ ទេតិ ឧបសម្បទារហស្ស តស្សបាបិយសិកាកម្មំ ករោតិ ឧបសម្បទារហស្ស តជ្ជនីយកម្មំ ករោតិ ឧបសម្បទារហស្ស និយស្សកម្មំ ករោតិ ឧបសម្បទារហស្ស បព្វាជនីយកម្មំ ករោតិ ឧបសម្បទារហស្ស បដិសារណីយកម្មំ ករោតិ ឧបសម្បទារហស្ស ឧក្ខេបនីយកម្មំ ករោតិ



ធ្វើឧក្ខេបនីយកម្មដល់ភិក្ខុដែលគួរដល់តស្សបាបិយសិកាកម្ម ឲ្យបរិវាសដល់ភិក្ខុដែលគួរដល់តស្សបាបិយសិកាកម្ម ។បេ។ ឲ្យសតិវិន័យដល់ភិក្ខុដែលគួរដល់តស្សបាបិយសិកាកម្ម ឲ្យអមូឡ្ហវិន័យដល់ភិក្ខុដែលគួរដល់តស្សបាបិយសិកាកម្ម ម្នាលភិក្ខុទាំងឡាយ កម្មយ៉ាងនេះឯង ជាអធម្មកម្ម អវិនយកម្ម ឯសង្ឃរមែងប្រកបដោយទោស ដោយប្រការយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ សង្ឃណាមួយព្រមព្រៀងគ្នា ឲ្យសតិវិន័យដល់ភិក្ខុដែលគួរដល់តជ្ជនីយកម្ម ។បេ។ ដល់ភិក្ខុដែលគួរដល់និយស្សកម្ម ដល់ភិក្ខុដែលគួរដល់បព្វាជនីយកម្ម ដល់ភិក្ខុដែលគួរដល់បដិសារណីយកម្ម ដល់ភិក្ខុដែលគួរដល់ឧក្ខេបនីយកម្ម ដល់ភិក្ខុដែលគួរដល់បរិវាស ដល់ភិក្ខុដែលគួរដល់មូលាយបដិកស្សនៈ ដល់ភិក្ខុដែលគួរដល់មានត្ត ដល់ភិក្ខុដែលគួរដល់អព្ភាន ដល់កុលបុត្រដែលគួរដល់ឧបសម្បទា ឲ្យអមូឡ្ហវិន័យដល់កុលបុត្រដែលគួរដល់ឧបសម្បទា ធ្វើតស្សបាបិយសិកាកម្មដល់កុលបុត្រដែលគួរដល់ឧបសម្បទា ធ្វើតជ្ជនីយកម្មដល់កុលបុត្រដែលគួរដល់ឧបសម្បទា ធ្វើនិយស្សកម្មដល់កុលបុត្រដែលគួរដល់ឧបសម្បទា ធ្វើបព្វាជនីយកម្មដល់កុលបុត្រដែលគួរដល់ឧបសម្បទា ធ្វើបដិសារណីយកម្មដល់កុលបុត្រដែលគួរដល់ឧបសម្បទា ធ្វើឧក្ខេបនីយកម្មដល់កុលបុត្រដែលគួរដល់ឧបសម្បទា

ឧបសម្បទារហស្ស បរិវាសំ ទេតិ ឧបសម្បទារហំ មូលាយ បដិកស្សតិ ឧបសម្បទារហស្ស មានត្តំ ទេតិ ឧបសម្បទារហំ អព្ភេតិ ឯវំ ខោ ភិក្ខវេ អធម្មកម្មំ ហោតិ អវិនយកម្មំ ឯវញ្ច បន សង្ឃោ សាតិសារោ ហោតីតិ ។

ឧបាលិបុច្ឆាភាណវារំ ទុតិយំ ។

(១១០) ឥធ បន ភិក្ខវេ ភិក្ខុ ភណ្ឌនការកោ ហោតិ កលហការកោ វិវាទការកោ ភស្សការកោ សង្ឃេ អធិករណការកោ ។ តត្រ ចេ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ ភណ្ឌនការកោ កលហការកោ វិវាទការកោ ភស្សការកោ សង្ឃេ អធិករណការកោ ហន្ទស្ស មយំ តជ្ជនីយកម្មំ ករោមាតិ ។ តេ តស្ស តជ្ជនីយកម្មំ ករោន្តិ អធម្មេន វគ្គា ។ សោ តម្ហា អាវាសា អញ្ញំ អាវាសំ គច្ឆតិ ។ តត្ថបិ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សង្ឃេន



ឲ្យបរិវាសដល់កុលបុត្តដែលគួរដល់ឧបសម្បទា ឲ្យមូលាយបដិកស្សនៈ ដល់កុលបុត្តដែលគួរដល់ឧបសម្បទា ឲ្យមានត្តដល់កុលបុត្តដែលគួរដល់ឧបសម្បទា ឲ្យអព្ភានដល់កុលបុត្តដែលគួរដល់ឧបសម្បទា ម្នាលភិក្ខុទាំងឡាយ កម្មយ៉ាងនេះឯង ជាអធម្មកម្ម អវិនយកម្ម ឯសង្ឃនោះ ក៏ប្រកបដោយទោស ដោយប្រការយ៉ាងនេះ ។

ចប់ ឧបាលិបុច្ឆាភាណវារៈ ទី ២ ។

(១១០) ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ មានភិក្ខុជាអ្នកធ្វើនូវការបង្កហេតុ ជាអ្នកធ្វើនូវជំលោះ ជាអ្នកធ្វើនូវវិវាទ (ពាក្យទទឹងគ្នា) ជាអ្នកធ្វើនូវតិរច្ឆានកថា ជាអ្នកធ្វើនូវអធិករណ៍ក្នុងសង្ឃ ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ជាអ្នកធ្វើនូវការបង្កហេតុ ជាអ្នកធ្វើនូវជំលោះ ជាអ្នកធ្វើនូវវិវាទ ជាអ្នកធ្វើនូវតិរច្ឆានកថា ជាអ្នកធ្វើនូវអធិករណ៍ក្នុងសង្ឃ បើដូច្នោះមានតែយើងរាល់គ្នាធ្វើតជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងឡាយនោះជាពួកមិនប្រកបដោយធម៌ ធ្វើតជ្ជនីយកម្មដល់ភិក្ខុនោះ ។ ឯភិក្ខុនោះក៏ចេញពីអាវាសនោះទៅកាន់អាវាសដទៃទៀត ។ ឯភិក្ខុទាំងឡាយក្នុងអាវាសនោះ ក៏គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯងដែលសង្ឃ

តជ្ជនីយកម្មកតោ អធម្មេន វគ្គេហិ ហន្ទស្ស មយំ តជ្ជនីយកម្មំ ករោមាតិ ។ តេ តស្ស តជ្ជនីយកម្មំ ករោន្តិ អធម្មេន សមគ្គា ។ សោ តម្ហា អាវាសា អញ្ញំ អាវាសំ គច្ឆតិ ។ តត្ថបិ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សង្ឃេន តជ្ជនីយ-កម្មកតោ អធម្មេន សមគ្គេហិ ហន្ទស្ស មយំ តជ្ជនីយកម្មំ ករោមាតិ ។ តេ តស្ស តជ្ជនីយកម្មំ ករោន្តិ ធម្មេន វគ្គា ។ សោ តម្ហា អាវាសា អញ្ញំ អាវាសំ គច្ឆតិ ។ តត្ថបិ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សង្ឃេន តជ្ជនីយកម្មកតោ ធម្មេ-ន វគ្គេហិ ហន្ទស្ស មយំ តជ្ជនីយកម្មំ ករោមាតិ ។ តេ តស្ស តជ្ជនីយកម្មំ ករោន្តិ ធម្មប្បតិរូបកេន វគ្គា ។ សោ តម្ហា អាវាសា អញ្ញំ អាវាសំ គច្ឆតិ ។ តត្ថបិ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សង្ឃេន តជ្ជនីយកម្មកតោ ធម្មប្បតិរូបកេន វគ្គេហិ



បានធ្វើតជ្ជនីយកម្មហើយដោយភិក្ខុទាំងឡាយដែលជាពួកមិនប្រកបដោយធម៌ បើដូច្នោះមានតែយើងទាំងឡាយធ្វើតជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងឡាយនោះព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ ក៏ធ្វើតជ្ជនីយកម្មដល់ភិក្ខុនោះ (ទៀត) ។ ភិក្ខុនោះចេញពីអាវាសនោះទៅកាន់អាវាសដទៃ ។ ឯភិក្ខុទាំងឡាយក្នុងអាវាសនោះក៏គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯងដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយដោយភិក្ខុទាំងឡាយដែលព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ បើដូច្នោះមានតែយើងរាល់គ្នាធ្វើតជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងឡាយនោះជាពួក តែប្រកបដោយធម៌ ធ្វើតជ្ជនីយកម្មដល់ភិក្ខុនោះ ។ ភិក្ខុនោះក៏ចេញពីអាវាសនោះទៅកាន់អាវាសដទៃ (ទៀត) ។ ឯភិក្ខុទាំងឡាយក្នុងអាវាសនោះគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯងដែលសង្ឃបានធ្វើតជ្ជ-នីយកម្មហើយដោយភិក្ខុទាំងឡាយជាពួក តែប្រកបដោយធម៌ បើដូច្នោះមានតែយើងទាំងឡាយធ្វើតជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងឡាយនោះជាពួកតែប្រកបដោយធម្មប្បដិរូប ធ្វើតជ្ជនីយកម្មដល់ភិក្ខុនោះ ។ ភិក្ខុនោះក៏ចេញពីអាវាសនោះទៅកាន់អាវាសដទៃទៀត ។ ឯភិក្ខុទាំងឡាយក្នុងអាវាសនោះគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯងដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយដោយភិក្ខុទាំងឡាយជាពួកតែប្រកបដោយធម៌

ហន្ទស្ស មយំ តជ្ជនីយកម្មំ ករោមាតិ ។ តេ តស្ស តជ្ជនីយកម្មំ ករោន្តិ ធម្មប្បតិរូបកេន សម្មុខា ។

[១១១] ឥធ បន ភិក្ខវេ ភិក្ខុ ភណ្ឌនការកោ ហោតិ កលហការកោ វិវាទការកោ ភស្សការកោ សង្ឃេ អធិករណការកោ ។ តត្រ ចេ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ ភណ្ឌនការកោ កលហការកោ វិវាទការកោ ភស្សការកោ សង្ឃេ អធិករណការកោ ហន្ទស្ស មយំ តជ្ជនីយកម្មំ ករោមាតិ ។ តេ តស្ស តជ្ជនីយកម្មំ ករោន្តិ អធម្មេន សមគ្គា ។ សោ តម្ហា អាវាសា អញ្ញំ អាវាសំ គច្ឆតិ ។ តត្ថបិ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សង្ឃេន តជ្ជនីយកម្មកតោ អធម្មេន សមគ្គេហិ ហន្ទស្ស មយំ តជ្ជនីយកម្មំ ករោមាតិ ។ តេ តស្ស តជ្ជនីយកម្មំ ករោន្តិ ធម្មេន វគ្គា ។ សោ តម្ហា អាវាសា



ចុម បើដូច្នោះមានតែយើងរាល់គ្នាធ្វើតជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងឡាយនោះព្រមព្រៀងគ្នា តែប្រកបដោយធម្មប្បតិរូប ក៏ធ្វើតជ្ជនីយកម្មដល់ភិក្ខុនោះ (ទៀត) ។

(១១១) ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុក្នុងសាសនានេះ ជាអ្នកធ្វើនូវការបង្កហេតុ ជាអ្នកធ្វើនូវជំលោះ ជាអ្នកធ្វើនូវវិវាទ ជាអ្នកធ្វើនូវតិរច្ឆានកថា ជាអ្នកធ្វើនូវអធិករណ៍ក្នុងសង្ឃ ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ជាអ្នកធ្វើនូវការបង្កហេតុ ជាអ្នកធ្វើនូវជំលោះ ជាអ្នកធ្វើនូវវិវាទ ជាអ្នកធ្វើនូវតិរច្ឆានកថា ជាអ្នកធ្វើនូវអធិករណ៍ក្នុងសង្ឃ បើដូច្នោះមានតែយើងទាំងឡាយធ្វើតជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ ធ្វើតជ្ជនីយកម្មដល់ភិក្ខុនោះ ។ ភិក្ខុនោះក៏ចេញពីអាវាសនោះទៅកាន់អាវាសដទៃ (ទៀត) ។ ឯភិក្ខុទាំងឡាយក្នុងអាវាសនោះ ក៏គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯងដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយ ដោយភិក្ខុទាំងឡាយដែលព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ បើដូច្នោះមានតែយើងទាំងឡាយធ្វើតជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងឡាយនោះជាពួក តែប្រកបដោយធម៌ ធ្វើតជ្ជនីយកម្មដល់ភិក្ខុនោះ ។ ភិក្ខុនោះក៏ចេញពីអាវាសនោះទៅកាន់អាវាស

អញ្ញំបិ អាវាសំ គច្ឆតិ ។ តត្ថបិ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សង្ឃេន តជ្ជនីយកម្មកតោ ធម្មេន វគ្គេហិ ហន្ទស្ស មយំ តជ្ជនីយកម្មំ ករោមាតិ ។ តេ តស្ស តជ្ជនីយកម្មំ ករោន្តិ ធម្មប្បដិរូបកេន វគ្គា ។ សោ តម្ហា អាវាសា អញ្ញំបិ អាវាសំ គច្ឆតិ ។ តត្ថបិ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សង្ឃេន តជ្ជនីយកម្មកតោ ធម្មប្បដិរូបកេន វគ្គេហិ ហន្ទស្ស មយំ តជ្ជនីយកម្មំ ករោមាតិ ។ តេ តស្ស តជ្ជនីយកម្មំ ករោន្តិ ធម្មប្បដិរូបកេន សមគ្គា ។ សោ តម្ហា អាវាសា អញ្ញំបិ អាវាសំ គច្ឆតិ ។ តត្ថបិ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សង្ឃេន តជ្ជនីយកម្មកតោ ធម្មប្បដិរូបកេន សមគ្គេហិ ហន្ទស្ស មយំ តជ្ជនីយកម្មំ ករោមាតិ ។ តេ តស្ស តជ្ជនីយកម្មំ ករោន្តិ អធម្មេន វគ្គា ។



ដទៃ (ទៀត) ។ ឯភិក្ខុទាំងឡាយក្នុងអាវាសនោះក៏គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯងដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយ ដោយភិក្ខុទាំងឡាយដែលជាពួក តែប្រកបដោយធម៌ បើដូច្នោះមានតែយើងទាំងឡាយធ្វើតជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះជាពួកទាំងប្រកបដោយធម្មប្បតិរូប ធ្វើតជ្ជនីយកម្មដល់ភិក្ខុនោះ (ទៀត) ។ ភិក្ខុនោះក៏ចេញពីអាវាសនោះទៅកាន់អាវាសដទៃ (ទៀត) ។ ឯភិក្ខុទាំងឡាយក្នុងអាវាសនោះគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯងដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយ ដោយភិក្ខុទាំងឡាយដែលជាពួក ទាំងប្រកបដោយធម្មប្បតិរូប បើដូច្នោះមានតែយើងទាំងឡាយធ្វើតជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះព្រមព្រៀងគ្នា តែប្រកបដោយធម្មប្បតិរូប ធ្វើតជ្ជនីយកម្មដល់ភិក្ខុនោះ (ទៀត) ។ ភិក្ខុនោះក៏ចេញពីអាវាសនោះទៅកាន់អាវាសដទៃ (ទៀត) ។ ឯភិក្ខុទាំងឡាយក្នុងអាវាសនោះគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯងដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយ ដោយភិក្ខុទាំងឡាយដែលព្រមព្រៀងគ្នា តែប្រកបដោយធម្មប្បតិរូប បើដូច្នោះមានតែយើងទាំងឡាយធ្វើតជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះជាពួកទាំងមិនប្រកបដោយធម៌ ធ្វើតជ្ជនីយកម្មដល់ភិក្ខុនោះ (ទៀត) ។

[១១៦] ឥធ បន ភិក្ខវេ ភិក្ខុ ភណ្ឌនការកោ ហោតិ កលហការកោ វិវាទការកោ ភស្សការកោ សង្ឃេ អធិករណការកោ ។ តត្រ ចេ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ ភណ្ឌនការកោ កលហការកោ វិវាទការកោ ភស្សការកោ សង្ឃេ អធិករណការកោ ហន្ទស្ស មយំ តជ្ជនីយកម្មំ ករោមាតិ ។ តេ តស្ស តជ្ជនីយកម្មំ ករោន្តិ អធម្មេន វគ្គា ។ សោ តម្ហា អាវាសា អញ្ញំ អាវាសំ គច្ឆតិ ។ តត្ថបិ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សង្ឃេន តជ្ជនីយកម្មកតោ អធម្មេន វគ្គេហិ ហន្ទស្ស មយំ តជ្ជនីយកម្មំ ករោមាតិ ។ តេ តស្ស តជ្ជនីយកម្មំ ករោន្តិ ធម្មប្បដិរូបកេន វគ្គា ។ សោ តម្ហា អាវាសា អញ្ញំ អាវាសំ គច្ឆតិ ។ តត្ថបិ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សង្ឃេន តជ្ជនីយកម្មកតោ ធម្មប្បដិរូបកេន វគ្គេហិ ហន្ទស្ស មយំ តជ្ជនីយកម្មំ



[១១៦] ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ភិក្ខុក្នុងសាសនានេះ ជាអ្នកធ្វើនូវការបង្កហេតុ ជាអ្នកធ្វើនូវជំលោះ ជាអ្នកធ្វើនូវវិវាទ ជាអ្នកធ្វើនូវតិរច្ឆានកថា ជាអ្នកធ្វើនូវអធិករណ៍ក្នុងសង្ឃ ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ជាអ្នកធ្វើនូវការបង្កហេតុ ជាអ្នកធ្វើនូវជំលោះ ជាអ្នកធ្វើនូវវិវាទ ជាអ្នកធ្វើនូវតិរច្ឆានកថា ជាអ្នកធ្វើនូវអធិករណ៍ក្នុងសង្ឃ បើដូច្នោះមានតែយើងទាំងឡាយធ្វើតជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះជាពួក តែប្រកបដោយអធម៌ ធ្វើតជ្ជនីយកម្មដល់ភិក្ខុនោះ ។ ភិក្ខុនោះក៏ចេញពីអាវាសនោះ ទៅកាន់អាវាសដទៃ (ទៀត) ។ ឯភិក្ខុទាំងឡាយក្នុងអាវាសនោះគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯងដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយ ដោយភិក្ខុទាំងឡាយដែលជាពួក តែប្រកបដោយអធម៌ បើដូច្នោះមានតែយើងទាំងឡាយធ្វើតជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះជាពួកទាំងប្រកបដោយធម្មប្បដិរូប ធ្វើតជ្ជនីយកម្មដល់ភិក្ខុនោះ (ទៀត) ។ ភិក្ខុនោះក៏ចេញពីអាវាសនោះទៅកាន់អាវាសដទៃ ។ ឯភិក្ខុទាំងឡាយក្នុងអាវាសនោះគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯងដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយ ដោយភិក្ខុទាំងឡាយដែលជាពួកទាំងប្រកបដោយធម្មប្បដិរូប បើដូច្នោះមានតែយើងទាំងឡាយ

ករោមាតិ ។ តេ តស្ស តជ្ជនីយកម្មំ ករោន្តិ ធម្មប្បដិរូបកេន សមគ្គា ។ សោ តម្ហា អាវាសា អញ្ញំ អាវាសំ គច្ឆតិ ។ តត្ថបិ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សង្ឃេន តជ្ជនីយកម្មកតោ ធម្មប្បដិរូបកេន សមគ្គេហិ ហន្ទស្ស មយំ តជ្ជនីយកម្មំ ករោមាតិ ។ តេ តស្ស តជ្ជនីយកម្មំ ករោន្តិ អធម្មេន វគ្គា ។ សោ តម្ហា អាវាសា អញ្ញំ អាវាសំ គច្ឆតិ ។ តត្ថបិ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សង្ឃេន តជ្ជនីយកម្មកតោ អធម្មេន វគ្គេហិ ហន្ទស្ស មយំ តជ្ជនីយកម្មំ ករោមាតិ ។ តេ តស្ស តជ្ជនីយកម្មំ ករោន្តិ អធម្មេន សមគ្គា ។

[១១៣] ឥធ បន ភិក្ខវេ ភិក្ខុ ភណ្ឌនការកោ ហោតិ កលហការកោ វិវាទការកោ ភស្សការកោ សង្ឃេ អធិករណការកោ ។ តត្រ ចេ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ ភណ្ឌនការកោ



ធ្វើតជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះព្រមព្រៀងគ្នា តែប្រកបដោយធម្មប្បតិរូប ធ្វើតជ្ជនីយកម្មដល់ភិក្ខុនោះ (ទៀត) ។ ភិក្ខុនោះក៏ចេញពីអាវាសនោះទៅកាន់អាវាសដទៃ ។ ឯភិក្ខុទាំងឡាយក្នុងអាវាសនោះគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយ ដោយភិក្ខុទាំងឡាយដែលព្រមព្រៀងគ្នា តែប្រកបដោយធម្មប្បតិរូប បើដូច្នោះមានតែយើងទាំងឡាយធ្វើតជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះជាពួកទាំងមិនប្រកបដោយធម៌ ធ្វើតជ្ជនីយកម្មដល់ភិក្ខុនោះ (ទៀត) ។ ភិក្ខុនោះក៏ចេញពីអាវាសនោះទៅកាន់អាវាសដទៃ ។ ឯភិក្ខុទាំងឡាយក្នុងអាវាសនោះគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយ ដោយភិក្ខុទាំងឡាយជាពួកទាំងមិនប្រកបដោយធម៌ បើដូច្នោះមានតែយើងទាំងឡាយធ្វើតជ្ជនីយកម្មដល់ភិក្ខុនេះ (ទៀត) ។ ភិក្ខុទាំងនោះព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ ធ្វើតជ្ជនីយកម្មដល់ភិក្ខុនោះ (ទៀត) ។

(១១៣) ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុក្នុងសាសនានេះ ជាអ្នកធ្វើនូវការបង្កហេតុ ជាអ្នកធ្វើនូវជំលោះ ជាអ្នកធ្វើនូវវិវាទ ជាអ្នកធ្វើនូវតិរច្ឆានកថា ជាអ្នកធ្វើនូវអធិករណ៍ក្នុងសង្ឃ ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯងជាអ្នក

កលហការកោ វិវាទការកោ ភស្សការកោ សង្ឃេ អធិករណការកោ ហន្ទស្ស មយំ តជ្ជនីយកម្មំ ករោមាតិ ។ តេ តស្ស តជ្ជនីយកម្មំ ករោន្តិ ធម្មប្បដិរូបកេន វគ្គា ។ សោ តម្ហា អាវាសា អញ្ញំ អាវាសំ គច្ឆតិ ។ តត្ថបិ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សង្ឃេន តជ្ជនីយកម្មកតោ ធម្មប្បដិរូបកេន វគ្គេហិ ហន្ទស្ស មយំ តជ្ជនីយកម្មំ ករោមាតិ ។ តេ តស្ស តជ្ជនីយកម្មំ ករោន្តិ ធម្មប្បដិរូបកេន សមគ្គា ។ សោ តម្ហា អាវាសា អញ្ញំ អាវាសំ គច្ឆតិ ។ តត្ថបិ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សង្ឃេន តជ្ជនីយកម្មកតោ ធម្មប្បដិរូបកេន សមគ្គេហិ ហន្ទស្ស មយំ តជ្ជនីយកម្មំ ករោមាតិ ។ តេ តស្ស តជ្ជនីយកម្មំ ករោន្តិ អធម្មេន វគ្គា ។ សោ តម្ហា អាវាសា អញ្ញំ អាវាសំ គច្ឆតិ ។ តត្ថបិ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ



ធ្វើនូវការបង្ករឿង ជាអ្នកធ្វើនូវជំលោះ ជាអ្នកធ្វើនូវវិវាទ ជាអ្នកធ្វើនូវតែពាក្យឥតការ ជាអ្នកធ្វើនូវអធិករណ៍ក្នុងសង្ឃ បើដូច្នោះមានតែយើងទាំងឡាយធ្វើតជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងឡាយនោះជាពួកទាំងប្រកបដោយធម៌ប្លម ធ្វើតជ្ជនីយកម្មដល់ភិក្ខុនោះ ។ ភិក្ខុនោះក៏ចេញអំពីអាវាសនោះទៅកាន់អាវាសដទៃ ។ ឯភិក្ខុទាំងឡាយក្នុងអាវាសនោះគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯងដែលសង្ឃបានធ្វើតជ្ជនីយកម្ម ដោយភិក្ខុទាំងឡាយជាពួកទាំងប្រកបដោយធម៌ប្លម បើដូច្នោះមានតែយើងទាំងឡាយធ្វើតជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម ធ្វើតជ្ជនីយកម្មដល់ភិក្ខុនោះ (ទៀត) ។ ភិក្ខុនោះក៏ចេញអំពីអាវាសនោះទៅកាន់អាវាសដទៃ (ទៀត) ។ ឯភិក្ខុទាំងឡាយក្នុងអាវាសនោះគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯងដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយ ដោយភិក្ខុទាំងឡាយព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម បើដូច្នោះមានតែយើងទាំងឡាយ ធ្វើតជ្ជនីយកម្មដល់ភិក្ខុនេះ (ទៀត) ។ ភិក្ខុទាំងនោះជាពួកទាំងមិនប្រកបដោយធម៌ ធ្វើតជ្ជនីយកម្មដល់ភិក្ខុនោះ (ទៀត) ។ ភិក្ខុនោះក៏ចេញអំពីអាវាសនោះទៅកាន់អាវាសដទៃ (ទៀត) ។ ឯភិក្ខុទាំងឡាយក្នុងអាវាសនោះគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឃបានធ្វើ

សង្ឃេន តជ្ជនីយកម្មកតោ អធម្មេន វគ្គេហិ ហន្ទស្ស មយំ តជ្ជនីយកម្មំ ករោមាតិ ។ តេ តស្ស តជ្ជនីយកម្មំ ករោន្តិ អធម្មេន សមគ្គា ។ សោ តម្ហា អាវាសា អញ្ញំ អាវាសំ គច្ឆតិ ។ តត្ថបិ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សង្ឃេន តជ្ជនីយកម្មកតោ អធម្មេន សមគ្គេហិ ហន្ទស្ស មយំ តជ្ជនីយកម្មំ ករោមាតិ ។ តេ តស្ស តជ្ជនីយកម្មំ ករោន្តិ ធម្មេន វគ្គា ។

(១១៤) ឥធ បន ភិក្ខវេ ភិក្ខុ ភណ្ឌនការកោ ហោតិ កលហការកោ វិវាទការកោ ភស្សការកោ សង្ឃេ អធិករណការកោ ។ តត្រ ចេ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ ភណ្ឌនការកោ កលហការកោ វិវាទការកោ ភស្សការកោ សង្ឃេ អធិករណការកោ ហន្ទស្ស មយំ តជ្ជនីយកម្មំ ករោមាតិ ។ តេ តស្ស តជ្ជនីយកម្មំ ករោន្តិ ធម្មប្បដិរូបកេន សមគ្គា ។ សោ តម្ហា អាវាសា



តជ្ជនីយកម្មហើយ ដោយភិក្ខុទាំងឡាយជាពួកទាំងមិនប្រកបដោយធម៌ បើដូច្នោះមានតែយើងទាំងឡាយធ្វើតជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ ធ្វើតជ្ជនីយកម្មដល់ភិក្ខុនោះ (ទៀត) ។ ភិក្ខុនោះក៏ចេញពីអាវាសនោះទៅកាន់អាវាសដទៃ (ទៀត) ។ ឯភិក្ខុទាំងឡាយក្នុងអាវាសនោះគិតយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯងដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយ ដោយភិក្ខុទាំងឡាយដែលព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ បើដូច្នោះមានតែយើងទាំងឡាយធ្វើតជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះជាពួក តែប្រកបដោយធម៌ ធ្វើតជ្ជនីយកម្មដល់ភិក្ខុនោះ (ទៀត) ។

(១១៤) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះជាអ្នកធ្វើនូវការបង្កហេតុ ជាអ្នកធ្វើនូវជំលោះ ជាអ្នកធ្វើនូវការទាស់ទែង ជាអ្នកធ្វើនូវតិរច្ឆានកថា ជាអ្នកធ្វើនូវអធិករណ៍ក្នុងសង្ឃ ។ ក្នុងវត្តនោះ បើភិក្ខុទាំងឡាយគិតយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ជាអ្នកធ្វើនូវការបង្កហេតុ ជាអ្នកធ្វើនូវជំលោះ ជាអ្នកធ្វើនូវការទាស់ទែង ជាអ្នកធ្វើនូវតិរច្ឆានកថា ជាអ្នកធ្វើនូវអធិករណ៍ក្នុងសង្ឃ បើដូច្នោះមានតែយើងទាំងឡាយធ្វើតជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លោម ធ្វើតជ្ជនីយកម្មដល់ភិក្ខុនោះ ។ ភិក្ខុនោះក៏ចេញពីអាវាសនោះទៅ

អញ្ញំ អាវាសំ គច្ឆតិ ។ តត្ថ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សង្ឃេន តជ្ជនីយកម្មកតោ ធម្មប្បដិរូបកេន សមគ្គេហិ ហន្ទស្ស មយំ តជ្ជនីយកម្មំ ករោមាតិ ។ តេ តស្ស តជ្ជនីយកម្មំ ករោន្តិ អធម្មេន វគ្គា ។ សោ តម្ហា អាវាសា អញ្ញំ អាវាសំ គច្ឆតិ ។ តត្ថបិ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សង្ឃេន តជ្ជនីយកម្មកតោ អធម្មេន វគ្គេហិ ហន្ទស្ស មយំ តជ្ជនីយកម្មំ ករោមាតិ ។ តេ តស្ស តជ្ជនីយកម្មំ ករោន្តិ អធម្មេន សមគ្គា ។ សោ តម្ហា អាវាសា អញ្ញំ អាវាសំ គច្ឆតិ ។ តត្ថបិ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សង្ឃេន តជ្ជនីយកម្មកតោ អធម្មេន សមគ្គេហិ ហន្ទស្ស មយំ តជ្ជនីយកម្មំ ករោមាតិ ។ តេ តស្ស តជ្ជនីយកម្មំ ករោន្តិ ធម្មេន វគ្គា ។ សោ តម្ហា អាវាសា អញ្ញំ អាវាសំ គច្ឆតិ ។



កាន់អាវាសដទៃទៀត ។ ឯភិក្ខុទាំងឡាយក្នុងអាវាសនោះគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯងដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយ ដោយភិក្ខុទាំងឡាយដែលព្រមព្រៀងគ្នា តែប្រកបដោយធម្មប្បដិរូប បើដូច្នោះមានតែយើងទាំងឡាយធ្វើតជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះជាពួកទាំងមិនប្រកបដោយធម៌ ធ្វើតជ្ជនីយកម្មដល់ភិក្ខុនោះ (ទៀត) ។ ភិក្ខុនោះក៏ចេញពីអាវាសនោះទៅកាន់អាវាសដទៃ ។ ឯភិក្ខុទាំងឡាយក្នុងអាវាសនោះគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយ ដោយភិក្ខុទាំងឡាយជាពួកទាំងមិនប្រកបដោយធម៌ បើដូច្នោះមានតែយើងទាំងឡាយធ្វើតជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ ធ្វើតជ្ជនីយកម្មដល់ភិក្ខុនោះ (ទៀត) ។ ភិក្ខុនោះក៏ចេញពីអាវាសនោះទៅកាន់អាវាសដទៃ ។ ឯភិក្ខុទាំងឡាយក្នុងអាវាសនោះគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯងដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយ ដោយភិក្ខុទាំងឡាយដែលព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ បើដូច្នោះមានតែយើងទាំងឡាយធ្វើតជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះជាពួក តែប្រកបដោយធម៌ ធ្វើតជ្ជនីយកម្មដល់ភិក្ខុនោះ ។ ភិក្ខុនោះក៏ចេញពីអាវាសនោះទៅកាន់អាវាសដទៃ ។

តត្ថបិ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សង្ឃេន តជ្ជនីយកម្មកតោ ធម្មេន វគ្គេហិ ហន្ទស្ស មយំ តជ្ជនីយកម្មំ ករោមាតិ ។ តេ តស្ស តជ្ជនីយកម្មំ ករោន្តិ ធម្មប្បដិរូបកេន វគ្គា ។

[១១៩] ឥធ បន ភិក្ខវេ ភិក្ខុ ពាលោ ហោតិ អព្យត្តោ អាបត្តិពហុលោ អនបទានោ គិហិសំសដ្ឋោ វិហរតិ អននុលោមិកេហិ គិហិសំសគ្គេហិ ។ តត្រ ចេ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ ពាលោ អព្យត្តោ អាបត្តិពហុលោ អនបទានោ គិហិសំសដ្ឋោ វិហរតិ អននុលោមិកេហិ គិហិសំសគ្គេហិ ហន្ទស្ស មយំ និយស្សកម្មំ ករោមាតិ ។ តេ តស្ស និយស្សកម្មំ ករោន្តិ អធម្មេន វគ្គា ។ សោ តម្ហា អាវាសា អញ្ញំ អាវាសំ គច្ឆតិ ។ តត្ថបិ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សង្ឃេន និយស្សកម្មកតោ អធម្មេន វគ្គេហិ ហន្ទស្ស មយំ និយស្សកម្មំ ករោមាតិ ។



ឯភិក្ខុទាំងឡាយក្នុងអាវាសនោះគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯងដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយ ដោយភិក្ខុទាំងឡាយជាពួក តែប្រកបដោយធម៌ បើដូច្នោះមានតែយើងទាំងឡាយធ្វើតជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះជាពួកទាំងប្រកបដោយធម្មប្បដិរូប ធ្វើតជ្ជនីយកម្មដល់ភិក្ខុនោះ(ទៀត) ។

[១១៩] ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុក្នុងសាសនានេះ ល្ងង់មិនឆ្លាស មានអាបត្តិច្រើន មិនមានកំណត់អាបត្តិ នៅច្រឡូកច្រឡំដោយគ្រហស្ថ ដោយការច្រឡូកច្រឡំមិនសមគួរ ។ ក្នុងវត្តនោះ បើភិក្ខុទាំងឡាយគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ល្ងង់មិនឆ្លាស មានអាបត្តិច្រើន មិនមានការកំណត់អាបត្តិ នៅច្រឡូកច្រឡំដោយគ្រហស្ថ ដោយការច្រឡូកច្រឡំមិនសមគួរ បើដូច្នោះមានតែយើងទាំងឡាយធ្វើនិយស្សកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងអម្បាលនោះ ជាពួកទាំងមិនប្រកបដោយធម៌ ធ្វើនិយស្សកម្មដល់ភិក្ខុនោះ ។ ភិក្ខុនោះក៏ចេញពីអាវាសនោះទៅកាន់អាវាសដទៃ ។ ឯភិក្ខុទាំងឡាយក្នុងអាវាសនោះគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯងដែលសង្ឃបានធ្វើនិយស្សកម្មហើយ ដោយភិក្ខុទាំងឡាយជាពួកទាំងមិនប្រកបដោយធម៌ បើដូច្នោះមានតែយើងទាំងឡាយធ្វើនិយស្សកម្មដល់ភិក្ខុនេះ(ទៀត) ។

តេ តស្ស និយស្សកម្មំ ករេយ្យុំ អធម្មេន សមគ្គា ។ បេ ។ ធម្មេន វគ្គា ។ ធម្មប្បដិរូបកេន វគ្គា ។ ធម្មប្បដិរូបកេន សមគ្គា ។ យថា ហេដ្ឋា តថា ចក្កំ កាតព្វំ ។

(៣០៦) ឥធ បន ភិក្ខវេ ភិក្ខុ កុលទូសកោ ហោតិ បាបសមាចារោ ។ តត្រ ចេ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ កុលទូសកោ បាបសមាចារោ ហន្ទស្ស មយំ បព្វាជនីយកម្មំ ករោមាតិ ។ តេ តស្ស បព្វាជនីយកម្មំ ករោន្តិ អធម្មេន វគ្គា ។ សោ តម្ហា អាវាសា អញ្ញំ អាវាសំ គច្ឆតិ ។ តត្ថបិ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សង្ឃេន បព្វាជនីយកម្មកតោ អធម្មេន វគ្គេហិ ហន្ទស្ស មយំ



ភិក្ខុទាំងឡាយនោះព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ ធ្វើនិយស្សកម្មដល់ភិក្ខុនោះ ។ បេ ។ ជាពួក តែមិនប្រកបដោយធម៌ ។ ជាពួកទាំងប្រកបដោយធម៌ប្តូម ។ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្តូម ។ បណ្ឌិតគប្បីធ្វើចក្ក[1]ឲ្យដូចសេចក្តីដែលបានពោលមកហើយក្នុងខាងក្រោយ ។

(៣០៦) ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះមានភិក្ខុជាអ្នកប្រទូស្តត្រកូល មានមារយាទអាក្រក់ ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ជាអ្នកប្រទូស្តត្រកូល មានមារយាទអាក្រក់ បើដូច្នោះមានតែយើងទាំងឡាយធ្វើបព្វាជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះជាពួកទាំងមិនប្រកបដោយធម៌ ធ្វើបព្វាជនីយកម្មដល់ភិក្ខុនោះ ។ ភិក្ខុនោះក៏ចេញពីអាវាសនោះទៅកាន់អាវាសដទៃ ។ ឯភិក្ខុទាំងឡាយក្នុងអាវាសនោះគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឃបានធ្វើបព្វាជនីយកម្មហើយ ដោយភិក្ខុទាំងឡាយដែលជាពួកទាំងមិនប្រកបដោយធម៌ បើដូច្នោះមានតែយើងទាំងឡាយ

១ រឿងដែលត្រូវសំដែងវិលទៅរកសេចក្តីដើមវិញ ហៅថា ចក្ក គឺត្រូវបន្ថែមសេចក្តីខាងដើមនឹងខាងចុងដូចរឿងក៏ដែលនិយាយមកហើយ ។

បព្វាជនីយកម្មំ ករោមាតិ ។ តេ តស្ស បព្វាជនីយ-កម្មំ ករោន្តិ អធម្មេន សមគ្គា ។ បេ ។ ធម្មេន វគ្គា ។ ធម្មប្បដិរូបកេន វគ្គា ។ ធម្មប្បដិរូបកេន សមគ្គា ។ ចក្កំ កាតព្វំ ។

(១១៧) ឥធ បន ភិក្ខវេ ភិក្ខុ គិហី អក្កោសតិ បរិភាសតិ ។ តត្រ ចេ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ គិហី អក្កោសតិ បរិភាសតិ ហន្ទស្ស មយំ បដិសារណីយកម្មំ ករោមាតិ ។ តេ តស្ស បដិសារណីយកម្មំ ករោន្តិ អធម្មេន វគ្គា ។ បេ ។ អធម្មេន សមគ្គា ។ ធម្មេន វគ្គា ។ ធម្មប្បដិរូបកេន វគ្គា ។ ធម្មប្បដិរូបកេន សមគ្គា ។ ចក្កំ កាតព្វំ ។

(១១៨) ឥធ បន ភិក្ខវេ ភិក្ខុ អាបត្តឹ អាបជ្ជិត្វា ន ឥច្ឆតិ អាបត្តឹ បស្សិតុំ ។ តត្រ ចេ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ អាបត្តឹ អាបជ្ជិត្វា ន ឥច្ឆតិ អាបត្តឹ បស្សិតុំ ហន្ទស្ស មយំ អាបត្តិយា



ធ្វើបព្វាជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ ធ្វើបព្វាជនីយកម្មដល់ភិក្ខុនោះ (ទៀត) ។ បេ ។ ជាពួកតែប្រកបដោយធម៌ ។ ជាពួកទាំងប្រកបដោយធម៌ប្លំ ។ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លំ ។ បណ្ឌិតគប្បីធ្វើចក្ក (បំពេញសេចក្តីដូចខាងដើម) ។

(១១៧) ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ភិក្ខុក្នុងសាសនានេះ ភិក្ខុជេរប្រទេចពួកគ្រហស្ថ ។ គង់មានរឿងនោះ បើភិក្ខុទាំងឡាយគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ជេរប្រទេចពួកគ្រហស្ថ បើដូច្នោះមានតែយើងទាំងឡាយធ្វើបដិសារណីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះជាពួកទាំងមិនប្រកបដោយធម៌ ធ្វើបដិសារណីយកម្មដល់ភិក្ខុនោះ ។ បេ ។ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ ។ ជាពួកតែប្រកបដោយធម៌ ។ ជាពួកទាំងប្រកបដោយធម៌ប្លំ ។ ព្រមព្រៀងគ្នាតែប្រកបដោយធម៌ប្លំ ។ បណ្ឌិតគប្បីធ្វើចក្ក(បំពេញសេចក្តីដូចខាងដើម) ។

(១១៨) ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិហើយមិនប្រាថ្នានឹងឃើញអាបត្តិ ។ គង់មានរឿងនោះ បើភិក្ខុទាំងឡាយគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯងត្រូវអាបត្តិហើយ មិនប្រាថ្នានឹងឃើញអាបត្តិសោះ បើដូច្នោះមានតែយើងទាំងឡាយ

អទស្សនេ ឧក្ខេបនីយកម្មំ ករោមាតិ ។ តេ តស្ស អាបត្តិយា អទស្សនេ ឧក្ខេបនីយកម្មំ ករោន្តិ អធម្មេន វគ្គា ។ បេ ។ អធម្មេន សមគ្គា ។ ធម្មេន វគ្គា ។ ធម្មប្បតិរូបកេន វគ្គា ។ ធម្មប្បតិរូបកេន សមគ្គា ។ ចក្កំ កាតព្ពំ ។ ឥធ បន ភិក្ខវេ ភិក្ខុ អាបត្តិំ អាបជ្ជិត្វា ន ឥច្ឆតិ អាបត្តិំ បដិ-កាតុំ ។ តត្រ ចេ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ អាបត្តិំ អាបជ្ជិត្វា ន ឥច្ឆតិ អាបត្តិំ បដិកាតុំ ហន្ទស្ស មយំ អាបត្តិយា អប្បដិកម្មេ ឧក្ខេបនីយកម្មំ ករោមាតិ ។ តេ តស្ស អាបត្តិយា អប្បដិកម្មេ ឧក្ខេបនីយកម្មំ ករោន្តិ អធម្មេន វគ្គា ។ បេ ។ អធម្មេន សមគ្គា ។ ធម្មេន វគ្គា ។ ធម្មប្បតិរូបកេន វគ្គា ។ ធម្មប្បតិរូបកេន សមគ្គា ។ ចក្កំ កាតព្ពំ ។ ឥធ បន ភិក្ខវេ ភិក្ខុ ន ឥច្ឆតិ បាបិកំ ទិដ្ឋិំ បដិនិស្សជ្ជិតុំ ។ តត្រ ចេ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ



ធ្វើឧក្ខេបនីយកម្មដល់ភិក្ខុនេះ ព្រោះមិនឃើញអាបត្តិ ។ ភិក្ខុទាំងនោះជាពួក ទាំងមិនត្រូវតាមធម៌ ធ្វើឧក្ខេបនីយកម្មដល់ភិក្ខុនោះ ព្រោះមិនឃើញអាបត្តិ ។ បេ ។ ព្រមព្រៀងគ្នា តែមិនត្រូវតាមធម៌ ។ ជាពួក តែត្រូវតាមធម៌ ។ ជាពួកទាំងត្រូវតាមធម៌ប្លម ។ ព្រមព្រៀងគ្នា តែត្រូវតាមធម៌ប្លម ។ បណ្ឌិតគប្បីធ្វើចក្កចុះ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិហើយ មិនប្រាថ្នានឹងសំដែងអាបត្តិ ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយមានគំនិតយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ត្រូវអាបត្តិហើយ មិនប្រាថ្នានឹងសំដែងអាបត្តិ បើដូច្នោះមានតែយើងទាំងឡាយធ្វើឧក្ខេបនីយកម្មដល់ភិក្ខុនោះ ព្រោះមិនសំដែងអាបត្តិ ។ ភិក្ខុទាំងនោះជាពួកទាំងមិនត្រូវតាមធម៌ ធ្វើឧក្ខេបនីយកម្មដល់ភិក្ខុនោះ ព្រោះមិនសំដែងអាបត្តិ ។ បេ ។ ព្រមព្រៀងគ្នា តែមិនត្រូវតាមធម៌ ។ ជាពួក តែត្រូវតាមធម៌ ។ ជាពួកទាំងត្រូវតាមធម៌ប្លម ។ ព្រមព្រៀងគ្នា តែត្រូវតាមធម៌ប្លម ។ បណ្ឌិតគប្បីធ្វើចក្កចុះ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុក្នុងសាសនានេះ មិនប្រាថ្នានឹងលះបង់ទិដ្ឋិអាក្រក់ចេញ ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយមានគំនិតយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង

ន ឥច្ឆតិ បាបិកំ ទិដ្ឋឹ បដិនិស្សជ្ជិតុំ ហន្ទស្ស មយំ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មំ ករោមាតិ ។ តេ តស្ស បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មំ ករោន្តិ អធម្មេន វគ្គា ។ បេ ។ អធម្មេន សមគ្គា ។ ធម្មេន វគ្គា ។ ធម្មប្បដិរូបកេន វគ្គា ។ ធម្មប្បដិរូបកេន សមគ្គា ។ ជគ្គិ កាតព្វំ ។

[១១៩] ឥធ បន ភិក្ខវេ ភិក្ខុ សង្ឃេន តជ្ជនីយកម្មកតោ សម្មាវត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ តជ្ជនីយកម្មស្ស បដិប្បស្សទ្ធឹ យាចតិ ។ តត្រ ចេ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សង្ឃេន តជ្ជនីយកម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ តជ្ជនីយកម្មស្ស បដិប្បស្សទ្ធឹ យាចតិ ហន្ទស្ស មយំ តជ្ជនីយកម្មំ បដិប្បស្សម្ភេមាតិ ។ តេ តស្ស តជ្ជនីយកម្មំ បដិប្បស្សម្ភេន្តិ អធម្មេន វគ្គា ។ សោ តម្ហា អាវាសា អញ្ញំ អាវាសំ គច្ឆតិ ។ តត្ថបិ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សង្ឃេន



មិនប្រាថ្នានឹងលះបង់ទិដ្ឋិអាក្រក់ចេញសោះ បើដូច្នោះមានតែយើងទាំងឡាយធ្វើឧក្ខេបនីយកម្មដល់ភិក្ខុនោះព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ។ ភិក្ខុទាំងអម្បាលនោះជាពួកទាំងមិនប្រកបដោយធម៌ ធ្វើឧក្ខេបនីយកម្មដល់ភិក្ខុនោះព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ។ បេ ។ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ ។ ជាពួក តែប្រកបដោយធម៌ ។ ជាពួកទាំងប្រកបដោយធម៌ប្លម ។ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម ។ បណ្ឌិតគប្បីធ្វើចក្កុះ ។

(១១៩) ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុក្នុងសាសនានេះ សង្ឃបានធ្វើតជ្ជនីយកម្មហើយ ក៏ប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្របតាម ប្រព្រឹត្តវត្តគួរដល់ការយាសោះចេញចាកកម្ម ហើយមកសូមការរម្ងាប់តជ្ជនីយកម្ម(នឹងសង្ឃ) ។ គង់ត្រូវនោះ បើភិក្ខុទាំងឡាយមានគំនិតយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង សង្ឃបានធ្វើតជ្ជនីយកម្មហើយ ក៏ប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្របតាមប្រព្រឹត្តវត្តគួរដល់ការយាសោះចេញចាកកម្ម ឥឡូវនេះមកសូមការរម្ងាប់តជ្ជនីយកម្មនោះ បើដូច្នោះមានតែយើងទាំងឡាយរម្ងាប់តជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងអម្បាលនោះជាពួកទាំងមិនប្រកបដោយធម៌ រម្ងាប់តជ្ជនីយកម្មដល់ភិក្ខុនោះ ។ ភិក្ខុនោះក៏ចេញពីអាវាសនោះទៅកាន់អាវាសដទៃ ។ ឯភិក្ខុទាំងឡាយក្នុងអាវាសនោះមានគំនិតយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯងសង្ឃ

តជ្ជនីយកម្មំ បដិប្បស្សទ្ធំ អធម្មេន វគ្គេហិ ហន្ទស្ស មយំ តជ្ជនីយកម្មំ បដិប្បស្សម្ភេមាតិ ។ តេ តស្ស តជ្ជនីយកម្មំ បដិប្បស្សម្ភេន្តិ អធម្មេន សមគ្គា ។ បេ ។ ធម្មេន វគ្គា ។ ធម្មប្បដិរូបកេន វគ្គា ។ ធម្មប្បដិរូបកេន សមគ្គា ។ ឥធ បន ភិក្ខវេ ភិក្ខុ សង្ឃេន តជ្ជនីយ-កម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ តជ្ជនីយកម្មស្ស បដិប្បស្សទ្ធឹ យាចតិ ។ តត្ថ ចេ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សង្ឃេន តជ្ជនីយកម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ តជ្ជនីយកម្មស្ស បដិប្បស្សទ្ធឹ យាចតិ ហន្ទស្ស មយំ តជ្ជនីយកម្មំ បដិប្បស្សម្ភេមាតិ ។ តេ តស្ស តជ្ជនីយកម្មំ បដិប្បស្សម្ភេន្តិ អធម្មេន សមគ្គា ។ បេ ។ ធម្មេន វគ្គា ។ ធម្មប្បដិរូបកេន វគ្គា ។ ធម្មប្បដិរូបកេន សមគ្គា ។ អធម្មេន វគ្គា ។ ឥធ បន ភិក្ខវេ ភិក្ខុ សង្ឃេន





បានរម្ងាប់តជ្ជនីយកម្មហើយ ដោយភិក្ខុទាំងឡាយជាពួកទាំងមិនប្រកបដោយធម៌ បើដូច្នោះមានតែយើងទាំងឡាយរម្ងាប់តជ្ជនីយកម្មដល់ភិក្ខុនេះ (ទៀត) ។ ភិក្ខុទាំងនោះព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌រម្ងាប់តជ្ជនីយកម្មដល់ភិក្ខុនោះ ។ បេ ។ ជាពួក តែប្រកបដោយធម៌ ។ ជាពួកទាំងប្រកបដោយធម្មប្បតិរូប ។ ព្រមព្រៀងគ្នា តែប្រកបដោយធម្មប្បតិរូប ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុក្នុងសាសនានេះ សង្ឃបានធ្វើតជ្ជនីយកម្មហើយ ក៏ប្រព្រឹត្តត្រូវដោយប្រពៃ ទាំងសម្រួលរោមប្រព្រឹត្តតម្រូវដល់កិរិយារលាស់ចេញចាកកម្មហើយ មកសូមការរម្ងាប់តជ្ជនីយកម្ម ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង សង្ឃបានធ្វើតជ្ជនីយកម្មហើយ ក៏បានប្រព្រឹត្តត្រូវដោយប្រពៃ ទាំងសម្រួលរោមប្រព្រឹត្តតម្រូវដល់កិរិយារលាស់ចេញចាកកម្ម ឥឡូវនេះមកសូមការរម្ងាប់តជ្ជនីយកម្ម (នោះ) បើដូច្នោះមានតែយើងទាំងឡាយរម្ងាប់តជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ រម្ងាប់តជ្ជនីយកម្មដល់ភិក្ខុនោះ ។ បេ ។ ជាពួក តែប្រកបដោយធម៌ ។ ជាពួកទាំងប្រកបដោយធម្មប្បតិរូប ។ ព្រមព្រៀងគ្នា តែប្រកបដោយធម្មប្បតិរូប ។ ជាពួកទាំងមិនប្រកបដោយធម៌ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត

តជ្ជនីយកម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ តជ្ជនីយកម្មស្ស បដិប្បស្សទ្ធិំ យាចតិ ។ តត្រ ចេ ភិក្ខូ ឯវំ វទន្តិ អយំ ខោ អាវុសោ ភិក្ខុ សង្ឃេន តជ្ជនីយកម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ តជ្ជនីយកម្មស្ស បដិប្បស្សទ្ធិំ យាចតិ ហន្ទស្ស មយំ តជ្ជនីយកម្មំ បដិប្បស្សម្ភេមាតិ ។ តេ តស្ស តជ្ជនីយកម្មំ បដិប្បស្សម្ភេន្តិ ធម្មេន វគ្គា ។ បេ ។ ធម្មប្បដិរូបកេន វគ្គា ។ ធម្មប្បដិរូបកេន សមគ្គា ។ អធម្មេន វគ្គា ។ អធម្មេន សមគ្គា ។ ឥធ បន ភិក្ខវេ ភិក្ខុ សង្ឃេន តជ្ជនីយកម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ តជ្ជនីយកម្មស្ស បដិប្បស្សទ្ធិំ យាចតិ ។ តត្រ ចេ ភិក្ខូ ឯវំ វទន្តិ អយំ ខោ អាវុសោ ភិក្ខុ សង្ឃេន តជ្ជនីយកម្មកតោ សម្មា វត្តតិ



ភិក្ខុក្នុងសាសនានេះ សង្ឃបានធ្វើតជ្ជនីយកម្មហើយ ក៏ប្រព្រឹត្តត្រូវដោយប្រពៃ ចាំនូវសម្មាវត្តប្រព្រឹត្តត្រូវដល់កិរិយារលាស់ចេញចាកកម្ម ហើយសូមការរម្ងាប់តជ្ជនីយកម្ម ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង សង្ឃបានធ្វើតជ្ជនីយកម្មហើយ ក៏បានប្រព្រឹត្តត្រូវដោយប្រពៃ ចាំនូវសម្មាវត្តប្រព្រឹត្តត្រូវដល់កិរិយារលាស់ចេញចាកកម្ម ឥឡូវនេះមកសូមការរម្ងាប់តជ្ជនីយកម្ម បើដូច្នោះ មានតែយើងទាំងឡាយរម្ងាប់តជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះជាពួក តែប្រកបដោយធម៌ រម្ងាប់តជ្ជនីយកម្មដល់ភិក្ខុនោះ ។ បេ ។ ជាពួកទាំងប្រកបដោយធម្មប្បដិរូប ។ ព្រមព្រៀងគ្នា តែប្រកបដោយធម្មប្បដិរូប ។ ជាពួកទាំងមិនប្រកបដោយធម៌ ។ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុក្នុងសាសនានេះសង្ឃបានធ្វើតជ្ជនីយកម្មហើយ ក៏ប្រព្រឹត្តត្រូវដោយប្រពៃ ចាំនូវសម្មាវត្តប្រព្រឹត្តត្រូវដល់កិរិយារលាស់ចេញចាកកម្ម ហើយមកសូមការរម្ងាប់តជ្ជនីយកម្ម ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយ ក៏បានប្រព្រឹត្តត្រូវដោយប្រពៃ

លោមំ បាតេតិ នេត្ថារំ វត្តតិ តជ្ជនីយកម្មស្ស បដិប្បស្សទ្ធិំ យាចតិ ហន្ទស្ស មយំ តជ្ជនីយកម្មំ បដិប្បស្សម្ភេមាតិ ។ តេ តស្ស តជ្ជនីយកម្មំ បដិប្បស្សម្ភេន្តិ ធម្មប្បដិរូបកេន វគ្គា ។ បេ ។ ធម្មប្បដិរូបកេន សមគ្គា ។ អធម្មេន វគ្គា ។ អធម្មេន សមគ្គា ។ ធម្មេន វគ្គា ។ ឥធ បន ភិក្ខវេ ភិក្ខុ សង្ឃេន តជ្ជនីយកម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ តជ្ជនីយកម្មស្ស បដិប្បស្សទ្ធិំ យាចតិ ។ តត្រ ចេ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សង្ឃេន តជ្ជនីយកម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ តជ្ជនីយកម្មស្ស បដិប្បស្សទ្ធិំ យាចតិ ហន្ទស្ស មយំ តជ្ជនីយកម្មំ បដិប្បស្សម្ភេមាតិ ។ តេ តស្ស តជ្ជនីយកម្មំ បដិប្បស្សម្ភេន្តិ ធម្មប្បដិរូបកេន សមគ្គា ។ បេ ។ អធម្មេន វគ្គា ។ អធម្មេន សមគ្គា ។ ធម្មេន វគ្គា ។ ធម្មប្បដិរូបកេន វគ្គា ។



ទាំងសម្ងប់រោម ប្រព្រឹត្តវត្តត្រូវដល់កិរិយារលាស់ចេញចាកកម្ម ស្ដ្រីនេះ មកសូមការរម្ងាប់តជ្ជនីយកម្ម(នោះ) បើដូច្នោះមានតែយើងទាំងឡាយរម្ងាប់តជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះជាពួកទាំងប្រកបដោយធម៌ប្លម រម្ងាប់តជ្ជនីយកម្មដល់ភិក្ខុនោះ ។ បេ ។ ព្រមព្រៀងគ្នា ដែលប្រកបដោយធម៌ប្លម ។ ជាពួកទាំងមិនប្រកបដោយធម៌ ។ ព្រមព្រៀងគ្នា ដែលមិនប្រកបដោយធម៌ ។ ជាពួក ដែលប្រកបដោយធម៌ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទៀត ភិក្ខុក្នុងសាសនានេះ សង្ឃបានធ្វើតជ្ជនីយកម្មហើយ ក៏ប្រព្រឹត្តដោយប្រពៃ ទាំងសម្ងប់រោម ប្រព្រឹត្តវត្តត្រូវដល់កិរិយារលាស់ចេញចាកកម្ម ហើយមកសូមការរម្ងាប់តជ្ជនីយកម្ម ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយ មានយោបល់ដូច្នេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯងដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយ ក៏បានប្រព្រឹត្តដោយប្រពៃ ទាំងសម្ងប់រោម ប្រព្រឹត្តវត្តត្រូវដល់កិរិយារលាស់ចេញចាកកម្ម ហើយមកសូមការរម្ងាប់តជ្ជនីយកម្ម (នោះ) បើដូច្នោះមានតែយើងទាំងឡាយរម្ងាប់តជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះព្រមព្រៀងគ្នា ដែលប្រកបដោយធម៌ប្លម រម្ងាប់តជ្ជនីយកម្មដល់ភិក្ខុនោះ ។ បេ ។ ជាពួកទាំងមិនប្រកបដោយធម៌ ។ ព្រមព្រៀងគ្នា ដែលមិនប្រកបដោយធម៌ ។ ជាពួក ដែលប្រកបដោយធម៌ ។ ជាពួកទាំងប្រកបដោយធម៌ប្លម ។

(១៦០) ឥធ បន ភិក្ខវេ ភិក្ខុ សង្ឃេន និយស្ស-
កម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ និ-
យស្សកម្មស្ស បដិប្បស្សទ្ធិំ យាចតិ ។ តត្រ ចេ
ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សង្ឃេន
និយស្សកម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ
វត្តតិ និយស្សកម្មស្ស បដិប្បស្សទ្ធិំ យាចតិ ហន្ទស្ស
មយំ និយស្សកម្មំ បដិប្បស្សម្ភេមាតិ ។ តេ តស្ស
និយស្សកម្មំ បដិប្បស្សម្ភេន្តិ អធម្មេន វគ្គា ។ បេ ។
អធម្មេន សមគ្គា ។ ធម្មេន វគ្គា ។ ធម្មប្បដិរូបកេន
វគ្គា ។ ធម្មប្បដិរូបកេន សមគ្គា ។ ចក្កំ កាតព្វំ ។

(១៦១) ឥធ បន ភិក្ខវេ ភិក្ខុ សង្ឃេន
បព្វាជនីយកម្មកតោ សម្មា វត្តតិ លោមំ បាតេតិ
នេត្ថារំ វត្តតិ បព្វាជនីយកម្មស្ស បដិប្បស្សទ្ធិំ យាចតិ ។
តត្រ ចេ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ
ភិក្ខុ សង្ឃេន បព្វាជនីយកម្មកតោ សម្មា វត្តតិ



(១៦០) ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុក្នុងសាសនានេះ
សង្ឃបានធ្វើនិយស្សកម្មហើយ ក៏ប្រព្រឹត្តត្រូវដោយប្រពៃ ដាក់ស្មូបរោម
ប្រព្រឹត្តត្រូវដល់កិរិយារលាស់ចេញចាកកម្មហើយ មកសូមការរម្ងាប់
និយស្សកម្ម ។ គង់មានភិក្ខុទាំងឡាយគិតគ្នាយ៉ាងនេះថា ម្នាលអាវុ-
សោទាំងឡាយ ភិក្ខុនេះឯងដែលសង្ឃបានធ្វើនិយស្សកម្មហើយ ក៏បាន
ប្រព្រឹត្តត្រូវដោយប្រពៃ ដាក់ស្មូបរោម ប្រព្រឹត្តត្រូវដល់កិរិយារលាស់
ចេញចាកកម្ម ស្រាប់មកសូមការរម្ងាប់និយស្សកម្ម (នោះ) បើដូច្នោះមានតែ
យើងទាំងឡាយរម្ងាប់និយស្សកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះជាពួកទាំង
មិនប្រកបដោយធម៌ រម្ងាប់និយស្សកម្មដល់ភិក្ខុនោះ ។ បេ ។ ព្រមព្រៀង
គ្នា តែមិនប្រកបដោយធម៌ ។ ជាពួក តែប្រកបដោយធម៌ ។ ជាពួក
ទាំងប្រកបដោយធម៌ប្លម ។ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម ។
បណ្ឌិតគប្បីធ្វើចក្កៈ ។

(១៦១) ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុក្នុងសាសនានេះ
សង្ឃបានធ្វើបព្វាជនីយកម្មហើយ ក៏ប្រព្រឹត្តត្រូវដោយប្រពៃ ដាក់ស្មូប
រោម ប្រព្រឹត្តត្រូវដល់កិរិយារលាស់ចេញចាកកម្មហើយ មកសូមការ
រម្ងាប់បព្វាជនីយកម្ម ។ គង់មានភិក្ខុទាំងឡាយគិតគ្នាយ៉ាងនេះ
ថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯងដែលសង្ឃបានធ្វើបព្វាជនីយកម្ម

លោមំ បាតេតិ នេត្ថារំ វត្តតិ បព្វាជនីយកម្មស្ស បដិប្បស្សទ្ធិំ យាចតិ ហន្ទស្ស មយំ បព្វាជនីយកម្មំ បដិប្បស្សម្ភេម ។ តេ តស្ស បព្វាជនីយកម្មំ បដិប្បស្សម្ភេន្តិ អធម្មេន វគ្គា ។បេ។ អធម្មេន សមគ្គា ។ ធម្មេន វគ្គា ។ ធម្មប្បតិរូបកេន វគ្គា ។ ធម្មប្បតិរូបកេន សមគ្គា ។ ចតុក្កំ កាតព្វំ ។

(៤៤៤) ឥធ បន ភិក្ខវេ ភិក្ខុ សង្ឃេន បដិសារណីយកម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ បដិសារណីយកម្មស្ស បដិប្បស្សទ្ធិំ យាចតិ ។ តត្រ ចេ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សង្ឃេន បដិសារណីយកម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ បដិសារណីយកម្មស្ស បដិប្បស្សទ្ធិំ យាចតិ ហន្ទស្ស មយំ បដិសារណីយកម្មំ បដិប្បស្សម្ភេម ។ តេ តស្ស បដិសារណីយកម្មំ





ហើយ ក៏ប្រព្រឹត្តដោយប្រពៃ ទាំងសម្រុបរោមប្រព្រឹត្តនូវដល់កិរិយារលាស់ចេញចាកកម្ម តែងតែមកសូមការរម្ងាប់បព្វាជនីយកម្ម (នោះ) បើដូច្នោះមានតែយើងទាំងឡាយរម្ងាប់បព្វាជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះជាពួកទាំងមិនប្រកបដោយធម៌ រម្ងាប់បព្វាជនីយកម្មដល់ភិក្ខុនោះ ។បេ។ ព្រមព្រៀងគ្នា ដែលមិនប្រកបដោយធម៌ ។ ជាពួក ដែលប្រកបដោយធម៌ ។ ជាពួកទាំងប្រកបដោយធម៌ប្លម ។ ព្រមព្រៀងគ្នា ដែលប្រកបដោយធម៌ប្លម ។ បណ្ឌិតគប្បីធ្វើចតុក្កៈ ។

[៤៤៤] ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ភិក្ខុក្នុងសាសនានេះ សង្ឃបានធ្វើបដិសារណីយកម្មហើយ ក៏ប្រព្រឹត្តដោយប្រពៃ ទាំងសម្រុបរោមប្រព្រឹត្តនូវដល់កិរិយារលាស់ចេញចាកកម្មហើយ មកសូមការរម្ងាប់បដិសារណីយកម្ម ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯងដែលសង្ឃបានធ្វើបដិសារណីយកម្មហើយ ក៏បានប្រព្រឹត្តដោយប្រពៃ ទាំងសម្រុបរោមប្រព្រឹត្តនូវដល់កិរិយារលាស់ចេញចាកកម្ម តែងតែមកសូមការរម្ងាប់បដិសារណីយកម្ម (នោះ) បើដូច្នោះមានតែយើងទាំងឡាយរម្ងាប់បដិសារណីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះជាពួកទាំងមិនប្រកបដោយធម៌ រម្ងាប់បដិសារណីយកម្ម

បដិប្បស្សម្ភេន្តិ អធម្មេន វគ្គា ។បេ។ អធម្មេន សមគ្គា ។ ធម្មេន វគ្គា ។ ធម្មប្បដិរូបកេន វគ្គា ។ ធម្មប្បដិរូបកេន សមគ្គា ។ ចក្កំ កាតព្វំ ។

[១៦៣] ឥធ បន ភិក្ខវេ ភិក្ខុ សង្ឃេន អាបត្តិយា អទស្សនេ ឧក្ខេបនីយកម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ អាបត្តិយា អទស្សនេ ឧក្ខេបនីយកម្មស្ស បដិប្បស្សទ្ធិំ យាចតិ ។ តត្រ ចេ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សង្ឃេន អាបត្តិយា អទស្សនេ ឧក្ខេបនីយកម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ អាបត្តិយា អទស្សនេ ឧក្ខេបនីយកម្មស្ស បដិប្បស្សទ្ធិំ យាចតិ ហន្ទស្ស មយំ អាបត្តិយា អទស្សនេ ឧក្ខេបនីយកម្មំ បដិប្បស្សម្ភេមាតិ ។ តេ តស្ស អាបត្តិយា អទស្សនេ ឧក្ខេបនីយកម្មំ បដិប្បស្សម្ភេន្តិ ធម្មេន វគ្គា ។បេ។ អធម្មេន សមគ្គា ។ ធម្មេន វគ្គា ។ ធម្មប្បដិរូបកេន វគ្គា ។ ធម្មប្បដិរូបកេន សមគ្គា ។ ចក្កំ កាតព្វំ ។ ឥធ បន ភិក្ខវេ ភិក្ខុ



ដល់ភិក្ខុនោះ ។បេ។ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ ។ ជាពួក តែប្រកបដោយធម៌ ។ ជាពួកតាំងប្រកបដោយធម្មប្បដិរូប ។ ព្រមព្រៀងគ្នា តែប្រកបដោយធម្មប្បដិរូប ។ បណ្ឌិតគប្បីធ្វើចក្កចុះ ។

(១៦៣) ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុក្នុងសាសនានេះ ដែលសង្ឃបានធ្វើឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិហើយ ក៏ប្រព្រឹត្តដោយប្រពៃ ទាំងសម្ងួបរោម ប្រព្រឹត្តតាមដល់កិរិយារលាស់ចេញចាកកម្មហើយ មកសូមការរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ។ ក្នុងទីនោះ បើភិក្ខុទាំងឡាយគិតយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឃបានធ្វើឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិហើយ ក៏ប្រព្រឹត្តដោយប្រពៃ ទាំងសម្ងួបរោម ប្រព្រឹត្តតាមដល់កិរិយារលាស់ចេញចាកកម្ម ឥឡូវមកសូមការរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ (នោះ) បើដូច្នោះមានតែយើងទាំងឡាយរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិដល់ភិក្ខុនេះចុះ ។ ភិក្ខុទាំងនោះជាពួក តែប្រកបដោយធម៌ រម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិដល់ភិក្ខុនោះ ។បេ។ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ ។ ជាពួក តែប្រកបដោយធម៌ ។ ជាពួកតាំងប្រកបដោយធម្មប្បដិរូប ។ ព្រមព្រៀងគ្នា តែប្រកបដោយធម្មប្បដិរូប ។ បណ្ឌិតគប្បីធ្វើចក្កចុះ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុ

សាវេជ្ជ អាបត្តិយា អប្បដិកម្មេ ឧក្ខេបនីយកម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ អាបត្តិយា អប្បដិកម្មេ ឧក្ខេបនីយកម្មស្ស បដិប្បស្សទ្ធិំ យាចតិ ។ តត្រ ចេ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សាវេជ្ជ អាបត្តិយា អប្បដិកម្មេ ឧក្ខេបនីយកម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ អាបត្តិយា អប្បដិកម្មេ ឧក្ខេបនីយកម្មស្ស បដិប្បស្សទ្ធិំ យាចតិ ហន្ទស្ស មយំ អាបត្តិយា អប្បដិកម្មេ ឧក្ខេបនីយកម្មំ បដិប្បស្សម្ភេមាតិ ។ តេ តស្ស អាបត្តិយា អប្បដិកម្មេ ឧក្ខេបនីយកម្មំ បដិប្បស្សម្ភេន្តិ អធម្មេន វគ្គា ។បេ។ អធម្មេន សមគ្គា ។ ធម្មេន វគ្គា ។ ធម្មប្បដិរូបកេន វគ្គា ។ ធម្មប្បដិរូបកេន សមគ្គា ។ ចត្តំ ការកត្តំ ។ ឥធ បន ភិក្ខវេ ភិក្ខុ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មស្ស បដិប្បស្សទ្ធិំ យាចតិ ។ តត្រ ចេ



ក្នុងសាសនានេះ សង្ឃបានធ្វើឧក្ខេបនីយកម្មព្រោះមិនសំដែងអាបត្តិចេញហើយ ក៏ប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្រួលរោមប្រព្រឹត្តវត្តដល់កិរិយារលាស់ចេញចាកកម្មហើយ មកសូមការរម្ងាប់ឧក្ខេបនីយកម្មព្រោះមិនសំដែងអាបត្តិ ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយគិតយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឃបានធ្វើឧក្ខេបនីយកម្មព្រោះមិនសំដែងអាបត្តិចេញហើយ ក៏បានប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្រួលរោមប្រព្រឹត្តវត្តដល់កិរិយារលាស់ចេញចាកកម្ម ឥឡូវមកសូមការរម្ងាប់ឧក្ខេបនីយកម្មព្រោះមិនសំដែងអាបត្តិ (នោះ) បើដូច្នោះមានតែយើងទាំងឡាយរម្ងាប់ឧក្ខេបនីយកម្មព្រោះមិនសំដែងអាបត្តិដល់ភិក្ខុនេះចុះ ។ ភិក្ខុទាំងនោះជាពួកទាំងមិនប្រកបដោយធម៌ រម្ងាប់ឧក្ខេបនីយកម្មព្រោះមិនសំដែងអាបត្តិដល់ភិក្ខុនោះ ។បេ។ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ ។ ជាពួក តែប្រកបដោយធម៌ ។ ជាពួកទាំងប្រកបដោយធម៌ប្លម ។ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម ។ បណ្ដាំគប្បីធ្វើចក្កចុះ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ សង្ឃបានធ្វើឧក្ខេបនីយកម្មហើយ ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ ក៏ប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្រួលរោមប្រព្រឹត្តវត្តដល់កិរិយារលាស់ចេញចាកកម្មហើយ មកសូមការរម្ងាប់ឧក្ខេបនីយកម្មព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ ។ ក្នុងរឿងនោះបើ

ភិក្ខូនំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សង្ឃេន អាបត្តិយា អទស្សនេ ឧក្ខេបនីយកម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ អាបត្តិយា អទស្សនេ ឧក្ខេបនីយកម្មស្ស បដិប្បស្សទ្ធិំ យាចតិ ហន្ទស្ស មយំ អាបត្តិយា អទស្សនេ ឧក្ខេបនីយកម្មំ បដិប្បស្សម្ភេមាតិ ។ តេ តស្ស អាបត្តិយា អទស្សនេ ឧក្ខេបនីយកម្មំ បដិប្បស្សម្ភេន្តិ អធម្មេន វគ្គា ។ បេ ។ អធម្មេន សមគ្គា ។ ធម្មេន វគ្គា ។ ធម្មប្បដិរូបកេន វគ្គា ។ ធម្មប្បដិរូបកេន សមគ្គា ។ ឧទ្ធំ ការកំ ។

(១៦៦) ឥធ បន ភិក្ខវេ ភិក្ខុ ភណ្ឌនការកោ ហោតិ កលហការកោ វិវាទការកោ ភស្សការកោ សង្ឃេ អធិករណការកោ ។ តត្រ ចេ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ ភណ្ឌនការកោ កលហការកោ វិវាទការកោ ភស្សការកោ សង្ឃេ អធិករណការកោ ហន្ទស្ស មយំ តជ្ជនីយកម្មំ ករោមាតិ ។ តេ



ភិក្ខុទាំងឡាយគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឃបានធ្វើឧក្ខេបនីយកម្ម ហើយព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ក៏បានប្រព្រឹត្តត្រូវដោយប្រពៃ ។ បានសម្របកាយប្រព្រឹត្តត្រូវដល់កិរិយារលាស់ចេញចាកកម្ម សូមនូវការរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ បើដូច្នោះមានតែយើងទាំងឡាយរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះជាពួកទាំងមិនប្រកបដោយធម៌ រម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញដល់ភិក្ខុនោះ ។ បេ ។ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ ។ ជាពួកតែប្រកបដោយធម៌ ។ ជាពួកទាំងប្រកបដោយធម៌ប្ដូម ។ ព្រមព្រៀងគ្នាតែប្រកបដោយធម៌ប្ដូម ។ បណ្ឌិតគប្បីធ្វើបក្ខ្យុ ។

(១៦៦) ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះជាអ្នកធ្វើនូវការប្រកួតប្រកាន់ ជាអ្នកធ្វើនូវជំលោះ ជាអ្នកធ្វើនូវវិវាទ ជាអ្នកធ្វើនូវតំណាលកថា ជាអ្នកធ្វើនូវអធិករណ៍ក្នុងសង្ឃ ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯងជាអ្នកធ្វើនូវការប្រកួតប្រកាន់ ជាអ្នកធ្វើនូវជំលោះ ជាអ្នកធ្វើនូវវិវាទ ជាអ្នកធ្វើនូវតំណាលកថា ជាអ្នកធ្វើនូវអធិករណ៍ក្នុងសង្ឃ បើដូច្នោះមានតែយើងទាំងឡាយធ្វើតជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះជាពួកទាំងមិនប្រកបដោយធម៌

តស្ស តជ្ជនីយកម្មំ ករោន្តិ អធម្មេន វគ្គា ។ តត្រដ្ឋោ សង្ឃោ វិវទតិ អធម្មេន វគ្គកម្មំ អធម្មេន សមគ្គកម្មំ ធម្មបតិរូបកេន វគ្គកម្មំ ធម្មបតិរូបកេន សមគ្គកម្មំ អកតំ កម្មំ ទុក្កដំ កម្មំ បុន កាតព្វំ កម្មន្តិ ។ តត្រ ភិក្ខវេ យេ តេ ភិក្ខូ ឯវមាហំសុ អធម្មេន វគ្គកម្មន្តិ យេ ច តេ ភិក្ខូ ឯវមាហំសុ អកតំ កម្មំ ទុក្កដំ កម្មំ បុន កាតព្វំ កម្មន្តិ ។ ឥមេ តត្ថ ភិក្ខូ ធម្មវាទិនោ ។

(១៦៨) ឥធ បន ភិក្ខវេ ភិក្ខុ ភណ្ឌនការកោ ហោតិ កលហការកោ វិវាទការកោ ភស្សការកោ សង្ឃេ អធិករណការកោ ។ តត្រ ចេ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ ភណ្ឌនការកោ កលហការកោ វិវាទការកោ ភស្សការកោ សង្ឃេ អធិករណការកោ ហន្ទស្ស មយំ តជ្ជនីយកម្មំ ករោមាតិ ។ តេ តស្ស តជ្ជនីយកម្មំ ករោន្តិ



ធ្វើតជ្ជនីយកម្មដល់ភិក្ខុនោះ ។ សង្ឃដែលស្ថិតនៅក្នុងអាវាសនោះ ពោលគ្នាថា កម្មរបស់ភិក្ខុជាពួកចាំទីមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុដែលព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួកចាំទីប្រកបដោយធម៌ប្លម កម្មរបស់ភិក្ខុដែលព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម កម្មឈ្មោះថាភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថាភិក្ខុធ្វើមិនល្អហើយ កម្មសង្ឃត្រូវធ្វើទៀត ។ ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុទាំងនោះ ភិក្ខុទាំងពួកណានិយាយយ៉ាងនេះថា កម្មរបស់ភិក្ខុជាពួកចាំទីមិនប្រកបដោយធម៌ ក្តីនោះ សោត ភិក្ខុណានិយាយយ៉ាងនេះថា កម្មឈ្មោះថាភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថាភិក្ខុធ្វើមិនល្អហើយ កម្មគប្បីធ្វើទៀត ។ ភិក្ខុទាំងអម្បាលនេះ ឈ្មោះថាធម្មវាទី (អ្នកពោលត្រូវធម៌) ក្នុងកម្មនោះ ។

(១៦៨) ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ ជាអ្នកធ្វើនូវការបង្កហេតុ ជាអ្នកធ្វើនូវជម្លោះ ជាអ្នកធ្វើនូវវិវាទ ជាអ្នកធ្វើនូវតែច្រូចគេថា ជាអ្នកធ្វើនូវអធិករណ៍ក្នុងសង្ឃ ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯងជាអ្នកធ្វើនូវការបង្កហេតុ ជាអ្នកធ្វើនូវជម្លោះ ជាអ្នកធ្វើនូវវិវាទ ជាអ្នកធ្វើនូវតែច្រូចគេថា ជាអ្នកធ្វើនូវអធិករណ៍ក្នុងសង្ឃ បើដូច្នោះមានតែយើងទាំងឡាយធ្វើតជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះព្រមព្រៀងគ្នា

អធម្មេន សមគ្គា ។ តត្រដ្ឋោ សង្ឃោ វិវទតិ អធម្មេន វគ្គកម្មំ អធម្មេន សមគ្គកម្មំ ធម្មេន វគ្គកម្មំ ធម្មប្បដិរូបកេន វគ្គកម្មំ ធម្មប្បដិរូបកេន សមគ្គកម្មំ អកតំ កម្មំ ទុក្កដំ កម្មំ បុន កាតព្វំ កម្មន្តិ ។ តត្រ ភិក្ខវេ យេ តេ ភិក្ខូ ឯវមាហំសុ អធម្មេន សមគ្គកម្មន្តិ យេ ច តេ ភិក្ខូ ឯវមាហំសុ អកតំ កម្មំ ទុក្កដំ កម្មំ បុន កាតព្វំ កម្មន្តិ ។ ឥមេ តត្ថ ភិក្ខូ ធម្មវាទិនោ ។

[១៦៦] ឥធ បន ភិក្ខវេ ភិក្ខុ ភណ្ឌនការកោ ហោតិ កលហការកោ វិវាទការកោ ភស្សការកោ សង្ឃេ អធិករណការកោ ។ តត្រ ចេ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ ភណ្ឌនការកោ កលហការកោ វិវាទការកោ ភស្សការកោ សង្ឃេ អធិករណការកោ ហន្ទស្ស មយំ



តែមិនប្រកបដោយធម៌ ធ្វើកម្មដល់ភិក្ខុនោះ ។ សង្ឃដែលស្ថិតនៅក្នុងវិវាទនោះ ក៏ទាស់ទែងគ្នាថា កម្មរបស់ភិក្ខុជាពួកតែមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក តែប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួកដែលប្រកបដោយធម៌ប្លម កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម កម្មឈ្មោះថាភិក្ខុមិនធ្វើហើយ កម្មឈ្មោះថាភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាភិក្ខុទាំងនោះ ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ ក៏ុនោះសោត ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មឈ្មោះថាភិក្ខុមិនទាន់ធ្វើហើយ កម្មឈ្មោះថាភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត ។ ភិក្ខុទាំងអម្បាលនេះ ឈ្មោះថាធម្មវាទី ក្នុងកម្មនោះ ។

[១៦៦] ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ ជាអ្នកធ្វើនូវការបង្កហេតុ ជាអ្នកធ្វើនូវជំលោះ ជាអ្នកធ្វើនូវវិវាទ ជាអ្នកធ្វើនូវតិរច្ឆានកថា ជាអ្នកធ្វើនូវអធិករណ៍ក្នុងសង្ឃ ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយមានគំនិតយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯងជាអ្នកធ្វើនូវការបង្កហេតុ ជាអ្នកធ្វើនូវជំលោះ ជាអ្នកធ្វើនូវវិវាទ ជាអ្នកធ្វើនូវតិរច្ឆានកថា ជាអ្នកធ្វើនូវអធិករណ៍ក្នុងសង្ឃ បើដូច្នោះគួរតែយើងទាំងឡាយ

តជ្ជនីយកម្មំ ករោមាតិ ។ តេ តស្ស តជ្ជនីយកម្មំ ករោន្តិ អធម្មេន វគ្គា ។ តត្រដ្ឋោ សង្ឃោ ភណតិ អធម្មេន វគ្គកម្មំ អធម្មេន សមគ្គកម្មំ ធម្មេន វគ្គកម្មំ ធម្មប្បដិរូបកេន វគ្គកម្មំ ធម្មប្បដិរូបកេន សមគ្គកម្មំ អកតំ កម្មំ ទុក្កដំ កម្មំ បុន កាតព្វំ កម្មន្តិ ។ តត្រ ភិក្ខវេ យេ តេ ភិក្ខូ ឯវមាហំសុ អធម្មេន វគ្គកម្មន្តិ យេ ច តេ ភិក្ខូ ឯវមាហំសុ អកតំ កម្មំ ទុក្កដំ កម្មំ បុន កាតព្វំ កម្មន្តិ ។ ឥមេ តត្ថ ភិក្ខូ ធម្មវាទិនោ ។

(១៦៧) ឥធ បន ភិក្ខវេ ភិក្ខុ ភណ្ឌនការកោ ហោតិ កលហការកោ វិវាទការកោ ភស្សការកោ សង្ឃេ អធិករណការកោ ។ តត្រ ចេ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ ភណ្ឌនការកោ កលហការកោ វិវាទការកោ ភស្សការកោ



ធ្វើតជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះជាពួក តែប្រកបដោយអធម៌ ធ្វើតជ្ជនីយកម្មដល់ភិក្ខុនោះ ។ សង្ឃដែលនៅក្នុងទីនោះពោលថាកម្ម ជា កម្មរបស់ភិក្ខុជាពួកទាំងមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក តែប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួកទាំងប្រកបដោយធម៌ប្លម កម្មរបស់ភិក្ខុដែលព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម កម្មឈ្មោះថាភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថាភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាភិក្ខុទាំងនោះ ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មរបស់ភិក្ខុជាពួក តែប្រកបដោយអធម៌ ពុំនោះសោត ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មឈ្មោះថាភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថាភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត ។ ឯភិក្ខុទាំងអម្បាលនេះ ឈ្មោះថាធម្មវាទី ក្នុងកម្មនោះ ។

(១៦៧) ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ ជាអ្នកធ្វើនូវការប្រកួតប្រកាន់ ជាអ្នកធ្វើនូវជំលោះ ជាអ្នកធ្វើនូវវិវាទ ជាអ្នកធ្វើនូវពាក្យឥតប្រយោជន៍ ជាអ្នកធ្វើនូវអធិករណ៍ក្នុងសង្ឃ ។ ក្នុងវត្តនោះ បើភិក្ខុទាំងឡាយគិតឃើញយ៉ាងនេះថា ម្នាលអាវុសោ ភិក្ខុនេះឯងជាអ្នកធ្វើនូវការប្រកួតប្រកាន់ ជាអ្នកធ្វើនូវជំលោះ ជាអ្នកធ្វើនូវវិវាទ ជាអ្នកធ្វើនូវពាក្យ-

សង្ឃេ អធិករណការកោ ហន្ទស្ស មយំ តជ្ជនីយកម្មំ ករោមាតិ ។ តេ តស្ស តជ្ជនីយកម្មំ ករោន្តិ ធម្មប្បដិរូបកេន វគ្គា ។ តត្រដ្ឋោ សង្ឃោ វិវទតិ អធម្មេន វគ្គកម្មំ អធម្មេន សមគ្គកម្មំ ធម្មេន វគ្គកម្មំ ធម្មប្បដិរូបកេន វគ្គកម្មំ ធម្មប្បដិរូបកេន សមគ្គកម្មំ អកតំ កម្មំ ទុក្កដំ កម្មំ បុន កាតព្វំ កម្មន្តិ ។ តត្រ ភិក្ខវេ យេ តេ ភិក្ខូ ឯវមាហំសុ ធម្មប្បដិរូបកេន វគ្គកម្មន្តិ យេ ច តេ ភិក្ខូ ឯវមាហំសុ អកតំ កម្មំ ទុក្កដំ កម្មំ បុន កាតព្វំ កម្មន្តិ ។ ឥមេ តត្ថ ភិក្ខូ ធម្មវាទិនោ ។

[១៦៨] ឥធ បន ភិក្ខវេ ភិក្ខុ ភណ្ឌនការកោ ហោតិ កលហការកោ វិវាទការកោ ភស្សការកោ សង្ឃេ អធិករណការកោ ។ តត្រ ចេ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ ភណ្ឌនការកោ



ករជា ជាអ្នកធ្វើនូវអធិករណ៍ក្នុងសង្ឃ បើដូច្នោះមានតែយើងទាំងឡាយធ្វើតជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះជាពួកទាំងប្រកបដោយធម៌ប្លម ធ្វើតជ្ជនីយកម្មដល់ភិក្ខុនោះ ។ សង្ឃដែលប្រជុំនៅក្នុងទីនោះជជែកគ្នាថា កម្មរបស់ភិក្ខុជាពួកទាំងមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក តែប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួកទាំងប្រកបដោយធម៌ប្លម កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម កម្មឈ្មោះថាភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថាភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត ។ ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុទាំងនោះ ភិក្ខុទាំងឡាយណានិយាយយ៉ាងនេះថា កម្មរបស់ភិក្ខុជាពួកទាំងប្រកបដោយធម៌ប្លម ពុំនោះសោត ភិក្ខុទាំងឡាយណានិយាយយ៉ាងនេះថា កម្មឈ្មោះថាភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថាភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត ។ ភិក្ខុទាំងអម្បាលនេះ ឈ្មោះជាធម្មវាទី ក្នុងកម្មនោះ ។

(១៦៨) ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ភិក្ខុក្នុងសាសនានេះ ជាអ្នកធ្វើនូវការបង្កហេតុ ជាអ្នកធ្វើនូវជំលោះ ជាអ្នកធ្វើនូវវិវាទ ជាអ្នកធ្វើនូវតិរច្ឆានកថា ជាអ្នកធ្វើនូវអធិករណ៍ក្នុងសង្ឃ ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយគិតយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង

កលហការកោ វិវាទការកោ ភស្សការកោ សង្ឃេ អធិករណការកោ ហន្ទស្ស មយំ តជ្ជនីយកម្មំ ករោមាតិ ។ តេ តស្ស តជ្ជនីយកម្មំ ករោន្តិ ធម្មប្បដិរូបកេន សមគ្គា ។ តត្រដ្ឋោ សង្ឃោ វិវទតិ អធម្មេន វគ្គកម្មំ អធម្មេន សមគ្គកម្មំ ធម្មេន វគ្គកម្មំ ធម្មប្បដិរូបកេន វគ្គកម្មំ ធម្មប្បដិរូបកេន សមគ្គកម្មំ អកតំ កម្មំ ទុក្កដំ កម្មំ បុន កាតព្វំ កម្មន្តិ ។ តត្រ ភិក្ខវេ យេ តេ ភិក្ខូ ឯវមាហំសុ ធម្មប្បដិរូបកេន សមគ្គកម្មន្តិ យេ ច តេ ភិក្ខូ ឯវមាហំសុ អកតំ កម្មំ ទុក្កដំ កម្មំ បុន កាតព្វំ កម្មន្តិ ។ ឥមេ តត្ថ ភិក្ខូ ធម្មវាទិនោ ។

[១៦៩] ឥធ បន ភិក្ខវេ ភិក្ខុ ពាលោ ហោតិ អព្យត្តោ អាបត្តិពហុលោ អនបទានោ គិហិសំសដ្ឋោ វិហរតិ អននុលោមិកេហិ គិហិសំសគ្គេហិ ។ តត្រ



ជាអ្នកធ្វើនូវសេចក្ដីឈ្លោះ ជាអ្នកធ្វើនូវជំលោះ ជាអ្នកធ្វើនូវវិវាទ ជាអ្នកធ្វើនូវពាក្យច្រើន ជាអ្នកធ្វើនូវអធិករណ៍ក្នុងសង្ឃ ។ បើដូច្នោះមានតែយើងទាំងឡាយធ្វើតជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះព្រមព្រៀងគ្នា តែប្រកបដោយធម្មប្បដិរូប ធ្វើតជ្ជនីយកម្មដល់ភិក្ខុនោះ ។ សង្ឃដែលនៅក្នុងទីនោះតែងតែពោលថា កម្មរបស់ភិក្ខុជាពួកទាំងមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក តែប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួកទាំងប្រកបដោយធម្មប្បដិរូប កម្មរបស់ភិក្ខុដែលព្រមព្រៀងគ្នា តែប្រកបដោយធម្មប្បដិរូប កម្មឈ្មោះថាភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថាភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាភិក្ខុទាំងនោះ ភិក្ខុទាំងឡាយណានិយាយយ៉ាងនេះថា កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម្មប្បដិរូប មួយទៀត ភិក្ខុទាំងឡាយណានិយាយយ៉ាងនេះថា កម្មឈ្មោះថាភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថាភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត ។ ភិក្ខុទាំងឡាយនេះ ឈ្មោះថាជាធម្មវាទីក្នុងកម្មនោះ ។

[១៦៩] ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ ជាអ្នកល្ងង់មិនឈ្លាសវៃ មានអាបត្តិច្រើន មិនមានការកំណត់អាបត្តិ នៅច្រឡូកច្រឡំដោយគ្រហស្ថ ដោយការច្រឡូកច្រឡំមិនសមគួរ ។ ក្នុងរឿង

៤៥ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ ពាលោ
អព្យត្តោ អាបត្តិពហុលោ អនបទានោ គិហិសំសដ្ឋោ
វិហរតិ អននុលោមិកេហិ គិហិសំសគ្គេហិ ហន្ទស្ស
មយំ និយស្សកម្មំ ករោមាតិ ។ តេ តស្ស និយស្សកម្មំ
ករោន្តិ អធម្មេន វគ្គា ។ បេ ។ អធម្មេន សមគ្គា ។
ធម្មេន វគ្គា ។ ធម្មប្បដិរូបកេន វគ្គា ។ ធម្មប្បដិរូបកេន
សមគ្គា ។ តត្រដ្ឋោ សង្ឃោ វិវទតិ អធម្មេន វគ្គកម្មំ
អធម្មេន សមគ្គកម្មំ ធម្មេន វគ្គកម្មំ ធម្មប្បដិរូបកេន
វគ្គកម្មំ ធម្មប្បដិរូបកេន សមគ្គកម្មំ អកតំ កម្មំ
ទុក្កដំ កម្មំ បុន កាតព្វំ កម្មន្តិ ។ តត្រ ភិក្ខវេ
យេ តេ ភិក្ខូ ឯវមាហំសុ ធម្មប្បដិរូបកេន សមគ្គ
កម្មន្តិ យេ ច តេ ភិក្ខូ ឯវមាហំសុ អកតំ កម្មំ



នោះ បើភិក្ខុទាំងឡាយគិតឃើញយ៉ាងនេះថា ម្នាលអាវុសោ ភិក្ខុ
នេះឯងជាអ្នកល្ងង់មិនឈ្លាសមានអាបត្តិច្រើន មិនមានការកំណត់អាបត្តិ នៅ
ច្រឡូកច្រឡំដោយគ្រហស្ថ ដោយការច្រឡូកច្រឡំមិនសមគួរ បើដូច្នោះ
មានតែយើងទាំងឡាយធ្វើនិយស្សកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះជាពួក
ទាំងមិនប្រកបដោយធម៌ ធ្វើនិយស្សកម្មដល់ភិក្ខុនោះ ។ បេ ។ ព្រមព្រៀង
គ្នា តែមិនប្រកបដោយធម៌ ។ ជាពួក តែប្រកបដោយធម៌ ។ ជាពួកទាំងប្រ
កបដោយធម៌ប្លម ។ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម ។ សង្ឃដែល
ឋិតនៅក្នុងទីនោះវិវាទគ្នាថា កម្មរបស់ភិក្ខុជាពួកទាំងមិនប្រកបដោយធម៌
កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក
តែប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួកទាំងប្រកបដោយធម៌ប្លម កម្មរបស់
ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម កម្មឈ្មោះថាភិក្ខុមិនបានធ្វើ
ហើយ កម្មឈ្មោះថាភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត ។ ម្នាល
ភិក្ខុទាំងឡាយ បណ្តាភិក្ខុទាំងនោះ ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះ
ថា កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម ពួកនោះ ១ ភិក្ខុ
ទាំងឡាយណា និយាយយ៉ាងនេះថា កម្មឈ្មោះថាភិក្ខុមិនបានធ្វើហើយ

ទុក្កដំ កម្មំ បុន កាតព្វំ កម្មន្តិ ។ ឥមេ តត្ថ ភិក្ខូ ធម្មវាទិនោ ។ ឥមេ បញ្ច វារា សំខិត្តា ។

(៤៣០) ឥធ បន ភិក្ខវេ ភិក្ខុ កុលទូសកោ ហោតិ បាបសមាចារោ ។ តត្រ ចេ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ កុលទូសកោ បាបសមាចារោ ហន្ទស្ស មយំ បព្វាជនីយកម្មំ ករោមាតិ ។ តេ តស្ស បព្វាជនីយកម្មំ ករោន្តិ អធម្មេន វគ្គា ។ បេ ។ អធម្មេន សមគ្គា ។ ធម្មេន វគ្គា ។ ធម្មប្បតិរូបកេន វគ្គា ។ ធម្មប្បតិរូបកេន សមគ្គា ។ តត្រដ្ឋោ សង្ឃោ វិវទតិ អធម្មេន វគ្គកម្មំ អធម្មេន សមគ្គកម្មំ ធម្មេន វគ្គកម្មំ ធម្មប្បតិរូបកេន វគ្គកម្មំ ធម្មប្បតិរូបកេន សមគ្គកម្មំ អកតំ កម្មំ ទុក្កដំ កម្មំ បុន កាតព្វំ កម្មន្តិ ។ តត្រ ភិក្ខវេ យេ តេ ភិក្ខូ



កម្មឈ្មោះថាភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត ។ ភិក្ខុទាំងអម្បាលនេះ ឈ្មោះថាជាអ្នកពោលត្រូវតាមធម៌ ។ វារៈទាំង ៥ ប្រការនេះជាសេចក្តីសង្ខេប ។

(៤៣០) ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រទូស្តត្រកូល ជាអ្នកមានមារយាទអាក្រក់ ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯងជាអ្នកប្រទូស្តត្រកូល ជាអ្នកមានមារយាទអាក្រក់ បើដូច្នោះមានតែយើងទាំងឡាយធ្វើបព្វាជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះជាពួកទាំងមិនប្រកបដោយធម៌ ធ្វើបព្វាជនីយកម្មដល់ភិក្ខុនោះ ។ បេ ។ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ ។ ជាពួក តែប្រកបដោយធម៌ ។ ជាពួកទាំងប្រកបដោយធម៌ប្លម ។ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម ។ សង្ឃដែលមិននៅក្នុងវិវាទនោះ ថែកគ្នាថា កម្មរបស់ភិក្ខុជាពួកទាំងមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក តែប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួកទាំងប្រកបដោយធម៌ប្លម កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម កម្មឈ្មោះថាភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថាភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត ។ ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុទាំងនោះ បើភិក្ខុទាំងឡាយណា

ឯវមាហំសុ ធម្មប្បដិរូបកេន សមគ្គកម្មន្តិ យេ ច តេ ភិក្ខូ ឯវមាហំសុ អកតំ កម្មំ ទុក្កដំ កម្មំ បុន កាតព្វំ កម្មន្តិ ។ ឥមេ តត្ថ ភិក្ខូ ធម្មវាទិនោ ។ ឥមេ បញ្ចក សត្តិកា ។

(១៣១) ឥធ បន ភិក្ខវេ ភិក្ខុ គិហី អក្កោសតិ បរិភាសតិ ។ តត្រ ចេ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ គិហី អក្កោសតិ បរិភាសតិ ហន្ទស្ស មយំ បដិសារណីយកម្មំ ករោមាតិ ។ តេ តស្ស បដិសារណីយកម្មំ ករោន្តិ អធម្មេន វគ្គា ។ បេ ។ អធម្មេន សមគ្គា ។ ធម្មេន វគ្គា ។ ធម្មប្បដិរូបកេន វគ្គា ។ ធម្មប្បដិរូបកេន សមគ្គា ។ តត្រដ្ឋោ សង្ឃោ វិវទតិ អធម្មេន វគ្គកម្មំ អធម្មេន សមគ្គកម្មំ ធម្មេន វគ្គកម្មំ ធម្មប្បដិរូបកេន វគ្គកម្មំ ធម្មប្បដិរូបកេន សមគ្គកម្មំ អកតំ កម្មំ ទុក្កដំ កម្មំ



និយាយយ៉ាងនេះថា កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម ពុំគោរពសោត ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មឈ្មោះថា ភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថាភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត ។ ភិក្ខុទាំងអម្បាលនេះ ឈ្មោះថាជាធម្មវាទីក្នុងហេតុនោះ ។ ការទាំង៥ប្រការនេះជាសេចក្ដីសង្ខេប ។

(១៣១) ម្នាលភិក្ខុទាំងឡាយ នៃយមួយទៀត ភិក្ខុក្នុងសាសនានេះ ជេរប្រទេចពួកគ្រហស្ថ ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយគិតឃើញយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯងជេរប្រទេចពួកគ្រហស្ថ បើដូច្នោះមានតែយើងទាំងឡាយធ្វើបដិសារណីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះជាពួកទាំងមិនប្រកបដោយធម៌ ធ្វើបដិសារណីយកម្មដល់ភិក្ខុនោះ ។ បេ ។ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ ។ ជាពួក តែប្រកបដោយធម៌ ។ ជាពួកទាំងប្រកបដោយធម៌ប្លម ។ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម ។ សង្ឃដែលឋិតនៅក្នុងវិវាទនោះជជែកគ្នាថា កម្មរបស់ភិក្ខុជាពួកទាំងមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក តែប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួកទាំងប្រកបដោយធម៌ប្លម កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម កម្មឈ្មោះថាភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថាភិក្ខុធ្វើអាក្រក់

បុន កាតព្វំ កម្មន្តិ ។ តត្រ ភិក្ខវេ យេ តេ ភិក្ខូ ឯវមាហំសុ ធម្មប្បតិរូបកេន សមគ្គកម្មន្តិ យេ ច តេ ភិក្ខូ ឯវមាហំសុ អកតំ កម្មំ ទុក្កដំ កម្មំ បុន កាតព្វំ កម្មន្តិ ។ ឥមេ តត្ថ ភិក្ខូ ធម្មវាទិនោ ។ ឥមេ បញ្ច វារា សង្ខិត្តា ។

(១៣៦) ឥធ បន ភិក្ខវេ ភិក្ខុ អាបត្តឹ អាបជ្ជិត្វា ន ឥច្ឆតិ អាបត្តឹ បស្សិតុំ ។ តត្រ ចេ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ អាបត្តឹ អាបជ្ជិត្វា ន ឥច្ឆតិ អាបត្តឹ បស្សិតុំ ហន្ទស្ស មយំ អាបត្តិយា អទស្សនេ ឧក្ខេបនីយកម្មំ ករោមាតិ ។ តេ តស្ស អាបត្តិយា អទស្សនេ ឧក្ខេបនីយកម្មំ ករោន្តិ អធម្មេន វគ្គា ។ បេ ។ អធម្មេន សមគ្គា ។ ធម្មេន វគ្គា ។ ធម្មប្បតិរូបកេន វគ្គា ។ ធម្មប្បតិរូបកេន សមគ្គា ។ តត្រដ្ឋោ



ហើយ កម្មត្រូវធ្វើទៀត ។ ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុទាំងនោះ ភិក្ខុទាំងឡាយណានិយាយយ៉ាងនេះថា កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្តូម គួរនោះសោត ភិក្ខុទាំងឡាយណានិយាយយ៉ាងនេះថា កម្មឈ្មោះថាភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថាភិក្ខុធ្វើអាក្រក់ហើយ កម្មត្រូវធ្វើទៀត ។ ភិក្ខុទាំងអម្បាលនេះ ឈ្មោះថាជាធម្មវាទីក្នុងកម្មនោះ ។ វារៈទាំង៥នេះជាសេចក្តីសង្ខេប ។

(១៣៦) ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះត្រូវអាបត្តិហើយ មិនប្រាថ្នានឹងឃើញនូវអាបត្តិ (នោះ) ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯងត្រូវអាបត្តិហើយ មិនប្រាថ្នានឹងឃើញនូវអាបត្តិ បើដូច្នោះមានតែយើងទាំងឡាយធ្វើឧក្ខេបនីយកម្មព្រោះមិនឃើញនូវអាបត្តិដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះជាពួកនាំគ្នាមិនប្រកបដោយធម៌ ធ្វើឧក្ខេបនីយកម្មព្រោះមិនឃើញនូវអាបត្តិដល់ភិក្ខុនោះ ។ បេ ។ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ ។ ជាពួក តែប្រកបដោយធម៌ ។ ជាពួកទាំងប្រកបដោយធម៌ប្តូម ។ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្តូម ។ សង្ឃដែលឋិតនៅក្នុងទីនោះ

សាវេត្វា វិធតិ អធម្មេន វគ្គកម្មំ អធម្មេន សមគ្គកម្មំ ធម្មេន វគ្គកម្មំ ធម្មប្បតិរូបកេន វគ្គកម្មំ ធម្មប្បតិរូបកេន សមគ្គកម្មំ អកតំ កម្មំ ទុក្កដំ កម្មំ បុន កាតព្វំ កម្មន្តិ ។ តត្រ ភិក្ខវេ យេ តេ ភិក្ខូ ឯវមាហំសុ ធម្មប្ប-តិរូបកេន សមគ្គកម្មន្តិ យេ ច តេ ភិក្ខូ ឯវមាហំសុ អកតំ កម្មំ ទុក្កដំ កម្មំ បុន កាតព្វំ កម្មន្តិ ។ ឥមេ តត្ថ ភិក្ខូ ធម្មវាទិនោ ។ ឥមេ បញ្ច ភាគ សង្ខិត្តា ។

ឥធ បន ភិក្ខវេ ភិក្ខុ អាបត្តឹ អាបន្នោ ន ឥច្ឆតិ អាបត្តឹ បដិកាតុំ ។ តត្រ ចេ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ អាបត្តឹ អាបន្នោ ន ឥច្ឆតិ អាបត្តឹ បដិ-កាតុំ ហន្ទស្ស មយំ អាបត្តិយា អប្បដិកម្មេ ឧក្ខេបនីយកម្មំ ករោមាតិ ។ តេ តស្ស អាបត្តិយា អប្បដិកម្មេ ឧក្ខេបនីយកម្មំ ករោន្តិ អធម្មេន វគ្គា



ជាវគ្គកាថា កម្មរបស់ភិក្ខុជាពួកតាំងមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក តែប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួកតាំងប្រកបដោយធម៌ក្លែង កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ក្លែង កម្មឈ្មោះថាភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថាភិក្ខុធ្វើខុសហើយ កម្មភិក្ខុត្រូវធ្វើទៀត ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាភិក្ខុទាំងនោះ ភិក្ខុទាំងឡាយណានិយាយយ៉ាងនេះថា កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ក្លែង ពួកនោះផង ភិក្ខុទាំងឡាយណានិយាយយ៉ាងនេះថា កម្មឈ្មោះថាភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថាភិក្ខុធ្វើខុសហើយ កម្មភិក្ខុត្រូវធ្វើទៀត ។ ឯភិក្ខុទាំងឡាយនេះ ឈ្មោះថាជាធម្មវាទីក្នុងកម្មនោះ ។ ភ. ទាំងប្រាំនេះជាសេចក្ដីសង្ខេប ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិហើយ មិនប្រាថ្នានឹងសំដែងអាបត្តិចេញ ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯងត្រូវអាបត្តិហើយ មិនប្រាថ្នានឹងសំដែងអាបត្តិ បើដូច្នោះមានតែយើងទាំងឡាយធ្វើឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះជាពួកតាំងមិនប្រកបដោយធម៌ ធ្វើឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញដល់ភិក្ខុនោះ

។ បេ ។ អធម្មេន សមគ្គា ។ ធម្មេន វគ្គា ។ ធម្មប្ប-
ដិរូបកេន វគ្គា ។ ធម្មប្បដិរូបកេន សមគ្គា ។ តត្រដ្ឋា
សាវេត្វា វិវទតិ អធម្មេន វគ្គកម្មំ អធម្មេន សមគ្គកម្មំ
ធម្មេន វគ្គកម្មំ ធម្មប្បដិរូបកេន វគ្គកម្មំ ធម្មប្បដិរូបកេន
សមគ្គកម្មំ អកតំ កម្មំ ទុក្កដំ កម្មំ បុន កាតព្វំ
កម្មន្តិ ។ តត្រ ភិក្ខូ យេ តេ ភិក្ខូ ឯវមាហំសុ ធម្មប្ប-
ដិរូបកេន សមគ្គកម្មន្តិ យេ ច តេ ភិក្ខូ ឯវមាហំសុ
អកតំ កម្មំ ទុក្កដំ កម្មំ បុន កាតព្វំ កម្មន្តិ ។ ឥមេ
តត្ថ ភិក្ខូ ធម្មវាទិនោ ។ ឥមេ បញ្ច កក សង្ខិត្តា ។ ឥធ
បន ភិក្ខុ ភិក្ខុ ន ឥច្ឆតិ បាបិកំ ទិដ្ឋឹ បដិនិស្សជ្ជិតុំ ។
តត្រ ចេ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ
ភិក្ខុ ន ឥច្ឆតិ បាបិកំ ទិដ្ឋឹ បដិនិស្សជ្ជិតុំ ហន្ទស្ស



។ បេ ។ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ ។ ជាពួក តែប្រកប
ដោយធម៌ ។ ជាពួកដែលប្រកបដោយធម៌ប្លម ។ ព្រមព្រៀងគ្នា តែ
ប្រកបដោយធម៌ប្លម ។ សង្ឃដែលបែកទៅក្នុងទីនោះនិយាយគ្នាថា កម្ម
របស់ភិក្ខុជាពួកដែលមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែ
មិនប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក តែប្រកបដោយធម៌ កម្មរបស់
ភិក្ខុជាពួកដែលប្រកបដោយធម៌ប្លម កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកប
ដោយធម៌ប្លម កម្មឈ្មោះថាភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថាភិក្ខុធ្វើអា-
ក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាភិក្ខុទាំង
នោះ ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មរបស់ភិក្ខុព្រមព្រៀង
គ្នា តែប្រកបដោយធម៌ប្លម [illegible] ភិក្ខុទាំងឡាយណា និយាយ
យ៉ាងនេះថា កម្មឈ្មោះថាភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថាភិក្ខុធ្វើអាក្រក់
ហើយ កម្មភិក្ខុត្រូវធ្វើទៀត ។ ភិក្ខុទាំងអម្បាលនេះឈ្មោះថាជាធម្មវាទី
ក្នុងកម្មនោះ ។ [illegible] ទាំង ៥ ប្រការនេះជាសេចក្ដីសង្ខេប ។ ម្នាលភិក្ខុទាំងឡាយ
មួយទៀត ភិក្ខុក្នុងសាសនានេះ មិនប្រាថ្នានឹងលះបង់ទិដ្ឋិអាក្រក់ចេញ ។
ក្នុងរឿងនោះ បើភិក្ខុទាំងឡាយគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំង
ឡាយ ភិក្ខុនេះឯងមិនប្រាថ្នានឹងលះបង់ទិដ្ឋិអាក្រក់ចេញសោះ បើដូច្នោះ

មយំ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយ-
កម្មំ ករោមាតិ ។ តេ តស្ស បាបិកាយ ទិដ្ឋិយា
អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មំ ករោន្តិ អធម្មេន វគ្គា
។ បេ ។ អធម្មេន សមគ្គា ។ ធម្មេន វគ្គា ។ ធម្មប្បដិ-
រូបកេន វគ្គា ។ ធម្មប្បដិរូបកេន សមគ្គា ។ តត្រដ្ឋោ
សង្ឃោ វិវទតិ អធម្មេន វគ្គកម្មំ អធម្មេន សមគ្គកម្មំ
ធម្មេន វគ្គកម្មំ ធម្មប្បដិរូបកេន វគ្គកម្មំ ធម្មប្ប-
ដិរូបកេន សមគ្គកម្មំ អកតំ កម្មំ ទុក្កដំ កម្មំ
បុន កាតព្វំ កម្មន្តិ ។ តត្រ ភិក្ខូ យេ តេ ភិក្ខូ ឯវមា-
ហំសុ ធម្មប្បដិរូបកេន សមគ្គកម្មន្តិ យេ ច តេ ភិក្ខូ
ឯវមាហំសុ អកតំ កម្មំ ទុក្កដំ កម្មំ បុន កាតព្វំ
កម្មន្តិ ។ ឥមេ តត្ថ ភិក្ខូ ធម្មវាទិនោ ។ ឥមេ បញ្ច-
កា សង្ខិត្តា ។



ចាំតែយើងទាំងឡាយធ្វើនូវឧក្ខេបនីយកម្ម ព្រោះមិនលះបង់នូវទិដ្ឋិអាក្រក់ដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះជាពួកដែលមិនប្រកបដោយធម៌ ធ្វើនូវឧក្ខេបនីយកម្ម ព្រោះមិនលះបង់នូវទិដ្ឋិអាក្រក់ដល់ភិក្ខុនោះ ។ បេ ។ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ ។ ជាពួក តែប្រកបដោយធម៌ ។ ជាពួកដែលប្រកបដោយធម៌ប្លម ។ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម ។ សង្ឃដែលឋិតនៅក្នុងទីនោះក៏ជែកគ្នាថា កម្មរបស់ភិក្ខុជាពួកដែលមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក តែប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួកដែលប្រកបដោយធម៌ប្លម កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម កម្មឈ្មោះថាភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថាភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាភិក្ខុទាំងនោះ ភិក្ខុទាំងឡាយណានិយាយយ៉ាងនេះថា កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម ពួកនោះ ឯភិក្ខុទាំងឡាយណានិយាយយ៉ាងនេះថា កម្មឈ្មោះថាភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថាភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត ។ ភិក្ខុទាំងអម្បាលនេះ ឈ្មោះថាជាធម្មវាទីក្នុងកម្មនោះ ។ បញ្ចកៈទាំងប្រាំនេះជាសេចក្ដីសង្ខេប ។

(១៣៣) ឥធ បន ភិក្ខវេ ភិក្ខុ សង្ឃេន តជ្ជនីយ-កម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ តជ្ជនីយកម្មស្ស បដិប្បស្សទ្ធឹ យាចតិ ។ តត្រ ចេ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សង្ឃេន តជ្ជនីយកម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ តជ្ជនីយកម្មស្ស បដិប្បស្សទ្ធឹ យាចតិ ហន្ទស្ស មយំ តជ្ជនីយកម្មំ បដិប្បស្សម្ភេមាតិ ។ តេ តស្ស តជ្ជនីយកម្មំ បដិប្បស្សម្ភេន្តិ អធម្មេន វគ្គា ។ តត្រដ្ឋោ សង្ឃោ វិវទតិ អធម្មេន វគ្គកម្មំ អធម្មេន សមគ្គកម្មំ ធម្មេន វគ្គកម្មំ ធម្មប្បដិរូបកេន វគ្គកម្មំ ធម្មប្បដិរូបកេន សមគ្គកម្មំ អកតំ កម្មំ ទុក្កដំ កម្មំ បុន កាតព្វំ កម្មន្តិ ។ តត្រ ភិក្ខវេ យេ តេ ភិក្ខូ ឯវមាហំសុ អធម្មេន វគ្គកម្មន្តិ





(១៣៣) ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុក្នុងសាសនានេះ សង្ឃបានធ្វើតជ្ជនីយកម្មហើយ ក៏ប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្ងំរោម ប្រព្រឹត្តវត្តល្មមដល់កិរិយាលោះសេចក្តីចេញចាកកម្មហើយ មកសូមការរម្ងាប់តជ្ជនីយកម្ម (នឹងសង្ឃ) ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយគិតឃើញថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯងដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយ ក៏ប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្ងំរោម ប្រព្រឹត្តវត្តល្មមដល់កិរិយាលោះសេចក្តីចេញចាកកម្ម ឥឡូវមកសូមការរម្ងាប់តជ្ជនីយកម្ម (នោះ) បើដូច្នោះមានតែយើងទាំងឡាយរម្ងាប់តជ្ជនីយកម្មដល់ភិក្ខុនេះចុះ ។ ភិក្ខុទាំងនោះជាពួកទាំងមិនប្រកបដោយធម៌ រម្ងាប់តជ្ជនីយកម្មដល់ភិក្ខុនោះ ។ សង្ឃដែលឋិតនៅក្នុងទីនោះតែងទាស់ថា កម្មរបស់ភិក្ខុជាពួកទាំងមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក តែប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួកទាំងប្រកបដោយធម៌ប្លម កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម កម្មឈ្មោះថាភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថាភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត ។ ម្នាលភិក្ខុទាំងឡាយ ចំណែកភិក្ខុទាំងនោះ ភិក្ខុទាំងឡាយណានិយាយយ៉ាងនេះថា កម្មរបស់ភិក្ខុជាពួកទាំងមិនប្រកបដោយធម៌

យេ ច តេ ភិក្ខូ ឯវមាហំសុ អកតំ កម្មំ ទុក្កដំ កម្មំ បុន កាតព្វំ កម្មន្តិ ។ ឥមេ តត្ថ ភិក្ខូ ធម្មវាទិនោ ។

[១៣៤] ឥធ បន ភិក្ខវេ ភិក្ខុ សង្ឃេន តជ្ជនីយកម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ តជ្ជនីយកម្មស្ស បដិប្បស្សទ្ធិំ យាចតិ ។ តត្រ ចេ ភិក្ខូ ឯវំ វទន្តិ អយំ ខោ អាវុសោ ភិក្ខុ សង្ឃេន តជ្ជនីយកម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ តជ្ជនីយកម្មស្ស បដិប្បស្សទ្ធិំ យាចតិ ហន្ទស្ស មយំ តជ្ជនីយកម្មំ បដិប្បស្សម្ភេមាតិ ។ តេ តស្ស តជ្ជនីយកម្មំ បដិប្បស្សម្ភេន្តិ អធម្មេន សមគ្គា ។ តត្រដ្ឋោ សង្ឃោ វិវទតិ អធម្មេន វគ្គកម្មំ អធម្មេន សមគ្គកម្មំ ធម្មេន វគ្គកម្មំ ធម្មប្បដិរូបកេន វគ្គកម្មំ ធម្មប្បដិរូបកេន សមគ្គកម្មំ អកតំ កម្មំ ទុក្កដំ កម្មំ



ពួកនោះទៀត ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មឈ្មោះថាភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថាភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀតៗ ភិក្ខុទាំងឡាយនេះឈ្មោះថាជាធម្មវាទីក្នុងកម្មនោះ ។

(១៣៤) ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ សង្ឃបានធ្វើតជ្ជនីយកម្មហើយ ប្រព្រឹត្តត្រូវដោយប្រពៃ ទាំងសម្រួបរោម ប្រព្រឹត្តត្រូវដល់កិរិយារលាស់ចេញចាកកម្មហើយ មកសូមការរម្ងាប់តជ្ជនីយកម្ម ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយតែងពោលយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯងសង្ឃបានធ្វើតជ្ជនីយកម្មហើយ ក៏បានប្រព្រឹត្តត្រូវដោយប្រពៃ ទាំងសម្រួបរោម ប្រព្រឹត្តត្រូវដល់កិរិយារលាស់ចេញចាកកម្ម ឥឡូវមកសូមការរម្ងាប់តជ្ជនីយកម្ម (នោះ) បើដូច្នោះគួរតែយើងទាំងឡាយរម្ងាប់តជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងឡាយនោះព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌រម្ងាប់តជ្ជនីយកម្មដល់ភិក្ខុនោះ ។ សង្ឃដែលប៉ះនៅក្នុងទីនោះជជែកគ្នាថា កម្មរបស់ភិក្ខុជាពួកទាំងមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក តែប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួកតែប្រកបដោយធម៌ប្លម កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម កម្មឈ្មោះថាភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថាភិក្ខុធ្វើអាក្រក់ហើយ

បុន កាតព្វំ កម្មន្តិ ។ តត្រ ភិក្ខវេ យេ តេ ភិក្ខូ ឯវមាហំសុ អធម្មេន សមគ្គកម្មន្តិ យេ ច តេ ភិក្ខូ ឯវមាហំសុ អកតំ កម្មំ ទុក្កដំ កម្មំ បុន កាតព្វំ កម្មន្តិ ។ ឥមេ តត្ថ ភិក្ខូ ធម្មវាទិនោ ។

(១៣៩) ឥធ បន ភិក្ខវេ ភិក្ខុ សង្ឃេន តជ្ជនីយកម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ តជ្ជនីយស្ស កម្មស្ស បដិប្បស្សទ្ធឹ យាចតិ ។ តត្រ ចេ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សង្ឃេន តជ្ជនីយកម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ តជ្ជនីយស្ស កម្មស្ស បដិប្បស្សទ្ធឹ យាចតិ ហន្ទស្ស មយំ តជ្ជនីយកម្មំ បដិប្បស្សម្ភេមាតិ ។ តេ តស្ស តជ្ជនីយកម្មំ បដិប្បស្សម្ភេន្តិ អធម្មេន វគ្គា ។ តត្រ ចេ សង្ឃោ វិវទតិ អធម្មេន វគ្គកម្មំ អធម្មេន សមគ្គកម្មំ ធម្មេន វគ្គកម្មំ ធម្មប្បដិរូបកេន វគ្គកម្មំ ធម្មប្បដិរូបកេន





កម្មភិក្ខុគប្បីធ្វើទៀត ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាភិក្ខុទាំងនោះ បើភិក្ខុទាំងឡាយណានិយាយយ៉ាងនេះថា កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ ក៏ឯសោតភិក្ខុទាំងឡាយណានិយាយយ៉ាងនេះថា កម្មឈ្មោះថាភិក្ខុមិនបានធ្វើ ហើយកម្មឈ្មោះថាភិក្ខុធ្វើអាក្រក់ ហើយកម្មភិក្ខុគប្បីធ្វើទៀត ។ ភិក្ខុទាំងអម្បាលនេះ ឈ្មោះថាជាធម្មវាទីក្នុងកម្មនោះ ។

(១៣៩) ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុក្នុងសាសនានេះ សង្ឃបានធ្វើតជ្ជនីយកម្មហើយ ក៏ប្រព្រឹត្តត្រូវដោយប្រពៃ ចុះសម្រួលរោម ប្រព្រឹត្តតាមដល់កិរិយារលាស់ចេញចាកកម្ម ហើយមកសូមការរម្ងាប់តជ្ជនីយកម្ម ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯងដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយ ក៏ប្រព្រឹត្តត្រូវដោយប្រពៃ ចុះសម្រួលរោម ប្រព្រឹត្តតាមដល់កិរិយារលាស់ចេញចាកកម្ម ទើបមកសូមការរម្ងាប់តជ្ជនីយកម្ម បើដូច្នោះមានតែយើងទាំងឡាយរម្ងាប់តជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះជាពួក តែប្រកបដោយអធម៌រម្ងាប់តជ្ជនីយកម្មដល់ភិក្ខុនោះ ។ សង្ឃដែលបែកនៅក្នុងទីនោះជាផែកគ្នាថា កម្មរបស់ភិក្ខុជាពួកទាំងមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក តែប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួកទាំងប្រកបដោយធម៌ប្លម កម្មរបស់ភិក្ខុព្រមព្រៀងគ្នា

សមគ្គកម្មំ អកតំ កម្មំ ទុក្កដំ កម្មំ បុន កាតព្វំ កម្មន្តិ ។ តត្រ ភិក្ខវេ យេ តេ ភិក្ខូ ឯវមាហំសុ អធម្មេន វគ្គកម្មន្តិ យេ ច តេ ភិក្ខូ ឯវមាហំសុ អកតំ កម្មំ ទុក្កដំ កម្មំ បុន កាតព្វំ កម្មន្តិ ។ ឥមេ តត្ថ ភិក្ខូ ធម្មវាទិនោ ។

[១៣៦] ឥធ បន ភិក្ខវេ ភិក្ខុ សង្ឃេន តជ្ជនីយកម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ តជ្ជនីយកម្មស្ស បដិប្បស្សទ្ធិំ យាចតិ ។ តត្រ ចេ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សង្ឃេន តជ្ជនីយកម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ តជ្ជនីយកម្មស្ស បដិប្បស្សទ្ធិំ យាចតិ ហន្ទស្ស មយំ តជ្ជនីយកម្មំ បដិប្បស្សម្ភេមាតិ ។ តេ តស្ស តជ្ជនីយកម្មំ បដិប្បស្សម្ភេន្តិ ធម្មប្បដិរូបកេន វគ្គា ។ តត្រដ្ឋោ សង្ឃោ វិវទតិ អធម្មេន វគ្គកម្មំ



តែប្រកបដោយធម៌ប្លម កម្មឈ្មោះថាភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថា ភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាភិក្ខុទាំងនោះ ភិក្ខុទាំងឡាយណានិយាយយ៉ាងនេះថា កម្មរបស់ភិក្ខុជាពួកទាំងមិនប្រកបដោយធម៌ ពួកនោះសោតភិក្ខុទាំងឡាយណានិយាយយ៉ាងនេះថា កម្មឈ្មោះថាភិក្ខុបានធ្វើហើយ កម្មឈ្មោះថាភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត ។ ភិក្ខុទាំងអម្បាលនេះឈ្មោះថាជាធម្មវាទីក្នុងកម្មនោះ ។

(១៣៦) ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុក្នុងសាសនានេះ សង្ឃបានធ្វើតជ្ជនីយកម្មហើយ ក៏ប្រព្រឹត្តត្រូវដោយប្រពៃ ទាំងសម្រួមរោម ប្រព្រឹត្តត្រូវដល់កិរិយាលោះចេញចាកកម្ម ហើយមកសូមការរម្ងាប់តជ្ជនីយកម្ម ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយគិតយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯងដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយ ក៏ប្រព្រឹត្តត្រូវដោយប្រពៃ ទាំងសម្រួមរោម ប្រព្រឹត្តត្រូវដល់កិរិយាលោះចេញចាកកម្ម ត្រឡប់មកសូមការរម្ងាប់តជ្ជនីយកម្ម (នោះ) បើដូច្នោះមានតែយើងទាំងឡាយរម្ងាប់តជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះជាពួកទាំងប្រកបដោយធម៌ប្លមរម្ងាប់តជ្ជនីយកម្មដល់ភិក្ខុនោះ ។ សង្ឃដែលបាននៅក្នុងទីនោះឈ្លោះគ្នាថា កម្មរបស់ភិក្ខុជាពួកទាំងមិនប្រកបដោយធម៌

អធម្មេន សមគ្គកម្មំ ធម្មេន វគ្គកម្មំ ធម្មប្បដិរូបកេន វគ្គកម្មំ ធម្មប្បដិរូបកេន សមគ្គកម្មំ អកតំ កម្មំ ទុក្កដំ កម្មំ បុន កាតព្វំ កម្មន្តិ ។ តត្រ ភិក្ខវេ យេ តេ ភិក្ខូ ឯវមាហំសុ ធម្មប្បដិរូបកេន វគ្គកម្មន្តិ យេ ច តេ ភិក្ខូ ឯវមាហំសុ អកតំ កម្មំ ទុក្កដំ កម្មំ បុន កាតព្វំ កម្មន្តិ ។ ឥមេ តត្ថ ភិក្ខូ ធម្មវាទិនោ ។

(១៣៧) ឥធ បន ភិក្ខវេ ភិក្ខុ សង្ឃេន ឧក្ខេបនីយកម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ ឧក្ខេបនីយកម្មស្ស បដិប្បស្សទ្ធឹ យាចតិ ។ តត្រ ចេ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សង្ឃេន ឧក្ខេបនីយកម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ ឧក្ខេបនីយកម្មស្ស បដិប្បស្សទ្ធឹ យាចតិ ហន្ទស្ស



កម្មរបស់ភិក្ខុព្រមព្រៀងគ្នា ដែលមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក ដែលប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួកដែលប្រកបដោយធម៌ប្លម កម្មរបស់ភិក្ខុព្រមព្រៀងគ្នា ដែលប្រកបដោយធម៌ប្លម កម្មឈ្មោះថាភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថាភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត ។ ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុទាំងនោះ ភិក្ខុទាំងឡាយណានិយាយយ៉ាងនេះថា កម្មរបស់ភិក្ខុជាពួកដែលប្រកបដោយធម៌ប្លម ពុំនោះសោតភិក្ខុទាំងឡាយណានិយាយយ៉ាងនេះថា កម្មឈ្មោះថាភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថាភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត ។ ភិក្ខុទាំងអម្បាលនេះឈ្មោះថាជាធម្មវាទីក្នុងកម្មនោះ ។

(១៣៧) ម្នាលភិក្ខុទាំងឡាយ ចំណែកមួយទៀត ភិក្ខុក្នុងសាសនានេះ សង្ឃបានលើកឧក្ខេបនីយកម្មហើយ ក៏ប្រព្រឹត្តតែដោយប្រពៃ ទាំងសម្ងប់រោម ប្រព្រឹត្តវត្តគួរដល់ការយាសចេញចាកកម្ម ហើយមកសូមការរម្ងាប់ឧក្ខេបនីយកម្ម ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯងដែលសង្ឃបានលើកឧក្ខេបនីយកម្មហើយ ក៏ប្រព្រឹត្តតែដោយប្រពៃ ទាំងសម្ងប់រោម ប្រព្រឹត្តវត្តគួរដល់ការយាសចេញចាកកម្ម ក៏ចូលមកសូមការរម្ងាប់ឧក្ខេបនីយកម្ម (នោះ) បើដូច្នោះមានតែ

មយំ តជ្ជនីយកម្មំ បដិប្បស្សម្ភេមាតិ ។ តេ តស្ស
តជ្ជនីយកម្មំ បដិប្បស្សម្ភេន្តិ ធម្មប្បតិរូបកេន សមគ្គា ។
តត្រដ្ឋោ សង្ឃោ វិវទតិ អធម្មេន វគ្គកម្មំ អធម្មេន
សមគ្គកម្មំ ធម្មេន វគ្គកម្មំ ធម្មប្បតិរូបកេន វគ្គកម្មំ
ធម្មប្បតិរូបកេន សមគ្គកម្មំ អកតំ កម្មំ ទុក្កដំ កម្មំ
បុន កាតព្វំ កម្មន្តិ ។ តត្រ ភិក្ខវេ យេ តេ ភិក្ខូ
ឯវមាហំសុ ធម្មប្បតិរូបកេន សមគ្គកម្មន្តិ យេ ច តេ
ភិក្ខូ ឯវមាហំសុ អកតំ កម្មំ ទុក្កដំ កម្មំ បុន កាតព្វំ
កម្មន្តិ ។ ឥមេ តត្ថ ភិក្ខូ ធម្មវាទិនោ ។

(១៣៨) ឥធ បន ភិក្ខវេ ភិក្ខុ សង្ឃេន និយស្ស-
កម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ
និយស្សកម្មស្ស បដិប្បស្សទ្ធឹ យាចតិ ។ តត្រ ចេ ភិក្ខូ
ឯវំ វទន្តិ អយំ ខោ អាវុសោ ភិក្ខុ សង្ឃេន និយស្ស-



យើងទាំងឡាយរម្ងាប់តជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះព្រមព្រៀង
គ្នា តែប្រកបដោយធម្មប្បដិរូប រម្ងាប់តជ្ជនីយកម្មដល់ភិក្ខុនោះ ។ សង្ឃដែល
ឋិតនៅក្នុងទីនោះជជែកគ្នាថា កម្មរបស់ភិក្ខុជាពួកទាំងមិនប្រកបដោយ
ធម៌ កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុ
ជាពួក តែប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួកទាំងប្រកបដោយធម្មប្បដិរូប
កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម្មប្បដិរូប កម្មឈ្មោះថាភិក្ខុមិន
បានធ្វើហើយ កម្មឈ្មោះថាភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត ។
ម្នាលភិក្ខុទាំងឡាយ បណ្ដាភិក្ខុទាំងនោះ ភិក្ខុទាំងឡាយណានិយាយ
យ៉ាងនេះថា កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម្មប្បដិរូប ពួកនោះ
ឯភិក្ខុទាំងឡាយណានិយាយយ៉ាងនេះថា កម្មឈ្មោះថាភិក្ខុមិនបាន
ធ្វើហើយ កម្មឈ្មោះថាភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត ។
ភិក្ខុទាំងអម្បាលនេះ ឈ្មោះថាជាធម្មវាទីក្នុងកម្មនោះ ។

(១៣៨) ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសា-
សនានេះ សង្ឃបានធ្វើនិយស្សកម្មហើយ ក៏ប្រព្រឹត្តដោយប្រពៃ ទាំង
ស្ងប់រោម ប្រព្រឹត្តនូវដំណើរដែលនាំឲ្យចេញចាកកម្ម ហើយមកសូម
ការរម្ងាប់និយស្សកម្ម ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយនិយាយយ៉ាងនេះថា
ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯងដែលសង្ឃបានធ្វើនិយស្សកម្មហើយ

កម្មការកោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ និយស្សកម្មស្ស បដិប្បស្សទ្ធឹ យាចតិ ហន្ទស្ស មយំ និយស្សកម្មំ បដិប្បស្សម្ភេមាតិ ។ តេ តស្ស និយស្សកម្មំ បដិប្បស្សម្ភន្តិ អធម្មេន វគ្គា ។ បេ ។ អធម្មេន សមគ្គា ។ ធម្មេន វគ្គា ។ ធម្មប្បដិរូបកេន វគ្គា ។ ធម្មប្បដិរូបកេន សមគ្គា ។ តត្រដ្ឋោ សង្ឃោ វិវទតិ អធម្មេន វគ្គកម្មំ អធម្មេន សមគ្គកម្មំ ធម្មេន វគ្គកម្មំ ធម្មប្បដិរូបកេន វគ្គកម្មំ ធម្មប្បដិរូបកេន សមគ្គកម្មំ អកតំ កម្មំ ទុក្កដំ កម្មំ បុន កាតព្វំ កម្មន្តិ ។ តត្រ ភិក្ខវេ យេ តេ ភិក្ខូ ឯវមាហំសុ ធម្មប្បដិរូបកេន សមគ្គកម្មន្តិ យេ ច តេ ភិក្ខូ ឯវមាហំសុ អកតំ កម្មំ ទុក្កដំ កម្មំ បុន កាតព្វំ កម្មន្តិ ។ ឥមេ តត្ថ ភិក្ខូ ធម្មវាទិនោ ។

ឥមេ បញ្ច ភក សត្តកា ។





ក៏ប្រព្រឹត្តវត្តដោយប្រពៃ ដាក់ឃុំសម្បុររោម ប្រព្រឹត្តវត្តស្មើដល់កិរិយារលាស់ចេញចាកកម្ម ហើយមកសូមការរម្ងាប់និយស្សកម្ម (នោះ) បើពួកសង្ឃតែងរម្ងាប់និយស្សកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងអម្បាលនោះ ជាពួកទាំងមិនប្រកបដោយធម៌រម្ងាប់និយស្សកម្មដល់ភិក្ខុនោះ ។ បេ ។ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ ។ ជាពួក តែប្រកបដោយធម៌ ។ ជាពួកទាំងប្រកបដោយធម៌ប្តូម ។ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្តូម ។ សង្ឃដែលបរិបាលក្នុងទីនោះដែលគាត់ជា កម្មរបស់ភិក្ខុជាពួកទាំងមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក តែប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួកទាំងប្រកបដោយធម៌ប្តូម កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្តូម កម្មឈ្មោះថាភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថាភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត ។ ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុទាំងនោះ ភិក្ខុទាំងឡាយណា ទំលាយយាកនេះថា កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្តូម ពួកនោះសោតភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មឈ្មោះថាភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថាភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត ។ ភិក្ខុទាំងអម្បាលនេះ ឈ្មោះថាជាធម្មវាទីក្នុងកម្មនោះ ។

ពួកទាំងប្រាំនេះជាសេចក្តីសង្ខេប ។

[១៣៤] ឥធ បន ភិក្ខវេ ភិក្ខុ សង្ឃេន បព្វាជនិយកម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ បព្វាជនីយកម្មស្ស បដិប្បស្សទ្ធឹ យាចតិ ។ តត្រ ចេ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សង្ឃេន បព្វាជនីយកម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ បព្វាជនីយកម្មស្ស បដិប្បស្សទ្ធឹ យាចតិ ហន្ទស្ស មយំ បព្វាជនីយកម្មំ បដិប្បស្សម្ភេមាតិ ។ តេ តស្ស បព្វាជនីយកម្មំ បដិប្បស្សម្ភេន្តិ អធម្មេន វគ្គា ។ បេ ។ អធម្មេន សមគ្គា ។ ធម្មេន វគ្គា ។ ធម្មប្បដិរូបកេន វគ្គា ។ ធម្មប្បដិរូបកេន សមគ្គា ។ តត្រដ្ឋោ សង្ឃោ វិវទតិ អធម្មេន វគ្គកម្មំ អធម្មេន សមគ្គកម្មំ ធម្មេន វគ្គកម្មំ ធម្មប្បដិរូបកេន វគ្គកម្មំ ធម្មប្បដិរូបកេន សមគ្គកម្មំ អកតំ កម្មំ ទុក្កដំ កម្មំ បុន កាតព្វំ កម្មន្តិ ។ តត្រ ភិក្ខវេ



(១៣៤) ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុក្នុងសាសនានេះ សង្ឃបានធ្វើបព្វាជនីយកម្មហើយ ក៏ប្រព្រឹត្តត្រូវដោយប្រពៃ ទាំងសម្រួលរោម ប្រព្រឹត្តតាមដល់កិរិយាដោះស្រាយចេញបានកម្ម ហើយមកសូមការរម្ងាប់បព្វាជនីយកម្ម ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯងដែលសង្ឃបានធ្វើបព្វាជនីយកម្ម ហើយក៏ប្រព្រឹត្តត្រូវដោយប្រពៃ ទាំងសម្រួលរោម ប្រព្រឹត្តតាមដល់កិរិយាដោះស្រាយចេញបានកម្ម ឥឡូវមកសូមការរម្ងាប់បព្វាជនីយកម្ម (នោះ) បើដូច្នោះមានតែយើងទាំងឡាយរម្ងាប់បព្វាជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះជាពួកទាំងមិនប្រកបដោយធម៌ រម្ងាប់បព្វាជនីយកម្មដល់ភិក្ខុនោះ ។ បេ ។ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ ។ ជាពួក តែប្រកបដោយធម៌ ។ ជាពួកទាំងប្រកបដោយធម៌ប្បូម ។ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្បូម ។ សង្ឃដែលឋិតនៅក្នុងវិវាទនោះវិវាទគ្នាថា កម្មរបស់ភិក្ខុជាពួកទាំងមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក តែប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួកទាំងប្រកបដោយធម៌ប្បូម កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្បូម កម្មឈ្មោះថាភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថាភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាភិក្ខុទាំងនោះ

យេ តេ ភិក្ខូ ឯវមាហំសុ ធម្មប្បដិរូបកេន សមគ្គកម្មន្តិ យេ ច តេ ភិក្ខូ ឯវមាហំសុ អកតំ កម្មំ ទុក្កដំ កម្មំ បុន កាតព្វំ កម្មន្តិ ។ ឥមេ តត្ថ ភិក្ខូ ធម្មវាទិនោ ។ ឥមេ បញ្ច ភិក សន្និដ្ឋា ។

(១៦០) ឥធ បន ភិក្ខវេ ភិក្ខុ សង្ឃេន បដិសារណីយកម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ បដិសារណីយកម្មស្ស បដិប្បស្សទ្ធិំ យាចតិ ។ តត្រ ចេ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សង្ឃេន បដិសារណីយកម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ បដិសារណីយកម្មស្ស បដិប្បស្សទ្ធិំ យាចតិ ហន្ទស្ស មយំ បដិសារណីយកម្មំ បដិប្បស្សម្ភេមាតិ ។ តេ តស្ស បដិសារណីយកម្មំ បដិប្បស្សម្ភេន្តិ អធម្មេន វគ្គា ។ បេ ។ អធម្មេន សមគ្គា ។



ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មរបស់ភិក្ខុ[ពួកនោះ]ដែលសង្ឃធ្វើប្រកបដោយធម្មប្បដិរូប ចំណែកភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មឈ្មោះថាភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថាភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត ។ ភិក្ខុទាំងអម្បាលនេះ ឈ្មោះថាជាធម្មវាទី ។ ភិក្ខុទាំង៥នេះជាសេចក្តីសង្ខេប ។

(១៦០) ម្នាលភិក្ខុទាំងឡាយ ន័យមួយទៀត ភិក្ខុក្នុងសាសនានេះ សង្ឃបានធ្វើបដិសារណីយកម្មហើយ ក៏ប្រព្រឹត្តដោយប្រពៃ ទាំងសម្របខ្លួន ប្រព្រឹត្តគួរដល់កិរិយារលាស់ចេញចាកកម្ម ហើយមកសូមការរម្ងាប់បដិសារណីយកម្ម ។ ក្នុងរឿងនោះ ភិក្ខុទាំងឡាយគិតយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯងដែលសង្ឃបានធ្វើបដិសារណីយកម្មហើយ ក៏ប្រព្រឹត្តដោយប្រពៃ ទាំងសម្របខ្លួន ប្រព្រឹត្តគួរដល់កិរិយារលាស់ចេញចាកកម្ម ឥឡូវមកសូមការរម្ងាប់បដិសារណីយកម្ម (នោះ) បើដូច្នោះមានតែយើងទាំងឡាយរម្ងាប់បដិសារណីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះជាពួកទាំងមិនប្រកបដោយធម៌ រម្ងាប់បដិសារណីយកម្មដល់ភិក្ខុនោះ ។ បេ ។ [ព្រមព្រៀង]គ្នា តែមិនប្រកបដោយធម៌ ។

ធម្មេន វគ្គា ។ ធម្មប្បដិរូបកេន វគ្គា ។ ធម្មប្បដិរូបកេន សមគ្គា ។ តត្រដ្ឋោ សង្ឃោ វិហញ្ញតិ អធម្មេន វគ្គកម្មំ អធម្មេន សមគ្គកម្មំ ធម្មេន វគ្គកម្មំ ធម្មប្បដិរូបកេន វគ្គកម្មំ ធម្មប្បដិរូបកេន សមគ្គកម្មំ អកតំ កម្មំ ទុក្កដំ កម្មំ បុន កាតព្វំ កម្មន្តិ ។ តត្រ ភិក្ខវេ យេ តេ ភិក្ខូ បដិក្កោសន្តិ ធម្មប្បដិរូបកេន សមគ្គកម្មន្តិ យេ ច តេ ភិក្ខូ បដិក្កោសន្តិ អកតំ កម្មំ ទុក្កដំ កម្មំ បុន កាតព្វំ កម្មន្តិ ។ ឥមេ តត្ថ ភិក្ខូ ធម្ម-វាទិនោ ។ ឥមេ បញ្ច នយា សង្ខិត្តា ។

(៤៤១) ឥធ បន ភិក្ខវេ ភិក្ខុ សង្ឃេន អាបត្តិយា អទស្សនេ ឧក្ខេបនីយកម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ អាបត្តិយា អទស្សនេ ឧក្ខេ-បនីយកម្មស្ស បដិប្បស្សទ្ធឹ យាចតិ ។ តត្រ ចេ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សង្ឃេន



ជាពួក ដែលប្រកបដោយធម៌ ។ ជាពួកទាំងប្រកបដោយធម្មប្បតិរូប ។ ព្រមព្រៀងគ្នា ដែលប្រកបដោយធម្មប្បតិរូប ។ សង្ឃដែលស្ថិតនៅក្នុងទីនោះ រមែងលំបាកដោយកម្មរបស់ភិក្ខុជាពួកទាំងមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក ដែលប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួកទាំងប្រកបដោយធម្មប្បតិរូប កម្មរបស់ភិក្ខុព្រមព្រៀងគ្នា ដែលប្រកបដោយធម្មប្បតិរូប កម្មឈ្មោះថាភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថាភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុគប្បីធ្វើទៀត ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាភិក្ខុទាំងនោះ ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មរបស់ភិក្ខុព្រមព្រៀងគ្នា ដែលប្រកបដោយធម្មប្បតិរូប ពុំនោះសោត ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មឈ្មោះថាភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថាភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុគប្បីធ្វើទៀត ។ ភិក្ខុទាំងអម្បាលនេះ ឈ្មោះថាជាធម្មវាទីក្នុងកម្មនោះ ។ ន័យទាំងប្រាំនេះជាសេចក្ដីសង្ខេប ។

(៤៤១) ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ភិក្ខុក្នុងសាសនានេះ សង្ឃបានធ្វើឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិហើយ ក៏ប្រព្រឹត្តត្រូវដោយប្រពៃ ទាំងសម្រួបរោម ប្រព្រឹត្តគួរដល់កិរិយារលាស់ចេញចាកកម្ម ហើយមកសូមការរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយនឹកនាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង

អាបត្តិយា អទស្សនេ ឧក្ខេបនីយកម្មកតា សម្មា
វត្តន្តិ លោមំ បាតេន្តិ នេត្ថារំ វត្តន្តិ អាបត្តិយា អទស្សនេ
ឧក្ខេបនីយកម្មស្ស បដិប្បស្សទ្ធិំ យាចន្តិ តត្ថ សង្ឃោ អយំ
អាបត្តិយា អទស្សនេ ឧក្ខេបនីយកម្មំ បដិប្បស្សម្ភេ-
តិ ។ តេ តស្ស អាបត្តិយា អទស្សនេ ឧក្ខេបនី-
យកម្មំ បដិប្បស្សម្ភិ អធម្មេន វគ្គា ។ បេ ។ អធម្មេន
សមគ្គា ។ ធម្មេន វគ្គា ។ ធម្មប្បដិរូបកេន វគ្គា ។
ធម្មប្បដិរូបកេន សមគ្គា ។ ឧក្ខិត្តា សង្ឃោ វិវទតិ
អធម្មេន វគ្គកម្មំ អធម្មេន សមគ្គកម្មំ ធម្មេន វគ្គកម្មំ
ធម្មប្បដិរូបកេន វគ្គកម្មំ ធម្មប្បដិរូបកេន សមគ្គកម្មំ
អកម្មំ ន ច ករណីយំ កម្មំ បុន កាតព្វំ កម្មន្តិ ។ អត្រ
ភិក្ខវេ យេ តេ ភិក្ខូ វិវទមានា ធម្មប្បដិរូបកេន ស-
មគ្គកម្មន្តិ យេ ច តេ ភិក្ខូ ឯវមាហំសុ អកតំ កម្មំ



ដែលសង្ឃធ្វើឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិហើយ គឺបានប្រ-
ព្រឹត្តត្រូវប្រពៃ តាំងសង្កត់រោម ប្រព្រឹត្តនូវវត្តសម្រាប់សេចក្ដីរលាស់ចេញ
ពាក្យ សូមសង្ឃរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ បើ
ពួកភិក្ខុនោះជាសង្ឃរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ
ដល់ភិក្ខុនោះ ៗ ភិក្ខុតាំងវិវាទនោះថាពួកតាំងមិនប្រកបដោយធម៌ រម្ងាប់
ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិដល់ភិក្ខុនោះ ។ បេ ។ ព្រមព្រៀងគ្នា
តែមិនប្រកបដោយធម៌ ៗ ជាពួក តែប្រកបដោយធម៌ ៗ ជាពួកតាំងប្រកប
ដោយធម៌ប្បដិរូប ៗ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្បដិរូប សង្ឃវិវាទថា
ទោះកម្មនោះនៃសង្ឃជា កម្មរបស់ភិក្ខុជាពួកតាំងមិនប្រកបដោយធម៌ កម្ម
របស់ភិក្ខុព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក តែ
ប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួកតាំងប្រកបដោយធម៌ប្បដិរូប កម្មរបស់ភិក្ខុ
ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្បដិរូប កម្មឈ្មោះថាភិក្ខុមិនបានធ្វើហើយ
កម្មឈ្មោះថាភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត ។ ម្នាលភិក្ខុទាំង-
ឡាយ បណ្ដាភិក្ខុទាំងនោះ បើភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា
កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្បដិរូប ពួកនោះសោតភិក្ខុ
ទាំងឡាយណានិយាយយ៉ាងនេះថា កម្មឈ្មោះថាភិក្ខុមិនបានធ្វើហើយ

ទុក្កដំ កម្មំ បុន កាតព្វំ កម្មំ ។ ឥមេ តត្ថ ភិក្ខុ ធម្មាធិកោ ។ ឥមេ បញ្ច វារា សំខិត្តា ។ ឥធ បន ភិក្ខវេ ភិក្ខុ សង្ឃេន អាបត្តិយា អប្បដិកម្មេ ឧក្ខេបនិយកម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ អាបត្តិយា អប្បដិកម្មេ ឧក្ខេបនិយកម្មស្ស បដិប្បស្សទ្ធិំ យាចតិ ។ តត្រ ចេ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សង្ឃេន អាបត្តិយា អប្បដិកម្មេ ឧក្ខេបនិយកម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ អាបត្តិយា អប្បដិកម្មេ ឧក្ខេបនិយកម្មស្ស បដិប្បស្សទ្ធិំ យាចតិ ហន្ទស្ស មយំ អាបត្តិយា អប្បដិកម្មេ ឧក្ខេបនីយកម្មំ បដិប្បស្សម្ភេមាតិ ។ តេ តស្ស អាបត្តិយា អប្បដិកម្មេ ឧក្ខេបនីយកម្មំ បដិប្បស្សម្ភេន្តិ អធម្មេន វគ្គា ។ បេ ។ អធម្មេន សមគ្គា ។ ធម្មេន វគ្គា ។ ធម្មប្បដិរូបកេន វគ្គា ។ ធម្មប្បដិរូបកេន សមគ្គា ។ តត្រដ្ឋោ សង្ឃោ វិវទតិ អធម្មេន វគ្គកម្មំ អធម្មេន



កម្មណាដែលភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត ។ ភិក្ខុទាំងអម្បាលនេះ ឈ្មោះថាជាធម្មវាទីកម្មវាទី ។ វារៈទាំងប្រាំនេះជាសេចក្តីសង្ខេប ។ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ភិក្ខុក្នុងសាសនានេះ សង្ឃបានធ្វើឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញហើយ ក៏ប្រព្រឹត្តដោយប្រពៃ ទាំងសម្រួមរោម ប្រព្រឹត្តត្រូវដល់កិរិយារលាស់ចេញចាកកម្ម ហើយមកសូមការរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឃបានធ្វើឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញហើយ ក៏ប្រព្រឹត្តដោយប្រពៃ ទាំងសម្រួមរោម ប្រព្រឹត្តត្រូវដល់កិរិយារលាស់ចេញចាកកម្ម គប្បីមកសូមការរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ បើដូច្នោះមានតែពួកយើងទាំងឡាយរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញដល់ភិក្ខុនេះ ។ ភិក្ខុទាំងអម្បាលនោះជាពួកបែក មិនប្រកបដោយធម៌ រម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញដល់ភិក្ខុនោះ ។ បេ ។ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ ។ ជាពួកបែកប្រកបដោយធម៌ ។ ជាពួកបែកប្រកបដោយធម៌ប្លម ។ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម ។ សង្ឃដែលឋិតនៅក្នុងវិវាទនោះ ចែកគ្នាថា កម្មរបស់ភិក្ខុជាពួកទាំងមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុព្រមព្រៀងគ្នា

សមគ្គកម្មំ ធម្មេន វគ្គកម្មំ ធម្មប្បដិរូបកេន វគ្គកម្មំ ធម្មប្បដិរូបកេន សមគ្គកម្មំ អកតំ កម្មំ ទុក្កដំ កម្មំ បុន កាតព្វំ កម្មន្តិ ។ តត្រ ភិក្ខវេ យេ តេ ភិក្ខូ ឯវមាហំសុ ធម្មប្បដិរូបកេន សមគ្គកម្មន្តិ យេ ច តេ ភិក្ខូ ឯវមាហំសុ អកតំ កម្មំ ទុក្កដំ កម្មំ បុន កាតព្វំ កម្មន្តិ ។ ឥមេ តត្ថ ភិក្ខូ ធម្មវាទិនោ ។ ឥមេ បញ្ចកា សង្ខិត្តា ។

[១៦៦] ឥធ បន ភិក្ខវេ ភិក្ខុ សង្ឃេន បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មស្ស បដិប្បស្សទ្ធិំ យាចតិ ។ តត្រ ចេ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សង្ឃេន បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មកតោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មស្ស បដិប្បស្សទ្ធិំ យាចតិ ហន្ទស្ស



ដែលមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក ដែលប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួកដែលប្រកបដោយធម៌ប្លម កម្មរបស់ភិក្ខុព្រមព្រៀងគ្នា ដែលប្រកបដោយធម៌ប្លម កម្មឈ្មោះថាភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថាភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាភិក្ខុទាំងនោះ ភិក្ខុទាំងឡាយណានិយាយយ៉ាងនេះថា កម្មរបស់ភិក្ខុព្រមព្រៀងគ្នា ដែលប្រកបដោយធម៌ប្លម ពួកនោះសោតភិក្ខុទាំងឡាយណានិយាយយ៉ាងនេះថា កម្មឈ្មោះថាភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថាភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត ។ ភិក្ខុទាំងអម្បាលនេះឈ្មោះថាជាធម្មវាទីក្នុងកម្មនោះ ។ វារៈទាំងប្រាំនេះជាសេចក្ដីសង្ខេប ។

[១៦៦] ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុក្នុងសាសនានេះ សង្ឃបានធ្វើឧក្ខេបនីយកម្មហើយ ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ ក៏ប្រព្រឹត្តត្រូវដោយប្រពៃ ទាំងសម្របតាមប្រព្រឹត្តត្រូវផលកិរិយារលាស់ចេញចាកកម្ម ហើយមកសូមការរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយគិតយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯងដែលសង្ឃធ្វើឧក្ខេបនីយកម្មហើយ ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ ក៏បានប្រព្រឹត្តត្រូវដោយប្រពៃ ទាំងសម្របតាមប្រព្រឹត្តត្រូវផលកិរិយារលាស់ចេញចាកកម្ម ហើយមកសូមការរម្ងាប់ឧក្ខេបនីយកម្ម

អយំ អាបត្តិយា ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនី-
យកម្មំ បដិប្បស្សម្ភេតិ ។ តេ តស្ស អាបត្តិយា
ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មំ បដិប្បស្សម្ភេន្តិ
អធម្មេន វគ្គា ។ បេ ។ អធម្មេន សមគ្គា ។ ធម្មេន
វគ្គា ។ ធម្មប្បតិរូបកេន វគ្គា ។ ធម្មប្បតិរូបកេន
សមគ្គា ។ តត្រដ្ឋា សង្ឃេ វិវទតិ អធម្មេន វគ្គកម្មំ
អធម្មេន សមគ្គកម្មំ ធម្មេន វគ្គកម្មំ ធម្មប្បតិរូបកេន
វគ្គកម្មំ ធម្មប្បតិរូបកេន សមគ្គកម្មំ អកតំ កម្មំ
ទុក្កដំ កម្មំ បុន កាតព្វំ កម្មន្តិ ។ តត្រ ភិក្ខវេ
យេ តេ ភិក្ខូ ឯវមាហំសុ ធម្មប្បតិរូបកេន សមគ្គ-
កម្មន្តិ យេ ច តេ ភិក្ខូ ឯវមាហំសុ អកតំ កម្មំ
ទុក្កដំ កម្មំ បុន កាតព្វំ កម្មន្តិ ។ ឥមេ តត្ថ ភិក្ខូ
ធម្មវាទិនោ ។ [illegible] ។

ចម្បេយ្យក្ខន្ធកំ នវមំ ។

ឥមម្ហិ ខន្ធកេ វត្ថូនិ ឆត្តឹស ។



ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ បើពួកនោះមានតែយើងទាំងនោះឲ្យរំងាប់
ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញដល់ភិក្ខុនេះ ។ ភិក្ខុទាំង
អម្បាលនោះជាពួកទាំងមិនប្រកបដោយធម៌ រំងាប់ឧក្ខេបនីយកម្ម ព្រោះមិន
លះបង់ទិដ្ឋិអាក្រក់ចេញដល់ភិក្ខុនោះ ។ បេ ។ ព្រមព្រៀងគ្នា តែមិនប្រកប
ដោយធម៌ ។ ជាពួក តែប្រកបដោយធម៌ ។ ជាពួកទាំងប្រកបដោយ
ធម៌ប្លម ។ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម ។ បរិស័ទដែល[illegible]
ក្នុងទីនោះវិវាទគ្នាថា កម្មរបស់ភិក្ខុជាពួកទាំងមិនប្រកបដោយធម៌ កម្ម
របស់ភិក្ខុព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក តែ
ប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួកទាំងប្រកបដោយធម៌ប្លម កម្មរបស់ភិក្ខុ
ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម កម្មឈ្មោះថាភិក្ខុមិនបានធ្វើហើយ
កម្មឈ្មោះថាភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុគួរធ្វើទៀត ។ ម្នាលភិក្ខុទាំង
ឡាយ បណ្ដាភិក្ខុទាំងនោះ ពួកភិក្ខុទាំងឡាយឯណា និយាយយ៉ាងនេះថា
កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម ពួកនោះសោតភិក្ខុទាំង
ឡាយណា និយាយយ៉ាងនេះថា កម្មឈ្មោះថាភិក្ខុមិនបានធ្វើហើយ កម្ម
ឈ្មោះថាភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុគួរធ្វើទៀត ។ ភិក្ខុទាំងអម្បាល
នេះឈ្មោះថាជាធម្មវាទីក្នុងកម្មនោះ ។ [illegible]ជាសេចក្ដីសង្ខេប ។

ចប់ចម្បេយ្យក្ខន្ធកៈ ទី ៩ ។

ក្នុងខន្ធកៈនេះមានរឿង ៣៦ ។

តស្សុទ្ទានំ

(១៦៣) ចម្បាយំ ភគវា អាសិ
វត្ថុ វាសភគាមកេ
អាគន្តុកានំ ឧស្សុក្កំ
អកាសិ ឥច្ឆិតព្វកេ
បកតញ្ញុនោតិ ញត្វា
ឧស្សុក្កំ ន ករី តទា
ឧក្ខិត្តោ ន ករោតីតិ
អគមា ជិនសន្តិកេ ។
អធម្មេន វគ្គកម្មំ
សមគ្គំ អធម្មេន ច
ធម្មេន វគ្គកម្មំ ច
បដិរូបកេន វគ្គិកំ
បដិរូបកេន សមគ្គំ
ឯកោ ឧក្ខិបតេកកំ
ឯកោ ច ទ្វេ សម្ពហុលេ





• ឧទ្ទាននៃចម្បេយ្យក្ខន្ធកៈនោះ គឺ

(១៦៣) កាលព្រះមានព្រះភាគគង់នៅក្នុងនគរចម្បា (មានភិក្ខុឈ្មោះកស្សបគោត្តជាអាវាសិក) នៅក្នុងស្រុកឈ្មោះវាសភៈ បានធ្វើសេចក្ដីខ្វល់ខ្វាយដល់ពួកភិក្ខុជាអាគន្តុកៈ លុះដឹងថាពួកភិក្ខុជាអាគន្តុកៈស្គាល់ច្បាស់នូវគោចរដែលភិក្ខុគប្បីត្រូវជាហើយ ក៏លែងធ្វើសេចក្ដីខ្វល់ខ្វាយក្នុងកាលនោះ ភិក្ខុឈ្មោះកស្សបគោត្តនោះ ពួកភិក្ខុជាអាគន្តុកៈលើកវត្តហើយមិនធ្វើ (សេចក្ដីខ្វល់ខ្វាយដល់យើង) ហើយបានទៅកាន់សំណាក់ព្រះជិនស្រី ។ (ពួកភិក្ខុក្នុងនគរចម្បា) ធ្វើកម្មជាពួកពាក់មិនប្រកបដោយធម៌ផង ធ្វើកម្មព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ផង ធ្វើកម្មជាពួក តែប្រកបដោយធម៌ផង ធ្វើកម្មជាពួកពាក់ប្រកបដោយធម្មប្បដិរូបផង ធ្វើកម្មព្រមព្រៀងគ្នា តែប្រកបដោយធម្មប្បដិរូបផង ភិក្ខុមួយរូបលើកវត្តភិក្ខុមួយរូបផង ភិក្ខុមួយរូបលើកវត្តភិក្ខុពីររូបផង លើកវត្តភិក្ខុច្រើនរូបផង

សង្ឃំ ឧក្ខិបតេ ករោ
ទ្វេបិ សម្ពហុលាបិ
សង្ឃោ សង្ឃំ ច ឧក្ខិបេ ។
សព្វញ្ញូ បវរោ សុត្វា
អធម្មន្តិ បដិក្ខិបិ ។
ញត្តិវិបន្នំ យំ កម្មំ
សម្បន្នំ អនុស្សាវនំ
អនុស្សាវនវិបន្នំ
សម្បន្នំ ញត្តិយា ច យំ
ឧភយេន វិបន្នញ្ច
អញ្ញត្រ ធម្មេន ច
វិនយំ សត្ថុ បដិកុដ្ឋំ
កុប្បំ អដ្ឋានារហំ
អធម្មវគ្គសមគ្គំ
បតិរូបេន យេ ទុវេ
ធម្មេនេវ ច សាមគ្គី
អនុញ្ញាសិ តថាគតោ ។



លើកវត្តសង្ឃផង ភិក្ខុពីររូប ភិក្ខុច្រើនរូប សង្ឃ លើកវត្តសង្ឃផង ។ ព្រះសព្វញ្ញុពុទ្ធដ៏ប្រសើរទ្រង់ព្រោះ (រឿងនោះ) ហើយទ្រង់ហាមថាជាកម្មមិនប្រកបដោយធម៌ ។ (ឧក្ខិត្តិយ-ភិក្ខុ ) ធ្វើកម្មវិបត្តិចាកញត្តិ តែដល់ព្រមដោយអនុស្សាវនាផង ធ្វើកម្មវិបត្តិចាកអនុស្សាវនាតែដល់ព្រមដោយញត្តិផង ធ្វើកម្មវិបត្តិចាកញត្តិនិងអនុស្សាវនាទាំងពីរផង ធ្វើកម្មវៀរចាកធម៌ផង ធ្វើកម្មវៀរចាកវិន័យផង ធ្វើកម្មវៀរចាកសាសនានៃព្រះសាស្តាផង ធ្វើកម្មដែលព្រះដ៏មានព្រះភាគតិះដៀលថាជាកម្មកំរើក មានរូបមិនគួរដល់ហេតុផង កម្មមិនប្រកបដោយធម៌ផង កម្មជាពួកផង កម្មព្រមព្រៀងគ្នាផង កម្មពីរទៀតគឺ (កម្មជាពួក ) ដ៏ប្រកបដោយធម៌ប្រតិរូបផង (កម្មព្រមព្រៀងគ្នាដែលប្រកបដោយធម៌ប្រតិរូបផង ) ម្យ៉ាងទៀត ព្រះតថាគតទ្រង់អនុញ្ញាតកម្មដែលព្រមព្រៀងគ្នា ទាំងប្រកបដោយធម៌ប៉ុណ្ណោះ ។

ចតុវគ្គោ បញ្ចវគ្គោ
ទសវគ្គោ ច វីសតិ
អតិរេកវីសតិវគ្គោ
សង្ឃោ បញ្ចវិធោ តថា ។
ឋបេត្វា ឧបសម្បទំ
យញ្ច កម្មំ បវារណំ
អព្ភានកម្មេន សហ
ចតុវគ្គេហិ កម្មិកោ ។
ទុវេ កម្មេ ឋបេត្វាន
មជ្ឈទេសូបសម្បទំ
អព្ភានំ បញ្ចវគ្គិកោ
សព្វកម្មេសុ កម្មិកោ ។
អព្ភានេកំ ឋបេត្វាន
យេ ភិក្ខូ ទសវគ្គិកា ។
សព្វកម្មករោ សង្ឃោ
វីសោ សព្វត្ថ កម្មិកោ ។
ភិក្ខុនី សិក្ខមានា ច



សង្ឃមាន ៥ ពួកគឺ សង្ឃចតុវគ្គ១ បញ្ចវគ្គ១ ទសវគ្គ១ វីសតិវគ្គ១ អតិរេកវីសតិវគ្គ១ ។ សង្ឃចតុវគ្គ គួរធ្វើកម្ម ( ទាំងពួង ) វៀរលែងតែ ( កម្ម ៣ យ៉ាង ) គឺ ឧបសម្បទាកម្ម១ បវារណាកម្ម១ អព្ភានកម្ម១ ។ សង្ឃបញ្ចវគ្គគួរធ្វើកម្មគឺកម្មទាំងពួង វៀរលែងតែកម្ម២យ៉ាង គឺឧបសម្បទាកម្មក្នុងមជ្ឈិមប្រទេស ១ អព្ភានកម្ម១ ។ ភិក្ខុសង្ឃទសវគ្គ ( ធ្វើកម្មទាំងអស់បាន ) វៀរលែងតែអព្ភានកម្មមួយចេញ ។ សង្ឃវីសតិវគ្គ គួរធ្វើកម្មគឺកម្មទាំងពួង ឈ្មោះថាធ្វើកម្មបានគ្រប់កម្ម ។ ភិក្ខុនីក្តី សិក្ខមានាក្តី

សាមណេរោ សាមណេរិកា
បច្ចក្ខាតន្តិមវត្ថុ
ឧក្ខិត្តាបត្តិទស្សនេ
អប្បដិកម្មទិដ្ឋិយា
បណ្ឌកាថេយ្យសំវាសកំ
តិត្ថិយតិរច្ឆានគតំ
មាតុ បិតុ ច ឃាតកំ
អរហំ ភិក្ខុនិទូសី
ភេទកំ លោហិតុប្បាទកំ
ព្យញ្ជនំ នានាសំវាសំ
នានាសីមាយ ឥទ្ធិយា
យស្ស សង្ឃោ ករេ កម្មំ
ហោតិ តេ ចតុវីសតិ
សម្មុខេន បដិក្កុដ្ឋា
ន ហោន្តិ គណបូរកា
បារិវាសិកចតុត្ថោ
បរិវាសំ ទទេយ្យ វា



សាមណេរក្តី សាមណេរីក្តី ភិក្ខុដែលបានលាសិក្ខាក្តី ភិក្ខុដែលត្រូវអន្តិមវត្ថុក្តី ភិក្ខុដែលសង្ឃលើកវត្តព្រោះមិនឃើញអាបត្តិក្តី ព្រោះមិនសំដែងអាបត្តិក្តី ព្រោះមិនលះបង់ទិដ្ឋិបាបក្តី មនុស្សខ្ទើយក្តី មនុស្សដែលលួចសំវាសក្តី ភិក្ខុដែលចូលទៅកាន់លទ្ធិតិរ្ថិយក្តី សត្វតិរច្ឆានក្តី បុគ្គលដែលធ្វើមាតុឃាតក្តី បិតុឃាតក្តី អរហន្តឃាតក្តី បុគ្គលដែលប្រទូស្តភិក្ខុនីក្តី បុគ្គលដែលធ្វើសង្ឃភេទក្តី បុគ្គលដែលធ្វើលោ-ហិតុប្បាទក្តី ឧភតោព្យញ្ជនកក្តី ភិក្ខុមានសំវាសផ្សេងៗគ្នាក្តី ភិក្ខុនៅក្នុងសីមាផ្សេងៗគ្នាក្តី (ភិក្ខុឋិតនៅលើអាកាស) ដោយឫទ្ធិក្តី (បណ្តាបុគ្គលទាំងនេះ) បើជំនុំសង្ឃធ្វើកម្មដល់បុគ្គលឯណាមួយ ឯបុគ្គលទាំង ២៤ ពួកនោះព្រះសម្ពុទ្ធទ្រង់ហាមថា បុគ្គលទាំងអម្បាលនេះជាគណបូរកៈមិនបានឡើយ ម្យ៉ាងទៀត សង្ឃមានបារិវាសិកភិក្ខុជាគំរប់ ៤ ឲ្យបរិវាស

មូលា មានត្តមព្ភេយ្យ
អកម្មំ ន ច ករណំ
មូលា អរហមានត្តា
អព្ភានារហមេវ ច
ន កម្មការកា បញ្ច
សម្ពុទ្ធេន បកាសិតា ។
ភិក្ខុនី សិក្ខមានា ច
សាមណេរោ សាមណេរិកា
បច្ចក្ខាតន្តិមវត្ថុកា
ខិត្តវេទនទស្សនេ
អប្បដិកម្មេ ទិដ្ឋិយា
បណ្ឌកោ ថេយ្យសំវាសកំ
តិត្ថិយ តិរច្ឆានគតំ
មាតា បិតុ ច ឃាតកំ
អរហំ ភិក្ខុនីទូសិ
ភេទកំ លោហិតុប្បាទកំ
ឧភតោព្យញ្ជនញ្ចេវ



ឲ្យមូលាយបដិកស្សនៈ ឲ្យមានត្ត ឲ្យអព្ភាន (កម្មរបស់សង្ឃនោះ) មិនឈ្មោះថាកម្មផង សង្ឃមិនត្រូវធ្វើផង ម្យ៉ាងទៀត សង្ឃមានភិក្ខុដែលគួរផល់មូលាយបដិកស្សនៈជាគំរប់ ៤ ក្ដី មានភិក្ខុដែលគួរផល់មានត្តជាគំរប់ ៤ ក្ដី មានភិក្ខុដែលប្រព្រឹត្តមានត្តជាគំរប់ ៤ ក្ដី មានភិក្ខុដែលគួរផល់អព្ភានជាគំរប់ ៤ ក្ដី ភិក្ខុទាំង ៨ ពួកនេះ ព្រះសម្ពុទ្ធទ្រង់ប្រកាសថា មិនមែនជាអ្នកធ្វើកម្មឡើយ ។ ភិក្ខុនីក្ដី សិក្ខមានាក្ដី សាមណេរក្ដី សាមណេរីក្ដី ភិក្ខុដែលបោលលាសិក្ខាក្ដី ភិក្ខុដែលត្រូវអន្តិមវត្ថុក្ដី ភិក្ខុឧម្មត្តកក្ដី ភិក្ខុមានចិត្តរវើរវាយក្ដី ភិក្ខុមានវេទនាគ្របសង្កត់ក្ដី ភិក្ខុដែលសង្ឃលើកវត្តព្រោះមិនឃើញអាបត្តិក្ដី ព្រោះមិនសំដែងអាបត្តិក្ដី ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញក្ដី ខ្ទើយក្ដី បុគ្គលដែលលួចសំវាសក្ដី ភិក្ខុដែលចូលទៅកាន់លទ្ធិតិរ្ថិយក្ដី សត្វតិរច្ឆានក្ដី បុគ្គលជាមាតុឃាតកក្ដី បិតុឃាតកក្ដី អរហន្តឃាតកក្ដី បុគ្គលដែលប្រទូស្តភិក្ខុនីក្ដី ដែលធ្វើសង្ឃភេទក្ដី ធ្វើលោហិតុប្បាទក្ដី ឧភតោព្យញ្ជនកក្ដី

សមានសំវាសកំ ចេ
សមានសីមាយ ឋិតកំ
វេហាសំ យស្ស កម្មំ ច
សត្តវីសានមេតេសំ
បដិក្កោសំ ន រូហតិ ។
ភិក្ខុស្ស បកតត្តស្ស
រូហតិ បដិក្កោសនា
សុទ្ធស្ស ទុន្និសារិតោ
ពាលោ ហិ សុនិស្សារិតោ
បណ្ឌកោ ថេយ្យសំវាសោ
បក្កន្តោ តិរច្ឆានគតោ
មាតាបិតុអរហន្ត
ទូសកោ សង្ឃភេទកោ
លោហិតុប្បាទកោ ចេវ
ឧភតោព្យញ្ជនោ ច យោ
ឯកាទសន្នមេតេសំ
ឧបសម្បទំ ន យុជ្ជតិ ។





ភិក្ខុដែលមានសំវាសស្មើៗគ្នាក្តី ភិក្ខុដែលឋិតនៅក្នុងសីមាស្មើៗគ្នាក្តី ភិក្ខុដែលឋិតនៅលើអាកាសក្តី (សង្ឃធ្វើ) កម្មដល់បុគ្គលណា បុគ្គលនោះក្តី ជាការហាមឃាត់ (ក្នុងកណ្តាលជំនុំសង្ឃ) របស់បុគ្គលទាំង ២៧ ពួកនេះមិនឡើងឡើយ ។ (ការហាមឃាត់ក្នុងកណ្តាលជំនុំសង្ឃ) របស់ភិក្ខុជាបកតត្ត ទើបឡើង ភិក្ខុបរិសុទ្ធ (បើសង្ឃបណ្តេញចេញ) ឈ្មោះថា បណ្តេញចេញដោយមិនត្រូវ ឯភិក្ខុល្ងង់ (បើសង្ឃបណ្តេញចេញ) ឈ្មោះថា បណ្តេញចេញដោយល្អ មនុស្សខ្ទើយក្តី បុគ្គលលួចសំវាសក្តី ភិក្ខុចូលទៅកាន់លទ្ធិតិរ្ថិយក្តី តិរច្ឆានក្តី បុគ្គលជាមាតុឃាតកៈក្តី បិតុឃាតកៈក្តី អរហន្តឃាតកៈក្តី ភិក្ខុនីទូសកៈក្តី សង្ឃភេទកៈក្តី លោហិតុប្បាទកៈក្តី ឧភតោព្យញ្ជនកៈក្តី ឯបុគ្គលទាំង ១១ ពួកនេះ មិនគួរដល់ឧបសម្បទាឡើយ ។

ហត្ថបាទា តទុភយំ
កណ្ណនាសា តទុភយំ
អង្គុលិអឡកណ្ឌរំ
ផណំ ខុជ្ជំ ច វាមនោ
គលគណ្ឌី លក្ខណាកសា ច
លិខិតកោ ច សីបទិ
បាបបរិសទូសកោ ច
កាណំ កុណិ ខញ្ជោ ច
ឆិន្នឥរិយាបថនោ
អន្ធោ មូគោ ច ពធិរោ
អន្ធមូគបធិរោ
អន្ធពធិរមេវ ច
អន្ធមូគពធិរោ ច
ទុក្ខិតេសេ អន្ធនា
តេសំ ឱសារណំ ហោតិ
សម្ពុទ្ធេន បកាសិតំ ។





មនុស្សកំបុតដៃក្តី កំបុតជើងក្តី កំបុតដៃនឹងជើងទាំងពីរក្តី កំបុតត្រចៀកក្តី កំបុតច្រមុះក្តី កំបុតត្រចៀកនឹងច្រមុះទាំងពីរក្តី កំបុតម្រាមដៃក្តី កំបុតមេដៃ មេជើងក្តី មនុស្សដាច់សរសៃក្តី មនុស្សមានម្រាមដៃកែកក្តី មនុស្សគមក្តី មនុស្សតឿក្តី មនុស្សពកក ឬពកត្រង់អវយវៈណាមួយក្តី មនុស្សដែលគេចៀតចៀន ឲ្យមានស្នាកស្នាមក្តី មនុស្សមានស្នាមដែលគេវាយដោយរំពាត់ក្តី មនុស្សដែលគេកត់ឈ្មោះក្នុងក្បួរការសព្ទក្តី មនុស្សដែលមានជើងហើមស្ទូកក្តី មនុស្សដែលមានរោគអាក្រក់ក្តី មនុស្សប្រទូស្តបរិសទ្យ គឺមនុស្សមានរូបអាក្រក់ខុសគេក្តី មនុស្សដែលរេចដៃនិងខ្វាក់ក្តី មនុស្សខ្វិនក្ងិនត្រង់អវយវៈណាមួយក្តី មនុស្សខ្វិនក្តី មនុស្សដែលស្លាប់មួយចំហៀងខ្លួនក្តី មនុស្សខ្វិនក្តី មនុស្សចាស់គ្រាំគ្រាក្តី មនុស្សដែលខ្វាក់ពីកំណើតក្តី មនុស្សគក្តី ថ្លង់ក្តី មនុស្សខ្វាក់ផង គផងក្តី មនុស្សខ្វាក់ផង ថ្លង់ផងក្តី មនុស្សគផង ថ្លង់ផងក្តី មនុស្សទាំងខ្វាក់ទាំងគទាំងថ្លង់ក្តី មនុស្សទាំង ៣២ ពួកនេះ ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ប្រកាសថា មនុស្សទាំងនោះគួរដល់ឱសារណាកម្ម ។

ឆន្ទញ្ច បដិកោសញ្ច

និស្សជ្ជេតា ច វត្តតិ

តស្ស ឧក្ខេបនា កម្មា

សត្ត ហោន្តិ អធម្មិកា

អាបន្នំ អនុវត្តន្តិ

សត្ត តេបិ អធម្មិកា

អាបន្នំ អនុវត្តន្តិ

សត្ត កម្មា សុធម្មិកា

សម្មុខា បដិបុច្ឆា ច

បដិញ្ញាយ ច ការកា

សតិអមូឡ្ហបាបិកា

តជ្ជនីយនិយស្ស ច

បព្វាជនីយបដិសារា

ឧក្ខេបបរិវាស ច

មូលមានត្តអព្ភានា

តថេវ ឧបសម្បទា

អញ្ញំ ករេយ្យ អញ្ញស្ស



ពាក្យដែលត្រូវឃាត់ ពាក្យដែលត្រូវសំដែងនូវទិដ្ឋិការ ត្រូវ ដែលត្រូវលះបង់ មិនមានផល (និគ្គហៈ) ការលើកវត្ត ផលភិក្ខុនោះ ជាកម្មមិនប្រកបដោយធម៌មាន ៧ យ៉ាង ភិក្ខុទាំងឡាយពួកភិក្ខុដែលត្រូវអាបត្តិ ស្ងប់កម្មរបស់ភិក្ខុទាំងនោះ ក៏ជាកម្មមិនប្រកបដោយធម៌មាន ៧ យ៉ាង ភិក្ខុទាំងឡាយពួកភិក្ខុដែលត្រូវអាបត្តិ (ស្ងៀម) កម្មរបស់ភិក្ខុទាំងនោះ ក៏ជាកម្មប្រកបដោយធម៌ល្អមាន ៧ យ៉ាង កាលសង្ឃធ្វើកម្មដែលត្រូវធ្វើក្នុងទីចំពោះមុខក្តី ធ្វើដោយការសាកសួរក្តី ធ្វើដោយសេចក្តីប្តេជ្ញាក្តី ស្មតិវិន័យក្តី អមូឡ្ហវិន័យក្តី ធ្វើតស្សបាបិយសិកាកម្មក្តី តជ្ជនីយកម្មក្តី និយស្សកម្មក្តី បព្វាជនីយកម្មក្តី បដិសារណីយកម្មក្តី ឧក្ខេបនីយកម្មក្តី ឲ្យបរិវាសក្តី ឲ្យមូលាយបដិកស្សនៈក្តី មានត្តក្តី អព្ភានក្តី ឧបសម្បទាក្តី ហើយសង្ឃត្រឡប់ធ្វើកម្មដទៃដល់បុគ្គលដទៃវិញ

លោក្យលោកេ អធម្មិកា
តន្តិ ការយេ តន្តស្ស
លោក្យលោកេ សុធម្មិកា
បច្ចាកេបេយ្យ អញ្ញាតំ
លោក្យលោកេ អធម្មិកា
ទ្វេ ទ្វេ មូលា ការា តស្ស
ទេមិ លោក្យស ធម្មិកា ៗ
វារាការមូលកំ ចក្កំ
សធម្មិ ធំពោ ត្រី
អនាសិ ឧទ្ធរិយំ ការ៉ុ
សរៀ្យ ពុទ្ធពការោកា
អធម្មេន វក្កកម្ម
អញ្ញំ បព្វស ការ៉ុ លោ
តត្ថា ធម្មេន សមគ្គា
តស្ស ឧទ្ធរិយំ ការ៉ុ
អញ្ញត្ថ វត្តធម្មេន
តស្ស ឧទ្ធរិយំ ការ៉ុ



គម្ពីរទី១៦ នេះឈ្មោះថាមិនប្រកបដោយធម៌ សង្ស័យធ្វើកម្មនោះ ៗ ដល់ភិក្ខុដែលគួរដល់កម្មនោះ ៗ គម្ពីរទី ១៦ នេះឈ្មោះថាប្រកបដោយធម៌ល្អ សង្ស័យលើកទៀតថាកម្មដែលថានោះភិក្ខុដែលគួរដល់កម្មដទៃវិញ គម្ពីរទី ១៦ នេះឈ្មោះថាមិនប្រកបដោយធម៌ កម្មមានមូលពីរ ៗ ដែលសង្ស័យបានធ្វើដល់ភិក្ខុនោះ គម្ពីរទី១៦ នោះក៏ឈ្មោះថាកម្មប្រកបដោយធម៌ដែរ ។ សូម្បីចក្កដែលមានមូលមួយ ៗ ព្រះជិនស្រី ទ្រង់ត្រាស់ថា មិនប្រកបដោយធម៌ សង្ស័យ (គឺគម្ពីរ) ភិក្ខុនេះជាអ្នកធ្វើការបង្កហេតុ ហើយបានធ្វើកម្មដល់ ( ដល់ភិក្ខុនោះ ) តែធ្វើកម្មណាក្ដីក៏មិនប្រកបដោយធម៌ ភិក្ខុនោះក៏ចេញទៅកាន់អាវាសដទៃ ឯភិក្ខុជាទីស្រឡាញ់ដែលនៅក្នុងអាវាសនោះក៏ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ ធ្វើឧក្ខេបនិយកម្មដល់ភិក្ខុនោះទៀត ( ភិក្ខុនោះ ) ក៏ចេញទៅកាន់អាវាសដទៃ ភិក្ខុជាទីស្រឡាញ់ដែលនៅក្នុងអាវាសដទៃ (នោះ)ជាពួក តែប្រកបដោយធម៌ធ្វើឧក្ខេបនិយកម្មដល់ភិក្ខុនោះ

បដិរូបកេន វគ្គាបិ
សមគ្គាបិ តថា ការី
អធម្មេន សមគ្គា ច
ធម្មេន វគ្គមេវ ច
បដិរូបកេន វគ្គា ច
សមគ្គា ច ឥមេ បញ្ច
ឯកោកតំ ទូលតំ ការកា
ចក្កំ តន្តុ វិទត្តាណោ ។
ពាលាព្យត្តស្ស និយស្សំ
បព្វាជេ កុលទូសកំ
បដិសារណីយំ កម្មំ
ករេ អក្កោសកស្ស ច
អទស្សនាប្បដិកម្មេ
យោ ច ទិដ្ឋិំ ន និស្សជ្ជេ
តេសំ ឧក្ខេបនំ កម្មំ
សត្ថុវាហេន កាសិតំ
ឧបរិនយកម្មាទិ



ទៀត ឯភិក្ខុទាំងឡាយនោះជាពួកទាំងពីរ ប្រកបដោយធម៌ប្ដូរ គំនាន់ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្ដូរក៏មាន បានធ្វើឧក្ខេបនីយកម្ម (ដល់ភិក្ខុនោះ) ដូចគ្នា ពួកទាំងឡាយនេះជា កម្មព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ កម្មជាពួក តែប្រកបដោយធម៌ កម្មជាពួកទាំងពីរប្រកបដោយធម៌ប្ដូរក៏ កម្មព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្ដូរក៏ (ពួកទាំងអស្សាលនេះ) អ្នកមានប្រាជ្ញាគប្បីធ្វើឲ្យមានមូលមួយ ៗ ហើយជនឲ្យជាពួក ។ សង្ឃធ្វើនិយស្សកម្ម ដល់ភិក្ខុល្ងង់ក៏ មិនឈ្លាសក៏ សង្ឃធ្វើបព្វាជនីយកម្ម ដល់ភិក្ខុដែលប្រទូស្តត្រកូលក៏ សង្ឃធ្វើបដិសារណីយកម្ម ដល់ភិក្ខុដែលជេរគ្រហស្ថក៏ ភិក្ខុណា មិនឃើញអាបត្តិក៏ មិនសំដែងអាបត្តិក៏ មិនលះបង់ទិដ្ឋិអាក្រក់ចេញក៏ ព្រះបរមគ្រូជាសត្ថុបានទ្រង់សំដែងនូវឧក្ខេបនីយកម្មដល់ភិក្ខុទាំងនោះ អ្នកមានប្រាជ្ញាគប្បីនាំទៅ

បរោក្ខា អត្ថចិយំ ជយេ

តេសំយោវ អនុលោមំ

សង្ហា វត្តិ យាចតិ

បសុត្តិ តេសំ កម្មានំ

ហេត្វា កម្មជាយេន ច

តស្មិំ តស្មិំ យំ កម្មេសុ

តត្រេត្វា ច វិកនតំ

អភាតំ ទុក្ខជាតេវ

បុន កាកាកាត្តិ ច

កម្មេ បសុត្តិយា ជាប់

តេ ភិក្ខូ ចម្មភធេតោ

វិបត្តិញ្ញាធិតេ ធិស្វា

កាម្មប្បត្តេ ឋយាធុំ

បធិប្បសុត្តិមគ្គាសំ

សល្លកាត្តោវ និសជត្តិ[១] ។

១ ឆដ្ឋ សង្គាយនា ១ ហេតុតេន យោគុយោ្យេន វិសេសត្តិ ញាតត្ថិ ។



តិចតួចទៀតក៏ដឹងច័យកម្មឧបាសិកាភិក្ខុទាំងឡាយដែលត្រូវដល់នៃយ-
កម្ម ភិក្ខុដែលសង្ឃធានទ្ធេកម្មហើយ ក៏ប្រព្រឹត្តដោយប្រពៃ
ចំពោះវត្តធំសមគួរដល់កម្មទាំងអម្បាលនោះ ហើយមកសូម
ការរម្ងាប់កម្មទាំងនោះ (នឹងសង្ឃ) តាមន័យនៃកម្មក្នុងខាង
ក្រោយ សង្ឃដែលឋិតនៅ ក្នុងទីនោះជាដៃគម្ព ក្នុងកម្ម
នោះៗក្តី ព្រំនោះសោភ ភិក្ខុទាំងឡាយណាមិយាយថា កម្ម
ឈ្មោះថា សង្ឃមិនបានធ្វើហើយ កម្មឈ្មោះថាសង្ឃធ្វើអា-
ក្រក់ហើយ កម្មសង្ឃគួរធ្វើឡើងវិញក្តី ភិក្ខុទាំងនោះឈ្មោះថា
ជម្រាំ ក្នុងការរម្ងាប់នូវកម្ម (នោះ) ព្រះសម្ពុទ្ធជាអ្នកប្រាជ្ញ
ដ៏ប្រសើរ ទ្រង់ឃើញភិក្ខុទាំងឡាយដែលមានវិបត្តិប្រៀតប្រៀន
ហើយជាភិក្ខុត្រូវដល់កម្ម ទើបទ្រង់សំដែងនូវវិធីរម្ងាប់កម្មដូច
ជាគេគ្រូពេទ្យល្បួសប្រាប់ឱ្យសេងឱសថឯង ។

[១៤៤] តេន សមយេន ពុទ្ធោ ភគវា កោសម្ពិយំ វិហរតិ ឃោសិតារាមេ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ អាបត្តឹ អាបន្នោ ហោតិ ។ សោ តស្សា អាបត្តិយា អាបត្តិទិដ្ឋិ ហោតិ អញ្ញេ ភិក្ខូ តស្សា អាបត្តិយា អនាបត្តិទិដ្ឋិនោ ហោន្តិ ។ សោ អបរេន សមយេន តស្សា អាបត្តិយា អនាបត្តិទិដ្ឋិ ហោតិ អញ្ញេ ភិក្ខូ តស្សា អាបត្តិយា អាបត្តិទិដ្ឋិនោ ហោន្តិ ។ អថខោ តេ ភិក្ខូ តំ ភិក្ខុំ ឯតទវោចុំ អាបត្តឹ ត្វំ អាវុសោ អាបន្នោ បស្សសេតំ អាបត្តិន្តិ ។ នត្ថិ មេ អាវុសោ អាបត្តិ យមហំ បស្សេយ្យន្តិ ។ អថខោ តេ ភិក្ខូ សាមគ្គឹ លភិត្វា តំ ភិក្ខុំ អាបត្តិយា អទស្សនេ ឧក្ខិបឹសុ ។ សោ ច ភិក្ខុ ពហុស្សុតោ ហោតិ អាគតាគមោ ធម្មធរោ វិនយធរោ មាតិកាធរោ បណ្ឌិតោ ព្យត្តោ មេធាវី លជ្ជី កុក្កុច្ចកោ សិក្ខាកាមោ ។ អថខោ សោ ភិក្ខុ សន្ទិដ្ឋេ សម្ភត្តេ ភិក្ខូ ឧបសង្កមិត្វា



(១៤៤) សម័យនោះឯង ព្រះពុទ្ធជាម្ចាស់មានព្រះភាគ ទ្រង់គង់នៅក្នុងឃោសិតារាម ទៀបក្រុងកោសម្ពី ។ វេលានោះឯង មានភិក្ខុមួយរូបត្រូវអាបត្តិ ។ ភិក្ខុនោះយល់ឃើញអាបត្តិនោះថា ជាអាបត្តិមែន ពួកភិក្ខុដទៃយល់ឃើញអាបត្តិនោះថា មិនមែនជាអាបត្តិទេវិញ ។ លុះកាលជាខាងក្រោយមក ភិក្ខុនោះត្រឡប់យល់ឃើញអាបត្តិនោះថា មិនមែនជាអាបត្តិទៅវិញ ពួកភិក្ខុដទៃត្រឡប់យល់ឃើញអាបត្តិនោះថា ជាអាបត្តិទៅវិញ ។ គ្រានោះ ភិក្ខុទាំងនោះបាននិយាយពាក្យនេះនឹងភិក្ខុនោះថា ម្នាលអាវុសោ លោកត្រូវអាបត្តិហើយ តើលោកបានឃើញអាបត្តិនុ៎ះឬទេ ។ ភិក្ខុនោះតបទៅវិញថា ម្នាលអាវុសោ អាបត្តិដែលខ្ញុំត្រូវឃើញនោះគ្មានទេ ។ វេលានោះ ភិក្ខុទាំងនោះបានសេចក្តីព្រមព្រៀងគ្នាហើយ ក៏លើកវត្តភិក្ខុនោះព្រោះមិនឃើញអាបត្តិ ។ ឯភិក្ខុនោះសោត ក៏ជាពហុស្សុត (ជាអ្នកចេះដឹងច្រើន) ស្ទាត់ក្នុងបិដក ជាអ្នកទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា ជាបណ្ឌិត ឈ្លៀវឆ្លាស មានប្រាជ្ញា មានសេចក្តីអៀនខ្មាស មានសេចក្តីរង្កៀស ទាំងមានសេចក្តីស្រឡាញ់ក្នុងសិក្ខា ។ លំដាប់នោះ ភិក្ខុនោះក៏បានចូលទៅរកពួកភិក្ខុដែលជាមិត្តធ្លាប់ឃើញគ្នា ជាមិត្តដ៏ស្និទ្ធ

ឯតទវោច អនាបត្តិ ឯសា អាវុសោ នេសា អាបត្តិ អនាបន្នោម្ហិ នម្ហិ អាបន្នោ អនុក្ខិត្តោម្ហិ នម្ហិ ឧក្ខិត្តោ អធម្មិកេនម្ហិ កម្មេន ឧក្ខិត្តោ កុប្បេន អដ្ឋានារហេន ហោថ មេ អាយស្មន្តោ ធម្មតោ វិនយតោ បក្ខាតិ ។ អលភិ ខោ សោ ភិក្ខុ សន្ទិដ្ឋេ សម្ភត្តេ ភិក្ខូ បក្ខេ ។ ជានបទានំ ច សន្ទិដ្ឋានំ សម្ភត្តានំ ភិក្ខូនំ សន្តិកេ ទូតំ បាហេសិ អនាបត្តិ ឯសា អាវុសោ នេសា អាបត្តិ អនាបន្នោម្ហិ នម្ហិ អាបន្នោ អនុក្ខិត្តោម្ហិ នម្ហិ ឧក្ខិត្តោ អធម្មិកេនម្ហិ កម្មេន ឧក្ខិត្តោ កុប្បេន អដ្ឋានារហេន ហោន្តុ មេ អាយស្មន្តោ ធម្មតោ វិនយតោ បក្ខាតិ ។ អលភិ ខោ សោ ភិក្ខុ ជានបទេបិ សន្ទិដ្ឋេ សម្ភត្តេ ភិក្ខូ បក្ខេ ។ អថ ខោ តេ ឧក្ខិត្តានុវត្តកា ភិក្ខូ យេន ឧក្ខេបកា ភិក្ខូ តេនុបសង្កមឹសុ ឧបសង្កមិត្វា



ហើយនិយាយពាក្យនេះថា នែអាវុសោ នេះជាអនាបត្តិ នេះមិនមែនជាអាបត្តិទេ ខ្ញុំជាភិក្ខុដែលមិនត្រូវអាបត្តិ ជាភិក្ខុឥតត្រូវអាបត្តិ(អ្វីទេ) ខ្ញុំជាភិក្ខុដែលសង្ឃមិនគួរលើកវត្ត ជាភិក្ខុដែលសង្ឃលើកវត្តមិនបានទេ សង្ឃបានលើកវត្តខ្ញុំដោយកម្មមិនប្រកបដោយធម៌ ជាកម្មកំរើក ជាកម្មមិនគួរដល់ហេតុ បពិត្រលោកដ៏មានអាយុទាំងឡាយ សូមលោកទាំងឡាយមកជាបក្ខពួករបស់ខ្ញុំតាមធម៌តាមវិន័យ ។ ភិក្ខុនោះក៏បានភិក្ខុដែលជាមិត្តគ្រាន់តែបានឃើញគ្នា និងមិត្តជំនាំមួនមកជាបក្ខពួកឡើង ។ មិនតែប៉ុណ្ណោះ ភិក្ខុនោះក៏បញ្ជូនបម្រើទៅក្នុងសំណាក់ពួកភិក្ខុដែលជាមិត្តគ្រាន់តែបានឃើញគ្នា និងមិត្តជំនាំមួនដែលនៅក្នុងជនបទថា នែអាវុសោ នេះជាអនាបត្តិ នេះមិនមែនជាអាបត្តិទេ ខ្ញុំជាភិក្ខុដែលមិនត្រូវអាបត្តិ ជាភិក្ខុឥតត្រូវអាបត្តិ(អ្វីទេ) ខ្ញុំជាភិក្ខុដែលសង្ឃមិនគួរលើកវត្ត ជាភិក្ខុដែលសង្ឃលើកវត្តមិនបានទេ សង្ឃបានលើកវត្តខ្ញុំដោយកម្មមិនប្រកបដោយធម៌ ជាកម្មកំរើក ជាកម្មមិនគួរដល់ហេតុឡើយ សូមអស់លោកដ៏មានអា-យុមកជាបក្ខពួកនៃខ្ញុំតាមធម៌តាមវិន័យ ។ ភិក្ខុនោះក៏បានភិក្ខុដែលជាមិត្តគ្រាន់តែបានឃើញគ្នា និងមិត្តជំនាំមួនដែលនៅក្នុងជនបទមកជាបក្ខពួកឡើង ។ គ្រានោះ ពួកភិក្ខុអ្នកប្រព្រឹត្តតាមភិក្ខុដែលសង្ឃលើកវត្តនោះ បានចូលទៅរកពួកភិក្ខុអ្នកលើកវត្ត លុះចូលទៅដល់ហើយក៏បាននិយាយ

ឧក្ខេបកោ ភិក្ខុ ឯតទវោច អនាបត្តិ ឯសា អាវុសោ នេសា អាបត្តិ អនាបន្នោ ឯសោ ភិក្ខុ នេសោ ភិក្ខុ អាបន្នោ អនុក្ខិត្តោ ឯសោ ភិក្ខុ នេសោ ភិក្ខុ ឧក្ខិត្តោ អធម្មិកេន កម្មេន ឧក្ខិត្តោ កុប្បេន អដ្ឋានារហេនាតិ ។ ឯវំ វុត្តេ ឧក្ខេបកា ភិក្ខូ ឧក្ខិត្តានុវត្តកេ ភិក្ខូ ឯតទវោចុំ អាបត្តិ ឯសា អាវុសោ នេសា អនាបត្តិ អាបន្នោ ឯសោ ភិក្ខុ នេសោ ភិក្ខុ អនាបន្នោ ឧក្ខិត្តោ ឯសោ ភិក្ខុ នេសោ ភិក្ខុ អនុក្ខិត្តោ ធម្មិកេន កម្មេន ឧក្ខិត្តោ អកុប្បេន ឋានារហេន មា ខោ តុម្ហេ អាយស្មន្តោ ឯតំ ឧក្ខិត្តកំ ភិក្ខុំ អនុវត្តិត្ថ អនុបរិវារេថាតិ ។ ឯវម្បិ ខោ តេ ឧក្ខិត្តានុវត្តកា ភិក្ខូ ឧក្ខេបកេហិ ភិក្ខូហិ វុច្ចមានា តថេវ តំ ឧក្ខិត្តកំ ភិក្ខុំ អនុវត្តឹសុ អនុបរិវារេសុំ ។



ពាក្យនេះនឹងពួកភិក្ខុលើកវត្តថា នែអាវុសោ នេះជាអនាបត្តិ នេះមិនមែនជាអាបត្តិទេ ភិក្ខុនេះមិនត្រូវអាបត្តិ ភិក្ខុនេះឥតត្រូវអាបត្តិ ( ទេ ) ភិក្ខុនេះសង្ឃមិនគួរលើកវត្ត ភិក្ខុនេះសង្ឃលើកវត្តមិនបាននេះ សង្ឃលើកវត្តភិក្ខុនេះដោយកម្មមិនប្រកបដោយធម៌ ជាកម្មកំរើក ជាកម្មមិនគួរដល់ហេតុឡើយ ។ កាលបើភិក្ខុទាំងនោះនិយាយយ៉ាងនេះហើយ ពួកភិក្ខុអ្នកលើកវត្តបាននិយាយពាក្យនេះនឹងពួកភិក្ខុអ្នកប្រព្រឹត្តតាមភិក្ខុដែលសង្ឃលើកវត្តវិញថា នែអាវុសោ នេះជាអាបត្តិ នេះមិនមែនជាអនាបត្តិទេ ភិក្ខុនេះត្រូវអាបត្តិហើយ ភិក្ខុនេះមិនមែនជាមិនត្រូវអាបត្តិទេ ភិក្ខុនេះសង្ឃគួរលើកវត្តបានហើយ ភិក្ខុនេះមិនមែនជាភិក្ខុដែលសង្ឃលើកវត្តមិនបានទេ ភិក្ខុនេះសង្ឃលើកវត្តដោយកម្មប្រកបដោយធម៌ ជាកម្មមិនកំរើក ជាកម្មគួរដល់ហេតុហើយ បពិត្រលោកដ៏មានអាយុទាំងឡាយ អស់លោកកុំប្រព្រឹត្តតាម កុំតាមចោមរោមភិក្ខុដែលសង្ឃបានលើកវត្តនេះឡើយ ។ ឯពួកភិក្ខុអ្នកប្រព្រឹត្តតាមភិក្ខុដែលសង្ឃលើកវត្តនោះ កាលបើពួកភិក្ខុអ្នកលើកវត្តនិយាយយ៉ាងនេះហើយ ក៏នៅតែប្រព្រឹត្តតាម នៅតែតាមចោមរោមភិក្ខុដែលសង្ឃបានលើកវត្តហើយនោះដដែល ។

[១៤៨] អថខោ អញ្ញតរោ ភិក្ខុ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច ឥធ ភន្តេ អញ្ញតរោ ភិក្ខុ អាបត្តឹ អាបន្នោ អហោសិ សោ តស្សា អាបត្តិយា អាបត្តិទិដ្ឋិ អហោសិ អញ្ញេ ភិក្ខូ តស្សា អាបត្តិយា អនាបត្តិទិដ្ឋិនោ អហេសុំ សោ អបរេន សមយេន តស្សា អាបត្តិយា អនាបត្តិទិដ្ឋិ អហោសិ អញ្ញេ ភិក្ខូ តស្សា អាបត្តិយា អាបត្តិទិដ្ឋិនោ អហេសុំ អថខោ តេ ភន្តេ ភិក្ខូ តំ ភិក្ខុំ ឯតទវោចុំ អាបត្តឹ ត្វំ អាវុសោ អាបន្នោ បស្សសេតំ អាបត្តិន្តិ ។ នត្ថិ មេ អាវុសោ អាបត្តិ យមហំ បស្សេយ្យន្តិ ។ អថខោ តេ ភន្តេ ភិក្ខូ សាមគ្គឹ លភិត្វា តំ ភិក្ខុំ អាបត្តិយា អទស្សនេ ឧក្ខិបឹសុ ។ សោ ច ភន្តេ ភិក្ខុ ពហុស្សុតោ អាគតាគមោ ធម្មធរោ វិនយធរោ មាតិកាធរោ បណ្ឌិតោ ព្យត្តោ មេធាវី លជ្ជី កុក្កុច្ចកោ សិក្ខាកាមោ





[១៤៨] គ្រានោះ មានភិក្ខុ១រូបចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ ភិក្ខុនោះលុះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ក្នុងវត្តនេះមានភិក្ខុ១រូបត្រូវអាបត្តិហើយ ភិក្ខុនោះបានយល់ឃើញអាបត្តិនោះថាជាអាបត្តិមែន តែពួកភិក្ខុដទៃយល់ឃើញអាបត្តិនោះថាមិនមែនជាអាបត្តិ លុះកាលជាខាងក្រោយ ភិក្ខុនោះត្រឡប់យល់ឃើញអាបត្តិនោះថាមិនមែនជាអាបត្តិទៅវិញ ពួកភិក្ខុដទៃត្រឡប់យល់ឃើញអាបត្តិនោះថាជាអាបត្តិទៅវិញ សូមទ្រង់ព្រះមេត្តាប្រោស គ្រាវេលានោះឯង ភិក្ខុទាំងឡាយនោះនិយាយពាក្យនេះនឹងភិក្ខុនោះថា នែអាវុសោ លោកត្រូវអាបត្តិហើយ តើលោកឃើញអាបត្តិនុះឬទេ ភិក្ខុនោះឆ្លើយថា នែអាវុសោ អាបត្តិដែលខ្ញុំត្រូវឃើញនោះគ្មានទេ សូមទ្រង់ព្រះមេត្តាប្រោស គ្រានោះ ភិក្ខុទាំងនោះបាននូវសេចក្តីសាមគ្គីគ្នាហើយក៏លើកវត្តភិក្ខុនោះព្រោះមិនឃើញអាបត្តិ សូមទ្រង់ព្រះមេត្តាប្រោស ឯភិក្ខុនោះសោតក៏ជាពហុស្សុត ស្ទាត់ក្នុងបិដក ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា ហើយជាបណ្ឌិត ឈ្លៀវឈ្លាស មានប្រាជ្ញា មានសេចក្តីអៀនខ្មាស មានសេចក្តីរង្កៀស មានសេចក្តី

អថខោ សោ ភន្តេ ភិក្ខុ សន្ទិដ្ឋេ សម្ភត្តេ ភិក្ខូ ឧបសង្កមិត្វា ឯវំ វទេតិ អនាបត្តិ ឯសា អាវុសោ នេសា អាបត្តិ អនាបន្នោម្ហិ នត្ថម្ហិ អាបន្នោ អនុក្ខិត្តោម្ហិ នត្ថម្ហិ ឧក្ខិត្តោ អធម្មិកេនម្ហិ កម្មេន ឧក្ខិត្តោ កុប្បេន អដ្ឋានារហេន ហោថ មេ អាយស្មន្តោ ធម្មតោ វិនយតោ បក្ខាតិ អលភិ ខោ សោ ភន្តេ ភិក្ខុ សន្ទិដ្ឋេ សម្ភត្តេ ភិក្ខូ បក្ខេ ជានបទានំបិ សន្ទិដ្ឋានំ សម្ភត្តានំ សន្តិកេ ទូតំ បាហេសិ អនាបត្តិ ឯសា អាវុសោ នេសា អាបត្តិ អនាបន្នោម្ហិ នត្ថម្ហិ អាបន្នោ អនុក្ខិត្តោម្ហិ នត្ថម្ហិ ឧក្ខិត្តោ អធម្មិកេនម្ហិ កម្មេន ឧក្ខិត្តោ កុប្បេន អដ្ឋានារហេន ហោន្តុ មេ អាយស្មន្តោ ធម្មតោ វិនយតោ បក្ខាតិ អលភិ ខោ សោ ភន្តេ ភិក្ខុ ជានបទេបិ សន្ទិដ្ឋេ សម្ភត្តេ



ស្រេចព្រមក្នុងសង្ឃ សូមទ្រង់ព្រះមេត្តាប្រោស គ្រានោះ ភិក្ខុនោះចូលទៅរកពួកភិក្ខុដែលជាមិត្តគ្រាន់តែឃើញគ្នា នឹងមិត្តដ៏មាំមួនហើយនិយាយពាក្យនេះថា នែអាវុសោ នេះជាអនាបត្តិ នេះមិនមែនជាអាបត្តិទេ ខ្ញុំជាភិក្ខុដែលមិនត្រូវអាបត្តិ ជាភិក្ខុឥតត្រូវអាបត្តិ (ក្តីទេ) ខ្ញុំជាភិក្ខុដែលសង្ឃមិនគួរលើកវត្ត ជាភិក្ខុដែលសង្ឃលើកវត្តមិនបានទេ សង្ឃបានលើកវត្តខ្ញុំដោយកម្មមិនប្រកបដោយធម៌ ជាកម្មកំរើក ជាកម្មមិនគួរដល់ហេតុ បពិត្រលោកដ៏មានអាយុទាំងឡាយ សូមអស់លោកមកជាបក្សពួកនឹងខ្ញុំតាមធម៌ តាមវិន័យ សូមទ្រង់ព្រះមេត្តាប្រោស ភិក្ខុនោះក៏បានភិក្ខុដែលជាមិត្តគ្រាន់តែឃើញគ្នា នឹងជាមិត្តដ៏មាំមួនមកជាបក្សពួកឡើង មិនតែប៉ុណ្ណោះ ភិក្ខុនោះបានបញ្ជូនបំរើទៅក្នុងសំណាក់ពួកភិក្ខុដែលជាមិត្តគ្រាន់តែឃើញគ្នា នឹងជាមិត្តដ៏មាំមួនដែលនៅក្នុងជនបទថា នែអាវុសោ នេះជាអនាបត្តិ នេះមិនមែនជាអាបត្តិទេ ខ្ញុំជាភិក្ខុដែលមិនត្រូវអាបត្តិ ជាភិក្ខុឥតត្រូវអាបត្តិ (ក្តីទេ) ខ្ញុំជាភិក្ខុដែលសង្ឃមិនគួរលើកវត្ត ជាភិក្ខុដែលសង្ឃលើកវត្តមិនបានទេ សង្ឃបានលើកវត្តខ្ញុំដោយកម្មមិនប្រកបដោយធម៌ ជាកម្មកំរើក ជាកម្មមិនគួរដល់ហេតុ សូមអស់លោកដ៏មានអាយុមកជាបក្សពួកនឹងខ្ញុំតាមធម៌ តាមវិន័យ សូមទ្រង់ព្រះមេត្តាប្រោស ភិក្ខុនោះក៏បានភិក្ខុដែលជាមិត្តគ្រាន់តែឃើញគ្នា នឹងជាមិត្តដ៏មាំមួន

ភិក្ខូ បក្ខំ អលត្ថុំ អថ ខោ តេ ឧក្ខិត្តានុវត្តកា ភិក្ខូ យេន ឧក្ខេបកា ភិក្ខូ តេនុបសង្កមឹសុ ឧបសង្កមិត្វា ឧក្ខេបកេ ភិក្ខូ ឯតទវោចុំ អនាបត្តិ ឯសា អាវុសោ នេសា អាបត្តិ អនាបន្នោ ឯសោ ភិក្ខុ នេសោ ភិក្ខុ អាបន្នោ អនុក្ខិត្តោ ឯសោ ភិក្ខុ នេសោ ភិក្ខុ ឧក្ខិត្តោ អធម្មិកេន កម្មេន ឧក្ខិត្តោ កុប្បេន អដ្ឋានារហេនាតិ ឯវំ វុត្តេ ឧក្ខេបកា ភិក្ខូ ឧក្ខិត្តានុវត្តកេ ភិក្ខូ ឯតទវោចុំ អាបត្តិ ឯសា អាវុសោ នេសា អនាបត្តិ អាបន្នោ ឯសោ ភិក្ខុ នេសោ ភិក្ខុ អនាបន្នោ ឧក្ខិត្តោ ឯសោ ភិក្ខុ នេសោ ភិក្ខុ អនុក្ខិត្តោ ធម្មិកេន កម្មេន ឧក្ខិត្តោ អកុប្បេន ឋានារហេន មា ខោ តុម្ហេ អាយស្មន្តោ ឯតំ ឧក្ខិត្តកំ ភិក្ខុំ អនុវត្តិត្ថ អនុបរិវារេថាតិ



ដែលនៅក្នុងទីជនបទមកជាបក្សពួកទៀត សូមទ្រង់ព្រះមេត្តាប្រោស វេលានោះ ពួកភិក្ខុអ្នកប្រព្រឹត្តតាមភិក្ខុដែលសង្ឃលើកវត្តនោះបានចូលទៅរកពួកភិក្ខុអ្នកលើកវត្ត លុះចូលទៅដល់ហើយ ក៏និយាយពាក្យនេះនឹងពួកភិក្ខុអ្នកលើកវត្តថា នែអាវុសោ នេះជាអនាបត្តិ នេះមិនមែនជាអាបត្តិទេ ភិក្ខុនេះមិនត្រូវអាបត្តិ ភិក្ខុនេះឥតត្រូវអាបត្តិ(ឡើយ) ភិក្ខុនេះសង្ឃមិនឲ្យលើកវត្ត ភិក្ខុនេះសង្ឃលើកវត្តមិនបានទេ សង្ឃបានលើកវត្តភិក្ខុនេះដោយកម្មមិនប្រកបដោយធម៌ ជាកម្មកំរើក ជាកម្មមិនគួរដល់ហេតុ សូមទ្រង់ព្រះមេត្តាប្រោស កាលបើភិក្ខុទាំងនោះនិយាយយ៉ាងនេះហើយ ឯពួកភិក្ខុអ្នកលើកវត្តក៏និយាយពាក្យនេះនឹងពួកភិក្ខុអ្នកប្រព្រឹត្តតាមភិក្ខុដែលសង្ឃលើកវត្តយ៉ាងនេះថា នែអាវុសោ នេះជាអាបត្តិ នេះមិនមែនជាអនាបត្តិទេ ភិក្ខុនេះត្រូវអាបត្តិហើយ ភិក្ខុនេះមិនមែនជាមិនត្រូវអាបត្តិទេ ភិក្ខុនេះសង្ឃឲ្យលើកវត្តហើយ ភិក្ខុនេះមិនមែនជាភិក្ខុដែលសង្ឃលើកវត្តមិនបានទេ សង្ឃបានលើកវត្តភិក្ខុនេះដោយកម្មប្រកបដោយធម៌ ជាកម្មមិនកំរើក ជាកម្មគួរដល់ហេតុហើយ បពិត្រលោកដ៏មានអាយុទាំងឡាយ អស់លោកកុំប្រព្រឹត្តតាម កុំចោមរោមភិក្ខុដែលសង្ឃ

ឯវម្បិ ខោ តេ ភន្តេ ឧក្ខិត្តានុវត្តកា ភិក្ខូ ឧក្ខេប-កេហិ ភិក្ខូហិ វុច្ចមានា តថេវ តំ ឧក្ខិត្តកំ ភិក្ខុំ អនុវត្តន្តិ អនុបរិវត្តន្តីតិ ។ អថខោ ភគវា ភិន្នោ ភិក្ខុ-សង្ឃោ ភិន្នោ ភិក្ខុសង្ឃោតិ ឧដ្ឋាយាសនា យេន ឧក្ខេបកា ភិក្ខូ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ និសជ្ជ ខោ ភគវា ឧក្ខេបកេ ភិក្ខូ ឯតទវោច មា ខោ តុម្ហេ ភិក្ខវេ បដិភាតិ នោ បដិភាតិ នោតិ យស្មឹ វា តស្មឹ វា ភិក្ខុំ ឧក្ខិបិតព្វំ មញ្ញិត្ថ ។ ឥធ បន ភិក្ខវេ ភិក្ខុ អាបត្តឹ អាបន្នោ ហោតិ ។ សោ តស្សា អាបត្តិយា អនាបត្តិទិដ្ឋិ ហោតិ អញ្ញេ ភិក្ខូ តស្សា អាបត្តិយា អាបត្តិទិដ្ឋិនោ ហោន្តិ ។ តេ ចេ ភិក្ខវេ ភិក្ខូ តំ ភិក្ខុំ ឯវំ ជានន្តិ អយំ ខោ អា-យស្មា ពហុស្សុតោ ។បេ។ សិក្ខាកាមោ សចេ មយំ ឥមំ ភិក្ខុំ អាបត្តិយា អទស្សនេ ឧក្ខិបិស្សាម ន មយំ



បានលើកវត្តនេះឡើយ សូមទ្រង់ព្រះមេត្តាប្រោស ពួកភិក្ខុអ្នកប្រព្រឹត្តតាមភិក្ខុដែលសង្ឃលើកវត្តនោះ កាលបើពួកភិក្ខុអ្នកលើកវត្តនិយាយយ៉ាងនេះហើយ ក៏នៅតែប្រព្រឹត្តតាម នៅតែតាមចោមរោមភិក្ខុដែលសង្ឃបានលើកវត្តនោះដដែល ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ភិក្ខុសង្ឃបែកគ្នាហើយ ភិក្ខុសង្ឃបែកគ្នាហើយ ទើបទ្រង់ក្រោកចាកអាសនៈហើយ យាងចូលទៅរកពួកភិក្ខុអ្នកលើកវត្ត លុះយាងចូលទៅដល់ហើយ ក៏ទ្រង់គង់លើអាសនៈដែលគេរៀបចំក្រាលថ្វាយ ។ លុះព្រះដ៏មានព្រះភាគទ្រង់គង់រួចហើយក៏មានព្រះពុទ្ធដីកានឹងពួកភិក្ខុអ្នកលើកវត្តយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំសំគាល់ភិក្ខុដែលសង្ឃគប្បីលើកវត្តព្រោះហេតុណាមួយថា ការនេះប្រាកដដល់យើងហើយ ការនេះប្រាកដដល់យើងហើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះត្រូវអាបត្តិហើយ ។ ភិក្ខុនោះយល់ឃើញអាបត្តិនោះថាជាអនាបត្តិ ឯពួកភិក្ខុដទៃយល់ឃើញអាបត្តិនោះថាជាអាបត្តិមែន ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទាំងនោះស្គាល់ភិក្ខុនោះយ៉ាងនេះថា លោកដ៏មានអាយុនេះជាពហុស្សូត ។បេ។ មានសេចក្តីស្រឡាញ់ក្នុងសិក្ខា បើយើងនឹងលើកវត្តភិក្ខុនេះព្រោះមិនឃើញអាបត្តិ យើងនឹងមិនធ្វើ

ឥមិនា ភិក្ខុនា សទ្ធិំ ឧបោសថំ ករិស្សាម វិនា ឥមិនា ភិក្ខុនា ឧបោសថំ ករិស្សាម ភវិស្សតិ សង្ឃស្ស តតោនិទានំ ភណ្ឌនំ កលហោ វិគ្គហោ វិវាទោ សង្ឃភេទោ សង្ឃរាជិ សង្ឃវវត្ថានំ សង្ឃនានាករណន្តិ ។ ភេទគរុកេហិ ភិក្ខវេ ភិក្ខូហិ ន សោ ភិក្ខុ អាបត្តិយា អទស្សនេ ឧក្ខិបិតព្វោ ។ ឥធ បន ភិក្ខវេ ភិក្ខុ អាបត្តិំ អាបន្នោ ហោតិ ។ សោ តស្សា អាបត្តិយា អនាបត្តិទិដ្ឋិ ហោតិ អញ្ញេ ភិក្ខូ តស្សា អាបត្តិយា អាបត្តិទិដ្ឋិនោ ហោន្តិ ។ តេ ចេ ភិក្ខវេ ភិក្ខូ តំ ភិក្ខុំ ឯវំ ជានន្តិ អយំ ខោ អាយស្មា ពហុស្សុតោ ។បេ។ សិក្ខាកាមោ សចេ មយំ ឥមំ ភិក្ខុំ អាបត្តិយា អទស្សនេ ឧក្ខិបិស្សាម ន មយំ ឥមិនា ភិក្ខុនា សទ្ធិំ បវារេស្សាម វិនា ឥមិនា ភិក្ខុនា បវារេស្សាម ន មយំ ឥមិនា ភិក្ខុនា សទ្ធិំ សង្ឃកម្មំ ករិស្សាម វិនា ឥមិនា ភិក្ខុនា សង្ឃកម្មំ ករិស្សាម ន មយំ ឥមិនា ភិក្ខុនា សទ្ធិំ អាសនេ និសីទិស្សាម វិនា ឥមិនា ភិក្ខុនា អាសនេ និសីទិស្សាម ន មយំ ឥមិនា ភិក្ខុនា សទ្ធិំ



ធ្វើឧបោសថជាមួយនឹងភិក្ខុនេះ យើងវៀរលែងភិក្ខុនេះចេញទើបធ្វើឧបោសថ (នោះ) ការបង្កហេតុ ការឈ្លោះ ការប្រកាន់ផ្សេង ៗ សេចក្តីវិវាទ សេចក្តីបែកធ្លាយនៃសង្ឃ សេចក្តីប្រេះឆានៃសង្ឃ សេចក្តីកំណត់របស់សង្ឃ និងអំពើផ្សេង ៗ របស់សង្ឃ មុខជានឹងមានដល់សង្ឃ ព្រោះការលើកវត្តភិក្ខុនោះជាហេតុមិនខាន ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុដែលមានចិត្តធ្ងន់ក្នុងការបំបែកសង្ឃ មិនគួរនឹងលើកវត្តភិក្ខុនោះ ព្រោះមិនឃើញអាបត្តិទេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មានភិក្ខុត្រូវអាបត្តិហើយ ។ ភិក្ខុនោះយល់ឃើញអាបត្តិនោះថាជាអនាបត្តិ ឯពួកភិក្ខុដទៃយល់ឃើញអាបត្តិនោះថាជាអាបត្តិ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទាំងនោះស្គាល់ភិក្ខុនោះយ៉ាងនេះថា លោកដ៏មានអាយុនេះជាពហុស្សុត ។បេ។ មានសេចក្តីស្រឡាញ់ក្នុងសិក្ខា បើយើងនឹងលើកវត្តភិក្ខុនេះព្រោះមិនឃើញនូវអាបត្តិហើយ យើងមុខជាមិនបវារណាជាមួយនឹងភិក្ខុនេះ តែយើងវៀរលែងភិក្ខុនេះចេញហើយបវារណា យើងមុខជានឹងមិនធ្វើសង្ឃកម្មជាមួយនឹងភិក្ខុនេះដែរ តែយើងវៀរលែងភិក្ខុនេះចេញហើយធ្វើសង្ឃកម្ម យើងមុខជានឹងមិនអង្គុយលើអាសនៈជាមួយនឹងភិក្ខុនេះដែរ តែយើង វៀរលែងភិក្ខុនេះចេញហើយអង្គុយលើអាសនៈ យើងមុខជានឹងមិនអង្គុយក្នុងទីឆាន់បបរជាមួយនឹង

យាគុបានេ និសីទិស្សាម វិនា ឥមិនា ភិក្ខុនា យាគុបានេ និសីទិស្សាម ន មយំ ឥមិនា ភិក្ខុនា សទ្ធឹ ភត្តគ្គេ និសីទិស្សាម វិនា ឥមិនា ភិក្ខុនា ភត្តគ្គេ និសីទិស្សាម ន មយំ ឥមិនា ភិក្ខុនា សទ្ធឹ ឯកច្ឆន្នេ វសិស្សាម វិនា ឥមិនា ភិក្ខុនា ឯកច្ឆន្នេ វសិស្សាម ន មយំ ឥមិនា ភិក្ខុនា សទ្ធឹ យថាវុឌ្ឍំ អភិវាទនំ បច្ចុដ្ឋានំ អញ្ជលិកម្មំ សាមីចិកម្មំ ករិស្សាម វិនា ឥមិនា ភិក្ខុនា យថាវុឌ្ឍំ អភិវាទនំ បច្ចុដ្ឋានំ អញ្ជលិកម្មំ សាមីចិកម្មំ ករិស្សាម ភវិស្សតិ សង្ឃស្ស តតោនិទានំ ភណ្ឌនំ កលហោ វិគ្គហោ វិវាទោ សង្ឃភេទោ សង្ឃរាជិ សង្ឃវវត្ថានំ សង្ឃនានាករណន្តិ ។ ភេទគរុកេហិ ភិក្ខវេ ភិក្ខូហិ ន អយំ ភិក្ខុ អាបត្តិយា អទស្សនេ ឧក្ខិបិតព្វោតិ ។ អថខោ ភគវា ឧក្ខេបកានំ ភិក្ខូនំ ឯតមត្ថំ ភាសិត្វា



ភិក្ខុនេះដែរ តែបើវៀរលែងភិក្ខុនេះចេញ ហើយអង្គុយនៅក្នុងទីផឹកបបរ ដើម្បីជាទីមិនអង្គុយក្នុងរោងភត្តជាមួយនឹងភិក្ខុនេះដែរ តែបើវៀរលែងភិក្ខុនេះចេញ ហើយអង្គុយក្នុងរោងភត្ត ដើម្បីជាទីមិននៅក្នុងទីដែលមានដំបូលមួយជាមួយនឹងភិក្ខុនេះដែរ តែបើវៀរលែងភិក្ខុនេះចេញ ហើយនៅក្នុងទីដែលមានដំបូលមួយ ដើម្បីជាទីមិនធ្វើអភិវាទនកម្ម(១) បច្ចុដ្ឋានកម្ម(២) អញ្ជលីកម្ម(៣) និងសាមីចិកម្ម(៤) តាមលំដាប់ចាស់ជាមួយនឹងភិក្ខុនេះដែរ តែបើវៀរលែងភិក្ខុនេះចេញ ហើយធ្វើអភិវាទនកម្ម បច្ចុដ្ឋានកម្ម អញ្ជលីកម្ម និងសាមីចិកម្ម តាមលំដាប់ចាស់ទុំ(នោះ)ការបង្កហេតុ ការឈ្លោះ ការប្រកាន់ផ្សេងៗ សេចក្តីទាស់ សេចក្តីបែកធ្លាយនៃសង្ឃ សេចក្តីប្រេះឆានៃសង្ឃ សេចក្តីកំណត់របស់សង្ឃ និងការធ្វើផ្សេងៗរបស់សង្ឃ មុខជានឹងមានដល់សង្ឃ ព្រោះការលើកវត្តភិក្ខុនោះជាហេតុមិនខាន ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុដែលមានចិត្តធ្ងន់នឹងការបំបែកសង្ឃ មិនគួរនឹងលើកវត្តភិក្ខុនោះ ព្រោះមិនឃើញអាបត្តិទេ ។ គ្រានោះ ព្រះដ៏មានព្រះភាគបានសំដែងសេចក្តីនុះដល់ពួកលើកវត្តភិក្ខុ ហើយក៏ទ្រង់ក្រោកចាក

១ ការក្រាបថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ។ ២ ការក្រោកទទួលដោយកិរិយាក្រាបទូល ។ ៣ ការគោរពដោយការប្រណម្យដៃ ។ ៤ ការគោរពត្រង់ ។

ឧដ្ឋាយាសនា យេន ឧក្ខិត្តានុវត្តកា ភិក្ខូ តេនុប-
សង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។
និសជ្ជ ខោ ភគវា ឧក្ខិត្តានុវត្តកេ ភិក្ខូ ឯតទវោច មា
ខោ តុម្ហេ ភិក្ខវេ អាបត្តឹ អាបជ្ជិត្វា នម្ហ អាបន្នា នម្ហ
អាបន្នាតិ អាបត្តិ ន បដិកាតព្វំ មញ្ញិត្ថ ។ ឥធ បន
ភិក្ខវេ ភិក្ខុ អាបត្តឹ អាបន្នោ ហោតិ ។ សោ តស្សា
អាបត្តិយា អនាបត្តិទិដ្ឋិ ហោតិ អញ្ញេ ភិក្ខូ តស្សា អា-
បត្តិយា អាបត្តិទិដ្ឋិនោ ហោន្តិ ។ សោ ចេ ភិក្ខវេ ភិក្ខុ
តេ ភិក្ខូ ឯវំ ជានាតិ ឥមេ ខោ អាយស្មន្តា[១]
ពហុស្សុតា ។បេ។ សិក្ខាកាមា នាលំ មមំ វា ការ-
ណា អញ្ញស្ស វា ការណា ឆន្ទា ទោសា មោហា ភយា
អគតឹ គន្តុំ សចេ មំ ឥមេ ភិក្ខូ អាបត្តិយា អទស្សនេ
ឧក្ខិបិស្សន្តិ ន មយា សទ្ធឹ ឧបោសថំ ករិស្សន្តិ
វិនា មយា ឧបោសថំ ករិស្សន្តិ ភវិស្សតិ សង្ឃស្ស
តតោនិទានំ ភណ្ឌនំ កលហោ វិគ្គហោ វិវាទោ សង្ឃភេ-
ទោ សង្ឃរាជិ សង្ឃវវត្ថានំ សង្ឃនានាករណន្តិ ។

១ ឱ. អាយស្មា ។



អាសនៈហើយ យាងចូលទៅរកពួកឧក្ខិត្តានុវត្តកភិក្ខុ លុះយាងចូលទៅដល់
ហើយ ទ្រង់គង់លើអាសនៈដែលគេរៀបចំទុក ។ លុះព្រះមានព្រះភាគ
ទ្រង់គង់ហើយ ក៏មានព្រះពុទ្ធដីកាទៅនឹងពួកឧក្ខិត្តានុវត្តកភិក្ខុយ៉ាងនេះថា
ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវអាបត្តិហើយ កុំសំគាល់អាបត្តិថា
គួរមិនត្រូវសំដែង ដោយគិតថា យើងមិនត្រូវអាបត្តិទេ យើងមិនត្រូវអាបត្តិ
ទេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះត្រូវអាបត្តិហើយ ។ ភិក្ខុនោះ
យល់ឃើញអាបត្តិនោះថាជាអនាបត្តិ តែពួកភិក្ខុដទៃយល់ឃើញអាបត្តិ
នោះថាជាអាបត្តិមែន ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុនោះស្គាល់ភិក្ខុទាំង
នោះយ៉ាងនេះថា អស់លោកដ៏មានអាយុនេះជាពហុស្សុត ។បេ។ មានការ
ប្រាថ្នាក្នុងសិក្ខា មិនគួរទៅនឹងលុះអគតិ ព្រោះសេចក្តីស្រឡាញ់ សេចក្តីស្អប់
សេចក្តីវង្វេង សេចក្តីខ្លាច ព្រោះហេតុតែអាត្មាអញ ឬព្រោះហេតុតែបុគ្គល
ដទៃឡើយ បើភិក្ខុទាំងនេះនឹងលើកវត្តអាត្មាអញ ព្រោះមិនឃើញអាបត្តិ
ហើយ មុខជានឹងមិនធ្វើឧបោសថជាមួយនឹងអាត្មាអញទេ តែភិក្ខុទាំងនោះ
វៀរលែងអាត្មាអញហើយធ្វើឧបោសថ (នោះ) ការបង្កហេតុ ការឈ្លោះ
ការប្រកាន់ផ្សេង ៗ សេចក្តីវិវាទ សេចក្តីបែកធ្លាយនៃសង្ឃ សេចក្តីប្រេះឆា
នៃសង្ឃ សេចក្តីកំណត់របស់សង្ឃ នឹងអំពើផ្សេង ៗ របស់សង្ឃ មុខ
ជានឹងមានដល់សង្ឃ ព្រោះការលើកវត្តអាត្មាអញនោះជាហេតុមិនខាន ។

ភេទគរុកេន ភិក្ខវេ ភិក្ខុនា បរេសំបិ សទ្ធាយ[1] សា អាបត្តិ ទេសេតព្វា ។ ឥធ បន ភិក្ខវេ ភិក្ខុ អាបត្តឹ អាបន្នោ ហោតិ ។ សោ តស្សា អាបត្តិយា អនាបត្តិទិដ្ឋិ ហោតិ អញ្ញេ ភិក្ខូ តស្សា អាបត្តិយា អាបត្តិទិដ្ឋិនោ ហោន្តិ ។ សោ ចេ ភិក្ខវេ ភិក្ខុ តេ ភិក្ខូ ឯវំ ជានាតិ ឥមេ ខោ អាយស្មន្តោ ពហុស្សុតា ។ បេ ។ សិក្ខាកាមា នាលំ មមំ វា ការណា អញ្ញស្ស វា ការណា ឆន្ទា ទោសា មោហា ភយា អគតឹ គន្តុំ សចេ មំ ឥមេ ភិក្ខូ អាបត្តិយា អទស្សនេ ឧក្ខិបិស្សន្តិ ន មយា សទ្ធឹ ឧបោសថំ ករិស្សន្តិ វិនា មយា ឧបោសថំ ករិស្សន្តិ ន មយា សទ្ធឹ សង្ឃកម្មំ ករិស្សន្តិ វិនា មយា សង្ឃកម្មំ ករិស្សន្តិ ន មយា សទ្ធឹ អាសនេ និសីទិស្សន្តិ វិនា មយា អាសនេ និសីទិស្សន្តិ ន មយា សទ្ធឹ យាគុបានេ និសីទិស្សន្តិ វិនា មយា យាគុបានេ និសីទិស្សន្តិ ន មយា សទ្ធឹ ភត្តគ្គេ និសីទិស្សន្តិ វិនា មយា ភត្តគ្គេ និសីទិស្សន្តិ ន មយា សទ្ធឹ ឯកច្ឆន្នេ វសិស្សន្តិ វិនា មយា ឯកច្ឆន្នេ

---

១ សទ្ធាយ ។



ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលមានចិត្តខ្លាចនូវការបំបែកសង្ឃ គួរតែសំដែងអាបត្តិនោះចេញ តាមសេចក្តីជឿពាក្យរបស់ភិក្ខុដទៃ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិហើយ ។ ភិក្ខុនោះយល់ឃើញអាបត្តិនោះថាជាអនាបត្តិ តែពួកភិក្ខុដទៃ យល់ឃើញអាបត្តិនោះថាជាអាបត្តិមែន ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុនោះស្គាល់ភិក្ខុទាំងនោះយ៉ាងនេះថា លោកដ៏មានអាយុទាំងនេះជាពហុស្សូត ។ បេ ។ មានការប្រាថ្នាក្នុងសិក្ខា មិនគួរនឹងលុះអគតិ ព្រោះសេចក្តីស្រឡាញ់ សេចក្តីស្អប់ សេចក្តីវង្វេង សេចក្តីខ្លាច ព្រោះហេតុអាត្មាអញ ឬព្រោះហេតុពួកភិក្ខុដទៃឡើយ បើភិក្ខុទាំងនេះនឹងលើកវត្តអាត្មាអញ ព្រោះមិនឃើញអាបត្តិហើយ មុខជានឹងមិនបវារណាជាមួយនឹងអាត្មាអញដែរ តែវៀរចាកអាត្មាអញហើយបវារណា មុខជានឹងមិនធ្វើសង្ឃកម្មជាមួយនឹងអាត្មាអញដែរ តែវៀរចាកអាត្មាអញហើយធ្វើសង្ឃកម្ម មុខជានឹងមិនអង្គុយលើអាសនៈជាមួយនឹងអាត្មាអញដែរ តែវៀរចាកអាត្មាអញហើយអង្គុយនៅលើអាសនៈ មុខជានឹងមិនអង្គុយក្នុងទីផឹកបបរជាមួយនឹងអាត្មាអញដែរ តែវៀរចាកអាត្មាអញហើយអង្គុយក្នុងទីផឹកបបរ មុខជានឹងមិនអង្គុយក្នុងរោងភត្តជាមួយនឹងអាត្មាអញដែរ តែវៀរចាកអាត្មាអញហើយអង្គុយក្នុងរោងភត្ត មុខជានឹងមិននៅក្នុងទីមានដំបូលមួយ ជាមួយនឹងអាត្មាអញដែរ តែវៀរចាកអាត្មាអញហើយអង្គុយក្នុងទីមានដំបូលមួយ

វិស្សន្តិ ន មយា សទ្ធឹ យថាវុឌ្ឍំ អភិវាទនំ បច្ចុដ្ឋានំ អញ្ជលិកម្មំ សាមីចិកម្មំ ករិស្សន្តិ វិនា មយា យថាវុឌ្ឍំ អភិវាទនំ បច្ចុដ្ឋានំ អញ្ជលិកម្មំ សាមីចិកម្មំ ករិស្សន្តិ ករិស្សន្តិ សង្ឃស្ស តតោនិទានំ ភណ្ឌនំ កលហោ វិគ្គហោ វិវាទោ សង្ឃភេទោ សង្ឃរាជិ សង្ឃវវត្ថានំ សង្ឃនានាករណន្តិ ។ ភេទគរុកេហិ ភិក្ខវេ ភិក្ខូហិ បរេសំបិ សទ្ធាយ សា អាបត្តិ ទេសេតព្វាតិ ។ អថខោ ភគវា ឧក្ខិត្តានុវត្តកានំ ភិក្ខូនំ ឯតមត្ថំ ភាសិត្វា ឧដ្ឋាយាសនា បក្កាមិ ។

[១៤៦] តេន ខោ បន សមយេន ឧក្ខិត្តានុវត្តកា ភិក្ខូ តត្ថេវ អន្តោសីមាយ ឧបោសថំ ករោន្តិ សង្ឃកម្មំ ករោន្តិ ។ ឧក្ខេបកា បន ភិក្ខូ និស្សីមំ គន្ត្វា ឧបោសថំ ករោន្តិ សង្ឃកម្មំ ករោន្តិ ។ អថខោ អញ្ញតរោ ឧក្ខេបកោ ភិក្ខុ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច



មុខជានឹងមិនធ្វើអភិវាទនកម្ម បច្ចុដ្ឋានកម្ម អញ្ជលិកម្ម សាមីចិកម្ម តាមលំដាប់វស្សាជាមួយនឹងអាត្មាអញទេ តែរៀរចាកអាត្មាអញហើយធ្វើនូវអភិវាទនកម្ម បច្ចុដ្ឋានកម្ម អញ្ជលិកម្ម សាមីចិកម្ម តាមលំដាប់វស្សា (វិញ) សេចក្តីបង្កហេតុ សេចក្តីឈ្លោះ សេចក្តីប្រកាន់ផ្សេងៗ សេចក្តីវិវាទ សេចក្តីបែកធ្លាយនៃសង្ឃ សេចក្តីប្រេះឆានៃសង្ឃ សេចក្តីកំណត់របស់សង្ឃ នឹងធ្វើផ្សេងៗ របស់សង្ឃ ព្រោះហេតុតែអាត្មាអញនោះមុខជានឹងមានដល់សង្ឃមិនខាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលជាអ្នកមានចិត្តខ្ពង់ខ្ពស់ក្នុងការបំបែកសង្ឃហើយ ត្រូវតែសំដែងអាបត្តិនោះចេញតាមសេចក្តីជឿពាក្យរបស់ភិក្ខុដទៃ ។ វេលានោះ ព្រះដ៏មានព្រះភាគទ្រង់សំដែងសេចក្តីនុ៎ះដល់ពួកភិក្ខុអ្នកប្រព្រឹត្តតាមភិក្ខុដែលសង្ឃលើកវត្តហើយក៏ទ្រង់ក្រោកចាកអាសនៈយាងចេញទៅ ។

[១៤៦] សម័យនោះឯង ពួកភិក្ខុអ្នកប្រព្រឹត្តតាមភិក្ខុដែលសង្ឃលើកវត្តក៏នៅតែធ្វើឧបោសថ ធ្វើសង្ឃកម្មខាងក្នុងសីមានោះដដែល ។ ចំណែកខាងពួកភិក្ខុអ្នកលើកវត្ត ក៏ទៅធ្វើឧបោសថ ធ្វើសង្ឃកម្មក្រៅសីមាវិញ ។ វេលានោះ មានភិក្ខុអ្នកលើកវត្ត ១ រូបចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយក្រាបបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ លុះភិក្ខុនោះអង្គុយនៅក្នុងទីដ៏សមគួរហើយបានក្រាបបង្គំទូល

តេ ភន្តេ ឧក្ខិត្តានុវត្តកា ភិក្ខូ តត្ថេវ អន្តោសីមាយ ឧបោសថំ ករោន្តិ សង្ឃកម្មំ ករោន្តិ មយំ បន ភន្តេ ឧក្ខេបកា ភិក្ខូ និស្សីមំ គន្ត្វា ឧបោសថំ ករោម សង្ឃកម្មំ ករោមាតិ ។ តេ ចេ ភិក្ខវេ ឧក្ខិត្តានុវត្តកា ភិក្ខូ តត្ថេវ អន្តោសីមាយ ឧបោសថំ ករិស្សន្តិ សង្ឃកម្មំ ករិស្សន្តិ យថា មយា ញត្តិ ច អនុស្សាវនា ច បញ្ញត្តា តេសំ តានិ កម្មានិ ធម្មិកានិ ភវិស្សន្តិ អកុប្បានិ ឋានារហានិ ។ តុម្ហេ ចេ ភិក្ខវេ ឧក្ខេបកា ភិក្ខូ តត្ថេវ អន្តោសីមាយ ឧបោសថំ ករិស្សថ សង្ឃកម្មំ ករិស្សថ យថា មយា ញត្តិ ច អនុស្សាវនា ច បញ្ញត្តា តុម្ហាកម្បិ តានិ កម្មានិ ធម្មិកានិ ភវិស្សន្តិ អកុប្បានិ ឋានារហានិ ។ តំ កិស្ស ហេតុ ។ នានាសំវាសកា តេ ភិក្ខូ តុម្ហេហិ តុម្ហេ ច តេហិ នានាសំវាសកា ។ ទ្វេមា ភិក្ខវេ នានាសំវាសកភូមិយោ អត្តនា វា អត្តានំ នានាសំវាសកំ ករោតិ សមគ្គោ វា នំ សង្ឃោ



ព្រះដ៏មានព្រះភាគយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ឥឡូវពួកភិក្ខុអ្នកប្រព្រឹត្តតាមភិក្ខុដែលសង្ឃលើកវត្តនោះធ្វើឧបោសថធ្វើសង្ឃកម្មខាងក្នុងសីមានោះឯដែល សូមទ្រង់ព្រះមេត្តាប្រោស ចំណែកខាងយើងខ្ញុំព្រះអង្គដែលជាឧក្ខេបកភិក្ខុក៏ទៅធ្វើឧបោសថធ្វើសង្ឃកម្មក្រៅសីមាវិញហើយ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុ បើពួកភិក្ខុអ្នកប្រព្រឹត្តតាមភិក្ខុដែលសង្ឃលើកវត្តទាំងនោះនឹងធ្វើឧបោសថ ធ្វើសង្ឃកម្មខាងក្នុងសីមានោះឯដែល ត្រូវដូចជាញត្តិនិងអនុស្សាវនាដែលតថាគតបានបញ្ញត្តហើយ កម្មរបស់ភិក្ខុទាំងនោះក៏ឈ្មោះថាប្រកបដោយធម៌ ឥតមានកំរើក ហើយជាកម្មសមគួរដល់ហេតុ ។ ម្នាលភិក្ខុ បើអស់អ្នកជាឧក្ខេបកភិក្ខុ (ភិក្ខុអ្នកលើកវត្ត) នឹងធ្វើឧបោសថ ធ្វើសង្ឃកម្មខាងក្នុងសីមានោះឯដែល ត្រូវដូចជាញត្តិនិងអនុស្សាវនាដែលតថាគតបានបញ្ញត្តហើយ កម្មរបស់អ្នកទាំងឡាយនោះសោតក៏ឈ្មោះថាប្រកបដោយធម៌ ឥតមានកំរើក ហើយជាកម្មសមគួរដល់ហេតុ ។ ហេតុអ្វីបានជាតថាគតពោលយ៉ាងនោះ ។ ម្នាលភិក្ខុ ព្រោះភិក្ខុទាំងនោះមានសំវាសផ្សេងគ្នានឹងអ្នកទាំងឡាយ ចំណែកខាងអ្នកទាំងឡាយក៏មានសំវាសផ្សេងគ្នានឹងភិក្ខុទាំងនោះដែរ ។ ម្នាលភិក្ខុ ភូមិរបស់ភិក្ខុមានសំវាសផ្សេងគ្នានេះមាន ២ យ៉ាង គឺភិក្ខុធ្វើខ្លួនឲ្យមានសំវាសផ្សេងគ្នាដោយខ្លួនឯង ១ សង្ឃព្រមព្រៀងគ្នា

ឧក្ខិបតិ អទស្សនេ វា អប្បដិកម្មេ វា អប្បដិនិស្សគ្គេ វា ។ ឥមា ខោ ភិក្ខុ ទ្វេ នានាសំវាសកភូមិយោ ។ ទ្វេមា ភិក្ខុ សមានសំវាសកភូមិយោ អត្តនា វា អត្តានំ សមានសំវាសកំ ករោតិ សមគ្គោ វា នំ សង្ឃោ ឧក្ខិត្តំ ឱសារេតិ អទស្សនេ វា អប្បដិកម្មេ វា អប្បដិនិស្សគ្គេ វា ។ ឥមា ខោ ភិក្ខុ ទ្វេ សមានសំវាសកភូមិយោតិ ។

[១៤៧] តេន ខោ បន សមយេន ភិក្ខូ ភត្តគ្គេ អន្តរឃរេ ភណ្ឌនជាតា កលហជាតា វិវាទាបន្នា អញ្ញមញ្ញំ អននុលោមិកំ កាយកម្មំ វចីកម្មំ ឧបទំសេន្តិ ហត្ថបរាមាសំ ករោន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម សមណា សក្យបុត្តិយា ភត្តគ្គេ អន្តរឃរេ ភណ្ឌនជាតា កលហជាតា វិវាទាបន្នា អញ្ញមញ្ញំ អននុលោមិកំ កាយកម្មំ វចីកម្មំ ឧបទំសេស្សន្តិ ហត្ថបរាមាសំ ករិស្សន្តីតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ



លើកវត្តភិក្ខុនោះ ព្រោះមិនឃើញអាបត្តិ ឬមិនបានសំដែងអាបត្តិ ឬមិនបានលះបង់ទិដ្ឋិអាក្រក់ចេញ ១ ម្នាលភិក្ខុ ភូមិរបស់ភិក្ខុដែលមានសំវាសផ្សេងគ្នាមាន២យ៉ាងនេះឯង ។ ម្នាលភិក្ខុ ភូមិរបស់ភិក្ខុដែលមានសំវាសស្មើគ្នានេះមាន ២ យ៉ាង គឺភិក្ខុធ្វើខ្លួនឲ្យមានសំវាសស្មើគ្នាដោយខ្លួនឯង ១ សង្ឃព្រមព្រៀងគ្នាធ្វើឱសារណាកម្ម (លើកលែងទោស) ភិក្ខុដែលសង្ឃបានលើកវត្តហើយ ព្រោះមិនឃើញអាបត្តិ ឬមិនសំដែងអាបត្តិ ឬមិនបានលះបង់ទិដ្ឋិអាក្រក់ចេញនោះ ១ ម្នាលភិក្ខុ ភូមិរបស់ភិក្ខុដែលមានសំវាសស្មើគ្នាមាន២យ៉ាងនេះឯង ។

[១៤៧] សម័យនោះឯង ភិក្ខុទាំងឡាយកើតសេចក្តីបង្កហេតុ ឈ្លោះទាស់ទែងគ្នា សំដែងកាយកម្មនិងវចីកម្មធ្វើអាការប៉ះពាល់ដោយដៃមិនសមគួរដល់គ្នានឹងគ្នាក្នុងរោងភត្តក្នុងចន្លោះផ្ទះ ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាសក្យបុត្តមិនសមបើនឹងកើតសេចក្តីបង្កហេតុ ឈ្លោះ ទាស់ទែងគ្នា សំដែងកាយកម្មនិងវចីកម្មធ្វើអាការប៉ះពាល់ដោយដៃ មិនសមគួរដល់គ្នានឹងគ្នាក្នុងរោងភត្តក្នុងចន្លោះផ្ទះសោះ ។ ភិក្ខុទាំងឡាយក៏បានឮសំដីមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ ។ ពួកភិក្ខុណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះ

ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខូ
ភត្តគ្គេ អន្តរឃរេ ភណ្ឌនជាតា ។បេ។ ហត្ថបរាមាសំ
បាបុណិស្សន្តីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ
អារោចេសុំ ។ សច្ចំ កិរ ភិក្ខវេ ភិក្ខូ ភត្តគ្គេ
អន្តរឃរេ ភណ្ឌនជាតា ។បេ។ ហត្ថបរាមាសំ បាបុណ-
ន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា ។បេ។
វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ ភិន្នេ ភិក្ខវេ
សង្ឃេ អធម្មិយាយមានេ អសម្មោទិកាយ វត្តមានាយ
ឯត្តាវតា ន អញ្ញមញ្ញំ អននុលោមិកំ កាយកម្មំ វចី-
កម្មំ ឧបទំសេស្សាម ហត្ថបរាមាសំ បាបុណិស្សាមាតិ អាស-
នេ និសីទិតព្វំ ។ ភិន្នេ ភិក្ខវេ សង្ឃេ ធម្មិយាយមានេ សម្មោទិ-
កាយ វត្តមានាយ អាសនន្តរិកាយ និសីទិតព្វន្តិ ។



តំពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុទាំងឡាយមិនសមបើនឹងកើត
សេចក្តីបង្កហេតុ ។បេ។ ធ្វើអាការប៉ះពាល់ដោយដៃក្នុងរោងភត្តក្នុងចន្លោះ
ផ្ទះសោះ ។ គ្រានោះ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះ
ដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា
មានភិក្ខុកើតសេចក្តីបង្កហេតុ ។បេ។ ធ្វើអាការប៉ះពាល់ដោយដៃក្នុង
រោងភត្តក្នុងចន្លោះផ្ទះ ពិតមែនឬ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលថា ការនោះ
ពិតមែនព្រះអង្គ ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោស ។បេ។ លុះ
បន្ទោសរួចហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាល
ភិក្ខុទាំងឡាយ កាលបើសង្ឃបែកគ្នាហើយ កំពុងធ្វើកិច្ចមិនប្រកបដោយធម៌
កំពុងតែពោលពាក្យមិនជាទីរីករាយគ្នា អ្នកទាំងឡាយមិនគប្បីអង្គុយលើ
អាសនៈដោយគិតថា យើងនឹងធ្វើកាយកម្មនិងវចីកម្មធ្វើអាការប៉ះពាល់
ដោយដៃ មិនសមគួរដល់គ្នានឹងគ្នា ដោយហេតុមានប្រមាណប៉ុណ្ណេះទេ
ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃបែកគ្នាហើយ កំពុងធ្វើកិច្ចប្រកបដោយ
ធម៌ កំពុងតែពោលពាក្យជាទីរីករាយគ្នា អ្នកទាំងឡាយ គួរអង្គុយលើ
អាសនៈឃ្លាតគ្នា ។

[១៤៨] តេន ខោ បន សមយេន ភិក្ខូ សង្ឃមជ្ឈេ ភណ្ឌនជាតា កលហជាតា វិវាទាបន្នា អញ្ញមញ្ញំ មុខសត្តីហិ វិតុទន្តា វិហរន្តិ ។ តេ ន សក្កោន្តិ តំ អធិករណំ វូបសមេតុំ ។ អថខោ អញ្ញតរោ ភិក្ខុ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច ឥធ ភន្តេ ភិក្ខូ សង្ឃមជ្ឈេ ភណ្ឌនជាតា កលហជាតា វិវាទាបន្នា អញ្ញមញ្ញំ មុខសត្តីហិ វិតុទន្តា វិហរន្តិ តេ ន សក្កោន្តិ តំ អធិករណំ វូបសមេតុំ សាធុ ភន្តេ ភគវា យេន តេ ភិក្ខូ តេនុបសង្កមតុ អនុកម្បំ ឧបាទាយាតិ ។ អធិវាសេសិ ភគវា តុណ្ហីភាវេន ។ អថខោ ភគវា យេន តេ ភិក្ខូ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ និសជ្ជ ខោ ភគវា តេ ភិក្ខូ ឯតទវោច អលំ ភិក្ខវេ មា ភណ្ឌនំ មា កលហំ មា វិគ្គហំ មា វិវាទន្តិ ។ ឯវំ



[១៤៨] សម័យនោះឯង ភិក្ខុទាំងឡាយកើតសេចក្ដីបង្កហេតុ ឈ្លោះ ទាស់ទែងគ្នា ទាក់ទាញគ្នាទិទៃគ្នាដោយលំពែងមាត់ក្នុងកណ្ដាលជំនុំសង្ឃ ។ ភិក្ខុទាំងនោះមិនអាចនឹងរម្ងាប់អធិករណ៍នោះបានឡើយ ។ គ្រានោះ មានភិក្ខុ ១ រូបបានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីដ៏សមគួរ ។ លុះភិក្ខុនោះឋិតនៅក្នុងទីដ៏សមគួរហើយក៏ក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ក្នុងទីនេះមានពួកភិក្ខុកើតសេចក្ដីបង្កហេតុ ឈ្លោះ ទាស់ទែងគ្នា ទាក់ទាញគ្នាទិទៃគ្នាដោយលំពែងមាត់ក្នុងកណ្ដាលជំនុំសង្ឃ ភិក្ខុទាំងនោះមិនអាចនឹងរម្ងាប់អធិករណ៍នោះបានឡើយ សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះមានព្រះភាគយាងទៅជួបនឹងភិក្ខុទាំងនោះដោយសេចក្ដីអនុគ្រោះ ។ ព្រះមានព្រះភាគក៏ទ្រង់ទទួលនិមន្តដោយតុណ្ហីភាព ។ លំដាប់នោះ ព្រះមានព្រះភាគក៏យាងទៅជួបនឹងភិក្ខុទាំងនោះ លុះយាងចូលទៅដល់ហើយគង់លើអាសនៈដែលគេក្រាលទុកថ្វាយ ។ លុះព្រះដ៏មានព្រះភាគទ្រង់គង់ហើយក៏ត្រាស់ទៅនឹងភិក្ខុទាំងនោះយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ កុំឡើយ អ្នកទាំងឡាយកុំធ្វើសេចក្ដីបង្កហេតុ កុំធ្វើសេចក្ដីឈ្លោះគ្នា កុំធ្វើសេចក្ដីប្រកាន់ផ្ទុយគ្នា កុំធ្វើសេចក្ដីវិវាទគ្នា ។ កាលបើព្រះដ៏មានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ

វុត្តេ អញ្ញតរោ អធម្មវាទី ភិក្ខុ ភគវន្តំ ឯតទវោច អាគមេតុ ភន្តេ ភគវា ធម្មស្សាមី អប្បោស្សុក្កោ ភន្តេ ភគវា ទិដ្ឋធម្មសុខវិហារំ អនុយុត្តោ វិហរតុ មយមេតេន ភណ្ឌនេន កលហេន វិគ្គហេន វិវាទេន បញ្ញាយិស្សាមាតិ ។ ទុតិយម្បិ ខោ ភគវា តេ ភិក្ខូ ឯតទវោច អលំ ភិក្ខវេ មា ភណ្ឌនំ មា កលហំ មា វិគ្គហំ មា វិវាទន្តិ ។ ទុតិយម្បិ ខោ សោ អធម្មវាទី ភិក្ខុ ភគវន្តំ ឯតទវោច អាគមេតុ ភន្តេ ភគវា ធម្មស្សាមី អប្បោស្សុក្កោ ភន្តេ ភគវា ទិដ្ឋធម្មសុខវិហារំ អនុយុត្តោ វិហរតុ មយមេតេន ភណ្ឌនេន កលហេន វិគ្គហេន វិវាទេន បញ្ញាយិស្សាមាតិ ។



ក៏ស្រាប់តែមានភិក្ខុ ១ រូប ជាអធម្មវាទី ក្រាបបង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះដ៏មានព្រះភាគជាម្ចាស់ធម៌ ទ្រង់ឈប់សិនចុះ សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះដ៏មានព្រះភាគទ្រង់មានសេចក្តីខ្វល់ខ្វាយតិច ទ្រង់ប្រកបនូវធម៌ដែលជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្នហើយ ៗ ចុះ ឯយើងខ្ញុំមុខជានឹងប្រាកដ ដោយសេចក្តីបង្កហេតុ ដោយសេចក្តីឈ្លោះគ្នា ដោយសេចក្តីប្រកាន់ផ្សេង ៗ គ្នា ដោយសេចក្តីវិវាទគ្នានេះមិនខាន ។ ព្រះដ៏មានព្រះភាគទ្រង់មានព្រះបន្ទូលនឹងភិក្ខុទាំងនោះជាគំរប់ពីរដងទៀតថា ម្នាលភិក្ខុទាំងឡាយ កុំឡើយ អ្នកទាំងឡាយកុំធ្វើសេចក្តីបង្កហេតុ កុំធ្វើសេចក្តីឈ្លោះគ្នា កុំធ្វើសេចក្តីប្រកាន់ផ្សេង ៗ គ្នា កុំធ្វើសេចក្តីវិវាទគ្នា ។ ភិក្ខុជាអធម្មវាទីនោះក្រាបបង្គំទូលព្រះដ៏មានព្រះភាគជាគំរប់ពីរដងទៀតយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះដ៏មានព្រះភាគជាម្ចាស់ធម៌ទ្រង់ឈប់សិនចុះ សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះដ៏មានព្រះភាគមានសេចក្តីខ្វល់ខ្វាយតិច ទ្រង់ប្រកបនូវធម៌ដែលជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្នហើយ ៗ ចុះ ឯយើងខ្ញុំមុខជានឹងប្រាកដដោយសេចក្តីបង្កហេតុ ដោយសេចក្តីឈ្លោះគ្នា ដោយសេចក្តីប្រកាន់ផ្សេង ៗ គ្នា ដោយសេចក្តីវិវាទគ្នានេះមិនខានទេ ។

[៤៥៨] អថខោ ភគវា ភិក្ខូ អាមន្តេសិ ភូតបុព្វំ ភិក្ខវេ ពារាណសិយំ ព្រហ្មទត្តោ នាម កាសិរាជា អហោសិ អឌ្ឍោ មហទ្ធនោ មហាភោគោ មហព្ពលោ មហាវាហនោ មហាវិជិតោ បរិបុណ្ណកោសកោដ្ឋាគារោ ។ ទីឃីតិ នាម កោសលរាជា អហោសិ ទលិទ្ទោ អប្បធនោ អប្បភោគោ អប្បពលោ អប្បវាហនោ អប្បវិជិតោ អបរិបុណ្ណកោសកោដ្ឋាគារោ ។ អថខោ ភិក្ខវេ ព្រហ្មទត្តោ កាសិរាជា ចតុរង្គិនឹ សេនំ សន្នយ្ហិត្វា ទីឃីតឹ កោសលរាជានំ អព្ភុយ្យាសិ ។ អស្សោសិ ខោ ភិក្ខវេ ទីឃីតិ កោសលរាជា ព្រហ្មទត្តោ កិរ កាសិរាជា ចតុរង្គិនឹ សេនំ សន្នយ្ហិត្វា មំ(១) អព្ភុយ្យាតោតិ ។ អថខោ ភិក្ខវេ ទីឃីតិស្ស កោសលរញ្ញោ ឯតទហោសិ ព្រហ្មទត្តោ ខោ កាសិរាជា អឌ្ឍោ មហទ្ធនោ មហាភោគោ មហព្ពលោ មហាវាហនោ មហាវិជិតោ បរិបុណ្ណកោសកោដ្ឋាគារោ

១ ម. មមំ ។



[៤៥៨] គ្រានោះ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ កាលពីដើមមានស្តេចគង់ដែនកាសីក្រុងពារាណសី ទ្រង់ព្រះនាមព្រហ្មទត្ត ជាស្តេចស្តុកស្តម្ភមាំមួន មានទ្រព្យច្រើន មានសម្បត្តិច្រើន មានពលច្រើន មានពាហនៈច្រើន មានដែនច្រើន មានឃ្លាំងនិងជង្រុកពេញបរិបូណ៌ ។ មានស្តេចគង់ដែនកោសលឈ្មោះទីឃីតិ ជាស្តេចកំសត់មានទ្រព្យតិច មានសម្បត្តិតិច មានពលតិច មានពាហនៈតិច មានដែនតិច មានឃ្លាំងនិងជង្រុកមិនសូវបរិបូណ៌ ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ស្តេចគង់ដែនកាសីព្រះនាមព្រហ្មទត្ត បានរៀបចំពួកសេនាប្រកបដោយអង្គ ៤ លើកចេញទៅច្បាំងនឹងស្តេចទីឃីតិកោសល ។ ម្នាលភិក្ខុទាំងឡាយ ឯស្តេចគង់ដែនកោសលព្រះនាមទីឃីតិបានឮដំណឹងថា ស្តេចគង់ដែនកាសីព្រះនាមព្រហ្មទត្ត រៀបចំពួកសេនាប្រកបដោយអង្គ ៤ លើកចេញមកច្បាំងនឹងអាត្មាអញហើយ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ស្តេចដែនកោសលព្រះនាមទីឃីតិទ្រង់ព្រះតម្រិះយ៉ាងនេះថា ស្តេចគង់ដែនកាសីព្រះនាមព្រហ្មទត្ត ជាស្តេចស្តុកស្តម្ភមាំមួន មានទ្រព្យច្រើន មានសម្បត្តិច្រើន មានពលច្រើន មានពាហនៈច្រើន មានដែនច្រើន មានឃ្លាំងនិងជង្រុកពេញបរិបូណ៌

អហំ បនម្ហិ ទលិទ្ទោ អប្បធនោ អប្បភោគោ អប្បពលោ អប្បវាហនោ អប្បជនបទោ អបរិបុណ្ណកោសកោដ្ឋាគារោ នាហំ បដិពលោ ព្រហ្មទត្តេន កាសិរញ្ញា ឯកសង្ឃាតម្បិ សង្គាមេតុំ យន្នូនាហំ បដិកច្ចេវ(១) នគរម្ហា និប្បតេយ្យន្តិ ។ អថខោ ភិក្ខវេ ទីឃីតិ កោសលរាជា មហេសឹ អាទាយ បដិកច្ចេវ នគរម្ហា និប្បតិ ។ អថខោ ភិក្ខវេ ព្រហ្មទត្តោ កាសិរាជា ទីឃីតិស្ស កោសលរញ្ញោ ពលញ្ច វាហនញ្ច ជនបទញ្ច កោសញ្ច កោដ្ឋាគារញ្ច អភិវិជិយ អជ្ឈាវសតិ ។ អថខោ ភិក្ខវេ ទីឃីតិ កោសលរាជា សបជាបតិកោ យេន ពារាណសី តេន បក្កាមិ អនុបុព្វេន យេន ពារាណសី តទវសរិ ។ តត្រ សុទំ ភិក្ខវេ ទីឃីតិ កោសលរាជា សបជាបតិកោ ពារាណសិយំ អញ្ញតរស្មឹ បច្ចន្តិមេ ឱកាសេ កុម្ភការនិវេសនេ អញ្ញាតកវេសេន បរិព្វាជកច្ឆន្នេន បដិវសតិ ។ អថខោ ភិក្ខវេ ទីឃីតិស្ស កោសលរញ្ញោ មហេសី នចិរស្សេវ គព្ភិនី អហោសិ ។ តស្សា ឯវរូបោ ទោហឡោ ហោតិ

១ ម. បដិគច្ចេវ ។



ឯអាត្មាអញនេះសោត ជាស្តេចកំសត់ មានទ្រព្យតិច មានសម្បត្តិតិច មានពលតិច មានពាហនៈតិច មានដែនតិច មានឃ្លាំងនិងជង្រុកមិនបរិបូណ៌ អាត្មាអញមិនអាចដើម្បីនឹងច្បាំងនឹងស្តេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត សូម្បីតែមួយលើកបានទេ បើដូច្នោះ គួរតែអាត្មាអញលបចេញអំពីក្រុងជាមុនឲ្យហើយ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ស្តេចក្នុងដែនកោសល ព្រះនាមទីឃីតិ ក៏នាំមហេសីលបចេញអំពីក្រុងជាមុន ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ស្តេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត ដណ្តើមយកពួកពល ពាហនៈ ដែនជនបទ ឃ្លាំង ជង្រុក របស់ស្តេចក្នុងដែនកោសល ព្រះនាមទីឃីតិ ហើយគ្រប់គ្រងនៅ ។ ម្នាលភិក្ខុទាំងឡាយ ឯស្តេចក្នុងដែនកោសល ព្រះនាមទីឃីតិ ព្រមទាំងមហេសី យាងចេញទៅឯក្រុងពារាណសី ក៏បានទៅដល់ក្រុងពារាណសី ដោយលំដាប់ ។ ម្នាលភិក្ខុទាំងឡាយ បានឮមកថា ស្តេចក្នុងដែនកោសល ព្រះនាមទីឃីតិ ព្រមទាំងមហេសី ក្លែងភេទរបស់ខ្លួនមិនឲ្យគេស្គាល់បាន ទ្រង់ស្លៀកដណ្តប់ជាបរិព្វាជក ហើយគង់នៅក្នុងផ្ទះរបស់ជាងស្មូន ក្នុងឱកាសមួយជាទីបំផុតក្រុងពារាណសីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ មហេសីរបស់ស្តេចក្នុងដែនកោសល ព្រះនាមទីឃីតិ មិនយូរប៉ុន្មានក៏ទ្រង់គភ៌ ។ ឯព្រះមហេសីនោះ កើតមានចំណង់មានសភាពយ៉ាងនេះ

ឥច្ឆតិ សូរិយស្ស ឧគ្គមនកាលេ ចតុរង្គិនឹ សេនំ សន្នទ្ធំ វម្មិកំ សុភូមិយំ ឋិតំ បស្សិតុំ ខគ្គានញ្ច ធោវនំ បាតុំ ។ អថខោ ភិក្ខវេ ទីឃីតិស្ស កោសលរញ្ញោ មហេសី ទីឃីតឹ កោសលរាជានំ ឯតទវោច គព្ភិនីម្ហិ ទេវ តស្សា មេ ឯវរូបោ ទោហឡោ ឧប្បន្នោ ឥច្ឆាមិ សូរិយស្ស ឧគ្គមនកាលេ ចតុរង្គិនឹ សេនំ សន្នទ្ធំ វម្មិកំ សុភូមិយំ ឋិតំ បស្សិតុំ ខគ្គានញ្ច ធោវនំ បាតុន្តិ ។ កុតោ ទេវិ អម្ហាកំ ទុគ្គតានំ ចតុរង្គិនី សេនា សន្នទ្ធា វម្មិកា សុភូមិយំ ឋិតា ខគ្គានញ្ច ធោវនន្តិ ។ សចាហំ ទេវ ន លភិស្សាមិ មរិស្សាមីតិ ។ តេន ខោ បន សមយេន ព្រហ្មទត្តស្ស កាសិរញ្ញោ បុរោហិតោ ព្រាហ្មណោ ទីឃីតិស្ស កោសលរញ្ញោ សហាយោ ហោតិ ។ អថខោ ភិក្ខវេ ទីឃីតិ កោសលរាជា យេន



គឺព្រះនាងចង់ឃើញពួកសេនាប្រកបដោយអង្គ ៤ ស្លៀកសង្វាតគ្រឿងប្រដាប់ពាក់អាវក្រោះហើយឈរនៅក្នុងទីមានផែនដីល្អ ក្នុងវេលាដែលព្រះអាទិត្យរះឡើង ១ ចង់សោយទឹកដែលគេលាងព្រះខាន់ ១ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ មហេសីរបស់ស្ដេចក្នុងដែនកោសលព្រះនាមទីឃីតិក៏ក្រាបទូលស្ដេចក្នុងដែនកោសលព្រះនាមទីឃីតិយ៉ាងនេះថា បពិត្រព្រះសម្មតិទេព ខ្ញុំម្ចាស់មានគភ៌ហើយ ចំខ្ញុំម្ចាស់កើតមានចំណង់មានសភាពយ៉ាងនេះ គឺខ្ញុំម្ចាស់ចង់ឃើញសេនាប្រកបដោយអង្គ ៤ ស្លៀកសង្វាតគ្រឿងប្រដាប់ពាក់អាវក្រោះហើយឈរនៅក្នុងទីមានផែនដីល្អក្នុងវេលាដែលព្រះអាទិត្យរះឡើង ១ ចង់ផឹកទឹកដែលគេលាងព្រះខាន់ ១ ។ ស្ដេចនោះទ្រង់ត្រាស់តបទៅវិញថា នែនាងទេវី យើងជាអ្នកកំសត់ម្ដេចនឹងបានពួកសេនាប្រកបដោយអង្គ ៤ ស្លៀកសង្វាតគ្រឿងប្រដាប់ពាក់អាវក្រោះហើយឈរនៅក្នុងទីមានផែនដីល្អ និងទឹកដែលគេលាងព្រះខាន់បានមកពីទីណា ។ ព្រះនាងទេវីទូលតបថា បពិត្រព្រះសម្មតិទេព បើខ្ញុំម្ចាស់មិនបានគ្រឿងទាំងនោះទេ ខ្ញុំម្ចាស់មុខជានឹងស្លាប់មិនខាន ។ ម្នាលភិក្ខុទាំងឡាយ សម័យនោះឯង មានព្រាហ្មណ៍ជាបុរោហិតរបស់ស្ដេចក្នុងដែនកាសីព្រះនាមព្រហ្មទត្ត ជាសំឡាញ់នឹងស្ដេចក្នុងដែនកោសលព្រះនាមទីឃីតិ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ស្ដេចក្នុង

ព្រហ្មទត្តស្ស កាសិរញ្ញោ បុរោហិតោ ព្រាហ្មណោ តេនុបសង្កមិ ឧបសង្កមិត្វា ព្រហ្មទត្តស្ស កាសិរញ្ញោ បុរោហិតំ ព្រាហ្មណំ ឯតទវោច សខី តេ សម្ម គព្ភិនី តស្សា ឯវរូបោ ទោហឡោ ឧប្បន្នោ ឥច្ឆតិ សូរិយស្ស ឧគ្គមនកាលេ ចតុរង្គិនឹ សេនំ សន្នទ្ធំ វម្មិកំ សុភូមិយំ ឋិតំ បស្សិតុំ ខគ្គានញ្ច ធោវនំ បាតុន្តិ ។ តេនហិ ទេវ មយម្បិ ទេវឹ បស្សាមាតិ ។ អថខោ ភិក្ខវេ ទីឃីតិស្ស កោសលរញ្ញោ មហេសី យេន ព្រហ្មទត្តស្ស កាសិរញ្ញោ បុរោហិតោ ព្រាហ្មណោ តេនុបសង្កមិ ។ អទ្ទសា ខោ ភិក្ខវេ ព្រហ្មទត្តស្ស កាសិរញ្ញោ បុរោហិតោ ព្រាហ្មណោ ទីឃីតិស្ស កោសលរញ្ញោ មហេសឹ ទូរតោវ អាគច្ឆន្តឹ ទិស្វាន ឧដ្ឋាយាសនា ឯកំសំ ឧត្តរាសង្គំ ករិត្វា យេន ទីឃីតិស្ស កោសលរញ្ញោ មហេសី តេនញ្ជលឹ បណាមេត្វា តិក្ខត្តុំ ឧទានំ ឧទានេសិ



ដែនកោសលព្រះនាមទីឃីតិ យាងចូលទៅរកព្រាហ្មណ៍ជាបុរោហិតរបស់ស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្ត លុះចូលទៅដល់ហើយ ទ្រង់ត្រាស់ទៅនឹងព្រាហ្មណ៍ជាបុរោហិតរបស់ស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្ត យ៉ាងនេះថា នែសំឡាញ់ ស្ត្រីជាសំឡាញ់របស់អ្នកមានគភ៌ហើយ ឯចំណង់របស់នាងនោះកើតឡើងបែបនេះ គឺនាងនោះចង់តែឃើញពួកសេនាប្រកបដោយអង្គ ៤ ស្លៀកស្លាក់គ្រឿងប្រដាប់ពាក់សារក្រោះហើយ ឈរនៅក្នុងទីមានផែនដីរាបស្អាត ក្នុងវេលាព្រះអាទិត្យរះឡើង និងចង់ផឹកទឹកដែលគេលាងព្រះខាន់ ។ ឯព្រាហ្មណ៍បុរោហិតទូលតបវិញថា សូមទ្រង់ព្រះមេត្តាប្រោស បើដូច្នោះ យើងខ្ញុំចង់ឃើញព្រះនាងទេវីផង ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ មហេសីរបស់ស្តេចក្នុងដែនកោសលព្រះនាមទីឃីតិក៏បានចូលទៅរកព្រាហ្មណ៍ជាបុរោហិតរបស់ស្តេច ក្នុងដែនកាសីព្រះនាមព្រហ្មទត្ត ។ ម្នាលភិក្ខុទាំងឡាយ ឯព្រាហ្មណ៍ជាបុរោហិតរបស់ស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្ត បានឃើញមហេសីរបស់ស្តេចក្នុងដែនកោសលព្រះនាមទីឃីតិយាងមកអំពីចម្ងាយ លុះឃើញហើយក៏ក្រោកចាកអាសនៈ ហើយធ្វើសំពត់ឆៀងបង្គុំលើស្មាម្ខាង ប្រណម្យអញ្ជលីឡើងចំពោះមហេសីរបស់ស្តេចក្នុងដែនកោ-សលព្រះនាមទីឃីតិ ហើយបន្លឺឡើងនូវឧទាន ៣ ដងថា ឱហ្ន៎

កោសលរាជា វេទ កោ ទុច្ចិតកោ កោសលរាជា វេទ
កោ ទុច្ចិតកោតិ អវមជា ទេវី ហោតិ សច្ចំសុ សុរិយស្ស
ឧគ្គមនកាលេ ចតុរង្គិនឹ សេនំ សន្នទ្ធំ វម្មិកំ សុភូមិយំ
ឋិតំ បស្សិតុំ ខគ្គានញ្ច ធោវនំ បាតុន្តិ ។ អថខោ ភិក្ខវេ
ព្រហ្មទត្តស្ស កាសិរញ្ញោ បុរោហិតោ ព្រាហ្មណោ យេន
ព្រហ្មទត្តោ កាសិរាជា តេនុបសង្កមិ ឧបសង្កមិត្វា
ព្រហ្មទត្តំ កាសិរាជានំ ឯតទវោច ឯវំ ខោ ទេវ និមិត្តានិ
ទិស្សន្តិ ស្វេ សុរិយស្ស ឧគ្គមនកាលេ ចតុរង្គិនី សេនា
សន្នទ្ធា វម្មិកា សុភូមិយំ ឋស្សតិ ខគ្គា ច ធោវិយន្តិ ។
អថខោ ភិក្ខវេ ព្រហ្មទត្តោ កាសិរាជា មនុស្សេ
អាណាបេសិ យថា ភណេ បុរោហិតោ ព្រាហ្មណោ
អាហ តថា ករោថាតិ ។ អលភិ ខោ ភិក្ខវេ ទីឃីតិស្ស
កោសលរញ្ញោ មហេសី សុរិយស្ស ឧគ្គមនកាលេ



ស្ដេចគង់ដែនកោសលបានមកប៉ះនៅគង់ហើយ ម៉េចហ្ន៎ ស្ដេចគង់ដែន
កោសលបានមកប៉ះនៅគង់ហើយ បពិត្រព្រះនាងទេវី ព្រះនាង
កុំព្រួយព្រះទ័យឡើយ លុះវេលាព្រះអាទិត្យរះឡើងហើយ ព្រះនាង
នឹងបានទតឃើញពួកសេនាប្រកបដោយអង្គ ៤ ស្លៀកពាក់គ្រឿង
ប្រដាប់ការពារក្រោះហើយឈរនៅក្នុងទីមានដែនដីល្អ បាន
សោយទឹកដែលគេលាងព្រះខាន់ផងនោះឡើយ ។ ម្នាលភិក្ខុទាំង
ឡាយ វេលានោះ ព្រាហ្មណ៍ជាបុរោហិតរបស់ស្ដេចដែនកាសី
ព្រះនាមព្រហ្មទត្តបានចូលទៅគាល់ស្ដេចដែនកាសីព្រះនាមព្រហ្មទត្ត
លុះចូលទៅដល់ហើយក៏ក្រាបទូលស្ដេចដែនកាសីព្រះនាមព្រហ្មទត្ត
យ៉ាងនេះថា សូមទ្រង់ព្រះមេត្ដាប្រោស ទំនាយទាំងឡាយក៏ប្រាកដដូច្នោះ
កាលបើព្រះអាទិត្យរះឡើងក្នុងវេលាថ្ងៃស្អែកហើយ សូមឲ្យពួកសេនាប្រ-
កបដោយអង្គ ៤ ស្លៀកពាក់គ្រឿងប្រដាប់ការពារក្រោះហើយឈរនៅលើ
ទីមានដែនដីល្អ សូមឲ្យដងដាវទាំងឡាយលាងនូវព្រះខាន់ផង ។ ម្នាល
ភិក្ខុទាំងឡាយ គ្រានោះ ស្ដេចដែនកាសីព្រះនាមព្រហ្មទត្តក៏បានត្រាស់
បង្គាប់ទៅពួកមនុស្សថា ម្នាលនាយទាំងឡាយ ព្រាហ្មណ៍ជាបុរោហិត
ពោលបង្គាប់យ៉ាងណា ចូរអ្នកទាំងឡាយធ្វើយ៉ាងនោះចុះ ។ ម្នាល
ភិក្ខុទាំងឡាយ កាលបើព្រះអាទិត្យរះឡើងហើយ ឯមហេសីរបស់ស្ដេច

ចតុរង្គិនិំ សេនំ សន្នទ្ធំ វម្មិតំ សុភូមិយំ ឋិតំ បស្សិតុំ ខគ្គានញ្ច ធោវនំ បាតុំ ។ អថខោ ភិក្ខវេ ទីឃីតិស្ស កោសលរញ្ញោ មហេសី តស្ស គព្ភស្ស បរិបាកមន្វាយ បុត្តំ វិជាយិ ។ តស្ស ទីឃាវូតិ នាមំ អកំសុ ។ អថខោ ភិក្ខវេ ទីឃាវុ កុមារោ នចិរស្សេវ វិញ្ញុតំ បាបុណិ ។ អថខោ ភិក្ខវេ ទីឃីតិស្ស កោសលរញ្ញោ ឯតទហោសិ អយំ ខោ ព្រហ្មទត្តោ កាសិរាជា ពហុនោ អម្ហាកំ អនត្ថស្ស ការកោ ឥមិនា អម្ហាកំ ពលញ្ច វាហនញ្ច ជនបទោ ច កោសោ ច កោដ្ឋាគារញ្ច អច្ឆិន្នំ សចាយំ អម្ហេ ជានិស្សតិ សព្វេវ តយោ ឃាតាបេស្សតិ យន្នូនាហំ ទីឃាវុំ កុមារំ ពហិនគរេ វាសេយ្យន្តិ ។ អថខោ ភិក្ខវេ ទីឃីតិ កោសលរាជា ទីឃាវុំ កុមារំ ពហិនគរេ វាសេសិ ។ អថខោ ភិក្ខវេ ទីឃាវុ កុមារោ ពហិនគរេ បដិវសន្តោ នចិរស្សេវ សព្វសិប្បានិ សិក្ខិ ។



ក្រុងដែនកោសលព្រះនាមទីឃីតិក៏បានឃើញពួកសេនាប្រកបដោយអង្គ ៤ ស្លៀកស្អិតស្អាង ប្រដាប់ពាក់អាវក្រោះហើយឈរនៅលើទីរាបដែនដ៏ល្អផង បានសោយទឹកដែលគេលាងព្រះខាន់ផង ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ មហេសីរបស់ស្តេចក្រុងដែនកោសលព្រះនាមទីឃីតិលុះមានគភ៌ចាស់ហើយក៏ទ្រង់ប្រសូតព្រះរាជបុត្រមក ។ ព្រះរាជាទ្រង់ប្រទាននាមកុមារនោះថា ទីឃាវុ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ទីឃាវុកុមារមិនយូរប៉ុន្មានក៏បានដល់នូវការដឹងក្តី ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ស្តេចក្រុងដែនកោសលព្រះនាមទីឃីតិទ្រង់រំពឹងយ៉ាងនេះថា ស្តេចក្រុងដែនកាសីឈ្មោះព្រហ្មទត្តនេះបានធ្វើសេចក្តីវិនាសដល់យើងជាច្រើន តាំងពួកពលផង ពាហនៈផង ជនបទផង ឃ្លាំងផង ជង្រុកផង របស់យើង ស្តេចនេះក៏បានដណ្តើមយកអស់ ប្រសិនបើស្តេចនេះស្គាល់ដំណឹងយើងហើយ មុខជានឹងឲ្យមនុស្សសម្លាប់យើងទាំងបីនាក់មិនខានឡើយ បើដូច្នោះហើយ គួរតែអាត្មាអញឲ្យទីឃាវុកុមារចេញទៅនៅក្រៅក្រុងវិញ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ស្តេចក្រុងដែនកោសលព្រះនាមទីឃីតិក៏បានឲ្យទីឃាវុកុមារចេញទៅនៅខាងក្រៅក្រុង ។ ម្នាលភិក្ខុទាំងឡាយ វេលានោះទីឃាវុកុមារកាលនៅខាងក្រៅក្រុង មិនយូរប៉ុន្មានក៏បានសិក្សារៀនចេះនូវសិល្បសាស្ត្រគ្រប់ ។

[៤៨០] តេន ខោ បន ភិក្ខវេ សមយេន ទីឃីតិស្ស កោសលរញ្ញោ កប្បកោ ព្រហ្មទត្តេ កាសិរញ្ញេ បដិវសតិ ។ អទ្ទសា ខោ ភិក្ខវេ ទីឃីតិស្ស កោសលរញ្ញោ កប្បកោ ទីឃីតិំ កោសលរាជានំ សបជាបតិកំ វារាណសិយំ អញ្ញតរស្មឹ បច្ចន្តិមេ នគរេ កុម្ភការនិវេសនេ អញ្ញាតកវេសេន បរិព្វាជកច្ឆន្នេន បដិវសន្តំ ទិស្វាន យេន ព្រហ្មទត្តោ កាសិរាជា តេនុបសង្កមិ ឧបសង្កមិត្វា ព្រហ្មទត្តំ កាសិរាជានំ ឯតទវោច ទីឃីតិ ទេវ កោសលរាជា សបជាបតិកោ វារាណសិយំ អញ្ញតរស្មឹ បច្ចន្តិមេ នគរេ កុម្ភការនិវេសនេ អញ្ញាតកវេសេន បរិព្វាជកច្ឆន្នេន បដិវសតីតិ ។ អថ ខោ ភិក្ខវេ ព្រហ្មទត្តោ កាសិរាជា មនុស្សេ អាណាបេសិ តេនហិ ភណេ ទីឃីតិំ កោសលរាជានំ សបជាបតិកំ អានេថាតិ ។ ឯវំ ទេវាតិ ខោ ភិក្ខវេ តេ មនុស្សា ព្រហ្មទត្តស្ស កាសិរញ្ញោ បដិស្សុណិត្វា



[៤៨០] ម្នាលភិក្ខុទាំងឡាយ សម័យនោះឯង នាយភ្នាក់ព្រះកេសរបស់ស្ដេចក្នុងដែនកោសលព្រះនាមទីឃីតិនៅអាស្រ័យក្នុងសំណាក់ស្ដេចក្នុងដែនកាសីព្រះនាមព្រហ្មទត្ត ។ ម្នាលភិក្ខុទាំងឡាយ នាយភ្នាក់ព្រះកេសរបស់ស្ដេចក្នុងដែនកោសលព្រះនាមទីឃីតិបានឃើញស្ដេចក្នុងដែនកោសលព្រះនាមទីឃីតិព្រមទាំងមហេសី ធ្វើភេទរបស់ខ្លួនមិនឲ្យបុគ្គលដទៃស្គាល់បាន (ទ្រង់ស្លៀកដណ្ដប់ជាបរិព្វាជក) ហើយនៅអាស្រ័យក្នុងផ្ទះជាងឆ្នាំងក្នុងនិគមមួយជាទីបំផុតក្រុងពារាណសី លុះឃើញហើយ ក៏បានចូលទៅគាល់ស្ដេចក្នុងដែនកាសីព្រះនាមព្រហ្មទត្ត លុះចូលទៅដល់ហើយ ក៏ក្រាបទូលស្ដេចក្នុងដែនកាសីព្រះនាមព្រហ្មទត្តយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ស្ដេចក្នុងដែនកោសលព្រះនាមទីឃីតិព្រមទាំងមហេសីធ្វើភេទរបស់ខ្លួនមិនឲ្យបុគ្គលដទៃស្គាល់បាន (ទ្រង់ស្លៀកដណ្ដប់ជាបរិព្វាជក) ហើយនៅអាស្រ័យក្នុងផ្ទះជាងឆ្នាំង ក្នុងនិគមមួយជាទីបំផុតក្រុងពារាណសី ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ស្ដេចក្នុងដែនកាសីព្រះនាមព្រហ្មទត្តក៏ទ្រង់បង្គាប់ពួកមនុស្សទាំងឡាយថា នែនាយទាំងឡាយ បើដូច្នោះអ្នកទាំងអស់គ្នាចូរទៅនាំយកស្ដេចក្នុងដែនកោសលព្រះនាមទីឃីតិព្រមទាំងមហេសីមក ។ ម្នាលភិក្ខុទាំងឡាយ ពួកមនុស្សទាំងនោះបានទទួលព្រះឱង្ការរបស់ស្ដេចក្នុងដែនកាសីព្រះនាមព្រហ្មទត្ត

ទីឃីតឹ កោសលរាជំ សបជាបតិកំ អានេសុំ ។ អថខោ ភិក្ខវេ ព្រហ្មទត្តោ កាសិរាជា មនុស្សេ អាណាបេសិ តេនហិ ភណេ ទីឃីតឹ កោសលរាជំ សបជាបតិកំ ទឡ្ហាយ រជ្ជុយា បច្ឆាពាហំ គាឡ្ហពន្ធនំ ពន្ធិត្វា ខុរមុណ្ឌំ ករិត្វា ខរស្សរេន បណវេន រថិកាយ រថិកំ សិង្ឃាដកេន សិង្ឃាដកំ បរិនេត្វា ទក្ខិណេន ទ្វារេន និក្ខាមេត្វា ទក្ខិណតោ នគរស្ស ចតុធា ឆិន្ទិត្វា ចតុទ្ទិសា ពិលានិ និក្ខិបថាតិ ។ ឯវំ ទេវាតិ ខោ ភិក្ខវេ តេ មនុស្សា ព្រហ្មទត្តស្ស កាសិរញ្ញោ បដិស្សុត្វា ទីឃីតឹ កោសលរាជំ សបជាបតិកំ ទឡ្ហាយ រជ្ជុយា បច្ឆាពាហំ គាឡ្ហពន្ធនំ ពន្ធិត្វា ខុរមុណ្ឌំ ករិត្វា ខរស្សរេន បណវេន រថិកាយ រថិកំ សិង្ឃាដកេន សិង្ឃាដកំ បរិនេន្តិ ។ អថខោ ភិក្ខវេ ទីឃាវុស្ស កុមារស្ស ឯតទហោសិ ចិរំ ទិដ្ឋា[១] ខោ មេ មាតាបិតរោ យន្នូនាហំ មាតាបិតរោ បស្សេយ្យន្តិ ។

១ ម. ចិរទិដ្ឋា ។



ដោយពាក្យថា ព្រះករុណាវិសេសព្រះអង្គ ហើយក៏ទៅនាំយកស្តេចក្នុងដែនកោសល ព្រះនាមទីឃីតិ ព្រមទាំងមហេសីមក ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ស្តេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត ទ្រង់បង្គាប់ទៅពួកមនុស្សទាំងឡាយថា នែនាយទាំងឡាយ បើដូច្នោះអ្នកចូរនាំគ្នាចាប់ស្តេចក្នុងដែនកោសល ឈ្មោះទីឃីតិ ព្រមទាំងមហេសីចងឲ្យមានដើមដៃនៅខាងក្រោយ[១] ឲ្យខ្ជាប់ដោយខ្សែដ៏មាំ ហើយកោរក្បាលឲ្យរលីងចេញ រួច(ត្រូវជូន)ស្គរ ដែលមានសំឡេងខ្ទាំង ហើយនាំបណ្ដើរជុំវិញសព្វច្រកសព្វផ្លូវត្រឡែងកែង រួចនាំចេញតាមទ្វារខាងត្បូង ហើយកាប់ជា ៤ កំណាត់កប់ទៅក្នុងរណ្ដៅត្រង់ទិសទាំង ៤ ខាងត្បូងនៃក្រុង ។ ម្នាលភិក្ខុទាំងឡាយ ឯមនុស្សទាំងនោះបានទទួលព្រះឱង្ការស្តេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្តដោយពាក្យថា ព្រះករុណាវិសេស ហើយក៏ចាំចាប់ស្តេចក្នុងដែនកោសលព្រះនាមទីឃីតិព្រមទាំងមហេសីឲ្យមានដើមដៃនៅខាងក្រោយឲ្យខ្ជាប់ដោយខ្សែដ៏មាំហើយកោរក្បាលឲ្យរលីងចេញហើយ (ជូន) ស្គរដែលមានសំឡេងខ្ទាំង រួចនាំបណ្ដើរជុំវិញសព្វច្រកសព្វផ្លូវត្រឡែងកែង ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ទីឃាវុកុមារមានសេចក្ដីត្រិះរិះយ៉ាងនេះថា អាត្មាអញបានឃើញមាតាបិតាយូរណាស់ហើយ បើដូច្នោះគួរតែអាត្មាអញទៅមើលមាតាបិតាបានម្ដងសិន ។

១ ចងស្លាបសេក បណ្ដើរអាក្រាស ។

អថខោ ភិក្ខវេ ទីឃាវុ កុមារោ ពារាណសឹ បវិសិត្វា អទ្ទស មាតាបិតរោ ទឡ្ហាយ រជ្ជុយា បច្ឆាពាហំ គាឡ្ហពន្ធនំ ពន្ធិត្វា ខុរមុណ្ឌំ ករិត្វា ខរស្សរេន បណវេន រថិយាយ រថិយំ សិង្ឃាដកេន សិង្ឃាដកំ បរិនេន្តេ ទិស្វាន យេន មាតាបិតរោ តេនុបសង្កមិ ។ អទ្ទសា ខោ ភិក្ខវេ ទីឃីតិ កោសលរាជា ទីឃាវុំ កុមារំ ទូរតោវ អាគច្ឆន្តំ ទិស្វាន ទីឃាវុំ កុមារំ ឯតទវោច មា ខោ ត្វំ តាត ទីឃាវុ ទីឃំ បស្ស មា រស្សំ ន ហិ តាត ទីឃាវុ វេរេន វេរា សម្មន្តិ អវេរេន ហិ តាត ទីឃាវុ វេរា សម្មន្តីតិ ។ ឯវំ វុត្តេ ភិក្ខវេ តេ មនុស្សា ទីឃីតឹ កោសលរាជានំ ឯតទវោចុំ ឧម្មត្តកោ អយំ ទីឃីតិ កោសលរាជា វិប្បលបតិ កោ ឥមស្ស ទីឃាវុ កំ អយំ ឯវមាហ មា ខោ ត្វំ តាត ទីឃាវុ ទីឃំ បស្ស មា រស្សំ ន ហិ តាត ទីឃាវុ វេរេន វេរា សម្មន្តិ អវេរេន ហិ តាត ទីឃាវុ វេរា សម្មន្តីតិ ។



ម្នាលភិក្ខុទាំងឡាយ វេលានោះ ទីឃាវុកុមារចូលទៅក្នុងក្រុងពារាណសីហើយ ក៏បានឃើញមាតាបិតាដែលគេគៀបគុននឹងចងស្ពាយសងជាប់ដោយខ្សែដ៏មាំ កោរក្បាលឲ្យរលីងចេញ (ខុរ) ស្គរដែលមានសំឡេងគគ្រឹកខ្លាំង ហើយនាំបណ្ដើរវិលវល់ច្រកព្រែក សព្វផ្លូវបែកផ្លូវកែង លុះឃើញហើយក៏ចូលទៅរកមាតាបិតា ។ ម្នាលភិក្ខុទាំងឡាយ ឯស្ដេចកោសលព្រះនាមទីឃីតិទ្រង់ទតឃើញទីឃាវុកុមារមកអំពីចម្ងាយ លុះឃើញហើយក៏មានព្រះបន្ទូលទៅនឹងទីឃាវុកុមារយ៉ាងនេះថា នែទីឃាវុកូន អ្នកឯងកុំឃើញការវែង កុំឃើញការខ្លី នែទីឃាវុកូន ធម្មតាពៀរមិនដែលរម្ងាប់ដោយការចងពៀរទេ នែទីឃាវុកូន ឯពៀរតែងរម្ងាប់ដោយការមិនចងពៀរ ។ ម្នាលភិក្ខុទាំងឡាយ កាលបើស្ដេចនោះមានព្រះបន្ទូលយ៉ាងនេះហើយ ពួកមនុស្សទាំងនោះក៏ពោលពាក្យនេះនឹងស្ដេចកោសលព្រះនាមទីឃីតិថា ស្ដេចកោសលព្រះនាមទីឃីតិនេះឆ្កួតនិយាយផ្ដេសផ្ដាសទេតើ នរណាឈ្មោះទីឃាវុ (ជាកូន) របស់ស្ដេចនេះ ស្ដេចនេះនិយាយទៅនឹងនរណាយ៉ាងនេះថា នែទីឃាវុកូន អ្នកឯងកុំឃើញការវែង កុំឃើញការខ្លី នែទីឃាវុកូន ធម្មតាពៀរមិនដែលរម្ងាប់ដោយការចងពៀរទេ នែទីឃាវុកូន ឯពៀរតែងរម្ងាប់ដោយការមិនចងពៀរ ។

នាហំ ភណេ ឧម្មត្តកោ វិប្បលបាមិ អបិច យោ វិញ្ញូ សោ វិភាវេស្សតីតិ ។ ទុតិយម្បិ ខោ ភិក្ខវេ ។ បេ ។ តតិយម្បិ ខោ ភិក្ខវេ ទីឃីតិ កោសលរាជា ទីឃាវុំ កុមារំ ឯតទវោច មា ខោ ត្វំ តាត ទីឃាវុ ទីឃំ បស្ស មា រស្សំ ន ហិ តាត ទីឃាវុ វេរេន វេរា សម្មន្តិ អវេរេន ហិ តាត ទីឃាវុ វេរា សម្មន្តីតិ ។ តតិយម្បិ ខោ ភិក្ខវេ តេ មនុស្សា ទីឃីតឹ កោសលរាជានំ ឯតទវោចុំ ឧម្មត្តកោ អយំ ទីឃីតិ កោសលរាជា វិប្បលបតិ កោ ឥមស្ស ទីឃាវុ កំ អយំ ឯវមាហ មា ខោ ត្វំ តាត ទីឃាវុ ទីឃំ បស្ស មា រស្សំ ន ហិ តាត ទីឃាវុ វេរេន វេរា សម្មន្តិ អវេរេន ហិ តាត ទីឃាវុ វេរា សម្មន្តីតិ ។ នាហំ ភណេ ឧម្មត្តកោ វិប្បលបាមិ អបិច យោ វិញ្ញូ សោ



ស្ដេចទីឃីតិនោះតបទៅវិញថា នែនាយ យើងមិនមែនឆ្កួតនិយាយផ្ដេសផ្ដាសទេ បើនរណាជាអ្នកប្រាជ្ញ អ្នកនោះនឹងយល់សេចក្ដីបាន ។ ម្នាលភិក្ខុទាំងឡាយ ស្ដេចក្នុងដែនកោសលព្រះនាមទីឃីតិមានព្រះឱង្ការទៅនឹងទីឃាវុកុមារជាគំរប់ពីរដងដែរ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ស្ដេចក្នុងដែនកោសលព្រះនាមទីឃីតិមានព្រះឱង្ការទៅនឹងទីឃាវុកុមារជាគំរប់បីដងផង យ៉ាងនេះថា នែទីឃាវុកូន អ្នកឯងកុំឃើញការវែង កុំឃើញការខ្លី នែទីឃាវុកូន ពួកពៀរមិនដែលរម្ងាប់ដោយការចងពៀរទេ នែទីឃាវុកូន ឯពៀរតែងរម្ងាប់ដោយការមិនចងពៀរ ។ ម្នាលភិក្ខុទាំងឡាយ មនុស្សទាំងនោះក៏បាននិយាយពាក្យនេះនឹងស្ដេចក្នុងដែនកោសលព្រះនាមទីឃីតិជាគំរប់បីដងទៀតថា ស្ដេចក្នុងដែនកោសលព្រះនាមទីឃីតិនេះឆ្កួតនិយាយផ្ដេសផ្ដាសទេតើ នរណាឈ្មោះទីឃាវុ (ជាកូន) របស់ស្ដេចនេះ ស្ដេចនេះនិយាយទៅនឹងនរណា យ៉ាងនេះថា នែទីឃាវុកូន អ្នកកុំឃើញការវែង កុំឃើញការខ្លី នែទីឃាវុកូន ពួកពៀរមិនដែលរម្ងាប់ដោយការចងពៀរទេ នែទីឃាវុកូន ឯពៀរតែងរម្ងាប់ដោយការមិនចងពៀរ ។ ស្ដេចនោះទ្រង់តបទៅវិញថា នែនាយ យើងមិនមែនជាមនុស្សឆ្កួតនិយាយផ្ដេសផ្ដាសទេ ប៉ុន្តែបើនរណាជាអ្នកប្រាជ្ញ អ្នកនោះ

វិកាសេស្សតីតិ ។ អថខោ ភិក្ខវេ តេ មនុស្សា ទីឃីតឹ កោសលរាជានំ សបជាបតិកំ ទឡ្ហាយ រជ្ជុយា បច្ឆា-ពាហំ គាឡ្ហពន្ធនំ ពន្ធិត្វា ខុរមុណ្ឌំ ករិត្វា ខរស្សរេន បណវេន រថិកាយ រថិកំ សិង្ឃាដកេន សិង្ឃាដកំ បរិនេត្វា ទក្ខិណេន ទ្វារេន និក្ខាមេត្វា ទក្ខិណតោ នគរស្ស ចតុធា ឆិន្ទិត្វា ចតុទ្ទិសា ពិលានិ និក្ខិបិត្វា គុម្ពំ ឋបេត្វា បក្កមិំសុ ។ អថខោ ភិក្ខវេ ទីឃាវុ កុមារោ ពារាណសឹ បវិសិត្វា សុរំ នីហរិត្វា គុម្ពិយេ បាយេសិ ។ យទា តេ មត្តា អហេសុំ បតិតា អថ កដ្ឋានិ សង្កឌ្ឍិត្វា មាតាបិតូនំ សរីរំ ចិតកំ អារោបេត្វា អគ្គិំ ទត្វា បញ្ជលិកោ តិក្ខត្តុំ ចិតកំ បទក្ខិណំ អកាសិ ។ តេន ខោ បន ភិក្ខវេ សមយេន រាជា ព្រហ្មទត្តោ កាសិរាជា ឧបរិបាសាទវរគតោ ហោតិ ។ អទ្ទសា ខោ ភិក្ខវេ រាជា ព្រហ្មទត្តោ កាសិរាជា ទីឃាវុំ កុមារំ បញ្ជលិកំ តិក្ខត្តុំ ចិតកំ បទក្ខិណំ ករោន្តំ ទិស្វានស្ស ឯតទហោសិ និស្សំសយំ ខោ សោ មនុស្សោ ទីឃីតិស្ស កោសលរញ្ញោ ញាតិ វា សាលោហិតោ វា អហោ មេ អនត្ថតោ[១] ន ហិ នាម មេ កោចិ

១ អនត្ថោតិ កត្ថចិ បាឋោ ទិស្សតិ ។



ទើបថ្លែងសេចក្តីបាន ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ មនុស្សទាំងនោះក៏នាំយកស្តេចក្រុងនៃដែនកោសលព្រះនាមទីឃីតិព្រមទាំងមហេសីទៅសព្វច្រកល្ហកផ្លូវបែកខ្វែងផង ហើយចេញទៅតាមទ្វារខាងត្បូង ហើយកាត់ខ្លួនជា ៤ កំណាត់ រួចបោះក្នុងរណ្តៅនៃទិសទាំង ៤ ខាងត្បូងនៃក្រុងនគរ ហើយទុកពួកពល (ឲ្យនៅចាំ) រួចថយចេញទៅ ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ទីឃាវុកុមារចូលទៅកាន់ក្រុងពារាណសី ហើយក៏នាំយកស្រាមកបំផឹកពួកពល (ទាំងនោះ) ។ ពួកពលទាំងនោះស្រវឹងដួលដេកនៅកាលណា ទីឃាវុកុមារក៏ប្រមូលកំណាត់ឈើ ហើយលើកសរីរៈមាតាបិតាដាក់លើជើងថ្ករួចបញ្ឆេះភ្លើង ហើយផ្គងអញ្ជលីធ្វើប្រទក្សិណជើងថ្ករ ៣ ជុំ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងពេលនោះ ស្តេចក្រុងនៃដែនកាសីព្រះនាមព្រហ្មទត្ត ទ្រង់គង់នៅលើប្រាសាទដ៏ប្រសើរខាងលើ ។ ម្នាលភិក្ខុទាំងឡាយ ស្តេចក្រុងនៃដែនកាសីព្រះនាមព្រហ្មទត្ត បានទតទៅឃើញទីឃាវុកុមារកំពុងផ្គងអញ្ជលីធ្វើប្រទក្សិណជើងថ្ករ ៣ ជុំ លុះឃើញហើយក៏ទ្រង់ត្រិះរិះយ៉ាងនេះថា មនុស្សនោះច្បាស់ជាញាតិ ឬជាសាលោហិតរបស់ស្តេចក្រុងនៃដែនកោសលឈ្មោះទីឃីតិហើយ ឱ សេចក្តីវិនាស(ព្រោះបុរសនេះគង់នឹងវិនាស)ដល់អាត្មាអញ មិនសមបើ

អាបាទេស្សតីតិ ។ អថខោ ភិក្ខវេ ទីឃាវុ កុមារោ អរញ្ញំ គន្ត្វា យាវទត្ថំ កន្ទិត្វា រោទិត្វា វប្បំ បុញ្ឆិត្វា[1] ពារាណសី បវិសិត្វា អន្តេបុរស្ស សាមន្តា ហត្ថិសាលំ គន្ត្វា ហត្ថាចរិយំ ឯតទវោច ឥច្ឆាមហំ អាចរិយ សិប្បំ សិក្ខិតុន្តិ ។ តេនហិ ភណេ មាណវក សិក្ខស្សូតិ ។ អថខោ ភិក្ខវេ ទីឃាវុ កុមារោ រត្តិយា បច្ចូសសមយំ បច្ចុដ្ឋាយ ហត្ថិសាលាយំ មញ្ជុនា សរេន គាយិ វីណញ្ច វាទេសិ ។ អស្សោសិ ខោ ភិក្ខវេ ព្រហ្មទត្តោ កាសិរាជា រត្តិយា បច្ចូសសមយំ បច្ចុដ្ឋាយ ហត្ថិសាលាយំ មញ្ជុនា សរេន គីតំ វីណញ្ច វាទិតំ សុត្វាន មនុស្សេ បុច្ឆិ កោ ភណេ រត្តិយា បច្ចូសសមយំ បច្ចុដ្ឋាយ ហត្ថិសាលាយំ មញ្ជុនា សរេន គាយិ វីណញ្ច វាទេសីតិ ។ អមុកស្ស ទេវ ហត្ថាចរិយស្ស អន្តេវាសី មាណវកោ រត្តិយា បច្ចូសសមយំ បច្ចុដ្ឋាយ ហត្ថិសាលាយំ មញ្ជុនា សរេន គាយិ វីណញ្ច វាទេសីតិ ។ តេនហិ ភណេ

១ បប្ផំ បុញ្ឆិត្វាតិ កត្ថចិ បោត្ថកេ ទិស្សតិ ។



ក្នុងខណៈណាមួយ ប្រាប់អាត្មាអញទាំងនោះ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ទីឃាវុកុមារទៅឯព្រៃ ហើយស្រែកខ្សឹកខ្សួលយំអស់ចិត្ត ហើយជូតទឹកភ្នែក ហើយត្រឡប់ចូលទៅក្នុងក្រុងពារាណសីវិញ គំទៅឯរោងដំរីទៀបព្រះរាជដំណាក់ ហើយនិយាយនឹងគ្រូហាត់ដំរីថា នែអ្នកហាត់ដំរី ខ្ញុំចង់រៀនសិល្បៈ (អំពីអ្នកគឺជាអាចារ្យ) ។ ឯហ្មដំរីនោះនិយាយតបថា នែមាណព បើដូច្នោះចូរអ្នករៀនចុះ ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ទីឃាវុកុមារក្រោកឡើងក្នុងបច្ចូសសម័យនៃរាត្រី ក៏ស្រែកច្រៀងដោយសំឡេងដ៏ពីរោះ ហើយដេញពិណផង ក្នុងរោងដំរី ។ ម្នាលភិក្ខុទាំងឡាយ ឯស្តេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត បានទ្រង់ព្រះសណ្តាប់ចម្រៀងនិងពិណ ដែលទីឃាវុកុមារក្រោកឡើងក្នុងបច្ចូសសម័យនៃរាត្រី ហើយច្រៀងច្រៀប ដោយសំឡេងយ៉ាងពីរោះក្នុងរោងដំរី លុះទ្រង់ព្រះសណ្តាប់រួចហើយ ក៏ទ្រង់ត្រាស់សួរមនុស្សទាំងឡាយថា នែនាយ អ្នកណាក្រោកឡើងក្នុងបច្ចូសសម័យនៃរាត្រី គំច្រៀងដោយសំឡេងដ៏ពីរោះ ហើយដេញពិណផង ក្នុងរោងដំរី ។ មនុស្សទាំងនោះក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស មាណពជាកូនសិស្សរបស់ហ្មដំរីឯណោះ ក្រោកឡើងក្នុងបច្ចូសសម័យនៃរាត្រី គំច្រៀងដោយសំឡេងដ៏ពីរោះ ហើយដេញពិណផង ក្នុងរោងដំរី ។ ស្តេចនោះទ្រង់ត្រាស់ថា នែនាយ បើដូច្នោះ

តំ មាណវកំ អានេថាតិ ។ អថ ខោ ភិក្ខវេ តេ
មនុស្សា ព្រហ្មទត្តស្ស កាសិរញ្ញោ បដិស្សុណិត្វា ទីឃាវុំ
កុមារំ អានេសុំ ។ អថខោ ភិក្ខវេ ព្រហ្មទត្តោ កាសិ-
រាជា ទីឃាវុំ កុមារំ ឯតទវោច ត្វំ ភណេ មាណវក
រត្តិយា បច្ចូសសមយំ បច្ចុដ្ឋាយ ហត្ថិសាលាយំ មញ្ជុនា
សរេន គាយិ វីណញ្ច វាទេសីតិ ។ ឯវំ ទេវាតិ ។
តេនហិ ត្វំ ភណេ មាណវក គាយស្សុ វីណញ្ច វាទេហីតិ ។
ឯវំ ទេវាតិ ខោ ភិក្ខវេ ទីឃាវុ កុមារោ ព្រហ្មទត្តស្ស
កាសិរញ្ញោ បដិស្សុណិត្វា អារាធាបេក្ខោ មញ្ជុនា
សរេន គាយិ វីណញ្ច វាទេសិ ។ អថខោ ភិក្ខវេ
ព្រហ្មទត្តោ កាសិរាជា ទីឃាវុំ កុមារំ ឯតទវោច ត្វំ
ភណេ មាណវក មំ ឧបដ្ឋហាតិ ។ ឯវំ ទេវាតិ ខោ
ភិក្ខវេ ទីឃាវុ កុមារោ ព្រហ្មទត្តស្ស កាសិរញ្ញោ
បច្ចស្សោសិ ។ អថខោ ភិក្ខវេ ទីឃាវុ កុមារោ ព្រហ្ម-
ទត្តស្ស កាសិរញ្ញោ បុព្វុដ្ឋាយី អហោសិ បច្ឆានិបាតី



អ្នកទាំងឡាយចូរនាំមាណពនោះមក ។ ម្នាលភិក្ខុទាំងឡាយ មនុស្ស
ទាំងនោះទទួលស្តាប់ព្រះឱង្ការស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្តដោយ
ពាក្យថា ព្រះករុណាវិសេស ហើយក៏នាំទីឃាវុកុមារមក ។ ម្នាលភិក្ខុ
ទាំងឡាយ វេលានោះ ស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្តទ្រង់មានព្រះ
ឱង្ការទៅនឹងទីឃាវុកុមារយ៉ាងនេះថា នែនាយមាណព អ្នកឯងក្រោកឡើង
ក្នុងបច្ចូសសម័យនៃរាត្រី គឺច្រៀងដោយសំឡេងពីរោះ ហើយដេញ
ពិណផង គឺអ្នកឯងឬ ។ ទីឃាវុកុមារក្រាបទូលថា ព្រះករុណាវិ-
សេស ។ ស្តេចនោះទ្រង់ត្រាស់ថា នែនាយមាណព បើដូច្នោះចូរអ្នកឯង
ច្រៀងហើយដេញពិណឲ្យយើងស្តាប់មើល ។ ម្នាលភិក្ខុទាំងឡាយ ទីឃា-
វុកុមារទទួលស្តាប់ព្រះឱង្ការស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្តដោយ
ពាក្យថា ព្រះករុណាវិសេស ហើយចង់ឲ្យស្តេចត្រេកត្រអាល ទើបស្រែក
ច្រៀងដោយសំឡេងពីរោះ ហើយដេញពិណផង ។ ម្នាលភិក្ខុទាំងឡាយ
ខណៈនោះ ស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្តមានព្រះឱង្ការទៅនឹងទី-
ឃាវុកុមារយ៉ាងនេះថា នែនាយមាណព ចូរអ្នកឯងនៅបម្រើយើងចុះ ។
ម្នាលភិក្ខុទាំងឡាយ ទីឃាវុកុមារក៏ទទួលស្តាប់ព្រះឱង្ការស្តេចក្នុងដែនកា-
សីព្រះនាមព្រហ្មទត្តដោយពាក្យថា ព្រះករុណាវិសេស ។ ម្នាលភិក្ខុទាំង
ឡាយ វេលានោះទីឃាវុកុមារក៏ភ្ញាក់ក្រោកមុន ដេកក្រោយ នឹងទទួលស្តាប់

កិង្ការបដិស្សាវី មនាបចារី បិយវាទី ។ អថខោ ភិក្ខវេ ព្រហ្មទត្តោ កាសិរាជា ទីឃាវុំ កុមារំ នចិរស្សេវ អព្ភន្តរិកេ វិស្សាសិកដ្ឋានេ ឋបេសិ ។ អថខោ ភិក្ខវេ ព្រហ្មទត្តោ កាសិរាជា ទីឃាវុំ កុមារំ ឯតទវោច តេនហិ ភណេ មាណវក រថំ យោជេហិ មិគវំ គមិស្សាមាតិ ។ ឯវំ ទេវាតិ ខោ ភិក្ខវេ ទីឃាវុ កុមារោ ព្រហ្មទត្តស្ស កាសិរញ្ញោ បដិស្សុណិត្វា រថំ យោជេត្វា ព្រហ្មទត្តំ កាសិរាជានំ ឯតទវោច យុត្តោ ខោ តេ ទេវ រថោ យស្សទានិ កាលំ មញ្ញសីតិ ។ អថខោ ភិក្ខវេ ព្រហ្មទត្តោ កាសិរាជា រថំ អភិរុហិ ទីឃាវុ កុមារោ រថំ បេសេសិ ។ តថា តថា រថំ បេសេសិ យថា យថា អញ្ញេនេវ សេនា អគមាសិ អញ្ញេនេវ រថោ ។ អថខោ ភិក្ខវេ ព្រហ្មទត្តោ កាសិរាជា ទូរំ គន្ត្វា ទីឃាវុំ កុមារំ ឯតទវោច តេនហិ ភណេ



បង្គាប់ការអ្វី ។ ប្រព្រឹត្តគួរជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់ដល់ស្តេចគ្រងដែនកាសីព្រះនាមព្រហ្មទត្ត ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះស្តេចគ្រងដែនកាសីព្រះនាមព្រហ្មទត្ត ក៏មិនយូរប៉ុន្មាន ក៏ទ្រង់តាំងទីឃាវុកុមារក្នុងទីជាកន្លែងស្និទ្ធស្នាលខាងក្នុង ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ស្តេចគ្រងដែនកាសីព្រះនាមព្រហ្មទត្តទ្រង់មានព្រះឱង្ការទៅនឹងទីឃាវុកុមារយ៉ាងនេះថា នែនាយមាណព បើដូច្នោះចូរអ្នកទឹមរថមក យើងនឹងទៅកាន់ទីប្រពាតម្រឹគ ។ ម្នាលភិក្ខុទាំងឡាយ ទីឃាវុកុមារទទួលស្តាប់ព្រះឱង្ការស្តេចគ្រងដែនកាសីព្រះនាមព្រហ្មទត្តថា ព្រះករុណាវិសេស ហើយក៏រៀបចំរថថ្វាយ ក្រាបទូលស្តេចគ្រងដែនកាសីព្រះនាមព្រហ្មទត្តយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ឯរាជរថរបស់ព្រះអង្គខ្ញុំព្រះអង្គទឹមរួចស្រេចហើយ សូមព្រះអង្គទ្រង់ជ្រាបកាលគួរឥឡូវនេះចុះ ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ស្តេចគ្រងដែនកាសីព្រះនាមព្រហ្មទត្តទ្រង់ឡើងគង់លើរាជរថ ទីឃាវុកុមារក៏បររថទៅ ។ ពួកសេនាដើរទៅតាមផ្លូវឯទៀត ទីឃាវុកុមារនោះក៏បររថទៅតាមផ្លូវឯទៀតដែលបែកផ្សេងគ្នា ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ស្តេចគ្រងដែនកាសីព្រះនាមព្រហ្មទត្តយាងទៅដល់ទីឆ្ងាយ ហើយទ្រង់មានព្រះឱង្ការទៅនឹងទីឃាវុកុមារយ៉ាងនេះថា នែនាយមាណព បើដូច្នោះ

រាជភវតោ រថំ មុញ្ចស្សុ កិលន្តោម្ហិ និបជ្ជិស្សាមីតិ ។ ឯវំ ទេវាតិ ខោ ភិក្ខវេ ទីឃាវុ កុមារោ ព្រហ្មទត្តស្ស កាសិរញ្ញោ បដិស្សុណិត្វា រថំ មុញ្ចិត្វា បថវិយំ បល្លង្កេន និសីទិ ។ អថខោ ភិក្ខវេ ព្រហ្មទត្តោ កាសិរាជា ទីឃាវុស្ស កុមារស្ស ឧច្ឆង្គេ សីសំ កត្វា សេយ្យំ កប្បេសិ ។ តស្ស កិលន្តស្ស មុហុត្តកេនេវ និទ្ទា ឱក្កមិ ។ អថខោ ភិក្ខវេ ទីឃាវុស្ស កុមារស្ស ឯតទហោសិ អយំ ខោ ព្រហ្មទត្តោ កាសិរាជា ពហុនោ អម្ហាកំ អនត្ថស្ស ការកោ ឥមិនា អម្ហាកំ ពលញ្ច វាហនញ្ច ជនបទោ ច កោសោ ច កោដ្ឋាគារញ្ច អច្ឆិន្នំ ឥមិនា ច មេ មាតាបិតរោ ហតា អយំ ខ្វស្ស កាលោ យោហំ វេរំ អប្បេយ្យន្តិ កោសិយា ខគ្គំ និព្វាហិ ។ អថខោ ភិក្ខវេ ទីឃាវុស្ស កុមារស្ស ឯតទហោសិ បិតា ខោ មំ មរណកាលេ អវច មា ខោ ត្វំ តាត ទីឃាវុ ទីឃំ បស្ស មា រស្សំ ន ហិ តាត ទីឃាវុ វេរេន វេរា សម្មន្តិ អវេរេន ហិ តាត ទីឃាវុ វេរា សម្មន្តីតិ ន ខោ មេ តំ បតិរូបំ យោហំ បិតុ វចនំ អតិក្កមេយ្យន្តិ



ចូរអ្នកឯងដោះកំពក់រថសិន ត្បិតយើងនឿយព្រួយលំបាក យើងនឹងដេកសម្រាកបន្តិចសិន ។ ម្នាលភិក្ខុទាំងឡាយ ឯទីឃាវុកុមារបានទទួលស្ដាប់ព្រះឱង្ការស្ដេចក្នុងដែនកាសីព្រះនាមព្រហ្មទត្តដោយពាក្យថា ព្រះករុណាវិសេស ហើយក៏ដោះកំពក់រថចេញ អង្គុយពែនភ្នែនលើផែនដី ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ស្ដេចក្នុងដែនកាសីព្រះនាមព្រហ្មទត្តក៏ទ្រង់ផ្ទំកើយព្រះសិរសៈលើភ្លៅទីឃាវុកុមារ ។ ស្ដេចនោះនឿយព្រួយលំបាក ទ្រង់ផ្ទំលក់មួយរំពេច ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ទីឃាវុកុមារក៏មានសេចក្ដីត្រិះរិះយ៉ាងនេះថា ស្ដេចក្នុងដែនកាសីព្រះនាមព្រហ្មទត្តនេះបានធ្វើសេចក្ដីវិនាសជាច្រើនដល់គ្នាអញ កំឡាំងពល ពាហនៈ ជនបទ ឃ្លាំងទំនងស្រូវ របស់គ្នាអញ ស្ដេចនេះរឹបជាន់យកអស់ មិនតែប៉ុណ្ណោះ ទាំងមាតាបិតារបស់គ្នាអញ ស្ដេចនេះក៏សម្លាប់ចោលអស់ វេលានេះ គួរគ្នាអញសងពៀរដល់ស្ដេចនេះវិញ ហើយក៏ហូតព្រះខាន់ចេញពីស្រោម ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ទីឃាវុកុមារមានសេចក្ដីត្រិះរិះយ៉ាងនេះថា បិតាបានផ្ដាំគ្នាអញក្នុងពេលដែលរៀបនឹងមរណភាពថា នែទីឃាវុកូន អ្នកឯងកុំឃើញការវែង កុំឃើញការខ្លី នែទីឃាវុកូន ធម្មតាពៀរមិនដែលរម្ងាប់ដោយការចងពៀរទេ នែទីឃាវុកូន ឯពៀរតែងរម្ងាប់ដោយការមិនចងពៀរ បើគ្នាអញកន្លងពាក្យបិតាហើយ

កោសិយា ខគ្គំ បវេសេសិ ។ ទុតិយម្បិ ខោ ភិក្ខវេ ។ បេ ។ តតិយម្បិ ខោ ភិក្ខវេ ទីឃាវុស្ស កុមារស្ស ឯតទហោសិ អយំ ខោ ព្រហ្មទត្តោ កាសិរាជា ពហុនោ អម្ហាកំ អនត្ថស្ស ការកោ ឥមិនា អម្ហាកំ ពលញ្ច វាហនញ្ច ជនបទោ ច កោសោ ច កោដ្ឋាគារញ្ច អច្ឆិន្នំ ឥមិនា ច មេ មាតាបិតរោ ហតា អយំ ខ្វស្ស កាលោ យោហំ វេរំ អប្បេយ្យន្តិ កោសិយា ខគ្គំ និព្វាហិ ។ តតិយម្បិ ខោ ភិក្ខវេ ទីឃាវុស្ស កុមារស្ស ឯតទហោសិ បិតា ខោ មំ មរណកាលេ អវច មា ខោ ត្វំ តាត ទីឃាវុ ទីឃំ បស្ស មា រស្សំ ន ហិ តាត ទីឃាវុ វេរេន វេរា សម្មន្តិ អវេរេន ហិ តាត ទីឃាវុ វេរា សម្មន្តីតិ ន ខោ មេ តំ បតិរូបំ យោហំ បិតុ វចនំ អតិក្កមេយ្យន្តិ បុនទេវ កោសិយា ខគ្គំ បវេសេសិ ។ អថខោ ភិក្ខវេ ព្រហ្មទត្តោ កាសិរាជា ភីតោ ឧព្វិគ្គោ ឧស្សង្កី ឧត្រស្តោ សហសា វុដ្ឋាសិ ។ អថខោ ភិក្ខវេ



អំពើនេះឈ្មោះថាមិនសមគួរដល់អាត្មាអញឡើយ ហើយក៏សៀតព្រះខាន់ទៅក្នុងស្រោមវិញ ។ ម្នាលភិក្ខុទាំងឡាយ ទីឃាវុកុមារមានសេចក្តីត្រិះរិះជាគំរប់ពីរទៀត ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ទីឃាវុកុមារមានសេចក្តីត្រិះរិះជាគំរប់បីទៀតយ៉ាងនេះថា ស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្តនេះបានធ្វើសេចក្តីវិនាសជាច្រើនដល់អាត្មាអញ ទាំងពល ពាហនៈ ជនបទ ឃ្លាំង និងជង្រុករបស់អាត្មាអញ ស្តេចនេះរឹបជាន់យកអស់ មិនសល់ប៉ុណ្ណោះ ទាំងមាតាបិតារបស់អាត្មាអញ ស្តេចនេះក៏សម្លាប់ចោលអស់ វេលានេះ គួរអាត្មាអញសងពៀរដល់ស្តេចនេះវិញ ហើយក៏ហូតព្រះខាន់ចេញពីស្រោម(មួយទៀត) ។ ម្នាលភិក្ខុទាំងឡាយ ទីឃាវុកុមារមានសេចក្តីត្រិះរិះជាគំរប់បីទៀតយ៉ាងនេះថា បិតាបានផ្តាំអាត្មាអញក្នុងពេលដែលរៀបធ្វើមរណកាលថា នែទីឃាវុកូន អ្នកឯងកុំឃើញកាលវែង កុំឃើញកាលខ្លី នែទីឃាវុកូន ធម្មតាពៀរមិនដែលរម្ងាប់ដោយការចងពៀរទេ នែទីឃាវុកូន ឯពៀរតែងរម្ងាប់ដោយការមិនចងពៀរ បើអាត្មាអញកន្លងពាក្យបិតាហើយ អំពើនេះឈ្មោះថាមិនសមគួរដល់អាត្មាអញឡើយ ហើយក៏សៀតព្រះខាន់ទៅក្នុងស្រោមវិញ ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្តទ្រង់ភិតភ័យ ភ្ញាក់ផ្អើលស្ញើតស្លុតតក់ស្លុតហើយក៏ក្រោកឡើងភ្លាម ។ ម្នាលភិក្ខុទាំងឡាយ

ទីឃាវុ កុមារោ ព្រហ្មទត្តំ កាសិករាជំ ឯតទវោច កឹ ស្សុ ត្វំ ទេវ ភីតោ ឧព្វិគ្គោ ឧស្សង្កី ឧត្រស្តោ សហសា វុដ្ឋាសីតិ ។ ឥធ មំ ភណេ មាណវក ទីឃីតិស្ស កោសលរញ្ញោ បុត្តោ ទីឃាវុ កុមារោ សុបិនន្តេន ខគ្គេន បរិបាតេសិ តេនាហំ ភីតោ ឧព្វិគ្គោ ឧស្សង្កី ឧត្រស្តោ សហសា វុដ្ឋាសិន្តិ ។ អថខោ ភិក្ខវេ ទីឃាវុ កុមារោ វាមេន ហត្ថេន ព្រហ្មទត្តស្ស កាសិរញ្ញោ សីសំ បរាមសិត្វា ទក្ខិណេន ហត្ថេន ខគ្គំ និព្វាហេត្វា ព្រហ្មទត្តំ កាសិករាជំ ឯតទវោច អហំ ខោ សោ ទេវ ទីឃីតិស្ស កោសលរញ្ញោ បុត្តោ ទីឃាវុ កុមារោ ពហុ ខោ ត្វំ អម្ហាកំ អនត្ថស្ស ការកោ តយា អម្ហាកំ ពលញ្ច វាហនញ្ច ជនបទោ ច កោសោ ច កោដ្ឋាគារញ្ច អច្ឆិន្នំ តយា ច មេ មាតាបិតរោ ហតា អយំ ខ្វស្ស កាលោ យោហំ វេរំ អប្បដិយ្យាទេយ្យន្តិ ។ អថខោ ភិក្ខវេ ព្រហ្មទត្តោ កាសិរាជា ទីឃាវុស្ស កុមារស្ស បាទេសុ សិរសា និបតិត្វា ទីឃាវុំ កុមារំ ឯតទវោច ជីវិតំ មេ



ខណៈនោះ ទីឃាវុកុមារទូលសួរស្ដេចកាសីដែលមានព្រះនាមព្រហ្មទត្ត យ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ហេតុអ្វីបានជាព្រះអង្គទ្រង់ ភិតភ័យភ្ញាក់ផ្អើលស្ញើតស្លុតតក់ស្លុតហើយតើនឡើងភ្លាម ៗ ស្ដេច នោះតបវិញថា នែមាណពក ព្រោះយើងយល់សប្ដិ (ថាដូចជា) ទីឃាវុកុមារជាកូនស្ដេចកោសលឈ្មោះទីឃីតិ លើកព្រះខាន់ ឡើងកាប់យើងក្នុងទីនេះ ព្រោះហេតុនោះបានជាយើងភិតភ័យភ្ញាក់ ផ្អើលស្ញើតស្លុតតក់ស្លុតហើយក្រោកឡើងភ្លាម ៗ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ទីឃាវុកុមារយកដៃឆ្វេងចាប់សក់ព្រះសិរសាស្ដេចកាសី ដែលមានព្រះនាមព្រហ្មទត្ត ហើយយកដៃស្ដាំហូតព្រះខាន់ចេញ និយាយពាក្យនេះនឹងស្ដេចកាសីដែលមានព្រះនាមព្រហ្មទត្តថា នែព្រះអង្គ ខ្ញុំនេះឯងហើយដែលឈ្មោះទីឃាវុកុមារជាកូនស្ដេចកោសលព្រះនាមទីឃីតិ ព្រះអង្គបានធ្វើសេចក្ដីវិនាសជាច្រើនដល់ខ្ញុំ ទាំងពលពាហនៈ ជនបទ ឃ្លាំង និងជង្រុករបស់ខ្ញុំ ព្រះអង្គក៏រឹបជាន់យក អស់ ម្យ៉ាងទៀត ទាំងមាតាបិតារបស់ខ្ញុំ ព្រះអង្គក៏សម្លាប់ចោលអស់ វេលានេះ គួរខ្ញុំសងពៀរដល់ព្រះអង្គវិញ ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ស្ដេចកាសីដែលមានព្រះនាមព្រហ្មទត្តក៏ឱនព្រះសិរ ក្រាបទៀបជើងទីឃាវុកុមារ ហើយមានព្រះបន្ទូលទៅនឹងទីឃាវុកុមារ

តាត ទីឃាវុ ទេហិ ជីវិតំ មេ តាត ទីឃាវុ ទេហីតិ ។ ក្យាហំ ទេវ សក្កោមិ ទេវស្ស ជីវិតំ ទាតុំ ទេវោ ខោ មេ ជីវិតំ ទទេយ្យាតិ ។ តេនហិ តាត ទីឃាវុ ត្វញ្ចេវ មេ ជីវិតំ ទេហិ អហញ្ច តេ ជីវិតំ ទម្មីតិ ។ អថខោ ភិក្ខវេ ព្រហ្មទត្តោ ច កាសិរាជា ទីឃាវុ ច កុមារោ អញ្ញមញ្ញស្ស ជីវិតំ អទំសុ បាណិញ្ច អគ្គហេសុំ សបថញ្ច អកំសុ អទ្ទុហាយ[១] ។ អថខោ ភិក្ខវេ ព្រហ្មទត្តោ កាសិរាជា ទីឃាវុំ កុមារំ ឯតទវោច តេនហិ តាត ទីឃាវុ រថំ យោជេហិ គមិស្សាមាតិ ។ ឯវំ ទេវាតិ ខោ ភិក្ខវេ ទីឃាវុ កុមារោ ព្រហ្មទត្តស្ស កាសិរញ្ញោ បដិស្សុណិត្វា រថំ យោជេត្វា ព្រហ្មទត្តំ កាសិរាជានំ ឯតទវោច យុត្តោ ខោ តេ ទេវ រថោ យស្សទានិ កាលំ មញ្ញសីតិ ។ អថខោ ភិក្ខវេ ព្រហ្មទត្តោ កាសិរាជា រថំ អភិរុហិ ទីឃាវុ កុមារោ រថំ បេសេសិ ។ តថា តថា រថំ បេសេសិ យថា យថា នចិរស្សេវ សេនាយ

១ ម. អទ្ទុភាយ ។



ហើយនិយាយថា នែទីឃាវុកុមារ សូមអ្នកការពារឲ្យជីវិតដល់យើងផង នែទីឃាវុកុមារ សូមអ្នកការពារឲ្យជីវិតដល់យើងផង ។ ទីឃាវុកុមារតបវិញថា ខ្ញុំនឹងគាប់ប្រាយជីវិតព្រះអង្គដូចម្តេចបាន គួរតែព្រះអង្គប្រទានជីវិតមកខ្ញុំវិញ ។ ស្តេចនោះទ្រង់ត្រាស់ថា នែទីឃាវុកុមារ បើដូច្នោះអ្នកឯងចូរឲ្យជីវិតដល់យើងចុះ យើងក៏ឲ្យជីវិតដល់អ្នកឯងវិញ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្តនឹងទីឃាវុកុមារបានឲ្យជីវិតគ្នាទៅវិញទៅមក ហើយបានចាប់ដៃគ្នានឹងធ្វើសម្បថផង ដើម្បីមិនឲ្យមានរឿងប្រទូស្តគ្នាតទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្តទ្រង់មានព្រះបន្ទូលទៅនឹងទីឃាវុកុមារយ៉ាងនេះថា នែទីឃាវុកុមារ បើដូច្នោះចូរអ្នកទឹមរាជរថចុះ យើងនឹងត្រឡប់ទៅវិញ ។ ម្នាលភិក្ខុទាំងឡាយ ទីឃាវុកុមារបានទទួលស្តាប់ព្រះបន្ទូលស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្តដោយពាក្យថា ព្រះករុណាវិសេស ហើយក៏ទឹមរាជរថរួចក្រាបទូលស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្តយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ឯរាជរថរបស់ព្រះអង្គខ្ញុំព្រះអង្គទឹមរួចស្រេចហើយ សូមព្រះអង្គទ្រង់ជ្រាបកាលគួរនឹងស្តេចយាងចុះ ។ ម្នាលភិក្ខុទាំងឡាយ ខណៈនោះ ស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្តទ្រង់យាងឡើងគង់លើរាជរថ ឯទីឃាវុកុមារក៏បររាជរថទៅ ។ មិនយូរប៉ុន្មាន ទីឃាវុកុមារក៏បររាជរថទៅ

សមាគច្ឆុំ ។ អថខោ ភិក្ខវេ ព្រហ្មទត្តោ កាសិរាជា ពារាណសិំ បវិសិត្វា អមច្ចេ ចារិសេត្វា សន្និបាតាបេត្វា ឯតទវោច សចេ ភណេ ទីឃីតិស្ស កោសលរញ្ញោ បុត្តំ ទីឃាវុំ កុមារំ បស្សេយ្យាថ កិន្តិ តំ ករេយ្យាថាតិ ។ ឯកច្ចេ អមច្ចា ឯវមាហំសុ មយំ ទេវ ហត្ថេ ឆិន្ទេយ្យាម មយំ ទេវ បាទេ ឆិន្ទេយ្យាម មយំ ទេវ ហត្ថបាទេ ឆិន្ទេយ្យាម មយំ ទេវ កណ្ណេ ឆិន្ទេយ្យាម មយំ ទេវ នាសំ ឆិន្ទេយ្យាម មយំ ទេវ កណ្ណនាសំ ឆិន្ទេយ្យាម មយំ ទេវ សីសំ ឆិន្ទេយ្យាមាតិ ។ អយំ ខោ សោ ភណេ ទីឃីតិស្ស កោសលរញ្ញោ បុត្តោ ទីឃាវុ កុមារោ នាយំ លព្ភា កិញ្ចិ កាតុំ ឥមិនា ច មេ ជីវិតំ ទិន្នំ ឥមស្ស ច មយា ជីវិតំ ទិន្នន្តិ ។ អថខោ ភិក្ខវេ



ជួបជុំនឹងពួកសេនាដែលទៅតាមផ្លូវផ្សេងគ្នានោះ ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ស្តេចកាសីដែលមានព្រះនាមព្រហ្មទត្ត ទ្រង់យាងចូលទៅក្រុងពារាណសីហើយទ្រង់ប្រជុំពួកអមាត្យដោយបរិស័ទ្យរួចហើយទ្រង់មានព្រះបន្ទូលហៅទាំងនេះថា នែនាយ ប្រសិនបើអ្នកទាំងឡាយបានឃើញទីឃាវុកុមារជាកូនស្តេចដែនកោសលឈ្មោះទីឃីតិហើយ តើគួរធ្វើទីឃាវុកុមារនោះដូចម្តេច ។ អមាត្យទាំងឡាយក៏ក្រាបទូលដោយពួកៗ យ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស យើងខ្ញុំគួរតែកាត់ដៃចេញ សូមទ្រង់ព្រះមេត្តាប្រោស យើងខ្ញុំគួរតែកាត់ជើងចេញ សូមទ្រង់ព្រះមេត្តាប្រោស យើងខ្ញុំគួរតែកាត់ទាំងដៃទាំងជើងចេញ សូមទ្រង់ព្រះមេត្តាប្រោស យើងខ្ញុំគួរតែកាត់ត្រចៀកចេញ សូមទ្រង់ព្រះមេត្តាប្រោស យើងខ្ញុំគួរតែកាត់ច្រមុះចេញ សូមទ្រង់ព្រះមេត្តាប្រោស យើងខ្ញុំគួរតែកាត់ទាំងត្រចៀកទាំងច្រមុះចេញ សូមទ្រង់ព្រះមេត្តាប្រោស យើងខ្ញុំគួរតែកាត់ក្បាលចេញ ។ ស្តេចនោះទ្រង់ត្រាស់ថា នែនាយទាំងឡាយ បុរសនេះឯងហើយដែលឈ្មោះទីឃាវុកុមារជាកូនស្តេចដែនកោសលឈ្មោះទីឃីតិនោះ អ្នកទាំងឡាយមិនត្រូវធ្វើទោសកុមារនេះបន្តិចឡើយ ព្រោះកុមារនេះបានឲ្យជីវិតដល់យើង យើងក៏បានឲ្យជីវិតដល់កុមារនេះវិញ ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ

ព្រហ្មទត្តោ កាសិរាជា ទីឃាវុំ កុមារំ ឯតទវោច យំ ខោ តេ តាត ទីឃាវុ បិតា មរណកាលេ អវច មា ខោ ត្វំ តាត ទីឃាវុ ទីឃំ បស្ស មា រស្សំ ន ហិ តាត ទីឃាវុ វេរេន វេរា សម្មន្តិ អវេរេន ហិ តាត ទីឃាវុ វេរា សម្មន្តីតិ កិំ តេ បិតា សន្ធាយ អវចាតិ ។ យំ ខោ មេ ទេវ បិតា មរណកាលេ អវច មា ទីឃន្តិ មា ចិរំ វេរំ អកាសីតិ ឥមំ ខោ មេ ទេវ បិតា មរណកាលេ អវច មា ទីឃន្តិ យំ ខោ មេ ទេវ បិតា មរណកាលេ អវច មា រស្សន្តិ មា ខិប្បំ មិត្តេហិ ភិជ្ជិត្ថាតិ ឥមំ ខោ មេ ទេវ បិតា មរណកាលេ អវច មា រស្សន្តិ យំ ខោ មេ ទេវ បិតា មរណកាលេ អវច ន ហិ តាត ទីឃាវុ វេរេន វេរា



ស្ដេចគ្រងដែនកាសី ព្រះនាមព្រហ្មទត្ត ទ្រង់មានព្រះឱង្ការទៅនឹងទីឃាវុកុមារយ៉ាងនេះថា នែទីឃាវុកុមារ កាលដែលបិតារបស់អ្នកជិតនឹងធ្វើមរណកាលបានផ្ដាំបណ្ដាំណាចំពោះអ្នកឯងថា នែទីឃាវុកុមារ អ្នកឯងកុំឃើញកាលវែង កុំឃើញកាលខ្លី នែទីឃាវុកុមារ ពួកពៀរមិនដែលរម្ងាប់ដោយការចងពៀរទេ នែទីឃាវុកុមារ ឯពៀរតែងរម្ងាប់ដោយការមិនចងពៀរ តើបិតារបស់អ្នកសំដៅយកហេតុដូចម្ដេច បានជាផ្ដាំ (ដូច្នេះ) ។ ទីឃាវុកុមារក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស កាលដែលបិតារបស់ខ្ញុំព្រះអង្គជិតនឹងធ្វើមរណកាលបានផ្ដាំបណ្ដាំណាចំពោះខ្ញុំព្រះអង្គថា អ្នកកុំឃើញកាលវែង គឺថាអ្នកឯងកុំធ្វើពៀរឲ្យយូរអង្វែងឡើយ សូមទ្រង់ព្រះមេត្តាប្រោស កាលដែលបិតារបស់ខ្ញុំព្រះអង្គជិតនឹងធ្វើមរណកាលបានផ្ដាំបណ្ដាំនេះឯង (នេះហៅថា) កុំឃើញកាលវែង សូមទ្រង់ព្រះមេត្តាប្រោស កាលដែលបិតារបស់ខ្ញុំព្រះអង្គទៀបនឹងធ្វើមរណកាលបានផ្ដាំបណ្ដាំណាចំពោះខ្ញុំព្រះអង្គថា អ្នកឯងកុំឃើញកាលខ្លី គឺថាអ្នកឯងកុំប្រញាប់បែកបាក់នឹងមិត្តសំឡាញ់ឡើយ សូមទ្រង់ព្រះមេត្តាប្រោស កាលដែលបិតារបស់ខ្ញុំព្រះអង្គជិតនឹងធ្វើមរណកាលបានផ្ដាំបណ្ដាំនេះឯង (នេះហៅថា) កុំឃើញកាលខ្លី សូមទ្រង់ព្រះមេត្តាប្រោស កាលដែលបិតារបស់ខ្ញុំព្រះអង្គជិតនឹងធ្វើមរណកាលបានផ្ដាំបណ្ដាំណាចំពោះខ្ញុំព្រះអង្គថា នែទីឃាវុកុមារ ពួកពៀរ

សម្មន្តិ អវេរេន ហិ តាត ទីឃាវុ វេរា សម្មន្តីតិ ទេវេន មេ មាតាបិតរោ ឃាតិតាតិ សចាហំ ទេវំ ជីវិតា វោរោបេយ្យំ យេ ទេវស្ស អត្ថកាមា តេ មំ ជីវិតា វោរោបេយ្យុំ យេ មេ អត្ថកាមា តេ តេ ជីវិតា វោរោបេយ្យុំ ឯវន្តំ វេរំ វេរេន ន វូបសមេយ្យ ឥទានិ ច បន មេ ទេវេន ជីវិតំ ទិន្នំ មយា ច ទេវស្ស ជីវិតំ ទិន្នំ ឯវន្តំ[១] វេរំ អវេរេន វូបសន្តំ ឥទំ ខោ មេ ទេវ បិតា មរណកាលេ អវច ន ហិ តាត ទីឃាវុ វេរេន វេរា សម្មន្តិ អវេរេន ហិ តាត ទីឃាវុ វេរា សម្មន្តីតិ ។ អថខោ ភិក្ខវេ ព្រហ្មទត្តោ កាសិរាជា អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ យាវ បណ្ឌិតោ អយំ ទីឃាវុ កុមារោ យត្រ ហិ នាម បិតុនោ សង្ខិត្តេន ភាសិតស្ស វិត្ថារេន អត្ថំ អាជានិស្សតីតិ បេត្តិកំ ពលញ្ច វាហនញ្ច ជនបទញ្ច កោសញ្ច

---

១ ឱ. ឯវំ ។



មិនដែលរម្ងាប់ដោយការចងពៀរទេ នែទីឃាវុកុមារ ឯពៀរតែងរម្ងាប់ដោយការមិនចងពៀរ (នោះសោតទៅ(គត់)) មាតាបិតារបស់ខ្ញុំព្រះអង្គដែលព្រះអង្គសម្លាប់ហើយ ព្រោះហេតុនោះ បើខ្ញុំព្រះអង្គនឹងបំផ្លាញព្រះអង្គឲ្យដាច់ចាកជីវិតហើយ ពួកជនណាដែលប្រាថ្នាប្រយោជន៍ចំពោះព្រះអង្គ នឹងបំផ្លាញខ្ញុំព្រះអង្គឲ្យដាច់ចាកជីវិតវិញ ពួកជនដែលប្រាថ្នាប្រយោជន៍ដល់ខ្ញុំព្រះអង្គ មុខជានឹងបំផ្លាញជនទាំងនោះឲ្យដាច់ចាកជីវិតមិនខានឡើយ ពៀរនោះមិនបានរម្ងាប់ដោយការចងពៀរយ៉ាងនេះឯង ឥឡូវព្រះអង្គទ្រង់ប្រទានជីវិតដល់ខ្ញុំព្រះអង្គហើយ ខ្ញុំព្រះអង្គក៏ថ្វាយជីវិតដល់ព្រះអង្គវិញ ពៀរនោះនឹងរម្ងាប់ដោយការមិនចងពៀរយ៉ាងនេះឯង សូមទ្រង់ព្រះមេត្តាប្រោស កាលដែលបិតារបស់ខ្ញុំព្រះអង្គជិតនឹងធ្វើមរណកាលបានផ្តាំបណ្តាំនេះឯងថា នែទីឃាវុកុមារ បណ្តាពៀរមិនដែលរម្ងាប់ដោយការចងពៀរទេ នែទីឃាវុកុមារ ឯពៀរតែងរម្ងាប់ដោយការមិនចងពៀរ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្តទ្រង់ត្រាស់ថា អើហ្ន៎ (ហេតុនេះ) គួរជាអស្ចារ្យណាស់ អើហ្ន៎ (ហេតុនេះ) ហាក់ជាចម្លែកណាស់ ទីឃាវុកុមារនេះពិតជាអ្នកប្រាជ្ញមែន ព្រោះថានឹងដឹងសេចក្តីដែលបិតាពោលដោយសង្ខេប ដោយពិស្តារបាន ហើយក៏ទ្រង់ត្រឡប់ប្រគល់ពល ពាហនៈ ជនបទ ឃ្លាំង

បេត្តិកំ ពលញ្ច វាហនញ្ច ជនបទញ្ច កោសញ្ច កោដ្ឋាគារញ្ច បដិបាទេសិ ធីតរញ្ច អទាសិ ។ តេសំ ហិ នាម ភិក្ខវេ រាជូនំ អាទិន្នទណ្ឌានំ អាទិន្នសត្ថានំ ឯវរូបំ ខន្តិសោរច្ចំ ភវិស្សតីតិ ។ ឥធ ខោ តំ ភិក្ខវេ សោភេថ យំ តុម្ហេ ឯវំ ស្វាក្ខាតេ ធម្មវិនយេ បព្វជិតា សមានា ខមា ច ភវេយ្យាថ សោរតា ចាតិ ។

(៤៥០) តតិយម្បិ ខោ ភគវា តេ ភិក្ខូ ឯតទវោច អលំ ភិក្ខវេ មា ភណ្ឌនំ មា កលហំ មា វិគ្គហំ មា វិវាទន្តិ ។ តតិយម្បិ ខោ សោ អធម្មវាទី ភិក្ខុ ភគវន្តំ ឯតទវោច អាគមេតុ ភន្តេ ភគវា ធម្មស្សាមី អប្បោស្សុក្កោ ភន្តេ ភគវា ទិដ្ឋធម្មសុខវិហារំ អនុយុត្តោ វិហរតុ



ទ្រព្យសម្បត្តិ ជាមរតកនៃព្រះបិតាទៅទីឃាវុកុមារវិញ ព្រមទាំងប្រទានព្រះធីតា ១ ថែមទៀត ។ ម្នាលភិក្ខុទាំងឡាយ ស្ដេចក្សត្រទាំងពួកក្សត្រទាំងនោះ (ក្ដាប់ក) កាន់ដំបង (ក្ដាប់ក) កាន់គ្រឿងសស្ត្រាហើយ នៅមានអំណត់ និងសេចក្ដីប្រព្រឹត្តល្អយ៉ាងនេះបាន ។ ព្រោះហេតុដូច្នោះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយបានបួសក្នុងធម្មវិន័យនេះដែលតថាគតបានសំដែងហើយដោយល្អយ៉ាងនេះហើយ គួរតែអំណត់ គួរតែប្រព្រឹត្តល្អឲ្យល្អឡើង ។

[៤៥០] ព្រះដ៏មានព្រះភាគទ្រង់មានព្រះពុទ្ធដីកាទៅនឹងភិក្ខុទាំងនោះជាគំរប់បីដងយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ កុំឡើយ អ្នកទាំងឡាយកុំធ្វើសេចក្ដីបរិភាសគ្នា កុំធ្វើសេចក្ដីឈ្លោះគ្នា កុំធ្វើសេចក្ដីប្រកាន់ផ្សេង ៗ គ្នា កុំធ្វើសេចក្ដីវិវាទគ្នាឡើយ ។ ឯអធម្មវាទីភិក្ខុនោះក្រាបបង្គំទូលព្រះដ៏មានព្រះភាគជាគំរប់បីដងយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះមានព្រះភាគជាធម្មស្សាមីទ្រង់ឈប់សិនចុះ សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះដ៏មានព្រះភាគមានសេចក្ដីខ្វល់ខ្វាយតិច សូមទ្រង់ប្រកបនូវធម៌ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្នរឿយ ៗ ចុះ

មយមេតេន ភណ្ឌនេន កលហេន វិគ្គហេន វិវាទេន បញ្ញាយិស្សាមាតិ ។ អថខោ ភគវា បរិយាទិន្នរូបា ខោ ឥមេ មោឃបុរិសា នយិមេ សុករា សញ្ញាបេតុន្តិ ឧដ្ឋាយាសនា បក្កាមិ ។

ទីឃាវុភាណវារំ បឋមំ ។

(២៥៦) អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ កោសម្ពឹ បិណ្ឌាយ បាវិសិ កោសម្ពិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ សេនាសនំ សំសាមេត្វា បត្តចីវរមាទាយ ឋិតកោវ ឥមា គាថាយោ អភាសិ ។



ឯយើងខ្ញុំទាំងឡាយ នឹងប្រាកដដោយសេចក្តីប្រកួតប្រកាន់ ដោយសេចក្តីឈ្លោះគ្នា ដោយសេចក្តីប្រកាន់ផ្សេងៗគ្នា ដោយសេចក្តីវិវាទគ្នាមិនខាន ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ព្រះតម្រិះថា ពួកមោឃបុរសទាំងនេះមានសភាពគឺកិលេសគ្របសង្កត់ហើយ ពួកនេះមិនងាយនឹងពន្យល់មោឃបុរសទាំងនេះបានឡើយ ហើយក៏ទ្រង់ក្រោកចាកអាសនៈស្តេចចេញទៅ ។

ចប់ ភាណវារៈទីឃាវុកុមារ ទី ១ ។

(២៥៦) លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ស្បង់ហើយ ទ្រង់បាត្រនិងចីវរ យាងចូលទៅក្រុងកោសម្ពីដើម្បីបិណ្ឌបាត ក្នុងវេលាព្រឹកព្រលឹម លុះយាងទៅបិណ្ឌបាតក្នុងក្រុងកោសម្ពីហើយ ទ្រង់ត្រឡប់មកពីបិណ្ឌបាតវិញ ក៏ទ្រង់រៀបចំដាក់ទីសេនាសនៈ ហើយកាន់យកបាត្រនិងចីវរ ទ្រង់ឋិតកណ្តាលជំនុំសង្ឃ ក្នុងវេលាក្រោយភត្ត ហើយទ្រង់ពោលព្រះគាថាទាំងនេះថា

(១៩៣) បុថុសទ្ទោ សមជនោ
ន ពាលោ កោចិ មញ្ញថ
សង្ឃស្មឹ ភិជ្ជមានស្មឹ
នាញ្ញំ ភិយ្យោ អមញ្ញរុំ ។
បរិមុដ្ឋា បណ្ឌិតាភាសា
វាចាគោចរភាណិនោ
យាវិច្ឆន្តិ មុខាយាមំ
យេន នីតា ន តំ វិទូ
អក្កោច្ឆិ មំ អវធិ មំ
អជិនិ មំ អហាសិ មេ
យេ ច តំ ឧបនយ្ហន្តិ
វេរំ តេសំ ន សម្មតិ ។
អក្កោច្ឆិ មំ អវធិ មំ
អជិនិ មំ អហាសិ មេ
យេ ច តំ នុបនយ្ហន្តិ
វេរំ តេសូបសម្មតិ ។
ន ហិ វេរេន វេរានិ



(១៩៣) ជននេះមានសំឡេងខ្លាំងដូចគ្នា ជាជនប្រហែលគ្នាផង សូម្បីជនណាមួយដឹងខ្លួនថាជាបុគ្គលពាលក៏គ្មាន កាលបើសង្ឃកំពុងបែកគ្នា ជនទាំងឡាយក៏មិនបានដឹងហេតុដទៃឲ្យប្លែកលើស ។ ពួកជនដែលភ្លេចស្មារតី ហើយធ្វើឫកពនដូចជាអ្នកប្រាជ្ញ មានសំដីជាអារម្មណ៍ ចង់ហាមាត់និយាយប៉ុន្មាន ក៏និយាយប៉ុណ្ណោះទៅ ទុកជាមានគេនាំទៅប្រដល់ឲ្យឈ្លោះគ្នា ក៏មិនដឹងសេចក្តីនោះថាជាសេចក្តីឈ្លោះឡើយ ។ ពួកជនណាចងសេចក្តីក្រោធនោះទុកដោយគិតថា ជនឯណោះបានជេរអាត្មាអញ ជនឯណោះបានវាយអាត្មាអញ ជនឯណោះបានផ្ចាញ់ផ្ចាលអាត្មាអញ ជនឯណោះបានលួចទ្រព្យអាត្មាអញ ពៀររបស់ជនទាំងនោះមិនបានរម្ងាប់ទេ ។ ម្យ៉ាងទៀត ពួកជនណាមិនបានចងសេចក្តីក្រោធនោះទុកដោយគិតថា ជនឯណោះបានជេរអាត្មាអញ ជនឯណោះបានវាយអាត្មាអញ ជនឯណោះបានផ្ចាញ់ផ្ចាលអាត្មាអញ ជនឯណោះបានលួចទ្រព្យអាត្មាអញ ពៀររបស់ជនទាំងនោះរមែងរម្ងាប់ទៅបាន ។ ក្នុងលោកនេះ [illegible]ពៀរ

សម្មន្តីធ កុទាចនំ

អវេរេន ច សម្មន្តិ

ឯស ធម្មោ សនន្តនោ ។

បរេ ច ន វិជានន្តិ

មយមេត្ថ យមាមសេ

យេ ច តត្ថ វិជានន្តិ

តតោ សម្មន្តិ មេធគា ។

អដ្ឋិច្ឆិន្នា[១] បាណហរា

គវស្សធនហារិនោ

រដ្ឋំ វិលុម្បមានានំ

តេសម្បិ ហោតិ សង្គតិ ។

កស្មា តុម្ហាក នោ សិយា ។

សចេ លភេថ និបកំ សហាយំ

សទ្ធិញ្ចរំ សាធុវិហារិធីរំ

១ ម. អដ្ឋិច្ឆិន្នា ។



មិនដែលរម្ងាប់ទៅដោយការចងពៀរបានឡើយ រម្ងាប់បានតែដោយការមិនចងពៀរ នេះជាធម្មតាដែលមានពីដើមរៀងមក ។ ពួកជនដទៃមិនដឹងច្បាស់ថា យើងរាល់គ្នានឹងវិនាសក្នុងកណ្ដាលជំនុំសង្ឃនេះទេ បណ្ដាជនទាំងនោះ បើពួកជនណាមួយដឹងច្បាស់ សេចក្ដីឈ្លោះប្រកែករម្ងាប់អំពីសំណាក់ជនទាំងនោះបាន ។ សម្បូរស្ដីមានគប់ការបស់វិយោគ្នាកកាត់ឆ្អឹង ពួកដែលគេសម្លាប់បាណ ទាំងគោ សេះ និងធនធានដែលគេនាំយកទៅ ទាំងដែលគេប្លន់ផណ្ដឹមយកដែន ម្ដេចស្លួចទាំងនោះនៅមានសេចក្ដីព្រមព្រៀងគ្នាបាន ។ ចុះអ្នកទាំងឡាយហេតុអ្វីគ្មានសេចក្ដីព្រមព្រៀងគ្នា ។

បើបុគ្គលបានសំឡាញ់មានប្រាជ្ញាជាគ្រឿងរក្សាខ្លួន[១] ជាអ្នកប្រាជ្ញមានធម៌ជាគ្រឿងនៅសប្បាយ ត្រាច់ទៅជាមួយគ្នា

១ ក្នុងអដ្ឋកថា ថា និបកំ បុគ្គលមានប្រាជ្ញា ដោយប្រាជ្ញាដែលរក្សាខ្លួន ... មានចំណេះ ... ដឹងនូវសេចក្ដីល្អ ... មានប្រាជ្ញាជាគ្រឿងរក្សាខ្លួន ។

អភិភុយ្យ សព្វានិ បរិស្សយានិ

ចរេយ្យ តេនត្តមនោ សតីមា ។

នោ ចេ លភេថ និបកំ សហាយំ

សទ្ធិំចរំ សាធុវិហារិធីរំ

រាជាវ រដ្ឋំ វិជិតំ បហាយ

ឯកោ ចរេ មាតង្គរញ្ញេវ នាគោ ។

ឯកស្ស ចរិតំ សេយ្យោ

នត្ថិ ពាលេ សហាយតា ។

ឯកោ ចរេ ន ច បាបានិ កយិរា

អប្បោស្សុក្កោ មាតង្គរញ្ញេវ នាគោ ។



បុគ្គលនោះ គប្បីគ្របសង្កត់នូវសេចក្តីអន្តរាយទាំងពួងបាន ហើយជាអ្នកមានសេចក្តីត្រេកអរមានស្មារតី គប្បីត្រាច់ទៅជាមួយនឹងសំឡាញ់នោះចុះ ។ បើបុគ្គលមិនបានសំឡាញ់ដែលមានប្រាជ្ញាជាគ្រឿងរក្សាខ្លួន ជាអ្នកប្រាជ្ញ មានធម៌ជាគ្រឿងនៅសប្បាយ ត្រាច់ទៅជាមួយគ្នាទេ បុគ្គលនោះគួរត្រាច់ទៅតែម្នាក់ឯង ប្រៀបដូចជាស្តេចលះបង់ដែនដែលខ្លួនឈ្នះហើយត្រាច់ទៅម្នាក់ឯង (កុំអោះអាង) ប្រៀបដូចជាដំរីដ៏ប្រសើរត្រាច់ទៅម្នាក់ឯងក្នុងព្រៃ ។ ការដែលបុគ្គលត្រាច់ទៅតែម្នាក់ឯង ហៅថាប្រសើរ ព្រោះបុគ្គលពាលគ្មានសហាយគុណ[១]ទេ ។ ម្យ៉ាងទៀត បុគ្គលគួរត្រាច់ទៅតែម្នាក់ឯង មិនគួរធ្វើអំពើលាមកឡើយ ប្រៀបដូចជាដំរីដ៏ប្រសើរមានសេចក្តីខ្វល់ខ្វាយតិច ត្រាច់ទៅតែម្នាក់ឯងក្នុងព្រៃ ។

---

១ អដ្ឋកថាធម្មបទ ចុល្លសីល មជ្ឈិមសីល មហាសីល កថាវត្ថុ ១០ ធុតង្គគុណ ១៣ វិបស្សនាញាណ មគ្គ ៤ ផល ៤ វិជ្ជា ៣ អភិញ្ញា ៦ អមតមហានិព្វាន ហៅថា សហាយគុណ ។

[៤៥៦] អថខោ ភគវា សង្ឃមជ្ឈេ ឋិតកោវ ឥមា គាថាយោ ភាសិត្វា យេន ពាលកលោណការគាមោ[១] តេនុបសង្កមិ ។ តេន ខោ បន សមយេន អាយស្មា ភគុ ពាលកលោណការគាមេ វិហរតិ ។ អទ្ទសា ខោ អាយស្មា ភគុ ភគវន្តំ ទូរតោវ អាគច្ឆន្តំ ទិស្វាន អាសនំ បញ្ញបេសិ បាទោទកំ បាទបីឋំ បាទកឋលិកំ ឧបនិក្ខិបិ បច្ចុគ្គន្ត្វា បត្តចីវរំ បដិគ្គហេសិ ។ និសីទិ ភគវា បញ្ញត្តេ អាសនេ និសជ្ជ ខោ ភគវា បាទេ បក្ខាលេសិ ។ អាយស្មាបិ ខោ ភគុ ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ ភគុំ ភគវា ឯតទវោច កច្ចិ ភិក្ខុ ខមនីយំ កច្ចិ យាបនីយំ កច្ចិ បិណ្ឌកេន ន កិលមសីតិ ។ ខមនីយំ ភគវា យាបនីយំ ភគវា ន ចាហំ ភន្តេ បិណ្ឌកេន កិលមាមីតិ ។ អថខោ ភគវា អាយស្មន្តំ

---
១ ម. ពាលកលោណការគាមោ ។



[៤៥៦] កាលបើព្រះមានព្រះភាគទ្រង់ឋិតកណ្ដាលនៃភិក្ខុសង្ឃ ពោលព្រះគាថាអម្បាលនេះហើយ ក៏ទ្រង់យាងចូលទៅកាន់ពាលកលោណការកគ្រាម ។ សម័យនោះឯង ព្រះភគុដ៏មានអាយុគង់នៅក្នុងពាលកលោណការកគ្រាមនោះ ។ ឯព្រះភគុដ៏មានអាយុបានឃើញព្រះមានព្រះភាគទ្រង់យាងមកអំពីចម្ងាយ លុះឃើញហើយក៏រៀបក្រាលអាសនៈទុក ដាក់ទឹកសម្រាប់លាងព្រះបាទ តាំងសម្រាប់ទ្រព្រះបាទដែលលាងរួច ហើយនិងក្បឿងសម្រាប់ទ្រព្រះបាទដែលមិនទាន់លាង ក្រោកហើយដើរក្រោកឡើងទៅទទួលបាត្រនិងចីវរ ។ ព្រះមានព្រះភាគក៏ទ្រង់គង់លើអាសនៈដែលភិក្ខុក្រាលថ្វាយ លុះគង់ហើយទើបលាងព្រះបាទ ។ ចំណែកឯព្រះភគុដ៏មានអាយុ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគរួចអង្គុយនៅក្នុងទីសមគួរ ។ លុះព្រះភគុដ៏មានអាយុអង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគទ្រង់ត្រាស់សួរយ៉ាងនេះថា ម្នាលភិក្ខុ អ្នកល្មមអត់ទនបាននៅឬ អ្នកល្មមប្រព្រឹត្តទៅបាននៅឬ អ្នកមិនលំបាកដោយបិណ្ឌបាតទេឬ ។ ព្រះភគុដ៏មានអាយុក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គល្មមអត់ទនបាន បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គល្មមប្រព្រឹត្តទៅបាន សូមទ្រង់ព្រះមេត្តាប្រោស មួយទៀត ខ្ញុំព្រះអង្គមិនលំបាកដោយបិណ្ឌបាតទេ ។ វេលានោះ ព្រះមានព្រះភាគ

ភគុំ ធម្មិយា កថាយ សន្ទស្សេត្វា សមាទបេត្វា សមុត្តេជេត្វា សម្បហំសេត្វា ឧដ្ឋាយាសនា យេន បាចីនវំសទាយោ តេនុបសង្កមិ ។ តេន ខោ បន សមយេន អាយស្មា ច អនុរុទ្ធោ អាយស្មា ច នន្ទិយោ អាយស្មា ច កិម្ពិលោ បាចីនវំសទាយេ វិហរន្តិ ។ អទ្ទសា ខោ ទាយបាលោ ភគវន្តំ ទូរតោវ អាគច្ឆន្តំ ទិស្វាន ភគវន្តំ ឯតទវោច មា មហាសមណ ឯតំ ទាយំ បាវិសិ សន្តេត្ថ តយោ កុលបុត្តា អត្តកាមរូបា វិហរន្តិ មា តេសំ អផាសុមកាសីតិ ។ អស្សោសិ ខោ អាយស្មា អនុរុទ្ធោ ទាយបាលស្ស ភគវតា សទ្ធឹ មន្តយមានស្ស សុត្វាន ទាយបាលំ ឯតទវោច មា អាវុសោ ទាយបាល ភគវន្តំ វារេសិ សត្ថា នោ ភគវា អនុប្បត្តោតិ ។ អថខោ អាយស្មា អនុរុទ្ធោ យេនាយស្មា ច នន្ទិយោ អាយស្មា ច កិម្ពិលោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តញ្ច នន្ទិយំ អាយស្មន្តញ្ច កិម្ពិលំ ឯតទវោច



ទ្រង់ពន្យល់ព្រះភគុដ៏មានអាយុឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថា ហើយទ្រង់ក្រោកចាកអាសនៈ យាងទៅឯព្រៃឫស្សីឈ្មោះបាចីនវង្ស ។ សម័យនោះឯង ចួនជាព្រះអនុរុទ្ធដ៏មានអាយុ ១ ព្រះនន្ទិយៈដ៏មានអាយុ ១ ព្រះកិម្ពិលៈដ៏មានអាយុ ១ គង់នៅក្នុងព្រៃឫស្សីឈ្មោះបាចីនវង្សដែរ ។ មានបុរសម្នាក់ជាអ្នករក្សាព្រៃ បានឃើញព្រះមានព្រះភាគទ្រង់យាងមកអំពីចម្ងាយ លុះឃើញហើយក៏ក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះសមណៈ ព្រះអង្គកុំយាងចូលទៅក្នុងព្រៃនេះឡើយ ដ្បិតមានពួកកុលបុត្ត ៣ រូប មានសភាពជាអ្នកស្រឡាញ់ខ្លួននៅក្នុងព្រៃនេះ ព្រះអង្គកុំធ្វើសេចក្តីអផ្សុកដល់កុលបុត្តទាំងនោះឡើយ ។ ព្រះអនុរុទ្ធដ៏មានអាយុក៏បានឮពាក្យបុរសជាអ្នករក្សាព្រៃ កំពុងប្រឹក្សាជាមួយនឹងព្រះមានព្រះភាគដែរ លុះឮហើយក៏និយាយទៅនឹងបុរសជាអ្នករក្សាព្រៃយ៉ាងនេះថា ម្នាលអ្នករក្សាព្រៃដ៏មានអាយុ អ្នកឯងកុំឃាត់ព្រះមានព្រះភាគឡើយ ដ្បិតព្រះមានព្រះភាគជាគ្រូរបស់យើង ព្រះអង្គស្តេចយាងមកដល់ហើយ ។ ខណៈនោះ ព្រះអនុរុទ្ធដ៏មានអាយុចូលទៅរកព្រះនន្ទិយៈដ៏មានអាយុ នឹងព្រះកិម្ពិលៈដ៏មានអាយុ លុះចូលទៅដល់ហើយក៏និយាយនឹងព្រះនន្ទិយៈដ៏មានអាយុនឹងព្រះកិម្ពិលៈ

អភិក្កមថាយស្មន្តោ អភិក្កមថាយស្មន្តោ សត្ថា នោ ភគវា អនុប្បត្តោតិ ។ អថខោ អាយស្មា ច អនុរុទ្ធោ អាយស្មា ច នន្ទិយោ អាយស្មា ច កិម្ពិលោ ភគវន្តំ បច្ចុគ្គន្ត្វា ឯកោ ភគវតោ បត្តចីវរំ បដិគ្គហេសិ ឯកោ អាសនំ បញ្ញាបេសិ ឯកោ បាទោទកំ បាទបីឋំ បាទ-កឋលិកំ ឧបនិក្ខិបិ ។ និសីទិ ភគវា បញ្ញត្តេ អាសនេ និសជ្ជ ខោ ភគវា បាទេ បក្ខាលេសិ ។ តេបិ ខោ អាយស្មន្តោ[១] ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិំសុ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ អនុរុទ្ធំ ភគវា ឯត-ទវោច កច្ចិ វោ អនុរុទ្ធា ខមនីយំ កច្ចិ យាបនីយំ

១ ឱ. អាយស្មន្តា ។



ដ៏មានអាយុយ៉ាងនេះថា ម្នាលលោកដ៏មានអាយុទាំងឡាយ ចូរលោកទាំងឡាយនិមន្តទៅទទួល ម្នាលលោកដ៏មានអាយុទាំងឡាយ ចូរលោកទាំងឡាយនិមន្តទៅទទួល ព្រោះព្រះមានព្រះភាគជាគ្រូរបស់យើង ព្រះអង្គទ្រង់យាងមកដល់ហើយ ។ វេលានោះ ព្រះអនុរុទ្ធដ៏មានអាយុ ព្រះនន្ទិយៈដ៏មានអាយុ និងព្រះកិម្ពិលៈដ៏មានអាយុ ក៏ក្រោកទៅទទួលព្រះមានព្រះភាគ មួយអង្គទទួលបាត្រនិងចីវរព្រះមានព្រះភាគ មួយអង្គរៀបចំក្រាលអាសនៈ មួយអង្គដំកល់ទឹកសម្រាប់លាងព្រះបាទ តាំងសម្រាប់ដំកល់ព្រះបាទដែលលាងហើយ និងគ្រឿងសម្រាប់ដំកល់ព្រះបាទដែលមិនទាន់បានលាង ។ ព្រះមានព្រះភាគទ្រង់គង់លើអាសនៈដែលភិក្ខុទាំងនោះក្រាលហើយ លុះគង់ហើយទ្រង់លាងព្រះបាទ ។ ចំណែកលោកដ៏មានអាយុទាំងនោះ ក៏នាំគ្នាក្រាបថ្វាយបង្គំព្រះមានព្រះភាគជាម្ចាស់រួចហើយ អង្គុយនៅក្នុងទីសមគួរ ។ លុះព្រះអនុរុទ្ធដ៏មានអាយុអង្គុយក្នុងទីសមគួរហើយ ព្រះអង្គទ្រង់ត្រាស់សួរយ៉ាងនេះថា ម្នាលអនុរុទ្ធទាំងឡាយ[១] អ្នកទាំងឡាយល្មមអត់ធន់បានឬទេ អ្នកទាំងឡាយល្មមប្រព្រឹត្តទៅបានស្រួលឬទេ

១ ព្រះអង្គទ្រង់ត្រាស់ហៅមិនសំដៅយកព្រះអនុរុទ្ធតែមួយអង្គទេ ទ្រង់ត្រាស់ហៅចំពោះព្រះនាមព្រះថេរៈជាធំនៃព្រះអង្គ ។

កច្ចិ បិណ្ឌកេន ន កិលមថាតិ ។ ខមនីយំ ភគវា យាបនីយំ ភគវា ន ច មយំ ភន្តេ បិណ្ឌកេន កិលមាមាតិ ។ កច្ចិ បន វោ អនុរុទ្ធា សមគ្គា សម្មោទមានា អវិវទមានា ខីរោទកីភូតា អញ្ញមញ្ញំ បិយចក្ខូហិ សម្បស្សន្តា វិហរថាតិ ។ តគ្ឃ[1] មយំ ភន្តេ សមគ្គា សម្មោទមានា អវិវទមានា ខីរោទកីភូតា អញ្ញមញ្ញំ បិយចក្ខូហិ សម្បស្សន្តា វិហរាមាតិ ។ យថាកថំ បន តុម្ហេ អនុរុទ្ធា សមគ្គា សម្មោទមានា អវិវទមានា ខីរោទកីភូតា អញ្ញមញ្ញំ បិយចក្ខូហិ សម្បស្សន្តា វិហរថាតិ ។ ឥធ មយ្ហំ ភន្តេ ឯវំ ហោតិ លាភា វត មេ សុលទ្ធំ វត មេ យោហំ ឯវរូបេហិ សព្រហ្មចារីហិ

១ ម. ពោត្ថកេសុ តគ្ឃោ ទិស្សតិ ។

អ្នកទាំងឡាយមិនលំបាកដោយបិណ្ឌបាតទេឬ ។ ព្រះថេរៈទាំងពួកនោះក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ យើងខ្ញុំល្មមអត់ធនបាន បពិត្រព្រះដ៏មានព្រះភាគ យើងខ្ញុំល្មមប្រព្រឹត្តទៅបានស្រួល សូមទ្រង់ព្រះមេត្តាប្រោស ម្យ៉ាងទៀត យើងខ្ញុំមិនបានលំបាកដោយបិណ្ឌបាតទេ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរទៀតថា ម្នាលអនុរុទ្ធទាំងឡាយ ចុះអ្នកទាំងឡាយបានព្រមព្រៀងស្រុះស្រួលមិនវិវាទគ្នា ដូចជាទឹកដោះលាយទឹក សំឡឹងមើលគ្នានឹងគ្នាទៅវិញទៅមកដោយភ្នែកជាទីស្រឡាញ់ដែរឬ ។ ព្រះអនុរុទ្ធក្រាបបង្គំទូលថា ព្រះករុណា យើងខ្ញុំទាំងនោះព្រមព្រៀងស្រុះស្រួលនឹងគ្នាមិនវិវាទគ្នា ដូចជាទឹកដោះលាយទឹក សំឡឹងមើលគ្នាទៅវិញទៅមកដោយភ្នែកជាទីស្រឡាញ់បាន ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរទៀតថា ម្នាលអនុរុទ្ធទាំងឡាយ អ្នកទាំងឡាយបានជាព្រមព្រៀងស្រុះស្រួលនឹងគ្នាមិនវិវាទគ្នា ដូចជាទឹកដោះលាយទឹក សំឡឹងមើលគ្នាទៅវិញទៅមកដោយភ្នែកជាទីស្រឡាញ់ ដូចម្ដេចទៅ ។ ព្រះអនុរុទ្ធក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស គំនិតនេះខ្ញុំព្រះអង្គមានសេចក្ដីត្រិះរិះថា អាត្មាអញបាននៅជាមួយនឹងពួកបុគ្គលដែលប្រព្រឹត្តធម៌ប្រសើរស្មើគ្នាបែបនេះ ហៅថាជាលាភរបស់អាត្មាអញ អាត្មាអញបានល្អពិត

សទ្ធឹ វិហរាមិ តស្ស មយ្ហំ ភន្តេ ឥមេសុ អាយស្មន្តេ-
សុ មេត្តំ កាយកម្មំ បច្ចុបដ្ឋិតំ អាវិ ចេវ រហោ ច
មេត្តំ វចីកម្មំ មេត្តំ មនោកម្មំ បច្ចុបដ្ឋិតំ អាវិ ចេវ
រហោ ច តស្ស មយ្ហំ ភន្តេ ឯវំ ហោតិ យន្នូនាហំ
សកំ ចិត្តំ និក្ខិបិត្វា ឥមេសំយេវ អាយស្មន្តានំ ចិត្តស្ស
វសេន វត្តេយ្យន្តិ សោ ខោ អហំ ភន្តេ សកំ ចិត្តំ
និក្ខិបិត្វា ឥមេសំយេវ អាយស្មន្តានំ ចិត្តស្ស វសេន
វត្តាមិ នានា ហិ ខោ នោ ភន្តេ កាយា ឯកញ្ច បន
មញ្ញេ ចិត្តន្តិ ។ អាយស្មាបិ ខោ នន្ទិយោ អា-
យស្មាបិ ខោ កិម្ពិលោ ភគវន្តំ ឯតទវោច មយ្ហម្បិ ខោ
ភន្តេ ឯវំ ហោតិ លាភា វត មេ សុលទ្ធំ វត មេ
យោហំ ឯវរូបេហិ សព្រហ្មចារីហិ សទ្ធឹ វិហរាមិ តស្ស
មយ្ហំ ភន្តេ ឥមេសុ អាយស្មន្តេសុ មេត្តំ កាយកម្មំ
បច្ចុបដ្ឋិតំ អាវិ ចេវ រហោ ច មេត្តំ វចីកម្មំ មេត្តំ
មនោកម្មំ បច្ចុបដ្ឋិតំ អាវិ ចេវ រហោ ច តស្ស



បានស្រួលពេកហើយ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គតែងដំកល់
កាយកម្មប្រកបដោយមេត្តាចំពោះលោកដ៏មានអាយុអម្បាលនេះ ទាំង
ចំពោះមុខទាំងទីកំបាំង ខ្ញុំព្រះអង្គ តែងដំកល់វចីកម្មនិងមនោកម្មប្រកប
ដោយមេត្តា ទាំងចំពោះមុខទាំងទីកំបាំង សូមទ្រង់ព្រះមេត្តាប្រោស
ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរអាត្មាអញដាក់ចិត្ត
របស់ខ្លួនចេញ ហើយប្រព្រឹត្តតាមអំណាចចិត្តលោកដ៏មានអាយុទាំងនេះ
វិញ សូមទ្រង់ព្រះមេត្តាប្រោស (លុះគិតដូច្នេះហើយ) ខ្ញុំព្រះអង្គក៏បាន
ដាក់ចិត្តរបស់ខ្លួនចេញ ហើយប្រព្រឹត្តតាមអំណាចចិត្តលោកដ៏មានអាយុ
ទាំងនេះទៅ សូមទ្រង់ព្រះមេត្តាប្រោស ឯកាយរបស់យើងខ្ញុំផ្សេងគ្នាពិ
តមែន ប៉ុន្តែចិត្តដូចគ្នាតែមួយពិត ។ ឯព្រះនន្ទិយៈដ៏មានអាយុ និងព្រះ
កិម្ពិលៈដ៏មានអាយុក៏បានក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ
ទៀតថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះយ៉ាងនេះ
ថា អាត្មាអញនៅជាមួយនឹងពួកបុគ្គលដែលប្រព្រឹត្តធម៌ប្រសើរស្មើគ្នា
បែបនេះ ហៅពេញជាលាភរបស់អាត្មាអញ អាត្មាអញហៅពេញជាបាន
ស្រួលពេកហើយ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គតែងដំកល់កាយ-
កម្មប្រកបដោយមេត្តាចំពោះលោកដ៏មានអាយុអម្បាលនេះ ទាំងចំពោះ
មុខទាំងទីកំបាំង ខ្ញុំព្រះអង្គតែងដំកល់វចីកម្មនិងមនោកម្មប្រកបដោយមេត្តា

មយ្ហំ ភន្តេ ឯវំ ហោតិ យន្នូនាហំ សកំ ចិត្តំ និក្ខិបិត្វា ឥមេសំយេវ អាយស្មន្តានំ ចិត្តស្ស វសេន វត្តេយ្យន្តិ ។ សោ ខោ អហំ ភន្តេ សកំ ចិត្តំ និក្ខិបិត្វា ឥមេសំ-យេវ អាយស្មន្តានំ ចិត្តស្ស វសេន វត្តាមិ នានា ហិ ខោ នោ ភន្តេ កាយា ឯកញ្ច បន មញ្ញេ ចិត្តន្តិ ។ ឯវំ ខោ មយំ ភន្តេ សមគ្គា សម្មោទមានា អវិវទមានា ខីរោទកីភូតា អញ្ញមញ្ញំ បិយចក្ខូហិ សម្បស្សន្តា វិហរាមាតិ ។ កច្ចិ បន វោ អនុរុទ្ធា អប្បមត្តា អាតាបិនោ បហិតត្តា វិហរថាតិ ។ តគ្ឃ មយំ ភន្តេ អប្បមត្តា អាតាបិនោ បហិតត្តា វិហរាមាតិ ។ យថា-កថំ បន តុម្ហេ អនុរុទ្ធា អប្បមត្តា អាតាបិនោ បហិ-តត្តា វិហរថាតិ ។ ឥធ ភន្តេ អម្ហាកំ យោ បឋមំ



ទាំងទីចំពោះមុខនិងទីកំបាំង សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញដាក់ចិត្តរបស់ខ្លួនចេញ ហើយប្រព្រឹត្តតាមអំណាចចិត្តលោកដ៏មានអាយុទាំងនេះវិញចុះ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គនោះបានដាក់ចិត្តរបស់ខ្លួនចេញ ហើយប្រព្រឹត្តតាមអំណាចចិត្តលោកដ៏មានអាយុទាំងនេះវិញ សូមទ្រង់ព្រះមេត្តាប្រោស ឯកាយរបស់យើងខ្ញុំផ្សេងគ្នាពិតមែន ប៉ុន្តែចិត្តដូចគ្នាតែមួយ សូមទ្រង់ព្រះមេត្តាប្រោស ដោយហេតុយ៉ាងនេះហើយ បានជាយើងខ្ញុំព្រមព្រៀងស្រុះស្រួល មិនវិវាទគ្នា ដូចជាទឹកដោះលាយទឹក សំឡឹងមើលគ្នានឹងគ្នាទៅមកដោយចក្ខុជាទីស្រឡាញ់បាន ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរថា ម្នាលអនុរុទ្ធទាំងឡាយ អ្នកទាំងឡាយមិនបានប្រហែសធ្វេស មានព្យាយាមដុតកិលេស មានចិត្តបញ្ជូនទៅព្រះនិព្វានឬ ។ ព្រះអនុរុទ្ធក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស យើងខ្ញុំមិនបានប្រហែសធ្វេសទេ ហើយមានព្យាយាមដុតកិលេសនិងមានចិត្តបញ្ជូនទៅព្រះនិព្វាន ។ ព្រះមានព្រះភាគទ្រង់ត្រាស់សួរថា ម្នាលអនុរុទ្ធទាំងឡាយ អ្នកទាំងឡាយដែលឥតមានប្រហែសធ្វេស មានតែព្យាយាមដុតកិលេស មានចិត្តបញ្ជូនទៅព្រះនិព្វាន តើយ៉ាងដូចម្តេច ។ ព្រះអនុរុទ្ធក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស បណ្តាយើងខ្ញុំដែលនៅក្នុងទីនេះ អង្គណា

គាមតោ បិណ្ឌាយ បដិក្កមតិ សោ អាសនំ បញ្ញាបេតិ
បាទោទកំ បាទបីឋំ បាទកឋលិកំ ឧបនិក្ខិបតិ
អវក្ការបាតឹ ធោវិត្វា ឧបដ្ឋាបេតិ បានីយំ បរិភោជនីយំ
ឧបដ្ឋាបេតិ យោ បច្ឆា គាមតោ បិណ្ឌាយ បដិក្កមតិ
សចេ ហោតិ ភុត្តាវសេសោ សចេ អាកង្ខតិ ភុញ្ជតិ
នោ ចេ អាកង្ខតិ អប្បហរិតេ វា ឆឌ្ឌេតិ អប្បាណកេ
វា ឧទកេ ឱបិលាបេតិ សោ អាសនំ ឧទ្ធរតិ
បាទោទកំ បាទបីឋំ បាទកឋលិកំ បដិសាមេតិ
អវក្ការបាតឹ ធោវិត្វា បដិសាមេតិ បានីយំ បរិភោ-
ជនីយំ បដិសាមេតិ ភត្តគ្គំ សម្មជ្ជតិ យោ បស្សតិ
បានីយឃដំ វា បរិភោជនីយឃដំ វា វច្ចឃដំ វា រិត្តំ
តុច្ឆំ សោ ឧបដ្ឋាបេតិ សចស្ស ហោតិ អវិសយ្ហំ
ហត្ថវិការេន ទុតិយំ អាមន្តេត្វា ហត្ថវិលង្ឃកេន
ឧបដ្ឋាបេម ន ត្វេវ មយំ ភន្តេ តប្បច្ចយា វាចំ ភិន្ទាម



ត្រឡប់មកពីបិណ្ឌបាតអំពីស្រុកមុនគេ លោកនោះរៀបចំក្រាលអាសនៈ ដាក់លាំទឹកសម្រាប់លាងជើង ដាក់តាំងសម្រាប់ទ្រជើង ដែលលាងរួច គីឥដ្ឋដាក់លាំក្បឿងសម្រាប់ទ្រជើងដែលមិនទាន់លាង ហើយលាងភាជន៍សម្រាប់ផ្ទុកបាយដាក់តម្កល់ទុកឲ្យស្រួល រួចដាក់លាំទឹកឆាន់និងទឹកប្រើប្រាស់ លោកណាមកពីបិណ្ឌបាតអំពីស្រុកក្រោយគេ បើមានរបស់ដែលសល់ពីឆាន់ បើគិតនោះបើចង់ឆាន់ក៏ឆាន់ទៅ បើមិនចង់ឆាន់ទេ ចាក់ចោលទៅក្នុងទីគ្មានស្មៅស្រស់ក៏បាន ឬចាក់ចោលទៅក្នុងទឹកដែលគ្មានសត្វល្អិតក៏បាន រួចលោកនោះរើអាសនៈចេញ ហើយរៀបចំទុកដាក់ទឹកសម្រាប់លាងជើង តាំងសម្រាប់ទ្រជើងដែលលាងរួចហើយ ឥដ្ឋក្បឿងសម្រាប់ទ្រជើងដែលមិនទាន់លាង ហើយលាងភាជន៍សម្រាប់ផ្ទុកបាយរៀបចំទុកដាក់ រួចរៀបទុកដាក់ទឹកឆាន់និងទឹកប្រើប្រាស់ ហើយបោសរោងភត្ត បើលោកណាឃើញក្អមសម្រាប់ដាក់ទឹកឆាន់ក្តី ក្អមសម្រាប់ដាក់ទឹកប្រើប្រាស់ក្តី ក្អមសម្រាប់ដាក់ទឹកលាងវច្ចៈក្តី ទទេសោះខ្វះ លោកនោះក៏ដាក់តម្កល់ទុកឲ្យមានឡើង បើលោកនោះមិនអាចលើកដោយកំឡាំងដៃបានទេ ក៏ហៅភិក្ខុទី២ (ឯទៀត) មកជាគ្នាជួយលើកឬសន្មតដោយវៃដៃហៅគេទៅដាក់តម្កល់ទុក សូមទ្រង់ព្រះមេត្តាប្រោស យើងខ្ញុំមិនបាច់បញ្ចេញវាចាព្រោះហេតុតែប៉ុណ្ណោះឡើយ សូមទ្រង់ព្រះមេត្តាប្រោស

បញ្ចាហិកំ ខោ បន មយំ ភន្តេ សព្វរត្តិយា ធម្មិយា កថាយ សន្និសីទាម ឯវំ ខោ មយំ ភន្តេ អប្បមត្តា អាតាបិនោ បហិតត្តា វិហរាមាតិ ។ អថខោ ភគវា អាយស្មន្តញ្ច អនុរុទ្ធំ អាយស្មន្តញ្ច នន្ទិយំ អាយស្មន្តញ្ច កិម្ពិលំ ធម្មិយា កថាយ សន្ទស្សេត្វា សមាទបេត្វា សមុត្តេជេត្វា សម្បហំសេត្វា ឧដ្ឋាយាសនា យេន បាលិលេយ្យកំ តេន ចារិកំ បក្កាមិ អនុបុព្វេន ចារិកំ ចរមានោ យេន បាលិលេយ្យកំ តទវសរិ ។ តត្រ សុទំ ភគវា បាលិលេយ្យកេ វិហរតិ រក្ខិតវនសណ្ឌេ ភទ្ទសាលមូលេ ។

[២៩៩] អថខោ ភគវតោ រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ អហំ ខោ បុព្វេ អាកិណ្ណោ ន ផាសុ វិហាសឹ តេហិ កោសម្ពកេហិ ភិក្ខូហិ ភណ្ឌនការកេហិ កលហការកេហិ វិវាទការកេហិ ភស្សការកេហិ សង្ឃេ អធិករណការកេហិ សោម្ហិ



ម្យ៉ាងទៀត តែគ្រប់៥ថ្ងៃហើយ យើងខ្ញុំគង់អង្គុយប្រជុំគ្នាដោយធម្មីកថា អស់ពេញមួយយប់[១] សូមទ្រង់ព្រះមេត្តាទ្រាប ដោយហេតុយ៉ាងនេះហើយ បានជាយើងខ្ញុំព្រះអង្គមិនមានសេចក្តីប្រមាទ មានព្យាយាមដុតកិលេស មានចិត្តបញ្ជូនទៅក្រៅ កិច្ចខាងខាំងការ (ដល់កាយមិនដឹកស្បើយ) ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ពន្យល់ព្រះអនុរុទ្ធដ៏មានអាយុផង ព្រះនន្ទិយៈដ៏មានអាយុផង ព្រះកិម្ពិលៈដ៏មានអាយុផង ឲ្យយល់ប្រយោជន៍ក្នុងបច្ចុប្បន្ននិងបរលោក ឲ្យប្រតិបត្តិតាម ឲ្យទ្រាំទ្រនឹងការកុសល ឲ្យរីករាយ ដោយធម្មីកថា រួចទ្រង់ក្រោកចាកអាសនៈហើយ យាងទៅកាន់ចារិកប្រទេសបាលិលេយ្យកៈ កាលទ្រង់យាងទៅកាន់ចារិកដោយលំដាប់ក៏បានដល់ទៅប្រទេសបាលិលេយ្យកៈ ។ ឮថា ព្រះមានព្រះភាគទ្រង់គង់នៅក្រោមម្លប់ភទ្ទសាលព្រឹក្ស ក្នុងដងព្រៃឈ្មោះរក្ខិតឆាប្រទេសបាលិលេយ្យកៈនោះ ។

[២៩៩] សម័យនោះ កាលព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងទីស្ងាត់ សម្ងំនៅក្នុងព្រះគន្ធកុដិ ទ្រង់កើតមានព្រះហឫទ័យត្រិះរិះយ៉ាងនេះថា កាលពីមុនតថាគតនៅច្រឡូកច្រឡំដោយពួកភិក្ខុទាំងនោះដែលនៅក្នុងក្រុងកោសម្ពីជាអ្នកធ្វើសេចក្តីបង្កហេតុ ធ្វើសេចក្តីឈ្លោះ ធ្វើសេចក្តីវិវាទ ធ្វើការជជែកគ្នា ធ្វើអធិករណ៍ក្នុងសង្ឃ មិនបានសេចក្តីសប្បាយ

---

១ គ្រប់ថ្ងៃទី៥ ប្រជុំគ្នាម្តងរហូតអស់ទាំងយប់ ។

ឯកកោ ឯកោ អទុតិយោ សុខំ ផាសុ វិហរាមិ អញ្ញត្រ តេហិ កោសម្ពកេហិ ភិក្ខូហិ ភណ្ឌនការកេហិ កលហការកេហិ វិវាទការកេហិ ភស្សការកេហិ សង្ឃេ អធិករណការកេហីតិ ។ អញ្ញតរោបិ ខោ ហត្ថិនាគោ អាកិណ្ណោ វិហរតិ ហត្ថីហិ ហត្ថិនីហិ ហត្ថិកលភេហិ(១) ហត្ថិច្ឆាបេហិ(២) ឆិន្នគ្គានិ ចេវ តិណានិ ខាទតិ ឱភគ្គោភគ្គញ្ចស្ស សាខាភង្គំ ខាទន្តិ អាវិលានិ ច បានីយានិ បិវតិ ឱគាហា(៣) ចស្ស ឧត្តិណ្ណស្ស ហត្ថិនិយោ កាយំ ឧបនិឃំសន្តិយោ គច្ឆន្តិ ។ អថខោ តស្ស ហត្ថិនាគស្ស ឯតទហោសិ អហំ ខោ អាកិណ្ណោ វិហរាមិ ហត្ថីហិ ហត្ថិនីហិ ហត្ថិកលភេហិ ហត្ថិច្ឆាបេហិ ឆិន្នគ្គានិ ចេវ តិណានិ ខាទាមិ ឱភគ្គោភគ្គញ្ច មេ សាខាភង្គំ ខាទន្តិ អាវិលានិ ច បានីយានិ បិវាមិ

១ ហត្ថិកុលភេហិ ។ ២ ហត្ថិច្ឆាបេហិ ។ ៣ ឱគាហស្ស ។



គង់ភាពនេះ ឥឡូវនេះ ម្នាក់ឯងគ្មានទីពីរ ជាសុខស្រួល ហើយបាននៅជាសប្បាយ (ព្រោះវៀរចេញពីពួកភិក្ខុទាំងនោះដែលនៅក្នុងក្រុងកោសម្ពីជាអ្នកធ្វើសេចក្ដីបាក់បែក ធ្វើសេចក្ដីឈ្លោះ ធ្វើសេចក្ដីវិវាទគ្នា ធ្វើពាក្យនិ-ន្ទា ធ្វើអធិករណ៍ក្នុងសង្ឃ ។ មានដំរីប្រសើរ ១ នៅព្រៃឬក្សព្រៃនឹងពួកដំរីឈ្មោល ពួកដំរីញី ពួកដំរីស្ទាវ និងពួកកូនដំរីតូច ៗ ហើយស៊ីស្មៅដែលពួកដំរី (មានដំរីឈ្មោលជាដើមនោះ) បោចផ្ដាច់ចុងចេញ ចំណែកពួកដំរីទាំងនោះក៏ស៊ីមែកឈើបាក់ៗ ដែលដំរីប្រសើរនោះកាច់បំបាក់ទុកវិញ ឯដំរីប្រសើរក៏ផឹកតែទឹកល្អក់ កាលបើដំរីប្រសើរដើរចុះទៅផឹកទឹក អស់ពួកមេដំរីក៏ដើរត្រដុសកាយ ។ ឯដំរីប្រសើរនោះក៏មានសេចក្ដីត្រិះរិះយ៉ាងនេះថា អាត្មាអញនៅច្រឡូកច្រឡំដោយពួកដំរីឈ្មោល ពួកដំរីញី ពួកដំរីស្ទាវ និងពួកកូនដំរីតូច ៗ ហើយស៊ីស្មៅដែលដំរីទាំងនោះបោចផ្ដាច់ចុងចេញ ចំណែកពួកដំរីទាំងនោះក៏ស៊ីមែកឈើបាក់ ៗ ដែលអាត្មាអញកាច់បំបាក់ទុកវិញ អាត្មាអញផឹកទឹកល្អក់

ឱគាហញ្ច[១] មេ ឧត្តិណ្ណស្ស ហត្ថិនិយោ កាយំ ឧបនិ-
ឃំសន្តិយោ គច្ឆន្តិ យន្នូនាហំ ឯកោវ គណម្ហា
វូបកដ្ឋោ វិហរេយ្យន្តិ ។ អថខោ សោ ហត្ថិនាគោ
យូថា អបក្កម្ម យេន បាលិលេយ្យកំ រក្ខិតវនសណ្ឌោ
ភទ្ទសាលមូលំ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា
សោណ្ឌាយ ភគវតោ បានីយំ បរិភោជនីយំ ឧបដ្ឋាបេតិ
អប្បហរិតញ្ច ករោតិ ។ អថខោ តស្ស ហត្ថិនាគស្ស
ឯតទហោសិ អហំ ខោ បុព្វេ អាកិណ្ណោ ន ផាសុ
វិហាសឹ ហត្ថីហិ ហត្ថិនីហិ ហត្ថិកលភេហិ ហត្ថិច្ឆាបេហិ
ឆិន្នគ្គានិ ចេវ តិណានិ ខាទឹ ឱភគ្គោភគ្គញ្ច មេ សា-
ខាភង្គំ ខាទឹសុ អាវិលានិ ច បានីយានិ អបាយឹ ឱគាហញ្ច
មេ ឧត្តិណ្ណស្ស ហត្ថិនិយោ កាយំ ឧបនិឃំសន្តិយោ
អគមំសុ សោម្ហិ ឯតរហិ ឯកោ អទុតិយោ សុខំ ផាសុ
វិហរាមិ អញ្ញត្រ ហត្ថីហិ ហត្ថិនីហិ ហត្ថិកលភេហិ

១ ម. ឱគាហត្ថស្ស ។



កាលបើអាត្មាអញចុះទៅក្នុងកំពង់ទឹក អស់ពួកមេដំរីក៏ដើរត្រដុសកាយ
បើដូច្នោះគួរតែអាត្មាអញចៀសចេញចាកហ្វូងទៅនៅម្នាក់ឯងវិញចុះ ។ គ្រានោះ
ដំរីប្រសើរនោះ ចៀសចេញចាកហ្វូង ចូលទៅកាន់សំណាក់ព្រះដ៏មានព្រះ
ភាគដែលគង់នៅក្រោមម្លប់ភទ្ទសាលព្រឹក្សក្នុងដងព្រៃឈ្មោះរក្ខិត ជាបា-
លិលេយ្យកប្រទេស លុះចូលទៅដល់ហើយ ក៏ដងយកទឹកឆាន់ទឹកប្រើ-
ប្រាស់ដោយប្រមោយ ដំកល់ព្រះដ៏មានព្រះភាគ ហើយធ្វើទីកន្លែងនោះ
មិនឲ្យមានស្មៅស្រស់ទទឹ ។ លំដាប់តពីនោះមក ដំរីប្រសើរនោះក៏មាន
សេចក្តីត្រិះរិះយ៉ាងនេះថា កាលពីដើមអាត្មាអញនៅច្រឡូកច្រឡំនឹងពួក
ដំរីឈ្មោល ពួកមេដំរី ពួកដំរីស្ទាវ និងពួកកូនដំរីតូច ៗ ហើយអាត្មាអញ
បានស៊ីស្មៅដែលពួកដំរីកាត់ចុងខាងចុងចេញ ចំណែកខាងពួកដំរី
ទាំងនោះក៏បានស៊ីមែកឈើធ្លាក់ ៗ ដែលអាត្មាអញកាច់បាក់ខ្ទេចខ្ទីវិញ
មិនតែប៉ុណ្ណោះសោត អាត្មាអញបានផឹកនូវទឹកល្អក់ កាលបើអាត្មាអញ
ដើរចុះទៅក្នុងកំពង់ទឹក ពួកមេដំរីក៏ដើរត្រដុសកាយ ឥឡូវនេះអាត្មា
អញតែម្នាក់ឯងឥតមានគ្នាជាគំរប់ពីរ ទើបបាននៅជាសុខស្រួល-
បួល (ព្រោះបានចៀសចាកពួកដំរីឈ្មោល ពួកដំរីញី ពួកដំរីស្ទាវ

ហត្ថិច្ឆាបេហីតិ ។ អថខោ ភគវា អត្តនោ ច បវិវេកំ វិទិត្វា តស្ស ច ហត្ថិនាគស្ស ចេតសា ចេតោបរិ-វិតក្កមញ្ញាយ តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

ឯតំ នាគស្ស នាគេន
ឦសាទន្តស្ស ហត្ថិនោ
សមេតិ ចិត្តំ ចិត្តេន
យទេកោ រមតិ វនេ ។

[១៤៦] អថខោ ភគវា បាលិលេយ្យកេ យថាភិរន្តំ វិហរិត្វា យេន សាវត្ថិ តេន ចារិកំ បក្កាមិ អនុបុព្វេន ចា-រិកំ ចរមានោ យេន សាវត្ថិ តទវសរិ ។ តត្រ សុទំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។

[១៤៧] អថខោ កោសម្ពិកានំ(១) ឧបាសកានំ ឯតទហោសិ ឥមេ ខោ អយ្យា កោសម្ពិកា ភិក្ខូ ពហុនោ អម្ហាកំ អនត្ថស្ស ការកា ឥមេហិ ឧព្ពាឡ្ហោ ភគវា បក្កន្តោ ហន្ទ មយំ អយ្យេ កោសម្ពិកេ ភិក្ខូ នេវ អភិវាទេយ្យាម ន បច្ចុដ្ឋេយ្យាម ន អញ្ជលិកម្មំ

១ ឱ. ម. កោសម្ពកា ឧបាសកា ឥតិ ហោតិ ទិស្សតិ ។



ទាំងពួកកូនដំរីតូចៗ ។ វេលានោះ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបនូវសេចក្តីវិវេករបស់ព្រះអង្គផង ហើយទ្រង់ជ្រាបនូវសេចក្តីត្រិះរិះនៃចិត្តរបស់ដំរីប្រសើរនោះដោយព្រះហឫទ័យរបស់ព្រះអង្គផង ហើយក៏ទ្រង់បន្លឺព្រះឧទាននេះក្នុងវេលានោះ ថា

ហត្ថិនាគ (ដំរីប្រសើរ) រីករាយក្នុងព្រៃ តែម្នាក់
ឯង ដោយហេតុណា ហេតុនុ៎ះ ចិត្តរបស់ហត្ថិនាគមានភ្លុក
ដូចនង្គ័លនេះ ស្មើគ្នានឹងចិត្តរបស់ព្រះពុទ្ធនាគផង(១) ។

[១៤៦] គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងបាលិលេយ្យ-កប្រទេស គួរដល់ព្រះអធ្យាស្រ័យហើយ ទ្រង់យាងទៅកាន់ចារិកនៃក្រុងសាវត្ថី កាលទ្រង់យាងទៅកាន់ចារិកដោយលំដាប់ ក៏បានដល់នៅក្រុងសាវត្ថីនោះ ។ បានឮមកថា ព្រះដ៏មានព្រះភាគទ្រង់គង់នៅវត្តជេត-ពនរបស់អនាថបិណ្ឌិកសេដ្ឋីទៀបក្រុងសាវត្ថីនោះ ។

[១៤៧] វេលានោះ ពួកឧបាសកដែលនៅក្នុងក្រុងកោសម្ពីមានសេចក្តីត្រិះរិះយ៉ាងនេះថា ពួកលោកជាម្ចាស់ភិក្ខុនេះ ជាភិក្ខុនៅក្នុងក្រុងកោសម្ពីបានធ្វើអំពើឥតប្រយោជន៍ជាច្រើនដល់យើង ព្រះដ៏មានព្រះភាគសោត ក៏ត្រូវភិក្ខុទាំងនេះបៀតបៀនទាល់តែទ្រង់យាងចេញបាត់ទៅ បើដូច្នោះ យើងមិនត្រូវសំពះ មិនត្រូវក្រោកទទួល មិនត្រូវធ្វើអញ្ជលីកម្ម

១ ពាក្យថា ពុទ្ធនាគ គឺព្រះពុទ្ធជាម្ចាស់ ។

សាមីចិកម្មំ ករេយ្យាម ន សក្ករេយ្យាម ន គរុករេយ្យា-
ម ន មានេយ្យាម ន បូជេយ្យាម ឧបគតានំបិ បិណ្ឌបាតំ[1]
ន ទទេយ្យាម ឯវំ ឥមេ អម្ហេហិ អសក្ករិយមានា អ-
គរុករិយមានា អមានិយមានា អបូជិយមានា អសក្ការ-
បកតា បក្កមិស្សន្តិ វា វិព្ភមិស្សន្តិ វា ភគវន្តំ វា បសា-
ទេស្សន្តីតិ ។ អថខោ កោសម្ពកា ឧបាសកា កោសម្ព-
កេ ភិក្ខូ នេវ អភិវាទេសុំ ន បច្ចុដ្ឋេសុំ ន អញ្ជលិកម្មំ
សាមីចិកម្មំ អកំសុ ន សក្ករិំសុ ន គរុករិំសុ ន មានេសុំ
ន បូជេសុំ ឧបគតានំបិ បិណ្ឌបាតំ ន អទំសុ ។ អថខោ
កោសម្ពកា ភិក្ខូ កោសម្ពកេហិ ឧបាសកេហិ អ-
សក្ករិយមានា អគរុករិយមានា អមានិយមានា អបូ-
ជិយមានា អសក្ការបកតា ឯវមាហំសុ ហន្ទ មយំ
អាវុសោ សាវត្ថឹ គន្ត្វា ភគវតោ សន្តិកេ ឥមំ អធិករណំ
វូបសមេយ្យាមាតិ ។ អថខោ កោសម្ពកា ភិក្ខូ សេ-
នាសនំ សំសាមេត្វា បត្តចីវរមាទាយ យេន សាវត្ថី
តេនុបសង្កមឹសុ ។

---

១ ឱ. បិណ្ឌបាតំ ។



មិនត្រូវធ្វើសាមីចិកម្ម មិនត្រូវធ្វើសក្ការៈ មិនត្រូវធ្វើសេចក្តីគោរព មិនត្រូវ
កប់កាន មិនត្រូវបូជា ពួកលោកម្ចាស់ជាភិក្ខុនៅក្នុងក្រុងកោសម្ពីទេ ទុក
ជាភិក្ខុទាំងនោះចូលមកដល់ យើងក៏មិនត្រូវឲ្យបិណ្ឌបាតឡើយ ភិក្ខុទាំង
នេះតែពួកយើង ដែលមិនធ្វើសក្ការៈ ដែលមិនធ្វើសេចក្តីគោរព ដែលមិនកប់កាន
ដែលមិនបូជា យ៉ាងនេះហើយ គង់នៅជាអ្នកគ្មានគ្រឿងសក្ការៈហើយមុខជា
នឹងត្រាច់ចេញទៅខ្លះ សឹកចេញទៅខ្លះ ញុំាងព្រះមានព្រះភាគឲ្យជ្រះ
ថ្លាណាខ្លះមិនខាន ។ គ្រានោះ ពួកឧបាសកក្រុងកោសម្ពីដែលមិន
សំពះ ដែលមិនក្រោកទទួល ដែលមិនធ្វើអញ្ជលិកម្ម និងសាមីចិកម្ម ដែលមិន
ធ្វើសក្ការៈ គោរព កប់កាន បូជាពួកភិក្ខុក្រុងកោសម្ពី ទុកជាភិក្ខុ
ទាំងនោះចូលទៅបិណ្ឌបាត ក៏មិនឲ្យបិណ្ឌបាត ។ គ្រានោះ
ពួកភិក្ខុក្រុងកោសម្ពី កាលបើពួកឧបាសកក្រុងកោសម្ពីមិនធ្វើសក្ការៈ
គោរព កប់កាន បូជា គង់នៅជាអ្នកគ្មានគ្រឿងសក្ការៈ ហើយក៏
និយាយនឹងគ្នាយ៉ាងនេះថា នែអាវុសោ បើដូច្នោះមានតែយើង ទៅ
ក្រុងសាវត្ថីរម្ងាប់អធិករណ៍នេះ ក្នុងសំណាក់ព្រះមានព្រះភាគចេញ ។
លំដាប់នោះ ពួកភិក្ខុក្រុងកោសម្ពីក៏រៀបចំទុកដាក់គ្រឿងសេនាសនៈរួច
នាំយកបាត្រនិងចីវរចូលទៅក្រុងសាវត្ថី ។

(១៥៨) អស្សោសិ ខោ អាយស្មា សារីបុត្តោ តេ កិរ កោសម្ពកា ភិក្ខូ ភណ្ឌនការកា កលហការកា វិវាទការកា ភស្សការកា សង្ឃេ អធិករណការកា សាវត្ថឹ អាគច្ឆន្តីតិ ។ អថ ខោ អាយស្មា សារីបុត្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា សារីបុត្តោ ភគវន្តំ ឯតទវោច តេ កិរ ភន្តេ កោសម្ពកា ភិក្ខូ ភណ្ឌនការកា កលហការកា វិវាទការកា ភស្សការកា សង្ឃេ អធិករណការកា សាវត្ថឹ អាគច្ឆន្តិ កថាហំ ភន្តេ តេសុ ភិក្ខូសុ បដិបជ្ជាមីតិ ។ តេនហិ ត្វំ សារីបុត្ត យថា ធម្មោ តថា តិដ្ឋាហីតិ ។ កថាហំ ភន្តេ ជានេយ្យំ ធម្មំ វា អធម្មំ វាតិ ។ អដ្ឋារសហិ ខោ សារីបុត្ត វត្ថូហិ អធម្មវាទី ជានិតព្វោ ។ ឥធ សារីបុត្ត ភិក្ខុ អធម្មំ ធម្មោតិ ទីបេតិ ធម្មំ អធម្មោតិ ទីបេតិ អវិនយំ វិនយោតិ ទីបេតិ វិនយំ អវិនយោតិ



(១៥៨) ព្រះសារីបុត្តដ៏មានអាយុបានឮដំណឹងថា ពួកភិក្ខុក្រុងកោសម្ពីនោះជាអ្នកធ្វើការបង្កហេតុ ឈ្លោះ ទាស់ទែងគ្នា ធ្វើវាទកថា ធ្វើអធិករណ៍ក្នុងសង្ឃ បានមកដល់ក្រុងសាវត្ថី ។ ទើបព្រះសារីបុត្តដ៏មានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយនៅក្នុងទីសមគួរ ។ លុះព្រះសារីបុត្តដ៏មានអាយុអង្គុយនៅក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ឮថាពួកភិក្ខុក្រុងកោសម្ពីនោះជាអ្នកធ្វើសេចក្តីបង្កហេតុ ឈ្លោះ ទាស់ទែងគ្នា ធ្វើវាទកថា ធ្វើអធិករណ៍ក្នុងសង្ឃ បានមកដល់ក្រុងសាវត្ថី សូមទ្រង់ព្រះមេត្តាប្រោស តើខ្ញុំព្រះអង្គនឹងប្រតិបត្តិក្នុងពួកភិក្ខុទាំងនោះដូចម្តេចខ្លះ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា នែសារីបុត្ត បើដូច្នោះ អ្នកចូរតាំងនៅឲ្យសមគួរតាមធម៌ចុះ ។ ព្រះសារីបុត្តក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ធ្វើដូចម្តេចខ្ញុំព្រះអង្គអាចស្គាល់ថាជាធម៌ឬមិនមែនជាធម៌បាន ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា នែសារីបុត្ត អ្នកត្រូវស្គាល់អធម្មវាទីបុគ្គល (បុគ្គលពោលខុសធម៌) ដោយវត្ថុ ១៨ យ៉ាង ។ នែសារីបុត្ត ក្នុងសាសនានេះ ភិក្ខុសំដែងសភាវៈដែលមិនមែនជាធម៌ថាជាធម៌វិញ សំដែងធម៌ថា មិនមែនជាធម៌វិញ សំដែងសភាវៈមិនមែនវិន័យថាជាវិន័យវិញ សំដែងវិន័យថាមិនមែនវិន័យ

ទីបេតិ អភាសិតំ អលបិតំ តថាគតេន ភាសិតំ លបិតំ តថាគតេនាតិ ទីបេតិ ភាសិតំ លបិតំ តថាគតេន អភាសិតំ អលបិតំ តថាគតេនាតិ ទីបេតិ អនាចិណ្ណំ តថាគតេន អាចិណ្ណំ តថាគតេនាតិ ទីបេតិ អាចិណ្ណំ តថាគតេន អនាចិណ្ណំ តថាគតេនាតិ ទីបេតិ អប្បញ្ញត្តំ តថាគតេន បញ្ញត្តំ តថាគតេនាតិ ទីបេតិ បញ្ញត្តំ តថាគតេន អប្បញ្ញត្តំ តថាគតេនាតិ ទីបេតិ អនាបត្តិំ អាបត្តីតិ ទីបេតិ អាបត្តិំ អនាបត្តីតិ ទីបេតិ លហុកំ អាបត្តិំ គរុកា អាបត្តីតិ ទីបេតិ គរុកំ អាបត្តិំ លហុកា អាបត្តីតិ ទីបេតិ សាវសេសំ អាបត្តិំ អនវសេសា អាបត្តីតិ ទីបេតិ អនវសេសំ អាបត្តិំ សាវសេសា អាបត្តីតិ ទីបេតិ ទុដ្ឋុល្លំ អាបត្តិំ អទុដ្ឋុល្លា អាបត្តីតិ ទីបេតិ អទុដ្ឋុល្លំ អាបត្តិំ ទុដ្ឋុល្លា អាបត្តីតិ ទីបេតិ ឥមេហិ ខោ សារីបុត្ត អដ្ឋារសហិ វត្ថូហិ អធម្មវាទី ជានិតព្វោ អដ្ឋារសហិ ខោ សារីបុត្ត វត្ថូហិ ធម្មវាទី ជានិតព្វោ ឥធ សារីបុត្ត ភិក្ខុ អធម្មំ អធម្មោតិ ទីបេតិ ធម្មំ ធម្មោតិ ទីបេតិ អវិនយំ អវិនយោតិ ទីបេតិ វិនយំ



វិញ សំដែងនូវពាក្យដែលតថាគតមិនបានពោលមិនបានចរចាថា តថាគតបានពោលបានចរចាវិញ សំដែងនូវពាក្យដែលតថាគតបានពោលបានចរចាថា តថាគតមិនបានពោលមិនបានចរចាវិញ សំដែងនូវកិច្ចដែលតថាគតមិនបានសន្សំថាតថាគតបានសន្សំវិញ សំដែងនូវកិច្ចដែលតថាគតបានសន្សំថាតថាគតមិនបានសន្សំវិញ សំដែងនូវសិក្ខាបទដែលតថាគតមិនបានបញ្ញត្តថាតថាគតបានបញ្ញត្តវិញ សំដែងនូវសិក្ខាបទដែលតថាគតបានបញ្ញត្តថាតថាគតមិនបានបញ្ញត្តវិញ សំដែងនូវអនាបត្តិថាជាអាបត្តិវិញ សំដែងនូវអាបត្តិថាជាអនាបត្តិវិញ សំដែងនូវអាបត្តិស្រាលថាជាអាបត្តិធ្ងន់វិញ សំដែងនូវអាបត្តិធ្ងន់ថាជាអាបត្តិស្រាលវិញ សំដែងនូវអាបត្តិដែលជាសាវសេស[១] ថាអាបត្តិជាអនវសេស[២]វិញ សំដែងនូវអាបត្តិដែលជាអនវសេសថាអាបត្តិជាសាវសេសវិញ សំដែងនូវទុដ្ឋុល្លាបត្តិថាជាអទុដ្ឋុល្លាបត្តិវិញ សំដែងនូវអទុដ្ឋុល្លាបត្តិថាជាទុដ្ឋុល្លាបត្តិវិញ ម្នាលសារីបុត្ត អ្នកត្រូវស្គាល់អធម្មវាទីបុគ្គលដោយវត្ថុ ១៨ យ៉ាងនេះឯង ម្នាលសារីបុត្ត ចំណែកធម្មវាទីបុគ្គល អ្នកត្រូវស្គាល់ដោយវត្ថុ ១៨ យ៉ាងដែរ ម្នាលសារីបុត្ត ភិក្ខុក្នុងសាសនានេះ សំដែងនូវសភាវៈមិនមែនធម៌ ថា មិនមែនធម៌ សំដែងនូវធម៌ថាធម៌ សំដែងនូវសភាវៈមិនមែនជាវិន័យ ថា មិនមែនវិន័យ សំដែងនូវវិន័យ ថា វិន័យ

---

១ លើសអាបត្តិបារាជិកចេញ អាបត្តិទាំងអស់ហៅថាសាវសេស ។ ២ គឺអាបត្តិបារាជិក ។

វិនយោតិ ទីបេតិ អភាសិតំ អលបិតំ តថាគតេន អភា-សិតំ អលបិតំ តថាគតេនាតិ ទីបេតិ ភាសិតំ លបិតំ តថាគតេន ភាសិតំ លបិតំ តថាគតេនាតិ ទីបេតិ អនា-ចិណ្ណំ តថាគតេន អនាចិណ្ណំ តថាគតេនាតិ ទីបេតិ អាចិណ្ណំ តថាគតេន អាចិណ្ណំ តថាគតេនាតិ ទីបេតិ អប្បញ្ញត្តំ តថាគតេន អប្បញ្ញត្តំ តថាគតេនាតិ ទីបេតិ បញ្ញត្តំ តថាគតេន បញ្ញត្តំ តថាគតេនាតិ ទីបេតិ អនា-បត្តិំ អនាបត្តីតិ ទីបេតិ អាបត្តិំ អាបត្តីតិ ទីបេតិ លហុកំ អាបត្តិំ លហុកា អាបត្តីតិ ទីបេតិ គរុកំ អាបត្តិំ គរុកា អាបត្តីតិ ទីបេតិ សាវសេសំ អាបត្តិំ សាវសេសា អា-បត្តីតិ ទីបេតិ អនវសេសំ អាបត្តិំ អនវសេសា អាបត្តីតិ ទីបេតិ ទុដ្ឋុល្លំ អាបត្តិំ ទុដ្ឋុល្លា អាបត្តីតិ ទីបេតិ អ-ទុដ្ឋុល្លំ អាបត្តិំ អទុដ្ឋុល្លា អាបត្តីតិ ទីបេតិ ឥមេហិ ខោ សារីបុត្ត អដ្ឋារសហិ វត្ថូហិ ធម្មវាទី ជានិតព្វោតិ ។

(១៨៥) អស្សោសិ ខោ អាយស្មា មហាមោគ្គល្លា-នោ ។បេ។ អស្សោសិ ខោ អាយស្មា មហាកស្សបោ អស្សោសិ ខោ អាយស្មា មហាកច្ចានោ អស្សោសិ ខោ



សំដែងភាសិតដែលតថាគតមិនបានពោលមិនបានបរាយថា តថាគតមិនបានពោលមិនបានបរាយ សំដែងភាសិតដែលតថាគតបានពោលបានបរាយថា តថាគតបានពោលបានបរាយ សំដែងកិច្ចដែលតថាគតមិនបានសន្សំថា តថាគតមិនបានសន្សំ សំដែងកិច្ចដែលតថាគតបានសន្សំថា តថាគតបានសន្សំ សំដែងសិក្ខាបទដែលតថាគតមិនបានបញ្ញត្តថា តថាគតមិនបានបញ្ញត្ត សំដែងសិក្ខាបទដែលតថាគតបានបញ្ញត្តថា តថាគតបានបញ្ញត្ត សំដែងអនាបត្តិថា អនាបត្តិ សំដែងអាបត្តិថា អាបត្តិ សំដែងអាបត្តិស្រាលថា អាបត្តិស្រាល សំដែងអាបត្តិធ្ងន់ថា អាបត្តិធ្ងន់ សំដែងអាបត្តិដែលជាសាវសេសៈ ថាអាបត្តិជាសាវសេសៈ សំដែងអាបត្តិដែលជាអនវសេសៈ ថាអាបត្តិជាអនវសេសៈ សំដែងទុដ្ឋុល្លាបត្តិថា ទុដ្ឋុល្លាបត្តិ សំដែងអទុដ្ឋុល្លាបត្តិ ថា អទុដ្ឋុល្លាបត្តិដដែល នែសារីបុត្ត អ្នកត្រូវស្គាល់ធម្មវាទីបុគ្គលដោយវត្ថុ ១៨ យ៉ាងនេះឯង ។

(១៨៥) ព្រះមហាមោគ្គល្លានមានអាយុបានឮ ។បេ។ ព្រះមហាកស្សបមានអាយុ ព្រះមហាកច្ចាន-មានអាយុ ព្រះមហាកោដ្ឋិក

អាយស្មា មហាកោដ្ឋិតោ អស្សោសិ ខោ អាយស្មា ម-
ហាកប្បិនោ អស្សោសិ ខោ អាយស្មា មហាចុន្ទោ
អស្សោសិ ខោ អាយស្មា អនុរុទ្ធោ អស្សោសិ ខោ អា-
យស្មា រេវតោ អស្សោសិ ខោ អាយស្មា ឧបាលិ អស្សោ-
សិ ខោ អាយស្មា អានន្ទោ អស្សោសិ ខោ អាយស្មា
រាហុលោ តេ កិរ កោសម្ពកា ភិក្ខូ ភណ្ឌនការកា
កលហការកា វិវាទការកា ភស្សការកា សង្ឃេ
អធិករណការកា សាវត្ថឹ អាគច្ឆន្តីតិ ។ អថ ខោ អា-
យស្មា រាហុលោ យេន ភគវា តេនុបសង្កមិ ឧបសង្ក-
មិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ
និសិន្នោ ខោ អាយស្មា រាហុលោ ភគវន្តំ ឯតទវោច
តេ កិរ ភន្តេ កោសម្ពកា ភិក្ខូ ភណ្ឌនការកា ក-
លហការកា វិវាទការកា ភស្សការកា សង្ឃេ
អធិករណការកា សាវត្ថឹ អាគច្ឆន្តិ កថាហំ ភន្តេ
តេសុ ភិក្ខូសុ បដិបជ្ជាមីតិ ។ តេនហិ ត្វំ រាហុល
យថា ធម្មោ តថា តិដ្ឋាហីតិ ។ កថាហំ ភន្តេ
ជានេយ្យំ ធម្មំ វា អធម្មំ វា ។ អដ្ឋារសហិ ខោ រាហុល



ដ៏មានអាយុ ព្រះមហាកប្បិនដ៏មានអាយុ ព្រះមហាចុន្ទដ៏មានអាយុ ព្រះអនុរុទ្ធដ៏មានអាយុ ព្រះរេវតដ៏មានអាយុ ព្រះឧបាលិដ៏មានអាយុ ព្រះអានន្ទដ៏មានអាយុ ព្រះរាហុលដ៏មានអាយុបានឮដំណឹងថា ពួកភិក្ខុក្រុងកោសម្ពីនោះជាអ្នកធ្វើសេចក្តីបាក់បែក ឈ្លោះ ទាស់ទែង ធ្វើវិវាទគ្នា ធ្វើអធិករណ៍ក្នុងសង្ឃបានមកដល់ក្រុងសាវត្ថីហើយ ។ គ្រានោះ ព្រះរាហុលដ៏មានអាយុចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយទើបក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគរួចអង្គុយនៅក្នុងទីដ៏សមគួរ ។ លុះព្រះរាហុលដ៏មានអាយុអង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ឮថាពួកភិក្ខុក្រុងកោសម្ពីនោះជាអ្នកធ្វើសេចក្តីបាក់បែក ឈ្លោះ ទាស់ទែង ធ្វើវិវាទគ្នា ធ្វើអធិករណ៍ក្នុងសង្ឃបានមកដល់ក្រុងសាវត្ថី សូមទ្រង់ព្រះមេត្តាប្រោស តើខ្ញុំព្រះអង្គនឹងប្រតិបត្តិក្នុងពួកភិក្ខុនោះដូចម្តេច ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់តបថា នែរាហុល បើដូច្នោះ ចូរអ្នកតាំងនៅឲ្យសមគួរតាមធម៌ចុះ ។ ព្រះរាហុលដ៏មានអាយុក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស តើខ្ញុំព្រះអង្គគប្បីដឹងថាជាធម៌ឬជាមិនមែនជាធម៌បាន ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា នែរាហុល អ្នកត្រូវ

វត្ថូហិ អធម្មវាទី ជានិតព្វោ ។ បេ ។ ឥមេហិ ខោ សារិបុត្ត អដ្ឋារសហិ វត្ថូហិ អធម្មវាទី ជានិតព្វោ អដ្ឋារសហិ ច ខោ សារិបុត្ត វត្ថូហិ ធម្មវាទី ជានិតព្វោ ។ បេ ។ ឥមេហិ ខោ សារិបុត្ត អដ្ឋារសហិ វត្ថូហិ ធម្មវាទី ជានិតព្វោតិ ។

(១៦០) អស្សោសិ ខោ មហាបជាបតី គោតមី តេ កិរ កោសម្ពិកា ភិក្ខូ ភណ្ឌនការកា កលហការកា វិវាទការកា ភស្សការកា សង្ឃេ អធិករណការកា សាវត្ថឹ អាគច្ឆន្តីតិ ។ អថខោ មហាបជាបតី គោតមី យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតា ខោ មហាបជាបតី គោតមី ភគវន្តំ ឯតទវោច តេ កិរ ភន្តេ កោសម្ពិកា ភិក្ខូ ភណ្ឌនការកា កលហការកា វិវាទការកា ភស្សការកា សង្ឃេ អធិករណការកា សាវត្ថឹ អាគច្ឆន្តិ កថាហំ ភន្តេ តេសុ ភិក្ខូសុ បដិបជ្ជាមីតិ ។ តេនហិ ត្វំ គោតមី ឧភយត្ថ ធម្មំ សុណ



ស្គាល់អធម្មវាទីបុគ្គលដោយវត្ថុ ១៨ យ៉ាង ។ បេ ។ ម្នាលសារីបុត្ត អ្នកត្រូវស្គាល់អធម្មវាទីបុគ្គលដោយវត្ថុ ១៨ យ៉ាងនេះឯង ម្នាលសារីបុត្ត ចំណែកខាងធម្មវាទីបុគ្គល អ្នកគឺត្រូវស្គាល់ដោយវត្ថុ ១៨ យ៉ាងវិញ ។ បេ ។ ម្នាលសារីបុត្ត អ្នកត្រូវស្គាល់ធម្មវាទីបុគ្គលដោយវត្ថុ ១៨ យ៉ាងនេះឯង ។

(១៦០) ព្រះនាងមហាបជាបតីគោតមីបានឮដំណឹងថា ពួកភិក្ខុក្រុងកោសម្ពីទាំងនោះជាអ្នកធ្វើសេចក្តីបង្កហេតុឈ្លោះ ទាស់ទែងគ្នា ធ្វើការប្រកែកគ្នា ធ្វើអធិករណ៍ ក្នុងសង្ឃបានមកដល់ក្រុងសាវត្ថីហើយ ។ គ្រានោះ ព្រះនាងមហាបជាបតីគោតមី បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ទើបក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីដ៏សមគួរ ។ លុះព្រះនាងមហាបជាបតីគោតមីបានឋិតនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ឮថា ពួកភិក្ខុក្រុងកោសម្ពីទាំងនោះជាអ្នកធ្វើសេចក្តីបង្កហេតុឈ្លោះ ទាស់ទែងគ្នា ធ្វើការប្រកែកគ្នា ធ្វើអធិករណ៍ ក្នុងសង្ឃបានមកដល់ក្រុងសាវត្ថីហើយ បពិត្រព្រះអង្គដ៏ចំរើន តើខ្ញុំព្រះអង្គនឹងប្រតិបត្តិក្នុងពួកភិក្ខុទាំងនោះដូចម្តេច ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលគោតមី បើដូច្នោះ ព្រះនាងចូរស្តាប់ធម៌ក្នុងពួកភិក្ខុទាំងពីរពួកចុះ

ឧភយត្ថ ធម្មំ សុណ ។ យេ តត្ថ ភិក្ខូ ធម្មវាទិនោ តេសំ ទិដ្ឋិញ្ច ខន្តិញ្ច រុចិញ្ច អាទាយញ្ច[១] រោចេហិ យញ្ច កិញ្ចិ ភិក្ខុនិសង្ឃេន ភិក្ខុសង្ឃតោ បច្ចាសីសិតព្វំ សព្វន្តំ ធម្មវាទិតោវ បច្ចាសីសិតព្វន្តិ ។

[១៦១] អស្សោសិ ខោ អនាថបិណ្ឌិកោ គហបតិ តេ កិរ កោសម្ពកា ភិក្ខូ ភណ្ឌនការកា កលហការកា វិវាទការកា ភស្សការកា សង្ឃេ អធិករណការកា សាវត្ថឹ អាគច្ឆន្តីតិ ។ អថខោ អនាថបិណ្ឌិកោ គហបតិ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អនាថបិណ្ឌិកោ គហបតិ ភគវន្តំ ឯតទវោច តេ កិរ ភន្តេ កោសម្ពកា ភិក្ខូ ភណ្ឌនការកា កលហការកា វិវាទការកា ភស្សការកា សង្ឃេ អធិករណការកា សាវត្ថឹ អាគច្ឆន្តិ កថាហំ ភន្តេ តេសុ ភិក្ខូសុ បដិបជ្ជាមីតិ ។ តេនហិ ត្វំ គហបតិ ឧភយត្ថ ទានំ ទេហិ ឧភយត្ថ ទានំ ទត្វា

១ អាទាយាតិបិ បាឋោ ទិស្សតិ ។



បើនាងស្តាប់ធម៌ក្នុងសំណាក់សង្ឃទាំងពីរពួកហើយ បណ្តាភិក្ខុទាំងនោះ ពួកភិក្ខុណាដែលជាធម្មវាទី ចូរព្រះនាងកាន់យកតាមទិដ្ឋិ សេចក្តីគាប់ចិត្ត សេចក្តីពេញចិត្ត និងលទ្ធិរបស់ពួកភិក្ខុនោះ ម្យ៉ាងទៀត របស់ឯណានីមួយដែលភិក្ខុនីសង្ឃគប្បីប្រាថ្នាអំពីសំណាក់ភិក្ខុសង្ឃ របស់ទាំងអស់នោះភិក្ខុនីត្រូវប្រាថ្នាអំពីធម្មវាទីបុគ្គលចុះ ។

[១៦១] អនាថបិណ្ឌិកគហបតិបានឮដំណឹងថា ពួកភិក្ខុក្រុងកោសម្ពីនោះជាអ្នកធ្វើសេចក្តីបាក់បែក ឈ្លោះ តាស់តែងគ្នា ធ្វើវិវាទគ្នា ធ្វើអធិករណ៍ ក្នុងសង្ឃបានមកដល់ក្រុងសាវត្ថី ។ វេលានោះ អនាថបិណ្ឌិកគហបតិបានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅគាល់ហើយទើបក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគរួចអង្គុយនៅក្នុងទីដ៏សមគួរ ។ លុះអនាថបិណ្ឌិកគហបតិអង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ឮថា ពួកភិក្ខុក្រុងកោសម្ពីនោះជាអ្នកធ្វើសេចក្តីបាក់បែក ឈ្លោះ តាស់តែងគ្នា ធ្វើវិវាទគ្នា ធ្វើអធិករណ៍ ក្នុងសង្ឃបានមកដល់ក្រុងសាវត្ថីហើយ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គនឹងប្រតិបត្តិក្នុងពួកភិក្ខុទាំងនោះដូចម្តេច ។ ព្រះដ៏មានព្រះភាគទ្រង់តបថា នែគហបតិ បើដូច្នោះអ្នកត្រូវឲ្យទានក្នុងសង្ឃទាំងពីរពួកចុះ លុះអ្នកឲ្យទានក្នុងសង្ឃទាំងពីរពួករួចហើយ

ឧភយត្ថ ធម្មំ សុណ ឧភយត្ថ ធម្មំ សុត្វា យេ តត្ថ ភិក្ខូ ធម្មវាទិនោ តេសំ ទិដ្ឋិញ្ច ខន្តិញ្ច រុចិញ្ច អាទាយញ្ច រោចេហីតិ ។

(១៦៤) អស្សោសិ ខោ វិសាខា មិគារមាតា តេ កិរ កោសម្ពកា ភិក្ខូ ភណ្ឌនការកា កលហការកា វិវាទការកា ភស្សការកា សង្ឃេ អធិករណការកា សាវត្ថឹ អាគច្ឆន្តីតិ ។ អថខោ វិសាខា មិគារមាតា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នា ខោ វិសាខា មិគារមាតា ភគវន្តំ ឯតទវោច តេ កិរ ភន្តេ កោសម្ពកា ភិក្ខូ ភណ្ឌនការកា កលហការកា វិវាទការកា ភស្សការកា សង្ឃេ អធិករណការកា សាវត្ថឹ អាគច្ឆន្តិ កថាហំ ភន្តេ តេសុ ភិក្ខូសុ បដិបជ្ជាមីតិ ។ តេនហិ ត្វំ វិសាខេ ឧភយត្ថ ទានំ ទេហិ ឧភយត្ថ ទានំ ទត្វា ឧភយត្ថ ធម្មំ សុណ



អ្នកចូរស្ដាប់ធម៌ក្នុងសំណាក់សង្ឃទាំងពីរពួកទៀត លុះអ្នកស្ដាប់ធម៌ក្នុងសំណាក់សង្ឃទាំងពីរពួកហើយ បណ្ដាភិក្ខុទាំងនោះ ពួកភិក្ខុណាដែលជាធម្មវាទី អ្នកចូរកាន់យកតាមទិដ្ឋិ សេចក្ដីគាប់ចិត្ត សេចក្ដីពេញចិត្ត និងលទ្ធិរបស់ពួកភិក្ខុនោះចុះ ។

(១៦៤) នាងវិសាខាមិគារមាតា បានឮដំណឹងថា ពួកភិក្ខុក្រុងកោសម្ពីនោះ ជាអ្នកធ្វើសេចក្ដីបាក់បែក ឈ្លោះ ទាស់ទែងគ្នា ធ្វើវិវាទគ្នា ធ្វើអធិករណ៍ក្នុងសង្ឃ បានមកដល់ក្រុងសាវត្ថីហើយ ។ លំដាប់នោះ នាងវិសាខាមិគារមាតា បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយនៅក្នុងទីដ៏សមគួរ ។ លុះនាងវិសាខាមិគារមាតា អង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ឮថា ពួកភិក្ខុក្រុងកោសម្ពីនោះ ជាអ្នកធ្វើសេចក្ដីបាក់បែក ឈ្លោះ ទាស់ទែងគ្នា ធ្វើវិវាទគ្នា ធ្វើអធិករណ៍ក្នុងសង្ឃ បានមកដល់ក្រុងសាវត្ថីហើយ បពិត្រព្រះអង្គដ៏ចំរើន តើខ្ញុំព្រះអង្គនឹងប្រតិបត្តិក្នុងពួកភិក្ខុទាំងនោះដូចម្ដេច ។ ព្រះដ៏មានព្រះភាគត្រាស់ថា វិសាខា បើដូច្នោះ ចូរនាងឲ្យទានក្នុងសង្ឃទាំងពីរពួកចុះ លុះនាងឲ្យទានដល់សង្ឃទាំងពីរពួកហើយ ចូរនាងស្ដាប់ធម៌ក្នុងសំណាក់សង្ឃទាំងពីរពួកទៀត

ឧភយត្ថ ធម្មំ សុត្វា យេ តត្ថ ភិក្ខូ ធម្មវាទិនោ តេសំ ទិដ្ឋិញ្ច ខន្តិញ្ច រុចិញ្ច អាទាយញ្ច រោចេហីតិ ។

(៤៦៣) អថខោ កោសម្ពិកា ភិក្ខូ អនុបុព្វេន យេន សាវត្ថី តទវសរឹសុ(១) ។ អថខោ អាយស្មា សារីបុត្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា សារីបុត្តោ ភគវន្តំ ឯតទវោច តេ កិរ ភន្តេ កោសម្ពិកា ភិក្ខូ ភណ្ឌនការកា កលហការកា វិវាទការកា ភស្សការកា សង្ឃេ អធិករណការកា សាវត្ថឹ អនុប្បត្តា កថំ នុ ខោ ភន្តេ តេសុ ភិក្ខូសុ សេនាសនេ(២) បដិបជ្ជិតព្វន្តិ ។ តេនហិ ត្វំ(៣) សារីបុត្ត វិវិត្តំ សេនាសនំ ទាតព្វន្តិ ។ សចេ បន ភន្តេ វិវិត្តំ ន ហោតិ កថំ បដិបជ្ជិតព្វន្តិ ។ តេនហិ សារីបុត្ត វិវិត្តំ កត្វាបិ ទាតព្វំ ន ត្វេវាហំ

---

១ ម. តទវសរុំ ។ ២ សេនាសនេបិ ពាហិ ទិស្សតិ ។ ៣ ឱ. ម. តេនហិ ត្វំ ... ៤ ទិស្សតិ ។



លុះនាងស្ដាប់ធម៌ក្នុងសំណាក់សង្ឃទាំងពីរពួកហើយ បណ្ដាភិក្ខុទាំងនោះ ពួកភិក្ខុណាដែលជាធម្មវាទី ចូរនាងកាន់យកតាមទិដ្ឋិ សេចក្ដីគាប់ចិត្ត សេចក្ដីពេញចិត្ត និងលទ្ធិរបស់ពួកភិក្ខុនោះចុះ ។

[៤៦៣] គ្រានោះ ពួកភិក្ខុក្រុងកោសម្ពីបានដល់ទៅក្រុងសាវត្ថី ដោយលំដាប់ ។ សម័យនោះ ព្រះសារីបុត្តដ៏មានអាយុបានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ទើបក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគរួចអង្គុយនៅក្នុងទីដ៏សមគួរ ។ លុះព្រះសារីបុត្តដ៏មានអាយុអង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ឮថា ពួកភិក្ខុក្រុងកោសម្ពីនោះជាអ្នកធ្វើសេចក្ដីបង្កហេតុ ឈ្លោះ ទាស់ទែងគ្នា ជជែកគ្នានឹងវាចា ធ្វើអធិករណ៍ក្នុងសង្ឃបានមកដល់ក្រុងសាវត្ថីហើយ សូមទ្រង់ព្រះមេត្តាប្រោស តើខ្ញុំព្រះអង្គនឹងប្រតិបត្តិក្នុងភិក្ខុទាំងនោះដោយសេនាសនៈដូចម្ដេច ។ ព្រះមានព្រះភាគទ្រង់តបថា នែសារីបុត្ត បើដូច្នោះអ្នកចូរឲ្យនូវសេនាសនៈដ៏ស្ងាត់ទៅភិក្ខុទាំងនោះចុះ ។ ព្រះសារីបុត្តក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស បើគ្មានទីសេនាសនៈស្ងាត់ទេ តើខ្ញុំព្រះអង្គត្រូវប្រតិបត្តិដូចម្ដេច ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា នែសារីបុត្ត បើដូច្នោះអ្នកត្រូវធ្វើសេនាសនៈដ៏ស្ងាត់ឲ្យកើតមានឡើង ហើយប្រគល់ឲ្យភិក្ខុទាំងនោះទៅ

សារីបុត្ត កេនចិ បរិយាយេន វុឌ្ឍតរស្ស ភិក្ខុនោ សេនាសនំ បដិពាហិតព្វន្តិ វទាមិ យោ បដិពាហេយ្យ អាបត្តិ ទុក្កដស្សាតិ ។ អាមិសេ បន ភន្តេ កថំ បដិបជ្ជាមីតិ ។ អាមិសំ ខោ សារីបុត្ត សព្វេសំ សមកំ ភាជេតព្វន្តិ ។

[១៦៤] អថខោ តស្ស ឧក្ខិត្តកស្ស ភិក្ខុនោ អបរេន សមយេន ឯតទហោសិ អាបត្តិ ឯសា នេសា អនាបត្តិ អាបន្នោម្ហិ នម្ហិ អនាបន្នោ ឧក្ខិត្តោម្ហិ នម្ហិ អនុក្ខិត្តោ ធម្មិកេនម្ហិ កម្មេន ឧក្ខិត្តោ អកុប្បេន ឋានារហេនាតិ ។ អថខោ សោ ឧក្ខិត្តកោ ភិក្ខុ យេន ឧក្ខិត្តានុវត្តកា ភិក្ខូ តេនុបសង្កមិ ឧបសង្កមិត្វា ឧក្ខិត្តានុវត្តកេ ភិក្ខូ ឯតទវោច អាបត្តិ ឯសា អាវុសោ នេសា អនាបត្តិ អាបន្នោម្ហិ នម្ហិ អនាបន្នោ ឧក្ខិត្តោម្ហិ នម្ហិ អនុក្ខិត្តោ ធម្មិកេនម្ហិ កម្មេន ឧក្ខិត្តោ អកុប្បេន



នែសារីបុត្ត តថាគតមិនបានពោលថា ភិក្ខុត្រូវហាមឃាត់សេនាសនៈដល់ភិក្ខុដែលចាស់ជាងដោយបរិយាយណាមួយទេ ភិក្ខុណាហាមឃាត់ ត្រូវអាបត្តិទុក្កដ ។ ព្រះសារីបុត្តក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ចំណែកអាមិស គ្រឿងអាមិសៈវិញ ខ្ញុំព្រះអង្គត្រូវប្រតិបត្តិដូចម្តេច ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា នែសារីបុត្ត ចំណែកអាមិស គ្រឿងអាមិសៈនោះអ្នកត្រូវចែកទៅភិក្ខុទាំងអស់ឲ្យស្មើគ្នា ។

[១៦៤] គ្រានោះ ឧក្ខិត្តកភិក្ខុនោះកាលពិចារណាធម៌វិន័យហើយ ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា នេះជាអាបត្តិ នេះមិនមែនជាអនាបត្តិទេ អាត្មាអញជាភិក្ខុត្រូវអាបត្តិហើយ មិនមែនជាភិក្ខុមិនត្រូវអាបត្តិទេ អាត្មាអញជាភិក្ខុដែលសង្ឃ (ស្ង) លើកវត្តហើយ មិនមែនជាភិក្ខុដែលសង្ឃលើកវត្តមិនបានទេ អាត្មាអញជាភិក្ខុដែលសង្ឃលើកវត្តហើយដោយកម្មប្រកបដោយធម៌ ជាកម្មមិនកំរើក ជាកម្មគួរដល់ហេតុ ។ វេលានោះ ឧក្ខិត្តកភិក្ខុនោះបានចូលទៅរកពួកឧក្ខិត្តានុវត្តកភិក្ខុ លុះចូលទៅដល់ហើយ ទើបនិយាយពាក្យនេះនឹងពួកឧក្ខិត្តានុវត្តកភិក្ខុថា នែអាវុសោ នេះជាអាបត្តិ នេះមិនមែនជាអនាបត្តិទេ ខ្ញុំជាភិក្ខុត្រូវអាបត្តិហើយ មិនមែនជាភិក្ខុមិនត្រូវអាបត្តិទេ ខ្ញុំជាភិក្ខុដែលសង្ឃ (ស្ង) លើកវត្តហើយ មិនមែនជាភិក្ខុដែលសង្ឃលើកវត្តមិនបានទេ ខ្ញុំជាភិក្ខុដែលសង្ឃលើកវត្តហើយដោយកម្មប្រកប

ឋានារហេន ឯថ មំ អាយស្មន្តា ឱសារេថាតិ ។ អថខោ តេ ឧក្ខិត្តានុវត្តកា ភិក្ខូ តំ ឧក្ខិត្តកំ ភិក្ខុំ អាទាយ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ អយំ ភន្តេ ឧក្ខិត្តកោ ភិក្ខុ ឯវមាហ អាបត្តិ ឯសា អាវុសោ នេសា អនាបត្តិ អាបន្នោម្ហិ នម្ហិ អនាបន្នោ ឧក្ខិត្តោម្ហិ នម្ហិ អនុក្ខិត្តោ ធម្មិកេនម្ហិ កម្មេន ឧក្ខិត្តោ អកុប្បេន ឋានារហេន ឯថ មំ អាយស្មន្តា ឱសារេថាតិ កថំ នុ ខោ ភន្តេ បដិបជ្ជិតព្វន្តិ ។ អាបត្តិ ឯសា ភិក្ខវេ នេសា អនាបត្តិ អាបន្នោ ឯសោ ភិក្ខុ នេសោ ភិក្ខុ អនាបន្នោ ឧក្ខិត្តោ ឯសោ ភិក្ខុ នេសោ ភិក្ខុ អនុក្ខិត្តោ ធម្មិកេន កម្មេន ឧក្ខិត្តោ



ដោយធម៌ ជាកម្មមិនកំរើក ជាកម្មគួរដល់ហេតុ បពិត្រលោកដ៏មានអាយុទាំងឡាយ សូមអស់លោកមកធ្វើឱសារណាកម្មចំពោះខ្ញុំចុះ ។ លំដាប់នោះ ឧក្ខិត្តានុវត្តកភិក្ខុទាំងនោះបាននាំឧក្ខិត្តកភិក្ខុនោះចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគរួចអង្គុយនៅក្នុងទីដ៏សមគួរ ។ លុះភិក្ខុទាំងនោះអង្គុយនៅក្នុងទីដ៏សមគួរហើយក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ឧក្ខិត្តកភិក្ខុនេះបាននិយាយយ៉ាងនេះថា នែអាវុសោ នេះជាអាបត្តិ នេះមិនមែនជាអនាបត្តិទេ ខ្ញុំជាភិក្ខុត្រូវអាបត្តិហើយ មិនមែនជាភិក្ខុមិនត្រូវអាបត្តិទេ ខ្ញុំជាភិក្ខុដែលសង្ឃ(គួរ)លើកវត្តហើយ មិនមែនជាភិក្ខុដែលសង្ឃលើកវត្តមិនបានទេ ខ្ញុំជាភិក្ខុដែលសង្ឃលើកវត្តហើយដោយកម្មប្រកបដោយធម៌ ជាកម្មមិនកំរើក ជាកម្មគួរដល់ហេតុ បពិត្រលោកដ៏មានអាយុទាំងឡាយ សូមអស់លោកមកធ្វើឱសារណាកម្មចំពោះខ្ញុំចុះ សូមទ្រង់ព្រះមេត្តាប្រោស តើយើងខ្ញុំព្រះអង្គគួរប្រតិបត្តិដូចម្ដេចទៅ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ នេះជាអាបត្តិ នេះមិនមែនជាអនាបត្តិទេ ភិក្ខុនេះជាអ្នកត្រូវអាបត្តិហើយ ភិក្ខុនេះមិនមែនជាមិនត្រូវអាបត្តិទេ ភិក្ខុនេះជាភិក្ខុដែលសង្ឃ(គួរ)លើកវត្តហើយ ភិក្ខុនេះមិនមែនជាភិក្ខុដែលសង្ឃលើកវត្តមិនបានទេ ភិក្ខុនេះសង្ឃបានលើកវត្តហើយ

[illegible] យតោ ច ខោ សោ ភិក្ខវេ ភិក្ខុ អាបន្នោ ច ឧក្ខិត្តោ ច បស្សតិ ច តេនហិ ភិក្ខវេ តំ ភិក្ខុំ ឱសារេថាតិ ។ អថខោ តេ ឧក្ខិត្តានុវត្តកា ភិក្ខូ តំ ឧក្ខិត្តកំ ភិក្ខុំ ឱសារេត្វា យេន ឧក្ខេបកា ភិក្ខូ តេនុបសង្កមឹសុ ឧបសង្កមិត្វា ឧក្ខេបកេ ភិក្ខូ ឯតទវោចុំ យស្មឹ អាវុសោ វត្ថុស្មឹ អហោសិ សង្ឃស្ស ភណ្ឌនំ កលហោ វិគ្គហោ វិវាទោ សង្ឃភេទោ សង្ឃរាជិ សង្ឃវវត្ថានំ សង្ឃនានាករណំ សោ ឯសោ ភិក្ខុ អាបន្នោ ច ឧក្ខិត្តោ ច បស្សិ ច ឱសារិតោ ច ហន្ទ មយំ អាវុសោ តស្ស វត្ថុស្ស វូបសមាយ សង្ឃសាមគ្គឹ ករោមាតិ ។ អថខោ តេ ឧក្ខេបកា ភិក្ខូ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ឧក្ខេបកា ភិក្ខូ ភគវន្តំ ឯតទវោចុំ តេ ភន្តេ ឧក្ខិត្តានុវត្តកា ភិក្ខូ ឯវមាហំសុ



ដោយកម្មប្រកបដោយធម៌ ជាកម្មមិនកំរើក ជាកម្មគួរដល់ហេតុ ម្នាលភិក្ខុទាំងឡាយ វេលាណាបើភិក្ខុនោះត្រូវអាបត្តិផង សង្ឃលើកវត្តហើយផង ឃើញអាបត្តិផង ម្នាលភិក្ខុទាំងឡាយ បើដូច្នោះអ្នកទាំងឡាយគួរធ្វើឱសារណកម្មភិក្ខុនោះវេលានោះចុះ ។ វេលានោះ ឧក្ខិត្តានុវត្តកភិក្ខុទាំងនោះក៏បានធ្វើឱសារណកម្មដល់ឧក្ខិត្តកភិក្ខុនោះរួចហើយ ក៏ចូលទៅរកពួកឧក្ខេបកភិក្ខុវិញ លុះចូលទៅដល់ហើយ ទើបនិយាយពាក្យនេះនឹងពួកឧក្ខេបកភិក្ខុថា នែអាវុសោ សេចក្តីបង្កហេតុ សេចក្តីឈ្លោះ សេចក្តីកាន់យកផ្សេង ៗ ការវិវាទ ការបែកសង្ឃ សេចក្តីប្រេះឆារបស់សង្ឃ សេចក្តីកំណត់របស់សង្ឃ និងការធ្វើផ្សេង ៗ របស់សង្ឃ កើតដល់សង្ឃព្រោះរឿងណា ភិក្ខុនោះឯងត្រូវអាបត្តិផង សង្ឃបានលើកវត្តផង ឃើញអាបត្តិផង សង្ឃបានធ្វើឱសារណកម្មស្រេចហើយ នែអាវុសោ ណ្ហើយចុះ យើងធ្វើសង្ឃសាមគ្គីដើម្បីនឹងរម្ងាប់រឿងនោះចេញ ។ វេលានោះ ឧក្ខេបកភិក្ខុទាំងនោះក៏បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ទើបក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគរួចអង្គុយនៅក្នុងទីដ៏សមគួរ ។ លុះពួកឧក្ខេបកភិក្ខុនោះអង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ពួកឧក្ខិត្តានុវត្តកភិក្ខុនោះបាននិយាយយ៉ាងនេះថា នែអាវុសោ

យស្មឹ អាវុសោ វត្ថុស្មឹ អហោសិ សង្ឃស្ស ភណ្ឌនំ កលហោ វិគ្គហោ វិវាទោ សង្ឃភេទោ សង្ឃរាជិ សង្ឃវវត្ថានំ សង្ឃនានាករណំ សោ ឯសោ ភិក្ខុ អាបន្នោ ច ឧក្ខិត្តោ ច បស្សតិ ច ឱសារិតោ ច ហន្ទ មយំ អាវុសោ តស្ស វត្ថុស្ស វូបសមាយ សង្ឃសាមគ្គឹ ករោមាតិ កថំ នុ ខោ ភន្តេ បដិបជ្ជិតព្វន្តិ ។ យតោ ច ខោ សោ ភិក្ខវេ ភិក្ខុ អាបន្នោ ច ឧក្ខិត្តោ ច បស្សតិ ច ឱសារិតោ ច តេនហិ ភិក្ខវេ សង្ឃោ តស្ស វត្ថុស្ស វូបសមាយ សង្ឃសាមគ្គឹ ករោតុ ។ ឯវញ្ច បន ភិក្ខវេ កាតព្វា ។ សព្វេហេវ ឯកជ្ឈំ សន្និបតិតព្វំ គិលានេហិ ច អគិលានេហិ ច ន កេហិចិ ឆន្ទោ ទាតព្វោ ។ សន្និបតិត្វា ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ យស្មឹ វត្ថុស្មឹ អហោសិ សង្ឃស្ស ភណ្ឌនំ កលហោ វិគ្គហោ វិវាទោ សង្ឃភេទោ សង្ឃរាជិ សង្ឃវវត្ថានំ សង្ឃនានាករណំ



សេចក្តីបង្កហេតុ សេចក្តីឈ្លោះ សេចក្តីកាន់យកផ្សេង ៗ ការវិវាទ ការបំបែកសង្ឃ សេចក្តីប្រេះឆារបស់សង្ឃ សេចក្តីកំណត់របស់សង្ឃនិង អំពើផ្សេង ៗ របស់សង្ឃ ប្រាកដដល់សង្ឃព្រោះរឿងក្តីណា ភិក្ខុនោះឯង ដែលត្រូវអាបត្តិផង សង្ឃបានលើកវត្តផង បានឃើញអាបត្តិផង សង្ឃបានធ្វើឱសារណកម្មស្រេចហើយផង នែអាវុសោ ណ្ហើយចុះយើងធ្វើសង្ឃសាមគ្គីដើម្បីរម្ងាប់រឿងក្តីនោះចេញ សូមទ្រង់ព្រះមេត្តាប្រោស តើពួកខ្ញុំព្រះអង្គត្រូវប្រតិបត្តិដូចម្តេចទៅ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ វេលាណាបើភិក្ខុនោះត្រូវអាបត្តិផង សង្ឃបានលើកវត្តផង ឃើញអាបត្តិផង សង្ឃបានធ្វើឱសារណកម្មផង ម្នាលភិក្ខុទាំងឡាយ បើដូច្នោះសង្ឃគួរធ្វើសង្ឃសាមគ្គីដើម្បីរម្ងាប់រឿងក្តីនោះចេញ ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវធ្វើបែបយ៉ាងនេះ ។ ភិក្ខុទាំងអស់ត្រូវប្រជុំគ្នាក្នុងទីតែមួយ ពួកភិក្ខុឯណានីមួយទោះឈឺក្តី មិនឈឺក្តី មិនបាច់ឲ្យឆន្ទៈទេ ។ លុះប្រជុំគ្នារួចហើយត្រូវភិក្ខុដែលឈ្លាសប្រតិពលផ្ទៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ព្រោះសេចក្តីបង្កហេតុ សេចក្តីឈ្លោះគ្នា សេចក្តីប្រកាន់ផ្សេងៗគ្នា ការវិវាទគ្នា ការបំបែកសង្ឃ សេចក្តីប្រេះឆារបស់សង្ឃ សេចក្តីកំណត់របស់សង្ឃ និងអំពើផ្សេង ៗ របស់សង្ឃ ប្រាកដមានដល់សង្ឃហើយ

សោ ឯសោ ភិក្ខុ អាបន្នោ ច ឧក្ខិត្តោ ច បស្សតិ ច ឱសារិតោ ច ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ តស្ស វត្ថុស្ស វូបសមាយ សង្ឃសាមគ្គឹ ករេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ យស្មឹ វត្ថុស្មឹ អហោសិ សង្ឃស្ស ភណ្ឌនំ កលហោ វិគ្គហោ វិវាទោ សង្ឃភេទោ សង្ឃរាជិ សង្ឃវវត្ថានំ សង្ឃនានាករណំ សោ ឯសោ ភិក្ខុ អាបន្នោ ច ឧក្ខិត្តោ ច បស្សតិ ច ឱសារិតោ ច ។ សង្ឃោ តស្ស វត្ថុស្ស វូបសមាយ សង្ឃសាមគ្គឹ ករោតិ ។ យស្សាយស្មតោ ខមតិ តស្ស វត្ថុស្ស វូបសមាយ សង្ឃសាមគ្គិយា ករណំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ កតា សង្ឃេន តស្ស វត្ថុស្ស វូបសមាយ សង្ឃសាមគ្គី និហតោ សង្ឃភេទោ និហតា សង្ឃរាជិ និហតំ សង្ឃវវត្ថានំ និហតំ សង្ឃនានាករណំ(១) ។ ខមតិ

១ ឱ. កតា សង្ឃេន តស្ស វត្ថុស្ស វូបសមាយ សង្ឃសាមគ្គី និហតា សង្ឃរាជិ និហតោ សង្ឃភេទោ ។



ព្រោះរឿងណា ភិក្ខុនោះហើយដែលត្រូវអាបត្តិផង សង្ឃបានលើកវត្តផង ឃើញអាបត្តិផង សង្ឃបានធ្វើឱសារណាកម្មស្រេចហើយផង ។ បើកម្មមានកាលសមគួរដល់សង្ឃហើយ សង្ឃត្រូវធ្វើសង្ឃសាមគ្គីដើម្បីរម្ងាប់រឿងនោះចេញ ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ដ្បិតសេចក្តីបង្កហេតុ សេចក្តីឈ្លោះគ្នា សេចក្តីប្រកាន់ផ្សេងៗគ្នា ការកែកគ្នា ការបំបែកសង្ឃ សេចក្តីប្រេះឆារបស់សង្ឃ សេចក្តីកំណត់របស់សង្ឃ ទីធ្វើផ្សេងៗរបស់សង្ឃ ប្រាកដដល់សង្ឃហើយ ព្រោះរឿងណា ភិក្ខុនោះហើយដែលត្រូវអាបត្តិផង សង្ឃបានលើកវត្តផង ឃើញអាបត្តិផង សង្ឃបានធ្វើឱសារណាកម្មផង ។ ឥឡូវសង្ឃបានធ្វើសង្ឃសាមគ្គីដើម្បីរម្ងាប់រឿងនោះហើយ ។ ការធ្វើសង្ឃសាមគ្គីដើម្បីរម្ងាប់រឿងនោះ គាប់ចិត្តដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម បើមិនគាប់ចិត្តដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវនិយាយឡើង ។ ឯសង្ឃសាមគ្គី សង្ឃបានធ្វើហើយ ការបំបែកសង្ឃ សង្ឃក៏បានផ្សះផ្សាហើយ សេចក្តីកំណត់របស់សង្ឃ សង្ឃក៏បានផ្សះផ្សាហើយ ទីធ្វើផ្សេងៗរបស់សង្ឃ សង្ឃក៏បានផ្សះផ្សាហើយ ដើម្បីរម្ងាប់នូវរឿងនោះ ។ ការធ្វើសង្ឃសាមគ្គីប្រហែលជាគាប់ចិត្តដល់សង្ឃហើយ

សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។ តាវទេវ ឧបោសថោ កាតព្វោ បាដិមោក្ខំ ឧទ្ទិសិតព្វន្តិ ។

[១៦៩] អថខោ អាយស្មា ឧបាលិ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា ឧបាលិ ភគវន្តំ ឯតទវោច យស្ស ភន្តេ វត្ថុស្ស ហេតុ សង្ឃស្ស ភណ្ឌនំ កលហោ វិគ្គហោ វិវាទោ សង្ឃភេទោ សង្ឃរាជិ សង្ឃវវត្ថានំ សង្ឃនានាករណំ សង្ឃោ តំ វត្ថុំ អវិនិច្ឆិនិត្វា អមូលា មូលំ គន្ត្វា សង្ឃសាមគ្គឹ ករោតិ ធម្មិកា នុ ខោ សា ភន្តេ សង្ឃសាមគ្គីតិ ។ យស្ស ឧបាលិ វត្ថុស្ស ហេតុ សង្ឃស្ស ភណ្ឌនំ កលហោ វិគ្គហោ វិវាទោ សង្ឃភេទោ សង្ឃរាជិ សង្ឃវវត្ថានំ សង្ឃនានាករណំ សង្ឃោ តំ វត្ថុំ អវិនិច្ឆិនិត្វា អមូលា



ព្រោះហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកនូវសេចក្តីព្រម-ព្រៀងនេះដោយការស្ងៀមយ៉ាងនេះ ។ សង្ឃត្រូវធ្វើឧបោសថ ត្រូវសំដែងបាតិមោក្ខក្នុងខណៈនោះឯង ។

[១៦៩] គ្រានោះ ព្រះឧបាលិដ៏មានអាយុបានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគរួចអង្គុយក្នុងទីសមគួរ ។ លុះព្រះឧបាលិដ៏មានអាយុអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស សេចក្តីបង្កហេតុ សេចក្តីឈ្លោះគ្នា សេចក្តីប្រកាន់ផ្សេងៗគ្នា ការវិវាទគ្នា ការបំបែកសង្ឃ សេចក្តីប្រេះឆារបស់សង្ឃ សេចក្តីកំណត់របស់សង្ឃ និងអំពើផ្សេងៗរបស់សង្ឃ ប្រាកដដល់សង្ឃហើយ ព្រោះរឿងណា សង្ឃមិនទាន់បានជំរះរឿងនោះ មិនទាន់ដឹងដើមហេតុតាមហេតុនៃរឿងនោះ ហើយស្រាប់តែធ្វើសង្ឃសាមគ្គីតែម្តង សូមទ្រង់ព្រះមេត្តាប្រោស សង្ឃសាមគ្គីនោះប្រកបដោយធម៌ដែរឬ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលឧបាលិ សេចក្តីបង្កហេតុ សេចក្តីឈ្លោះ សេចក្តីប្រកាន់ផ្សេងៗគ្នា ការវិវាទគ្នា ការបំបែកសង្ឃ សេចក្តីប្រេះឆារបស់សង្ឃ សេចក្តីកំណត់របស់សង្ឃ និងអំពើផ្សេងៗរបស់សង្ឃ ប្រាកដដល់សង្ឃហើយ ព្រោះរឿងណា សង្ឃមិនទាន់បានជំរះរឿងនោះ

មូលំ គន្ត្វា សង្ឃសាមគ្គី ការិយតិ អធម្មិកា សា ឧបាលិ សង្ឃសាមគ្គីតិ ។ យំ បន ភន្តេ វត្ថុស្មឹ ហោតិ សង្ឃស្ស ភណ្ឌនំ កលហោ វិគ្គហោ វិវាទោ សង្ឃភេទោ សង្ឃរាជិ សង្ឃវវត្ថានំ សង្ឃនានាករណំ សង្ឃោ តំ វត្ថុំ វិនិច្ឆិនិត្វា មូលា មូលំ គន្ត្វា សង្ឃសាមគ្គី ករោតិ ធម្មិកា នុ ខោ សា ភន្តេ សង្ឃសាមគ្គីតិ ។ យស្មឹ ឧបាលិ វត្ថុស្មឹ ហោតិ សង្ឃស្ស ភណ្ឌនំ កលហោ វិគ្គហោ វិវាទោ សង្ឃភេទោ សង្ឃរាជិ សង្ឃវវត្ថានំ សង្ឃនានាករណំ សង្ឃោ តំ វត្ថុំ វិនិច្ឆិនិត្វា មូលា មូលំ គន្ត្វា សង្ឃសាមគ្គឹ ករោតិ ធម្មិកា សា ឧបាលិ សង្ឃសាមគ្គីតិ ។ កតិ នុ ខោ ភន្តេ សង្ឃសាមគ្គិយោតិ ។ ទ្វេ ឧបាលិ



មិនបានដឹងដើមហេតុតាមហេតុនៃរឿងនោះ ហើយក្រោយតែធ្វើសង្ឃសាមគ្គីតែម្ដង នែឧបាលិ សង្ឃសាមគ្គីនោះមិនប្រកបដោយធម៌ទេ ។ ព្រះឧបាលិក្រាបបង្គំទូលសួរថា សូមទ្រង់ព្រះមេត្តាប្រោស ម្យ៉ាងទៀត ចុះបើសេចក្ដីបង្កហេតុ សេចក្ដីឈ្លោះគ្នា សេចក្ដីប្រកាន់ផ្សេង ៗ គ្នា ការវិវាទគ្នា ការបំបែកសង្ឃ សេចក្ដីប្រេះឆារបស់សង្ឃ សេចក្ដីកំណត់របស់សង្ឃ ទីនាំកើតផ្សេង ៗ របស់សង្ឃ ប្រាកដដល់សង្ឃហើយ ព្រោះរឿងណា សង្ឃបានជំរះរឿងនោះ បានដឹងដើមហេតុតាមហេតុនៃរឿងនោះ ហើយក៏ធ្វើសង្ឃសាមគ្គីទៅ សូមទ្រង់ព្រះមេត្តាប្រោស សង្ឃសាមគ្គីនោះប្រកបដោយធម៌ដែរឬ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា នែឧបាលិ សេចក្ដីបង្កហេតុ សេចក្ដីឈ្លោះគ្នា សេចក្ដីប្រកាន់ផ្សេង ៗ គ្នា ការវិវាទគ្នា ការបំបែកសង្ឃ សេចក្ដីប្រេះឆារបស់សង្ឃ សេចក្ដីកំណត់របស់សង្ឃ ទីនាំកើតផ្សេង ៗ របស់សង្ឃ ប្រាកដដល់សង្ឃហើយ ព្រោះរឿងណា សង្ឃក៏បានជំរះរឿងនោះចេញ បានដឹងដើមហេតុតាមហេតុនៃរឿងនោះ ហើយក៏ធ្វើសង្ឃសាមគ្គីទៅ នែឧបាលិ សង្ឃសាមគ្គីនោះហៅថា ប្រកបដោយធម៌ ។ ព្រះឧបាលិក្រាបបង្គំទូលសួរថា សូមទ្រង់ព្រះមេត្តាប្រោស សង្ឃសាមគ្គីមានប៉ុន្មានយ៉ាង ។ ព្រះអង្គទ្រង់ត្រាស់ថា

សង្ឃសាមគ្គិយោ អត្ថិ ឧបាលិ សង្ឃសាមគ្គី អត្ថាបេតា ព្យញ្ជនុបេតា អត្ថិ ឧបាលិ សង្ឃសាមគ្គី អត្ថុបេតា ច ព្យញ្ជនុបេតា ច ។ កតមា ច ឧបាលិ សង្ឃសាមគ្គី អត្ថាបេតា ព្យញ្ជនុបេតា ។ យស្មឹ ឧបាលិ វត្ថុស្មឹ ហោតិ សង្ឃស្ស ភណ្ឌនំ កលហោ វិគ្គហោ វិវាទោ សង្ឃភេទោ សង្ឃរាជិ សង្ឃវវត្ថានំ សង្ឃនានាករណំ សង្ឃោ តំ វត្ថុំ អវិនិច្ឆិនិត្វា អមូលា មូលំ គន្ត្វា សង្ឃសាមគ្គិំ ករោតិ អយំ វុច្ចតិ ឧបាលិ សង្ឃសាមគ្គី អត្ថាបេតា ព្យញ្ជនុបេតា ។ កតមា ច ឧបាលិ សង្ឃសាមគ្គី អត្ថុបេតា ច ព្យញ្ជនុបេតា ច ។ យស្មឹ ឧបាលិ វត្ថុស្មឹ ហោតិ សង្ឃស្ស ភណ្ឌនំ កលហោ វិគ្គហោ វិវាទោ សង្ឃភេទោ សង្ឃរាជិ សង្ឃវវត្ថានំ សង្ឃនានាករណំ សង្ឃោ តំ វត្ថុំ វិនិច្ឆិនិត្វា មូលា មូលំ គន្ត្វា សង្ឃសាមគ្គិំ ករោតិ អយំ វុច្ចតិ ឧបាលិ សង្ឃសាមគ្គី អត្ថុបេតា ច ព្យញ្ជនុបេតា ច ។ ឥមា ខោ ឧបាលិ



នែឧបាលិ សង្ឃសាមគ្គីមានពីរយ៉ាង នែឧបាលិ សង្ឃសាមគ្គីប្រាសចាកអត្ថ តែប្រកបដោយព្យញ្ជនៈ ១ នែឧបាលិ សង្ឃសាមគ្គីប្រកបទាំងអត្ថទាំងព្យញ្ជនៈ ១ ។ នែឧបាលិ ឯសង្ឃសាមគ្គីដែលប្រាសចាកអត្ថ តែប្រកបដោយព្យញ្ជនៈ តើដូចម្តេច ។ នែឧបាលិ សេចក្តីប្រកែក សេចក្តីឈ្លោះគ្នា សេចក្តីប្រកាន់ផ្សេងៗគ្នា ការវិវាទ ការបែកសង្ឃ សេចក្តីប្រេះឆារបស់សង្ឃ សេចក្តីកំណត់របស់សង្ឃ ទីនិមិត្តផ្សេងៗរបស់សង្ឃ ក្រុកដល់សង្ឃហើយ ព្រោះរឿងណា សង្ឃមិនកាត់បានចប់រឿងនោះមិនទាន់ដល់ដើមហេតុតាមហេតុនៃរឿងនោះ ហើយស្រាប់តែធ្វើសង្ឃសាមគ្គីទៅ នែឧបាលិ សង្ឃសាមគ្គីនេះ តថាគតហៅថា ប្រាសចាកអត្ថ តែប្រកបដោយព្យញ្ជនៈ ។ នែឧបាលិ ចំណែកខាងសង្ឃសាមគ្គីដែលប្រកបទាំងអត្ថទាំងព្យញ្ជនៈ តើដូចម្តេច ។ នែឧបាលិ សេចក្តីប្រកែក សេចក្តីឈ្លោះគ្នា សេចក្តីប្រកាន់ផ្សេងៗគ្នា ការវិវាទគ្នា ការបែកសង្ឃ សេចក្តីប្រេះឆារបស់សង្ឃ សេចក្តីកំណត់របស់សង្ឃ ទីនិមិត្តផ្សេងៗរបស់សង្ឃ ក្រុកដល់សង្ឃហើយ ព្រោះរឿងណា សង្ឃក៏បានកាត់រឿងនោះបានដល់ដើមហេតុតាមហេតុនៃរឿងនោះ ហើយក៏ធ្វើសង្ឃសាមគ្គីទៅ នែឧបាលិ សង្ឃសាមគ្គីនេះ តថាគតហៅថា ប្រកបទាំងអត្ថទាំងព្យញ្ជនៈ ។ នែឧបាលិ សង្ឃសាមគ្គីមានពីរយ៉ាងនេះឯង ។ លំដាប់នោះ ព្រះឧបាលិ

ទេ សព្វសាមគ្គិយោគំ ។ អថខោ អាយស្មា ឧបាលិ ឧដ្ឋាយាសនា ឯកំសំ ឧត្តរាសង្គំ ករិត្វា យេន ភគវា តេនញ្ជលិំ បណាមេត្វា ភគវន្តំ គាថាយ អជ្ឈភាសិ

(១៦៦) សព្វស្ស កិច្ចេសុ ច មគ្គតាសុ ច
អត្ថេសុ ជាតេសុ វិនិច្ឆយេសុ ច
កាលប្បការេន ឧភោ មហត្ថិកោ
ភិក្ខុ កថំ ហោតិធ យុត្តការិយោ ។
អនានុវជ្ជោ បឋមេន សីលតោ
អវេក្ខិតាចារសុសំវុតិន្ទ្រិយោ
បច្ចត្ថិកា នោបវទន្តិ ធម្មតោ
ន ហិស្ស តំ ហោតិ វទេយ្យ យេន តំ ។
សោ តាទិសោ សីលវិសុទ្ធិយា ឋិតោ
វិសារទោ ហោតិ វិសយ្ហ ភាសតិ
នច្ឆម្ភតិ បរិសគតោ ន វេធតិ
អត្ថំ ន ហាបេតិ អនុយ្យុតំ ភណំ



ដ៏មានអាយុ ក្រោកចាកអាសនៈធ្វើឧត្តរាសង្គៈ (ចីវរ) ឆៀងស្មាម្ខាង រួចប្រណម្យអញ្ជលីចំពោះព្រះដ៏មានព្រះភាគ ហើយក្រាបបង្គំទូលព្រះដ៏-មានព្រះភាគដោយព្រះគាថា ថា

(១៦៦) កាលបើកិច្ចក្តី ការប្រតិបត្តិវិន័យក្តី សេចក្តីអនុប្បញ្ញត្តិវិន័យក្តី សេចក្តីវិនិច្ឆ័យវិន័យក្តី កើតចំពោះសង្ឃហើយ ភិក្ខុមានប្រការដូចម្តេច ទើបហៅថាមានឧបការៈប្រែក្នុងសាសនានេះ នឹងដូចម្តេចដែលគួរលើកតម្កើងក្នុងសាសនានេះ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ភិក្ខុណាដែលគេមិនគួរតិះដៀលដោយសីលជាបឋម បានពិចារណាមើលមារយាទខ្លួន បានសង្រួមឥន្ទ្រិយៈដោយល្អហើយ ពួកសត្រូវក៏មិនបានតិះដៀលដោយធម៌ឡើយ ព្រោះថាខ្លួននិយាយ (បន្ទោស) ភិក្ខុដោយហេតុណា ហេតុនោះមិនមានដល់ភិក្ខុនោះឡើយ ។ ភិក្ខុប្រែបនោះឯងតាំងនៅក្នុងសីលវិសុទ្ធិ ក្លៀវក្លាអង់អាចនិយាយប្រែបសង្កត់គេបាន នៅក្នុងកណ្តាលបរិ-សទ្យក៏គ្មានតក់ស្លុតគ្មានរន្ធត់ឡើយ ភិក្ខុនោះមិនបាននិយាយពាក្យមិនគួរ ដែលញ៉ាំងប្រយោជន៍ឲ្យសាបសូន្យឡើយ

កាលេ បញ្ហំ បរិសាសុ បុដ្ឋោ
ន ចាបិ បជ្ឈាយតិ ន មង្កុ ហោតិ ។
សោ កាលាគតំ ព្យាករណារហំ វចោ
រញ្ជេតិ វិញ្ញូបរិសំ វិចក្ខណោ
សគារវោ វុឌ្ឍតរេសុ ភិក្ខុសុ
អាចេរកម្ហិ ច សកេ វិសារទោ
អលំ បមេតុំ បគុណោ កថេតវេ
បច្ចត្ថិកានញ្ច វិរទ្ធកោវិទោ
បច្ចត្ថិកា យេន វជន្តិ និគ្គហំ
មហាជនោ សញ្ញបនញ្ច គច្ឆតិ
សកញ្ច អាទាយមយំ ន រិញ្ចតិ
វេយ្យាករំ បញ្ហមនូបឃាតិកំ
ទូតេយ្យកម្មេសុ អលំ សមុគ្គហោ
សង្ឃស្ស កិច្ចេសុ ច អាហុនំ យថា
ករំ វចោ ភិក្ខុគណេន បេសិតោ
អហំ ករោមីតិ ន តេន មញ្ញតិ



(ដើមាន) គេសួរប្រស្នាក្នុងបរិសទ្យហើយនោះ ក៏ឥតព្រួយ ស្រពោន ឥតភៀនអន់ឡើយ ១ ភិក្ខុនោះមានប្រាជ្ញា ញុំាងបរិសទ្យជាអ្នកប្រាជ្ញឲ្យត្រេកអរ ដោយពាក្យដែលមានមកក្នុងកាលគួរ ដោយគួរជាទីដោះស្រាយប្រស្នាបាន ជាអ្នកមានសេចក្តីគោរពក្នុងភិក្ខុចាស់ជាង ដោយក្លៀវក្លាក្នុងពាក្យអាចារ្យរបស់ខ្លួន ហើយអាចពិចារណាឲ្យហេតុនោះៗ ដោយស្ទាត់ក្នុងពាក្យដែលគួរនិយាយ ឆ្លាសក្នុងហេតុដែលភ្លាត់ខុសរបស់ពួកសត្រូវ ពួកសត្រូវសង្កត់សង្កិនក្តី មហាជនក៏ពន្យល់ក្តី ដោយពាក្យណា ភិក្ខុនេះមិនលះបង់នូវពាក្យអាចារ្យរបស់ខ្លួន ដោយពាក្យនោះឡើយ កាលដោះស្រាយប្រស្នា ជាប្រស្នាមិនបានបៀតបៀនឡើយ ហើយអាចក្នុងទូតេយ្យ-កម្មផង ទទួលនូវនាទីកិច្ចការ របស់សង្ឃផង ដូចជាជនអ្នកទទួលយកនូវគ្រឿងបូជា ភិក្ខុនោះ កាលពួកភិក្ខុបញ្ជូនទៅ (ដើម្បី) ធ្វើនូវពាក្យជាកិច្ចការរបស់សង្ឃ ក៏មិនបានមើលងាយ ដោយអំពើនោះថា អាត្មាអញធ្វើឡើយ

កោសម្ពិក្ខន្ធក បាលីគាថា

អាបន្នំ យាវតកេសុ វត្ថុសុ
អាបត្តិយា ហោតិ យថា ច វុដ្ឋិតំ
ឯតេ វិភត្តា ឧភយស្ស សាគតា
អាបត្តិវុដ្ឋានបទស្ស កោវិទោ
និស្សារណំ គច្ឆតិ យាទិ តាទិ
និស្សារិតា ហោតិ យថា ច វត្តនា
ឱសារណំ តំវុសិតស្ស ជន្តុនោ
ឯតំបិ ជានាតិ វិភង្គកោវិទោ
សគារវោ វុឌ្ឍតរេសុ ភិក្ខុសុ
នវេសុ ថេរេសុ ច មជ្ឈិមេសុ ច
មហាជនស្សត្ថចរោធ បណ្ឌិតោ
សោ តាទិសោ ភិក្ខុ ឥធ បាសំសិយោតិ ។

កោសម្ពិក្ខន្ធកំ ទសមំ ។



កោសម្ពិក្ខន្ធកៈ ប្រែគាថា

ដឹងត្រូវអាបត្តិ ក្នុងវត្ថុមានប្រមាណណា ការចេញចាកអាបត្តិ ដោយសមគួរតាម (វត្ថុមានប្រមាណប៉ុណ្ណោះ) ភិក្ខុនោះចេះចាំស្ទាត់នូវកិច្ចទាំងពីរនេះ ហើយក៏វៃក្នុងហេតុដែលចេញចាកអាបត្តិ ប្រសិនបើភិក្ខុដទៃប្រព្រឹត្តនូវអំពើតាំងឡាយណា មានសេចក្តីបង្ខំហេតុជាដើម ហើយនូវទីរំដេញនិស្សារណាកម្ម (កម្មដែលបណ្តេញចេញ) ភិក្ខុនោះបានជួយធ្វើនិស្សារណាកម្មដោយសមគួរតាមរឿង (វិនិច្ឆ័យការ) ឱសារណាកម្ម (កម្មដែលសង្ឃឲ្យចូលពួកវិញ) ណាដែលសង្ឃត្រាប្រើចំពោះជនភិក្ខុដែលប្រព្រឹត្តតាមវត្តនោះ ភិក្ខុនោះក៏ឈ្លាសក្នុងវិភង្គ អាចស្គាល់ឱសារណាកម្មនោះឯង ភិក្ខុនោះប្រកបដោយសេចក្តីគោរពក្នុងពួកភិក្ខុដែលចាស់ជាងខ្លួន ម្យ៉ាងទៀត ប្រកបដោយសេចក្តីគោរពក្នុងភិក្ខុថ្មីផង ភិក្ខុចាស់ផង ភិក្ខុជាកណ្តាលផង ជាបណ្ឌិតប្រព្រឹត្តនូវប្រយោជន៍ដល់មហាជនក្នុងលោកនេះ ភិក្ខុបែបនោះឯង គួរនឹងផ្តល់ដំកើងក្នុងសាសនានេះ ។

ចប់ កោសម្ពិក្ខន្ធកៈ ទី ១០ ។

តស្សុទ្ទានំ

[៣៦៧] កោសម្ពិយំ ជិនវរោ
វិវាទាបត្តិទស្សនេ
នុក្ខិបេយ្យ យស្មិំ តស្មិំ
តស្ស យាបត្តិ ទេសយេ ។
អន្តោសីមាយ តត្ថេវ
ពាលកញ្ចេវ វំសទា
បារិលេយ្យា ច សាវត្ថី
សារីបុត្តោ ច កោលិតោ
មហាកស្សបកច្ចានោ
កោដ្ឋិតោ កប្បិនេន ច
មហាចុន្ទោ ច អនុរុទ្ធោ
រេវតោ ឧបាលិចូភោ
អានន្ទោ រាហុលោ ចេវ
គោតមីនាថបិណ្ឌិកោ
វិសាខា មិគារមាតា ច



ឧទ្ទាននៃកោសម្ពិក្ខន្ធកៈនោះ គឺ

(១៦៧) រឿងព្រះជិនស្រេចប្រថាប់នៅក្នុងក្រុងកោសម្ពី ១ រឿងវិវាទព្រោះឃើញអាបត្តិ ១ រឿងភិក្ខុលើកវត្តព្រោះមិនឃើញអាបត្តិនោះ ១ រឿងព្រះអង្គទ្រង់ត្រាស់ថា អាបត្តិណាមានដល់ភិក្ខុនោះ ភិក្ខុនោះត្រូវសំដែងអាបត្តិនោះចេញ ១ រឿងទុក្កដនូវភិក្ខុធ្វើឧបោសថសង្ឃកម្មខាងក្នុងសីមា ១ រឿងព្រះជិនមានព្រះភាគទ្រង់យាងទៅកាន់ពាលកលោណការកគ្រាម ១ រឿងព្រះជិនមានព្រះភាគទ្រង់យាងទៅកាន់ព្រៃបាចីនវង្ស ១ រឿងព្រះជិនមានព្រះភាគទ្រង់យាងទៅកាន់ប្រទេសឈ្មោះបារិលេយ្យកៈ ១ រឿងព្រះមានព្រះភាគទ្រង់យាងទៅកាន់ក្រុងសាវត្ថី ១ រឿងព្រះសារីបុត្ត ព្រះកោលិតៈ (មោគ្គល្លាន) ព្រះមហាកស្សប ព្រះមហាកច្ចានៈ ព្រះកោដ្ឋិតៈ ព្រះកប្បិន ព្រះមហាចុន្ទ ព្រះអនុរុទ្ធ ព្រះរេវតៈ ព្រះឧបាលិ ព្រះអានន្ទ និងព្រះរាហុល ១ រឿងព្រះនាងគោតមី ១ រឿងអនាថបិណ្ឌិកសេដ្ឋី ១ រឿងនាងវិសាខាជាមិគារមាតា ១

សេនាសនំ ភិក្ខូនំ
អាមិសំ សមកំបិ ច
ន ខោ ហិ ឆន្ទោ ទាតព្វោ
ឧបាលិ បរិបុច្ឆិតោ
អនុបវជ្ជោ សីលេន
សាមគ្គី ជិនសាសនេតិ ។

មហាវគ្គោ សមត្តោ ។

---





រឿងព្រះសារីបុត្រក្រាបបង្គំទូលព្រះអង្គថា យើងខ្ញុំត្រូវប្រតិបត្តិក្នុងភិក្ខុទាំងនោះដោយសេចក្ដីដូចម្ដេច ១ រឿងសេនាសនៈស្ងាត់ ១ រឿងចែកគ្រឿងអាមិសៈស្មើគ្នា ១ រឿងភិក្ខុណាមួយមិនត្រូវឲ្យឆន្ទៈ ១ រឿងព្រះឧបាលិក្រាបបង្គំទូលសួរ ១ រឿងបុគ្គលដែលគេមិនគួរតិះដៀលដោយសីល ១ រឿងសទ្រ-សាមគ្គីក្នុងសាសនាព្រះជិនស្រី ១ ។

ចប់ មហាវគ្គ ។

---

# សង្ខេបចង្អុលប្រាប់មាតិកា

លេខទំព័រ

កឋិនក្ខន្ធក ១

រឿងភិក្ខុ ៣០ រូបនៅក្នុងដែនបាវេយ្យ. . . . . . . . . . . . . . . . . . ២
គោលនៃពីអានិសង្ស (កឋិន) មាន ៥ យ៉ាង. . . . . . . . . . . . . ៣
គោលនៃពីកឋិនដែលភិក្ខុក្រាលមិនឡើង. . . . . . . . . . . . . . . ៤
គោលនៃពីកឋិនដែលភិក្ខុក្រាលឡើង. . . . . . . . . . . . . . . . ៥
គោលនៃពីកឋិនដែលដំណើះ (និយាយអំពីមាតិកា) ៨ យ៉ាង. . . . . . . . . ៦
និយាយពីកឋិនដោះ អាទាយសត្តកវារ. . . . . . . . . . . . . . . ១១
និយាយពីកឋិនដោះ អាទាយឆក្កវារ. . . . . . . . . . . . . . . . ១៣
និយាយពីកឋិនដោះ សមាទាយឆក្កវារ. . . . . . . . . . . . . . . ១៤
និយាយពីកឋិនដោះ ការដោះកឋិនត្រង់ចីវរវិតាសជាកំណត់ជាដើម. . . . . ១៥
និយាយពីកឋិនដោះ ការដោះកឋិនត្រង់សេចក្តីសន្និដ្ឋានជាកំណត់ជាដើម. . . ២១
និយាយពីកឋិនដោះ ការដោះកឋិនត្រង់ចីវរសម្រេចជាកំណត់ជាដើម. . . . ២៣
និយាយពីកឋិនដោះ ការដោះកឋិនត្រង់ជានក្ខមណ៌ជាកំណត់ជាដើម. . . . ២៤
និយាយពីកឋិនដោះ ការដោះកឋិនត្រង់ចីវរវិនាសជាកំណត់ជាដើម. . . . ២៥
និយាយពីកឋិនដោះ ការដោះកឋិនត្រង់ចីវរសម្រេចជាកំណត់ជាដើម. . . ២៦
និយាយពីកឋិនដោះ ការដោះកឋិនត្រង់សេចក្តីសន្និដ្ឋានជាកំណត់ជាដើម. . . . ៣៣
និយាយពីកឋិនដោះ ការដោះកឋិនត្រង់អស់សេចក្តីសង្ឃឹមជាកំណត់ជាដើម. . . ៣៤
និយាយពីកឋិនដោះ ការដោះកឋិនត្រង់ចីវរវិនាសជាកំណត់ជាដើម. . . . . ៣៥
និយាយពីកឋិនដោះ ការដោះកឋិនត្រង់អស់សេចក្តីសង្ឃឹមជាកំណត់ជាដើម. . ៣៦
និយាយពីកឋិនដោះ ការដោះកឋិនត្រង់ចីវរវិនាសជាកំណត់ជាដើម. . . . . ៤១
និយាយពីកឋិនដោះ ការដោះកឋិនត្រង់សេចក្តីសន្និដ្ឋានជាកំណត់ជាដើម. . . ៤៤
និយាយពីកឋិនដោះ ការដោះកឋិនត្រង់ចីវរសម្រេចជាកំណត់ជាដើម. . . . . ៤៥
និយាយពីកឋិនដោះ ការដោះកឋិនត្រង់សេចក្តីសន្និដ្ឋានជាកំណត់ជាដើម. . . . ៤៦
និយាយពីបលិពោធ និងអបលិពោធ. . . . . . . . . . . . . . . . . ៥១
ឧទ្ទានគាថា. . . . . . . . . . . . . . . . . . . . . . . . . ៥៣

លេខទំព័រ

ចីវរក្ខន្ធក ៦១

រឿងស្ត្រីគណិកានៅក្រុងរាជគ្រឹះ........ ៦៣
រឿងជីវកកោមារភច្ច........ ៦៥
រឿងជីវកកោមារភច្ច ចំនួនរឿងភរិយាសេដ្ឋី........ ៦៧
និយាយពីរឿងព្រះបាទពិម្ពិសារកើតជារោគឫសដូងបាត........ ៧៤
និយាយពីសេដ្ឋីក្រុងរាជគ្រឹះកើតជារោគឈឺក្បាល........ ៧៧
និយាយពីរឿងកូនសេដ្ឋីកើតជារោគវិលពោះវៀន........ ៨៣
និយាយពីរឿងព្រះបាទចណ្ឌប្បជ្ជោតកើតជារោគខាន់លឿង........ ៨៥
រឿងព្រះបាទចណ្ឌប្បជ្ជោត និយាយពីការថ្វាយសំពត់........ ៨៧
រឿងព្រះបាទចណ្ឌប្បជ្ជោត និយាយពីការឲ្យឈ្មួញទៅព្រៃនិងសំរិទ្ធឈ្មោះកាក........ ៨៩
និយាយពីព្រះជីវកថ្វាយព្រះភាគ (ថ្នាំបរិហារ) ថ្នាំបញ្ចុះ........ ៩១
ការទ្រង់អនុញ្ញាតគហបតិចីវរ........ ៩៧
សំពត់កម្ពលមានតម្លៃច្រើនរបស់ស្តេចកាសី........ ៩៩
និយាយពី (ការទ្រង់អនុញ្ញាត) ចីវរ ៦ យ៉ាងនិងគហបតិចីវរ........ ១០១
និយាយពីភិក្ខុចូលទៅកាន់ព្រៃស្មសាន........ ១០៣
ការសន្មតិភិក្ខុឲ្យជាអ្នកទទួលចីវរ........ ១០៥
ការសន្មតិឃ្លាំង........ ១០៧
ការសន្មតិភិក្ខុឲ្យជាអ្នករក្សាឃ្លាំង........ ១០៨
ការសន្មតិភិក្ខុឲ្យជាអ្នកចែកចីវរ........ ១១១
ការទ្រង់អនុញ្ញាតទឹកជ្រលក់ (៦ យ៉ាង)........ ១១៣
ការទ្រង់អនុញ្ញាតវិធីសម្រាប់ចងជាយចីវរជាដើម........ ១១៥
រឿងព្រះអានន្ទត្ថេរ........ ១១៧
និយាយពីត្រៃចីវរព្រោះតែខែមាឃនិងខែផល្គុន........ ១១៩
សេចក្តីបញ្ញត្តិអតិរេកចីវរ........ ១២១
រឿងភិក្ខុ ១ រូប (មានស្បង់ធ្លុះ)........ ១២៣



លេខទំព័រ

រឿងនាងវិសាខាមិគារមាតា........ ១២៥
រឿងនាងវិសាខាមិគារមាតា និយាយអំពីពរ ៨ ប្រការ........ ១២៩
និយាយពីភិក្ខុរៀបស្លាក់សំពត់........ ១៣៧
ការទ្រង់អនុញ្ញាតនិសីទនៈ (សំពត់ក្រាលអង្គុយ)........ ១៣៩
ការទ្រង់អនុញ្ញាតសំពត់សម្រាប់ជូតមុខ........ ១៤១
ការទ្រង់អនុញ្ញាតគ្រឿងការអធិដ្ឋានត្រៃចីវរជាដើម........ ១៤៣
ភិក្ខុមិនត្រូវទ្រទ្រង់ចីវរដែលមិនកាត់ទាំងអស់........ ១៤៥
ហេតុដែលត្រូវទុកដាក់ត្រៃចីវរ........ ១៤៧
និយាយពីចីវរជារបស់សង្ឃ........ ១៤៩
រឿងឧបនន្ទ និយាយអំពីចំណែកចីវរ........ ១៥១
រឿងភិក្ខុមានរោគឈឺពោះ........ ១៥៣
និយាយអំពីភិក្ខុអ្នកបម្រើជម្ងឺ........ ១៥៥
និយាយអំពីការឲ្យបាត្រនិងចីវររបស់ភិក្ខុស្លាប់ដល់អ្នកបម្រើជម្ងឺ........ ១៦១
និយាយអំពីតិត្ថិយសមាទានវត្តអាក្រាតជាដើម........ ១៦៥
រឿងឆព្វគ្គិយភិក្ខុ និយាយអំពីការទ្រទ្រង់ចីវរមានពណ៌ខៀវសុទ្ធជាដើម........ ១៦៧
និយាយអំពីចីវរដែលមិនទាន់កើតឡើងដល់ភិក្ខុដែលនៅចាំវស្សារួចហើយ........ ១៦៩
រឿងព្រះរេវតត្ថេរ និយាយអំពីការកាន់យកចីវរដោយសេចក្តីស្និទ្ធស្នាល........ ១៧៤
មាតិកា ៨ យ៉ាងដែលជាហេតុឲ្យកើតចីវរ........ ១៧៩
ឧទ្ទានគាថា........ ១៨០

ចម្បេយ្យក្ខន្ធក ១៨៤

រឿងកស្សបគោត្តភិក្ខុ........ ១៨៧
រឿងអាគន្តុកភិក្ខុ........ ១៩១
វគ្គបរិយកម្ម និយាយអំពីកម្មដ៏មិនមែនធម៌........ ១៩៩
និយាយអំពីកម្ម ៦ យ៉ាង........ ២០១

## សង្ខិត្តផ្តុំប្រាប់មាតិកា

លេខទំព័រ


| | |
|---|---|
| រឿងបណ្ឌុកភិក្ខុ និយាយអំពីកម្មជាធម៌និងមិនមែនជាធម៌ . . . . . . . . . . | ២០៣ |
| និយាយអំពីកម្ម ៦ យ៉ាង . . . . . . . . . . . . . . . . . . . | ២០៥ |
| និយាយអំពីជំនុំសង្ឃមាន ៤ ពួកនឹងកម្មសម្រាប់ធ្វើដោយសង្ឃចតុវគ្គ . . . . . | ២១៣ |
| និយាយអំពីជំនុំសង្ឃមាន ៤ ពួកនឹងកម្មសម្រាប់ធ្វើដោយសង្ឃបញ្ចវគ្គ . . . . . | ២១៥ |
| និយាយអំពីជំនុំសង្ឃមាន ៤ ពួកនឹងកម្មសម្រាប់ធ្វើដោយសង្ឃវីសតិវគ្គ . . . . | ២១៧ |
| ការហាមឃាត់ (កណ្តាលជំនុំសង្ឃ) របស់បុគ្គល ខ្លះឡើង ខ្លះមិនឡើង . . . . . | ២១៩ |
| និស្សារណកម្ម (ការបណ្តេញចេញ) មានពីរយ៉ាង . . . . . . . . . . . . | ២២១ |
| ឱសារណកម្ម (ការហៅចូលពួក) មានពីរយ៉ាង . . . . . . . . . . . . | ២២៣ |
| សេចក្តីយកម្មដែលជាកម្មមិនប្រកបដោយធម៌ . . . . . . . . . . . . . | ២២៥ |
| សេចក្តីយកម្មដែលជាកម្មប្រកបដោយធម៌ . . . . . . . . . . . . . | ២៣១ |
| ពាក្យសួររបស់ឧបាលិត្ថេរអំពីបញ្ចនីយកម្មជាដើម . . . . . . . . . . | ២៣៣ |
| ពាក្យសួររបស់ឧបាលិត្ថេរអំពីកម្មដែលមិនមែនជាធម៌ជាវិន័យ . . . . . . . . | ២៣៧ |
| ពាក្យសួររបស់ឧបាលិត្ថេរអំពីកម្មដែលជាធម៌ជាវិន័យ . . . . . . . . . . | ២៤១ |
| កម្មដែលមិនមែនជាធម៌ជាវិន័យ . . . . . . . . . . . . . . . . . . | ២៤៣ |
| ភិក្ខុទាំងឡាយជាពួក (ធ្វើ) តជ្ជនីយកម្មមិនប្រកបដោយធម៌ជាដើម . . . . . . . | ២៤៥ |
| ពួកភិក្ខុព្រមព្រៀងគ្នា (ធ្វើ) តជ្ជនីយកម្មមិនប្រកបដោយធម៌ជាដើម . . . . . . | ២៤៧ |
| ភិក្ខុទាំងឡាយជាពួក (ធ្វើ) តជ្ជនីយកម្មប្រកបដោយធម៌ជាដើម . . . . . . . . | ២៤៩ |
| ភិក្ខុទាំងឡាយជាពួក (ធ្វើ) តជ្ជនីយកម្មប្រកបដោយធម្មប្បតិរូបជាដើម . . . . . . | ២៥១ |
| ភិក្ខុទាំងឡាយជាពួក (ធ្វើ) តជ្ជនីយកម្មមិនប្រកបដោយធម៌ជាដើម . . . . . . . | ២៥៣ |
| ភិក្ខុទាំងឡាយជាពួក (ធ្វើ) បព្វាជនីយកម្មមិនប្រកបដោយធម៌ជាដើម . . . . . | ២៥៥ |
| ភិក្ខុទាំងឡាយជាពួក (ធ្វើ) ឧក្ខេបនីយកម្មមិនប្រកបដោយធម៌ជាដើម . . . . . . | ២៥៧ |
| ពួកភិក្ខុព្រមព្រៀងគ្នា (រំងាប់) តជ្ជនីយកម្មមិនប្រកបដោយធម៌ជាដើម . . . . . . | ២៥៩ |
| ភិក្ខុទាំងឡាយជាពួក (រំងាប់) តជ្ជនីយកម្មដោយការប្រែធម៌ជាដើម . . . . . . . | ២៦១ |
| ភិក្ខុទាំងឡាយជាពួក (រំងាប់) បដិសារណីយកម្មមិនប្រកបដោយធម៌ជាដើម . . . | ២៦៣ |
| ភិក្ខុទាំងឡាយជាពួក (រំងាប់) ឧក្ខេបនីយកម្មមិនប្រកបដោយធម៌ជាដើម . . . . . | ២៦៥ |




## សង្ខិត្តផ្តុំប្រាប់មាតិកា

លេខទំព័រ


| | |
|---|---|
| ពួកភិក្ខុព្រមព្រៀងគ្នា (ធ្វើ) តជ្ជនីយកម្មមិនប្រកបដោយធម៌ជាដើម . . . . . . | ២៦៧ |
| ភិក្ខុទាំងឡាយជាពួក (ធ្វើ) តជ្ជនីយកម្មដោយការប្រែធម៌ជាដើម . . . . . . . | ២៦៩ |
| ភិក្ខុទាំងឡាយជាពួក (ធ្វើ) និយស្សកម្មមិនប្រកបដោយធម៌ជាដើម . . . . . . . | ២៧១ |
| ភិក្ខុទាំងឡាយជាពួក (ធ្វើ) បព្វាជនីយកម្មមិនប្រកបដោយធម៌ជាដើម . . . . . . | ២៧៣ |
| ភិក្ខុទាំងឡាយជាពួក (ធ្វើ) ឧក្ខេបនីយកម្មមិនប្រកបដោយធម៌ជាដើម . . . . . . | ២៧៥ |
| ពួកភិក្ខុព្រមព្រៀងគ្នា (ធ្វើ) ឧក្ខេបនីយកម្មមិនប្រកបដោយធម៌ជាដើម . . . . . . | ២៧៧ |
| ភិក្ខុទាំងឡាយជាពួក (រំងាប់) តជ្ជនីយកម្មមិនប្រកបដោយធម៌ជាដើម . . . . . | ២៧៩ |
| ភិក្ខុទាំងឡាយជាពួក (រំងាប់) តជ្ជនីយកម្មប្រកបដោយធម៌ជាដើម . . . . . . . | ២៨១ |
| ពួកភិក្ខុព្រមព្រៀងគ្នា (រំងាប់) តជ្ជនីយកម្មដោយការប្រែធម៌ជាដើម . . . . . . | ២៨៣ |
| ភិក្ខុទាំងឡាយជាពួក (រំងាប់) និយស្សកម្មមិនប្រកបដោយធម៌ជាដើម . . . . . . | ២៨៥ |
| ភិក្ខុទាំងឡាយជាពួក (រំងាប់) បដិសារណីយកម្មមិនប្រកបដោយធម៌ជាដើម . . . | ២៨៧ |
| ភិក្ខុទាំងឡាយជាពួក (រំងាប់) ឧក្ខេបនីយកម្មមិនប្រកបដោយធម៌ជាដើម . . . . . | ២៨៩ |
| ឧទ្ទានគាថា . . . . . . . . . . . . . . . . . . . . . . . . . | ២៩៣ |


### កោសម្ពក្ខន្ធក ទី ១០ — ៣០៣


| | |
|---|---|
| និទានភិក្ខុ ១ រូបត្រូវអាបត្តិ . . . . . . . . . . . . . . . . . . . . | ៣ |
| ការយល់ឃើញអាបត្តិថាជាអាបត្តិមែន . . . . . . . . . . . . . . . | ៣០៥ |
| ពួកភិក្ខុនាំគ្នាប្រព្រឹត្តតាមភិក្ខុដែលសង្ឃលើកវត្ត . . . . . . . . . . . . . | ៣០៧ |
| ការយល់ឃើញអាបត្តិថាជាអនាបត្តិ . . . . . . . . . . . . . . . . | ៣១១ |
| ការធ្វើឧបោសថកម្មជាដើមក្នុងទីដទៃខាងក្នុងនៃសីមាជាដើម . . . . . . . . . | ៣១៥ |
| និយាយអំពីការបង្កហេតុនិងជំលោះជាដើម . . . . . . . . . . . . . . . | ៣១៧ |
| រឿងទីឃាវុកុមារ . . . . . . . . . . . . . . . . . . . . . . . | ៣២៩ |
| សំណាក់នៃការប្រព្រឹត្តល្អនឹងពាក្យសំដែងអំពីការរំងាប់នូវពៀរ . . . . . . . . | ៣៤៣ |
| គាថាសំដែងអំពីការរំងាប់នូវពៀរ . . . . . . . . . . . . . . . . . . | ៣៤៥ |
| ព្រះមានព្រះភាគទ្រង់ស្តេចចេញទៅកាន់ពាលកលោណការគ្រាម . . . . . . . | ៣៤៧ |

| | លេខទំព័រ |
|---|---|
| សាមគ្គីធម្មកថា | ៣៤៩ |
| រឿងគំរីដ៏ប្រសើរឈ្មោះហរិសេយ្យក | ៣៥៤ |
| ឮគេបាសក្នុងក្រុងកោសម្ពីមិនធ្វើកម្មអាងអភ័ព្វនៅតាមផ្លាដើម | ៣៥៧ |
| បុគ្គលពោលខុសធម៌ដោយវត្ថុ ១៨ យ៉ាង | ៣៥៩ |
| បុគ្គលពោលត្រូវធម៌ដោយវត្ថុ ១៨ យ៉ាង | ៣៦១ |
| ពាក្យសួររបស់មហាបជាបតីគោតមី | ៣៦៣ |
| ពាក្យសួររបស់វិសាខាមិគារមាតា | ៣៦៥ |
| (ការធ្វើ) ឧបោសថកម្មចំពោះបុគ្គលភិក្ខុ | ៣៦៧ |
| ការធ្វើសង្ឃសាមគ្គី | ៣៦៩ |
| សង្ឃសាមគ្គី មានពីរយ៉ាង | ៣៧៣ |
| ឧបាលិគាថា | ៣៧៥ |
| ឧទ្ទានគាថា | ៣៧៩ |